

ឯកសារគម្ពីរព្រះត្រៃបិដកស្កានននេះ
ត្រូវបានថតចេញពី ច្បាប់គម្ពីរព្រះត្រៃបិដកដប៉ុន ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ៥១ ដល់ ភាគ១១០
ត្រូវបានរៀបចំធ្វើឡើងដោយ គេហទំព័រ៥០០០ឆ្នាំ បូជា
ចំពោះព្រះពុទ្ធសាសនា សម្រាប់ជាធម្មទាន ៗ

ផ្តល់សៀវភៅគម្ពីរព្រះត្រៃបិដកសម្រាប់ការងារ
ដោយ ឧបាសិកា កាំង ហ្គិចណៃ ៗ

គ្រប់គ្រងគម្រោង (ទូទៅ និងផ្នែកបច្ចេកទេស)
ដោយ ឧបាសក ស្រុង-ចាន់ណា ៗ

ត្រួតពិនិត្យឡើងវិញ
ដោយ ចន-ស្រីស្រស់ ៗ

ថតស្កានដោយ
ប្អូនប្រុស ម៉ាន់ សារ៉េត

www.5000-years.org

ក្រោមការឧបត្ថម្ភយ៉ាងច្រើនក្រៃលែងអំពី៖

- ឧបាសិកា កាំង ហ្គិចណៃ (ភ្នំពេញ)
- ឧបាសក ផុត លីស្រ៊ុង និង ឧបាសិកា លី សុខា ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក សរ ចន និង ឧបាសិកា អ៊ូច សាទៀង ព្រមទាំងបុត្រ (បាត់ដំបង)
- ឧបាសក ជា ស៊ីវត្ថានា និងឧបាសិកា ឃុន សូនីម៉ា ព្រមទាំងបុត្រី ជា សុមេធាធីតា (ស.រ.អ)
- លោក ជីម-ជា និងលោកស្រី រតនី ស្រីមុំ (ភ្នំពេញ)
- ឧបាសក ជីផង យឿន (កូរ៉េ)
- លោក ស៊ុក ចាន់សេរី (បន្ទាយមានជ័យ)
- ឧបាសិកា យ៉ា រ៉ាវី (បន្ទាយមានជ័យ)
- ប្អូនស្រី យ៉ា សុភ: (បន្ទាយមានជ័យ)
- ឧបាសិកា កោ សេង (ភ្នំពេញ)
- លោកស្រី ប៉ាន សុគន្ធានីន និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក ស្រ៊ុង ចាន់ណា និង ឧបាសិកា ចន ស្រីស្រស់
ព្រមទាំងបុត្រ ចាន់ណា សុធារនីរាជ, ចាន់ណា សុធារនិរោធ (ភ្នំពេញ)
- លោកស្រី ស្រ៊ុង ចាន់រស្មី និង ស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- កញ្ញា ស្រ៊ុង ចាន់រតនា (ភ្នំពេញ)
- លោក ស្រ៊ុង យូហេង (ភ្នំពេញ)
- លោក នង សុផល (កូរ៉េ)
- ប្អូនស្រី សុខ អេង (កំពង់ចាម)
- កញ្ញា ចន កក្កដា (បាត់ដំបង)
- លោកស្រី ចន សត្យា និងលោក ទូត សេរីស័ក ព្រមទាំងបុត្រ (ភ្នំពេញ)
- លោក ចន រចនា (បាត់ដំបង)
- កញ្ញា ស៊ែស សុផារី (បាត់ដំបង)
- កញ្ញា យឿម សុផានី (បាត់ដំបង)
- លោក ម៉ៅ តន្ធា និងលោកស្រី ធៀង សេដ្ឋា (បាត់ដំបង)
- លោក សៅ សារ៉ុម (បាត់ដំបង)
- ព្រះតេជព្រះគុណ ជុំ សារ: (ព្រះចៅអធិការវត្ត សម សាន្ត ខេត្តបាត់ដំបង)

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# ខុទ្ទកនិកាយ មហានិទ្ទេស
# ទុតិយភាគ
# ៦៥

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៥០៣

**ឧទ្ទិសកថា**

**យើងខ្ញុំ សូមផ្តល់ស្មារតីសូត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។**

**ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។**

**ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានសូត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុន ។**

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

# អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន " ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យ នៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៨ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្តានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវអន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្តីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើឃោរឃៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូ ខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្ដេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

**អ្នកតំណាងចាត់ការ** The Rev. Seikyo Muchaku

**ប្រធានការិយាល័យ** The Rev. Eiitsu Shinohara

**អ្នកចាត់ការ**

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# 『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

世話人代表　無着　成恭
事務局長　篠原　鋭一

世話人　松永　然道　有馬　実成
伊藤　佳通　渡井　奎一
杉谷　義純　茂田　真澄
前田　利勝　中島　教之
永　六輔

# Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

**TRIPITAKA PUBLISHING SUPPORT COMMITTEE**
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# សុត្តន្តបិដក

## ខុទ្ទកនិកាយ មហានិទ្ទេស

## ទុតិយភាគ

៦៥

ព.ស. ២៥០៣.

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស មហានិទ្ទេសោ

# ទុតិយោ ភាគោ

---

## នវមោ មាគន្ទិយសុត្តនិទ្ទេសោ

(១) ទិស្វាន តណ្ហំ អរតិញ្ច រគំ
នាហោសិ ឆន្ទោ អបិ មេថុនស្មឹ
កិមេវិទំ មុត្តករីសបុណ្ណំ
បាទាបិ នំ សម្ផុសិតុំ ន ឥច្ឆេ ។

(២) ទិស្វាន តណ្ហំ អរតិញ្ច រគំ នាហោសិ ឆន្ទោ អបិ មេថុនស្មិន្តិ តណ្ហាញ្ច អរតិញ្ច រគញ្ច មារធីតរោ ទិស្វា បស្សិត្វា មេថុនធម្មេ ឆន្ទោ វា រាគោ វា បេមំ វា នាហោសីតិ ទិស្វាន តណ្ហំ អរតិញ្ច រគំ នាហោសិ ឆន្ទោ អបិ មេថុនស្មឹ ។

# សុត្តន្តបិដក

# ខុទ្ទកនិកាយ មហានិទ្ទេស

# ទុតិយភាគ

---

## មាគន្ទិយសុត្តនិទ្ទេស ទី ៩

[១] (ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា) ឯចំណង់ក្នុងមេថុន មិនមាន (ដល់តថាគត) ព្រោះឃើញនាងតណ្ហា នាងអរតី នឹងនាងរាគាឡើយ (ចំណង់ក្នុងមេថុន នឹងមាន ដល់តថាគត ព្រោះឃើញ) នូវសរីរៈនៃធីតារបស់អ្នកនេះ ដ៏ពេញដោយមូត្រ នឹងករីស ដូចម្ដេចកើត តថាគតមិនត្រូវការ ដើម្បីប៉ះពាល់ នូវសរីរៈនៃធីតានោះ សូម្បីដោយជើងឡើយ ។

[២] ពាក្យថា ឯចំណង់ក្នុងមេថុន មិនមាន (ដល់តថាគត) ព្រោះឃើញនាងតណ្ហា ន.ងអរតី នឹងនាងរាគាឡើយ សេចក្ដីថា បំណង់ក្ដី តម្រេកក្ដី សេចក្ដីស្រឡាញ់ក្ដី ក្នុងមេថុនធម្ម មិនមាន ព្រោះឃើញ ព្រោះប្រទះ នូវមារធីតា ឈ្មោះតណ្ហា ១ អរតី ១ រាគា ១ ហេតុនោះ (ទ្រង់ត្រាស់ថា) ឯចំណង់ក្នុងមេថុន មិនមាន (ដល់តថាគត) ព្រោះឃើញនាងតណ្ហា នាងអរតី នឹងនាងរាគាឡើយ ។

(៣) កិមេវិទំ មុត្តករីសបុណ្ណំ បាទាបិ នំ សម្ផុសិតុំ ន ឥច្ឆេតិ កិមេវិទំ សរីរំ មុត្តបុណ្ណំ ករីសបុណ្ណំ សេម្ហបុណ្ណំ រុធិរបុណ្ណំ(១) អដ្ឋិសង្ឃាដំ ន្ហារុ-សម្ពន្ធំ រុធិរមំសាវលេបនំ ចម្មាវនទ្ធំ ឆវិយា បដិច្ឆន្នំ ឆិទ្ទាវឆិទ្ទំ ឧគ្ឃរំ បគ្ឃរំ(២) កិមិសង្ឃនិសេវិតំ នានា-កលិមលបរិបូរំ បាទេន អក្កមិតុំ ន ឥច្ឆេយ្យ កុតោ បន សំវាសោ វា សមាគមោ វាតិ កិមេវិទំ មុត្តករីសបុណ្ណំ បាទាបិ នំ សម្ផុសិតុំ ន ឥច្ឆេ(៣) ។

តេនាហ ភគវា

---

១ ម. រុហិរបុណ្ណំ ។ ២ ម. ឧគ្ឃរន្តំ បគ្ឃរន្តំ ។ ឱ. មគ្ឃរំ ។ ៣ ឱ. ម. ឥតោ បរំ អនុប្បរិយញ្ញត្តំ មនុស្សោ យំ ទិព្វេ កាមេ បត្ថយន្តោ មានុស្សកេ កាមេ ន ឥច្ឆេយ្យ មានុស្សកេ វា កាមេ បត្ថយន្តោ ទិព្វេ កាមេ ន ឥច្ឆេយ្យ យំ ត្វំ ឧភោបិ ន ឥច្ឆសិ ន សាទិយសិ ន បត្ថេសិ ន បិហេសិ នាភិជប្បសិ កិន្តេ ទស្សនំ កតមាយ ត្វំ ទិដ្ឋិយា សមន្នាគតោតិ បុច្ឆតីតិ អត្ថោ ។

(៣) ពាក្យថា (ចំណាប់ក្នុងមេថុនធម៌មានដល់តថាគត ព្រោះឃើញ) នូវសរីរៈនៃធីតារបស់អ្នកនេះ ដ៏ពេញដោយមូត្រនិងករីស ដូចម្តេចកើត តថាគតមិនត្រូវការ ដើម្បីប៉ះពាល់នូវសរីរៈនៃធីតានោះ សូម្បីដោយជើងឡើយ អធិប្បាយថា (ចំណាប់ក្នុងមេថុនធម៌មានដល់តថាគត ព្រោះឃើញ) នូវសរីរៈនេះដ៏ពេញដោយមូត្រ ពេញដោយករីស ពេញដោយស្លេស្ម ពេញដោយឈាម មានពន្ធឆ្អឹង រឹតរួតដោយសរសៃ លាបដោយឈាមនិងសាច់ ពាសដោយស្បែក បិទបាំងដោយសម្បុរថ្ងៃ មានប្រហោងតូចប្រហោងធំ តែងហូរចេញហូរចូល ជាលំនៅនៃពួកដង្កូវ ដ៏ពេញដោយមន្ទិលមិនស្អាតផ្សេងៗ ដូចម្តេចបាន តថាគតមិនត្រូវការ ដើម្បីជាន់ដោយជើងឡើយ ការនៅរួមឬការសមាគម មានមកពីណា ហេតុនោះ (ទ្រង់ត្រាស់ថា) (ចំណាប់ក្នុងមេថុនធម៌មានដល់តថាគតព្រោះឃើញ) នូវសរីរៈនេះ ដ៏ពេញដោយមូត្រនិងករីស ដូចម្តេចកើត តថាគតមិនត្រូវការ ដើម្បីប៉ះពាល់នូវសរីរៈនៃធីតានោះ សូម្បីដោយជើងឡើយ ។ ហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ហើយថា

## នវមោ មាគន្ទិយសុត្តនិទ្ទេសោ

ទិស្វាន តណ្ហំ អរតិញ្ច រាគំ
នាហោសិ ឆន្ទោ អបិ មេថុនស្មឹ
កិមេវិទំ មុត្តករីសបុណ្ណំ
បាទាបិ នំ សម្ផុសិតុំ ន ឥច្ឆេ ។

(២) ឯតាទិសញ្ចេ រតនំ ន ឥច្ឆសិ
នារឹ នរិន្ទេហិ ពហូហិ បត្ថិតំ
ទិដ្ឋិគតំ សីលវតានុជីវិតំ
ភវូបបត្តិញ្ច វទេសិ កីទិសំ ។

(៣) ឥទំ វទាមីតិ ន តស្ស ហោតិ (មាគន្ទិយាតិ ភគវា)
ធម្មេសុ(១) និច្ឆេយ្យ សមុគ្គហីតំ
បស្សញ្ច(២) ទិដ្ឋីសុ អនុគ្គហាយ
អជ្ឈត្តសន្តឹ បចិនំ អទស្សំ ។

---

១ ម. ឥ ប ធម្មេសុ ។ ២ ម. សយញ្ច ។

ឯចំណង់ក្នុងមេថុន មិនមាន (ដល់តថាគត) ព្រោះឃើញ នាងតណ្ហា នាងអរតី និងនាងរាគាឡើយ (ចំណង់ក្នុងមេ-ថុននឹងមានដល់តថាគត ព្រោះឃើញ) នូវសរីរៈនៃធីតារបស់អ្នកនេះ ដ៏ពេញដោយមូត្រនឹងករីស ដូចម្ដេចកើត តថាគតមិនត្រូវការ ដើម្បីប៉ះពាល់នូវសរីរៈ នៃធីតានោះ សូម្បីដោយជើងឡើយ ។

(៤) (មាគន្ទិយព្រាហ្មណ៍សួរថា) បើព្រះអង្គមិនត្រូវការនារីរតន៍បែបនុ៎ះ ដែលពួកនរិន្ទ្រមានប្រមាណច្រើន ប្រាថ្នាហើយទេ តើព្រះអង្គ ពោលនូវទិដ្ឋិ សីល វត ជីវិត កិរិយាកើតក្នុងភព បែបណាវិញ ។

(៥) (ព្រះមានព្រះភាគត្រាស់ថា ម្នាលមាគន្ទិយៈ) ការជ្រើសរើសហើយប្រកាន់ ក្នុងធម៌ទាំងឡាយថា អាត្មាអញពោលនូវពាក្យនេះដូច្នេះ មិនមានដល់តថាគតនោះទេ ព្រោះតថាគតឃើញ (ទោស) ក្នុងទិដ្ឋិទាំងឡាយ មិនប្រកាន់ ហើយបានពិចារណាឃើញ នូវសេចក្ដីស្ងប់ខាងក្នុង ។

(៦) ឥទំ វទាមីតិ ច តស្ស ហោតីតិ ឥទំ វទាមីតិ ឥទំ វទាមិ ឯតំ វទាមិ ឯត្តកំ វទាមិ ឯត្តាវតា វទាមិ ឥទំ ទិដ្ឋិគតំ វទាមិ សស្សតោ លោកោតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វទតិ ។ ច តស្ស ហោតីតិ ច មយ្ហំ ហោតីតិ(១) ឥទំ វទាមីតិ ច តស្ស ហោតិ ។ មាគន្ទិយាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។ ភគវាតិ គារវាធិវចនំ ។ បេ ។ សច្ចិកា បញ្ញត្តិ យទិទំ ភគវាតិ មាគន្ទិយោតិ ភគវា ។

(៧) ធម្មេសុ និច្ឆេយ្យ សមុគ្គហីតន្តិ ធម្មេសូតិ ទ្វាសដ្ឋិយា ទិដ្ឋិគតេសុ ។ និច្ឆេយ្យាតិ និច្ឆិនិត្វា វិនិច្ឆិនិត្វា វិចិនិត្វា បវិចិនិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា ឱធិគ្គាហោ ពិលគ្គាហោ វរគ្គាហោ កោដ្ឋាសគ្គាហោ ឧច្ចយគ្គាហោ សមុច្ចយគ្គាហោ ឥទំ

១ ឱ. ម. ន. មយ្ហំ ហោតិ ឯត្តាវតា វទាមីតិ ន តស្ស ហោតីតិ ។

(៦) ពាក្យថា តថាគតពោលពាក្យនេះ របស់បទថា អាត្មាអញពោលពាក្យនេះ ដូច្នេះ មិនមាន ដល់តថាគតនោះទេ សេចក្តីថា តថាគតពោលពាក្យនេះ ពោលពាក្យនុ៎ះ ពោលពាក្យមានប្រមាណប៉ុណ្ណេះ ពោលពាក្យមានប្រមាណប៉ុណ្ណោះ ពោលទិដ្ឋិនេះថា លោកទៀង ដូច្នេះក្តី ។ បេ ។ សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះក្តី ។ ពាក្យថា មិនមាន ដល់តថាគតនោះ គឺមិនមានដល់តថាគតទេ ហេតុនោះ (ទ្រង់ត្រាស់ថា) អាត្មាអញពោលពាក្យនេះ ដូច្នេះ មិនមានដល់តថាគតនោះទេ ។ ពាក្យថា ម្នាលមាគន្ទិយៈ គឺព្រះមានព្រះភាគ ត្រាស់ហៅព្រាហ្មណ៍នោះដោយចំឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគ គឺជាពាក្យហៅដោយគោរព ។បេ។ ការបញ្ញត្តិថា ព្រះមានព្រះភាគ នេះ កើតដោយការត្រាស់ដឹង ហេតុនោះ លោកពោលថា ព្រះមានព្រះភាគ ត្រាស់ហៅថា មាគន្ទិយៈ ។

(៧) ពាក្យថា ក្នុងធម៌ទាំងឡាយ នៃបទថា ការជ្រើសរើសហើយប្រកាន់ក្នុងធម៌ទាំងឡាយ គឺក្នុងទិដ្ឋិ ៦២ ។ ពាក្យថា ជ្រើសរើស គឺការជ្រើសរើស ពិចារណា រិះរក រិះគិត ថ្លឹងមើល លៃលក ធ្វើឲ្យច្បាស់លាស់ ធ្វើឲ្យប្រាកដ ហើយប្រកាន់ដោយជួរ ប្រកាន់ដោយចន្លោះ ប្រកាន់ថាប្រសើរ ប្រកាន់ដោយចំណែក ប្រកាន់ដោយគំនរ ប្រកាន់ដោយគំនរធំ ប្រកាន់ បរាមាសអង្អែល ចូលចិត្ត ចុះចិត្ត ចុះចិត្តស៊ប់ថា

សច្ចំ តច្ឆំ តថំ ភូតំ យាថាវំ អវិបរីតន្តិ គហិតំ បរាមដ្ឋំ អភិនិវិដ្ឋំ អជ្ឈោសិតំ អធិមុត្តំ នត្ថិ ន សំវិជ្ជតិ នុបលព្ភតិ បហីនំ សមុច្ឆិន្នំ វូបសន្តំ បដិប្បស្សទ្ធំ អភព្វុប្បត្តិកំ ញាណគ្គិនា ទឌ្ឍន្តិ ធម្មេសុ និច្ឆេយ្យ សមុគ្គហីតំ ។

(៨) បស្សញ្ច ទិដ្ឋីសុ អនុគ្គហាយាតិ ទិដ្ឋីសុ អាទីនវំ បស្សន្តោ ទិដ្ឋិយោ ន គណ្ហាមិ ន បរាមសាមិ ន អភិនិវិសាមិ អថវា ន គណ្ហិតព្វា ន បរាមសិតព្វា ន អភិនិវិសិតព្វាតិ ឯវម្បិ បស្សញ្ច ទិដ្ឋីសុ អនុគ្គហាយ ។ អថវា សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ទិដ្ឋិគតមេតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារោ ទិដ្ឋិវិសូកាយិកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសញ្ញោជនំ សទុក្ខំ សវិឃាតំ សឧបាយាសំ សបរិឡាហំ

## មាគន្ធិយសុត្តនិទ្ទេស ទី ៩

ពាក្យនេះ ជាពាក្យទៀង ជាពាក្យពិត ពាក្យប្រាកដ ពាក្យមែន ពាក្យទៀងទាត់ ពាក្យមិនប្រែប្រួលដូច្នេះ មិនមាន មិនមានព្រម តថាគតមិនបាន តថាគតលះបង់ ផ្តាច់បង់ ឲ្យស្ងប់ រម្ងាប់ហើយ ធ្វើមិនគួរឲ្យកើតឡើងទៀត ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ការជ្រើសរើសហើយប្រកាន់ ក្នុងធម៌ទាំងឡាយ ។

(៨) ពាក្យថា តថាគតឃើញ (ទោស) ក្នុងទិដ្ឋិទាំងឡាយ មិនប្រ-កាន់ អធិប្បាយថា តថាគតកាលឃើញទោស ក្នុងទិដ្ឋិទាំងឡាយ មិនប្រ-កាន់ មិនបរាមាសអង្អែល មិនជាប់ចិត្ត នូវទិដ្ឋិទាំងឡាយ ឬថា ទិដ្ឋិទាំងឡាយ តថាគតមិនគប្បីប្រកាន់ មិនគប្បីបរាមាសអង្អែល មិនគប្បីជាប់ចិត្ត ហេតុនោះ(ទ្រង់ត្រាស់ថា) តថាគតឃើញ (ទោស)ក្នុងទិដ្ឋិទាំងឡាយ មិនប្រកាន់ ដោយប្រការយ៉ាងនេះឯង ។ មួយទៀត ដំណើរគឺទិដ្ឋិ សេចក្តីប្រកាន់គឺទិដ្ឋិ ផ្លូវឆ្ងាយគឺទិដ្ឋិ បម្រុងគឺទិដ្ឋិ ការអន្ទះអន្ទែងគឺទិដ្ឋិ សញ្ញោ-ជនៈគឺទិដ្ឋិនុ៎ះថា លោកទៀង ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃជាមោឃៈ ឯទិដ្ឋិនេះ ប្រកបដោយទុក្ខ ប្រកបដោយសេចក្តីថ្នាំងថ្នាក់ ប្រកបដោយសេចក្តីបង្អៀតបង្អល់ ប្រកបដោយសេចក្តីក្រហលក្រហាយ

ន និព្ពិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្ពានាយ សំវត្តតីតិ ទិដ្ឋីសុ អាទីនវំ បស្សន្តោ ទិដ្ឋិយោ ន គណ្ហាមិ ន បរាមសាមិ ន អភិនិវិសាមិ អថវា ន គណ្ហិតព្វា ន បរាមសិតព្វា ន អភិនិវិសិតព្វាតិ ឯវម្បិ បស្សន្តោ ទិដ្ឋីសុ អនុគ្គហាយ(១) ។ អសស្សតោ លោកោ អន្តវា លោកោ អនន្តវា លោកោ តំ ជីវំ តំ សរីរំ អញ្ញំ ជីវំ អញ្ញំ សរីរំ ហោតិ តថាគតោ បរម្មរណា ន ហោតិ តថាគតោ បរម្មរណា ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ទិដ្ឋិគតមេតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារោ ទិដ្ឋិវិសូកាយិកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសញ្ញោជនំ សទុក្ខំ សវិឃាតំ សឧបាយាសំ សបរិឡាហំ ន និព្ពិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ

---

១ ម. ឯត្ថន្តរេ អថវា សស្សតោ លោកោតិ ទិស្សតិ ។

មិនប្រព្រឹត្តទៅព្រម ដើម្បីសេចក្តីនឿយណាយទេ ដើម្បីប្រាសចាកតម្រេកទេ ដើម្បីសេចក្តីរលត់ទុក្ខទេ ដើម្បីសេចក្តីស្ងប់រម្ងាប់ទេ ដើម្បីអភិញ្ញាទេ ដើម្បីកិរិយាត្រាស់ដឹងទេ ដើម្បីព្រះនិព្វានទេ តថាគតឃើញទោស ក្នុងទិដ្ឋិទាំងឡាយដូច្នេះ ទើបមិនប្រកាន់យក មិនបរាមាសអង្អែល មិនជាប់ចិត្តនូវទិដ្ឋិទាំងឡាយ ឬថា ទិដ្ឋិទាំងឡាយ តថាគតមិនគប្បីប្រកាន់យក មិនគប្បីបរាមាសអង្អែល មិនគប្បីជាប់ចិត្ត ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតឃើញទោស ក្នុងទិដ្ឋិទាំងឡាយ មិនប្រកាន់ ដោយប្រការយ៉ាងនេះឯង ។ ដំណើរគឺទិដ្ឋិ ការប្រកាន់គឺទិដ្ឋិ ផ្លូវឆ្ងាយគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ សេចក្តីអន្ទះអន្ទែងគឺទិដ្ឋិ សញ្ញោជនៈគឺទិដ្ឋិនុ៎ះថា លោកមិនទៀង លោកមានទីបំផុត លោកមិនមានទីបំផុត ជីវៈនោះ សរីរៈនោះ ជីវៈដទៃ សរីរៈដទៃ សត្វស្លាប់ហើយកើតទៀត សត្វស្លាប់ហើយមិនកើតទៀត សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ឯទិដ្ឋិនេះ ប្រកបដោយទុក្ខ ប្រកបដោយសេចក្តីថ្នាំងថ្នាក់ ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្រហល់ក្រហាយ មិនប្រព្រឹត្តទៅព្រម ដើម្បីសេចក្តីនឿយណាយទេ ដើម្បីសេចក្តីប្រាសចាកតម្រេកទេ ដើម្បីសេចក្តីរលត់ទុក្ខទេ ដើម្បីសេចក្តីស្ងប់រម្ងាប់ទេ

## នវមោ មាគន្ទិយសុត្តនិទ្ទេសោ

ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តន្តីតិ ទិដ្ឋីសុ អាទីនវំ បស្សន្តោ ទិដ្ឋិយោ ន គណ្ហាមិ ន បរាមសាមិ ន អភិនិវិសាមិ អបិច ន គណ្ហិតព្វា ន បរាមសិតព្វា ន អភិនិវិសិតព្វាតិ ឯវម្បិ បស្សំ ទិដ្ឋីសុ អនុគ្គហាយ ។ អបិច ឥមា ទិដ្ឋិយោ ឯវំគហិតា ឯវំបរាមដ្ឋា ឯវំគតិកា ភវន្តិ ឯវំអភិសម្បរាយាតិ ទិដ្ឋីសុ អាទីនវំ បស្សន្តោ ទិដ្ឋិយោ ន គណ្ហាមិ ន បរាមសាមិ ន អភិនិវិសាមិ អបិច ន គណ្ហិតព្វា ន បរាមសិតព្វា ន អភិនិវិសិតព្វាតិ ឯវម្បិ បស្សំ ទិដ្ឋីសុ អនុគ្គហាយ ។ អបិច ឥមា ទិដ្ឋិយោ និរយសំវត្តនិកា តិរច្ឆានយោនិសំវត្តនិកា បេត្តិវិសយសំវត្តនិកាតិ ទិដ្ឋីសុ អាទីនវំ បស្សន្តោ ទិដ្ឋិយោ ន គណ្ហាមិ ន បរាមសាមិ នាភិនិវិសាមិ អបិច ន គណ្ហិតព្វា ន បរាមសិតព្វា នាភិនិវិសិតព្វាតិ ឯវម្បិ បស្សំ ទិដ្ឋីសុ អនុគ្គហាយ ។

## មាគន្ទិយសុត្តនិទ្ទេស ទី ៩

ដើម្បីអភិញ្ញាទេ ដើម្បីកិរិយាត្រាស់ដឹងទេ ដើម្បីព្រះនិព្វានទេ តថាគតឃើញទោស ក្នុងទិដ្ឋិទាំងឡាយដូច្នេះ ទើបមិនប្រកាន់ មិនបបោសអង្អែល មិនជាប់ចិត្ត នូវទិដ្ឋិទាំងឡាយ ឬថា ទិដ្ឋិទាំងឡាយ តថាគត មិនគប្បីប្រកាន់យក មិនគប្បីបបោសអង្អែល មិនគប្បីជាប់ចិត្ត ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតឃើញទោស ក្នុងទិដ្ឋិទាំងឡាយ មិនប្រកាន់ ដោយប្រការយ៉ាងនេះឯង ។ មួយទៀត តថាគតឃើញទោសក្នុងទិដ្ឋិទាំងឡាយថា ទិដ្ឋិទាំងនេះ ដែលតថាគត ប្រកាន់យ៉ាងនេះ បបោសអង្អែលយ៉ាងនេះ មានគតិយ៉ាងនេះ មានលោកខាងមុខយ៉ាងនេះ ទើបមិនប្រកាន់ មិនបបោសអង្អែល មិនជាប់ចិត្ត នូវទិដ្ឋិទាំងឡាយ ឬថា ទិដ្ឋិទាំងឡាយ តថាគតមិនគប្បីប្រកាន់ មិនគប្បីបបោសអង្អែល មិនគប្បីជាប់ចិត្ត ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតឃើញទោសក្នុងទិដ្ឋិទាំងឡាយ មិនប្រកាន់ ដោយប្រការយ៉ាងនេះឯង ។ មួយទៀត តថាគតឃើញទោស ក្នុងទិដ្ឋិទាំងឡាយថា ទិដ្ឋិទាំងនេះ ប្រព្រឹត្តទៅដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីតិរច្ឆានកំណើត ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ ទើបមិនប្រកាន់ មិនបបោសអង្អែល មិនជាប់ចិត្ត នូវទិដ្ឋិទាំងឡាយ ឬថា ទិដ្ឋិទាំងឡាយ តថាគត មិនគប្បីប្រកាន់ មិនគប្បីបបោសអង្អែល មិនគប្បីជាប់ចិត្ត ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតឃើញទោសក្នុងទិដ្ឋិទាំងឡាយ មិនប្រកាន់ ដោយប្រការយ៉ាងនេះឯង ។

អថវា ឥមា ទិដ្ឋិយោ អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា ខយធម្មា វយធម្មា វិរាគធម្មា និរោធធម្មាតិ ទិដ្ឋីសុ អាទីនវំ បស្សន្តោ ទិដ្ឋិយោ ន គណ្ហាតិ ន បរាមសតិ នាភិនិវិសតិ អថវា ន គណ្ហិតព្វា ន បរាមសិតព្វា នាភិនិវិសិតព្វាតិ ឯវម្បិ បស្សន្តោ ទិដ្ឋីសុ អនុគ្គហាយ ។

(៩) អជ្ឈត្តសន្តឹ បចិនំ អទស្សន្តិ អជ្ឈត្តំ រាគស្ស សន្តឹ ទោសស្ស សន្តឹ មោហស្ស សន្តឹ កោធស្ស ឧបនាហស្ស មក្ខស្ស បឡាសស្ស ឥស្សាយ មច្ឆរិយស្ស មាយាយ សាឋេយ្យស្ស ថម្ភស្ស សារម្ភស្ស មានស្ស អតិមានស្ស មទស្ស បមាទស្ស សព្វកិលេសានំ សព្វទុច្ចរិតានំ សព្វទរថានំ សព្វបរិឡាហានំ សព្វសន្តាបានំ សព្វាកុសលាភិសង្ខារានំ សន្តឹ វូបសន្តឹ និព្វុតឹ បដិប្បស្សទ្ធឹ ។ បចិនន្តិ បចិនន្តោ វិចិនន្តោ បវិចិនន្តោ តុលយន្តោ តីរយន្តោ វិភាវយន្តោ វិភូតំ ករោន្តោ

មួយទៀត តថាគតឃើញទោស ក្នុងទិដ្ឋិទាំងឡាយថា ទិដ្ឋិទាំងនេះ មិនទៀង គឺបច្ច័យតាក់តែងឡើងហើយ អាស្រ័យបច្ច័យកើតឡើងហើយ មានកិរិយាអស់ទៅ ជាធម្មតា មានកិរិយាសូន្យទៅ ជាធម្មតា មានកិរិយាប្រាសទៅជាធម្មតា មានកិរិយារលត់ទៅជាធម្មតា ទើបមិនប្រកាន់ មិនបបោសអង្អែល មិនជាប់ចិត្ត នូវទិដ្ឋិទាំងឡាយ ឬថា ទិដ្ឋិទាំងឡាយ តថាគត មិនគប្បីប្រកាន់ មិនគប្បីបបោសអង្អែល មិនគប្បីជាប់ចិត្ត ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគត ឃើញទោសក្នុងទិដ្ឋិទាំងឡាយ មិនប្រកាន់ ដោយប្រការយ៉ាងនេះឯង ។

(៩) ពាក្យថា បានពិចារណាឃើញ នូវសេចក្ដីស្ងប់ខាងក្នុង គឺ សេចក្ដីស្ងប់រាគៈ សេចក្ដីស្ងប់ទោសៈ សេចក្ដីស្ងប់មោហៈ ប្រព្រឹត្តទៅក្នុងខាងក្នុង ទឹង សេចក្ដីស្ងប់ សេចក្ដីស្ងប់រម្ងាប់ សេចក្ដីរលត់ សេចក្ដីស្ងប់ស្ងៀម នៃកោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ នឹងកិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្ដីក្រវល់ក្រវាយទាំងអស់ សេចក្ដីក្រហល់ក្រហាយទាំងអស់ សេចក្ដីអន្ទះសាទាំងអស់ អភិសង្ខារជាអកុសលទាំងអស់ ។ ពាក្យថា បានពិចារណា គឺកាលពិចារណា កាលត្រិះរិះ កាលរំពឹង កាលថ្លឹង កាលលៃលក កាលបំភ្លឺ កាលធ្វើឲ្យច្បាស់ថា

## នវមោ មាគន្ទិយសុត្តនិទ្ទេសោ

សព្វេ សង្ខារា អនិច្ចាតិ បចិនន្តោ វិចិនន្តោ បវិចិនន្តោ តុលយន្តោ តីរយន្តោ វិភាវយន្តោ វិភូតំ ករោន្តោ សព្វេ សង្ខារា ទុក្ខាតិ សព្វេ ធម្មា អនត្តាតិ ។ បេ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ បចិនន្តោ វិចិនន្តោ បវិចិនន្តោ តុលយន្តោ តីរយន្តោ វិភាវយន្តោ វិភូតំ ករោន្តោ ។ អទស្សន្តិ អទស្សំ អទក្ខឹ បស្សឹ បដិវិជ្ឈិន្តិ អជ្ឈត្តសន្តឹ បចិនំ អទស្សំ ។ តេនាហ ភគវា

ឥទំ វទាមីតិ ន តស្ស ហោតិ
ធម្មេសុ និច្ឆេយ្យ សមុគ្គហីតំ
បស្សញ្ច ទិដ្ឋីសុ អនុគ្គហាយ
អជ្ឈត្តសន្តឹ បចិនំ អទស្សន្តិ ។

(១០) វិនិច្ឆយា យានិ បកប្បិតានិ (ឥតិ មាគន្ទិយោ)
តេ វេ មុនិ ព្រូសិ អនុគ្គហាយ
អជ្ឈត្តសន្តីតិ យមេតមត្ថំ
កថំ នុ ធីរេហិ បវេទិតន្តិ ។

សញ្ញាទាំងឡាយទាំងពួង មិនទៀង កាលពិចារណា កាលត្រិះរិះ កាលរំពឹង កាលថ្លឹង កាលរៃលក កាលបំភ្លឺ កាលធ្វើឲ្យច្បាស់ថា សញ្ញាទាំងឡាយទាំងពួង ជាទុក្ខ ថា ធម៌ទាំងឡាយទាំងពួង ជាអនត្តា ។ បេ ។ កាលពិចារណា កាលត្រិះរិះ កាលរំពឹង កាលថ្លឹង កាលរៃលក កាលបំភ្លឺ កាលធ្វើឲ្យច្បាស់ថា វត្ថុណាមួយមានសភាពកើតឡើងហើយ វត្ថុទាំងអស់នោះ មានកិរិយារលត់ទៅវិញ ជាធម្មតា ។ ពាក្យថា បានឃើញ គឺបានជួប បានយល់ បានប្រទះ បានត្រាស់ដឹង ហេតុនោះ (ទ្រង់ត្រាស់ថា) បានពិចារណាឃើញនូវសេចក្តីស្ងប់ខាងក្នុង ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ការជ្រើសរើសហើយប្រកាន់ក្នុងធម៌ទាំងឡាយថា អាត្មាអញពោលនូវពាក្យនេះ ដូច្នេះ មិនមានដល់តថាគតនោះទេ ព្រោះតថាគត ឃើញ (ទោស) ក្នុងទិដ្ឋិទាំងឡាយ មិនប្រកាន់ ហើយបានពិចារណាឃើញនូវសេចក្តីស្ងប់ខាងក្នុង ។

(១០) (មាគន្ទិយព្រាហ្មណ៍សួរថា) ធម្មជាតិជាគ្រឿងជ្រើសរើសណា ដែលបុគ្គលកំណត់ហើយ ព្រះអង្គជាមុនិ មិនប្រកាន់ នូវធម្មជាតិជាគ្រឿងជ្រើសរើសទាំងនោះ ហើយត្រាស់សេចក្តីណាថា សេចក្តីស្ងប់ខាងក្នុង សេចក្តីនោះ អ្នកប្រាជ្ញទាំងឡាយ សំដែងហើយ ដូចម្តេចហ្ន៎ ។

(១១) វិនិច្ឆយា យានិ បកប្បិតានីតិ វិនិច្ឆយានិ វុច្ចន្តិ ទ្វាសដ្ឋី ទិដ្ឋិគតានិ ។ បកប្បិតានីតិ កប្បិតា អភិសង្ខតា សណ្ឋាបិតាតិបិ បកប្បិតា ។ អថវា អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា ខយធម្មា វយធម្មា វិរាគធម្មា និរោធធម្មា វិបរិណាមធម្មាតិបិ បកប្បិតាតិ វិនិច្ឆយា យានិ បកប្បិតានិ ។ ឥតិ មាគន្ទិយោតិ ឥតីតិ បទសន្ធិ ។បេ។ បទានុបុព្វតានមេតំ ឥតីតិ ។ មាគន្ទិយោតិ តស្ស ព្រាហ្មណស្ស នាមំ សង្ខា សមញ្ញា(១)វោហារោតិ ឥតិ មាគន្ទិយោ(២) ។

(១២) តេ វេ មុនី ព្រូសិ អនុគ្គហាយ អជ្ឈត្តសន្តីតិ យមេតមត្ថន្តិ តេ វេតិ ទ្វាសដ្ឋី ទិដ្ឋិគតានិ ។ មុនីតិ មោនំ វុច្ចតិ ញាណំ ។បេ។ សង្គជាលមតិច្ច សោ មុនីតិ ។ អនុគ្គហាយាតិ ទិដ្ឋីសុ អាទីនវំ បស្សន្តោ ទិដ្ឋិយោ ន គណ្ហាមិ ន បរាមសាមិ នាភិនិវិសាមីតិ បគ្គណ្ហាសិ(៣) អជ្ឈត្តសន្តីតិ ច ភណាសិ ។

---

១ ម. សមញ្ញា បញ្ញត្តិ ។ ២ ឱ. អយំ ជាហោ មាគន្ទិយាតិ ។ល។ មាគន្ទិយោតិ ឥត្តិ ។ ៣ ម. ច ភណសិ ។

[១១] ទិដ្ឋិ ៦២ លោកហៅថា ធម្មជាតិជាគ្រឿងជ្រើសរើស របស់បទថា ធម្មជាតិជាគ្រឿងជ្រើសរើស ដែលគេកំណត់ហើយ ។

ពាក្យថា គេកំណត់ហើយ គឺគេសម្រេច តែងតាំង រៀបចំ គេតែងតាំងដូច្នេះខ្លះ ឬថា មិនទៀង បច្ច័យតាក់តែង អាស្រ័យបច្ច័យ ហើយទើបកើតឡើង មានកិរិយាអស់ទៅជាធម្មតា សូន្យទៅជាធម្មតា ប្រាសទៅជាធម្មតា រលត់ទៅជាធម្មតា ប្រែប្រួលទៅជាធម្មតា គេតែងតាំងដូច្នេះខ្លះ ហេតុនោះ (ព្រាហ្មណ៍ពោលថា) ធម្មជាតិជាគ្រឿងជ្រើសរើសណា ដែលគេកំណត់ហើយ ។ ពាក្យថា ដូច្នេះ ក្នុងបទថា មាគន្ទិយព្រាហ្មណ៍ពោលដូច្នេះ គឺជាបទសន្ធិ ។ បេ ។ ពាក្យថា ដូច្នេះ នុះ ជាលំដាប់បទ ។ ពាក្យថា មាគន្ទិយៈ ជានាម ជាកិរិយាកប់ ជាឈ្មោះ ជាពាក្យហៅព្រាហ្មណ៍នោះ ហេតុនោះ មានពាក្យថា មាគន្ទិយព្រាហ្មណ៍ ពោលដូច្នេះ ។

[១២] ពាក្យថា នូវធម៌ទាំងនោះ ក្នុងបទថា ព្រះអង្គជាមុនិ មិនប្រកាន់នូវធម៌ទាំងនោះ ហើយត្រាស់នូវសេចក្តីណាថា សេចក្តីស្ងប់ខាងក្នុង គឺបានដល់ទិដ្ឋិ ៦២ ។ ញាណ ហៅថាមោនៈ ក្នុងបទថាមុនិ ។បេ។ មុនិនោះកន្លងបណ្តាញជាគ្រឿងជាប់ចំពាក់ ។ ពាក្យថា មិនប្រកាន់ គឺព្រះអង្គប្រ-កាន់ថា តថាគតឃើញទោសក្នុងទិដ្ឋិទាំងឡាយ មិនប្រកាន់ មិនបបោសអង្អែល មិនជាប់ចិត្តនូវទិដ្ឋិទាំងឡាយ ទាំងត្រាស់ថា សេចក្តីស្ងប់ខាងក្នុង។

## នវមោ មាគន្ធិយសុត្តនិទ្ទេសោ

យមេតមត្ថន្តិ យំ បរមត្ថំ តេ វេ មុនី ព្រូសិ អនុគ្គហាយ អជ្ឈត្តសន្តីតិ យមេតមត្ថំ ។

(១៣) កថំ នុ ធីរេហិ បវេទិតន្តិ កថន្តិ សំសយបុច្ឆា វិមតិបុច្ឆា ទ្វេឡ្ហកបុច្ឆា អនេកំសបុច្ឆា ឯវំ នុ ខោ ន នុ ខោ កិំ នុ ខោ កថំ នុ ខោតិ កថំ នុ ។ ធីរេហីតិ(១) បណ្ឌិតេហិ បញ្ញវន្តេហិ ពុទ្ធិមន្តេហិ ញាណីហិ វិភាវីហិ មេធាវីហិ ។ បវេទិតន្តិ វេទិតំ បវេទិតំ អាចិក្ខិតំ ទេសិតំ បញ្ញបិតំ បដ្ឋបិតំ វិវរិតំ វិភជិតំ(២) ឧត្តានីកតំ បកាសិតន្តិ កថំ នុ ធីរេហិ បវេទិតន្តិ ។ តេនាហ សោ ព្រាហ្មណោ

វិនិច្ឆយា យានិ បកប្បិតានិ
តេ វេ មុនិ ព្រូសិ អនុគ្គហាយ
អជ្ឈត្តសន្តីតិ យមេតមត្ថំ
កថំ នុ ធីរេហិ បវេទិតន្តិ ។

---

១ ម. ធិរេហីតិ ធិរេហិ ។ ២ ម. វិវដ្ដំ វិភត្តំ ។

## មាគន្ទិយសុត្តនិទ្ទេស ទី ៩

ពាក្យថា នូវសេចក្តីណា គឺព្រះអង្គជាមុនិ មិនប្រកាន់នូវធម៌ទាំងនោះ ត្រាស់នូវសេចក្តីដ៏ឧត្តមណាថា មានសេចក្តីស្ងប់ខាងក្នុង ហេតុនោះ (ព្រាហ្មណ៍ពោលថា) នូវសេចក្តីណា ។

(១៣) ពាក្យថា ដូចម្តេចហ្ន៎ ក្នុងបទថា ដែលអ្នកប្រាជ្ញទាំងឡាយ សំដែងហើយ ដូចម្តេចហ្ន៎ គឺជាការសួរដោយសង្ស័យ សួរដោយងឿងឆ្ងល់ សួរដោយមន្ទិល សួរដោយចំណែកច្រើន ដោយពាក្យថា យ៉ាងនេះឬហ្ន៎ មិនមែនទេហ្ន៎ ដូចម្តេចហ្ន៎ ដោយប្រការដូចម្តេចហ្ន៎ ហេតុនោះ (ព្រាហ្មណ៍ពោលថា) ដូចម្តេចហ្ន៎ ។ ពាក្យថា អ្នកប្រាជ្ញទាំងឡាយ គឺបណ្ឌិត អ្នកមានបញ្ញា មានបញ្ញាជាគ្រឿងត្រាស់ដឹង អ្នកមានញាណ អ្នកមានការយល់ច្បាស់ អ្នកមានប្រាជ្ញាជាគ្រឿងពុះពារទាំងឡាយ ។ ពាក្យថា សំដែងហើយ គឺពន្យល់ សំដែង ប្រាប់ បង្ហាញ បញ្ញត្ត តាំងទុក បង្ហើប វែកញែក ធ្វើឲ្យរាក់ ប្រកាសហើយ ហេតុនោះ ព្រាហ្មណ៍ពោលថា អ្នកប្រាជ្ញទាំងឡាយ សំដែងហើយដូចម្តេចហ្ន៎ ។ ហេតុនោះ ព្រាហ្មណ៍នោះទូលថា

ធម្មជាតិ ជាគ្រឿងជ្រើសរើសណា ដែលបុគ្គលកំណត់
ហើយ ព្រះអង្គជាមុនិ មិនប្រកាន់ធម៌ទាំងនោះ ហើយ
ត្រាស់នូវសេចក្តីណាថា សេចក្តីស្ងប់ខាងក្នុង សេចក្តី
នោះ អ្នកប្រាជ្ញទាំងឡាយ សំដែងហើយ ដូចម្តេចហ្ន៎ ។

(១៦) ន ទិដ្ឋិយា ន សុតិយា ន ញាណេន (មាគន្ទិយាតិ ភគវា) សីលព្វតេនាបិ ន សុទ្ធិមាហ

អទិដ្ឋិយា អស្សុតិយា អញាណា
អសីលតា អព្វតា នោបិ តេន
ឯតេ ច និស្សជ្ជ អនុគ្គហាយ
សន្តោ អនិស្សាយ ភវំ ន ជប្បេ ។

(១៧) ន ទិដ្ឋិយា ន សុតិយា ន ញាណេនាតិ ទិដ្ឋេនបិ សុទ្ធិំ វិសុទ្ធិំ បរិសុទ្ធិំ មុត្តិំ វិមុត្តិំ បរិមុត្តិំ នាហ ន កថេសិ ន ភណសិ ន ទីបយសិ ន វោហរសិ ។ សុតេនបិ សុទ្ធិំ វិសុទ្ធិំ បរិសុទ្ធិំ មុត្តិំ វិមុត្តិំ បរិមុត្តិំ នាហ ន កថេសិ ន ភណសិ ន ទីបយសិ ន វោហរសិ ។ ទិដ្ឋសុតេនបិ សុទ្ធិំ វិសុទ្ធិំ បរិសុទ្ធិំ មុត្តិំ វិមុត្តិំ បរិមុត្តិំ នាហ ន កថេសិ ន ភណសិ ន ទីបយសិ ន វោហរសិ ។ ញាណេនបិ សុទ្ធិំ វិសុទ្ធិំ បរិសុទ្ធិំ មុត្តិំ វិមុត្តិំ បរិមុត្តិំ នាហ ន កថេសិ ន ភណសិ ន ទីបយសិ ន វោហរសីតិ ន ទិដ្ឋិយា ន សុតិយា ន ញាណេន ។

(១៤) (ព្រះមានព្រះភាគ ត្រាស់តបថា ម្នាលមាគន្ទិយៈ) អ្នកប្រាជ្ញមិនពោលនូវសេចក្តីបរិសុទ្ធិ ព្រោះការឃើញទេ ព្រោះការឮទេ ព្រោះការដឹងទេ ព្រោះសីលនឹងវត្តទេ ទាំងមិន (ពោលនូវសេចក្តីបរិសុទ្ធិ) ព្រោះការមិនឃើញ ព្រោះការមិនឮ ព្រោះការមិនដឹង ព្រោះមិនមានសីល ព្រោះមិនមានវត្តនោះទេ ទាំងលះបង់ មិនប្រកាន់ធម៌ទាំងនោះ ជាអ្នកស្ងប់ មិនអាស្រ័យ មិនគប្បីប្រាថ្នាភព ។

(១៥) ពាក្យថា ព្រោះការឃើញទេ ព្រោះការឮទេ ព្រោះការដឹងទេ អធិប្បាយថា អ្នកប្រាជ្ញ មិនពោល មិនថ្លែង មិនពណ៌នា មិនពន្យល់ មិនសំដែង នូវសេចក្តីស្អាត ស្អាតវិសេស បរិសុទ្ធិ ការផុត ផុតស្រឡះ ផុតជុំវិញ ព្រោះការដែលឃើញ ។ មិនពោល មិនថ្លែង មិនពណ៌នា មិនពន្យល់ មិនសំដែងនូវសេចក្តីស្អាត ស្អាតវិសេស បរិសុទ្ធិ ការផុត ផុតស្រឡះ ផុតជុំវិញ ព្រោះការដែលឮ ។ មិនពោល មិនថ្លែង មិនពណ៌នា មិនពន្យល់ មិនសំដែងនូវសេចក្តីស្អាត ស្អាតវិសេស បរិសុទ្ធិ ការផុត ផុតស្រឡះ ផុតជុំវិញ ព្រោះការឃើញទាំងការឮ ។ មិនពោល មិនថ្លែង មិនពណ៌នា មិនពន្យល់ មិនសំដែងនូវសេចក្តីស្អាត ស្អាតវិសេស បរិសុទ្ធិ ការផុត ផុតស្រឡះ ផុតជុំវិញ ព្រោះការដឹង ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះការឃើញទេ ព្រោះការឮទេ ព្រោះការដឹងទេ ។

## នវមោ មាគន្ទិយសុត្តនិទ្ទេសោ

មាគន្ទិយាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។ ភគវាតិ គារវាធិវចនំ ។ បេ ។ សច្ឆិកាបញ្ញត្តិ យទិទំ ភគវាតិ មាគន្ទិយាតិ ភគវា ។

(១៦) សីលព្វតេនាបិ ន សុទ្ធិមាហាតិ សីលេនបិ សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ នាហ ន កថេតិ ន ភណតិ ន ទីបយតិ ន វោហរតិ ។ វត្តេនបិ សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ នាហ ន កថេតិ ន ភណតិ ន ទីបយតិ ន វោហរតិ ។ សីលព្វតេនបិ សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ នាហ ន កថេតិ ន ភណតិ ន ទីបយតិ ន វោហរតីតិ សីលព្វតេនាបិ ន សុទ្ធិមាហ ។

(១៧) អទិដ្ឋិយា អស្សុតិយា អញាណា អសីលតា អព្វតា នោបិ តេនាតិ ទិដ្ឋិំបិ ឥច្ឆិតព្វា ទសវត្ថុកា សម្មាទិដ្ឋិ អត្ថិ ទិន្នំ អត្ថិ យិដ្ឋំ

## មាគន្ទិយសុត្តនិទ្ទេស ទី ៩

ពាក្យថា មាគន្ទិយៈ គឺព្រះមានព្រះភាគ ត្រាស់ហៅ ព្រាហ្មណ៍នោះ ដោយចំណោះ ៗ ពាក្យថា ព្រះមានព្រះភាគ ជាពាក្យហៅដោយគោរព ៗ បេ ៗ សេចក្ដីបញ្ញត្តិថា ព្រះមានព្រះភាគនេះ ( កើត ) អំពីការត្រាស់ដឹង ហេតុនោះ ( មានពាក្យថា ) ព្រះមានព្រះភាគត្រាស់ហៅថា មាគន្ទិយៈ ៗ

( ១៦ ) ពាក្យថា អ្នកប្រាជ្ញមិនពោលនូវសេចក្ដីបរិសុទ្ធិ ព្រោះសីល នឹងវត្តទេ សេចក្ដីថា អ្នកប្រាជ្ញ មិនពោល មិនថ្លែង មិនពណ៌នា មិនពន្យល់ មិនសំដែងនូវសេចក្ដីស្អាត ស្អាតវិសេស បរិសុទ្ធិ ការផុត ផុតស្រឡះ ផុតជុំវិញ សូម្បីព្រោះសីលទេ ៗ អ្នកប្រាជ្ញ មិនពោល មិនថ្លែង មិនពណ៌នា មិនពន្យល់ មិនសំដែងនូវសេចក្ដីស្អាត ស្អាតវិសេស បរិសុទ្ធិ ការផុត ផុតស្រឡះ ផុតជុំវិញ សូម្បីព្រោះវត្តទេ ៗ អ្នកប្រាជ្ញ មិនពោល មិនថ្លែង មិនពណ៌នា មិនពន្យល់ មិនសំដែងនូវសេចក្ដីស្អាត ស្អាតវិសេស បរិសុទ្ធិ ការផុត ផុតស្រឡះ ផុតជុំវិញ សូម្បីព្រោះសីលនឹងវត្តទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) អ្នកប្រាជ្ញមិនពោលនូវសេចក្ដីបរិសុទ្ធិ សូម្បីព្រោះសីលនឹងវត្តទេ ៗ

( ១៧ ) ពាក្យថា ទាំងមិន ( សំដែងនូវសេចក្ដីបរិសុទ្ធិ ) ព្រោះការមិនឃើញ ព្រោះការមិនឮ ព្រោះការមិនដឹង ព្រោះមិនមានសីល ព្រោះមិនមានវត្តនោះទេ អធិប្បាយថា ទិដ្ឋិដែលគួរប្រាថ្នាក៏មាន បានដល់សម្មាទិដ្ឋិមានវត្ថុ ១០ គឺ ទានដែលបុគ្គលឲ្យហើយមានផល ការបូជាធំមានផល

អត្ថិ ហុតំ អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ
អត្ថិ អយំ លោកោ អត្ថិ បរោ លោកោ អត្ថិ មាតា
អត្ថិ បិតា អត្ថិ សត្តា ឱបបាតិកា អត្ថិ លោកេ សមណ-
ព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច
លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា
បវេទេន្តីតិ ។ សវនម្បិ ឥច្ឆិតព្វំ បរតោ ឃោសោ សុត្តំ
គេយ្យំ វេយ្យាករណំ គាថា ឧទានំ ឥតិវុត្តកំ ជាតកំ
អព្ភុតធម្មំ វេទល្លំ ។ ញាណម្បិ ឥច្ឆិតព្វំ កម្មស្សកត-
ញាណំ សច្ចានុលោមិកញាណំ អភិញ្ញាញាណំ សមា
បត្តិញាណំ ។ សីលម្បិ ឥច្ឆិតព្វំ បាតិមោក្ខសំវរោ ។
វត្តម្បិ ឥច្ឆិតព្វំ អដ្ឋ ធុតង្គានិ អារញ្ញិកង្គំ បិណ្ឌបាតិ-
កង្គំ បំសុកូលិកង្គំ តេចីវរិកង្គំ សបទានចារិកង្គំ
ខលុបច្ឆាភត្តិកង្គំ នេសជ្ជិកង្គំ យថាសន្ថតិកង្គំ ។
អទិដ្ឋិយា អស្សុតិយា អញាណា អសីលតា អវត្តា
នោបិ តេនាតិ នបិ សម្មាទិដ្ឋិមត្តេន នបិ សវនមត្តេន
នបិ ញាណមត្តេន នបិ សីលមត្តេន នបិ វត្តមត្តេន
អជ្ឈត្តសន្តិប្បត្តោ ហោតិ នបិ វិនា ឯតេហិ ធម្មេហិ
អជ្ឈត្តសន្តិំ បាបុណាតិ អបិច សម្ភារា ឥមេ ធម្មា ហោន្តិ

ការបូជាតូចមានផល ផលវិបាករបស់កម្ម ដែលបុគ្គលធ្វើល្អនិងធ្វើអាក្រក់មាន លោកនេះមាន លោកដទៃមាន មាតាមានគុណ បិតាមានគុណ ពួកសត្វជាឱបបាតិកៈមាន ពួកសមណព្រាហ្មណ៍អ្នកប្រព្រឹត្តត្រូវ ប្រតិបត្តិត្រូវ ធ្វើឲ្យជាក់ច្បាស់ ត្រាស់ដឹងលោកនេះ និងលោកខាងមុខ ដោយបញ្ញាដ៏ក្រៃលែង ដោយខ្លួនឯង មានក្នុងលោក ។ ការស្តាប់ដែលគួរប្រាថ្នាក៏មាន បានដល់ការឃោសនា អំពីសំណាក់បុគ្គលដទៃគឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ ។ ញាណដែលគួរប្រាថ្នាក៏មាន គឺ កម្មស្សកតញ្ញាណ សច្ចានុលោមិកញ្ញាណ អភិញ្ញាញ្ញាណ សមាបត្តិញ្ញាណ ។ សីលដែលគួរប្រាថ្នាក៏មាន បានដល់បាតិមោក្ខសំវរសីល ។ វត្តដែលគួរប្រាថ្នាក៏មាន បានដល់ធុតង្គទាំង ៨ គឺអារញ្ញិកង្គៈ ១ បិណ្ឌបាតិកង្គៈ ១ បង្សុកូលិកង្គៈ ១ តេចីវរិកង្គៈ ១ សបទានចារិកង្គៈ ១ ខលុបច្ឆាភត្តិកង្គៈ ១ នេសជ្ជិកង្គៈ ១ យថាសន្ថតិកង្គៈ ១ ។ ពាក្យថា ទាំងមិន (សំដែងនូវសេចក្តីបរិសុទ្ធិ) ព្រោះការមិនឃើញ ព្រោះការមិនឮ ព្រោះការមិនដឹង ព្រោះមិនមានសីល ព្រោះមិនមានវត្តនោះទេ បានសេចក្តីថា បុគ្គលដែលដល់សេចក្តីស្ងប់ខាងក្នុង មិនមែនត្រឹមតែយល់ត្រូវ មិនមែនត្រឹមតែឮ មិនមែនត្រឹមតែដឹង មិនមែនត្រឹមតែសីល មិនមែនត្រឹមតែវត្ត ឬថា ដល់សេចក្តីស្ងប់ខាងក្នុង ព្រោះវៀរចាកធម៌ទាំងនេះ ក៏មិនមែនដែរ មួយទៀត ធម៌ទាំងនេះ ជាសម្ភារៈ

## នវមោ មាគន្ទិយសុត្តនិទ្ទេសោ

អជ្ឈត្តសន្តឹ បាបុណិតុំ អធិគន្តុំ ផុសិតុំ សច្ឆិកាតុន្តិ អទិដ្ឋិយា អស្សុតិយា អញ្ញាណា អសីលតា អព្វតា នោបិ តេន ។

(១៨) ឯតេ ច និស្សជ្ជ អនុគ្គហាយាតិ ឯតេហិ[១] កណ្ហបក្ខិកានំ ធម្មានំ សមុគ្ឃាតតោ បហានំ ឥច្ឆិតព្វំ ។ តេធាតុកេសុ កុសលេសុ ធម្មេសុ អតម្មយតា ឥច្ឆិតព្វា ។ យតោ កណ្ហបក្ខិកា ធម្មា សមុគ្ឃាតប្បហានេន បហីនា ហោន្តិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា តេធាតុកេសុ ច[២] កុសលេសុ ធម្មេសុ អតម្មយតា ហោតិ ឯត្តាវតាបិ ន គណ្ហាតិ ន បរាមសតិ នាភិនិវិសតិ អថវា ន គណ្ហិតព្វា ន បរាមសិតព្វា នាភិនិវិសិតព្វាតិ ឯវម្បិ ឯតេ ច និស្សជ្ជ អនុគ្គហាយ ។ យតោ តណ្ហា ច ទិដ្ឋិ ច[៣] មានោ ច បហីនា ហោន្តិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា[៤]

១ ឱ. ឯតេ ។ ម. ឯតេតិ ។ ២.៣ បោត្ថកេ នត្ថិ ។ ៤ អនុប្បាទធម្មាតិ ។

ដើម្បីដល់ ដើម្បីបាន ដើម្បីប៉ះពាល់ ដើម្បីធ្វើឲ្យជាក់ច្បាស់ សេចក្តីស្ងប់ខាងក្នុង ហេតុនោះ (ទ្រង់ត្រាស់ថា) ទាំងមិនសំដែងនូវសេចក្តីបរិសុទ្ធិ) ព្រោះការមិនឃើញ ព្រោះការមិនឮ ព្រោះការមិនដឹង ព្រោះមិនមានសីល ព្រោះមិនមានវត្តនោះទេ ។

(១៨) ពាក្យថា លះ មិនប្រកាន់ធម៌ទាំងនុ៎ះ អធិប្បាយថា ការលះបង់ដោយការគាស់រំលើងនូវធម៌ជាពួកខ្មៅដោយធម៌ទាំងនុ៎ះ ត្រូវតែប្រាជ្ញា ។ ការមិនមានចំណង់ក្នុងធម៌ទាំងឡាយ ជាកុសល ប្រព្រឹត្តទៅក្នុងធាតុបី គប្បីប្រាជ្ញា ។ ធម៌ទាំងឡាយជាពួកខ្មៅដែលលះបង់ហើយ ដោយការលះបង់ ដោយការគាស់រំលើងឫសគល់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមាន មានការមិនកើតឡើង តទៅជាធម្មតា ទាំងមិនមានចំណង់ក្នុងធម៌ទាំងឡាយ ជាកុសល ប្រព្រឹត្តទៅក្នុងធាតុបី ដោយហេតុណា សប្បុរសមិនប្រកាន់ មិនបរាមាសអង្អែល មិនជាប់ចិត្ត ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ឬថា ធម៌ជាពួកខ្មៅទាំងឡាយ សប្បុរស មិនគប្បីប្រកាន់ មិនគប្បីបរាមាសអង្អែល មិនគប្បីជាប់ចិត្ត ហេតុនោះ (ទ្រង់ត្រាស់ថា) លះ មិនប្រកាន់នូវធម៌ទាំងនុ៎ះ ដោយប្រការយ៉ាងនេះឯង ។ តណ្ហា ទិដ្ឋិ នឹង មានៈ សប្បុរសលះបង់ហើយ ផ្តាច់ផ្តិលឫសគល់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមាន មានការមិនកើតឡើងតទៅជាធម្មតា

ឯត្តាវតាបិ ន គណ្ហាតិ ន បរាមសតិ នាភិនិវិសតីតិ ឯវម្បិ ឯតេ ច និស្សជ្ជ អនុគ្គហាយ ។ យតោ បុញ្ញាភិសង្ខារោ ច អបុញ្ញាភិសង្ខារោ ច អានេញ្ជាភិសង្ខារោ ច បហីនា ហោន្តិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា[1] ឯត្តាវតាបិ ន គណ្ហាតិ ន បរាមសតិ នាភិនិវិសតីតិ ឯវម្បិ ឯតេ ច និស្សជ្ជ អនុគ្គហាយ ។

(១៩) សន្តោ អនិស្សាយ ករំ ន ជប្បតិ សន្តោតិ រាគស្ស សន្តត្តា សន្តោ ទោសស្ស សន្តត្តា សន្តោ មោហស្ស សន្តត្តា សន្តោ កោធស្ស ឧបនាហស្ស មក្ខស្ស បឡាសស្ស ឥស្សាយ មច្ឆរិយស្ស មាយាយ សាឋេយ្យស្ស ថម្ភស្ស សារម្ភស្ស មានស្ស អតិមានស្ស មទស្ស បមាទស្ស សព្វកិលេសានំ សព្វទុច្ចរិតានំ សព្វទរថានំ សព្វបរិឡាហានំ សព្វសន្តាបានំ សព្វាកុសលាភិសង្ខារានំ សន្តត្តា សមិតត្តា វូបសមិតត្តា វិជ្ឈាតត្តា និព្វុតត្តា វិគតត្តា បដិប្បស្សទ្ធត្តា សន្តោ វូបសន្តោ និព្វុតោ បដិប្បស្សទ្ធោតិ សន្តោ ។

១ ម. អនុប្បាទធម្មាតិ ។

ដោយហេតុណា សប្បុរសមិនប្រកាន់ មិនបបោសអង្អែល មិនជាប់ចិត្ត ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ហេតុនោះ (ទ្រង់ត្រាស់ថា) លះ មិនប្រកាន់ ដោយប្រការយ៉ាងនេះ ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ និង អានេញ្ជាភិសង្ខារ សប្បុរសលះបង់ហើយ ផ្តាច់ផ្តិលឫសគល់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមាន មានការមិនកើតតទៅជាធម្មតា ដោយហេតុណា សប្បុរសមិនប្រកាន់ មិនបបោសអង្អែល មិនជាប់ចិត្ត ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ហេតុនោះ (ទ្រង់ត្រាស់ថា) លះ មិនប្រកាន់ធម៌ទាំងនុ៎ះ ដោយប្រការយ៉ាងនេះឯង ។

(១៩) អធិប្បាយពាក្យថា ជាអ្នកស្ងប់ មិនអាស្រ័យហើយ មិនគប្បីប្រាថ្នាភព ត្រង់ពាក្យថា ជាអ្នកស្ងប់ សេចក្តីថា ជាអ្នកស្ងប់ ព្រោះស្ងប់រាគៈ ជាអ្នកស្ងប់ ព្រោះស្ងប់ទោសៈ ជាអ្នកស្ងប់ ព្រោះស្ងប់មោហៈ ជាអ្នកស្ងប់ រម្ងាប់ រំលត់ ស្ងប់ រម្ងាប់ ព្រោះស្ងប់ រម្ងាប់ បូលដិតរម្ងាប់ ផុត រំលត់ ឲ្យទៅប្រាស ស្ងប់ រម្ងាប់ នូវកោធៈ ឧបនាហៈ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីក្រហល់ក្រហាយទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង អភិសង្ខារជាអកុសលទាំងពួង ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកស្ងប់ ។

## នវមោ មាគន្ទិយសុត្តនិទ្ទេសោ

អនិស្សាយាតិ ទ្វេ និស្សយា តណ្ហានិស្សយោ ច ទិដ្ឋិនិស្សយោ ច ។ បេ ។ អយំ តណ្ហានិស្សយោ ។ បេ ។ អយំ ទិដ្ឋិនិស្សយោ ។ តណ្ហានិស្សយំ បហាយ ទិដ្ឋិនិស្សយំ បដិនិស្សជ្ជិត្វា ចក្ខុំ អនិស្សាយ សោតំ អនិស្សាយ ឃានំ អនិស្សាយ ជិវ្ហំ អនិស្សាយ កាយំ អនិស្សាយ មនំ អនិស្សាយ រូបេ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ កុលំ គណំ អាវាសំ លាភំ យសំ បសំសំ សុខំ ចីវរំ បិណ្ឌបាតំ សេនាសនំ គិលានបច្ចយភេសជ្ជបរិក្ខារំ កាមធាតុំ រូបធាតុំ អរូបធាតុំ កាមភវំ រូបភវំ អរូបភវំ សញ្ញាភវំ អសញ្ញាភវំ នេវសញ្ញានាសញ្ញាភវំ ឯកវោការភវំ ចតុវោការភវំ បញ្ចវោការភវំ អតីតំ អនាគតំ បច្ចុប្បន្នំ ទិដ្ឋសុតមុតវិញ្ញាតព្វេ ធម្មេ អនិស្សាយ អគ្គណ្ហិត្វា អបរាមសិត្វា អនភិនិវិសិត្វាតិ សង្ខា អនិស្សាយ ។ ភវំ ន ជប្បេតិ កាមភវំ ន ជប្បេយ្យ រូបភវំ ន ជប្បេយ្យ អរូបភវំ ន ជប្បេយ្យ ន បជប្បេយ្យ ន អភិជប្បេយ្យាតិ សង្ខា អនិស្សាយ ភវំ ន ជប្បេ ។

## មាគន្ទិយសុត្តនិទ្ទេស ទី ៩

ពាក្យថា មិនអាស្រ័យ បានដល់ការអាស្រ័យ ២ គឺ តណ្ហានិស្ស័យ ១ ទិដ្ឋិនិស្ស័យ ១ ។បេ។ នេះតណ្ហានិស្ស័យ ។បេ។ នេះ ទិដ្ឋិនិស្ស័យ ។ បុគ្គលលះតណ្ហានិស្ស័យ រលាស់ចោលទិដ្ឋិនិស្ស័យ មិនអាស្រ័យភ្នែក មិនអាស្រ័យត្រចៀក មិនអាស្រ័យច្រមុះ មិនអាស្រ័យអណ្ដាត មិនអាស្រ័យកាយ មិនអាស្រ័យចិត្ត មិនអាស្រ័យ មិនប្រកាន់ មិនបញោស អង្អែល មិនជាប់ចិត្ត នូវរូប សំឡេង ក្លិន រស ផ្សព្វ ត្រកូល គណៈ អាវាស លាភ យស សេចក្ដីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព អតីត អនាគត បច្ចុប្បន្ន និងធម៌ទាំងឡាយ ដែលឃើញ ឮ ប៉ះពាល់ ឬគប្បីដឹង ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកស្ងប់ មិនអាស្រ័យ ។ ពាក្យថា មិនគប្បីប្រាថ្នាភព សេចក្ដីថា មិនគប្បីប្រាថ្នាកាមភព មិនគប្បីប្រាថ្នារូបភព មិនគប្បីប្រាថ្នា មិនគប្បីប្រាថ្នាដោយប្រការៈ មិនគប្បីប្រាថ្នាចំពោះអរូបភព ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកស្ងប់ មិនអាស្រ័យ មិនគប្បីប្រាថ្នាភព ។

តេនាហ ភគវា

ន ទិដ្ឋិយា ន សុតិយា ន ញាណេន

សីលព្វតេនាបិ ន សុទ្ធិមាហ

អទិដ្ឋិយា អស្សុតិយា អញាណា

អសីលតា អព្វតា នោបិ តេន

ឯតេ ច និស្សជ្ជ អនុគ្គហាយ

សន្តោ អនិស្សាយ ភវំ ន ជប្បេតិ ។

(២០) នោ ចេ កិរ ទិដ្ឋិយា ន សុតិយា ន ញាណេន

(ឥតិ មាគន្ទិយោ)

សីលព្វតេនាបិ ន សុទ្ធិមាហ

អទិដ្ឋិយា អស្សុតិយា អញាណា

អសីលតា អព្វតា នោបិ តេន

មញ្ញេ មហំ មោមុហមេវ ធម្មំ

ទិដ្ឋិយា ឯកេ បច្ចេន្តិ សុទ្ធិំ ។

ហេតុនោះ ព្រះមានភាគត្រាស់ហើយថា

(ម្នាលមាគន្ទិយៈ) អ្នកប្រាជ្ញ មិនពោលនូវសេចក្ដីបរិសុទ្ធិ
ព្រោះការឃើញទេ ព្រោះការឮទេ ព្រោះការដឹងទេ
ព្រោះសីលនឹងវត្តទេ ទាំងមិន (ពោលនូវសេចក្ដីបរិសុទ្ធិ)
ព្រោះការមិនឃើញ ព្រោះការមិនឮ ព្រោះការមិនដឹង
ព្រោះមិនមានសីល ព្រោះមិនមានវត្តនោះទេ ទាំងលះ
មិនប្រកាន់នូវធម៌ទាំងនោះ ជាអ្នកស្ងប់ មិនអាស្រ័យ
ហើយ មិនគប្បីប្រាថ្នាភព ។

[២០] (មាគន្ទិយព្រាហ្មណ៍ទូលដូច្នេះថា) ប្រសិនបើអ្នកប្រាជ្ញ
មិនពោលនូវសេចក្ដីបរិសុទ្ធិ ព្រោះការឃើញទេ ព្រោះ
ការឮទេ ព្រោះការដឹងទេ ព្រោះសីលនឹងវត្តទេ ទាំង
មិន (ពោលនូវសេចក្ដីបរិសុទ្ធិ) ព្រោះការមិនឃើញ
ព្រោះការមិនឮ ព្រោះការមិនដឹង ព្រោះមិនមានសីល
ព្រោះមិនមានវត្តនោះទេ ខ្ញុំព្រះអង្គសំគាល់ធម៌ (របស់
ព្រះអង្គ ថាជាធម៌) នាំសត្វឲ្យវង្វេងជ្រប់ សមណ.
ព្រាហ្មណ៍ពួកខ្លះ ជឿសេចក្ដីបរិសុទ្ធិ ព្រោះទិដ្ឋិ ។

នវមោ មាគន្ទិយសុត្តនិទ្ទេសោ

[២១] នោ ចេ កិរ ទិដ្ឋិយា ន សុតិយា ន ញាណេនាតិ ទិដ្ឋិយាបិ សុទ្ធិំ វិសុទ្ធិំ បរិសុទ្ធិំ មុត្តិំ វិមុត្តិំ បរិមុត្តិំ នាហ ន កថេសិ ន ភណសិ ន ទីបយសិ ន វោហរសិ ។ សុតេនបិ សុទ្ធិំ វិសុទ្ធិំ បរិសុទ្ធិំ មុត្តិំ វិមុត្តិំ បរិមុត្តិំ នាហ ន កថេសិ ន ភណសិ ន ទីបយសិ ន វោហរសិ ។ ទិដ្ឋសុតេនបិ សុទ្ធិំ វិសុទ្ធិំ បរិសុទ្ធិំ មុត្តិំ វិមុត្តិំ បរិមុត្តិំ នាហ ន កថេសិ ន ភណសិ ន ទីបយសិ ន វោហរសិ ។ ញាណេនបិ សុទ្ធិំ វិសុទ្ធិំ បរិសុទ្ធិំ មុត្តិំ វិមុត្តិំ បរិមុត្តិំ នាហ ន កថេសិ ន ភណសិ ន ទីបយសិ ន វោហរសីតិ នោ ចេ កិរ ទិដ្ឋិយា ន សុតិយា ន ញាណេន ។ ឥតិ មាគន្ទិយោតិ ឥតីតិ បទសន្ធិ ។បេ។ បទានុបុព្វតាមេតំ ឥតីតិ ។ មាគន្ទិយោតិ តស្ស ព្រាហ្មណស្ស នាមត្តិ ឥតិ មាគន្ទិយោ ។

## មាគន្ទិយសុត្តនិទ្ទេស ទី ៩

[៦១] ពាក្យថា ប្រសិនបើ (អ្នកប្រាជ្ញ) មិនពោល (នូវសេចក្តីបរិសុទ្ធិ) ព្រោះការឃើញទេ ព្រោះការឮទេ ព្រោះការដឹងទេ អធិប្បាយថា អ្នកប្រាជ្ញមិនពោល គឺមិនថ្លែង មិនពណ៌នា មិនបំភ្លឺ មិនពន្យល់ នូវសេចក្តីស្អាត ស្អាតវិសេស សេចក្តីបរិសុទ្ធិ ការផុត ការផុតស្រឡះ ការផុតដោយជុំវិញ សូម្បីដោយការឃើញទេ ។ អ្នកប្រាជ្ញមិនពោល គឺមិនថ្លែង មិនពណ៌នា មិនបំភ្លឺ មិនពន្យល់ នូវសេចក្តីស្អាត ស្អាតវិសេស សេចក្តីបរិសុទ្ធិ ការផុត ការផុតស្រឡះ ការផុតដោយជុំវិញ សូម្បីដោយការឮទេ ។ អ្នកប្រាជ្ញមិនពោល គឺមិនថ្លែង មិនពណ៌នា មិនបំភ្លឺ មិនពន្យល់ នូវសេចក្តីស្អាត ស្អាតវិសេស សេចក្តីបរិសុទ្ធិ ការផុត ការផុតស្រឡះ ការផុតដោយជុំវិញ សូម្បីដោយការឃើញ ទាំងការឮទេ ។ អ្នកប្រាជ្ញមិនពោល គឺមិនថ្លែង មិនពណ៌នា មិនបំភ្លឺ មិនពន្យល់ នូវសេចក្តីស្អាត ស្អាតវិសេស សេចក្តីបរិសុទ្ធិ ការផុត ការផុតស្រឡះ ការផុតដោយជុំវិញ សូម្បីដោយការដឹងទេ ហេតុនោះ (ព្រាហ្មណ៍ពោលថា) ប្រសិនបើ (អ្នកប្រាជ្ញ)មិនពោល (នូវសេចក្តីបរិសុទ្ធិ) ព្រោះការឃើញទេ ព្រោះការឮទេ ព្រោះការដឹងទេ ។ ពាក្យថា ដូច្នេះ របស់បទថា មាគន្ទិយៈទូលដូច្នេះ ជាបទសន្ធិ ។ បេ ។ ពាក្យថាដូច្នេះ នុ៎ះ ជាលំដាប់បទ ។ ពាក្យថា មាគន្ទិយៈ ជាឈ្មោះព្រាហ្មណ៍នោះ ហេតុនោះ មានពាក្យថា មាគន្ទិយៈ (ទូល) ដូច្នេះ ។

(២២) សីលព្វតេនាបិ ន សុទ្ធិមាហាតិ សីលេនបិ សុទ្ធិំ វិសុទ្ធិំ បរិសុទ្ធិំ វត្តេនបិ សុទ្ធិំ វិសុទ្ធិំ បរិសុទ្ធិំ សីលព្វតេនបិ សុទ្ធិំ វិសុទ្ធិំ បរិសុទ្ធិំ មុត្តិំ វិមុត្តិំ បរិមុត្តិំ នាហ ន កថេតិ ន ភណតិ ន ទីបយតិ ន វោហរតីតិ សីលព្វតេនាបិ ន សុទ្ធិមាហ ។

(២៣) អទិដ្ឋិយា អស្សុតិយា អញាណា អសីលតា អព្វតា នោបិ តេនាតិ ទិដ្ឋិបិ ឥច្ឆិតព្វាតិ ឯវំ កថេសិ សវនម្បិ ឥច្ឆិតព្វន្តិ ឯវំ កថេសិ ញាណម្បិ ឥច្ឆិតព្វន្តិ ឯវំ កថេសិ សីលម្បិ ឥច្ឆិតព្វន្តិ ឯវំ កថេសិ វត្តម្បិ ឥច្ឆិតព្វន្តិ ឯវំ កថេសិ ន សក្កោតិ ឯកំសេន អនុជានិតុំ ន សក្កោតិ ឯកំសេន បដិក្ខិបិតុន្តិ អទិដ្ឋិយា អស្សុតិយា អញាណា អសីលតា អព្វតា នោបិ តេន ។

(៤២) ពាក្យថា អ្នកប្រាជ្ញមិនពោលនូវសេចក្តីបរិសុទ្ធិ ព្រោះសីលនឹងវត្តទេ សេចក្តីថា អ្នកប្រាជ្ញមិនពោល គឺមិនថ្លែង មិនពណ៌នា មិនបំភ្លឺ មិនពន្យល់ នូវសេចក្តីស្អាត ស្អាតវិសេស សេចក្តីបរិសុទ្ធិ សូម្បីដោយសីលទេ នូវសេចក្តីស្អាត ស្អាតវិសេស សេចក្តីបរិសុទ្ធិ សូម្បីដោយវត្តទេ នូវសេចក្តីស្អាត ស្អាតវិសេស សេចក្តីបរិសុទ្ធិ ការផុត ការផុតស្រឡះ ការផុតដោយជុំវិញ សូម្បីដោយសីលនឹងវត្តទេ ហេតុនោះ (ព្រាហ្មណ៍ពោលថា) អ្នកប្រាជ្ញមិនពោលនូវសេចក្តីបរិសុទ្ធិ ព្រោះសីលនឹងវត្តទេ ។

(៤៣) ពាក្យថា ទាំងមិន (ពោលនូវសេចក្តីបរិសុទ្ធិ) ព្រោះការមិនឃើញ ព្រោះការមិនឮ ព្រោះការមិនដឹង ព្រោះមិនមានសីល ព្រោះមិនមានវត្តនោះទេ សេចក្តីថា ព្រះអង្គពោលយ៉ាងនេះថា ទិដ្ឋិដែលគួរប្រាថ្នាក៏មាន ព្រះអង្គពោលយ៉ាងនេះថា ការស្តាប់ដែលគួរប្រាថ្នាក៏មាន ព្រះអង្គពោលយ៉ាងនេះថា ការដឹងដែលគួរប្រាថ្នាក៏មាន ព្រះអង្គពោលយ៉ាងនេះថា សីលដែលគួរប្រាថ្នាក៏មាន ព្រះអង្គពោលយ៉ាងនេះថា វត្តដែលគួរប្រាថ្នាក៏មាន ព្រះអង្គមិនអាចដើម្បីយល់តាម ដោយដាច់ខាត ព្រះអង្គមិនអាចដើម្បីបដិសេធ ដោយដាច់ខាត ហេតុនោះ (ព្រាហ្មណ៍ពោលថា) ទាំងមិន (ពោលនូវសេចក្តីបរិសុទ្ធិ) ព្រោះការមិនឃើញ ព្រោះការមិនឮ ព្រោះការមិនដឹង ព្រោះមិនមានសីល ព្រោះមិនមានវត្តនោះទេ ។

## នវមោ មាគន្ទិយសុត្តនិទ្ទេសោ

(២៤) មញ្ញាមហំ មោមុហាមេវ ធម្មន្តិ មោមូហាធម្មោ អយំ តុយ្ហំ ពាលធម្មោ មូឡ្ហធម្មោ អញ្ញាណធម្មោ អមរាវិក្ខេបធម្មោតិ ឯវំ មញ្ញាមិ ឯវំ ជានាមិ ឯវំ អាជានាមិ ឯវំ បដិវិជ្ឈាមីតិ មញ្ញាមហំ មោមុហាមេវ ធម្មំ ។

(២៥) ទិដ្ឋិយា ឯកេ បច្ចេន្តិ សុទ្ធិន្តិ ទិដ្ឋិយា ឯកេ សមណព្រាហ្មណា សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ បច្ចេន្តិ ។ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ទិដ្ឋិយា ឯកេ សមណព្រាហ្មណា សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ បច្ចេន្តិ ។ អសស្សតោ លោកោ ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ទិដ្ឋិយា ឯកេ សមណព្រាហ្មណា សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ បច្ចេន្តីតិ ទិដ្ឋិយា ឯកេ បច្ចេន្តិ សុទ្ធឹ ។ តេនាហ សោ ព្រាហ្មណោ

## មាគន្ទិយសុត្តនិទ្ទេស ទី ៩

[២៨] ពាក្យថា ខ្ញុំព្រះអង្គសំគាល់ធម៌ (របស់ព្រះអង្គ ថាជាធម៌) នាំសត្វឲ្យវៀនចេញជ្រប់ សេចក្ដីថា ខ្ញុំព្រះអង្គសំគាល់យ៉ាងនេះ ដឹងយ៉ាងនេះ ដឹងច្បាស់យ៉ាងនេះ យល់ច្បាស់យ៉ាងនេះថា ធម៌របស់ព្រះអង្គនេះ ជាធម៌ញុំាងសត្វឲ្យវៀនចេញ ជាធម៌ពាល ជាធម៌ងងឹត ជាធម៌ប្រាសចាកញាណ ជាអមរាវិក្ខេបធម៌ ហេតុនោះ (ព្រាហ្មណ៍ពោលថា) ខ្ញុំព្រះអង្គសំគាល់ធម៌ (របស់ព្រះអង្គ ថាជាធម៌) នាំសត្វឲ្យវង្វេងជ្រប់ ។

[២៩] ពាក្យថា សមណព្រាហ្មណ៍ពួកខ្លះ ជឿសេចក្ដីបរិសុទ្ធិ ព្រោះការឃើញ សេចក្ដីថា សមណព្រាហ្មណ៍ទាំងឡាយពួកខ្លះ ជឿថា សេចក្ដីស្អាត ស្អាតវិសេស សេចក្ដីបរិសុទ្ធិ ការផុត ការផុតស្រឡះ ការផុតដោយជុំវិញ ព្រោះការឃើញ ។ សមណព្រាហ្មណ៍ពួកខ្លះ ជឿសេចក្ដីស្អាត ស្អាតវិសេស សេចក្ដីបរិសុទ្ធិ ការផុត ការផុតស្រឡះ ការផុតដោយជុំវិញ ព្រោះការឃើញថា លោកទៀង ពាក្យនេះឯងពិត ពាក្យដទៃជាមោឃៈ ។ សមណព្រាហ្មណ៍ពួកខ្លះ ជឿសេចក្ដីស្អាត ស្អាតវិសេស សេចក្ដីបរិសុទ្ធិ ការផុត ការផុតស្រឡះ ការផុតដោយជុំវិញ ព្រោះការឃើញថា លោកមិនទៀង ។ បេ ។ សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះឯងពិត ពាក្យដទៃជាមោឃៈ ហេតុនោះ (ព្រាហ្មណ៍ពោលថា) សមណព្រាហ្មណ៍ពួកខ្លះ ជឿសេចក្ដីបរិសុទ្ធិ ព្រោះការឃើញ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

នោ ចេ កីរ ទិដ្ឋិយា ន សុតិយា ន ញាណេន
សីលព្វតេនាបិ ន សុទ្ធិមាហ
អទិដ្ឋិយា អស្សុតិយា អញ្ញាណា
អសីលតា អព្វតា នោបិ តេន
មញ្ញាមហំ មោមុហមេវ ធម្មំ
ទិដ្ឋិយា ឯកេ បច្ចេន្តិ សុទ្ធិំ ។

(៥៦) ទិដ្ឋីសុ និស្សាយ អនុបុច្ឆមានោ
( មាគណ្ឌិយាតិ ភគវា )
សមុគ្គហីតេសុ បមោហមាគា
ឥតោ ច នាទ្ទក្ខិ អណុម្បិ សញ្ញំ
តស្មា តុវំ មោមុហតោ ទហាសិ ។

(៥៧) ទិដ្ឋីសុ និស្សាយ អនុបុច្ឆមានោតិ មាគណ្ឌិយោ ព្រាហ្មណោ ទិដ្ឋី និស្សាយ ទិដ្ឋី បុច្ឆតិ លគ្គនំ និស្សាយ លគ្គនំ បុច្ឆតិ ពន្ធនំ និស្សាយ ពន្ធនំ បុច្ឆតិ បលិពោធំ និស្សាយ បលិពោធំ បុច្ឆតិ ។ អនុបុច្ឆមានោតិ បុនប្បុនំ បុច្ឆតីតិ ទិដ្ឋីសុ និស្សាយ អនុបុច្ឆមានោតិ ។

ប្រសិនបើអ្នកប្រាជ្ញមិនពោលនូវសេចក្តីបរិសុទ្ធិ ព្រោះការឃើញទេ ព្រោះការឮទេ ព្រោះការដឹងទេ ព្រោះសីលនិងវត្តទេ ទាំងមិន (ពោលនូវសេចក្តីបរិសុទ្ធិ) ព្រោះការមិនឃើញ ព្រោះការមិនឮ ព្រោះការមិនដឹង ព្រោះមិនមានសីល ព្រោះមិនមានវត្តនោះទេ ខ្ញុំព្រះអង្គសំគាល់ធម៌ (របស់ព្រះអង្គ ថាជាធម៌) នាំសត្វឲ្យវង្វេងជ្រប់ សមណព្រាហ្មណ៍ពួកខ្លះ ជឿសេចក្តីបរិសុទ្ធិ ព្រោះទិដ្ឋិ ។

(២៦) (ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលមាគន្ទិយៈ) អ្នកអាស្រ័យទិដ្ឋិទាំងឡាយហើយ ទើបសួររឿយៗ អ្នកដល់នូវសេចក្តីភ័ន្តច្រឡំក្នុងទិដ្ឋិទាំងឡាយ ដែលប្រកាន់ហើយ មិនបានឃើញសញ្ញាសូម្បីតិចតួច អំពីធម៌នេះ ហេតុនោះ ទើបអ្នកយល់ថាជាធម៌នាំឲ្យសត្វវង្វេងជ្រប់ ។

(២៧) ពាក្យថា អ្នកអាស្រ័យទិដ្ឋិទាំងឡាយហើយ ទើបសួររឿយ ៗ សេចក្តីថា មាគន្ទិយព្រាហ្មណ៍អាស្រ័យទិដ្ឋិ ហើយសួរទិដ្ឋិ អាស្រ័យការជាប់ចំពាក់ ហើយសួរការជាប់ចំពាក់ អាស្រ័យចំណង ហើយសួរចំណង អាស្រ័យបលិពោធ ហើយសួរបលិពោធ ។ ពាក្យថា សួររឿយៗ គឺ សួរញឹកញយ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកអាស្រ័យទិដ្ឋិទាំងឡាយហើយ ទើបសួររឿយ ៗ ។

### ឥរិយោ មាតុគ្គាមសុត្តនិទ្ទេសោ

មាតុឆ្កិយាតិ ភគភ តំ ព្រាហ្មណំ ឆាមេឆ អាលបតិ ៗ ភគភតិ គារភឆិរគដំ ៗ បេ ៗ សច្ចិកា បញ្ញត្តិ យតិទំ ភគភតិ មាតុឆ្កិយាតិ ភគភ ៗ

(២៨) សម្មុគ្គហីតេសុ បមោហមាគាតិ យោ តិដ្ឋ តយោ គហិតា បភមដ្ឋា អតិតិរិដ្ឋា អជ្ឈោសិតា អជិ-មុត្តា តាយេរ តុំ តិដ្ឋយោ ម្ហុទ្ធោសិ បម្ហុទ្ធោ សម្ហុទ្ធោ មោហំ អាគតោសិ បមោហំ អាគតោសិ សម្មោហំ អាគតោសិ អប្ពុគារំ បក្ខុទ្ធោសិតិ សម្មុគ្គហីតេសុ បមោហអាគា ៗ

(២៩) ឥតោ ច ឆាន្ទគ្ខិ អណាម្ហ៊ សញ្ញាដ្ឋិ ឥតោ អជ្ឈត្តសង្ខិតោ វា បដិបត្តិតោ វា ជម្ពុទេសជតោ វា យុត្តសញ្ញំ វា បត្តសញ្ញំ វា លក្ខណាសញ្ញំ វា គោរណា-សញ្ញំ វា ហាឧសញ្ញំ វា ជ បដិលភតិ គុតោ ញាណាដ្ឋិ ឃរម្ហ៊ ឥតោ ច ឆាន្ទគ្ខិ អណាម្ហ៊ សញ្ញំ ៗ

## មាគន្ទិយសុត្តនិទ្ទេស ទី ៩

ពាក្យថា មាគន្ទិយៈ គឺព្រះមានព្រះភាគត្រាស់ហៅ នូវព្រាហ្មណ៍នោះ ដោយចំឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគ ជាពាក្យហៅ ដោយគោរព ។ បេ ។ សេចក្ដីបញ្ញត្តិថា ព្រះមានព្រះភាគ នេះ (កើត) អំពីការត្រាស់ដឹង ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគត្រាស ហៅថា មាគន្ទិយៈ ។

(៤៨) ពាក្យថា អ្នកដល់នូវសេចក្ដីកន្ត័ប្រឡំ ក្នុងទិដ្ឋិទាំងឡាយ ដែលប្រកាន់ហើយ សេចក្ដីថា ទិដ្ឋិណាដែលអ្នកប្រកាន់ បបោស អង្អែល ចូលចិត្ត ចុះចិត្ត ចុះចិត្តស៊ប់ អ្នកជាបុគ្គលវង្វេង វង្វេងជ្រប់ វង្វេងស៊ប់ ជាអ្នកដល់នូវសេចក្ដីវង្វេង ដល់នូវសេចក្ដីវង្វេងជ្រប់ ដល់នូវសេចក្ដីវង្វេងស៊ប់ ជាអ្នកស្ទុងទៅកាន់សេចក្ដីងងឹតងងល់ក្នុងទិដ្ឋិនោះឯង ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកដល់នូវការកន្ត័ប្រឡំ ក្នុងទិដ្ឋិទាំងឡាយ ដែលប្រកាន់ហើយ ។

(៤៩) ពាក្យថាអ្នកមិនបានឃើញសញ្ញាសូម្បីបន្តិចបន្តួច អំពីធម៌នេះ សេចក្ដីថា អ្នកមិនបានសញ្ញាដែលគួរហើយក្ដី សញ្ញាដែលដល់ហើយក្ដី សញ្ញាជាគ្រឿងចំណាំក្ដី សញ្ញាជាហេតុក្ដី សញ្ញាជាទីតាំងក្ដី អំពីធម៌ដែលមានសេចក្ដីស្ងប់ខាងក្នុងនេះក្ដី អំពីសេចក្ដីបដិបត្តិនេះក្ដី អំពីធម្មទេសនានេះក្ដី តើញាណ (នឹងមានមក) អំពីណា ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមិនបានឃើញសញ្ញាសូម្បីបន្តិចបន្តួច អំពីធម៌នេះ ដោយប្រការយ៉ាងនេះឯង ៗ

អជ វា អនិច្ចំ វា អនិច្ចសញ្ញានុលោមំ វា ទុក្ខំ វា ទុក្ខសញ្ញានុលោមំ វា អនត្តំ វា អនត្តសញ្ញានុលោមំ វា សញ្ញុប្បាទមត្តំ វា សញ្ញានិមិត្តំ(១) វា ន បដិលភតិ កុតោ ញាណន្តិ ឯវម្បិ ឥតោ ច នាទ្ទក្ខិ អណុម្បិ សញ្ញំ ។

(៣០) តស្មា តុវំ មោមូហតោ ទហាសីតិ តស្មាតិ តស្មា តំការណា តំហេតុ តប្បច្ចយា តំនិទានា មោមូហធម្មតោ ពាលធម្មតោ មូឡ្ហធម្មតោ អញ្ញាណធម្មតោ អមរាវិក្ខេបធម្មតោ ទហាសិ បស្សសិ ទក្ខសិ ឱលោកេសិ និជ្ឈាយសិ ឧបបរិក្ខសីតិ តស្មា តុវំ មោមូហតោ ទហាសិ ។ តេនាហ ភគវា

ទិដ្ឋិញ្ច និស្សាយ អនុបុច្ឆមានោ
សមុគ្គហីតេសុ បមោហមាគា
ឥតោ ច នាទ្ទក្ខិ អណុម្បិ សញ្ញំ
តស្មា តុវំ មោមូហតោ ទហាសីតិ ។

---

១ ម សញ្ញាវិមិត្តំ ។

មួយវិញទៀត អ្នកមិនបានសញ្ញាថា បញ្ចក្ខន្ធ មិនទៀង ឬអនុលោមតាមសញ្ញាថា បញ្ចក្ខន្ធ មិនទៀង សញ្ញាថា បញ្ចក្ខន្ធ ជាទុក្ខ ឬអនុលោមតាមសញ្ញាថា បញ្ចក្ខន្ធ ជាទុក្ខ សញ្ញាថា បញ្ចក្ខន្ធ ជាអនត្តា ឬអនុលោមតាមសញ្ញាថា បញ្ចក្ខន្ធ ជាអនត្តា កិច្ចត្រឹមតែកិរិយាញុំាងសញ្ញាឲ្យកើតឡើង ឬនិមិត្តក្នុងសញ្ញា តើញាណនឹងមានមកអំពីណា ហេតុនោះ (ទ្រង់ត្រាស់ថា) មិនបានឃើញសញ្ញាសម្បប្បដិបន្ន អំពីធម៌នេះ ។

(៣០) ពាក្យថា ហេតុនោះ ទើបអ្នកយល់ថាជាធម៌នាំសត្វឲ្យវង្វេងជ្រប់ ត្រង់ពាក្យថា ហេតុនោះ គឺ ព្រោះហេតុដូច្នោះ ព្រោះការណ៍នោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ទើបអ្នកយល់ឃើញ ក្រឡេកឃើញ រំពឹងឃើញ ពិចារណាឃើញ ថាជាធម៌ញុំាងសត្វ ឲ្យវង្វេងជ្រប់ ថាជាធម៌ពាល ថាជាធម៌កន្តប្រឡំ ថាជាធម៌ប្រាសចាកញាណ ថាជាអមរាវិក្ខេបធម៌ ហេតុនោះ (ទ្រង់ត្រាស់ថា) ហេតុនោះ ទើបអ្នកយល់ថាជាធម៌ញុំាងសត្វ ឲ្យវង្វេងជ្រប់ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

អ្នកអាស្រ័យទិដ្ឋិទាំងឡាយហើយសួររឿយ ៗ ដល់ទូរសេចក្តី
កន្តប្រឡំ ក្នុងទិដ្ឋិទាំងឡាយ ដែលប្រកាន់យកហើយ មិន
បានឃើញសញ្ញាសម្បប្បដិបន្ន អំពីធម៌នេះ ហេតុនោះ
ទើបអ្នកយល់ថាជាធម៌នាំឲ្យវង្វេងជ្រប់ ។

## នវមោ មាគន្ទិយសុត្តនិទ្ទេសោ

(៣១) សមោ វិសេសី ឧទ វា និហីនោ
យោ មញ្ញតី សោ វិវទេថ តេន
តីសុ វិធាសុ អវិកម្បមានោ
សមោ វិសេសីតិ ន តស្ស ហោតិ ។

(៣២) សមោ វិសេសី ឧទ វា និហីនោ យោ មញ្ញតី សោ វិវទេថ តេនាតិ សេយ្យោហមស្មីតិ វា សទិសោហមស្មីតិ វា ហីនោហមស្មីតិ វា យោ មញ្ញតិ សោ តេន មានេន តាយ ទិដ្ឋិយា តេន វា បុគ្គលេន កលហំ ករេយ្យ ភណ្ឌនំ ករេយ្យ វិគ្គហំ ករេយ្យ វិវាទំ ករេយ្យ មេធគំ ករេយ្យ ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ អហំ ឥមំ ធម្មវិនយំ អាជានាមិ កឹ ត្វំ ឥមំ ធម្មវិនយំ អាជានិស្សសិ មិច្ឆាបដិបន្នោ ត្វមសិ អហមស្មិ សម្មាបដិបន្នោ សហិតំ មេ អសហិតំ តេ បុរេ វចនីយំ បច្ឆា អវច បច្ឆា វចនីយំ បុរេ អវច អធិចិណ្ណំ តេ វិបរាវត្តំ អារោបិតោ តេ វាទោ និគ្គហិតោសិ (១)

---

១ ម. និគ្គហិតោ ត្វមសិ ។

## មាគន្ទិយសុត្តនិទ្ទេស ទី ៩

(៣១) បុគ្គលណា សំគាល់ថាស្មើ ថាប្រសើរ ឬថាថោកថយ បុគ្គលនោះ គប្បីនិយាយទទឹងទាស់ ដោយសេចក្តីសំគាល់នោះ បុគ្គលណា មិនញាប់ញ័រក្នុងមានះ ៣ យ៉ាង ការប្រកាន់ថាស្មើ ថាប្រសើរ (ឬថាថោកថយ) នៃបុគ្គលនោះ មិនមានឡើយ ។

(៣២) ពាក្យថា បុគ្គលណា សំគាល់ថាស្មើ ថាប្រសើរ ឬថាថោកថយ បុគ្គលនោះ គប្បីនិយាយទទឹងទាស់ ដោយសេចក្តីសំគាល់នោះ អធិប្បាយថា បុគ្គលណាសំគាល់ថា អាត្មាអញប្រហែលនឹងគេក្តី ថាអាត្មាអញប្រសើរក្តី ថាអាត្មាអញថោកថយក្តី បុគ្គលនោះ គប្បីធ្វើជម្លោះ គប្បីធ្វើការទាស់ទែង គប្បីធ្វើការប្រកាន់ខុស គប្បីធ្វើវិវាទ គប្បីធ្វើការប្រកួតប្រកាន់ ព្រោះមានះនោះ ព្រោះទិដ្ឋិនោះ ឬព្រោះបុគ្គលនោះថា អ្នកមិនចេះធម្មវិន័យនេះទេ ខ្ញុំចេះដឹងធម្មវិន័យនេះ អ្នកនឹងចេះធម្មវិន័យនេះ ដូចម្តេចបាន អ្នកជាបុគ្គលប្រតិបត្តិខុស ខ្ញុំប្រតិបត្តិត្រូវ ពាក្យរបស់ខ្ញុំទើបប្រកបដោយប្រយោជន៍ ពាក្យរបស់អ្នកមិនប្រកបដោយប្រយោជន៍ទេ ពាក្យដែលគេត្រូវនិយាយមុន អ្នកនិយាយក្រោយ ពាក្យដែលគេត្រូវនិយាយក្រោយ អ្នកនិយាយមុន ពាក្យដែលអ្នកសន្សំមកយូរហើយ ត្រូវយើងឲ្យវិលត្រឡប់ហើយ វាទៈរបស់អ្នក យើងលើកពោលហើយ អ្នកត្រូវយើងសង្កតសង្កិនបានហើយ

ចរ វាទប្បមោក្ខាយ និព្វេឋេហិ វា សចេ បហោសីតិ សមោ វិសេសី ឧទ វា និហីនោ យោ មញ្ញតី សោ វិវទេថ តេន ។

(៣៣) តីសុ វិធាសុ អវិកម្បមានោ សមោ វិសេសីតិ ន តស្ស ហោតីតិ យស្សេតា តិស្សោ វិធា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា សោ តីសុ វិធាសុ ន កម្បតិ ន វិកម្បតិ អវិកម្បមានស្ស បុគ្គលស្ស សទិសោហមស្មីតិ វា សេយ្យោហមស្មីតិ វា ហីនោហមស្មីតិ វា ។ ន តស្ស ហោតីតិ ន មយ្ហំ ហោតីតិ តីសុ វិធាសុ អវិកម្បមានោ សមោ វិសេសីតិ ន តស្ស ហោតិ ។ តេនាហ ភគវា

សមោ វិសេសី ឧទ វា និហីនោ
យោ មញ្ញតី សោ វិវទេថ តេន
តីសុ វិធាសុ អវិកម្បមានោ
សមោ វិសេសីតិ ន តស្ស ហោតីតិ ។

អ្នកចូរត្រាច់ទៅ ដើម្បីដោះវាទៈចុះ ឬបើអ្នកអាច អ្នកចូរដោះចុះ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលណាសំគាល់ថាស្មើ ថាប្រសើរ ឬថាថោកទាប បុគ្គលនោះ គប្បីនិយាយទទឹងទាស់ ដោយសេចក្ដីសំគាល់នោះ ។

(៣៣) ពាក្យថា បុគ្គលណា មិនញាប់ញ័រ ក្នុងមានះ ៣ យ៉ាង ការប្រកាន់ ថាស្មើ ថាប្រសើរ (ឬថាថោកទាប) មិនមានដល់បុគ្គលនោះ សេចក្ដីថា មានះទាំងឡាយបីយ៉ាងនុ៎ះ បុគ្គលណាលះបង់ ផ្ដាច់បង់ ស្ងប់រម្ងាប់ កំចាត់បង់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ រមែងមិនញាប់ញ័រ មិនរំជួលក្នុងមានះទាំង៣ កាលបើបុគ្គលមិនញាប់ញ័រហើយ (រមែងមិនមានសេចក្ដីប្រកាន់ថា) អាត្មាអញជាបុគ្គលស្មើនឹងគេដូច្នេះផង ជាបុគ្គលប្រសើរជាងគេដូច្នេះផង ជាបុគ្គលថោកទាបជាងគេដូច្នេះផង ។ ពាក្យថា មិនមានដល់បុគ្គលនោះ សេចក្ដីថា មិនមានដល់តថាគត ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលមិនញាប់ញ័រក្នុងមានះ ៣ យ៉ាង (ការប្រកាន់ថា) ស្មើ ថាប្រសើរ រមែងមិនមានដល់បុគ្គលនោះ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

បុគ្គលណា សំគាល់ថាស្មើ ថាប្រសើរ ឬថាថោកទាប បុគ្គល
នោះ គប្បីនិយាយទទឹងទាស់ ដោយសេចក្ដីសំគាល់នោះ
បុគ្គលណា មិនញាប់ញ័រក្នុងមានះ៣ គឺ ការប្រកាន់ថាសើ ថា
ប្រសើរ (ឬថាថោកទាប) មិនមានដល់បុគ្គលនោះឡើយ ។

ខរ៉ោ  មាគន្ទិយសុត្តទំរេសោ

(៣៤) សច្ចន្តិ សោ ព្រាហ្មណោ កឹ វទេយ្យ
មុសាតិ វា សោ វិវទេថ កេន
យស្មឹ សមំ វិសមំ វាបិ នត្ថិ
ស កេន វាទំ បដិសញ្ញុជេយ្យ ។

(៣៥) សច្ចន្តិ សោ ព្រាហ្មណោ កឹ វទេយ្យាតិ
ព្រាហ្មណោតិ សត្តន្នំ ធម្មានំ ពាហិតត្តា ព្រាហ្មណោ
។ បេ ។ អសិតោ តាទិ បវុច្ចតេ ស ព្រហ្មាតិ សច្ចន្តិ
សោ ព្រាហ្មណោ ។ កឹ វទេយ្យាតិ សស្សតោ លោកោ
ឥទមេវ សច្ចំ មោឃមញ្ញន្តិ ព្រាហ្មណោ កឹ វទេយ្យ
កឹ កថេយ្យ កឹ ភណេយ្យ កឹ ទីបយេយ្យ
កឹ វោហរេយ្យ ។ អសស្សតោ លោកោ ។ បេ ។

(៣៨) ព្រាហ្មណ៍នោះ គប្បីពោលថា (សេចក្ដីយល់) នេះ ត្រូវពិតដូចម្ដេចបាន ឬក៏ព្រាហ្មណ៍នោះ គប្បីពោលទទឹងទាស់ថា (ពាក្យរបស់អ្នក) ជាពាក្យកុហក ដោយប្រការដូចម្ដេចបាន សេចក្ដីសំគាល់ថាស្មើ ឬមិនស្មើ មិនមានក្នុងព្រះខីណាស្រពអង្គណា ព្រះខីណាស្រពអង្គនោះ គប្បីផ្សាយវាទៈ ដោយប្រការដូចម្ដេចបាន ។

(៣៩) អធិប្បាយពាក្យថា ព្រាហ្មណ៍នោះ គប្បីពោលថា សេចក្ដីយល់នេះ ត្រូវពិតដូចម្ដេចបាន ត្រង់ពាក្យថា ព្រាហ្មណ៍ គឺ បុគ្គលឈ្មោះថា ព្រាហ្មណ៍ ព្រោះបន្សាត់បង់ធម៌ ៧ ។ បេ ។ ជាបុគ្គល មិនអាស្រ័យ ជាតាទិបុគ្គល បុគ្គលនោះ លោកហៅថា ព្រាហ្មណ៍ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រាហ្មណ៍នោះ (គប្បីពោលថា) សេចក្ដីយល់នេះត្រូវពិត ។ ពាក្យថា គប្បីពោលដូចម្ដេចបាន សេចក្ដីថា ព្រាហ្មណ៍ គប្បីពោលដូចម្ដេច គប្បីថ្លែងដូចម្ដេច គប្បីពណ៌នាដូចម្ដេច គប្បីបំភ្លឺដូចម្ដេច គប្បីពន្យល់ដូចម្ដេចថា លោកទៀង ពាក្យនេះឯងពិត ពាក្យដទៃជាមោឃៈ ។ គប្បីពោលដូចម្ដេច គប្បីថ្លែងដូចម្ដេច គប្បីពណ៌នាដូចម្ដេច គប្បីបំភ្លឺដូចម្ដេច គប្បីពន្យល់ដូចម្ដេចថា លោកមិនទៀង ។ បេ ។

នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ព្រាហ្មណោ កឹ វទេយ្យ កឹ កថេយ្យ កឹ ភណេយ្យ កឹ ទីបយេយ្យ កឹ វោហារេយ្យាតិ សង្ខន្តិ សោ ព្រាហ្មណោ កឹ វទេយ្យ ។

[៣៦] មុសាតិ វា សោ វិវទេថ កេនាតិ ព្រាហ្មណោ មយ្ហំ វ សច្ចំ តុយ្ហំ មុសាតិ កេន មានេន កាយ ទិដ្ឋិយា កេន វា បុគ្គលេន កលហំ ករេយ្យ ភណ្ឌនំ ករេយ្យ វិគ្គហំ ករេយ្យ វិវាទំ ករេយ្យ មេធគំ ករេយ្យ ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ ។ បេ ។ និព្ពេឋេហិ វា សចេ បហោសីតិ មុសាតិ វា សោ វិវទេថ កេន ។

[៣៧] យស្មឹ សមំ វិសមំ ចាបិ នត្ថីតិ យស្មឹ អរហន្តេ ខីណាសវេ សទិសោហមស្មីតិ មានោ នត្ថិ សេយ្យោហមស្មីតិ អតិមានោ នត្ថិ ហីនោហមស្មីតិ ឱមានោ នត្ថិ ន សំវិជ្ជតិ នុបលព្ភតិ បហីនំ សមុច្ឆិន្នំ

សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះឯងពិត ពាក្យដទៃជាមោឃៈ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រាហ្មណ៍នោះ គប្បីពោលថា (សេចក្ដីយល់) នេះ ត្រូវពិត ដូចម្ដេចបាន ។

(៣៦) ពាក្យថា ព្រាហ្មណ៍នោះ គប្បីពោលទទឹងទាស់ថា (ពាក្យរបស់អ្នក) ជាពាក្យកុហក ដោយប្រការដូចម្ដេចបាន សេចក្ដីថា ព្រាហ្មណ៍ គប្បីធ្វើជម្លោះ គប្បីធ្វើការទាស់ទែង គប្បីធ្វើសេចក្ដីប្រកាន់ខុស គប្បីធ្វើវិវាទ គប្បីធ្វើសេចក្ដីប្រកួតប្រកាន់ថា អ្នកមិនចេះដឹងធម្មវិន័យនេះទេ ។ បេ ។ បើអ្នកអាច អ្នកចូរដោះចុះ ដោយមានះដូចម្ដេច ដោយទិដ្ឋិដូចម្ដេច ឬដោយបុគ្គលដូចម្ដេចថា ពាក្យរបស់ខ្ញុំពិត ពាក្យរបស់អ្នកកុហក ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រាហ្មណ៍នោះ គប្បីពោលទទឹងទាស់ថា (ពាក្យរបស់អ្នក) ជាពាក្យកុហក ដោយប្រការដូចម្ដេចបាន ។

(៣៧) ពាក្យថា សេចក្ដីសំគាល់ថាស្មើក្ដី មិនស្មើក្ដី មិនមានក្នុងព្រះខីណាស្រពអង្គណា សេចក្ដីថា ព្រះអរហន្តខីណាស្រពអង្គណា មិនមានសេចក្ដីប្រកាន់ថា អាត្មាអញជាបុគ្គលស្មើនឹងគេ មិនមានសេចក្ដីប្រកាន់ខ្ពស់ថា អាត្មាអញជាបុគ្គលប្រសើរជាងគេ មិនមាន មិនមានព្រម មិនគប្បីបាននូវសេចក្ដីប្រកាន់ទាបថា អាត្មាអញជាបុគ្គលថោកទាបជាងគេ គឺជាកិលេសជាតនោះ ព្រះខីណាស្រពលះបង់ ផ្ដាច់ផ្ដិល

នវមោ មាគន្ទិយសុត្តនិទ្ទេសោ

វូបសន្តំ បដិប្បស្សទ្ធំ អភព្វុប្បត្តិកំ ញាណគ្គិនា ទឌ្ឍំ យស្មឹ សមំ វិសមំ វាបិ នត្ថិ ។

(៣៨) ស កេន វាទំ បដិសញ្ញុជេយ្យាតិ សោ កេន មានេន កាយ ទិដ្ឋិយា កេន វា បុគ្គលេន វាទំ បដិសញ្ញុជ្ជេយ្យ បដិប្ផរេយ្យ(១) កលហំ ករេយ្យ ភណ្ឌនំ ករេយ្យ វិគ្គហំ ករេយ្យ វិវាទំ ករេយ្យ មេធគំ ករេយ្យ ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ ។បេ។ និព្ពេឋេហិ វា សចេ បហោសីតិ ស កេន វាទំ បដិសញ្ញុជេយ្យ ។ តេនាហ ភគវា

សច្ចន្តិ សោ ព្រាហ្មណោ កឹ វទេយ្យ
មុសាតិ វា សោ វិវទេថ កេន
យស្មឹ សមំ វិសមំ វាបិ នត្ថិ
ស កេន វាទំ បដិសញ្ញុជេយ្យាតិ ។

---

១ ម. បដិពលេយ្យ ។

រម្ងាប់ ស្ងប់រម្ងាប់ មិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណ ហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) សេចក្តីសំគាល់ថាស្មើក្តី មិនស្មើក្តី មិនមានក្នុងព្រះខីណាស្រពអង្គណា ។

(៣៨) ពាក្យថា ព្រះខីណាស្រពអង្គនោះ គប្បីផ្សាយវាទៈដោយប្រការដូចម្តេចបាន សេចក្តីថា ព្រះខីណាស្រពអង្គនោះ គប្បីផ្សាយ គប្បីផ្សព្វផ្សាយវាទៈ គប្បីធ្វើជម្លោះ គប្បីធ្វើសេចក្តីទាស់ទែង គប្បីធ្វើការប្រកាន់ខុស គប្បីធ្វើវិវាទ គប្បីធ្វើសេចក្តីប្រកួតប្រកាន់ថា អ្នកមិនចេះធម្មវិន័យនេះទេ ។ បេ ។ ឬបើអ្នកអាច ចូរអ្នកដោះចុះ ដោយមានះដូចម្តេច ដោយទិដ្ឋិដូចម្តេច ឬក៏ ដោយបុគ្គលដូចម្តេចបាន ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រះខីណាស្រពអង្គនោះ គប្បីផ្សាយវាទៈដោយប្រការដូចម្តេចបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ហើយថា

ព្រាហ្មណ៍នោះ គប្បីពោលថា (សេចក្តីយល់) នេះ ត្រូវពិត
ដូចម្តេចបាន ឬក៏ព្រាហ្មណ៍នោះ គប្បីពោលទទឹងទាស់
ថា (ពាក្យរបស់អ្នក ជាពាក្យកុហក ដោយប្រការដូចម្តេច
សេចក្តីសំគាល់ ថាស្មើក្តី មិនស្មើក្តី មិនមានក្នុងព្រះខីណា-
ស្រពអង្គណា ព្រះខីណាស្រពអង្គនោះ គប្បីផ្សាយវាទៈ
ដោយប្រការដូចម្តេចបាន ។

(៣៩) ឱកម្បហាយ អនិកេតសារី
កាមេ(១) អកុព្វំ មុនិ សន្ថវានិ
កាមេហិ រិត្តោ អបុរេក្ខរានោ
កថំ ន វិគ្គយ្ហ ជនេន កយិរា ។

(៤០) អថ ខោ ហាលិទ្ទកានិ គហបតិ យេនាយស្មា មហាកច្ចានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ អភិវាទេត្វា ឯកមន្តំ និសីទិ ឯកមន្តំ និសិន្នោ ខោ ហាលិទ្ទកានិ គហបតិ អាយស្មន្តំ មហាកច្ចានំ ឯតទវោច វុត្តមិទំ ភន្តេ កច្ចាន ភគវតា អដ្ឋកវគ្គិកេ មាគណ្ឌិយបញ្ហេ

ឱកម្បហាយ អនិកេតសារី
កាមេ អកុព្វំ មុនិ សន្ថវានិ
កាមេហិ រិត្តោ អបុរេក្ខរានោ
កថំ ន វិគ្គយ្ហ ជនេន កយិរាតិ

ឥមស្ស នុ ខោ ភន្តេ កច្ចាន ភគវតា សង្ខិត្តេន ភាសិតស្ស កថំ អត្ថោ ទដ្ឋព្វោតិ ។ រូបធាតុ ខោ គហបតិ វិញ្ញាណស្ស ឱកោ រូបធាតុរាគវិនិពន្ធញ្ច បន វិញ្ញាណំ ឱកសារីតិ វុច្ចតិ វេទនាធាតុ ខោ គហបតិ

១ ឱ. ម. គាមេ ។

(៣៩) អ្នកប្រាជ្ញលះបង់លំនៅ មិនមានការលើកអាល័យ ចំពោះលំនៅ មិនធ្វើសេចក្តីស្និទ្ធស្នាលក្នុងកាម ជាអ្នកទំនេរ ចាកកាមទាំងឡាយ មិនធ្វើវដ្ដៈឲ្យជាប្រធាន មិនធ្វើជំទាស់ នូវពាក្យជាមួយជនទេ ។

(៤០) គ្រានោះឯង ហាលិទ្ទកានិគហបតី បានចូលទៅរកព្រះមហាកច្ចានៈ មានអាយុ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំព្រះមហាកច្ចានៈ មានអាយុ ហើយអង្គុយនៅក្នុងទីសមគួរ លុះហាលិទ្ទកានិគហបតី អង្គុយក្នុងទីសមគួរហើយ ទើបពោលចំពោះព្រះមហាកច្ចានៈ មានអាយុ យ៉ាងនេះថា បពិត្រព្រះកច្ចានៈដ៏ចំរើន ពាក្យនេះព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ក្នុងមាគន្ទិយបញ្ហាអដ្ឋកវគ្គ ថា

អ្នកប្រាជ្ញលះបង់លំនៅ មិនមានការលើកអាល័យចំពោះលំនៅ មិនធ្វើសេចក្តីស្និទ្ធស្នាលក្នុងកាម ជាអ្នកទំនេរ ចាកកាមទាំងឡាយ មិនធ្វើវដ្ដៈឲ្យជាប្រធាន មិនធ្វើជំទាស់នូវពាក្យជាមួយជនទេ ។

បពិត្រព្រះកច្ចានៈដ៏ចំរើន សេចក្តីនៃពាក្យនេះ ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ ដោយសេចក្តីសង្ខេប តើលោកម្ចាស់យល់ឃើញ ដោយសេចក្តីពិស្តារ ដោយប្រការដូចម្តេចហ្ន៎ ។ ម្នាលគហបតី រូបធាតុជាលំនៅរបស់វិញ្ញាណ ឯវិញ្ញាណដែលមានកិរិយាជាប់ទាក់ទង ដោយរាគៈក្នុងរូបធាតុ ហៅថា លើកអាល័យលំនៅ ម្នាលគហបតី វេទនាធាតុ

សញ្ញាធាតុ ខោ គហបតិ សង្ខារធាតុ ខោ គហបតិ វិញ្ញាណស្ស ឱកោ សង្ខារធាតុរាគវិនិពន្ធញ្ច បន វិញ្ញាណំ ឱកសារីតិ វុច្ចតិ ឯវំ ខោ គហបតិ ឱកសារី ហោតិ ។ កថញ្ច គហបតិ អនោកសារី ហោតិ ។ រូបធាតុយា ខោ គហបតិ យោ ឆន្ទោ យោ រាគោ យា នន្ទី យា តណ្ហា យេ ឧបាយុបាទានា ចេតសោ អធិដ្ឋានាភិនិវេសានុសយា តេ តថាគតស្ស បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា តស្មា តថាគតោ អនោកសារីតិ វុច្ចតិ ។ វេទនាធាតុយា ខោ គហបតិ សញ្ញាធាតុយា ខោ គហបតិ សង្ខារធាតុយា ខោ គហបតិ វិញ្ញាណធាតុយា ខោ គហបតិ យោ ឆន្ទោ យោ រាគោ យា នន្ទី យា តណ្ហា យេ ឧបាយុបាទានា ចេតសោ អធិដ្ឋានាភិនិវេសានុសយា តេ តថាគតស្ស បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា តស្មា តថាគតោ អនោកសារីតិ វុច្ចតិ ឯវំ ខោ គហបតិ អនោកសារី ហោតិ ។

## មាគន្ទិយសុត្តនិទ្ទេស ទី ៩

ម្នាលគហបតី សញ្ញាធាតុ ម្នាលគហបតី សង្ខារធាតុ សឹងជាលំនៅរបស់វិញ្ញាណ ឯវិញ្ញាណដែលមានកិរិយាជាប់ទាក់ទង ដោយរាគៈ ក្នុងសង្ខារធាតុ ហៅថា ការលើកអាល័យលំនៅ ម្នាលគហបតី វិញ្ញាណនឹកអាល័យទីលំនៅយ៉ាងនេះឯង ។ ម្នាលគហបតី ព្រះតថាគត មិនមានការលើកអាល័យលំនៅ តើដូចម្តេច ។ ម្នាលគហបតី បំណង់ តម្រេក សេចក្តីរីករាយ សេចក្តីប្រាថ្នា ឧបាយនឹងឧបាទាន ការតាំងស៊ប់ សេចក្តីប្រកាន់មាំ នឹងការដេកត្រាំនៅនៃចិត្ត ណា ក្នុងរូបធាតុ កិលេសទាំងនោះ ព្រះតថាគត លះបង់ ផ្តាច់ផ្តិលឫសគល់ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមាន ជាធម៌មិនមានការកើតតទៅទៀត ហេតុនោះ ព្រះតថាគតគេហៅថា មិនមានវិញ្ញាណលើកអាល័យលំនៅ ។ ម្នាលគហបតី ចំណង់ តម្រេក សេចក្តីរីករាយ សេចក្តីប្រាថ្នា ឧបាយនឹងឧបាទាន ការតាំងស៊ប់ សេចក្តីប្រកាន់មាំ នឹងការដេកត្រាំនៅនៃចិត្តណា ក្នុងវេទនាធាតុ ម្នាលគហបតី ក្នុងសញ្ញាធាតុ ម្នាលគហបតី ក្នុងសង្ខារធាតុ ម្នាលគហបតី ក្នុងវិញ្ញាណធាតុ កិលេសទាំងនោះ ព្រះតថាគត លះបង់ ផ្តាច់ផ្តិលឫសគល់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមាន ជាធម៌មិនមានការកើតតទៅទៀត ហេតុនោះ ព្រះតថាគតគេហៅថា មិនមានវិញ្ញាណលើកអាល័យលំនៅ ម្នាលគហបតីព្រះតថាគត គេហៅថា មិនមានវិញ្ញាណលើកអាល័យលំនៅយ៉ាងនេះឯង ។

កថញ្ច គហបតិ និកេតសារី ហោតិ ។ រូបនិមិ-
ត្តនិកេតសារវិនិពន្ធំ ខោ គហបតិ និកេតសារីតិ
វុច្ចតិ ។ សទ្ទនិមិត្តគន្ធនិមិត្តរសនិមិត្តផោដ្ឋព្វនិមិត្ត-
ធម្មនិមិត្តនិកេតសារវិនិពន្ធំ ខោ គហបតិ និកេត-
សារីតិ វុច្ចតិ ឯវំ ខោ គហបតិ និកេតសារី ហោតិ ។
កថញ្ច គហបតិ អនិកេតសារី ហោតិ ។ រូបនិមិត្ត-
និកេតសារវិនិពន្ធា ខោ គហបតិ តថាគតស្ស បហីនា
ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ
អនុប្បាទធម្មា តស្មា តថាគតោ អនិកេតសារីតិ
វុច្ចតិ ។ សទ្ទនិមិត្តគន្ធនិមិត្តរសនិមិត្តផោដ្ឋព្វនិមិត្តធម្ម-
និមិត្តនិកេតសារវិនិពន្ធា ខោ គហបតិ តថាគតស្ស
បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ
អនុប្បាទធម្មា តស្មា តថាគតោ អនិកេតសារីតិ
វុច្ចតិ ឯវំ ខោ គហបតិ អនិកេតសារី ហោតិ ។

ម្នាលគហបតី វិញ្ញាណរលឹកអាល័យលំនៅ តើដូចម្តេច ។ ម្នាលគហបតី វិញ្ញាណមានការរលឹកអាល័យនឹងការជាប់ចំពាក់ ក្នុងរូបដែលជានិមិត្តជាទីរលឹកអាល័យ លោកពោលថា ការរលឹកអាល័យលំនៅ ។ ម្នាលគហបតី វិញ្ញាណមានការរលឹកអាល័យ និងការជាប់ចំពាក់ ក្នុងសំឡេងដែលជានិមិត្ត ក្លិនដែលនិមិត្ត រសដែលជានិមិត្ត ផោដ្ឋព្វៈដែលជានិមិត្ត ធម្មារម្មណ៍ដែលជានិមិត្ត ជាលំនៅ លោកពោលថា ការរលឹកអាល័យលំនៅ ម្នាលគហបតី វិញ្ញាណមានការរលឹកអាល័យលំនៅ យ៉ាងនេះឯង ។ ម្នាលគហបតី ព្រះតថាគត មិនមានការរលឹកអាល័យលំនៅ តើដូចម្តេច ។ ម្នាលគហបតី ការរលឹកនឹងការជាប់ចំពាក់ ក្នុងរូបដែលជានិមិត្តជាលំនៅ ព្រះតថាគតលះបង់ ផ្តាច់ផ្តិលឫសគល់ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមាន ជាធម៌មិនមានការកើតតទៅទៀត ហេតុនោះ ព្រះតថាគតគេហៅថា មិនមានការរលឹកអាល័យលំនៅ ។ ម្នាលគហបតី ការរលឹកនឹងការជាប់ចំពាក់ ក្នុងសំឡេងដែលជានិមិត្ត ក្លិនជានិមិត្ត រសជានិមិត្ត ផោដ្ឋព្វៈជានិមិត្ត ធម្មារម្មណ៍ជានិមិត្ត ព្រះតថាគតលះបង់ ផ្តាច់ផ្តិលឫសគល់ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមាន ជាធម៌មិនមានការកើតតទៅទៀត ហេតុនោះ ព្រះតថាគតគេហៅថា មិនមានការរលឹកអាល័យលំនៅ ម្នាលគហបតី ព្រះតថាគត មិនមានការរលឹកអាល័យលំនៅ យ៉ាងនេះឯង ។

## នវមោ មាគណ្ឌិយសុត្តនិទ្ទេសោ

កថញ្ច គហបតិ កាមេ សន្ថុតោ ហោតិ ។ ឥធ គហបតិ ឯកច្ចោ គិហីហិ(១) សំសដ្ឋោ វិហរតិ សហនន្ទី សហសោកី សុខិតេសុ សុខិតោ ទុក្ខិតេសុ ទុក្ខិតោ ឧប្បន្នេសុ កិច្ចករណីយេសុ អត្តនា វោយោគំ អាបជ្ជតិ ឯវំ ខោ គហបតិ កាមេ សន្ថុតោ ហោតិ ។ កថញ្ច គហបតិ កាមេ ន សន្ថុតោ ហោតិ ។ ឥធ គហបតិ ភិក្ខុ គិហីហិ អសំសដ្ឋោ វិហរតិ ន សហនន្ទី ន សហសោកី ន សុខិតេសុ សុខិតោ ន ទុក្ខិតេសុ ទុក្ខិតោ ឧប្បន្នេសុ កិច្ចករណីយេសុ ន អត្តនា វោយោគំ អាបជ្ជតិ ឯវំ ខោ គហបតិ កាមេ ន សន្ថុតោ ហោតិ ។ កថញ្ច គហបតិ កាមេហិ អរិត្តោ ហោតិ ។ ឥធ គហបតិ ឯកច្ចោ កាមេសុ អវីតរាគោ ហោតិ អវីតច្ឆន្ទោ អវីតបេមោ អវីតបិបាសោ អវីតបរិឡាហោ អវីតតណ្ហោ ឯវំ ខោ គហបតិ កាមេហិ អរិត្តោ ហោតិ ។

---

១ ម. ឯកច្ចោ ភិក្ខុ គិហីហិ ។

## មាគន្ទិយសុត្តនិទ្ទេស ទី ៩

ម្នាលគហបតី បុគ្គលជាអ្នកស្និទ្ធស្នាលក្នុងកាម តើដូចម្តេច ។ ម្នាលគហបតី ភិក្ខុខ្លះក្នុងសាសនានេះ ជាអ្នកប្រឡូកប្រឡំ ដោយគ្រហស្ថទាំងឡាយ មានសេចក្តីរីករាយជាមួយ មានសោកជាមួយ កាលបើគ្រហស្ថទាំងឡាយដល់នូវសុខ ក៏ដល់នូវសុខ កាលបើគ្រហស្ថទាំងឡាយដល់នូវទុក្ខ ក៏ដល់នូវទុក្ខ កាលបើកិច្ចការដែលគ្រហស្ថទាំងឡាយ គប្បីធ្វើកើតឡើងហើយ ក៏ដល់នូវការចូលទៅប្រកប (ជួយ) ដោយខ្លួនឯង ម្នាលគហបតី ភិក្ខុជាអ្នកស្និទ្ធស្នាលក្នុងកាម យ៉ាងនេះឯង ។ ម្នាលគហបតី ភិក្ខុជាអ្នកមិនស្និទ្ធស្នាលក្នុងកាម តើដូចម្តេច ។ ម្នាលគហបតី ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនប្រឡូកប្រឡំដោយគ្រហស្ថទាំងឡាយ មិនរីករាយជាមួយ មិនមានសោកជាមួយ មិនដល់នូវសុខជាមួយនឹងគ្រហស្ថដែលដល់នូវសុខ មិនដល់នូវទុក្ខជាមួយនឹងគ្រហស្ថដែលដល់នូវទុក្ខ កាលបើកិច្ចការដែលគ្រហស្ថគប្បីធ្វើកើតឡើងហើយ ក៏មិនដល់នូវការចូលទៅប្រកបដោយខ្លួនឯងឡើយ ម្នាលគហបតី ភិក្ខុជាអ្នកមិនស្និទ្ធស្នាលក្នុងកាមទាំងឡាយ យ៉ាងនេះឯង ។ ម្នាលគហបតី ភិក្ខុមិនទំនេរចាកកាមទាំងឡាយ តើដូចម្តេច ។ ម្នាលគហបតី ភិក្ខុពួកខ្លះក្នុងសាសនានេះ ជាអ្នកមិនប្រាសចាករាគៈ មិនប្រាសចាកឆន្ទៈ មិនប្រាសចាកសេចក្តីស្រឡាញ់ មិនប្រាសចាកសេចក្តីស្រេកឃ្លាន មិនប្រាចាកសេចក្តីអន្ទះអន្ទែង មិនប្រាសចាកសេចក្តីប្រាថ្នាក្នុងកាមទាំងឡាយ ម្នាលគហបតី ភិក្ខុមិនទំនេរចាកកាមទាំងឡាយយ៉ាងនេះឯង ។

កតញ្ច គហបតិ កាមេហិ រិត្តោ ហោតិ ។ ឥធ គហបតិ ភិក្ខុ កាមេសុ វីតរាគោ ហោតិ វីតច្ឆន្ទោ វីតបេមោ វីតបិបាសោ វីតបរិឡាហោ វីតតណ្ហោ ឯវំ ខោ គហបតិ កាមេហិ រិត្តោ ហោតិ ។ កតញ្ច គហបតិ បុរេក្ខរានោ ហោតិ ។ ឥធ គហបតិ ឯកច្ចស្ស ឯវំ ហោតិ ឯវំរូបោ សិយំ អនាគតមទ្ធានន្តិ តត្ថ នន្ទឹ សមន្វានេតិ(១) ឯវំវេទនោ សិយំ ឯវំសញ្ញោ សិយំ ឯវំសង្ខារោ សិយំ ឯវំវិញ្ញាណោ សិយំ អនាគតមទ្ធានន្តិ តត្ថ នន្ទឹ សមន្វានេតិ ឯវំ ខោ គហបតិ បុរេក្ខរានោ ហោតិ ។ កតញ្ច គហបតិ អបុរេក្ខរានោ ហោតិ ។ ឥធ គហបតិ ភិក្ខុនោ ន ឯវំ ហោតិ(២) ឯវំរូបោ សិយំ អនាគតមទ្ធានន្តិ តត្ថ នន្ទឹ ន សមន្វានេតិ ឯវំវេទនោ សិយំ ឯវំសញ្ញោ សិយំ

---

១ ម. សមន្នានេតិ ។ ២ ឱ. ឥធ គហបតិ ឯកច្ចស្ស ឯវំ ហោតិ ។

ម្នាលគហបតី ភិក្ខុជាអ្នកទំនេរចាកកាមទាំងឡាយ តើដូចម្ដេច ។ ម្នាលគហបតី ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកប្រាសចាករាគៈ ប្រាសចាកឆន្ទៈ ប្រាសចាកសេចក្ដីស្រឡាញ់ ប្រាសចាកសេចក្ដីស្រេកឃ្លាន ប្រាសចាកសេចក្ដីអន្ទះអន្ទែង ប្រាសចាកសេចក្ដីប្រាថ្នា ក្នុងកាមទាំងឡាយ ម្នាលគហបតី ភិក្ខុជាអ្នកទំនេរចាកកាមទាំងឡាយ យ៉ាងនេះឯង ។ ម្នាលគហបតី ភិក្ខុអ្នកធ្វើវដ្ដៈឲ្យជាប្រធាន តើដូចម្ដេច ។ ម្នាលគហបតី ភិក្ខុពួកខ្លះក្នុងសាសនានេះ មានសេចក្ដីប្រាថ្នាយ៉ាងនេះ ថាអាត្មាអញសូមឲ្យមានរូបយ៉ាងនេះ ក្នុងអនាគតកាល ទើបញ៉ាំងសេចក្ដីរីករាយឲ្យប្រព្រឹត្តទៅរឿយ ៗ ក្នុងរូបនោះ អាត្មាអញសូមឲ្យមានវេទនាយ៉ាងនេះ សូមឲ្យមានសញ្ញាយ៉ាងនេះ សូមឲ្យមានសង្ខារយ៉ាងនេះ សូមឲ្យមានវិញ្ញាណយ៉ាងនេះ ក្នុងអនាគតកាល ទើបញ៉ាំងសេចក្ដីរីករាយឲ្យប្រព្រឹត្តទៅរឿយ ៗ ក្នុងខន្ធមានវេទនាជាដើមនោះ ម្នាលគហបតី ភិក្ខុអ្នកធ្វើវដ្ដៈឲ្យជាប្រធានយ៉ាងនេះឯង ។ ម្នាលគហបតី បុគ្គលអ្នកមិនធ្វើវដ្ដៈឲ្យជាប្រធាន តើដូចម្ដេច ។ ម្នាលគហបតី ភិក្ខុក្នុងធម្មវិន័យនេះ មិនមានសេចក្ដីប្រាថ្នាយ៉ាងនេះថា អាត្មាអញ សូមឲ្យមានរូបយ៉ាងនេះ ក្នុងអនាគតកាល ទាំងមិនញ៉ាំងសេចក្ដីរីករាយឲ្យប្រព្រឹត្តទៅរឿយ ៗ ក្នុងរូបនោះ (មិនមានសេចក្ដីប្រាថ្នាយ៉ាងនេះថា) អាត្មាអញសូមឲ្យមានវេទនាយ៉ាងនេះ សូមឲ្យមានសញ្ញាយ៉ាងនេះ

## នវមោ មាគន្ទិយសុត្តនិទ្ទេសោ

ឯវំសង្ខារោ សិយំ ឯវំវិញ្ញាណោ សិយំ អនាគតមទ្ធានន្តិ តត្ថ នន្ទឹ ន សមន្វានេតិ ឯវំ ខោ គហបតិ អបុរេក្ខរានោ ហោតិ ។ កថញ្ច គហបតិ កថំ វិគ្គយ្ហ ជនេន កត្តា ហោតិ ។ ឥធ គហបតិ ឯកច្ចោ ឯវរូបឹ កថំ កត្តា ហោតិ ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ ។ បេ ។ និព្វេឋេហិ វា សចេ បហោសីតិ ឯវំ ខោ គហបតិ កថំ វិគ្គយ្ហ ជនេន កត្តា ហោតិ ។ កថញ្ច គហបតិ កថំ ន វិគ្គយ្ហ ជនេន កត្តា ហោតិ ។ ឥធ គហបតិ ភិក្ខុ ន ឯវរូបឹ កថំ កត្តា ហោតិ ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ ។ បេ ។ និព្វេឋេហិ វា សចេ បហោសីតិ ឯវំ ខោ គហបតិ កថំ ន វិគ្គយ្ហ ជនេន កត្តា ហោតិ ។ ឥតិ ខោ គហបតិ យន្តំ វុត្តំ ភគវតា អដ្ឋកវគ្គិកេ មាគន្ទិយប្បញ្ហេ ។

ឱកម្បហាយ អនិកេតសារី
គាមេ អកុព្វំ មុនិ សន្ថវានិ
កាមេហិ រិត្តោ អបុរេក្ខរានោ
កថំ ន វិគ្គយ្ហ ជនេន កយិរាតិ ។

## មាគន្ទិយសុត្តនិទ្ទេស ទី ៩

សូមឲ្យមានសង្ខារយ៉ាងនេះ សូមឲ្យមានវិញ្ញាណយ៉ាងនេះ ក្នុងអនាគតកាល ទាំងមិនញុំាងសេចក្ដីរីករាយ ឲ្យប្រព្រឹត្តទៅរឿយ ៗ ក្នុងខន្ធមានវេទនាជាដើមនោះ ម្នាលគហបតី ភិក្ខុជាអ្នកមិនធ្វើវដ្ដៈឲ្យជាប្រធានយ៉ាងនេះឯង ។ ម្នាលគហបតី ភិក្ខុជាអ្នកធ្វើជំទាស់ នូវពាក្យដោយជន តើដូចម្ដេច ។ ម្នាលគហបតី ភិក្ខុពួកខ្លះក្នុងសាសនានេះ ជាអ្នកធ្វើពាក្យមានសភាពយ៉ាងនេះថា អ្នកមិនយល់ធម្មវិន័យនេះទេ ។ បេ ។ ឬប្រសិនបើអ្នកអាច អ្នកចូរដោះចុះ ម្នាលគហបតី ភិក្ខុជាអ្នកធ្វើជំទាស់នូវពាក្យដោយជន យ៉ាងនេះឯង ។ ម្នាលគហបតី ភិក្ខុអ្នកមិនធ្វើទទឹងទាស់នូវពាក្យដោយជន តើដូចម្ដេច ។ ម្នាលគហបតី ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកមិនធ្វើពាក្យ មានសភាពយ៉ាងនេះថា អ្នកមិនយល់ធម្មវិន័យនេះទេ ។ បេ ។ ឬបើអ្នកអាច អ្នកចូរដោះចុះ ម្នាលគហបតី ភិក្ខុអ្នកមិនធ្វើទទឹងទាស់នូវពាក្យដោយជន យ៉ាងនេះឯង ។ ម្នាលគហបតី ពាក្យដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ទុក ក្នុងមាគន្ទិយបញ្ហា ក្នុងអដ្ឋកវគ្គិកៈ យ៉ាងនេះឯង ។

អ្នកប្រាជ្ញលះបង់លំនៅ មិនមានការរលឹកអាល័យ ចំពោះ
លំនៅ មិនធ្វើសេចក្ដីស្និទ្ធស្នាលក្នុងកាម ជាអ្នកទំនេរចាក
កាមទាំងឡាយ មិនធ្វើវដ្ដៈឲ្យជាប្រធាន មិនគប្បីធ្វើជំទាស់
នូវពាក្យដោយជនទេ ។

ឥមស្ស ខោ គហបតិ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថោ ទដ្ឋព្វោ ។ តេនាហ ភគវា

ឱកំ បហាយ អនិកេតសារី
គាមេ អកុព្វំ មុនិ សន្ថវានិ
កាមេហិ រិត្តោ អបុរេក្ខរានោ
កថំ ន វិគ្គយ្ហ ជនេន កយិរាតិ ។

(៤១) យេហិ វិវិត្តោ វិចរេយ្យ លោកេ
ន តានិ ឧគ្គយ្ហ វទេយ្យ នាគោ
ឯលម្ពុជំ កណ្ដកវារិជំ យថា
ជលេន បង្កេន ច នូបលិត្តំ
ឯវំ មុនី សន្តិវាទោ អគិទ្ធោ
កាមេ ច លោកេ ច អនូបលិត្តោ ។

(៤២) យេហិ វិវិត្តោ វិចរេយ្យ លោកេតិ យេហីតិ ទិដ្ឋិគតេហិ ។ វិវិត្តោតិ កាយទុច្ចរិតេន រិត្តោ វិវិត្តោ បវិវិត្តោ វចីទុច្ចរិតេន មនោទុច្ចរិតេន រាគេន ។ បេ ។ សព្វាកុសលាភិសង្ខារេហិ រិត្តោ វិវិត្តោ បវិវិត្តោ ។ វិចរេយ្យាតិ ចរេយ្យ វិហរេយ្យ ឥរិយេយ្យ វត្តេយ្យ បាលេយ្យ យបេយ្យ យាបេយ្យ ។

ម្នាលគហបតី សេចក្តីនៃពាក្យនេះឯង ដែលព្រះមានព្រះភាគ ត្រាស់ហើយ ដោយសង្ខេប អ្នកគប្បីយល់ ដោយសេចក្តីពិស្តារយ៉ាងនេះចុះ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ហើយថា

អ្នកប្រាជ្ញលះបង់លំនៅ មិនមានការលើកអាល័យ ចំពោះ
លំនៅ មិនធ្វើសេចក្តីស្និទ្ធស្នាល ក្នុងកាម ជាអ្នកទំនេរ
ចាកកាមទាំងឡាយ មិនធ្វើវេដ្ដៈឲ្យជាប្រធាន មិនគប្បីធ្វើ
ជំទាស់នូវពាក្យដោយជនទេ ។

(៤១) នាគស្ងាត់ចាកធម៌ទាំងឡាយណា ប្រព្រឹត្តទៅក្នុងលោក
មិនគប្បីពោលប្រកាន់ទិដ្ឋិទាំងនោះទេ ឈូកជាត កណ្តកវារិ-
ជាត មិនប្រឡាក់ដោយទឹកផង ដោយភក់ផង យ៉ាង
ណាមិញ មុនិជាអ្នកពោលនូវសេចក្តីស្ងប់ មិនប្រាថ្នា មិន
ប្រឡាក់ ក្នុងកាមផង ក្នុងលោកផង ក៏យ៉ាងនោះឯង ។

(៤២) ពាក្យថា នាគស្ងាត់ចាកធម៌ទាំងឡាយណា ប្រព្រឹត្តទៅក្នុងលោក ត្រង់ពាក្យថា ចាកធម៌ទាំងឡាយណា គឺចាកទិដ្ឋិទាំងឡាយ ។ ពាក្យថា ស្ងាត់ គឺស្ងាត់ ស្ងាត់វិសេស ស្ងាត់ដោយប្រការ ចាកកាយទុច្ចរិត ចាកវចីទុច្ចរិត ចាកមនោទុច្ចរិត ចាករាគៈ ។ បេ ។ ស្ងាត់ ស្ងាត់វិសេស ស្ងាត់ដោយប្រការ ចាកអភិសង្ខារ ជាអកុសលទាំងពួង ។ ពាក្យថា ប្រព្រឹត្តទៅ គឺ ត្រាច់ នៅ ទៅ ប្រព្រឹត្ត រក្សា ប្រព្រឹត្តទៅ ឲ្យប្រព្រឹត្តទៅ ។

នវមោ មាគន្ធិយសុត្តនិទ្ទេសោ

លោកេតិ មនុស្សលោកេតិ យេហិ វិវិត្តោ វិចរេយ្យ លោកេ ។

(៤៣) ន តានិ ឧគ្គយ្ហ វទេយ្យ នាគោតិ នាគោតិ អាគុំ ន ករោតីតិ នាគោ ។ ន គច្ឆតីតិ នាគោ ។ នាគច្ឆតីតិ នាគោ ។ កថំ អាគុំ ន ករោតីតិ នាគោ ។ អាគុ វុច្ចតិ បាបកា អកុសលា ធម្មា សង្កិលេសិកា បោនោព្ភវិកា សទរា ទុក្ខវិបាកា អាយតឹ ជាតិជរាមរណីយា ។

អាគុំ ន ករោតិ កិញ្ចិ លោកេ
(សភិយាតិ ភគវា)
សព្វសំយោគេ វិសជ្ជ ពន្ធនានិ
សព្វត្ថ ន សជ្ជតិ វិមុត្តោ
នាគោ តាទិ វុច្ចតេ តថត្តាតិ

ឯវំ អាគុំ ន ករោតីតិ នាគោ ។

កថំ ន គច្ឆតីតិ នាគោ ។ ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយាគតឹ គច្ឆតិ

ពាក្យថា ក្នុងលោក បានដល់មនុស្សលោក ហេតុនោះ ទ្រង់ត្រាស់ថា ស្វាត់ចាកធម៌ទាំងឡាយណា ប្រព្រឹត្តទៅក្នុងលោក ។

(៤៣) អធិប្បាយពាក្យថា នាគមិនគប្បីពោលប្រកាន់នូវទិដ្ឋិទាំងនោះទេ ត្រង់ពាក្យថា នាគ សេចក្ដីថា ឈ្មោះថា នាគ ព្រោះហេតុមិនធ្វើបាប ១ ឈ្មោះថានាគ ព្រោះមិនលុះ ១ ឈ្មោះថានាគ ព្រោះមិនមក ១ ចុះឈ្មោះថា នាគ ព្រោះមិនធ្វើបាប តើដូចម្ដេច ។ អកុសលធម៌ទាំងឡាយដ៏លាមក មានសេចក្ដីសៅហ្មងព្រម មានកិរិយាញ៉ាំងសត្វឲ្យកើតក្នុងភពទៀត ប្រកបដោយសេចក្ដីក្រវល់ក្រវាយ មានសេចក្ដីទុក្ខជាផលជាបច្ច័យនៃជាតិ ជរា និងមរណៈ ទៅក្នុងអនាគត លោកហៅថា បាប ។

(ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសភិយៈ)

បុគ្គលមិនធ្វើបាបតិចតួច ក្នុងលោក ស្រាយនូវចំណងទាំង
ឡាយ ក្នុងកិលេសជាគ្រឿងប្រកបទាំងពួង មិនជាប់នៅ
ក្នុងកិលេសទាំងពួង ជាបុគ្គលផុតស្រឡះហើយ ហេតុនោះ
លោកហៅថា នាគ ជាតាទិបុគ្គល មានខ្លួនដ៏ទៀង

បុគ្គលឈ្មោះថា នាគ ព្រោះមិនធ្វើបាប យ៉ាងនេះឯង ។

ចុះបុគ្គលឈ្មោះថា នាគ ព្រោះមិនលុះ តើដូចម្ដេច ។ បុគ្គលមិនលុះឆន្ទាគតិ មិនលុះទោសាគតិ មិនលុះមោហាគតិ មិនលុះភយាគតិ

ន រាគវសេន គច្ឆតិ ន ទោសវសេន គច្ឆតិ ន មោហវសេន គច្ឆតិ ន មានវសេន គច្ឆតិ ន ទិដ្ឋិវសេន គច្ឆតិ ន ឧទ្ធច្ចវសេន គច្ឆតិ ន វិចិកិច្ឆាវសេន គច្ឆតិ ន អនុសយវសេន គច្ឆតិ ន វគ្គេហិ ធម្មេហិ យាយតិ និយ្យតិ វុយ្ហតិ សំហរិយតិ ឯវំ ន គច្ឆតិ ជាតោ ។

កថំ នាគច្ឆតិ ជាតោ ។ សោតាបត្តិមគ្គេន យេ កិលេសា បហីនា តេ កិលេសេ ន បុនេតិ ន បច្ចេតិ ន បច្ចាគច្ឆតិ សកទាគាមិមគ្គេន អនាគាមិមគ្គេន អរហត្តមគ្គេន យេ កិលេសា បហីនា តេ កិលេសេ ន បុនេតិ ន បច្ចេតិ ន បច្ចាគច្ឆតិ ឯវំ នាគច្ឆតិ ជាតោ ។ ន តានិ ឧគ្គយ្ហ ភជេយ្យ ជាតោតិ ជាតោ ន តានិ ទិដ្ឋិគតានិ គហេត្វា ឧគ្គហេត្វា គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វា ភជេយ្យ សជេយ្យ គណ្ហេយ្យ ទីបយេយ្យ វោហរេយ្យ សស្សតោ លោកោ អសស្សតោ លោកោ

មិនលុះដោយអំណាចរាគៈ មិនលុះដោយអំណាចទោសៈ មិនលុះដោយអំណាចមោហៈ មិនលុះដោយអំណាចមានះ មិនលុះដោយអំណាចទិដ្ឋិ មិនលុះដោយអំណាចឧទ្ធច្ចៈ មិនលុះដោយអំណាចវិចិកិច្ឆា មិនលុះដោយអំណាចអនុស័យ មិនប្រព្រឹត្តទៅ មិននាំទៅ មិនរសាត់ទៅ មិននាំទៅព្រម ដោយធម៌ទាំងឡាយជាពួក បុគ្គលឈ្មោះថា នាគ ព្រោះមិនលុះ យ៉ាងនេះឯង ។

ចុះបុគ្គលឈ្មោះថា នាគ ព្រោះមិនមក តើដូចម្តេច ។ កិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយសោតាបត្តិមគ្គ លោកមិនមក គឺមិនវិលមក មិនត្រឡប់មក កាន់កិលេសទាំងឡាយនោះទៀតទេ កិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយសកទាគាមិមគ្គ ដោយអនាគាមិមគ្គ ដោយអរហត្តមគ្គ លោកមិនមក គឺមិនវិលមក មិនត្រឡប់មកកាន់កិលេសទាំងឡាយនោះទៀតទេ បុគ្គលឈ្មោះថា នាគ ព្រោះមិនមក យ៉ាងនេះ ។ ពាក្យថា នាគមិនគប្បីពោលប្រកាន់នូវទិដ្ឋិទាំងនោះទេ បានសេចក្តីថា នាគគប្បីមិនកាន់យក មិនប្រកាន់យក មិនទទួលយក មិនបោសអង្អែល មិនជាប់ចិត្ត ហើយពោល ថ្លែង ពណ៌នា បំភ្លឺ ពន្យល់នូវទិដ្ឋិទាំងឡាយនោះទេ គឺមិនគប្បីពោល ថ្លែង ពណ៌នា បំភ្លឺ ពន្យល់ថា លោកទៀង លោកមិនទៀង

## នវមោ មាគន្ទិយសុត្តនិទ្ទេសោ

។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ វទេយ្យ កថេយ្យ ភណេយ្យ ទីបេយ្យ វោហរេយ្យាតិ ន តានិ ឧគ្គយ្ហ វទេយ្យ នាគោ ។

(៤៤) ឯលម្ពុជំ កណ្ដកវារិជំ យថា ជលេន បង្កេន ច នូបលិត្តន្តិ ឯលំ វុច្ចតិ ឧទកំ ។ អម្ពុ វុច្ចតិ ឧទកំ ។ អម្ពុជំ វុច្ចតិ បទុមំ ។ កណ្ដកោ វុច្ចតិ ខរទណ្ឌោ ។ វារិ វុច្ចតិ ឧទកំ ។ វារិជំ វុច្ចតិ បទុមំ វារិជំ វារិសម្ភវំ ។ ជលំ វុច្ចតិ ឧទកំ ។ បង្កោ វុច្ចតិ កទ្ទមោ ។ យថា បទុមំ វារិជំ វារិសម្ភវំ ជលេន ច បង្កេន ច ន លិម្បតិ ន សំលិម្បតិ នូបលិម្បតិ អលិត្តំ អសំលិត្តំ អនូបលិត្តន្តិ ឯលម្ពុជំ កណ្ដកវារិជំ យថា ជលេន បង្កេន ច នូបលិត្តំ ។

(៤៥) ឯវំ មុនី សន្តិវាទោ អគិទ្ធោ កាមេ ច លោកេ ច អនូបលិត្តោតិ ឯវន្តិ ឱបម្មសម្បដិបា-ទនា[1] ។ មុនីតិ មោនំ វុច្ចតិ ញាណំ ។បេ។ សង្គជាលមតិច្ច សោ មុនិ ។ សន្តិវាទោតិ

---

១ ម ឱបម្មសំបដិបាទនំ ។

## មាគន្ទិយសុត្តនិទ្ទេស ទី ៩

។ បេ ។ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះឯងពិត ពាក្យដទៃជាមោឃៈ ហេតុនោះ ( ទ្រង់ត្រាស់ថា ) នាគមិនគប្បីពោលប្រកាន់នូវទិដ្ឋិទាំងនោះទេ ។

(៤៤) ពាក្យថា ឯលម្ពុជាត កណ្ដកវារិជាត មិនប្រឡាក់ដោយទឹកផង ដោយភក់ផង យ៉ាងណាមិញ អធិប្បាយថា ទឹក លោកហៅថា ឯលៈ ។ ទឹក ហៅថា អម្ពុ ។ ឈូកហៅថា អម្ពុជាត ។ បន្ទា ហៅថា កណ្ដកៈ ។ ទឹក ហៅថា វារិ ។ ឈូកកើតក្នុងវារិ មានវារិជាដែនកើត ហៅថា វារិជាត ។ ទឹក ហៅថា ជលៈ ។ ភក់ ហៅថា បង្កៈ ។ ឈូកកើតក្នុងវារិ មានវារិជាដែនកើត មិនប្រឡាក់ មិនជាប់ មិនទទឹក មិនប្រឡាក់ មិនជាប់ មិនទទឹកហើយ ដោយទឹកផង ដោយភក់ផង យ៉ាងណាមិញ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ឯលម្ពុជាត កណ្ដកវារិជាត មិនប្រឡាក់ដោយទឹកផង ដោយភក់ផង យ៉ាងណាមិញ ។

(៤៥) អធិប្បាយពាក្យថា មុនិជាអ្នកពោលនូវសេចក្ដីស្ងប់ មិនប្រាថ្នា មិនប្រឡាក់ក្នុងកាមផង ក្នុងលោកផង យ៉ាងនោះឯង ត្រង់ពាក្យថា យ៉ាងនោះ ជាពាក្យញុំាងឧបមាឲ្យសម្រេច ។ ពាក្យថា មុនិ សេចក្ដីថា ញាណ ហៅថា មោនៈ ។ បេ ។ មុនិនោះ កន្លងហើយនូវបណ្ដាញជាគ្រឿងជាប់ចំពាក់ ។ ពាក្យថា ពោលនូវសេចក្ដីស្ងប់ សេចក្ដីថា

សន្តិវាទោ មុនិ តាណវាទោ លេណវាទោ សរណវាទោ អភយវាទោ អច្ចុតវាទោ អមតវាទោ និព្វានវាទោតិ ឯវំ មុនី សន្តិវាទោ ។ អគិទ្ធោតិ គេធោ វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ យស្សេសោ គេធោ បហីនោ សមុច្ឆិន្នោ វូបសន្តោ បដិប្បស្សទ្ធោ អភព្វុប្បត្តិកោ ញាណគ្គិនា ទឌ្ឍោ សោ វុច្ចតិ អគិទ្ធោ ។ សោ រូបេ អគិទ្ធោ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ កុលេ គណេ អាវាសេ លាភេ យសេ បសំសាយ សុខេ ចីវរេ បិណ្ឌបាតេ សេនាសនេ គិលានប្បច្ចយភេសជ្ជបរិក្ខារេ កាមធាតុយា រូបធាតុយា អរូបធាតុយា កាមភវេ រូបភវេ អរូបភវេ សញ្ញាភវេ អសញ្ញាភវេ នេវសញ្ញានាសញ្ញាភវេ ឯកវោការភវេ ចតុវោការភវេ បញ្ចវោការភវេ អតីតេ អនាគតេ បច្ចុប្បន្នេ ទិដ្ឋសុតមុតវិញ្ញាតព្វេសុ ធម្មេសុ អគិទ្ធោ អគថិតោ អមុច្ឆិតោ អនជ្ឈោបន្នោ វីតគេធោ ចត្តគេធោ វន្តគេធោ មុត្តគេធោ បហីនគេធោ បដិនិស្សដ្ឋគេធោ វីតរាគោ ចត្តរាគោ

មុនិពោលនូវសេចក្ដីស្ងប់ ពោលនូវទីពឹង ពោលនូវទីជ្រក ពោលនូវទីរឭក ពោលនូវទីមិនមានភ័យ ពោលនូវទីមិនច្យុត ពោលនូវទីមិនស្លាប់ ពោលនូវព្រះនិព្វាន ហេតុនោះ (ទ្រង់ត្រាស់ថា) មុនិ ជាអ្នកពោលនូវសេចក្ដីស្ងប់ យ៉ាងនេះ ។ ពាក្យថា មិនប្រាថ្នា អធិប្បាយថា តណ្ហា លោក ហៅថា សេចក្ដីប្រាថ្នា បានដល់ តម្រេក តម្រេកខ្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ សេចក្ដីប្រាថ្នានោះ បុគ្គលណា លះបង់ ផ្ដាច់បង់ ធ្វើឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោក ហៅថា មិនប្រាថ្នា ។ បុគ្គលនោះ មិនប្រាថ្នាក្នុងរូប មិនប្រាថ្នា ក្នុងសំឡេង ក្លិន រស ផ្សព្វ ត្រកូល ពួក អាវាស លាភ យស សេចក្ដីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ បរិក្ខារគឺថ្នាំជាបច្ច័យសម្រាប់អ្នកជម្ងឺ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព អតីត អនាគត បច្ចុប្បន្ន ក្នុងធម៌ទាំងឡាយ ដែលឃើញ ឮ ប៉ះពាល់ ប្តូគប្បដឹង មិនជាប់ មិនជំពាក់ មិនជ្រប់ មិនលង់ មានសេចក្ដីប្រាថ្នាទៅប្រាសហើយ មានសេចក្ដីប្រាថ្នាឃ្លាតចេញហើយ មានសេចក្ដីប្រាថ្នាខ្ជាក់ចោលហើយ មានសេចក្ដីប្រាថ្នាផុតហើយ មានសេចក្ដីប្រាថ្នាលះបង់ហើយ មានសេចក្ដីប្រាថ្នាកំចាត់បង់ហើយ មានរាគៈទៅប្រាសហើយ

## នវមោ មាគន្ទិយសុត្តនិទ្ទេសោ

វន្តកោ មុត្តកោ បហីនកោ បដិនិស្សដ្ឋកោ និច្ឆាតោ និព្វុតោ សីតិភូតោ សុខប្បដិសំវេទី ព្រហ្ម-ភូតេន អត្តនា វិហរតីតិ ឯវំ មុនិ សន្តិវាទោ អគិទ្ធោ ។ កាមេ ច លោកេ ច អនូបលិត្តោតិ កាមាតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។បេ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។បេ។ ឥមេ វុច្ចន្តិ កិលេសកាមា ។ លោកោតិ អបាយលោកោ មនុស្សលោកោ ទេវលោកោ ខន្ធលោកោ ធាតុលោកោ អាយតនលោកោ ។ លេបោតិ ទ្វេ លេបា តណ្ហាលេបោ ច ទិដ្ឋិលេបោ ច ។បេ។ អយំ តណ្ហាលេបោ ។បេ។ អយំ ទិដ្ឋិលេបោ ។ មុនិ តណ្ហាលេបំ បហាយ ទិដ្ឋិលេបំ បដិនិស្សជ្ជិត្វា កាមេ ច លោកេ ច ន លិម្បតិ ន សំលិម្បតិ នូបលិម្បតិ អលិត្តោ អសំលិត្តោ អនូបលិត្តោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ ឯវំ មុនិ សន្តិ-វាទោ អគិទ្ធោ កាមេ ច លោកេ ច អនូបលិត្តោ ។

តេនាហ ភគវា

## មាគន្ទិយសុត្តនិទ្ទេស ទី ៩

មានរាគៈឃ្លាតចេញហើយ មានរាគៈខ្ជាក់ចោលហើយ មានរាគៈផុតហើយ មានរាគៈលះបង់ហើយ មានរាគៈកំចាត់បង់ហើយ មិនមានសេចក្តីប្រាថ្នា រលត់ហើយ មានត្រជាក់ មានកិរិយាសោយសុខជាប្រក្រតី មានខ្លួនដ៏ប្រសើរ ហេតុនោះ (ទ្រង់ត្រាស់ថា) មុនិ ជាអ្នកពោលនូវសេចក្តីស្ងប់ មិនប្រាថ្នា យ៉ាងនេះ ។ ពាក្យថា កាម ក្នុងបទថា មិនប្រឡាក់ ក្នុងកាមផង ក្នុងលោកផង សេចក្តីថា តាមឧទ្ទាន កាមមាន ២ គឺ វត្ថុកាម ១ កិលេសកាម ១ ។ បេ ។ ទាំងនេះ ហៅថា វត្ថុកាម ។ បេ ។ ទាំងនេះ ហៅថា កិលេសកាម ។ ពាក្យថា លោក បានដល់អបាយលោក មនុស្សលោក ទេវលោក ខន្ធ-លោក ធាតុលោក អាយតនលោក ។ ពាក្យថា ប្រឡាក់ បានដល់ការប្រឡាក់ ២ គឺ ការប្រឡាក់គឺតណ្ហា ១ ការប្រឡាក់គឺទិដ្ឋិ ១ ។ បេ ។ នេះ ការប្រឡាក់គឺតណ្ហា ។ បេ ។ នេះ ការប្រឡាក់គឺទិដ្ឋិ ។ អ្នកប្រាជ្ញលះបង់ការប្រឡាក់គឺតណ្ហា រលាស់ចោលការប្រឡាក់គឺទិដ្ឋិ មិនប្រឡាក់ មិនប្រឡាក់ព្រម មិនជាប់នៅ ក្នុងកាមផង ក្នុងលោកផង មិនប្រឡាក់ មិនប្រឡាក់ព្រម មិនជាប់ ចេញ រលាសចេញ ផុតស្រឡះ ប្រាសចេញ មានចិត្តប្រកបដោយកិលេសដូចជាទំនប់ទៅប្រាសហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) មុនិពោលនូវសេចក្តីស្ងប់ មិនប្រាថ្នាក្នុងកាមផង ក្នុងលោកផង យ៉ាងនេះ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

យេហិ វិវិត្តោ វិចរេយ្យ លោកេ
ន តានិ ឧគ្គយ្ហ វទេយ្យ នាគោ
ឯលម្ពុជំ កណ្ដកវារិជំ យថា
ជលេន បង្កេន ច នូបលិត្តំ
ឯវំ មុនី សន្តិវាទោ អគិទ្ធោ
កាមេ ច លោកេ ច អនូបលិត្តោតិ ។

(៤៦) ន វេទគូ ទិដ្ឋិយា ន មុតិយា
ស មានមេតិ ន ហិ តម្មយោ សោ
ន កម្មុនា នោបិ សុតេន នេយ្យោ
អនូបនីតោ ស និវេសនេសុ ។

(៤៧) ន វេទគូ ទិដ្ឋិយា ន មុតិយា ស មានមេតីតិ ។ វេទគូតិ វេទោ វុច្ចតិ ចតូសុ មគ្គេសុ ញាណំ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ ធម្មវិចយសម្ពោជ្ឈង្គោ វីមំសា វិបស្សនា សម្មាទិដ្ឋិ ។ តេហិ វេទេហិ ជាតិជរាមរណស្ស អន្តគតោ អន្តប្បត្តោ កោដិគតោ កោដិប្បត្តោ បរិយន្តគតោ បរិយន្តប្បត្តោ វោសានគតោ វោសានប្បត្តោ តាណគតោ តាណប្បត្តោ លេណគតោ លេណប្បត្តោ សរណគតោ សរណប្បត្តោ

នាគស្វាត់ចាកធម៌ទាំងឡាយណា ប្រព្រឹត្តទៅ ក្នុងលោក មិនគប្បីពោលប្រកាន់ទិដ្ឋិទាំងឡាយនោះទេ ឯលម្ពុជាត កណ្ដក-កវារិជាត មិនប្រឡាក់ ដោយទឹកផង ដោយភក់ផង យ៉ាងណាមិញ មុនិ ជាអ្នកពោលនូវសេចក្ដីស្ងប់ មិនប្រាថ្នា មិនប្រឡាក់ ក្នុងកាមផង ក្នុងលោកផង យ៉ាងនោះឯង ។

(៩៦) វេទគូបុគ្គលនោះ មិនលុះមានះ ព្រោះទិដ្ឋិទេ ព្រោះការប៉ះពាល់ទេ ដ្បិតវេទគូបុគ្គលនោះ មិនសម្រេច ដោយមានះនោះ ជាបុគ្គលដែលកម្មដឹកនាំមិនបាន ដែលសុតៈដឹកនាំមិនបាន វេទគូបុគ្គលនោះ មិនជាប់ចំពាក់ក្នុងលំនៅទាំងឡាយ ។

(៩៧) អធិប្បាយពាក្យថា វេទគូបុគ្គលនោះ មិនលុះមានះព្រោះទិដ្ឋិទេ ព្រោះការប៉ះពាល់ទេ ត្រង់ពាក្យថា មិន គឺជាពាក្យហាមឃាត់ ។ ពាក្យថា វេទគូ សេចក្ដីថា ញាណ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ ធម្មវិចយៈ សម្ពោជ្ឈង្គ វីមំសា វិបស្សនា សម្មាទិដ្ឋិក្នុងមគ្គ ៤ លោកហៅថា វេទ ។ បុគ្គលទៅកាន់ទីបំផុត ដល់ទីបំផុត ទៅកាន់ទីខាងចុង ដល់ទីខាងចុង ទៅកាន់ទីបំផុតដោយជុំវិញ ដល់ទីបំផុតដោយជុំវិញ ទៅកាន់ទីអវសាន ដល់ទីអវសាន នៃជាតិ ជរា មរណៈ ទៅកាន់ទីពឹងពួន ដល់ទីពឹងពួន ទៅកាន់ទីជ្រកកោន ដល់ទីជ្រកកោន ទៅកាន់ទីរឭក ដល់ទីរឭក

អចយកោ អចយប្បយុត្តោ អបចយកោ អបចយប្បយុត្តោ អមមកោ អមមប្បយុត្តោ និញ្ជនកោ និញ្ជនប្បយុត្តោ ។ វេទានំ វា អន្តំ គតោតិ វេទគូ ។ វេទេហិ វា អន្តគតោតិ វេទគូ ។ សត្តន្នំ វា ធម្មានំ វិទិតត្តា វេទគូ សក្កាយទិដ្ឋិ វិទិតា ហោតិ វិចិកិច្ឆា វិទិតា ហោតិ សីលព្វតបរាមាសោ វិទិតោ ហោតិ រាគោ វិទិតោ ហោតិ ទោសោ វិទិតោ ហោតិ មោហោ វិទិតោ ហោតិ មានោ វិទិតោ ហោតិ ។ វិទិតស្ស ហោន្តិ បាបកា អកុសលា ធម្មា សង្កិលេសិកា ពោនោព្ភវិកា សទរា ទុក្ខវិបាកា អាយតឹ ជាតិជរាមរណីយា ។

វេទានិ វិចេយ្យ កេវលានិ (សភិយាតិ ភគវា)
សមណានំ យានិ បត្ថិ ព្រាហ្មណានំ
សព្វវេទនាសុ[១] វីតរាគោ
សព្វំ វេទមតិច្ច វេទគូ សោ[២] ។

---

១ ម សព្វវេទាសុ ។ ២ ឱ. តិសទ្ទោ អត្ថិ ។

## មាគន្ទិយសុត្តនិទ្ទេស ទី ៩

ទៅកាន់ទីមិនមានភ័យ ដល់ទីមិនមានភ័យ ទៅកាន់ទីមិនច្យុត ដល់ទីមិនច្យុត ទៅកាន់ទីអមតៈ ដល់ទីអមតៈ ទៅកាន់ព្រះនិព្វាន ដល់ព្រះនិព្វាន ដោយវេទទាំងឡាយនោះ ៗ មួយទៀត បុគ្គលឈ្មោះថាវេទគូ ព្រោះដល់នូវទីបំផុតនៃវេទទាំងឡាយ ឬឈ្មោះថា វេទគូ ព្រោះដល់នូវទីបំផុតដោយវេទទាំងឡាយ ឬថាឈ្មោះថា វេទគូ ព្រោះដឹងច្បាស់នូវធម៌ទាំងឡាយ ៧ ប្រការគឺ ដឹងច្បាស់នូវសក្កាយទិដ្ឋិ ១ ដឹងច្បាស់នូវវិចិកិច្ឆា ១ ដឹងច្បាស់នូវសីលព្វតបរាមាស ១ ដឹងច្បាស់នូវរាគៈ ១ ដឹងច្បាស់នូវទោសៈ ១ ដឹងច្បាស់នូវមោហៈ ១ ដឹងច្បាស់នូវមានះ ១ ៗ អកុសលធម៌ទាំងឡាយដ៏លាមក អកុសលជាគ្រឿងញុំាងសត្វឲ្យសៅហ្មងព្រម ជាធម៌ញុំាងសត្វឲ្យកើតក្នុងភពថ្មីទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានសេចក្តីទុក្ខជាផលជាទីតាំងនៃជាតិ ជរា មរណៈ តទៅទៀត សុទ្ធតែជាធម៌គឺវេទគូបុគ្គល ដឹងច្បាស់ហើយ ៗ

(ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសភិយៈ) វេទគូបុគ្គល គប្បីពិចារណានូវវេទទាំងអស់ ដែលជារបស់ពួកសមណព្រាហ្មណ៍ វេទគូបុគ្គលនោះ មានរាគៈទៅប្រាសហើយ ក្នុងវេទទាំងពួង កន្លងបង់នូវវេទទាំងពួង ៗ

ន ទិដ្ឋិយាតិ តស្ស ទ្វាសដ្ឋិ ទិដ្ឋិគតានិ បហីនានិ សមុច្ឆិន្នានិ វូបសន្តានិ បដិប្បស្សទ្ធានិ អភព្វុប្បត្តិកានិ ញាណគ្គិនា ទឌ្ឍានិ សោ ទិដ្ឋិយា ន យាយតិ ន និយ្យតិ ន វុយ្ហតិ ន សំហារិយតិ នបិ តំ ទិដ្ឋិគតំ សារតោ បច្ចេតិ ន បច្ចាគច្ឆតីតិ ន វេទគូ ទិដ្ឋិយា ។ ន មុតិយា ស មានមេតីតិ មុតរូបេន វា បរឃោសេន វា មហាជនសម្មុតិយា វា ន មានំ ឯតិ ន ឧបេតិ ន ឧបគច្ឆតិ ន គណ្ហាតិ ន បរាមសតិ នាភិនិវិសតីតិ ន វេទគូ ទិដ្ឋិយា ន មុតិយា ស មានមេតិ ។ ន ហិ តម្មយោ សោតិ ន តណ្ហាវសេន ទិដ្ឋិវសេន តម្មយោ ហោតិ តប្បរមោ តប្បរាយណោ ។ យតោ តណ្ហា ច ទិដ្ឋិ ច មានោ ច បហីនា ហោន្តិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតិំ អនុប្បាទធម្មា

ពាក្យថា មិន (លុះមានះ) ព្រោះទិដ្ឋិទេ សេចក្ដីថា ទិដ្ឋិទាំងឡាយ ៦២ វេទគូបុគ្គលនោះ លះបង់ ផ្ដាច់បង់ ឲ្យស្ងប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ ទិដ្ឋិឲ្យទៅមិនបាន នាំទៅមិនបាន បន្សាត់ទៅមិនបាន នាំទៅព្រមមិនបាន ព្រោះទិដ្ឋិ ទាំងមិនជឿ មិនប្រកាន់ នូវទិដ្ឋិនោះ ថាជាខ្លឹមសារ ហេតុនោះ (ទ្រង់ត្រាស់ថា) វេទគូបុគ្គល មិន (លុះមានះ) ព្រោះទិដ្ឋិទេ ។ ពាក្យថា វេទគូបុគ្គលនោះ មិនលុះមានះ ព្រោះការប៉ះពាល់ទេ សេចក្ដីថា មិនលុះ គឺមិនទៅជិត មិនចូលទៅ មិនប្រកាន់ មិនបបោសអង្អែល មិនជាប់ចិត្ត នូវមានះ ព្រោះរូបដែលប៉ះពាល់ ឬព្រោះការឃោសនារបស់បុគ្គលដទៃ ឬក៏ព្រោះសេចក្ដីសម្មតិរបស់មហាជន ហេតុនោះ (ទ្រង់ត្រាស់ថា) វេទគូបុគ្គលនោះ មិនលុះមានះ ព្រោះទិដ្ឋិទេ ព្រោះការប៉ះពាល់ទេ ។ ពាក្យថា វេទគូបុគ្គលនោះ មិនសម្រេចដោយមានះនោះ សេចក្ដីថា មិនមែនជាបុគ្គលសម្រេចដោយមានះ នោះ មានមានះនោះជាធំ មានមានះនោះ ប្រព្រឹត្តទៅក្នុងខាងមុខ ដោយអំណាចតណ្ហា ដោយអំណាចទិដ្ឋិទេ ។ តណ្ហាក្ដី ទិដ្ឋិក្ដី មានះក្ដី វេទគូបុគ្គល លះបង់ ផ្ដាច់ផ្ដិលឫសគល់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមាន ជាធម៌មិនមានការកើតតទៅទៀត ដោយហេតុណា

បច្ចាវត្តា ន តម្មយោ ហោតិ ន តប្បរមោ ន តប្បរាយណោតិ ន ហិ តម្មយោ សោ ។

(៤៨) ន កម្មុនា នោបិ សុតេន នេយ្យោតិ ន កម្មុនាតិ បុញ្ញាភិសង្ខារេន វា អបុញ្ញាភិសង្ខារេន វា អានេញ្ជាភិសង្ខារេន វា ន យាយតិ ន និយ្យតិ ន វុយ្ហតិ ន សំហារិយតីតិ ន កម្មុនា ។ នោបិ សុតេន នេយ្យោតិ សុតសុទ្ធិយា វា បរឃោសេន វា មហាជនសម្មុតិយា វា ន យាយតិ ន និយ្យតិ ន វុយ្ហតិ ន សំហារិយតីតិ ន កម្មុនា នោបិ សុតេន នេយ្យោ ។

(៤៩) អនូបនីតោ ស និវេសនេសូតិ ឧបយោតិ ទ្វេ ឧបយា តណ្ហូបយោ ច ទិដ្ឋូបយោ ច ។ បេ ។ អយំ តណ្ហូបយោ ។ បេ ។ អយំ ទិដ្ឋូបយោ ។

## មាគន្ទិយសុត្តនិទ្ទេស ទី ៩

វេទគូបុគ្គលនោះ មិនសម្រេចដោយមានះនោះ មិនមានមានះនោះផង មិនមានមានះនោះប្រព្រឹត្តទៅក្នុងខាងមុខ ដោយហេតុមានប្រមាណប៉ុណ្ណោះ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះវេទគូបុគ្គលនោះ មិនសម្រេចដោយមានះនោះ ។

(៤៨) អធិប្បាយពាក្យថា ជាបុគ្គលដែលកម្មនាំទៅមិនបាន ដែលសុតៈនាំទៅមិនបាន ត្រង់ពាក្យថា ដែលកម្មនាំទៅមិនបាន គឺដែលបុញ្ញាភិសង្ខារក្តី អបុញ្ញាភិសង្ខារក្តី អានេញ្ជាភិសង្ខារក្តី ឲ្យទៅមិនបាន នាំទៅមិនបាន បន្សាត់ទៅមិនបាន នាំទៅព្រមមិនបាន ហេតុនោះ (ទ្រង់ត្រាស់ថា) ដែលកម្មនាំទៅមិនបាន ។ ពាក្យថា ដែលសុតៈនាំទៅមិនបាន គឺដែលសេចក្តីបរិសុទ្ធិព្រោះការឮក្តី ដែលការឃោសនារបស់បុគ្គលដទៃក្តី ដែលការសម្មតិរបស់មហាជនក្តី ឲ្យទៅមិនបាន នាំទៅមិនបាន បន្សាត់ទៅមិនបាន នាំទៅព្រមមិនបាន ហេតុនោះ (ទ្រង់ត្រាស់ថា) ដែលកម្មនាំទៅមិនបាន ដែលសុតៈនាំទៅមិនបាន ។

(៤៩) អធិប្បាយពាក្យថា វេទគូបុគ្គលនោះ មិនជាប់ចំពាក់ក្នុងលំនៅទាំងឡាយ ត្រង់ពាក្យថា ជាប់ចំពាក់ បានដល់ការជាប់ចំពាក់ ២ យ៉ាង គឺការជាប់ចំពាក់គឺតណ្ហា ១ ការជាប់ចំពាក់គឺទិដ្ឋិ ១ ។ បេ ។ នេះការជាប់ចំពាក់គឺតណ្ហា ។ បេ ។ នេះការជាប់ចំពាក់គឺទិដ្ឋិ ។

តស្ស តណ្ហូបយោ បហីនោ ទិដ្ឋូបយោ បដិនិស្សដ្ឋោ តណ្ហូបយស្ស បហីនត្តា ទិដ្ឋូបយស្ស បដិនិស្សដ្ឋត្តា សោ និវេសនេសុ អនូបនីតោ អនុបលិត្តោ អនុបគតោ អនជ្ឈោសិតោ អនធិមុត្តោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ អនូបនីតោ ស និវេសនេសុ ។ តេនាហ ភគវា

ន វេទគូ ទិដ្ឋិយា ន មុតិយា
ស មានមេតិ ន ហិ តម្មយោ សោ
ន កម្មុនា នោបិ សុតេន នេយ្យោ
អនូបនីតោ ស និវេសនេសូតិ ។

(៥០) សញ្ញាវិរត្តស្ស ន សន្តិ គន្ថា
បញ្ញាវិមុត្តស្ស ន សន្តិ មោហា
សញ្ញញ្ច ទិដ្ឋិញ្ច យេ អគ្គហេសុំ
តេ ឃដ្ដយន្តា(១) វិចរន្តិ លោកេ ។

---

១ ម. តេ ឃដ្ដមានា ។

ការជាប់ចំពាក់គឺតណ្ហា វេទគូបុគ្គលនោះលះបង់ហើយ ការជាប់ចំពាក់គឺទិដ្ឋិ វេទគូបុគ្គលរលាស់ចោលហើយ ព្រោះលះបង់ការជាប់ចំពាក់គឺតណ្ហា រលាស់ចោលការជាប់ចំពាក់គឺទិដ្ឋិហើយ វេទគូបុគ្គលនោះ ឈ្មោះថា មិនជាប់ចំពាក់ មិនចូលទៅប្រឡាក់ មិនចូលទៅជិត មិនជក់ទៅ មិនលង់ទៅ ក្នុងលំនៅទាំងឡាយ គឺចេញទៅ រលាស់ចេញ ផុតស្រឡះ ប្រាសចេញ មានចិត្តប្រកបដោយកិលេស ដូចជាទំនប់ទៅប្រាសហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) វេទគូបុគ្គលនោះ មិនជាប់ចំពាក់ ក្នុងលំនៅទាំងឡាយ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

> វេទគូបុគ្គលនោះ មិនលុះមានះ ព្រោះទិដ្ឋិទេ ព្រោះការប៉ះ
> ពាល់ទេ ដ្បិតវេទគូបុគ្គលនោះ មិនសម្រេចដោយមានះនោះ
> ជាបុគ្គលដែលកម្មដឹកនាំមិនបាន ដែលសុតៈដឹកនាំមិនបាន
> វេទគូបុគ្គលនោះ មិនជាប់ចំពាក់ ក្នុងលំនៅទាំងឡាយ ។

> (៩០) កិលេសជាគ្រឿងចាក់ស្រែះទាំងឡាយ នៃបុគ្គលដែល
> ប្រាសចាកសញ្ញា មិនមានទេ មោហៈទាំងឡាយនៃបុគ្គល
> ដែលផុតស្រឡះដោយបញ្ញា មិនមានទេ បុគ្គលទាំងឡាយ
> ណា ប្រកាន់យកសញ្ញា នឹងទិដ្ឋិហើយ បុគ្គលទាំងនោះ
> រមែងបន្ត (នូវអត្តភាព) ប្រព្រឹត្តទៅ ក្នុងលោក ។

## ទសមោ មាគន្ទិយសុត្តនិទ្ទេសោ

(៥១) សញ្ញាវិរត្តស្ស ន សន្តិ គន្ថាតិ យោ
សមថបុព្វង្គមំ អរិយមគ្គំ ភាវេតិ តស្ស អាទិតោ ឧបា-
ទាយ គន្ថា វិក្ខម្ភិតា ហោន្តិ ។ អរហត្តប្បត្តេ អរហតោ
គន្ថា ច មោហា ច នីវរណា ច កាមសញ្ញា ព្យាបាទ-
សញ្ញា វិហឹសាសញ្ញា ទិដ្ឋិសញ្ញា បហីនា ហោន្តិ
ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុ-
ប្បាទធម្មាតិ សញ្ញាវិរត្តស្ស ន សន្តិ គន្ថា ។

(៥២) បញ្ញាវិមុត្តស្ស ន សន្តិ មោហាតិ យោ វិប-
ស្សនាបុព្វង្គមំ អរិយមគ្គំ ភាវេតិ តស្ស អាទិតោ
ឧបាទាយ មោហា វិក្ខម្ភិតា ហោន្តិ ។ អរហត្តប្បត្តេ
អរហតោ មោហា ច គន្ថា ច នីវរណា ច កាមសញ្ញា
ព្យាបាទសញ្ញា វិហឹសាសញ្ញា ទិដ្ឋិសញ្ញា បហីនា ហោន្តិ

## មាគន្ទិយសុត្តនិទ្ទេស ទី ៩

(៩១) ពាក្យថា កិលេសជាគ្រឿងចាក់ស្រែះទាំងឡាយ នៃបុគ្គលដែលប្រាសចាកសញ្ញាមិនមានទេ អធិប្បាយថា បុគ្គលណាចំរើនអរិយមគ្គមានសមថៈជាប្រធាន បុគ្គលនោះ ឈ្មោះថា ធ្វើសមាធិខាងដើមឲ្យកើតហើយ សង្កត់សង្កិនកិលេសជាគ្រឿងចាក់ស្រែះទាំងឡាយ ។ ក្នុងកាលសម្រេចព្រះអរហត្តហើយ ព្រះអរហន្តលះបង់កិលេសជាគ្រឿងចាក់ស្រែះទាំងឡាយ មោហៈទាំងឡាយ នីវរណៈទាំងឡាយ កាមសញ្ញា ព្យាបាទសញ្ញា វិហឹសាសញ្ញា ទិដ្ឋិសញ្ញា លោកបានផ្តាច់បង់ឫសគល់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមាន ជាធម៌មិនមានការកើតទៀត ហេតុនោះ (ទ្រង់ត្រាស់ថា) កិលេសជាគ្រឿងចាក់ស្រែះទាំងឡាយ នៃបុគ្គលដែលប្រាសចាកសញ្ញាមិនមានទេ ។

(៩២) ពាក្យថា មោហៈទាំងឡាយ នៃបុគ្គលដែលផុតស្រឡះដោយបញ្ញាមិនមានទេ អធិប្បាយថា បុគ្គលណាចំរើនអរិយមគ្គមានវិបស្សនាជាប្រធាន បុគ្គលនោះ ឈ្មោះថា ធ្វើសមាធិខាងដើមឲ្យកើត សង្កត់សង្កិននូវមោហៈ ។ ក្នុងកាលសម្រេចព្រះអរហត្តហើយ ព្រះអរហន្តលះបង់មោហៈទាំងឡាយ កិលេសជាគ្រឿងចាក់ស្រែះទាំងឡាយ នីវរណៈទាំងឡាយ កាមសញ្ញា ព្យាបាទសញ្ញា វិហឹសាសញ្ញា ទិដ្ឋិសញ្ញា

ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ
អនុប្បាទធម្មាតិ បញ្ញាវិមុត្តស្ស ន សន្តិ មោហា ។

(៥៣) សញ្ញញ្ច ទិដ្ឋិញ្ច យេ អគ្គហេសុំ តេ ឃដ្ដយន្តា វិចរន្តិ លោកេតិ យេ សញ្ញំ គណ្ហន្តិ កាមសញ្ញំ ព្យាបាទសញ្ញំ វិហឹសាសញ្ញំ តេ សញ្ញាវសេន ឃដ្ដេន្តិ សំឃដ្ដេន្តិ ។ រាជានោបិ រាជូហិ វិវទន្តិ ខត្តិយាបិ ខត្តិយេហិ វិវទន្តិ ព្រាហ្មណាបិ ព្រាហ្មណេហិ វិវទន្តិ គហបតីបិ គហបតីហិ វិវទន្តិ មាតាបិ បុត្តេន វិវទតិ បុត្តោបិ មាតរា វិវទតិ បិតាបិ បុត្តេន វិវទតិ បុត្តោបិ បិតរា វិវទតិ ភាតាបិ ភាតរា វិវទតិ ភគិនីបិ ភគិនិយា វិវទតិ ភាតាបិ ភគិនិយា វិវទតិ ភគិនីបិ ភាតរា វិវទតិ សហាយោបិ សហាយេន វិវទតិ ។

ផ្តាច់ឫសគល់ហើយ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើត នៃដើមត្នោត ដល់នូវការមិនមាន ជាធម៌មិនមានការកើត តទៅទៀត ហេតុនោះ (ទ្រង់ត្រាស់ថា) មោហៈទាំងឡាយ នៃបុគ្គលដែលផុតស្រឡះដោយបញ្ញា មិនមានទេ ។

(៨៣) ពាក្យថា បុគ្គលទាំងឡាយណា ប្រកាន់យកសញ្ញានិងទិដ្ឋិហើយ បុគ្គលទាំងនោះ រមែងបត្ត (នូវអត្តភាព) ប្រព្រឹត្តទៅក្នុងលោក អធិប្បាយថា បុគ្គលទាំងឡាយណា ប្រកាន់យកសញ្ញា គឺ កាមសញ្ញា ព្យាបាទសញ្ញា វិហឹសាសញ្ញា បុគ្គលទាំងឡាយនោះ រមែងប៉ះពាល់ ប៉ះទង្គិច ដោយអំណាចសញ្ញា ។ ពួកព្រះរាជារមែងទាស់ទែងនឹងពួកព្រះរាជា ពួកក្សត្រិយ៍ រមែងទាស់ទែងនឹងពួកក្សត្រិយ៍ ពួកព្រាហ្មណ៍រមែងទាស់ទែងនឹងពួកព្រាហ្មណ៍ ពួកគហបតីរមែងទាស់ទែងនឹងពួកគហបតី មាតារមែងទាស់ទែងនឹងបុត្ត បុត្តរមែងទាស់ទែងនឹងមាតា បិតារមែងទាស់ទែងនឹងបុត្ត បុត្តរមែងទាស់ទែងនឹងបិតា បងប្អូនប្រុសរមែងទាស់ទែងនឹងបងប្អូនប្រុស បងប្អូនស្រី រមែងទាស់ទែងនឹងបងប្អូនស្រី បងប្អូនប្រុសរមែងទាស់ទែងនឹងបងប្អូនស្រី បងប្អូនស្រីរមែងទាស់ទែងនឹងបងប្អូនប្រុស សំឡាញ់រមែងទាស់ទែងនឹងសំឡាញ់ ។

## ទសមោ មាតិគន្ថយុគ្គនិទ្ទេសោ

តេ តត្ថ កលហវិគ្គហវិវាទាបន្នា អញ្ញមញ្ញំ បាណីហិបិ ឧបក្កមន្តិ លេឌ្ឌូហិបិ ឧបក្កមន្តិ ទណ្ឌេហិបិ ឧបក្កមន្តិ សត្ថេហិបិ ឧបក្កមន្តិ ។ តេ តត្ថ មរណម្បិ និគច្ឆន្តិ មរណមត្តម្បិ ទុក្ខំ ។ យេ ទិដ្ឋឹ គណ្ហន្តិ សស្សតោ លោកោតិ វា ។ បេ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ វា តេ ទិដ្ឋិវសេន យជន្តិ សិំ យជន្តិ សត្ថារតោ សត្ថារំ យជន្តិ ធម្មក្ខានតោ ធម្មក្ខានំ យជន្តិ គណតោ គណំ យជន្តិ ទិដ្ឋិយា ទិដ្ឋឹ យជន្តិ បដិបទាយ បដិបទំ យជន្តិ មគ្គតោ មគ្គំ យជន្តិ ។ អថវា តេ វិទន្តិ កលហំ ការេន្តិ ភណ្ឌនំ ការេន្តិ វិគ្គហំ ការេន្តិ វិវាទំ ការេន្តិ មេធគំ ការេន្តិ ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ ។ បេ ។ និព្វេឋេហិ វា សចេ បហោសីតិ ។ តេសំ អភិសង្ខារា អប្បហីនា អភិសង្ខារានំ អប្បហីនត្តា គតិយា យជន្តិ និរយេ យជន្តិ តិរច្ឆានយោនិយា យជន្តិ បិត្តិវិសយេ យជន្តិ មនុស្សលោកេ យជន្តិ ទេវលោកេ យជន្តិ គតិយា គតឹ

## មាគន្ទិយសុត្តនិទ្ទេស ទី ៩

ជនទាំងនោះ ដល់នូវជម្លោះ ប្រកួតប្រកាន់ ការទាស់ទែង ប្រហារគ្នា នឹងគ្នាដោយដៃខ្លះ ប្រហារដោយដុំដីទាំងឡាយខ្លះ ប្រហារដោយដំបងទាំងឡាយខ្លះ ប្រហារដោយគ្រឿងសស្ត្រាទាំងឡាយខ្លះ ក្នុងហេតុនោះ ៗ ជនទាំងនោះដល់នូវសេចក្តីស្លាប់ខ្លះ នូវទុក្ខទៀបស្លាប់ខ្លះ ក្នុងហេតុនោះ ៗ ជនទាំងឡាយណា ប្រកាន់យកនូវទិដ្ឋិថា លោកទៀង ដូច្នេះក្តី ។ បេ ។ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះក្តី ជនទាំងនោះ រមែងបៀតបៀន បៀតបៀនព្រម ដោយអំណាចទិដ្ឋិ រមែងបៀតបៀនសាស្តា ព្រោះសាស្តា បៀតបៀនធម៌ ដែលសាស្តាសម្តែងហើយ ព្រោះធម៌ដែលសាស្តាសម្តែងហើយ បៀតបៀនពួក ព្រោះពួក បៀតបៀនទិដ្ឋិ ព្រោះទិដ្ឋិ បៀតបៀនបដិបទា ព្រោះបដិបទា បៀតបៀនមគ្គ ព្រោះមគ្គ ។ មួយទៀត ជនទាំងនោះ រមែងទាស់ទែង ធ្វើជម្លោះ ធ្វើសេចក្តីប្រកួតប្រកាន់ ធ្វើសេចក្តីប្រកាន់ខុស ធ្វើវិវាទ ធ្វើការដណ្តើមយកឈ្នះថា អ្នកមិនចេះធម៌វិន័យនេះទេ ។ បេ ។ ឬបើ អ្នកអាច អ្នកចូរដោះចុះ ។ អភិសង្ខារទាំងឡាយ គឺបុគ្គលទាំងនោះ មិនបានលះបង់ ព្រោះការមិនបានលះបង់អភិសង្ខារទាំងឡាយ ទើបបុគ្គលទាំងនោះ រមែងលំបាកក្នុងគតិ លំបាកក្នុងនរក លំបាកក្នុងកំណើតតិរច្ឆាន លំបាកក្នុងប្រេតវិស័យ លំបាក ក្នុងមនុស្សលោក លំបាក ក្នុងទេវលោក លំបាក ក្លាប់ នូវគតិដោយគតិ

ឧបបត្តិយោ ឧបបត្តឹ បដិសន្ធិយោ បដិសន្ធឹ ភវេន ភវំ សំសារេន សំសារំ វដ្ដេន វដ្ដំ ឃដ្ដេន្តិ សំឃដ្ដេន្តិ ឃដ្ដេន្តា ចរន្តិ វិហរន្តិ ឥរិយន្តិ វត្តេន្តិ បាលេន្តិ យបេន្តិ យាបេន្តិ ។ លោកេតិ អបាយលោកេ មនុស្ស-លោកេ ទេវលោកេ ខន្ធលោកេ ធាតុលោកេ អាយតនលោកេតិ សញ្ញញ្ច ទិដ្ឋិញ្ច យេ អគ្គហេសុំ តេ ឃដ្ដយន្តា វិចរន្តិ លោកេ ។ តេនាហ ភគវា

សញ្ញាវិរត្តស្ស ន សន្តិ គន្ថា
បញ្ញាវិមុត្តស្ស ន សន្តិ មោហា
សញ្ញញ្ច ទិដ្ឋិញ្ច យេ អគ្គហេសុំ
តេ ឃដ្ដយន្តា វិចរន្តិ លោកេតិ ។

នវមោ មាគន្ទិយសុត្តនិទ្ទេសោ និដ្ឋិតោ ។

នូវការកើតដោយការកើត នូវបដិសន្ធិដោយបដិសន្ធិ នូវភពដោយភព នូវសង្សារ ដោយសង្សារ នូវវដ្ដៈដោយវដ្ដៈ កាលលំបាក រមែងគ្រាប់ទៅ រមែងទៅ រមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ។ ពាក្យថា លោក គឺអបាយលោក មនុស្សលោក ទេវលោក ខន្ធ-លោក ធាតុលោក អាយតនលោក ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលទាំងឡាយ ណា ប្រកាន់យកសញ្ញានិងទិដ្ឋិ បុគ្គលទាំងនោះ ឈ្មោះថា បន្ត (នូវអត្តភាព) ប្រព្រឹត្តទៅ ក្នុងលោក ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

កិលេសជាគ្រឿងចាក់ស្រែះទាំងឡាយ នៃបុគ្គលដែលប្រាស
ចាកសញ្ញា មិនមានទេ មោហៈទាំងឡាយនៃបុគ្គល ដែល
ផុតស្រឡះដោយបញ្ញា មិនមានទេ បុគ្គលទាំងឡាយ
ណា ប្រកាន់យកសញ្ញានិងទិដ្ឋិហើយ បុគ្គលទាំងនោះ
រមែងបន្ត (នូវអត្តភាព) ប្រព្រឹត្តទៅ ក្នុងលោក ។

ចប់ មាគន្ទិយសុត្តនិទ្ទេស ទី ៩ ។

## ទសមោ បុរាភេទសុត្តនិទ្ទេសោ

(៨៤) កថំទស្សី កថំសីលោ ឧបសន្តោតិ វុច្ចតិ

តម្មេ គោតម បព្រូហិ បុច្ឆិតោ ឧត្តមំ នរំ។

(៨៥) កថំទស្សី កថំសីលោ ឧបសន្តោតិ វុច្ចតីតិ

កថំទស្សីតិ កីទិសេន ទស្សនេន សមន្នាគតោ កឹសណ្ឋិតេន កឹបការេន កឹបដិភាគេនាតិ កថំទស្សី ។ កថំសីលោតិ កីទិសេន សីលេន សមន្នាគតោ កឹសណ្ឋិតេន កឹបការេន កឹបដិភាគេនាតិ កថំទស្សី កថំសីលោ ។ ឧបសន្តោតិ វុច្ចតីតិ សន្តោ ឧបសន្តោ និព្វុតោ បដិប្បស្សទ្ធោតិ វុច្ចតិ បវុច្ចតិ កថិយតិ ភណិយតិ ទីបិយតិ វោហរិយតិ ។ កថំទស្សីតិ អធិបញ្ញំ បុច្ឆតិ ។ កថំសីលោតិ អធិសីលំ បុច្ឆតិ ។

# បុរាភេទសុត្តនិទ្ទេស ទី ១០

(៩៤) (ព្រះពុទ្ធនិម្មិតសួរថា) បុគ្គលមានការឃើញដូចម្ដេច មានសីលដូចម្ដេច ដែលព្រះអង្គហៅថា អ្នកស្ងប់ បពិត្រព្រះគោតម ព្រះអង្គដែលខ្ញុំសួរហើយ សូមប្រាប់ នូវនរជន ដ៏ឧត្តមនោះ ។

(៩៥) អធិប្បាយពាក្យថា បុគ្គលមានការឃើញដូចម្ដេច មានសីលដូចម្ដេច ដែលព្រះអង្គហៅថាអ្នកស្ងប់ ត្រង់ពាក្យថា បុគ្គលមានការឃើញដូចម្ដេច គឺបុគ្គលប្រកបដោយការឃើញដូចម្ដេច ប្រាកដដូចម្ដេច មានប្រការដូចម្ដេច មានចំណែកប្រៀបដូចម្ដេច ហេតុនោះ (ទើបសួរថា) បុគ្គលមានការឃើញដូចម្ដេច ។ ពាក្យថា មានសីលដូចម្ដេច គឺជាអ្នកប្រកបដោយសីលដូចម្ដេច ប្រាកដដូចម្ដេច មានប្រការដូចម្ដេច មានចំណែកដូចម្ដេច ហេតុនោះ (ទើបសួរថា) មានការឃើញដូចម្ដេច មានសីលដូចម្ដេច ។ ពាក្យថា ដែលព្រះអង្គហៅថា អ្នកស្ងប់ គឺដែលព្រះអង្គពោល ត្រាស់ សំដែង ពណ៌នា បំភ្លឺ ថ្លែង ថាជាអ្នកស្ងប់ ជាអ្នកស្ងប់ស្ងាត់ មានទុក្ខរលត់ ជាអ្នកស្ងប់រម្ងាប់ ។ ពាក្យថា បុគ្គលមានការឃើញដូចម្ដេច គឺសួរចំពោះអធិប្បញ្ញា ។ ពាក្យថា មានសីលដូចម្ដេច គឺសួរចំពោះអធិសីល ។

ឧបសន្តោតិ អធិចិត្តំ បុច្ឆិតិ កាជិកស្ស កាជិសីលោ ឧបសន្តោតិ វុច្ចតិ ។

(៥៦) តម្មេ គោតម បព្រូហីតិ តន្តិ យំ បុច្ឆាមិ យំ យាចាមិ យំ អជ្ឈេសាមិ យំ បសាទេមិ ។ គោតមាតិ សោ និម្មិតោ ពុទ្ធំ ភគវន្តំ គោត្តេន អាលបតិ ។ បព្រូហីតិ ព្រូហិ អាចិក្ខ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរ វិភជ ឧត្តានីករោហិ បកាសេហីតិ តម្មេ គោតម បព្រូហិ ។

(៥៧) បុច្ឆិតោ ឧត្តមំ នរន្តិ បុច្ឆិតោតិ បុដ្ឋោ បុច្ឆិតោ យាចិតោ អជ្ឈេសិតោ បសាទិតោ ។ ឧត្តមំ នរន្តិ អគ្គំ សេដ្ឋំ វិសេដ្ឋំ បាមោក្ខំ ឧត្តមំ បវរំ នរន្តិ បុច្ឆិតោ ឧត្តមំ នរំ ។ តេនាហ សោ និម្មិតោ

សួរចំពោះអធិចិត្តថា អ្នកស្ងប់ ហេតុនោះ (ទើបសួរថា) បុគ្គល មានការឃើញដូចម្ដេច មានសីលដូចម្ដេច ដែលព្រះអង្គ ហៅថា អ្នកស្ងប់ ។

(៥៦) អធិប្បាយពាក្យថា បពិត្រព្រះគោតម ព្រះអង្គដែលខ្ញុំ (សួរហើយ) សូមប្រាប់នូវនរជននោះ ត្រង់ពាក្យថា នោះ គឺខ្ញុំសួរចំពោះ បុគ្គលណា អង្វរចំពោះបុគ្គលណា អារាធនាចំពោះបុគ្គលណា ញុំាង ព្រះអង្គឲ្យជ្រះថ្លាចំពោះបុគ្គលណា ។ ព្រះពុទ្ធនិម្មិតនោះ ហៅព្រះពុទ្ធ មានព្រះភាគ តាមគោត្រថា បពិត្រព្រះគោតម ។ ពាក្យថា សូម ប្រាប់ គឺ សូមពោល សូមពណ៌នា សូមសំដែង សូមបញ្ញត្ត សូមផ្ដើម សូមបើក សូមចែក សូមធ្វើឲ្យរាក់ សូមប្រកាស ហេតុនោះ (ទើប សួរថា) បពិត្រព្រះគោតម ព្រះអង្គដែលខ្ញុំ (សួរហើយ) សូមប្រាប់ នូវនរជននោះ ។

(៥៧) ពាក្យថា ដែលខ្ញុំ សួរហើយ (សូមប្រាប់) នូវនរជនដ៏ឧត្តម ត្រង់ពាក្យថា សួរហើយ គឺសួរហើយ ដណ្ដឹងហើយ អង្វរហើយ អារាធនា ហើយ ឲ្យជ្រះថ្លាហើយ ។ ពាក្យថា នូវនរជនដ៏ឧត្តម គឺនូវនរជន ជាកំពូល ប្រសើរ ប្រសើរវិសេស ជាប្រធាន ដ៏ឧត្តម ប្រសើរក្រៃ លែង ហេតុនោះ (ទើបពោលថា) ព្រះអង្គដែលខ្ញុំសួរហើយ (សូមប្រាប់) នូវនរជនដ៏ឧត្តម ។ ហេតុនោះ ព្រះពុទ្ធនិម្មិតនោះ ត្រាស់សួរថា

ទសមោ បុរាភេទសុត្តនិទ្ទេសោ

កថំទស្សី កថំសីលោ ឧបសន្តោតិ វុច្ចតិ
តម្មេ គោតម បព្រូហិ បុច្ឆិតោ
ឧត្តមំ នរន្តិ ។

(៤៨) វីតតណ្ហោ បុរា ភេទា (តិ ភគវា)
បុព្វមន្តមនិស្សិតោ
វេមជ្ឈេ នុបសង្ខេយ្យោ
តស្ស នត្ថិ បុរេក្ខតំ ។

(៤៩) វីតតណ្ហោ បុរា ភេទាតិ ភគវាតិ បុរា កាយស្ស ភេទា បុរា អត្តភាវស្ស ភេទា បុរា កឡេវរស្ស និក្ខេបា បុរា ជីវិតិន្ទ្រិយស្ស ឧបច្ឆេទា វីតតណ្ហោ វិគតតណ្ហោ ចត្តតណ្ហោ វន្តតណ្ហោ មុត្តតណ្ហោ បហីនតណ្ហោ បដិនិស្សដ្ឋតណ្ហោ វីតរាគោ វិគតរាគោ ចត្តរាគោ វន្តរាគោ មុត្តរាគោ បហីនរាគោ បដិនិស្សដ្ឋរាគោ និច្ឆាតោ និព្វុតោ សីតិភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតិ ។ ភគវាតិ គារវាធិវចនំ ។ អបិច ភគ្គរាគោតិ ភគវា ។ ភគ្គទោសោតិ ភគវា ។ ភគ្គមោហោតិ ភគវា ។

បុគ្គលមានការឃើញដូចម្តេច មានសីលដូចម្តេច ដែលព្រះអង្គហៅថា អ្នកស្ងប់ បពិត្រព្រះគោតម ព្រះអង្គដែលខ្ញុំសួរហើយ សូមប្រាប់ នូវនរជន ដ៏ឧត្តមនោះ ។

(៨៨) (ព្រះមានព្រះភាគត្រាស់ថា) មុនអំពីការបែកធ្លាយសរីរៈទៅ បុគ្គលណា ប្រាសចាកតណ្ហា មិនអាស្រ័យកាលខាងដើម ជាអ្នកដែលគេមិនគួររាប់ ក្នុងកាលជាកណ្តាលទេ ភាពនៃការធ្វើឲ្យជាប្រធាននៃបុគ្គលនោះ មិនមានឡើយ ។

(៨៩) ពាក្យថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា មុនអំពីការបែកធ្លាយសរីរៈទៅ បុគ្គលណាប្រាសចាកតណ្ហា អធិប្បាយថា បុគ្គលប្រាសចាកតណ្ហា ឃ្លាតចាកតណ្ហា លះតណ្ហា ខ្ជាក់ចោលតណ្ហា រួចចាកតណ្ហា លះបង់តណ្ហា រលាស់ចោលតណ្ហា ប្រាសចាករាគៈ ឃ្លាតចាករាគៈ លះរាគៈ ខ្ជាក់ចោលរាគៈ រួចចាករាគៈ លះបង់រាគៈ រលាស់ចោលរាគៈ មិនស្រេកឃ្លាន រលត់ទុក្ខ ត្រជាក់ សោយសុខ នៅដោយចិត្តដ៏ប្រសើរ មុនអំពីការបែកធ្លាយកាយ មុនអំពីការបែកធ្លាយអត្តភាព មុនអំពីការដាក់ចុះនូវសាកសព មុនអំពីការដាច់ជីវិតិន្ទ្រិយ ។ ពាក្យថា ព្រះមានព្រះភាគ ជាពាក្យហៅដោយសេចក្តីគោរព ។ម្យ៉ាងទៀត ព្រះនាមថា មានព្រះភាគ ព្រោះហេតុទ្រង់បំបាក់រាគៈ ។ ព្រះនាមថា មានព្រះភាគ ព្រោះហេតុទ្រង់បំបាក់ទោសៈ ។ ព្រះនាមថា មានព្រះភាគ ព្រោះហេតុទ្រង់បំបាក់មោហៈ

ភគ្គមានោតិ ភគវា ។ ភគ្គទិដ្ឋីតិ ភគវា ។ ភគ្គកណ្ដកោតិ ភគវា ។ ភគ្គកិលេសោតិ ភគវា ។ ភជិ វិភជិ បវិភជិ ធម្មរតនន្តិ ភគវា ។ ភវានំ អន្តករោតិ ភគវា ។ ភាវិតកាយោតិ ភគវា ។ ភាវិតសីលោ ភាវិតចិត្តោ ភាវិតបញ្ញោតិ ភគវា ។ ភជិ វា ភគវា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហស្សេយ្យកានិ បដិសល្លានសារុប្បានីតិ ភគវា ។ ភាគី វា ភគវា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ភគវា ។ ភាគី វា ភគវា អត្ថរសស្ស ធម្មរសស្ស វិមុត្តិរសស្ស អធិសីលស្ស អធិចិត្តស្ស អធិបញ្ញាយាតិ ភគវា ។ ភាគី វា ភគវា ចតុន្នំ ឈានានំ

ព្រះនាមថា មានព្រះភាគ ព្រោះហេតុទ្រង់បំបាក់មានះ ព្រះនាមថា មានព្រះភាគ ព្រោះហេតុទ្រង់បំបាក់ទិដ្ឋិ ។ ព្រះនាមថា មានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បំរូង ។ ព្រះនាមថា មានព្រះភាគ ព្រោះហេតុ ទ្រង់បំបាក់កិលេស ។ ព្រះនាមថា មានព្រះភាគ ព្រោះហេតុទ្រង់ចែក រំលែក ញែក នូវធម្មរតនៈ ។ ព្រះនាមថា មានព្រះភាគ ព្រោះហេតុទ្រង់ធ្វើ នូវទីបំផុតនៃភពទាំងឡាយ ។ ព្រះនាមថា មានព្រះភាគ ព្រោះហេតុទ្រង់ចំរើនព្រះកាយ ។ ព្រះនាមថា មានព្រះភាគ ព្រោះហេតុទ្រង់ចំរើនសីល ចំរើនចិត្ត ចំរើនបញ្ញា ។ មួយទៀត ព្រះនាមថា មានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់គប់រកសេនាសនៈ ទាំងឡាយដ៏ស្ងាត់ គឺ ព្រៃតូចនិងព្រៃធំ ជាព្រៃមិនមានសំឡេង មិនមានការគឹកកង ជាព្រៃប្រាសចាកខ្យល់កាយនៃជន ជាព្រៃស្ងប់ស្ងាត់ចាកមនុស្ស សមគួរដល់ការពួនសម្ងំ ។ មួយទៀត ព្រះនាមថា មានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានបច្ច័យភេសជ្ជបរិក្ខារ ។ មួយទៀត ព្រះនាមថា មានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃអត្ថរស ធម្មរស វិមុត្តិរស អធិសីល អធិចិត្ត អធិប្បញ្ញា ។ មួយទៀត ព្រះនាមថា មានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគទ្រង់មានភាគនៃឈាន ៤

## ទសមោ បុគ្គលភេទសុត្តនិទ្ទេសោ

ចតុន្នំ អប្បមញ្ញានំ ចតុន្នំ អរូបសមាបត្តីនន្តិ កតមា ។ កាមី វា កតមា អដ្ឋន្នំ វិមោក្ខានំ អដ្ឋន្នំ អភិភាយត-នានំ នវន្នំ អនុបុព្វវិហារសមាបត្តីនន្តិ កតមា ។ កាមី វា កតមា ទសន្នំ សញ្ញាភាវនានំ ទសន្នំ កសិណ-សមាបត្តីនំ អានាបានស្សតិសមាធិស្ស អសុភសមា-បត្តិយាតិ កតមា ។ កាមី វា កតមា ចតុន្នំ សតិប្បដ្ឋា-នានំ ចតុន្នំ សម្មប្បធានានំ ចតុន្នំ ឥទ្ធិបាទានំ បញ្ចន្នំ ឥន្ទ្រិយានំ បញ្ចន្នំ ពលានំ សត្តន្នំ ពោជ្ឈង្គានំ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្សាតិ កតមា ។ កាមី វា កតមា ទសន្នំ តថាគតពលានំ ចតុន្នំ វេសារជ្ជានំ ចតុន្នំ បដិសម្ភិទានំ ឆន្នំ អភិញ្ញានំ ឆន្នំ ពុទ្ធធម្មានន្តិ កតមា ។ កតមាតិ ជេតិ ជាមំ មាតរា កាមំ វ បិតរា កាមំ វ ភាតរា កាមំ វ ភគិនិយា កាមំ វ មិត្តាមច្ចេហិ កាមំ វ ញាតិសាលោ-ហិតេហិ កាមំ វ សមណព្រាហ្មណេហិ កាមំ វ ទេវ-តាហិ កាមំ វិមោក្ខន្តិកាមេតំ ពុទ្ធានំ កតវន្តានំ ពោធិយា មូលេ សហ សព្វញ្ញុតញ្ញាណស្ស បដិលាភា សច្ចិកា បញ្ញត្តិ យថាតំ កតមាតិ វីតតណ្ហោ បុគ្គលោ ហោតិ កតមា ។

## បុរាភេទសុត្តនិទ្ទេស ទី ១០

អប្បមញ្ញា ៤ អរូបសមាបត្តិ ៤ ។ មួយទៀត ព្រះនាមថា មានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃវិមោក្ខ ៨ អភិភាយតនៈ ៨ អនុបុព្វវិហារសមាបត្តិ ៩ ។ មួយទៀត ព្រះនាមថា មានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគទ្រង់មានភាគនៃសញ្ញាភាវនា ១០ កសិណសមាបត្តិ ១០ អានាបានស្សតិសមាធិ អសុភសមាបត្តិ ។ មួយទៀត ព្រះនាមថា មានព្រះភាគ ព្រោះហេតុ ព្រះមានព្រះភាគ ទ្រង់មានភាគនៃសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ។ មួយទៀត ព្រះនាមថា មានព្រះភាគ ព្រោះហេតុព្រះមានបុណ្យ ទ្រង់មានភាគនៃតថាគតពល ១០ វេសារជ្ជៈ ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ ពុទ្ធធម៌ ៦ ។ ព្រះនាមថា ព្រះមានព្រះភាគនេះ មិនមែនមាតាធ្វើ មិនមែនបិតាធ្វើ មិនមែនបងប្អូនប្រុសធ្វើ មិនមែនបងប្អូនស្រីធ្វើ មិនមែនពួកមិត្រអាមាត្យធ្វើ មិនមែនពួកញាតិសាលោហិតធ្វើ មិនមែនពួកសមណព្រាហ្មណ៍ធ្វើ មិនមែនពួកទេវតាធ្វើទេ ព្រះនាមថា មានព្រះភាគនុ៎ះ របស់ព្រះពុទ្ធទាំងឡាយ ដ៏មានព្រះភាគ ជាព្រះនាមកើតក្នុងទីបំផុតនៃវិមោក្ខ ការបញ្ញត្តិថា មានព្រះភាគ នុ៎ះ (កើតហើយ) អំពីការត្រាស់ដឹង ព្រមដោយការបានចំពោះនូវសព្វញ្ញុតញ្ញាណ ទៀបគល់ពោធិព្រឹក្ស ហេតុនោះ មានពាក្យថា ព្រះមានព្រះភាគ (ត្រាស់ហើយ) ថា មុនអំពីការបែកធ្លាយសរីរៈទៅ បុគ្គលណា ប្រាសចាកតណ្ហា ។

(២០) បុព្វមន្តមនិស្សិតោតិ បុព្វន្តោ វុច្ចតិ អតីតោ អទ្ធា ។ អតីតំ អទ្ធានំ អារព្ភ តណ្ហា បហីនា ហោតិ ទិដ្ឋិ បដិនិស្សដ្ឋា តណ្ហាយ បហីនត្តា ទិដ្ឋិយា បដិនិស្សដ្ឋត្តា ឯវម្បិ បុព្វន្តមនិស្សិតោ ។ អថវា ឯវំរូបោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ ន សមន្នានេតិ ឯវំវេទនោ អហោសឹ ឯវំសញ្ញោ អហោសឹ ឯវំសង្ខារោ អហោសឹ ឯវំវិញ្ញាណោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ ន សមន្នានេតិ ឯវម្បិ បុព្វមន្តមនិស្សិតោ ។ អថវា ឥតិ មេ ចក្ខុ អហោសិ អតីតមទ្ធានំ ឥតិ រូបាតិ តត្ថ ន ឆន្ទរាគប្បដិពទ្ធំ ហោតិ វិញ្ញាណំ ន ឆន្ទរាគប្បដិពទ្ធត្តា វិញ្ញាណស្ស ន តទភិនន្ទតិ ន តទភិនន្ទន្តោ ឯវម្បិ បុព្វន្តមនិស្សិតោ ។ ឥតិ មេ សោតំ អហោសិ អតីតមទ្ធានំ ឥតិ សទ្ទាតិ ឥតិ មេ ឃានំ អហោសិ អតីតមទ្ធានំ ឥតិ គន្ធាតិ ឥតិ មេ ជិវ្ហា អហោសិ

(៦០) ពាក្យថា មិនអាស្រ័យនូវកាលជាខាងដើម អធិប្បាយថា អតីតកាល លោកហៅថា កាលខាងដើម ។ បុគ្គលប្រារព្ធអតីតកាល ហើយលះបង់តណ្ហា រលាស់ចោលទិដ្ឋិ ព្រោះលះបង់តណ្ហា ព្រោះរលាស់ចោលទិដ្ឋិ ឈ្មោះថា មិនអាស្រ័យកាលខាងដើម យ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលមិនដល់នូវសេចក្តីរីករាយក្នុងរូបារម្មណ៍នោះថា អាត្មាអញមានរូបយ៉ាងនេះហើយក្នុងអតីតកាល មិនដល់នូវសេចក្តីរីករាយ ក្នុងអារម្មណ៍នោះថា អាត្មាអញមានវេទនាយ៉ាងនេះ មានសញ្ញាយ៉ាងនេះ មានសង្ខារយ៉ាងនេះ មានវិញ្ញាណយ៉ាងនេះ ក្នុងអតីតកាល ឈ្មោះថា មិនអាស្រ័យកាលខាងដើម យ៉ាងនេះខ្លះ ។ មួយទៀត វិញ្ញាណមិនជាប់ចំពាក់ដោយឆន្ទរាគក្នុងអារម្មណ៍ទាំងនោះថា ចក្ខុរបស់អាត្មាអញមានយ៉ាងនេះ រូបទាំងឡាយមានយ៉ាងនេះ ក្នុងអតីតកាល បុគ្គលមិនត្រេកអរចំពោះចក្ខុនិងរូបនោះ ព្រោះវិញ្ញាណមិនជាប់ចំពាក់ដោយឆន្ទរាគ អ្នកដែលមិនត្រេកអរក្នុងចក្ខុនិងរូបនោះ ឈ្មោះថា មិនអាស្រ័យកាលខាងដើម យ៉ាងនេះខ្លះ ។ វិញ្ញាណមិនជាប់ចំពាក់ដោយឆន្ទរាគ ក្នុងអារម្មណ៍ទាំងនោះថា សោតៈរបស់អញ មានយ៉ាងនេះ សំឡេងទាំងឡាយមានយ៉ាងនេះ ក្នុងអតីតកាល ថា ឃានៈរបស់អញមានយ៉ាងនេះ ក្លិនទាំងឡាយមានយ៉ាងនេះក្នុងអតីតកាល ថា ជិវ្ហារបស់អញមានយ៉ាងនេះ

ទសមោ បុរាភេទសុត្តនិទ្ទេសោ

អតីតមទ្ធានំ ឥតិ រសាតិ ឥតិ មេ កាយោ អហោសិ អតីតមទ្ធានំ ឥតិ ផោដ្ឋព្វាតិ ឥតិ មេ មនោ អហោសិ អតីតមទ្ធានំ ឥតិ ធម្មាតិ តត្ថ ន ឆន្ទរាគប្បដិពទ្ធំ ហោតិ វិញ្ញាណំ ន ឆន្ទរាគប្បដិពទ្ធត្តា វិញ្ញាណស្ស ន តទភិ-នន្ទតិ ន តទភិនន្ទន្តោ ឯវម្បិ បុព្វមន្តមនិស្សិតោ ។ អថវា យានស្សុ តានិ បុព្វេ មាតុគ្គាមេន សទ្ធឹ ហសិតលបិតកថិតកីឡិតានិ ន តទស្សាទេតិ ន តំ និកាមេតិ ន ច តេន វិត្តឹ អាបជ្ជតិ ឯវម្បិ បុព្វមន្ត-មនិស្សិតោ ។

(៦១) វេមជ្ឈេ នុបសង្ខេយ្យោតិ វេមជ្ឈំ វុច្ចតិ បច្ចុ-ប្បន្នោ អទ្ធា ។ បច្ចុប្បន្នំ អទ្ធានំ អារព្ភ តណ្ហា បហីនា ហោតិ ទិដ្ឋិ បដិនិស្សដ្ឋា តណ្ហាយ បហីនត្តា ទិដ្ឋិយា បដិនិស្សដ្ឋត្តា រត្តោតិ នុបសង្ខេយ្យោ ទុដ្ឋោតិ នុបសង្ខេ-យ្យោ មូឡ្ហោតិ នុបសង្ខេយ្យោ វិនិពទ្ធោតិ នុបសង្ខេយ្យោ បរាមដ្ឋោតិ នុបសង្ខេយ្យោ វិក្ខេបគតោតិ នុបសង្ខេយ្យោ អនិដ្ឋង្គតោតិ នុបសង្ខេយ្យោ ថាមគតោតិ នុបសង្ខេ-យ្យោ ។ តេ អភិសង្ខារា បហីនា អភិសង្ខារានំ បហីនត្តា

បុរាភេទសុត្តនិទ្ទេស ទី ១០

រសទាំងឡាយមានយ៉ាងនេះ ក្នុងអតីតកាល ថាកាយរបស់អញមានយ៉ាងនេះ ផោដ្ឋព្វៈមានយ៉ាងនេះ ក្នុងអតីតកាល ថាចិត្តរបស់អញមានយ៉ាងនេះ ធម្មារម្មណ៍មានយ៉ាងនេះ ក្នុងអតីតកាល បុគ្គលមិនត្រេកអរនឹងអារម្មណ៍ទាំងនោះ ព្រោះវិញ្ញាណមិនជាប់ចំពាក់ដោយឆន្ទរាគ អ្នកដែលមិនត្រេកអរនឹងអារម្មណ៍ទាំងនោះ ឈ្មោះថាមិនអាស្រ័យកាលខាងដើមយ៉ាងនេះខ្លះ ។ មួយទៀត ការសើច ការចរចា ការនិយាយ ការលេងជាមួយនឹងមាតុគ្រាម ក្នុងកាលពីដើមណា បុគ្គលមិនត្រេកអរនឹងការសើចជាដើមនោះ មិនប្រាថ្នានឹងការសើចជាដើមនោះ មិនដល់នូវសេចក្តីត្រេកអរនឹងការសើចជាដើមនោះ ឈ្មោះថាមិនអាស្រ័យកាលខាងដើម យ៉ាងនេះខ្លះ ។

(៦១) ពាក្យថា ជាអ្នកដែលគេមិនគួររាប់ក្នុងកាលជាកណ្តាល ការអធិប្បាយថា បច្ចុប្បន្នកាល លោកហៅថា កាលជាកណ្តាល ។ បុគ្គលប្រារព្ធបច្ចុប្បន្នកាលហើយលះបង់តណ្ហា លះបង់ទិដ្ឋិ ព្រោះលះបង់តណ្ហា ព្រោះលះបង់ទិដ្ឋិ ទើបគេមិនគួររាប់ថា ជាអ្នកត្រេកអរ មិនគួររាប់ថា ជាអ្នកប្រទូស្ត មិនគួររាប់ថា ជាអ្នកវង្វេង មិនគួររាប់ថា ជាអ្នកជាប់ចំពាក់ មិនគួររាប់ថា ជាអ្នកស្ទាបអង្អែល មិនគួររាប់ថា ជាអ្នកដល់នូវសេចក្តីរាយមាយ មិនគួររាប់ថា ជាអ្នកដល់នូវសេចក្តីមិនដាច់ស្រេច មិនគួររាប់ថា ជាអ្នកដល់នូវកំឡាំង ។ អភិសង្ខារទាំងនោះ បុគ្គលនោះលះបង់ហើយ ព្រោះលះបង់អភិសង្ខារទាំងឡាយ

គតិយា ឧបសង្ខេយ្យោ នេរយិកោតិ វា តិរច្ឆានយោនិកោតិ វា បេត្តិវិសយិកោតិ វា មនុស្សោតិ វា ទេវោតិ វា រូបីតិ វា អរូបីតិ វា សញ្ញីតិ វា អសញ្ញីតិ វា នេវសញ្ញីនាសញ្ញីតិ វា ។ សោ ហេតុ នត្ថិ បច្ចយោ នត្ថិ ការណំ នត្ថិ យេន សង្ខំ គច្ឆេយ្យាតិ វេមជ្ឈេ នុបសង្ខេយ្យោ ។

(៦២) តស្ស នត្ថិ បុរេក្ខតន្តិ តស្សាតិ អរហតោ ខីណាសវស្ស ។ បុរេក្ខារាតិ ទ្វេ បុរេក្ខារា តណ្ហាបុរេក្ខារោ ច ទិដ្ឋិបុរេក្ខារោ ច ។បេ។ អយំ តណ្ហាបុរេក្ខារោ ។បេ។ អយំ ទិដ្ឋិបុរេក្ខារោ ។ តស្ស តណ្ហាបុរេក្ខារោ បហីនោ ទិដ្ឋិបុរេក្ខារោ បដិនិស្សដ្ឋោ តណ្ហាបុរេក្ខារស្ស បហីនត្តា ទិដ្ឋិបុរេក្ខារស្ស បដិនិស្សដ្ឋត្តា ន តណ្ហំ វា ទិដ្ឋឹ វា បុរតោ កត្វា ចរតិ ន តណ្ហាធជោ ន តណ្ហាកេតុ ន តណ្ហាធិបតេយ្យោ ន ទិដ្ឋិធជោ ន ទិដ្ឋិកេតុ ន ទិដ្ឋាធិបតេយ្យោ ន តណ្ហាយ វា ទិដ្ឋិយា វា

បុគ្គលនោះ ទើបគេមិនគួរពោលដោយគតិថា ជាអ្នកកើតក្នុងនរក ឬថាជាអ្នកកើតក្នុងកំណើតតិរច្ឆាន ថាជាអ្នកកើតក្នុងបិត្តិវិស័យ ថាជាមនុស្ស ថាជាទេវតា ថាជារូបព្រហ្ម ថាជាអរូបព្រហ្ម ថាជាសញ្ញីសត្វ ថាជាអសញ្ញីសត្វ ឬថាជានេវសញ្ញីនាសញ្ញីសត្វ ។ បុគ្គលដល់នូវការពោល ដោយហេតុណា ហេតុនោះ មិនមាន បច្ច័យមិនមាន ការណ៍មិនមាន ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកដែលគេមិនគួរពោលក្នុងកាលជាកណ្តាល ។

(៦៦) អធិប្បាយពាក្យថា ភាពនៃការធ្វើឲ្យជាប្រធាននៃបុគ្គលនោះមិនមានទេ ត្រង់ពាក្យថា បុគ្គលនោះ បានដល់ព្រះអរហន្តខីណាស្រព ។ ពាក្យថា ការធ្វើឲ្យជាប្រធាន បានដល់ ការធ្វើឲ្យជាប្រធានពីរ គឺ ការធ្វើឲ្យជាប្រធានគឺតណ្ហា ១ ការធ្វើឲ្យជាប្រធានគឺទិដ្ឋិ ១ ។ បេ ។ នេះ ការធ្វើឲ្យជាប្រធានគឺតណ្ហា ។ បេ ។ នេះ ការធ្វើឲ្យជាប្រធានគឺទិដ្ឋិ ។ ការធ្វើឲ្យជាប្រធានគឺតណ្ហា បុគ្គលនោះលះបង់ហើយ ការធ្វើឲ្យជាប្រធានគឺទិដ្ឋិ បុគ្គលនោះរលាស់ចោលហើយ ព្រោះលះបង់ការធ្វើឲ្យជាប្រធានគឺតណ្ហា ព្រោះរលាស់ចោលការធ្វើឲ្យជាប្រធានគឺទិដ្ឋិ (បុគ្គលនោះ) មិនប្រព្រឹត្តធ្វើនូវតណ្ហាឬទិដ្ឋិ ឲ្យជាប្រធាន ជាអ្នកមិនមានទង់ជ័យគឺតណ្ហា មិនមានទង់គឺតណ្ហា មិនមានតណ្ហាជាអធិបតេយ្យ មិនមានទង់ជ័យគឺទិដ្ឋិ មិនមានទង់គឺទិដ្ឋិ មិនមានទិដ្ឋិជាអធិបតេយ្យ មិនត្រូវតណ្ហាឬទិដ្ឋិ

បរិភវតោ ចរតីតិ យស្មា តស្ស នត្ថិ បុរេក្ខតំ ។ អថវា ឯវំរូបោ សិយំ អនាគតមទ្ធានន្តិ តត្ថ នន្ទឹ ន សមន្វានេតិ ឯវំវេទនោ សិយំ ឯវំសញ្ញោ សិយំ ឯវំសង្ខារោ សិយំ ឯវំវិញ្ញាណោ សិយំ អនាគតមទ្ធានន្តិ តត្ថ នន្ទឹ ន សមន្វានេតិ យស្មា តស្ស នត្ថិ បុរេក្ខតំ ។ អថវា ឥតិ មេ ចក្ខុ សិយា អនាគតមទ្ធានំ ឥតិ រូបាតិ អប្បដិលទ្ធស្ស បដិលាភាយ ចិត្តំ ន បណិទហាតិ ចេតសោ អប្បណិធានប្បច្ចយា ន តទភិនន្ទតិ ន តទភិនន្ទន្តោ យស្មា តស្ស នត្ថិ បុរេក្ខតំ ។ ឥតិ មេ សោតំ សិយា អនាគតមទ្ធានំ ឥតិ សទ្ទាតិ ឥតិ មេ ឃានំ សិយា អនាគតមទ្ធានំ ឥតិ គន្ធាតិ ឥតិ មេ ជិវ្ហា សិយា អនាគតមទ្ធានំ ឥតិ រសាតិ ឥតិ មេ កាយោ សិយា

បុរាភេទសុត្តនិទ្ទេស ទី ១០

ប្រព្រឹត្តព័ទ្ធទៅឡោមឡើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ភាពនៃការធ្វើឲ្យជាប្រធាននៃបុគ្គលនោះមិនមាន យ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលនោះមិនដល់នូវសេចក្ដីត្រេកអរ ក្នុងបុរារម្មណ៍នោះថា អាត្មាអញសូមមានរូបយ៉ាងនេះ ក្នុងអនាគតកាល មិនដល់នូវសេចក្ដីត្រេកអរ ក្នុងអារម្មណ៍ទាំងនោះថា អាត្មាអញសូមមានវេទនាយ៉ាងនេះ សូមមានសញ្ញាយ៉ាងនេះ សូមមានសង្ខារយ៉ាងនេះ សូមមានវិញ្ញាណយ៉ាងនេះ ក្នុងអនាគតកាល ភាពនៃការធ្វើឲ្យជាប្រធាន នៃបុគ្គលនោះមិនមាន យ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលនោះមិនដំកល់ចិត្ត ដើម្បីបាននូវអារម្មណ៍ ដែលមិនទាន់បានថា ចក្ខុរបស់អញ សូមមានយ៉ាងនេះ រូបទាំងឡាយសូមមានយ៉ាងនេះ ក្នុងអនាគតកាល បុគ្គលនោះ មិនត្រេកអរក្នុងចក្ខុនិងរូបនោះ ព្រោះការមិនដំកល់ចិត្តជាបច្ច័យ កាលមិនត្រេកអរចំពោះចក្ខុនិងរូបនោះ ភាពនៃការធ្វើឲ្យជាប្រធាន នៃបុគ្គលនោះមិនមាន យ៉ាងនេះខ្លះ ។ បុគ្គលមិនដំកល់ចិត្តដើម្បីបាននូវអារម្មណ៍ ដែលខ្លួនមិនទាន់បានថា សោតៈរបស់អញ សូមមានយ៉ាងនេះ សំឡេងទាំងឡាយសូមមានយ៉ាងនេះ ក្នុងអនាគតកាល ថា ឃានៈរបស់អញ សូមមានយ៉ាងនេះ គន្ធៈទាំងឡាយសូមមានយ៉ាងនេះ ក្នុងអនាគតកាល ថា ជិវ្ហារបស់អញ សូមមានយ៉ាងនេះ រសទាំងឡាយសូមមានយ៉ាងនេះ ក្នុងអនាគតកាល ថា កាយរបស់អញសូមមានយ៉ាងនេះ

អនាគតមទ្ធានំ ឥតិ ផោដ្ឋព្វាតិ ឥតិ មេ មនោ សិយា អនាគតមទ្ធានំ ឥតិ ធម្មាតិ អប្បដិលទ្ធស្ស បដិលាភាយ ចិត្តំ ន បណិទហតិ ចេតសោ អប្បណិធានប្បច្ចយា ន តទភិនន្ទតិ ន តទភិនន្ទេន្តោ ឯវម្បិ តស្ស នត្ថិ បុរេក្ខតំ ។ អថវា ឥមិនាហំ សីលេន វា វតេន វា តបេន វា ព្រហ្មចរិយេន វា ទេវោ វា ភវិស្សាមិ ទេវញ្ញតរោ វាតិ អប្បដិលទ្ធស្ស បដិលាភាយ ចិត្តំ ន បណិទហតិ ចេតសោ អប្បណិធានប្បច្ចយា ន តទភិនន្ទតិ ន តទភិនន្ទេន្តោ ឯវម្បិ តស្ស នត្ថិ បុរេក្ខតំ ។ តេនាហ ភគវា

វីតតណ្ហោ បុរា ភេទា បុព្វមន្តមនិស្សិតោ
វេមជ្ឈេ នុបសង្ខេយ្យោ តស្ស នត្ថិ បុរេក្ខតន្តិ ។

(៦៣) អក្កោធនោ អសន្តាសី អវិកត្ថី អកុក្កុចោ
មន្តភាណី អនុទ្ធតោ ស វេ វាចាយតោ មុនិ ។

ដោយឆន្ទៈទាំងឡាយសូមមានយ៉ាងនេះ ក្នុងអនាគតកាល ថា ចិត្តរបស់អញ សូមមានយ៉ាងនេះ ធម្មារម្មណ៍ទាំងឡាយ សូមមានយ៉ាងនេះ ក្នុងអនាគតកាល បុគ្គលនោះមិនត្រេកអរចំពោះអារម្មណ៍ទាំងនោះ ព្រោះការមិនដំកល់ចិត្តជាបច្ច័យ កាលមិនត្រេកអរចំពោះអារម្មណ៍ទាំងនោះ ភាពនៃការធ្វើឲ្យជាប្រធាននៃបុគ្គលនោះ មិនមាន យ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលមិនដំកល់ចិត្ត ដើម្បីបាននូវអារម្មណ៍ដែលមិនទាន់បានថា អាត្មាអញសូមឲ្យបានជាទេវតា ឬជាទេវតាណាមួយ ដោយសីល ឬដោយវត្ត ឬដោយតបៈ ឬក៏ដោយព្រហ្មចរិយៈនេះ បុគ្គលនោះមិនត្រេកអរចំពោះអារម្មណ៍ទាំងនោះ ព្រោះការមិនដំកល់ចិត្តជាបច្ច័យ កាលមិនត្រេកអរចំពោះអារម្មណ៍ទាំងនោះ ភាពនៃការធ្វើឲ្យជាប្រធាននៃបុគ្គលនោះ មិនមាន យ៉ាងនេះខ្លះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

មុនអំពីការបែកធ្លាយសរីរៈទៅ បុគ្គលណាប្រាសចាកតណ្ហា
មិនអាស្រ័យកាលខាងដើម ជាអ្នកដែលគេមិនគួររាប់ក្នុងកាល
ជាកណ្តាលទេ ភាពនៃការធ្វើឲ្យជាប្រធាន នៃបុគ្គលនោះ
មិនមានឡើយ ។

(៦៣) បុគ្គលអ្នកមិនក្រោធ អ្នកមិនតក់ស្លុត អ្នកមិនអួតអាង
អ្នកមិនមានកុក្កុច្ចៈ អ្នកពោលដោយការដឹង អ្នកមិនរាយមាយ
បុគ្គលអ្នកសង្រួមវាចានោះឯង ឈ្មោះថា មុនិ ។

ទសមោ បុរាភេទសុត្តនិទ្ទេសោ

[៦៤] អក្កោធនោ អនុបនាហីតិ អក្កោធនោតិ ហិ(១) ខោ វុត្តំ ។ អបិច កោធោ តាវ វត្តព្វោ ។ ទសហាការេហិ កោធោ ជាយតិ អនត្ថំ មេ អចរីតិ(២) កោធោ ជាយតិ អនត្ថំ មេ ចរតីតិ កោធោ ជាយតិ អនត្ថំ មេ ចរិស្សតីតិ កោធោ ជាយតិ បិយស្ស មេ មនាបស្ស អនត្ថំ អចរីតិ (៣)អនត្ថំ ចរតីតិ(៤) អនត្ថំ ចរិស្សតីតិ(៥) អប្បិយស្ស មេ អមនាបស្ស អត្ថំ អចរីតិ(៦) អត្ថំ ចរតីតិ(៧) អប្បិយស្ស មេ អមនាបស្ស(៨) អត្ថំ ចរិស្សតីតិ កោធោ ជាយតិ អដ្ឋានេ វា បន កោធោ ជាយតិ ។ យោ ឯវរូបោ ចិត្តស្ស អាឃាតោ បដិឃាតោ បដិឃំ បដិវិរោធោ កោបោ បកោបោ សម្បកោបោ ទោសោ បទោសោ សម្បទោសោ ចិត្តស្ស ព្យាបត្តិ មនោបទោសោ កោធោ កុជ្ឈនា កុជ្ឈិតត្តំ ទោសោ ទុស្សនា ទុស្សិតត្តំ

---

១ ម. យំ ហិ ។ ២ ឱ. ចរីតិ ។ ៣ ម. អចរិ ។ ៤ ម. ចរតិ ។ ៥ ឱ. ម. ចរិស្សតីតិ កោធោ ជាយតិ ។ ៦ ម. អចរិ ។ ៧ ម. ចរតិ ។ ៨ ម. អប្បិយស្ស មេ អមនាបស្សាតិ ឥ ទិស្សន្តិ ។

## បុកភេទសុត្តនិទ្ទេស ទី ១០

(៦៤) អធិប្បាយពាក្យថា បុគ្គលអ្នកមិនក្រោធ អ្នកមិនតក់ស្លុត ត្រង់ពាក្យថា បុគ្គលអ្នកមិនក្រោធ ជាពាក្យដែលព្រះមានព្រះភាគត្រាស់ ហើយក៏ពិតមែន ៗ តែសេចក្ដីក្រោធ យើងគប្បីពោលមុន ៗ សេចក្ដីក្រោធកើតដោយអាការៈ ១០ យ៉ាង គឺក្រោធកើតព្រោះគិតថា គេបានប្រព្រឹត្តហើយ នូវសេចក្ដីវិនាសដល់អញ ១ ក្រោធកើតព្រោះគិតថា គេកំពុងប្រព្រឹត្តនូវសេចក្ដីវិនាសដល់អញ ១ ក្រោធកើតព្រោះគិតថា គេនឹងប្រព្រឹត្តនូវសេចក្ដីវិនាសដល់អញ ១ ក្រោធកើតព្រោះគិតថា គេបានប្រព្រឹត្តហើយនូវសេចក្ដីវិនាស ១ ថាគេកំពុងប្រព្រឹត្តនូវសេចក្ដីវិនាស ១ ថាគេនឹងប្រព្រឹត្តនូវសេចក្ដីវិនាស ១ ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អញ ក្រោធកើតព្រោះគិតថា គេបានប្រព្រឹត្តហើយនូវសេចក្ដីចំរើន ១ ថាគេកំពុងប្រព្រឹត្តនូវសេចក្ដីចំរើន ១ ថាគេនឹងប្រព្រឹត្តនូវសេចក្ដីចំរើន ១ ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អញ មួយទៀត ក្រោធកើតក្នុងអំពើមិនជាហេតុ ១ (គ្រប់ជា ១០) ៗ សេចក្ដីគុំគួននៃចិត្ត សេចក្ដីបង្អៀតបង្អល់ សេចក្ដីតានតឹង សេចក្ដីថ្នាំងថ្នាក់ សេចក្ដីខឹង សេចក្ដីខឹងខ្លាំង សេចក្ដីខឹងក្រៃលែង សេចក្ដីប្រទូស្ត សេចក្ដីប្រទូស្តខ្លាំង សេចក្ដីប្រទូស្តក្រៃលែង ការព្យាបាទនៃចិត្ត ការប្រទូស្តក្នុងចិត្ត ក្រោធ អាការក្រោធ សេចក្ដីក្រោធ ការប្រទូស្ត អាការប្រទូស្ត សេចក្ដីប្រទូស្ត

ព្យាបត្តិ ព្យាបជ្ជនា ព្យាបជ្ជិតត្តំ វិរោធោ បដិវិរោធោ ចណ្ឌិក្កំ អស្សុរោបោ(១) អនត្តមនតា ចិត្តស្ស អយំ វុច្ចតិ កោធោ ។ អបិច កោធស្ស អធិមត្តបរិត្តតា វេទិតព្វា ។ អត្ថិ កញ្ចិ កាលំ កោធោ ចិត្តាវិលករណមត្តោ ហោតិ ន ច តាវ មុខកុលានវិកុលានោ ហោតិ ។ អត្ថិ កញ្ចិ កាលំ កោធោ មុខកុលានវិកុលានមត្តោ ហោតិ ន ច តាវ ហនុសញ្ចោបនោ ហោតិ អត្ថិ កញ្ចិ កាលំ កោធោ ហនុសញ្ចោបនមត្តោ ហោតិ ន ច តាវ ផរុសវាចនិច្ឆារណោ ហោតិ ។ អត្ថិ កញ្ចិ កាលំ កោធោ ផរុសវាចនិច្ឆារណមត្តោ ហោតិ ន ច តាវ ទិសាវិទិសំ អនុវិលោកនោ ហោតិ ។ អត្ថិ កញ្ចិ កាលំ កោធោ ទិសាវិទិសំ អនុវិលោកនមត្តោ ហោតិ ន ច តាវ ទណ្ឌសត្ថបរាមសនោ ហោតិ ។ អត្ថិ កញ្ចិ កាលំ កោធោ ទណ្ឌសត្ថបរាមសនមត្តោ ហោតិ

---

១ អសុរោបោតិ អដ្ឋកថាយំ ទិស្សតិ ។ ន ឯតេន សុរោបិតំ វចនំ ហោតិ ទុរុត្តំ អបរិបុណ្ណមេវ ហោតីតិ អសុរោបោ ។

ការព្យាបាទ អាការព្យាបាទ សេចក្តីព្យាបាទ សេចក្តីខឹង សេចក្តីខឹងតប ការកាច ការសម្រក់ទឹកភ្នែក សេចក្តីមិនត្រេកអរនៃចិត្ត ណាមានសភាពយ៉ាងនេះ នេះ លោកហៅថា សេចក្តីក្រោធ ។ មួយទៀត បណ្ឌិតគប្បីជ្រាប សេចក្តីក្រោធខ្លាំងនិងតិច ។ ជួនកាល សេចក្តីក្រោធគ្រាន់តែធ្វើចិត្តឲ្យល្អក់ប៉ុណ្ណោះ តែមិនទាន់ធ្វើមុខ ឲ្យកញ្ចុបកញ្ចូរនៅឡើយ ក៏មាន ។ ជួនកាល សេចក្តីក្រោធ គ្រាន់តែធ្វើមុខឲ្យកញ្ចុបកញ្ចូរប៉ុណ្ណោះ តែមិនទាន់ធ្វើចង្កាឲ្យញាក់ញ័រនៅឡើយ ក៏មាន ។ ជួនកាល សេចក្តីក្រោធគ្រាន់តែធ្វើចង្កាឲ្យញាក់ញ័រប៉ុណ្ណោះ តែមិនទាន់បញ្ចេញសំដីអាក្រក់នៅឡើយ ក៏មាន ។ ជួនកាល សេចក្តីក្រោធ គ្រាន់តែបញ្ចេញសំដីអាក្រក់ប៉ុណ្ណោះ តែមិនទាន់ក្រឡេកមើលរឿយ ៗ នូវទិសធំនិងទិសតូចនៅឡើយ ក៏មាន ។ ជួនកាល សេចក្តីក្រោធ គ្រាន់តែក្រឡេកមើលរឿយ ៗ នូវទិសធំនិងទិសតូចប៉ុណ្ណោះ

## ទសមោ បុកភេទសុត្តនិទ្ទេសោ

ន ច តាវ ទណ្ឌសត្ថអព្ភុក្កិរណោ ហោតិ ។ អត្ថិ កាញ្ចិ កាលំ កោធោ ទណ្ឌសត្ថអព្ភុក្កិរណមត្តោ ហោតិ ន ច តាវ ទណ្ឌសត្ថអភិនិបាតនោ ហោតិ ។ អត្ថិ កាញ្ចិ កាលំ កោធោ ទណ្ឌសត្ថអភិនិបាតនមត្តោ ហោតិ ន ច តាវ ឆិន្នវិច្ឆិន្នករណោ ហោតិ ។ អត្ថិ កាញ្ចិ កាលំ កោធោ ឆិន្នវិច្ឆិន្នករណមត្តោ ហោតិ ន ច តាវ សម្ភញ្ជនបរិភញ្ជនោ ហោតិ ។ អត្ថិ កាញ្ចិ កាលំ កោធោ សម្ភញ្ជនបរិភញ្ជនមត្តោ ហោតិ ន ច តាវ អង្គមង្គាបកឌ្ឍនោ ហោតិ ។ អត្ថិ កាញ្ចិ កាលំ កោធោ អង្គមង្គាបកឌ្ឍនមត្តោ ហោតិ ន ច តាវ ជីវិតបនាសនោ(១) ហោតិ ។ អត្ថិ កាញ្ចិ កាលំ កោធោ ជីវិតបនាសនមត្តោ(២) ហោតិ ន ច តាវ សព្វចាគបរិច្ចាគសណ្ឋិតោ(៣) ហោតិ ។ យតោ កោធោ បរបុគ្គលំ ឃាតេត្វា អត្តានំ ឃាតេតិ ឯត្តាវតា កោធោ បរមុស្សទគតោ បរមវេបុល្លប្បត្តោ ហោតិ ។

---

១ ម. ជីវិតាវោរោបនោ ។ ២ ម. ជីវិតាវោរោបនមត្តោ ។ ៣ ម. សព្វចាគបរិច្ចាគាយ សណ្ឋិតោ ។ អដ្ឋកថាយំ សព្វង្គបរិច្ចាគាយ ។

## បុរាភេទសុត្តនិទ្ទេស ទី ១០

តែមិនទាន់ចាប់ដំបងនឹងសស្ត្រានៅឡើយក៏មាន ។ ជួនកាលសេចក្តីក្រោធគ្រាន់តែចាប់ដំបងនឹងសស្ត្រាប៉ុណ្ណោះ តែមិនទាន់យារដំបងនឹងសស្ត្រានៅឡើយក៏មាន ។ ជួនកាល សេចក្តីក្រោធ គ្រាន់តែយារដំបងនឹងសស្ត្រាប៉ុណ្ណោះ តែមិនទាន់ពោលព្ទួយដំបងនឹងសស្ត្រាតម្រង់ទៅឡើយក៏មាន ។ ជួនកាលសេចក្តីក្រោធ គ្រាន់តែបោលព្ទួយដំបងនឹងសស្ត្រាតម្រង់ប៉ុណ្ណោះ តែមិនទាន់ធ្វើឲ្យដាច់មុតនៅឡើយក៏មាន ។ ជួនកាលសេចក្តីក្រោធ គ្រាន់តែធ្វើឲ្យដាច់មុតប៉ុណ្ណោះ តែមិនទាន់ធ្វើឲ្យបាក់បែកនៅឡើយក៏មាន ។ ជួនកាល សេចក្តីក្រោធ គ្រាន់តែធ្វើឲ្យបាក់បែកប៉ុណ្ណោះ តែមិនទាន់ទាញចេញនូវ អវយវៈតូចនឹងអវយវៈធំនៅឡើយ ក៏មាន ។ ជួនកាល សេចក្តីក្រោធ គ្រាន់តែទាញចេញ នូវអវយវៈតូចនឹងអវយវៈធំប៉ុណ្ណោះ តែមិនទាន់ផ្តាច់បង់ជីវិតនៅឡើយ ក៏មាន ។ ជួនកាល សេចក្តីក្រោធ គ្រាន់តែផ្តាច់បង់ជីវិតប៉ុណ្ណោះ តែមិនទាន់តាំងនៅ ដើម្បីផ្តាច់បង់ជីវិតទាំងពួង ( របស់អ្នកដទៃ នឹងរបស់ខ្លួន ) នៅឡើយក៏មាន ។ សេចក្តីក្រោធសំឡាប់បុគ្គលដទៃ ហើយទើបសំឡាប់ខ្លួន ក្នុងកាលណា កាលណោះ សេចក្តីក្រោធ ឈ្មោះថា ដល់នូវការក្រាសឡើងដ៏ក្រៃលែង ដល់នូវសេចក្តីទូលំទូលាយក្រៃលែង ដោយហេតុមានប្រមាណប៉ុណ្ណេះ ។

យស្ស សោ កោធោ បហីនោ សមុច្ឆិន្នោ វូបសន្តោ បដិប្បស្សទ្ធោ អភព្វុប្បត្តិកោ ញាណគ្គិនា ទឌ្ឍោ សោ វុច្ចតិ អក្កោធនោ ។ កោធស្ស បហីនត្តា អក្កោធនោ កោធវត្ថុស្ស បរិញ្ញាតត្តា អក្កោធនោ កោធហេតុស្ស ឧបច្ឆិន្នត្តា អក្កោធនោតិ អក្កោធនោ ។

(២៨) អសន្តាសីតិ ឥធេកច្ចោ តាសី ហោតិ ឧត្តាសី បរិត្តាសី ។ សោ តសតិ ឧត្តសតិ បរិត្តសតិ ភាយតិ សន្តាសំ អាបជ្ជតិ កុលំ វា ន លភាមិ គណំ វា ន លភាមិ អាវាសំ វា ន លភាមិ លាភំ វា ន លភាមិ យសំ វា ន លភាមិ បសំសំ វា ន លភាមិ សុខំ វា ន លភាមិ ចីវរំ វា ន លភាមិ បិណ្ឌបាតំ វា ន លភាមិ សេនាសនំ វា ន លភាមិ គិលានប្បច្ចយភេសជ្ជបរិក្ខារំ វា ន លភាមិ គិលានុបដ្ឋាកំ វា ន លភាមិ អប្បញ្ញាតោម្ហីតិ តសតិ ឧត្តសតិ បរិត្តសតិ ភាយតិ សន្តាសំ អាបជ្ជតិ ។

សេចក្ដីក្រោធនេះ បុគ្គលណាលះបង់ហើយ ផ្ដាច់បង់ហើយ រម្ងាប់ហើយ រម្ងាប់ហើយ គ្របសង្កត់ហើយ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះគេហៅថា អ្នកមិនក្រោធ ។ បុគ្គលឈ្មោះថា អ្នកមិនក្រោធ ព្រោះលះបង់ក្រោធ ឈ្មោះថា អ្នកមិនក្រោធ ព្រោះកំណត់ដឹងនូវវត្ថុក្រោធ ឈ្មោះថា អ្នកមិនក្រោធ ព្រោះផ្ដាច់ផ្ដិលនូវហេតុនៃក្រោធ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមិនក្រោធ ។

(៦៥) ពាក្យថា អ្នកមិនតក់ស្លុត អធិប្បាយថា បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកតក់ស្លុត តក់ស្លុតខ្លាំង តក់ស្លុតក្រៃលែង ។ បុគ្គលនោះ តក់ស្លុត តក់សុតខ្លាំង តក់ស្លុតក្រៃលែង ខ្លាចដល់នូវសេចក្ដីតក់ស្លុតថា អញមិនបានត្រកូល ឬមិនបានពួក ឬមិនបានអាវាស ឬមិនបានលាភ ឬមិនបានយស ឬមិនបានសេចក្ដីសរសើរ ឬមិនបានសុខ ឬមិនបានចីវរ ឬមិនបានបិណ្ឌបាត ឬមិនបានសេនាសនៈ ឬមិនបានគិលានប្បច្ច័យភេសជ្ជបរិក្ខារ ឬមិនបានគិលានុបដ្ឋាកបុគ្គល អញជាអ្នកមិនល្បីល្បាញ ក៏តក់ស្លុត តក់ស្លុតខ្លាំង តក់ស្លុតក្រៃលែង ខ្លាច ដល់នូវសេចក្ដីតក់ស្លុត ។

## ទសមោ បុរាភេទសុត្តនិទ្ទេសោ

ឥធ ភិក្ខុ អសន្តាសី ហោតិ អនុត្តាសី អបរិត្តាសី ។ សោ ន តសតិ ន ឧត្តសតិ ន បរិត្តសតិ ន ភាយតិ ន សន្តាសំ អាបជ្ជតិ កុលំ វា ន លភាមិ គណំ វា ន លភាមិ អាវាសំ វា ន លភាមិ លាភំ វា ន លភាមិ យសំ វា ន លភាមិ បសំសំ វា ន លភាមិ សុខំ វា ន លភាមិ ចីវរំ វា ន លភាមិ បិណ្ឌបាតំ វា ន លភាមិ សេនាសនំ វា ន លភាមិ គិលានប្បច្ចយភេសជ្ជបរិក្ខារំ វា ន លភាមិ គិលានុបដ្ឋាកំ វា ន លភាមិ អប្បញ្ញាតោម្ហីតិ ន តសតិ ន ឧត្តសតិ ន បរិត្តសតិ ន ភាយតិ ន សន្តាសំ អាបជ្ជតីតិ អក្កោធនោ អសន្តាសី ។

(៦៦) អវិកត្ថី អកុក្កុច្ចោតិ ឥធេកច្ចោ កត្ថី ហោតិ វិកត្ថី ។ សោ កត្ថតិ វិកត្ថតិ អហមស្មិ សីលសម្បន្នោតិ វា វត្តសម្បន្នោតិ វា សីលវត្តសម្បន្នោតិ វា ជាតិយា វា គោត្តេន វា កោលបុត្តិកេន វា វណ្ណបោក្ខរតាយ វា ធនេន វា អជ្ឈេនេន វា កម្មាយតនេន វា សិប្បាយតនេន វា វិជ្ជដ្ឋានេន វា សុតេន វា បដិភានេន វា អញ្ញតរញ្ញតរេន វា វត្ថុនា

បុរាភេទសុត្តនិទ្ទេស ទី ១០

ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនតក់ស្លុត មិនតក់ស្លុតខ្លាំង មិនតក់ស្លុតក្រៃលែង ។ លោកមិនតក់ស្លុត មិនតក់ស្លុតខ្លាំង មិនតក់ស្លុតក្រៃលែង មិនខ្លាប មិនដល់នូវសេចក្តីតក់ស្លុត ថា អញមិនបានត្រកូល ឬមិនបានពួក ឬមិនបានអាវាស ឬមិនបានលាភ ឬមិនបានយស ឬមិនបានសេចក្តីសរសើរ ឬមិនបានសុខ ឬមិនបានចីវរ ឬមិនបានបិណ្ឌបាត ឬមិនបានសេនាសនៈ ឬមិនបានគិលានប្បច្ចយ-ភេសជ្ជបរិក្ខារ ឬមិនបានគិលានុបដ្ឋាកបុគ្គល អញជាអ្នកមិនល្បីល្បាញក៏មិនតក់ស្លុត មិនតក់ស្លុតខ្លាំង មិនតក់ស្លុតក្រៃលែង មិនខ្លាប មិនដល់នូវសេចក្តីតក់ស្លុត ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមិនក្រោធ អ្នកមិនតក់ស្លុត ។

(៦៦) ពាក្យថា អ្នកមិនអួតអាង អ្នកមិនមានកុក្កុច្ចៈ អធិប្បាយថា បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកអួតអាង អួតអាងផ្សេងៗ ។ បុគ្គលនោះ រមែងអួតអាង អួតអាងផ្សេងៗថា អញជាអ្នកបរិបូណ៌ដោយសីលក្តី ថាជាអ្នកបរិបូណ៌ដោយវត្តក្តី ថាជាអ្នកបរិបូណ៌ដោយសីលនឹងវត្តក្តី ដោយជាតិក្តី ដោយគោត្រក្តី ដោយភាពនៃខ្លួនជាកូននៃត្រកូលក្តី ដោយភាពនៃខ្លួនមានសម្បុរល្អក្តី ដោយទ្រព្យក្តី ដោយការស្វាធ្យាយន៍ក្តី ដោយការងារក្តី ដោយសិប្បៈក្តី ដោយថ្នាក់នៃវិជ្ជាក្តី ដោយសុតៈក្តី ដោយបដិភាណក្តី ដោយវត្ថុណាមួយក្តី

ឧច្ចាកុលា បព្វជិតោតិ វា មហាកុលា បព្វជិតោតិ វា មហាភោគកុលា បព្វជិតោតិ វា ឧឡារភោគកុលា បព្វជិតោតិ វា ញាតោ យសស្សី គហដ្ឋបព្វជិតានន្តិ វា លាភិម្ហិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ វា សុត្តន្តិកោតិ វា វិនយធរោតិ វា ធម្មកថិកោតិ វា អារញ្ញិកោតិ វា បិណ្ឌបាតិកោតិ វា បំសុកូលិកោតិ វា តេចីវរិកោតិ វា សបទានចារិកោតិ វា ខលុបច្ឆាភត្តិកោតិ វា នេសជ្ជិកោតិ វា យថាសន្ថតិកោតិ វា បឋមស្ស ឈានស្ស លាភីតិ វា ទុតិយស្ស ឈានស្ស លាភីតិ វា តតិយស្ស ឈានស្ស លាភីតិ វា ចតុត្ថស្ស ឈានស្ស លាភីតិ វា អាកាសានញ្ចាយតនសមាបត្តិយា វិញ្ញាណញ្ចាយតនសមាបត្តិយា អាកិញ្ចញ្ញាយតនសមាបត្តិយា នេវសញ្ញានាសញ្ញាយតនសមាបត្តិយា លាភីតិ វា កត្ថតិ វិកត្ថតិ ។ ឯវំ ន កត្ថតិ ន វិកត្ថតិ ។ កត្ថនា អារតោ វិរតោ បដិវិរតោ និក្ខន្តោ និស្សដោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ អវិកត្ថី ។

ជាអ្នក (ចេញ) អំពីត្រកូលខ្ពស់ ហើយបួសក្តី ថាជាអ្នកចេញអំពីត្រកូលធំហើយបួសក្តី (ចេញ) អំពីត្រកូលមានភោគដ៏ច្រើនហើយបួសក្តី ថាជាអ្នកចេញអំពីត្រកូលមានភោគៈដ៏លើសលុបហើយបួសក្តី ថា អញជាអ្នកល្បីល្បាញ មានយសជាងពួកគ្រហស្ថនិងបព្វជិតក្តី ថាជាអ្នកបានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារក្តី ថាជាអ្នកចេះព្រះសូត្រក្តី ថាជាអ្នកទ្រទ្រង់ព្រះវិន័យក្តី ថាជាធម្មកថិកក្តី ថាជាអ្នកប្រព្រឹត្តអារញ្ញិកធុតង្គក្តី ថាជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គក្តី ថាជាអ្នកប្រ-ព្រឹត្តបំសុកូលិកធុតង្គក្តី ថាជាអ្នកប្រព្រឹត្តតេចីវរិកធុតង្គក្តី ថាជាអ្នកប្រព្រឹត្តចារិកធុតង្គក្តី ថាជាអ្នកប្រព្រឹត្តខលុបច្ឆាភត្តិកធុតង្គក្តី ថាជាអ្នកប្រព្រឹត្តនេស-ជ្ជិកសបទានធុតង្គក្តី ថាជាអ្នកប្រព្រឹត្តយថាសន្ថតិកធុតង្គក្តី រមែងអួតអាងអួតអាងផ្សេងៗ ថាជាអ្នកបានបឋមជ្ឈានក្តី ថាជាអ្នកបានទុតិយជ្ឈានក្តី ថាជាអ្នកបានតតិយជ្ឈានក្តី ថាជាអ្នកបានចតុត្ថជ្ឈានក្តី ថាជាអ្នកបានអាកា-សានញ្ចាយតនសមាបត្តិ វិញ្ញាណញ្ចាយតនសមាបត្តិ អាកិញ្ចញ្ញាយតន-សមាបត្តិ និងនេវសញ្ញានាសញ្ញាយតនសមាបត្តិក្តី ។ បុគ្គលមិនអួតអាងមិនអួតអាងផ្សេង ៗ យ៉ាងនេះ ៗ បុគ្គលវៀរទៅ វៀរស្រឡះ វៀរចំពោះ ឃ្លាតចេញ រលាស់ចេញ រួចស្រឡះ ប្រាសចេញ អំពីសេចក្តីអួតអាង រមែងនៅ ដោយចិត្ត ដែលប្រាសចាកដែនគឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមិនអួតអាង ។

## ទសមោ បុភភេទសុត្តនិទ្ទេសោ

(៦៧) អកុក្កុច្ចោតិ កុក្កុច្ចន្តិ ហត្ថកុក្កុច្ចម្បិ
កុក្កុច្ចំ បាទកុក្កុច្ចម្បិ កុក្កុច្ចំ ហត្ថបាទកុក្កុច្ចម្បិ
កុក្កុច្ចំ អកប្បិយេ កប្បិយសញ្ញិតា កប្បិយេ អកប្-
បិយសញ្ញិតា អវជ្ជេ វជ្ជសញ្ញិតា វជ្ជេ អវជ្ជសញ្ញិតា
យំ ឯវរូបំ កុក្កុច្ចំ កុក្កុច្ចាយនា កុក្កុច្ចាយិតត្តំ
ចេតសោ វិប្បដិសារោ មនោវិលេខោ ឥទំ វុច្ចតិ កុ-
ក្កុច្ចំ ។ អបិច ទ្វីហិ ការណេហិ ឧប្បជ្ជតិ កុក្កុច្ចំ
ចេតសោ វិប្បដិសារោ មនោវិលេខោ កតត្តា ច
អកតត្តា ច ។

កថំ កតត្តា ច អកតត្តា ច ឧប្បជ្ជតិ កុក្កុច្ចំ
ចេតសោ វិប្បដិសារោ មនោវិលេខោ ។ កតំ មេ
កាយទុច្ចរិតំ អកតំ មេ កាយសុចរិតន្តិ ឧប្បជ្ជតិ
កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។
កតំ មេ វចីទុច្ចរិតំ អកតំ មេ វចីសុចរិតន្តិ ឧប្បជ្ជតិ
កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។

## ទុកភេទសុត្តនិទ្ទេស ទី១០

(៦៧) អធិប្បាយពាក្យថា មិនមានកុក្កុច្ចៈ ត្រង់ពាក្យថា កុក្កុច្ចៈ គឺ ការរពឹសដៃ ហៅថា កុក្កុច្ចៈ ការរពឹសជើង ហៅថា កុក្កុច្ចៈ ការរពឹសដៃនឹងជើង ក៏ហៅថា កុក្កុច្ចៈ សេចក្តីសំគាល់ថាគួរក្នុងវត្ថុមិនគួរ សេចក្តីសំគាល់ថាមិនគួរក្នុងវត្ថុគួរ សេចក្តីសំគាល់ថាមានទោសក្នុងវត្ថុមិនមានទោស សេចក្តីសំគាល់ថាមិនមានទោសក្នុងវត្ថុមានទោស សេចក្តីរង្កៀស អាការៈនៃសេចក្តីរង្កៀស ភាពនៃសេចក្តីរង្កៀស សេចក្តីក្តៅក្រហាយចិត្ត សេចក្តីប្រេះស្រាំនៃចិត្ត ឯណា មានសភាពយ៉ាងនេះ នេះ ហៅថា កុក្កុច្ចៈ ។ មួយទៀត សេចក្តីរង្កៀស សេចក្តីក្តៅក្រហាយចិត្ត សេចក្តីប្រេះស្រាំនៃចិត្ត រមែងកើតដោយហេតុពីរ គឺភាពនៃអំពើដែលធ្វើហើយ ១ នឹង មិនធ្វើហើយ ១ ។ សេចក្តីរង្កៀស សេចក្តីក្តៅក្រហាយចិត្ត សេចក្តីប្រេះស្រាំនៃចិត្ត រមែងកើតឡើង ព្រោះអំពើដែលធ្វើហើយ ១ នឹង មិនធ្វើហើយ ១ តើដូចម្តេច ។ សេចក្តីរង្កៀស សេចក្តីក្តៅក្រហាយចិត្ត សេចក្តីប្រេះស្រាំនៃចិត្ត រមែងកើតឡើង (ដោយគិត) ថា កាយទុច្ចរិត អាត្មាអញបានធ្វើហើយ កាយសុចរិតអាត្មាអញមិនបានធ្វើទេ ។ សេចក្តីរង្កៀស សេចក្តីក្តៅក្រហាយចិត្ត សេចក្តីប្រេះស្រាំនៃចិត្ត រមែងកើតឡើងថា វចីទុច្ចរិត អាត្មាអញបានធ្វើហើយ វចីសុចរិត អាត្មាអញមិនបានធ្វើទេ ។

កតំ មេ មនោទុច្ចរិតំ អកតំ មេ មនោសុចរិតន្តិ ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។ កតោ មេ បាណាតិបាតោ អកតា មេ បាណាតិបាតា វេរមណីតិ ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។ កតំ មេ អទិន្នាទានំ អកតា មេ អទិន្នាទានា វេរមណីតិ ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។ កតោ មេ កាមេសុ មិច្ឆាចារោ អកតា មេ កាមេសុ មិច្ឆាចារា វេរមណីតិ ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។ កតោ មេ មុសាវាទោ អកតា មេ មុសាវាទា វេរមណីតិ ។ កតា មេ បិសុណាវាចា អកតា មេ បិសុណាយ វាចាយ វេរមណីតិ ។ កតា មេ ផរុសាវាចា អកតា មេ ផរុសាយ វាចាយ វេរមណីតិ ។ កតោ មេ សម្ផប្បលាបោ អកតា មេ សម្ផប្បលាបា វេរមណីតិ ។ កតា មេ អភិជ្ឈា អកតា មេ អនភិជ្ឈាតិ ។ កតោ មេ ព្យាបាទោ អកតោ មេ អព្យាបាទោតិ ។

សេចក្តីរង្កៀស សេចក្តីក្តៅក្រហាយចិត្ត សេចក្តីប្រែះស្រាំនៃចិត្ត រមែងកើតឡើងថា មនោទុច្ចរិតអាត្មាអញបានធ្វើហើយ មនោសុចរិតអាត្មាអញមិនបានធ្វើទេ ។ សេចក្តីរង្កៀស សេចក្តីក្តៅក្រហាយចិត្ត សេចក្តីប្រែះស្រាំនៃចិត្ត រមែងកើតឡើងថា បាណាតិបាត អាត្មាអញបានធ្វើហើយ ការវៀរចាកបាណាតិបាត អាត្មាអញមិនបានធ្វើទេ ។ សេចក្តីរង្កៀស សេចក្តីក្តៅក្រហាយចិត្ត សេចក្តីប្រែះស្រាំនៃចិត្ត រមែងកើតឡើងថា អទិន្នាទាន អាត្មាអញបានធ្វើហើយ ការវៀរចាកអទិន្នាទាន អាត្មាអញមិនបានធ្វើទេ ។ សេចក្តីរង្កៀស សេចក្តីក្តៅក្រហាយចិត្ត សេចក្តីប្រែះស្រាំនៃចិត្ត រមែងកើតឡើងថា កាមេសុមិច្ឆាចារៈ អាត្មាអញបានធ្វើហើយ ការវៀរចាកកាមេសុមិច្ឆាចារៈ អាត្មាអញមិនបានធ្វើទេ ។ ថា មុសាវាទ អាត្មាអញបានធ្វើហើយ ការវៀរចាកមុសាវាទ អាត្មាអញមិនបានធ្វើទេ ។ ថា បិសុណាវាចា អាត្មាអញបានធ្វើហើយ ការវៀរចាកបិសុណាវាចា អាត្មាអញមិនបានធ្វើទេ ។ ថា ផរុសវាចា អាត្មាអញបានធ្វើហើយ ការវៀរចាកផរុសវាចា អាត្មាអញមិនបានធ្វើទេ ។ ថា សម្ផប្បលាបៈ អាត្មាអញបានធ្វើហើយ ការវៀរចាកសម្ផប្បលាបៈ អាត្មាអញមិនបានធ្វើទេ ។ ថា អភិជ្ឈា អាត្មាអញបានធ្វើហើយ អនភិជ្ឈា អាត្មាអញមិនបានធ្វើទេ ។ ថា ព្យាបាទ អាត្មាអញ បានធ្វើហើយ អព្យាបាទ អាត្មាអញមិនបានធ្វើទេ ។

## ទសមោ បុរាភេទសុត្តនិទ្ទេសោ

កតា មេ មិច្ឆាទិដ្ឋិ អកតា មេ សម្មាទិដ្ឋីតិ ឧប្បជ្ជតិ
កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។ ឯវំ
កតត្តា ច អកតត្តា ច ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្ប-
ដិសារោ មនោវិលេខោ ។ អថវា សីលេសុម្ហិ ន បរិបូ-
រការីតិ ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោ-
វិលេខោ ។ ឥន្ទ្រិយេសុម្ហិ អគុត្តទ្វារោតិ ។ ភោជនេ
អមត្តញ្ញុម្ហីតិ ។ ជាគរិយំ អននុយុត្តោម្ហីតិ ។ ន សតិ-
សម្បជញ្ញេន សមន្នាគតោម្ហីតិ ។ អភាវិតា មេ ចត្តារោ
សតិប្បដ្ឋានាតិ ។ អភាវិតា មេ ចត្តារោ សម្មប្បធានាតិ ។
អភាវិតា មេ ចត្តារោ ឥទ្ធិបាទាតិ ។ អភាវិតានិ មេ
បញ្ចិន្ទ្រិយានីតិ ។ អភាវិតានិ មេ បញ្ច ពលានីតិ ។
អភាវិតា មេ សត្ត ពោជ្ឈង្គាតិ ។ អភាវិតោ មេ
អរិយោ អដ្ឋង្គិកោ មគ្គោតិ ។ ទុក្ខំ មេ អបរិញ្ញាតន្តិ ។
សមុទយោ មេ អប្បហីនោតិ ។ មគ្គោ មេ អភាវិតោតិ ។

បុរាភេទសុត្តនិទ្ទេស ទី ១០

សេចក្តីរង្កៀស សេចក្តីក្តៅក្រហាយចិត្ត សេចក្តីប្រែះស្រាំនៃចិត្ត រមែងកើតឡើងថា មិច្ឆាទិដ្ឋិអាត្មាអញបានធ្វើហើយ សម្មាទិដ្ឋិអាត្មាអញមិនបានធ្វើទេ ៗ សេចក្តីរង្កៀស សេចក្តីក្តៅក្រហាយចិត្ត សេចក្តីប្រែះស្រាំនៃចិត្ត រមែងកើតឡើងព្រោះភាពនៃអំពើដែលធ្វើហើយ ១ នឹង មិនធ្វើហើយ ១ យ៉ាងនេះ ៗ មួយទៀត សេចក្តីរង្កៀស សេចក្តីក្តៅក្រហាយចិត្ត សេចក្តីប្រែះស្រាំនៃចិត្ត រមែងកើតឡើងថា អាត្មាអញជាអ្នកមិនធ្វើឲ្យពេញក្នុងសីលទាំងឡាយ ៗ ថា អាត្មាអញ ជាអ្នកមានទ្វារមិនគ្រប់គ្រងហើយក្នុងឥន្ទ្រិយទាំងឡាយ ៗ ថា អាត្មាអញ ជាអ្នកមិនដឹងប្រមាណក្នុងភោជន ៗ ថា អាត្មាអញជាអ្នកមិនប្រកបរឿយ ៗ នូវការភ្ញាក់រលឹក ៗ ថា អាត្មាអញ ជាអ្នកមិនប្រកបដោយសតិនឹងសម្បជញ្ញៈ ៗ ថា សតិប្បដ្ឋាន ៤ អាត្មាអញមិនបានចំរើនហើយ ៗ ថា សម្មប្បធាន ៤ អាត្មាអញមិនបានចំរើនហើយ ៗ ថា ឥទ្ធិបាទ ៤ អាត្មាអញមិនបានចំរើនហើយ ៗ ថាឥន្ទ្រិយ ៥ អាត្មាអញមិនបានចំរើនហើយ ៗ ថា ពលៈ ៥ អាត្មាអញមិនបានចំរើនហើយ ៗ ថា ពោជ្ឈង្គ ៧ អាត្មាអញមិនបានចំរើនហើយ ៗ ថា អដ្ឋង្គិកមគ្គដ៏ប្រសើរ អាត្មាអញមិនបានចំរើនហើយ ៗ ថា ទុក្ខ អាត្មាអញមិនបានកំណត់ទេ ៗ ថា សមុទយៈ អាត្មាអញមិនបានលះបង់ទេ ៗ ថា មគ្គ អាត្មាអញមិនបានចំរើនទេ ៗ

និរោធោ មេ អសច្ឆិកតោតិ ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។ យស្សេតំ កុក្កុច្ចំ បហីនំ សមុច្ឆិន្នំ វូបសន្តំ បដិប្បស្សទ្ធំ អភព្វុប្បត្តិកំ ញាណគ្គិនា ទឌ្ឍំ សោ វុច្ចតិ អកុក្កុច្ចោតិ អវិកត្ថី អកុក្កុច្ចោ ។

(៦៨) មន្តភាណី អនុទ្ធតោតិ មន្តា វុច្ចតិ បញ្ញា យា បញ្ញា បជាននា ។បេ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ មន្តាយ បរិគ្គហេត្វា វាចំ ភាសតិ ពហុម្បិ កថេន្តោ ពហុម្បិ ភណន្តោ ពហុម្បិ ទីបយន្តោ ពហុម្បិ វោហរន្តោ ទុក្កថិតំ ទុព្ភាសិតំ ទុព្ភណិតំ ទុល្លបិតំ ទុរុត្តំ វាចំ ន ភាសតីតិ មន្តភាណី ។ អនុទ្ធតោតិ តត្ថ កតមំ ឧទ្ធច្ចំ ។ យំ ចិត្តស្ស ឧទ្ធច្ចំ អវូបសមោ ចេតសោ វិក្ខេបោ ភន្តត្តំ ចិត្តស្ស ឥទំ វុច្ចតិ ឧទ្ធច្ចំ ។ យស្សេតំ ឧទ្ធច្ចំ បហីនំ សមុច្ឆិន្នំ វូបសន្តំ បដិប្បស្សទ្ធំ អភព្វុប្បត្តិកំ

សេចក្ដីរង្កៀស សេចក្ដីក្ដៅក្រហាយចិត្ត សេចក្ដីប្រែះប្រហាំនៃចិត្ត រមែងកើតឡើងថា និពេធ អាត្មាអញមិនបានធ្វើឲ្យជាក់ច្បាស់ទេ ។ សេចក្ដីរង្កៀសនេះ បុគ្គលណា លះបង់ហើយ ផ្ដាច់ផ្ដិលហើយ រម្ងាប់ហើយ គ្របសង្កត់ហើយ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមិនមានកុក្កុច្ចៈ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមិនអួតអាង អ្នកមិនមានកុក្កុច្ចៈ ។

(៦៨) ពាក្យថា អ្នកពោលដោយការដឹង អ្នកមិនរាយមាយ សេចក្ដីថា បញ្ញា លោកហៅថា ការដឹង បានដល់ប្រាជ្ញា សេចក្ដីដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណានូវធម៌ សេចក្ដីយល់ត្រូវ ។ បុគ្គលស្ទួនដោយការដឹងហើយពោលនូវវាចា ទោះបីពោលច្រើន ពណ៌នាច្រើន បំភ្លឺច្រើន ថ្លែងច្រើន ក៏មិនពោលវាចាដែលគេពោលអាក្រក់ និយាយអាក្រក់ ចរចាអាក្រក់ បញ្ចេញអាក្រក់ទេ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកពោលដោយការដឹង ។ ពាក្យថា អ្នកមិនរាយមាយ សំនួរថា សេចក្ដីរាយមាយ ក្នុងដំណើរនោះ តើដូចម្ដេច ។ សេចក្ដីរាយមាយនៃចិត្ត សេចក្ដីមិនស្ងប់រម្ងាប់ សេចក្ដីរវើរវាយនៃចិត្ត សេចក្ដីវិលនៃចិត្ត ឯណា នេះ លោកហៅថា សេចក្ដីរាយមាយ ។ សេចក្ដីរាយមាយនេះ បុគ្គលណាលះបង់ ផ្ដាច់ផ្ដិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតបាន

ញាណគ្គិនា ទឌ្ឍំ សោ វុច្ចតិ អនុទ្ធតោតិ មន្តាភាណី អនុទ្ធតោ ។

(៥៩) សវេ វាចាយតោ មុនីតិ ឥធ ភិក្ខុ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ សច្ចវាទី សច្ចសន្ធោ ថេតោ បច្ចយិកោ អវិសំវាទកោ លោកស្ស ។ បិសុណំ វាចំ បហាយ បិសុណាយ វាចាយ បដិវិរតោ ហោតិ ឥតោ សុត្វា ន អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ន ឥមេសំ អក្ខាតា អមូសំ ភេទាយ ឥតិ ភិន្នានំ វា សន្ធាតា សហិតានំ វា អនុប្បទាតា សមគ្គារាមោ សមគ្គរតោ សមគ្គនន្ទី សមគ្គករណិំ វាចំ ភាសិតា ហោតិ ។ ផរុសំ វាចំ បហាយ ផរុសាយ វាចាយ បដិវិរតោ ហោតិ យា សា វាចា នេលា កណ្ណសុខា បេមនីយា ហទយង្គមា បោរី ពហុជនកន្តា ពហុជនមនាបា តថារូបិំ វាចំ ភាសិតា ហោតិ ។ សម្ផប្បលាបំ បហាយ សម្ផប្បលាបា បដិវិរតោ ហោតិ

ផុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថា ជាអ្នកមិនពយមាយ ហេតុនោះ (ទ្រង់ត្រាស់ថា) ពោលដោយការដឹង ជាអ្នកមិនពយមាយ ។

(៦៩) ពាក្យថា បុគ្គលសង្រួមវាចានោះឯង ជាមុនិ សេចក្តីថា ភិក្ខុក្នុងសាសនានេះ លះបង់មុសាវាទ វៀរចាកមុសាវាទ ពោលតែពាក្យពិត តពាក្យពិត មានវាចាខ្ជាប់ខ្ជួន គួរឲ្យអ្នកផងជឿបាន មិនពោលបំភាន់សត្វលោក ។ លះបង់បិសុណាវាចា វៀរស្រឡះចាកបិសុណាវាចា គឺឮអំពីពួកជននេះ មិនប្រាប់ពួកជនឯណោះ ដើម្បីបំបែកពួកជននេះ ឬឮអំពីពួកជនឯណោះ មិនប្រាប់ដល់ជនពួកនេះ ដើម្បីបំបែកពួកជនឯណោះ ជាអ្នកផ្សះផ្សានូវពួកជនដែលបែកគ្នាហើយក្តី ជាអ្នកបន្ថែមកំឡាំងឲ្យដល់ពួកដែលព្រមព្រៀងគ្នាហើយក្តី មានសេចក្តីត្រេកអរ ក្នុងការព្រមព្រៀង ត្រេកអរក្នុងសេចក្តីព្រមព្រៀង មានសេចក្តីរីករាយក្នុងការព្រមព្រៀង ពោលវាចាជាទីធ្វើនូវសេចក្តីព្រមព្រៀង ។ លះបង់ផរុសវាចា វៀរស្រឡះចាកផរុសវាចាហើយ ក៏វាចាណា ដែលជាសំដីឥតទោស ជាសុខដល់ត្រចៀក គួរឲ្យស្រឡាញ់ ជាទីពេញហឫទ័យ ជាសំដីរបស់អ្នកបុរី ជាទីត្រេកអរដល់ជនច្រើននាក់ ជាទីពេញចិត្តជនច្រើននាក់ ជាអ្នកពោលតែវាចាបែបនោះឯង ។ លះបង់សម្ផប្បលាបៈ វៀរស្រឡះចាកសម្ផប្បលាបៈ

កាលវាទី ភូតវាទី អត្ថវាទី ធម្មវាទី វិនយវាទី និធាន-
វតឹ(១) វាចំ ភាសិតា ហោតិ កាលេន សាបទេសំ
បរិយន្តវតឹ អត្ថសញ្ហិតំ ។ ចតូហិ វចីសុចរិតេហិ
សមន្នាគតោ ចតុទ្ទោសាបគតំ វាចំ ភាសតិ ។ ទ្វត្តឹ-
សាយ តិរច្ឆានកថាយ អារតោ វិរតោ បដិវិរតោ
និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិក-
តេន ចេតសា វិហរតិ ។ ទសវត្ថូនិ(២) កថេតិ ។
សេយ្យថីទំ ។ អប្បិច្ឆកថំ កថេតិ សន្តុដ្ឋិកថំ បវិវេ-
កកថំ អសំសគ្គកថំ វីរិយារម្ភកថំ សីលកថំ សមាធិ-
កថំ បញ្ញាកថំ វិមុត្តិកថំ វិមុត្តិញាណទស្សនកថំ
សតិប្បដ្ឋានកថំ សម្មប្បធានកថំ ឥទ្ធិបាទកថំ ឥន្ទ្រិ-
យកថំ ពលកថំ ពោជ្ឈង្គកថំ មគ្គកថំ ផលកថំ
និព្វានកថំ កថេតិ ។ វាចាយតោតិ យត្តោ បដិយត្តោ
គុត្តោ គោបិតោ រក្ខិតោ សំវុតោ វូបសន្តោ ។ មុនីតិ
មោនំ វុច្ចតិ ញាណំ ។ បេ ។ សង្គជាលមតិច្ច សោ
មុនីតិ សចេ វាចាយតោ មុនិ ។ តេនាហ ភគវា

---

១ ឱ. ម. និធានវតី ។ ២ ម. ទស កថា វត្ថូនិ ។

ហើយជាអ្នកពោលពាក្យក្នុងកាលគួរ ពោលតែពាក្យពិត ពោលអត្ថ ពោលធម៌ ពោលវិន័យ ពោលវាចាដែលគួរកប់ទុកក្នុងហឫទ័យ ជាវាចាមានគ្រឿងអាង មានទីបំផុត ប្រកបដោយប្រយោជន៍តាមកាលគួរ ។ បុគ្គលប្រកបដោយវចីសុចរិតទាំង ៤ តែងពោលវាចាប្រាសចាកទោស ៤ ប្រការ ។ បុគ្គលវៀរទូទៅ វៀរស្រឡះ វៀរបំពោះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ ប្រាសចេញឆ្ងាយអំពីតិរច្ឆានកថា ៣២ រមែងនៅដោយចិត្ត ដែលប្រាសចាកដែនគឺកិលេស ។ ពោលនូវវត្ថុ ១០ ប្រការ ។ ពោលនូវវត្ថុ ១០ ប្រការ តើដូចម្តេច ។ គឺ ពោលអប្បិច្ឆកថា ១ សន្តុដ្ឋិកថា ១ បវិវេកកថា ១ អសំសគ្គកថា ១ វីរិយារម្ភកថា ១ សីលកថា ១ សមាធិកថា ១ បញ្ញាកថា ១ វិមុត្តិកថា ១ វិមុត្តិញ្ញាណទស្សនកថា ១ សតិប្បដ្ឋានកថា ១ សម្មប្បធានកថា ១ ឥទ្ធិបាទកថា ១ ឥន្ទ្រិយកថា ១ ពលកថា ១ ពោជ្ឈង្គកថា ១ មគ្គកថា ១ ផលកថា ១ និព្វានកថា ១ ។ ពាក្យថា បុគ្គលអ្នកសង្រួមវាចា គឺ សង្រួម ប្រយ័ត្ន គ្រប់គ្រង បីបាច់ រក្សា រវាំង រម្ងាប់ ។ ញាណ លោកហៅថា មោនៈ របស់បទថា មុនិ ។ បេ ។ មុនិនោះ កន្លងនូវបណ្តាញ គឺសេចក្តីជាប់ចំពាក់ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលអ្នកសង្រួមវាចានោះឯង ឈ្មោះថា មុនិ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

សារម្ភេន មានេន អតិមានេន មទេន បមាទេន សព្វកិលេសេហិ សព្វទុច្ចរិតេហិ សព្វទរថេហិ សព្វ-បរិឡាហេហិ សព្វសន្តាបេហិ សព្វាកុសលាភិសង្ខារេហិ វិវិត្តេ បស្សតីតិ វិវេកទស្សី ផស្សេសុ ។

(៧៦) ទិដ្ឋីសុ ច ន និយ្យតីតិ តស្ស ទ្វាសដ្ឋី ទិដ្ឋិគតានិ បហីនានិ សមុច្ឆិន្នានិ វូបសន្តានិ បដិប្បស្សទ្ធានិ អភព្វុប្បត្តិកានិ ញាណគ្គិនា ទឌ្ឍានិ សោ ទិដ្ឋិយា ន យាយតិ ន និយ្យតិ ន វុយ្ហតិ ន សំហរិយតិ នបិ តំ ទិដ្ឋិគតំ សារតោ បច្ចេតិ ន បច្ចាគច្ឆតីតិ ទិដ្ឋីសុ ច ន និយ្យតិ ។ តេនាហ ភគវា

និរាសត្តី អនាគតេ អតីតំ នានុសោចតិ
វិវេកទស្សី ផស្សេសុ ទិដ្ឋីសុ ច ន និយ្យតីតិ ។

សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ ឃើញពួកលោកុត្តរផស្សៈដ៏ស្ងប់ស្ងាត់ ជាកកិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង សេចក្តីអន្ទះអន្ទែងទាំងពួង អកុសលាភិ-សង្ខារទាំងពួង ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកឃើញសេចក្តីស្ងប់ស្ងាត់ក្នុងផស្សៈទាំងឡាយ ។

(៧៤) ពាក្យថា ទិដ្ឋិទាំងឡាយនាំទៅមិនបាន គឺទិដ្ឋិទាំង ៦២ បុគ្គលនោះលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ ទិដ្ឋិឲ្យទៅមិនបាន នាំទៅមិនបាន បន្សាត់ទៅមិនបាន នាំទៅព្រមមិនបាន ទាំងមិនជឿ មិនត្រឡប់មក កាន់ទិដ្ឋិនោះថាមានខ្លឹម ហេតុនោះ (ទ្រង់ត្រាស់ថា) ទិដ្ឋិទាំងឡាយនាំទៅមិនបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលមិនមានសេចក្តីជាប់ចំពាក់ ក្នុងវត្ថុអនាគត មិន
សោយស្តាយ ចំពោះវត្ថុអតីត អ្នកឃើញសេចក្តីស្ងប់
ស្ងាត់ ក្នុងផស្សៈទាំងឡាយ បុគ្គលនោះ ទិដ្ឋិទាំងឡាយ
នាំទៅមិនបាន ។

## ទសមោ បុរាភេទសុត្តនិទ្ទេសោ

(៧៥) បដិលីនោ អកុហកោ អបិហាលុ អមច្ឆរី
អប្បគព្ភោ អជេគុច្ឆោ បេសុណេយ្យេ ច នោ យុតោ ។

(៧៦) បដិលីនោ អកុហកោតិ បដិលីនោតិ រាគស្ស
បហីនត្តា បដិលីនោ ទោសស្ស បហីនត្តា បដិលីនោ
មោហស្ស បហីនត្តា បដិលីនោ កោធស្ស ឧបនាហស្ស
មក្ខស្ស បឡាសស្ស ឥស្សាយ មច្ឆរិយស្ស ។បេ។
សព្វាកុសលាភិសង្ខារានំ បហីនត្តា បដិលីនោ ។
វុត្តំ ហេតំ ភគវតា កថញ្ច ភិក្ខវេ ភិក្ខុ បដិលីនោ
ហោតិ ឥធ ភិក្ខវេ ភិក្ខុនោ អស្មិមានោ បហីនោ
ហោតិ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវង្កតោ
អាយតឹ អនុប្បាទធម្មោ ឯវំ ខោ ភិក្ខវេ ភិក្ខុ បដិលីនោ
ហោតីតិ បដិលីនោ ។

(៧៧) អកុហកោតិ តីណិ កុហនវត្ថូនិ បច្ចយ-
បដិសេវនសង្ខាតំ កុហនវត្ថុ ឥរិយាបថសង្ខាតំ
កុហនវត្ថុ សាមន្តជប្បនសង្ខាតំ កុហនវត្ថុ ។

## បុរាភេទសុត្តនិទ្ទេស ទី ១០

(៧៥) បុគ្គលអ្នករួញចិត្ត អ្នកមិនកុហក អ្នកមិនមានសេចក្ដីប្រាថ្នា អ្នកមិនមានសេចក្ដីកំណាញ់ អ្នកមិនមានការឃ្នើសឃ្នង អ្នកដែលគេមិនគួរខ្ពើម រមែងមិនប្រកប ក្នុងការញុះញង់ទេ ។

(៧៦) អធិប្បាយពាក្យថា អ្នករួញចិត្ត អ្នកមិនកុហក ត្រង់ពាក្យថា អ្នករួញចិត្ត សេចក្ដីថា ដែលឈ្មោះថា អ្នករួញចិត្ត ព្រោះលះបង់រាគៈ អ្នករួញចិត្ត ព្រោះលះបង់ទោសៈ អ្នករួញចិត្ត ព្រោះលះបង់នូវមោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ ។ បេ ។ អ្នករួញចិត្ត ព្រោះលះបង់អកុសលាភិសង្ខារទាំងពួង ។ សមដូចព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នករួញចិត្ត តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ អស្មិមានះ ភិក្ខុក្នុងសាសនានេះ លះបង់ហើយ មានឫសគល់គាស់រំលើងហើយ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមានបែបភាព ជាធម៌លែងកើតតទៅទៀត ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នករួញចិត្ត យ៉ាងនេះឯង ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នករួញចិត្ត ។

(៧៧) ពាក្យថា អ្នកមិនកុហក អធិប្បាយថា កុហនវត្ថុ ៣ យ៉ាង៖ កុហនវត្ថុ ខាងការសេពបច្ច័យ ១ កុហនវត្ថុ ខាងឥរិយាបថ ១ កុហនវត្ថុខាងការខ្សឹបជិត ១ ។

កតមំ បច្ចយប្បដិសេវនសង្ខាតំ កុហនវត្ថុ ។ ឥធ គហបតិកា ភិក្ខុំ និមន្តេន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេហិ ។ សោ បាបិច្ឆោ ឥច្ឆាបកតោ អត្ថិកោ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ភិយ្យោកម្យតំ ឧបាទាយ ចីវរំ បច្ចក្ខាតិ បិណ្ឌបាតំ បច្ចក្ខាតិ សេនាសនំ បច្ចក្ខាតិ គិលានប្បច្ចយភេសជ្ជបរិក្ខារំ បច្ចក្ខាតិ ។ សោ ឯវមាហ កឹ សមណស្ស មហគ្ឃេន ចីវរេន ឯតំ សារុប្បំ យំ សមណោ សុសានា វា សង្ការកូដា វា បាបណិកា វា នន្តកានិ ឧច្ចិនិត្វា សង្ឃាដឹ កត្វា ធារេយ្យ កឹ សមណស្ស មហគ្ឃេន បិណ្ឌបាតេន ឯតំ សារុប្បំ យំ សមណោ ឧញ្ឆាចរិយាយ បិណ្ឌិយាលោបេន ជីវិកំ កប្បេយ្យ កឹ សមណស្ស មហគ្ឃេន សេនាសនេន ឯតំ សារុប្បំ យំ សមណោ រុក្ខមូលិកោ វា អស្ស សោសានិកោ វា អព្ភោកាសិកោ វា កឹ សមណស្ស មហគ្ឃេន គិលានប្បច្ចយភេសជ្ជបរិក្ខារេន

កុហនវត្ថុ ខាងការសេពបច្ច័យ តើដូចម្តេច ។ ពួកគហបតី ក្នុងសាសនានេះ រមែងនិមន្តភិក្ខុដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ ។ ភិក្ខុនោះ មានសេចក្តីប្រាថ្នាអាក្រក់ ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ ជាអ្នកមានសេចក្តីត្រូវការ នូវចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ អាស្រ័យ នូវសេចក្តីប្រាថ្នា ដ៏លើសលប់ ទើបហាមឃាត់ចីវរ ហាមឃាត់ បិណ្ឌបាត ហាមឃាត់សេនាសនៈ ហាមឃាត់គិលានប្បច្ច័យភេសជ្ជ-បរិក្ខារ ។ ភិក្ខុនោះបានពោលយ៉ាងនេះថា សមណៈមានប្រយោជន៍អ្វី ដោយចីវរមានថ្លៃច្រើន ការប្រើប្រាស់ចីវរដ៏សមគួរ ដល់សមណៈនុ៎ះ គឺសមណៈ ត្រូវតែរើសកំណាត់សំពត់ទាំងឡាយ អំពីព្រៃស្មសាន ឬ អំពីគំនរសម្រាម ឬអំពីពនផ្សារ មកធ្វើជាសង្ឃាដីប្រើប្រាស់ សមណៈ មានប្រយោជន៍អ្វីដោយបិណ្ឌបាត មានថ្លៃច្រើន ការចិញ្ចឹមជីវិតដ៏សមគួរដល់សមណៈនុ៎ះ គឺសមណៈត្រូវតែចិញ្ចឹមជីវិតដោយពំនូតបាយ ដោយការដើរទៅដើម្បីសូម សមណៈ មានប្រយោជន៍អ្វី ដោយសេនាសនៈ មានថ្លៃច្រើន ការនៅដ៏សមគួរដល់សមណៈនុ៎ះ គឺសមណៈត្រូវតែជាអ្នក នៅជិតគល់ឈើ ឬនៅក្នុងព្រៃស្មសាន ឬក៏នៅក្នុងទីវាល សមណៈ មានប្រយោជន៍អ្វី ដោយគិលានប្បច្ច័យភេសជ្ជបរិក្ខារ មានថ្លៃច្រើន

## ទសមោ បុរាភេទសុត្តនិទ្ទេសោ

ឯតំ សារុប្បំ យំ សមណោ បូតិមុត្តេន វា ហរីតកី-ខណ្ឌេន វា ឱសធំ ករេយ្យាតិ តទុបាទាយ លូខំ ចីវរំ ធារេតិ លូខំ បិណ្ឌបាតំ ភុញ្ជតិ(១) លូខំ សេនាសនំ បដិសេវតិ លូខំ គិលានប្បច្ចយភេសជ្ជបរិក្ខារំ បដិសេវតិ ។ តមេនំ គហបតិកា ឯវំ ជានន្តិ អយំ សមណោ អប្បិច្ឆោ សន្តុដ្ឋោ បវិវិត្តោ អសំសដ្ឋោ អារទ្ធវីរិយោ ធុតវាទោតិ ភិយ្យោ ភិយ្យោ និមន្តេន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេហិ ។ សោ ឯវមាហ តិណ្ណំ សម្មុខីភាវា សទ្ធោ កុលបុត្តោ ពហុំ បុញ្ញំ បសវតិ សទ្ធាយ សម្មុខីភាវា សទ្ធោ កុលបុត្តោ ពហុំ បុញ្ញំ បសវតិ ទេយ្យធម្មស្ស សម្មុខីភាវា សទ្ធោ កុលបុត្តោ ពហុំ បុញ្ញំ បសវតិ ទក្ខិណេយ្យានំ សម្មុខីភាវា សទ្ធោ កុលបុត្តោ ពហុំ បុញ្ញំ បសវតិ តុម្ហាកញ្ចាយំ សទ្ធា អត្ថិ ទេយ្យធម្មោ ចាយំ(២) សំវិជ្ជតិ អហញ្ច បដិគ្គាហកោ សចាហំ ន បដិគ្គហេស្សាមិ ឯវំ តុម្ហេ បុញ្ញេន បរិហីនា(៣) ភវិស្សថ ន មយ្ហំ ឥមិនា អត្ថោ អបិច តុម្ហាកញ្ញេវ អនុកម្បាយ បដិគ្គណ្ហាមីតិ តទុបាទាយ ពហុម្បិ ចីវរំ

---

១ ម· បរិភុញ្ជតិ ។ ២ ម. ច ។ ៣ ម. បរិពាហិរា ។

## បុរាភេទសុត្តនិទ្ទេស ទី ១០

ការធ្វើឧសថដ៏សមគួរដល់សមណៈនុះ+ គឺសមណៈត្រូវតែធ្វើថ្នាំដោយមូត្រផ្អូម ឬដោយចំណិតស្រម៉ តាំងអំពីនោះមក ភិក្ខុនោះក៏ទ្រទ្រង់ចីវរដ៏សៅហ្មង បរិភោគបិណ្ឌបាតដ៏សៅហ្មង សេពៈសនាសនៈដ៏សៅហ្មង សេពគិលានប្បច្ចយភេសជ្ជបរិក្ខារដ៏សៅហ្មង ៗ ពួកគហបតីដឹងភិក្ខុនោះយ៉ាងនេះថា សមណៈនេះមានសេចក្តីប្រាថ្នាតិច មានសន្តោស ស្ងប់ស្ងាត់ មិនច្របូកច្របល់ (ដោយពួក) ប្រារព្ធព្យាយាម ពោលធុតគុណ ក៏រឹតតែនិមន្ត ដោយចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ចយភេសជ្ជបរិក្ខារ ៗ ភិក្ខុនោះពោលយ៉ាងនេះថា កុលបុត្រមានសទ្ធា តែងប្រសពនូវបុណ្យដ៏ច្រើន ព្រោះធម៌ ៣ យ៉ាងមានចំពោះមុខ គឺកុលបុត្រមានសទ្ធា តែងប្រសពនូវបុណ្យដ៏ច្រើន ព្រោះសទ្ធាមានចំពោះមុខ ១ កុលបុត្រមានសទ្ធា តែងប្រសពនូវបុណ្យដ៏ច្រើន ព្រោះទេយ្យធម៌មានចំពោះមុខ ១ កុលបុត្រមានសទ្ធា តែងប្រសពនូវបុណ្យដ៏ច្រើន ព្រោះពួកទក្ខិណេយ្យបុគ្គលមានចំពោះមុខ ១ សទ្ធានេះ របស់ពួកអ្នកក៏មានផង ទេយ្យធម៌នេះ ក៏មានព្រមផង ទាំងអាត្មាក៏ជាអ្នកទទួល បើអាត្មាមិនទទួលទេ ពួកអ្នកនឹងជាបុគ្គលសាបសូន្យចាកបុណ្យយ៉ាងនេះ អាត្មាមិនមានសេចក្តីត្រូវការ ដោយទេយ្យធម៌នេះទេ ប៉ុន្តែអាត្មាទទួល ដើម្បីអនុគ្រោះដល់ពួកអ្នកតែម្យ៉ាង តាំងអំពីនោះមក ភិក្ខុនោះ ក៏ទទួលចីវរច្រើនផង

បដិគ្គណ្ហាតិ ពហុម្បិ បិណ្ឌបាតំ បដិគ្គណ្ហាតិ ពហុម្បិ
សេនាសនំ បដិគ្គណ្ហាតិ ពហុម្បិ គិលានបច្ចយ-
ភេសជ្ជបរិក្ខារំ បដិគ្គណ្ហាតិ ។ យា ឯវរូបា ភាកុដិ-
កា ភាកុដិយំ កុហនា កុហាយនា កុហិតត្តំ
ឥទំ វុច្ចតិ បដិសេវនសង្ខាតំ កុហនវត្ថុ ។ កតមំ
ឥរិយាបថសង្ខាតំ កុហនវត្ថុ ។ ឥធេកច្ចោ បាបិច្ឆោ
ឥច្ឆាបកតោ សម្ភាវនាធិប្បាយោ ឯវំ មំ ជនោ សម្ភាវេ-
ស្សតីតិ គមនំ សណ្ឋបេតិ ឋានំ សណ្ឋបេតិ និសជ្ជំ
សណ្ឋបេតិ សយនំ សណ្ឋបេតិ បណិធាយ គច្ឆតិ
បណិធាយ តិដ្ឋតិ បណិធាយ និសីទតិ បណិធាយ
សេយ្យំ កប្បេតិ សមាហិតោ វិយ គច្ឆតិ សមា-
ហិតោ វិយ តិដ្ឋតិ សមាហិតោ វិយ និសីទតិ សមា-
ហិតោ វិយ សេយ្យំ កប្បេតិ អាបាថកជ្ឈាយី ច
ហោតិ ។ យា ឯវរូបា ឥរិយាបថស្ស អាឋបនា ឋបនា
សណ្ឋបនា ភាកុដិកា ភាកុដិយំ កុហនា កុហាយនា
កុហិតត្តំ ឥទំ វុច្ចតិ ឥរិយាបថសង្ខាតំ កុហន-
វត្ថុ ។ កតមំ សាមន្តជប្បនសង្ខាតំ កុហនវត្ថុ ។

ទទួលបិណ្ឌបាតច្រើនផង ទទួលសេនាសនៈច្រើនផង ទទួលគិលានប្បច្ច័យភេសជ្ជបរិក្ខារច្រើនផង ។ កិរិយាធ្វើមុខស្រពោន ភាពនៃកិច្ចធ្វើមុខស្រពោន ការកុហក ការប្រព្រឹត្តទៅនៃកិច្ចកុហក ភាពនៃកិច្ចកុហក ឯណា មានសភាពយ៉ាងនេះ នេះ លោកហៅថា កុហនវត្ថុ ខាងការសេព(បច្ច័យ) ។ កុហនវត្ថុ ខាងឥរិយាបថ តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ មានសេចក្ដីប្រាថ្នាលាមក ត្រូវសេចក្ដីប្រាថ្នាគ្របសង្កត់ហើយ ប្រាថ្នាសេចក្ដីសរសើរថា អ្នកផងនឹងសរសើរអញយ៉ាងនេះ ក៏រៀបចំទំនងដើរ រៀបចំទំនងឈរ ក៏រៀបចំទំនងអង្គុយ រៀបចំទំនងដេក ប្រុងប្រៀបហើយទើបដើរទៅ ប្រុងប្រៀបឈរ ប្រុងប្រៀបអង្គុយ ប្រុងប្រៀបសម្រេចការដេក ដើរទៅហាក់ដូចជាមានចិត្តតាំងមាំ ឈរហាក់ដូចជាមានចិត្តតាំងមាំ អង្គុយហាក់ដូចជាមានចិត្តតាំងមាំ សម្រេចការដេក ហាក់ដូចជាមានចិត្តតាំងមាំ ហាក់ដូចជាចូលឈានក្នុងទីចំពោះមុខ (នៃអ្នកផង) ។ ការតាំងទុកខាងដើម អាការនៃការតាំងទុក ការរៀបចំឥរិយាបថ កិរិយាធ្វើមុខស្រពោន ភាពនៃកិច្ចអ្នកធ្វើមុខស្រពោន ការកុហក ការប្រព្រឹត្តទៅនៃកិច្ចកុហក ភាពនៃកិច្ចកុហក ឯណា មានសភាពយ៉ាងនេះ នេះ លោកហៅថា កុហនវត្ថុ ខាងឥរិយាបថ ។ កុហនវត្ថុ ខាងការខ្សឹបជិត តើដូចម្ដេច ។

## ទសមោ បុរាភេទសុត្តនិទ្ទេសោ

ឥធេកច្ចោ បាបិច្ឆោ ឥច្ឆាបកតោ សម្ភាវនាធិប្បាយោ ឯវំ មំ ជនោ សម្ភាវេស្សតីតិ អរិយធម្មសន្និស្សិតំ វាចំ ភាសតិ យោ ឯវរូបំ ចីវរំ ធារេតិ សោ សមណោ មហេសក្ខោតិ ភណតិ យោ ឯវរូបំ បត្តំ ធារេតិ លោហថាលកំ ធារេតិ ធម្មករកំ ធារេតិ បរិស្សាវនំ ធារេតិ កុញ្ចិកំ ធារេតិ ឧបាហនំ ធារេតិ កាយពន្ធនំ ធារេតិ អាយោគំ ធារេតិ សោ សមណោ មហេសក្ខោតិ ភណតិ ។ យស្ស ឯវរូបោ ឧបជ្ឈាយោ សោ សមណោ មហេសក្ខោតិ ភណតិ ។ យស្ស ឯវរូបោ អាចរិយោ ឯវរូបា សមានុបជ្ឈាយកា សមានាចរិយកា មិត្តា សន្ទិដ្ឋា សម្ភត្តា សហាយា សោ សមណោ មហេសក្ខោតិ ភណតិ ។ យោ ឯវរូបេ វិហារេ វសតិ សោ សមណោ មហេសក្ខោតិ ភណតិ ។ យោ ឯវរូបេ អឌ្ឍយោគេ វសតិ បាសាទេ វសតិ ហម្មិយេ វសតិ គុហាយំ វសតិ លេណេ វសតិ កុដិយា វសតិ កូដាគារេ វសតិ អដ្ដេ វសតិ មាឡេ វសតិ ឧទ្ទណ្ឌេ វសតិ ឧបដ្ឋានសាលាយំ វសតិ មណ្ឌបេ វសតិ

## បុរាភេទសុត្តនិទ្ទេស ទី ១០

ភិក្ខុខ្លះក្នុងសាសនានេះ មានសេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្រប សង្កត់ហើយ ប្រាថ្នាសេចក្តីសរសើរថា អ្នកផងនឹងសរសើរអញយ៉ាង នេះ ក៏ពោលវាចា ដែលអាស្រ័យអរិយធម៌ ពោលថា សមណៈណា ទ្រទ្រង់ចីវរ មានសភាពយ៉ាងនេះ សមណៈនោះមានស័ក្តិធំ ពោលថា សមណៈណា ទ្រទ្រង់បាត្រមានសភាពយ៉ាងនេះ ទ្រទ្រង់ផ្តិលជាវិការៈ នៃលោហៈ ទ្រទ្រង់ធម្មក្រក ទ្រទ្រង់តម្រងទឹក ទ្រទ្រង់កូនសោ ទ្រទ្រង់ ស្បែកជើង ទ្រទ្រង់វត្ថពន្ធបង្កេះ ទ្រទ្រង់សំពត់អាយោគ សមណៈនោះ មានស័ក្តិធំ ។ ពោលថា ឧបជ្ឈាយ៍របស់សមណៈណា មានសភាព យ៉ាងនេះ សមណៈនោះមានស័ក្តិធំ ។ ពោលថា អាចារ្យរបស់ សមណៈណា មានសភាពយ៉ាងនេះ ពួកភិក្ខុរបស់សមណៈណា មាន សភាពយ៉ាងនេះ មានឧបជ្ឈាយ៍ស្មើគ្នា មានអាចារ្យស្មើគ្នា ជាមិត្រ មិត្រឃើញព្រម ជាសំឡាញ់ សមណៈនោះមានស័ក្តិធំ ។ ពោលថា សមណៈណា នៅក្នុងវិហារមានសភាពយ៉ាងនេះ សមណៈនោះ មាន ស័ក្តិធំ ។ ពោលថា សមណៈណា នៅក្នុងបង្អួច មានសភាពយ៉ាង នេះ នៅក្នុងប្រាសាទ នៅក្នុងប្រាសាទមានកំពូល នៅក្នុងគុហា នៅក្នុងទីជ្រកកោន នៅក្នុងកុដិ នៅក្នុងផ្ទះមានកំពូល នៅក្នុង ប៉ម នៅក្នុងរោង នៅក្នុងថែវ នៅក្នុងរោងឆាន់ នៅក្នុងបារាំ

រុក្ខមូលេ វសតិ សោ សមណោ មហេសក្ខោតិ ភណតិ ។ អថវា កោរជិកកោរជិកោ ភាកុដិក-ភាកុដិកោ កុហកកុហកោ លបកលបកោ មុខសម្ភាវិតោ(១) អយំ សមណោ ឥមាសំ ឯវរូបានំ សន្តានំ វិហារសមាបត្តីនំ លាភីតិ តាទិសំ គម្ភីរំ គូឡ្ហំ(២) និបុណំ បដិច្ឆន្នំ លោកុត្តរំ សុញ្ញតបដិសញ្ញុត្តំ កថំ កថេតិ ។ យា ឯវរូបា ភាកុដិកា ភាកុដិយំ កុហនា កុហាយនា កុហាយិតត្តំ ឥទំ វុច្ចតិ សាមន្តជប្បនសង្ខាតំ កុហនវត្ថុ ។

យស្សិមានិ តីណិ កុហនវត្ថូនិ បហីនានិ សមុច្ឆិន្នានិ វូបសន្តានិ បដិប្បស្សទ្ធានិ អភព្វុប្បត្តិកានិ ញាណគ្គិនា ទឌ្ឍានិ សោ វុច្ចតិ អកុហកោតិ បដិលីនោ អកុហកោ ។

(៧៨) អបិហាលុ អមច្ឆរីតិ បិហា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ យស្សេសា បិហា បហីនា សមុច្ឆិន្នា វូបសន្តា

---

១ ម. មុខសម្ភាវិតោ ។ ២ ខ. គុយ្ហំ ។

នៅជិតគល់ឈើ សមណៈនោះ មានស័ក្តិធំ ៗ មួយទៀត សមណៈជាអ្នកស្រងូតស្រងាត់ពេក មានមុខស្រពោនក្រៃពេក ជាអ្នកកុហកក្រៃពេក រួសរាយក្រៃពេក ត្រូវគេសរសើរដោយអំណាចមាត់ (របស់ខ្លួន) ថា សមណៈនេះបានវិហារសមាបត្តិទាំងឡាយដ៏ស្ងប់ស្ងាត់នេះ មានសភាពយ៉ាងនេះពោលពាក្យប្រាកដដូច្នោះ ជាពាក្យដ៏ជ្រៅ លំបាកយល់ ដ៏ល្អិតកំបាំង ជាវាចាប្រកបដោយសុញ្ញតនិព្វាន ជាលោកុត្តរ ។ កិរិយាធ្វើមុខស្រពោន ភាពនៃភិក្ខុជាអ្នកធ្វើមុខស្រពោន ការកុហក ការប្រព្រឹត្តិទៅនៃភិក្ខុកុហក ភាពនៃភិក្ខុកុហក ឯណា មានសភាពយ៉ាងនេះ នេះលោកហៅថា កុហនវត្ថុ ខាងការខ្សឹបជិត ។ កុហនវត្ថុទាំង ៣ ប្រការនេះ ភិក្ខុណាលះបង់ ផ្តាច់បង់ ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ភិក្ខុនោះ លោកហៅថា អ្នកមិនកុហក ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នករួញចិត្ត អ្នកមិនកុហក ។

(៧៨) ពាក្យថា អ្នកមិនមានសេចក្តីប្រាថ្នា អ្នកមិនមានសេចក្តីកំណាញ់ អធិប្បាយថា តណ្ហា លោកហៅថា សេចក្តីជាប់ចំពាក់ បានដល់សេចក្តីត្រេកអរ សេចក្តីត្រេកអរមានកំឡាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ សេចក្តីប្រាថ្នានេះ ភិក្ខុណាលះបង់ ផ្តាច់បង់

### ទសមោ បុរាភេទសុត្តនិទ្ទេសោ

បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា សោ វុច្ចតិ អបិហាលុ។ សោ រូបេ ន បិហេតិ សទ្ទេ គន្ធេ រសេ ផោដ្ឋព្ពេ កុលំ គណំ អាវាសំ លាភំ យសំ បសំសំ សុខំ ចីវរំ បិណ្ឌបាតំ សេនាសនំ គិលានប្បច្ចយភេសជ្ជបរិក្ខារំ កាមធាតុំ រូបធាតុំ អរូបធាតុំ កាមភវំ រូបភវំ អរូបភវំ សញ្ញាភវំ អសញ្ញាភវំ នេវសញ្ញានាសញ្ញាភវំ ឯកវោការភវំ ចតុវោការភវំ បញ្ចវោការភវំ អតីតំ អនាគតំ បច្ចុប្បន្នំ ទិដ្ឋសុតមុតវិញ្ញាតព្វេ ធម្មេ ន បិហេតិ ន ឥច្ឆតិ ន សាទិយតិ ន បត្ថេតិ នាភិជប្បតីតិ អបិហាលុ។ អមច្ឆរីតិ បញ្ច មច្ឆរិយានិ អាវាសមច្ឆរិយំ កុលមច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ ធម្មមច្ឆរិយំ យំ ឯវរូបំ មច្ឆរិយំ មច្ឆរាយនា មច្ឆរាយិតត្តំ វេវិច្ឆំ កទរិយំ កដុកញ្ចុកតា អគ្គហិតត្តំ ចិត្តស្ស ឥទំ វុច្ចតិ មច្ឆរិយំ។ អបិច ខន្ធមច្ឆរិយម្បិ មច្ឆរិយំ ធាតុមច្ឆរិយម្បិ មច្ឆរិយំ

## បុរាភេទសុត្តនិទ្ទេស ទី ១០

ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ភិក្ខុនោះ លោកហៅថា អ្នកមិនមានសេចក្តីប្រាថ្នា ។ ភិក្ខុនោះ មិនប្រាថ្នារូបទាំងឡាយ មិនប្រាថ្នា មិនប៉ង មិនត្រេកអរ មិនបន់បាន មិនជាប់ចិត្តនឹងសំឡេង ក្លិន រស ផោដ្ឋព្វៈ ត្រកូល អាវាស លាភ យស សេចក្តីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯក-វោការភព ចតុវោការភព បញ្ចវោការភព អតីត អនាគត បច្ចុប្បន្ន នឹងពួកធម៌ដែលខ្លួនឃើញ ឮ ប៉ះពាល់ ឬគប្បីដឹង ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមិនមានសេចក្តីប្រាថ្នា ។ ពាក្យថា អ្នកមិនមានសេចក្តីកំណាញ់ សេចក្តីថា សេចក្តីកំណាញ់ ៥ គឺ កំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់វណ្ណៈ ១ កំណាញ់ធម៌ ១ សេចក្តីកំណាញ់ អាការនៃសេចក្តីកំណាញ់ ភាពសេចក្តីកំណាញ់ សេចក្តីប្រាថ្នាផ្សេងៗ សេចក្តីកំណាញ់រឹង សេចក្តីស្វិតស្វាញ ភាពនៃបុគ្គលមិនយកចិត្ត (នៃបុគ្គលដទៃ) ឯណា មានសភាពយ៉ាងនេះ នេះលោកហៅថា សេចក្តីកំណាញ់ ។ មួយទៀត សេចក្តីកំណាញ់ខន្ធក៏ហៅថា កំណាញ់ សេចក្តីកំណាញ់ធាតុ ក៏ ហៅថា កំណាញ់

អាយតនមច្ឆរិយម្បិ មច្ឆរិយំ គាហោ ឥទំ វុច្ចតិ មច្ឆរិយំ ។ យស្សេតំ មច្ឆរិយំ បហីនំ សមុច្ឆិន្នំ វូបសន្តំ បដិប្បស្សទ្ធំ អភព្វុប្បត្តិកំ ញាណគ្គិនា ទឌ្ឍំ សោ វុច្ចតិ អមច្ឆរីតិ អបិហាលុ អមច្ឆរី ។

(៧៩) អប្បគព្ភោ អជេគុច្ឆោតិ បាគព្ភិយន្តិ តីណិ បាគព្ភិយានិ កាយិកំ បាគព្ភិយំ វាចសិកំ បាគព្ភិយំ ចេតសិកំ បាគព្ភិយំ ។ កតមំ កាយិកំ បាគព្ភិយំ ។ ឥធេកច្ចោ សង្ឃគតោបិ កាយិកំ បាគព្ភិយំ ទស្សេតិ គណគតោបិ កាយិកំ បាគព្ភិយំ ទស្សេតិ ភោជនសាលាយបិ កាយិកំ បាគព្ភិយំ ទស្សេតិ ជន្តាឃរេបិ កាយិកំ បាគព្ភិយំ ទស្សេតិ ឧទកតិត្ថេបិ កាយិកំ បាគព្ភិយំ ទស្សេតិ អន្តរឃរំ បវិសន្តោបិ កាយិកំ បាគព្ភិយំ ទស្សេតិ អន្តរឃរំ បវិដ្ឋោបិ កាយិកំ បាគព្ភិយំ ទស្សេតិ ។

សេចក្តីកំណាញ់អាយតនៈ ក៏ហៅថា កំណាញ់ ទាំងហៅថា ការប្រកាន់នេះ លោកហៅថា សេចក្តីកំណាញ់ ។ សេចក្តីកំណាញ់នេះ បុគ្គលណាលះបង់ ផ្តាច់បង់ ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមិនមានសេចក្តីកំណាញ់ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមិនមានសេចក្តីប្រាថ្នា អ្នកមិនមានសេចក្តីកំណាញ់ ។

(៧៩) អធិប្បាយពាក្យថា អ្នកមិនមានការឃ្នើសឃ្នង ជាអ្នកដែលគេមិនគួរខ្ពើម ត្រង់ពាក្យថា ការឃ្នើសឃ្នង បានដល់ការឃ្នើសឃ្នង ៣ គឺការឃ្នើសឃ្នងប៉ែកខាងកាយ១ ការឃ្នើសឃ្នងប៉ែកខាងវាចា ១ ការឃ្នើសឃ្នងប៉ែកខាងចិត្ត ១ ។ ការឃ្នើសឃ្នងប៉ែកខាងកាយ តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ ទៅក្នុងសង្ឃ សំដែងការឃ្នើសឃ្នងប៉ែកខាងកាយខ្លះ ទៅក្នុងគណៈ សំដែងការឃ្នើសឃ្នងប៉ែកខាងកាយខ្លះ សំដែងការឃ្នើសឃ្នងប៉ែកខាងកាយក្នុងពេលឆាន់ខ្លះ សំដែងការឃ្នើសឃ្នងប៉ែកខាងកាយក្នុងពេលភ្លើងខ្លះ សំដែងការឃ្នើសឃ្នង ប៉ែកខាងកាយក្នុងកំពង់ទឹកខ្លះ កំពុងចូលទៅកាន់ចន្លោះផ្ទះ សំដែងការឃ្នើសឃ្នងប៉ែកខាងកាយខ្លះ ចូលទៅហើយកាន់ចន្លោះផ្ទះ សំដែងការឃ្នើសឃ្នងប៉ែកខាងកាយខ្លះ ។

## ទសមោ បុរាភេទសុត្តនិទ្ទេសោ

កថំ សង្ឃគតោ កាយិកំ បាគព្ភិយំ ទស្សេតិ ។ ឥធេកច្ចោ សង្ឃគតោ អចិត្តីការកតោ ថេរេ ភិក្ខូ ឃដ្ដយន្តោបិ តិដ្ឋតិ ឃដ្ដយន្តោបិ និសីទតិ បុរតោបិ តិដ្ឋតិ បុរតោបិ និសីទតិ ឧច្ចេបិ អាសនេ និសីទតិ សសីសំ បារុបិត្វាបិ និសីទតិ ឋិតកោបិ ភណតិ ពាហាវិក្ខេបកោបិ ភណតិ ឯវំ សង្ឃគតោ កាយិកំ បាគព្ភិយំ ទស្សេតិ ។

កថំ គណគតោ កាយិកំ បាគព្ភិយំ ទស្សេតិ ។ ឥធេកច្ចោ គណគតោ អចិត្តីការកតោ ថេរានំ ភិក្ខូនំ អនុបាហនានំ ចង្កមន្តានំ សឧបាហនោ ចង្កមតិ នីចេ ចង្កមេ ចង្កមន្តានំ ឧច្ចេ ចង្កមេ ចង្កមតិ ឆមាយំ ចង្កមន្តានំ ចង្កមេ ចង្កមតិ ឃដ្ដយន្តោបិ តិដ្ឋតិ ឃដ្ដយន្តោបិ និសីទតិ បុរតោបិ តិដ្ឋតិ បុរតោបិ និសីទតិ ឧច្ចេបិ អាសនេ និសីទតិ សសីសំ បារុបិត្វាបិ និសីទតិ ឋិតកោបិ ភណតិ ពាហាវិក្ខេបកោបិ ភណតិ ឯវំ គណគតោ កាយិកំ បាគព្ភិយំ ទស្សេតិ ។

កថំ ភោជនសាលាយ កាយិកំ បាគព្ភិយំ ទស្សេតិ ។

## បុរាភេទសុត្តនិទ្ទេស ទី ១០

ភិក្ខុទៅកាន់សង្ឃ សំដែងការឃ្នើសឃ្នងប៉ែកខាងកាយ តើដូចម្តេច ៗ ភិក្ខុខ្លះក្នុងសាសនានេះ ទៅកាន់សង្ឃ មិនធ្វើសេចក្តីកោតក្រែង គឺឈរប្រជ្រៀតពួកភិក្ខុជាថេរៈខ្លះ អង្គុយប្រជ្រៀតខ្លះ ឈរខាងមុខខ្លះ អង្គុយខាងមុខខ្លះ អង្គុយលើអាសនៈខ្ពស់ខ្លះ អង្គុយទទូរក្បាលខ្លះឈរនិយាយខ្លះ និយាយពាំសដៃខ្លះ ភិក្ខុទៅកាន់សង្ឃ សំដែងការឃ្នើសឃ្នងប៉ែកខាងកាយ យ៉ាងនេះឯង ៗ ភិក្ខុទៅកាន់គណៈ សំដែងនូវការឃ្នើសឃ្នងប៉ែកខាងកាយ តើដូចម្តេច ៗ ភិក្ខុខ្លះក្នុងសាសនានេះ ទៅកាន់គណៈ មិនធ្វើសេចក្តីកោតក្រែង គឺកាលពួកភិក្ខុជាថេរៈ មិនពាក់ស្បែកជើងចង្ក្រម ខ្លួនពាក់ស្បែកជើងចង្ក្រម កាលពួកភិក្ខុជាថេរៈចង្ក្រមក្នុងទីចង្ក្រមដ៏ទាប ខ្លួនចង្ក្រមក្នុងទីចង្ក្រមដ៏ខ្ពស់ កាលពួកភិក្ខុជាថេរៈ ចង្ក្រមលើផែនដី ខ្លួនចង្ក្រមក្នុងទីចង្ក្រម ឈរប្រជ្រៀតខ្លះ អង្គុយប្រជ្រៀតខ្លះ ឈរខាងមុខខ្លះ អង្គុយខាងមុខខ្លះ អង្គុយលើអាសនៈខ្ពស់ខ្លះ អង្គុយទទូរក្បាលខ្លះ ឈរនិយាយខ្លះ និយាយពាំសដៃខ្លះ ភិក្ខុទៅកាន់គណៈ សំដែងការឃ្នើសឃ្នងប៉ែកខាងកាយ យ៉ាងនេះឯង ៗ

ភិក្ខុសំដែងការឃ្នើសឃ្នងប៉ែកខាងកាយក្នុងពេលឆាន់ តើដូចម្តេច ៗ

ឥធេកច្ចោ ភោជនសាលាយ អចិត្តីការកតោ ថេរេ ភិក្ខូ អនុបខជ្ជ និសីទតិ នវេបិ ភិក្ខូ អាសនេន បដិ-ពាហតិ ឃដ្ដយន្តោបិ តិដ្ឋតិ ឃដ្ដយន្តោបិ និសីទតិ បុរតោបិ តិដ្ឋតិ បុរតោបិ និសីទតិ ឧច្ចេបិ អាសនេ និសីទតិ សសីសំ បារុបិត្វាបិ និសីទតិ ឋិតកោបិ ភណតិ ពាហាវិក្ខេបកោបិ ភណតិ ឥទំ ភោជន-សាលាយ កាយិកំ បាគព្ភិយំ ហោតិ ។

កថំ ជន្តាឃរេ កាយិកំ បាគព្ភិយំ ហោតិ ។ ឥធេកច្ចោ ជន្តាឃរេ អចិត្តីការកតោ ថេរេ ភិក្ខូ ឃដ្ដយន្តោបិ តិដ្ឋតិ ឃដ្ដយន្តោបិ និសីទតិ បុរតោបិ តិដ្ឋតិ បុរតោបិ និសីទតិ ឧច្ចេបិ អាសនេ និសីទតិ អនាបុច្ឆាបិ កដ្ឋំ បក្ខិបតិ អនាបុច្ឆាបិ ទ្វារំ បិទហតិ(១) ឥទំ ជន្តាឃរេ កាយិកំ បាគព្ភិយំ ហោតិ ។

កថំ ឧទកតិត្ថេ កាយិកំ បាគព្ភិយំ ហោតិ ។ ឥធេកច្ចោ ឧទកតិត្ថេ អចិត្តីការកតោ

---

១ ឱ. ម. អនាបុច្ឆាបិ អនជ្ឈិដ្ឋោបិ កដ្ឋំ បក្ខិបតិ ទ្វារំ បិទហតិ ពាហាវិក្ខេបកោបិ ភណតិ ។

ភិក្ខុខ្លះក្នុងសាសនានេះ មិនធ្វើសេចក្តីកោតក្រែងក្នុងពេលឆាន់ គឺអង្គុយប្រជ្រៀតពួកភិក្ខុជាថេរៈខ្លះ ឃាត់ពួកភិក្ខុថ្មី ដោយអាសនៈខ្លះ ឈរប្រជ្រៀតខ្លះ អង្គុយប្រជ្រៀតខ្លះ ឈរខាងមុខខ្លះ អង្គុយខាងមុខខ្លះ អង្គុយលើអាសនៈខ្ពស់ខ្លះ អង្គុយទទូរក្បាលខ្លះ ឈរនិយាយខ្លះ និយាយរវាសដៃខ្លះ ភិក្ខុសំដែងការឃ្វើសឃ្វងប៉ែកខាងកាយ ក្នុងពេលឆាន់ យ៉ាងនេះឯង ។

ភិក្ខុសំដែងការឃ្វើសឃ្វងប៉ែកខាងរោងភ្លើង តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ មិនធ្វើសេចក្តីកោតក្រែងក្នុងរោងភ្លើង គឺឈរប្រជ្រៀតពួកភិក្ខុជាថេរៈខ្លះ អង្គុយប្រជ្រៀតខ្លះ ឈរខាងមុខខ្លះ អង្គុយខាងមុខខ្លះ អង្គុយលើអាសនៈខ្ពស់ខ្លះ មិនប្រាប់សិនហើយដាក់អុសខ្លះ មិនប្រាប់សិនហើយបិទទ្វារខ្លះ ភិក្ខុសំដែងការឃ្វើសឃ្វងប៉ែកខាងកាយ ក្នុងរោងភ្លើង យ៉ាងនេះឯង ។

ភិក្ខុសំដែងការឃ្វើសឃ្វងប៉ែកខាងកាយ ក្នុងកំពង់ទឹក តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ មិនធ្វើសេចក្តីកោតក្រែងក្នុងកំពង់ទឹក

## ទសមោ បុរាភេទសុត្តនិទ្ទេសោ

ថេរេ ភិក្ខូ ឃដ្ដយន្តោបិ ឱតរតិ បុរតោបិ ឱតរតិ ឃដ្ដយន្តោបិ ន្ហាយតិ បុរតោបិ ន្ហាយតិ ឧបរិបិ(១) ន្ហាយតិ ឃដ្ដយន្តោបិ ឧត្តរតិ បុរតោបិ ឧត្តរតិ ឧបរិបិ(២) ឧត្តរតិ ឯវំ ឧទកតិត្ថេ កាយិកំ អាបត្តឹ អាបជ្ជតិ ។

កថំ អន្តរឃរំ បវិសន្តោ កាយិកំ អាបត្តឹ អាបជ្ជតិ ។ ឥធេកច្ចោ អន្តរឃរំ បវិសន្តោ អចិត្តីការកោ ថេរេ ភិក្ខូ ឃដ្ដយន្តោបិ គច្ឆតិ បុរតោបិ គច្ឆតិ ឱក្កម្មបិ ថេរានំ ភិក្ខូនំ បុរតោ គច្ឆតិ ឯវំ អន្តរឃរំ បវិសន្តោ កាយិកំ អាបត្តឹ អាបជ្ជតិ ។

កថំ អន្តរឃរំ បវិដ្ឋោ កាយិកំ អាបត្តឹ អាបជ្ជតិ។ ឥធេកច្ចោ អន្តរឃរំ បវិដ្ឋោ ន បវិស ភន្តេតិ វុច្ចមានោ បវិសតិ ន តិដ្ឋ ភន្តេតិ វុច្ចមានោ តិដ្ឋតិ ន និសីទ ភន្តេតិ វុច្ចមានោ និសីទតិ អនោកាសម្បិ បវិសតិ អនោកាសេបិ តិដ្ឋតិ អនោកាសេបិ និសីទតិ យានិ តានិ ហោន្តិ កុលានំ ឱវរកានិ គូឡ្ហានិ ច បដិច្ឆន្នានិ ច យត្ថ កុលិត្ថិយោ កុលធីតរោ កុលសុណ្ហាយោ កុលកុមារិយោ និសីទន្តិ តត្ថបិ សហសា បវិសតិ

---

១ ២ ឱ. ម. ឧបរិតោបិ ។

គឺចុះទៅប្រជ្រៀតពួកភិក្ខុជាថេរៈខ្លះ ចុះទៅខាងមុខខ្លះ ងូតប្រជ្រៀតខ្លះ ងូតខាងមុខខ្លះ ងូតខាងលើខ្លះ ឡើងប្រជ្រៀតខ្លះ ឡើងខាងមុខខ្លះ ឡើងខាងលើខ្លះ ភិក្ខុសំដែងការឃ្នើសឃ្នងប៉ែកខាងកាយ ក្នុងកំពង់ទឹក យ៉ាងនេះឯង ។

ភិក្ខុកំពុងចូលទៅកាន់ចន្លោះផ្ទះ សំដែងការឃ្នើសឃ្នងប៉ែកខាងកាយ តើដូចម្តេច ។ ភិក្ខុខ្លះ ក្នុងសាសនានេះ កំពុងចូលទៅកាន់ចន្លោះផ្ទះ មិនធ្វើសេចក្តីកោតក្រែង គឺដើរប្រជ្រៀតពួកភិក្ខុជាថេរៈខ្លះ ដើរខាងមុខខ្លះ កន្លងហើយដើរខាងមុខពួកភិក្ខុជាថេរៈខ្លះ ភិក្ខុកំពុងចូលទៅកាន់ចន្លោះផ្ទះ សំដែងការឃ្នើសឃ្នងប៉ែកខាងកាយ យ៉ាងនេះឯង ។

ភិក្ខុចូលទៅកាន់ចន្លោះផ្ទះ សំដែងការឃ្នើសឃ្នង ប៉ែកខាងកាយ តើដូចម្តេច ។ ភិក្ខុខ្លះ ក្នុងសាសនានេះ ចូលទៅកាន់ចន្លោះផ្ទះ គេមិនទាន់និយាយថា សូមចូលមកលោកម្ចាស់ ក៏ចូលទៅ គេមិនទាន់និយាយថា សូមឈររង់សិនលោកម្ចាស់ ក៏ឈររង់ គេមិនទាន់និយាយថា សូមគង់លោកម្ចាស់ ក៏អង្គុយ ចូលទៅកាន់ទីមិនមានឱកាសខ្លះ ឈរក្នុងទីមិនមានឱកាសខ្លះ អង្គុយក្នុងទីមិនមានឱកាសខ្លះ ម្នីម្នាចូលទៅក្នុងបន្ទប់ទាំងឡាយ របស់ត្រកូលទាំងឡាយ ជាទីលាក់ពួនបិទបាំង ដែលពួកស្ត្រីក្នុងត្រកូល ដែលពួកកូនស្រីរបស់ត្រកូល ដែលពួកកូនប្រសាស្រីរបស់ត្រកូល ដែលពួកកុមារីរបស់ត្រកូល កំពុងអង្គុយនោះខ្លះ

កុមារកស្សបិ សីសំ បរាមសតិ ឯវំ អន្តរឃរំ បវិដ្ឋោ កាយិកំ បាគព្ភិយំ ទស្សេតិ ។ ឥទំ កាយិកំ បាគព្ភិយំ(១) ។

កតមំ វាចសិកំ បាគព្ភិយំ ។ ឥធេកច្ចោ សង្ឃគតោបិ វាចសិកំ បាគព្ភិយំ ទស្សេតិ គណគតោបិ វាចសិកំ បាគព្ភិយំ ទស្សេតិ អន្តរឃរំ បវិដ្ឋោបិ វាចសិកំ បាគព្ភិយំ ទស្សេតិ ។

កថំ សង្ឃគតោ វាចសិកំ បាគព្ភិយំ ទស្សេតិ ។ ឥធេកច្ចោ សង្ឃគតោ អចិត្តីការកតោ ថេរេ ភិក្ខូ អនាបុច្ឆា វា អនជ្ឈិដ្ឋោ វា អារាមគតានំ ភិក្ខូនំ ធម្មំ ភណតិ បញ្ហំ វិស្សជ្ជេតិ បាតិមោក្ខំ ឧទ្ទិសតិ ឋិតកោបិ ភណតិ ពាហាវិក្ខេបកោបិ ភណតិ ឯវំ សង្ឃគតោ វាចសិកំ បាគព្ភិយំ ទស្សេតិ ។

កថំ គណគតោ វាចសិកំ បាគព្ភិយំ ទស្សេតិ ។ ឥធេកច្ចោ គណគតោ អចិត្តីការកតោ ថេរេ ភិក្ខូ អនាបុច្ឆា វា អនជ្ឈិដ្ឋោ វា អារាមគតានំ ភិក្ខូនំ ធម្មំ ភណតិ បញ្ហំ វិស្សជ្ជេតិ ឋិតកោបិ ភណតិ ពាហាវិក្ខេបកោបិ ភណតិ

១ ម. បាគព្ភិយំ ទស្សេតិ ។

ស្ទាបអង្អែលក្បាលរបស់កុមារតូចខ្លះ ភិក្ខុចូលទៅកាន់ចន្លោះផ្ទះ សំដែងការឃ្លើសឃ្លងប៉ែកខាងកាយ យ៉ាងនេះឯង ។ នេះ ការឃ្លើសឃ្លងប៉ែកខាងកាយ ។

ការឃ្លើសឃ្លងប៉ែកខាងវាចា តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ ទៅក្នុងសង្ឃ សំដែងការឃ្លើសឃ្លងប៉ែកខាងវាចាខ្លះ ទៅក្នុងគណៈ សំដែងការឃ្លើសឃ្លងប៉ែកខាងវាចាខ្លះ ចូលទៅក្នុងចន្លោះផ្ទះ សំដែងការឃ្លើសឃ្លងប៉ែកខាងវាចាខ្លះ ។

ភិក្ខុទៅក្នុងសង្ឃ សំដែងការឃ្លើសឃ្លងប៉ែកខាងវាចា តើដូចម្តេច ។ ភិក្ខុខ្លះ ក្នុងសាសនានេះ ទៅក្នុងសង្ឃ មិនធ្វើសេចក្តីគោរពក្រែង គឺមិនប្រាប់ពួកភិក្ខុជាថេរៈ ឬ (ពួកភិក្ខុជាថេរៈ) មិនបានអារាធនា ក៏សំដែងធម៌ វិសជ្ជនាប្រស្នា សំដែងបាតិមោក្ខ ដល់ពួកភិក្ខុដែលទៅកាន់អារាម ឈរនិយាយខ្លះ និយាយវាសដៃខ្លះ ភិក្ខុទៅក្នុងសង្ឃ សំដែងការឃ្លើសឃ្លងប៉ែកខាងវាចា យ៉ាងនេះឯង ។

ភិក្ខុទៅក្នុងគណៈ សំដែងការឃ្លើសឃ្លងប៉ែកខាងវាចា តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ ទៅក្នុងគណៈ មិនធ្វើសេចក្តីគោរពក្រែង គឺមិនប្រាប់ពួកភិក្ខុជាថេរៈ ឬ (ភិក្ខុជាថេរៈ) មិនបានអារាធនា ក៏សំដែងធម៌ វិសជ្ជនាប្រស្នាដល់ពួកភិក្ខុដែលទៅកាន់អារាម ឈរនិយាយខ្លះ និយាយវាសដៃខ្លះ

ទសមោ បុរាភេទសុត្តនិទ្ទេសោ

អារាមគតានំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ ធម្មំ ភណតិ បញ្ហំ វិសជ្ជេតិ ឋិតកោបិ ភណតិ ពាហាវិក្ខេប-កោបិ ភណតិ ឯវំ គណគតោ វាចសិកំ បាគព្ភិយំ ទស្សេតិ ។

កតមំ អន្តរឃរំ បវិដ្ឋោ វាចសិកំ បាគព្ភិយំ ទស្សេតិ ។ ឥធេកច្ចោ អន្តរឃរំ បវិដ្ឋោ ឥត្ថឹ វា កុមារឹ វា អាហ ឥត្ថន្នាមេ ឥត្ថង្គោត្តេ កឹ អត្ថិ យាគុ អត្ថិ ភត្តំ អត្ថិ ខាទនីយំ អត្ថិ កឹ បិវិស្សាម កឹ ភុញ្ជិស្សាម កឹ ខាទិស្សាម កឹ វា អត្ថិ កឹ វា មេ ទស្សថាតិ វិប្បលបតិ ឯវំ អន្តរឃរំ បវិដ្ឋោ វាចសិកំ បាគព្ភិយំ ទស្សេតិ ឥទំ វាចសិកំ បាគព្ភិយំ ។

កតមំ ចេតសិកំ បាគព្ភិយំ ។ ឥធេកច្ចោ ន ឧច្ចាកុលា បព្វជិតោ សមានោ ឧច្ចាកុលា បព្វជិតេន សទ្ធឹ សទិសំ អត្តានំ ទហតិ ចិត្តេន ។ ន មហាកុលា បព្វជិតោ សមានោ មហាកុលា បព្វជិតេន សទ្ធឹ សទិសំ អត្តានំ ទហតិ ចិត្តេន ។ ន មហាភោគកុលា បព្វជិតោ សមានោ មហាភោគកុលា បព្វជិតេន សទ្ធឹ សទិសំ អត្តានំ ទហតិ ចិត្តេន ។

## បុភាភេទសុត្តនិទ្ទេស ទី ១០

សំដែងធម៌ វិសជ្ជនាប្រស្នាដល់ពួកភិក្ខុនី ពួកឧបាសក ពួកឧបាសិកា ដែលទៅកាន់អារាម ឈរនិយាយវាសដែខ្លះ ភិក្ខុទៅក្នុងគណៈ សំដែងការឃ្លើសឃ្លួនប៉ែកខាងវាចា យ៉ាងនេះឯង ៗ

ភិក្ខុចូលទៅកាន់បន្ទោះផ្ទះ សំដែងការឃ្លើសឃ្លួនប៉ែកខាងវាចា តើដូចម្តេច ៗ ភិក្ខុខ្លះ ក្នុងសាសនានេះ ចូលទៅកាន់បន្ទោះផ្ទះ និយាយនឹងស្ត្រី ឬនឹងកុមារី និយាយពាក់ទាក់ថា នែនាងឈ្មោះនេះ នែនាងគោត្រនេះ មានអ្វីទេ មានបបរទេ មានបាយទេ មានបង្អែមទេ អាត្មានឹងផឹកអ្វី បរិភោគអ្វី ស៊ីអ្វី មានអ្វីទេ ពួកនាងនឹងឲ្យអ្វី ដល់អាត្មា ភិក្ខុចូលទៅកាន់បន្ទោះផ្ទះ សំដែងការឃ្លើសឃ្លួនប៉ែកខាងវាចា យ៉ាងនេះឯង ៗ នេះ ការឃ្លើសឃ្លួនប៉ែកខាងវាចា ៗ

ការឃ្លើសឃ្លួនប៉ែកខាងចិត្ត តើដូចម្តេច ៗ ភិក្ខុខ្លះ ក្នុងសាសនានេះ ជាអ្នកមិនមែន (ចេញ) អំពីត្រកូលខ្ពស់ហើយបួសទេ តែមានចិត្តតាំងខ្លួនស្មើនឹងបុគ្គលដែល (ចេញ) អំពីត្រកូលខ្ពស់ហើយបួស ៗ មិនមែនចេញអំពីត្រកូលធំហើយបួសទេ តែមានចិត្តតាំងខ្លួនស្មើនឹងបុគ្គលដែល (ចេញ) អំពីត្រកូលធំហើយបួស ៗ មិនមែន (ចេញ) អំពីត្រកូលមានភោគៈច្រើនហើយបួសទេ តែមានចិត្តតាំងខ្លួនស្មើនឹងបុគ្គលដែល (ចេញ) អំពីត្រកូលមានភោគៈច្រើន ហើយបួស ៗ

ន ឧឡារភោគកុលា បព្វជិតោ សមណោ ។ ន សុត្តន្តិកោ សមណោ សុត្តន្តិកេន សទ្ធឹ សទិសំ អត្តានំ ទហតិ ចិត្តេន ។ ន វិនយធរោ សមណោ ។ ន ធម្មកថិកោ សមណោ ។ ន អារញ្ញិកោ សមណោ ។ ន បិណ្ឌបាតិកោ សមណោ ។ ន បំសុកូលិកោ សមណោ ។ ន តេចីវរិកោ សមណោ ។ ន សបទានចារិកោ សមណោ ។ ន ខលុបច្ឆាភត្តិកោ សមណោ ។ ន នេសជ្ជិកោ សមណោ ។ ន យថាសន្ថតិកោ សមណោ ។ ន បឋមស្ស ឈានស្ស លាភី សមណោ បឋមស្ស ឈានស្ស លាភិនា សទ្ធឹ សទិសំ អត្តានំ ទហតិ ចិត្តេន ។ បេ ។ ន នេវសញ្ញានាសញ្ញាយតនសមាបត្តិយា លាភី សមណោ នេវសញ្ញានាសញ្ញាយតនសមាបត្តិយា លាភិនា សទ្ធឹ សទិសំ អត្តានំ ទហតិ ចិត្តេន ។ ឥទំ ចេតសិកំ បាគព្ភិយំ ។ យស្សិមានិ តីណិ បាគព្ភិយានិ បហីនានិ សមុច្ឆិន្នានិ វូបសន្តានិ បដិប្បស្សទ្ធានិ អភព្វុប្បត្តិកានិ ញាណគ្គិនា ទឌ្ឍានិ សោ វុច្ចតិ អប្បគព្ភោតិ អប្បគព្ភោ ។

មិនមែន (ចេញ) អំពីត្រកូលមានភោគៈ លើសលប់ហើយបួសទេ ។ មិនចេះព្រះសូត្រទេ តែមានចិត្តតាំងខ្លួនស្មើនឹងបុគ្គលដែលចេះព្រះសូត្រ ។ មិនទ្រទ្រង់ព្រះវិន័យ ។ មិនមែនជាធម្មកថិក ។ មិនប្រព្រឹត្តអារញ្ញិកធុតង្គ ។ មិនប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ។ មិនប្រព្រឹត្តបំសុកូលិកធុតង្គ ។ មិនប្រព្រឹត្តតេចីវរិកធុតង្គ ។ មិនប្រព្រឹត្តសបទានចារិកធុតង្គ ។ មិនប្រព្រឹត្តខលុបច្ឆាភត្តិកធុតង្គ ។ មិនប្រព្រឹត្តនេសជ្ជិកធុតង្គ ។ មិនប្រព្រឹត្តយថា-សន្ថតិកធុតង្គ ។ មិនបានបឋមជ្ឈានទេ តែមានចិត្តតាំងខ្លួនស្មើនឹងបុគ្គលដែលបានបឋមជ្ឈាន ។បេ។ មិនបាននេវសញ្ញានាសញ្ញាយតនសមាបត្តិទេ តែមានចិត្តតាំងខ្លួនស្មើនឹងបុគ្គលបាននេវសញ្ញានាសញ្ញាយតនសមាបត្តិ ។ នេះ ការឃ្មើសឃ្មើងប៉ែកខាងចិត្ត ។ ការឃ្មើសឃ្មើង ៣ នេះ បុគ្គលណាលះបង់ ផ្តាច់បង់ ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមិនមានការឃ្មើសឃ្មើង ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមិនមានការឃ្មើសឃ្មើង ។

ទសមោ បុរាភេទសុត្តនិទ្ទេសោ

(៨០) អជេគុច្ឆោតិ អត្ថិ បុគ្គលោ ជេគុច្ឆោ អត្ថិ អជេគុច្ឆោ ។ កតមោ ច បុគ្គលោ ជេគុច្ឆោ ។ ឥធេកច្ចោ បុគ្គលោ ទុស្សីលោ ហោតិ បាបធម្មោ អសុចិសង្កស្សរសមាចារោ បដិច្ឆន្នកម្មន្តោ អស្សមណោ សមណបដិញ្ញោ អព្រហ្មចារី ព្រហ្មចារិបដិញ្ញោ អន្តោបូតិ អវស្សុតោ កសម្ពុជាតោ អយំ វុច្ចតិ បុគ្គលោ ជេគុច្ឆោ ។ អថវា កោធនោ ហោតិ ឧបាយាសពហុលោ អប្បម្បិ វុត្តោ សមានោ អភិសជ្ជតិ កុប្បតិ ព្យាបជ្ជតិ បតិដ្ឋីយតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ អយំ វុច្ចតិ បុគ្គលោ ជេគុច្ឆោ ។ អថវា កោធនោ ហោតិ ឧបនាហី ហោតិ មក្ខី ហោតិ បឡាសី ហោតិ ឥស្សុកី ហោតិ មច្ឆរី ហោតិ សឋោ ហោតិ មាយាវី ហោតិ ថទ្ធោ ហោតិ អតិមានី ហោតិ បាបិច្ឆោ ហោតិ មិច្ឆាទិដ្ឋិ ហោតិ សន្ទិដ្ឋិបរាមាសី ហោតិ អាធានគ្គាហី ទុប្បដិនិស្សគ្គី ហោតិ អយំ វុច្ចតិ បុគ្គលោ ជេគុច្ឆោ ។

## បុភភេទសុត្តនិទ្ទេស ទី ១០

(៨០) ពាក្យថា ជាអ្នកដែលគេមិនគួរខ្ពើម អធិប្បាយថា បុគ្គលដែលគេគួរខ្ពើមក៏មាន ដែលគេមិនគួរខ្ពើមក៏មាន ។ បុគ្គលដែលគេគួរខ្ពើម តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងសាសនានេះ ជាអ្នកទ្រុស្ដសីល មានធម៌ដ៏លាមក មានមារយាទដែលបុគ្គលគួររឭកឃើញ ដោយសេចក្ដីរង្កៀសថាមិនស្អាត មានអំពើបិទបាំងទុក មិនមែនជាសមណៈ ប្ដេជ្ញាខ្លួនថាជាសមណៈ មិនមែនជាព្រហ្មចារីបុគ្គល ប្ដេជ្ញាខ្លួនថាជាព្រហ្ម-ចារីបុគ្គល ជាអ្នកស្អុយក្នុង ជោគដោយរាគៈ ជាបុគ្គលជ្រោកជ្រាក នេះហៅថា បុគ្គលដែលគេគួរខ្ពើម ។ មួយទៀត បុគ្គលជាអ្នកក្រោធច្រើនដោយសេចក្ដីចង្អៀតចង្អល់ សូម្បីគេនិយាយតិចតួច ក៏រមែងចាប់ថ្នាក់ ខឹង គុំគួន តបត ធ្វើនូវសេចក្ដីក្រោធ ប្រទូស្ដ អាក់អន់ ឲ្យប្រាកដ នេះ ហៅថា បុគ្គលដែលគេគួរខ្ពើម ។ មួយវិញទៀត បុគ្គលជាអ្នកក្រោធ ចងសេចក្ដីក្រោធទុក លុបគុណគេ វាយឫកស្មើ ប្រ-ណែន កំណាញ់ អួតអាង មានមាយា រឹងរូស មើលងាយគេ មានប្រាថ្នាដ៏លាមក មានសេចក្ដីយល់ខុស ប្រកាន់តាមសេចក្ដីយល់របស់ខ្លួន ប្រកាន់មាំ ជាអ្នកលះបង់បានដោយក្រ នេះ ហៅថា បុគ្គលដែលគេគួរខ្ពើម ។

កតមោ ច បុគ្គលោ អជេគុច្ឆោ ។ ឥធ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ អយំ វុច្ចតិ បុគ្គលោ អជេគុច្ឆោ ។ អថវា អក្កោធនោ ហោតិ អនុបាយាសពហុលោ ពហុម្បិ វុត្តោ សមានោ ន អភិសជ្ជតិ ន កុប្បតិ ន ព្យាបជ្ជតិ ន បតិដ្ឋីយតិ ន កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ អយំ វុច្ចតិ បុគ្គលោ អជេគុច្ឆោ ។ អថវា អក្កោធនោ ហោតិ អនុបនាហី ហោតិ អមក្ខី ហោតិ អបឡាសី ហោតិ អនិស្សុកី ហោតិ អមច្ឆរី ហោតិ អសឋោ ហោតិ អមាយាវី ហោតិ អថទ្ធោ ហោតិ អនតិមានី ហោតិ ន បាបិច្ឆោ ហោតិ ន មិច្ឆាទិដ្ឋិ ហោតិ អសន្ទិដ្ឋិបរាមាសី ហោតិ អនាធានគ្គាហី សុប្បដិនិស្សគ្គី ហោតិ អយំ វុច្ចតិ បុគ្គលោ អជេគុច្ឆោ ។ សត្តោ កល្យាណបុថុជ្ជនំ ឧបាទាយ អរិយបុគ្គលោ អជេគុច្ឆោតិ អប្បគព្ភោ អជេគុច្ឆោ ។

បុគ្គលដែលគេមិនគួរខ្ពើម តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទាន សិក្សា ក្នុងសិក្ខាបទទាំងឡាយ នេះ ហៅថា បុគ្គលដែលគេមិនគួរខ្ពើម ។ មួយទៀត ភិក្ខុជាអ្នកមិនក្រោធ មិនច្រើនដោយសេចក្ដីបង្អៀតបង្អល់ បើទុកជាគេនិយាយច្រើន ក៏មិនចាប់ថ្នាក់ មិនខឹង មិនគុំគួន មិនតបត មិនធ្វើនូវសេចក្ដីក្រោធ សេចក្ដីប្រទូស្ដ និងសេចក្ដីអាក់អន់ឲ្យប្រាកដ នេះ ហៅថា បុគ្គលដែលគេមិនគួរខ្ពើម ។ មួយវិញទៀត បុគ្គលជាអ្នកមិនក្រោធ មិនចងសេចក្ដីក្រោធទុក មិនលុបគុណគេ មិនរាយឫកស្មើ មិនច្រណែន មិនកំណាញ់ មិនអួតអាង មិនមានមាយា មិនរឹងត្អឹង មិនមើលងាយគេ មិនមានសេចក្ដីប្រាថ្នាដ៏លាមក មិនមានសេចក្ដីយល់ខុស មិនប្រកាន់តាមសេចក្ដីយល់របស់ខ្លួន មិនប្រកាន់មាំ ជាអ្នកលះបង់បានដោយងាយ នេះ ហៅថា បុគ្គលដែលគេមិនគួរខ្ពើម ។ អរិយបុគ្គលទាំងអស់ រាប់ទាំងកល្យាណបុថុជ្ជន ឈ្មោះថា បុគ្គលដែលគេមិនគួរខ្ពើម ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលមិនមានការឃ្លើសឃ្លង ជាអ្នកដែលគេមិនគួរខ្ពើម ។

## ទសមោ បុរាភេទសុត្តនិទ្ទេសោ

(៨១) បេសុណេយ្យេ ច នោ យុត្តោតិ បេសុញ្ញន្តិ ឥធេកច្ចោ បិសុណវាចោ ហោតិ ឥតោ សុត្វា អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ឥមេសំ អក្ខាតា អមូសំ ភេទាយ ឥតិ សមគ្គានំ វា ភេត្តា ភិន្នានំ វា អនុប្បទាតា វគ្គារាមោ វគ្គរតោ វគ្គនន្ទី វគ្គករណិំ វាចំ ភាសិតា ហោតិ ឥទំ វុច្ចតិ បេសុញ្ញំ ។ អបិច ទ្វីហិ ការណេហិ បេសុញ្ញំ ឧបសំហរតិ បិយកម្យតាយ វា ភេទាធិប្បាយេន វា ។

កថំ បិយកម្យតាយ បេសុញ្ញំ ឧបសំហរតិ ។ ឥមស្ស បិយោ ភវិស្សាមិ មនាបោ ភវិស្សាមិ វិស្សាសិកោ ភវិស្សាមិ អព្ភន្តរិកោ ភវិស្សាមិ សុហទយោ ភវិស្សាមីតិ ឯវំ បិយកម្យតាយ បេសុញ្ញំ ឧបសំហរតិ ។

កថំ ភេទាធិប្បាយេន បេសុញ្ញំ ឧបសំហរតិ ។

## បុគ្គលនិទ្ទេស ទី ១០

(៨១) ពាក្យថា បុគ្គលមិនប្រកបក្នុងការញុះញង់ ត្រង់ពាក្យថា ការញុះញង់ អធិប្បាយថា បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកនិយាយញុះញង់ គឺឮអំពីពួកជននេះ ប្រាប់ពួកជនឯណោះ ដើម្បីបំបែកពួកជននេះ ឬឮអំពីពួកជនឯណោះ ប្រាប់ពួកជននេះ ដើម្បីបំបែកពួកជនឯណោះ ឬក៏ជាអ្នកបំបែកពួកជន ដែលព្រមព្រៀងគ្នាក្តី ថែមកំឡាំងដល់ពួកជនដែលបែកគ្នាហើយក្តី ជាអ្នកមានពួកជាទីត្រេកអរ ត្រេកអរហើយក្នុងពួក រីករាយក្នុងពួក ជាអ្នកនិយាយនូវពាក្យជាគ្រឿងធ្វើនូវពួក នេះ លោកហៅថា ការញុះញង់ ។ មួយទៀត បុគ្គលរមែងសន្សំការញុះញង់ ដោយហេតុពីរគឺ ដោយសេចក្តីប្រាថ្នាឲ្យគេស្រឡាញ់ ឬដោយសេចក្តីប៉ុនប៉ងដើម្បីបំបែក ។

បុគ្គលសន្សំការញុះញង់ ព្រោះសេចក្តីប្រាថ្នាឲ្យគេស្រឡាញ់ តើដូចម្តេច ។ បុគ្គលសន្សំការញុះញង់ ព្រោះសេចក្តីប្រាថ្នាឲ្យគេស្រឡាញ់យ៉ាងនេះ ដូចនេះថា អាត្មាអញនឹងបានជាទីស្រឡាញ់នៃជននេះ នឹងបានជាទីពេញចិត្ត នឹងបានជាទីស្និទ្ធស្នាល នឹងបានជាអ្នកនៅខាងក្នុង នឹងបានជាអ្នកមានចិត្តល្អ ។

បុគ្គលមានសេចក្តីប៉ុនប៉ង ដើម្បីបំបែក រមែងសន្សំការញុះញង់ តើដូចម្តេច ។

កថំ ឥមេ នានា អស្សុ វិនា អស្សុ វគ្គា អស្សុ ទ្វេធា អស្សុ ទ្វេជ្ឈា អស្សុ ទ្វេបក្ខា អស្សុ ភិជ្ជេយ្យុំ ន សមាគច្ឆេយ្យុំ ទុក្ខំ ន ផាសុ វិហរេយ្យុន្តិ ឯវំ ភេទាធិប្បាយោ បេសុញ្ញំ ឧបសំហរតិ ។

យស្សេតំ បេសុញ្ញំ បហីនំ សមុច្ឆិន្នំ វូបសន្តំ បដិប្បស្សទ្ធំ អភព្វុប្បត្តិកំ ញាណគ្គិនា ទឌ្ឍំ សោ បេសុញ្ញេ ន យុត្តោ នប្បយុត្តោ នាយុត្តោ ន សមា-យុត្តោតិ បេសុណេយ្យេ ច នោ យុត្តោ ។

តេនាហ ភគវា

បដិលីនោ អកុហកោ អបិហាលុ អមច្ឆរី
អប្បគព្ភោ អជេគុច្ឆោ បេសុណេយ្យេ ច នោ យុត្តោតិ ។

(៨២) សាតិយេសុ អនស្សាវី អតិមានេ ច នោ យុត្តោ
សណ្ហោ ច បដិភាណវា ន សទ្ធោ ន វិរជ្ជតិ ។

បុគ្គលមានសេចក្តីប៉ុនប៉ង ដើម្បីបំបែក រមែងសន្សំការញុះញង់ យ៉ាងនេះថា ធ្វើម្តេចឲ្យពួកជននេះ ផ្សេងៗពីគ្នា ទីទៃពីគ្នា ជាពួក ជាចំណែកពីរ បែកគ្នាជាពីរ ជាពីរក្រុម គប្បីបែកគ្នា មិនគប្បីប្រួមគ្នា នៅជាទុក្ខ មិនសប្បាយ ។

ការញុះញង់នុ៎ះ ដែលបុគ្គលណា បានលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ មិនប្រកប មិនឈម មិនជ្ពាក់ មិនស្រុបចុះក្នុងការញុះញង់ ហេតុនោះ (ទ្រង់ត្រាស់ថា) រមែងមិនប្រកប ក្នុងការញុះញង់ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

បុគ្គលអ្នកវៀរចិត្ត អ្នកមិនកុហក អ្នកមិនមានសេចក្តីប្រាថ្នា
អ្នកមិនមានសេចក្តីកំណាញ់ អ្នកមិនមានការយើសយ្ហង អ្នក
ដែលគេមិនគួរខ្ពើម រមែងជាអ្នកមិនប្រកប ក្នុងការញុះញង់ ។

(៨៦) បុគ្គលអ្នកមិនស្រស់ស្រាយ ក្នុងវត្ថុជាទីត្រេកអរផង អ្នកមិន
ប្រកបក្នុងការមើលងាយផង អ្នកទន់ភ្លន់ផង អ្នកមានប្រាជ្ញា
វាងវៃផង រមែងជាអ្នកមិនមានជំនឿ មិនប្រាសចាកតម្រេក ។

## ទសមោ បុរាភេទសុត្តនិទ្ទេសោ

(៨៣) សាតិយេសុ អនស្សាវីតិ សាតិយា វុច្ចន្តិ បញ្ច កាមគុណា ។ កិំការណា សាតិយា វុច្ចន្តិ បញ្ច កាមគុណា ។ យេភុយ្យេន ទេវមនុស្សា បញ្ចកាមគុណេ ឥច្ឆន្តិ សាទិយន្តិ បត្ថយន្តិ បិហយន្តិ អភិជប្បន្តិ តំការណា សាតិយា វុច្ចន្តិ បញ្ច កាមគុណា ។ យេសំ ឯសា សាតិយា តណ្ហា អប្បហីនា តេសំ ចក្ខុតោ រូបតណ្ហា សវតិ បសវតិ(១) សន្ទតិ បវត្តតិ ។ សោតតោ សទ្ទតណ្ហា ។ ឃានតោ គន្ធតណ្ហា ។ ជិវ្ហាតោ រសតណ្ហា ។ កាយតោ ផោដ្ឋព្វតណ្ហា ។ មនតោ ធម្មតណ្ហា សវតិ បសវតិ សន្ទតិ បវត្តតិ ។ យេសំ ឯសា សាតិយា តណ្ហា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា តេសំ ចក្ខុតោ រូបតណ្ហា ន សវតិ ន បសវតិ ន សន្ទតិ ន បវត្តតិ ។ សោតតោ សទ្ទតណ្ហា ។បេ។ មនតោ ធម្មតណ្ហា ន សវតិ ន បសវតិ ន សន្ទតិ ន បវត្តតីតិ សាតិយេសុ អនស្សាវី ។

---

១ ម. សវតិ អាសវតិ ។

បុរាភេទសុត្តនិទ្ទេស ទី ១០

(៨៣) ពាក្យថា អ្នកមិនស្រស់ស្រាយ ក្នុងវត្ថុជាទីត្រេកអរ អធិប្បាយថា កាមគុណ ៥ លោកហៅថា វត្ថុជាទីត្រេកអរ ។ កាមគុណ ៥ លោកហៅថា វត្ថុជាទីត្រេកអរ តើព្រោះហេតុអ្វី ។ (ព្រោះថា) ពួកទេវតានិងមនុស្ស ច្រើនតែចង់បាន ត្រេកអរ ប្រាថ្នា ស្រឡាញ់ ក្តួចការ់ នូវកាមគុណ ៥ ហេតុនោះ កាមគុណ ៥ លោកហៅថា វត្ថុជាទីត្រេកអរ ។ តណ្ហាជាទីត្រេកអរនុ៎ះ ដែលពួកជនណា មិនទាន់លះបង់ហើយ រូបតណ្ហារបស់ជននោះ រមែងផ្សាយទៅ សោតទៅ ហូរទៅ ប្រព្រឹត្តទៅតាមចក្ខុ ។ សទ្ទតណ្ហា តាមសោតៈ ។ គន្ធតណ្ហា តាមឃានៈ ។ រសតណ្ហា តាមជិវ្ហា ។ ផោដ្ឋព្វតណ្ហា តាមកាយ ។ ធម្មតណ្ហា រមែងផ្សាយទៅ សោតទៅ ហូរទៅ ប្រព្រឹត្តទៅ តាមចិត្ត ។ តណ្ហាជាទីត្រេកអរនុ៎ះ ដែលពួកជនណា បានលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ រូបតណ្ហារបស់ពួកជននោះ រមែងមិនផ្សាយទៅ មិនសោតទៅ មិនហូរទៅ មិនប្រព្រឹត្តទៅ តាមចក្ខុ ។ សទ្ទតណ្ហា តាមសោត ។បេ។ ធម្មតណ្ហា រមែងមិនផ្សាយ មិនសោតទៅ មិនហូរទៅ មិនប្រព្រឹត្តទៅ តាមចិត្ត ។ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមិនស្រស់ស្រាយ ក្នុងវត្ថុជាទីត្រេកអរ ។

(៨៤) អតិមានេ ច នោ យុត្តោតិ កតមោ អតិមានោ ។ ឥធេកច្ចោ បរំ អតិមញ្ញតិ ជាតិយា វា គោត្តេន វា ។ បេ ។ អញ្ញតរញ្ញតរេន វា វត្ថុនា ។ យោ ឯវរូបោ មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណតិ ឧណ្ណាមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ វុច្ចតិ អតិមានោ ។ យស្សេសោ អតិមានោ បហីនោ សមុច្ឆិន្នោ វូបសន្តោ បដិប្បស្សទ្ធោ អភព្វុប្បត្តិកោ ញាណគ្គិនា ទឌ្ឍោ សោ អតិមានេ នោ យុត្តោ នប្បយុត្តោ នាយុត្តោ ន សមាយុត្តោតិ អតិមានេ ច នោ យុត្តោ ។

(៨៥) សណ្ហោ ច បដិភាណវាតិ សណ្ហោ(១)កាយកម្មេន សមន្នាគតោតិ សណ្ហោ ។ សណ្ហេន វចីកម្មេន ។ សណ្ហេន មនោកម្មេន សមន្នាគតោតិ សណ្ហោ ។ សណ្ហេហិ សតិបដ្ឋានេហិ សមន្នាគតោតិ សណ្ហោ ។ សណ្ហេហិ សម្មប្បធានេហិ ។ សណ្ហេហិ ឥទ្ធិបាទេហិ ។ សណ្ហេហិ ឥន្ទ្រិយេហិ ។ សណ្ហេហិ ពលេហិ ។

---

១ ឱ. ម. សណ្ហោតិ សណ្ហេន ។

(៨៤) ពាក្យថា អ្នកមិនប្រកបក្នុងការមើលងាយ អធិប្បាយថា ចុះការមើលងាយ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ រមែងមើលងាយបុគ្គលដទៃ ដោយជាតិ ឬដោយគោត្រ ។បេ។ ឬក៏ដោយវត្ថុណាមួយ ។ មានះ អាការមានះ ភាពនៃមានះ ការឆ្មើងឆ្មៃ អាការឆ្មើងឆ្មៃ ចិត្តដូចទង់ជ័យ ការប្រកាន់ចិត្ត ភាពនៃចិត្តប្រាថ្នាដូចជាទង់ ឯណា មានសភាពបែបនេះ នេះហៅថា សេចក្តីមើលងាយ ។ សេចក្តីមើលងាយនុ៎ះ បុគ្គលណា បានលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះមិនប្រកប មិនឈម មិនជ្ជាក់ មិនស្របចុះ ក្នុងសេចក្តីមើលងាយ ។ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមិនប្រកបក្នុងការមើលងាយ ។

(៨៥) ពាក្យថា អ្នកទន់ភ្លន់ផង អ្នកមានប្រាជ្ញាវាងវៃផង អធិប្បាយថា ដែលឈ្មោះថា អ្នកទន់ភ្លន់ ព្រោះជាអ្នកប្រកបដោយកាយកម្មដ៏ទន់ភ្លន់ ដោយវចីកម្មដ៏ទនភ្លន់ ។ ឈ្មោះថា អ្នកទន់ភ្លន់ ព្រោះជាអ្នកប្រកបដោយមនោកម្មដ៏ទន់ភ្លន់ ។ ឈ្មោះថា អ្នកទន់ភ្លន់ ព្រោះជាអ្នកប្រកបដោយសតិប្បដ្ឋានដ៏ល្អិត ។ ដោយសម្មប្បធានដ៏ល្អិត ។ ដោយឥទ្ធិ-បាទដ៏ល្អិត ។ ដោយឥន្ទ្រិយដ៏ល្អិត ។ ដោយពលៈដ៏ល្អិត ។

សណ្ហេហិ ពោជ្ឈង្គេហិ សមន្នាគតោតិ សណ្ហោ ។ សណ្ហេន អរិយេន អដ្ឋង្គិកេន មគ្គេន សមន្នាគតោតិ សណ្ហោ ។

(៨៦) បដិភាណវាតិ តយោ បដិភាណវន្តោ ។ បរិយត្តិប្បដិភាណវា បរិបុច្ឆាបដិភាណវា អធិគមប្បដិភាណវា ។

កតមោ បរិយត្តិប្បដិភាណវា ។ ឥធេកច្ចស្ស បរិយាបុដំ ហោតិ សុត្តំ គេយ្យំ វេយ្យាករណំ គាថា ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ ។ តស្ស បរិយត្តឹ និស្សាយ បដិភាយតិ ។ អយំ បរិយត្តិប្បដិភាណវា ។

កតមោ បរិបុច្ឆាបដិភាណវា ។ ឥធេកច្ចោ បរិបុច្ឆកោ(១) ហោតិ អត្ថេ ច ញាយេ ច លក្ខណេ ច ការណេ ច ឋានាឋានេ ច ។ តស្ស តំ បរិបុច្ឆំ និស្សាយ បដិភាយតិ ។ អយំ បរិបុច្ឆាបដិភាណវា ។

---

១ ម. បរិបុច្ឆិតា ។

ឈ្មោះថា អ្នកទន់ភ្លន់ ព្រោះជាអ្នកប្រកបដោយពោជ្ឈង្គដ៏ល្អិត ។ ឈ្មោះថា អ្នកទន់ភ្លន់ ព្រោះជាអ្នកប្រកបដោយអរិយមគ្គ មានអង្គ ៨ ដ៏ល្អិត ។

(៨៦) ពាក្យថា អ្នកមានប្រាជ្ញាវាងវៃ បានដល់ បុគ្គលអ្នកមានប្រាជ្ញាវាងវៃ ៣ ពួក គឺ បុគ្គលមានបរិយត្តិប្បដិភាណ (មានប្រាជ្ញាវាងវៃ ព្រោះអាស្រ័យការរៀនសូត្រ) ១ មានបរិបុច្ឆាបដិភាណ (មានប្រាជ្ញាវាងវៃ ព្រោះអាស្រ័យការសាកសួរ) ១ មានអធិគមប្បដិភាណ (មានប្រាជ្ញាវាងវៃ ព្រោះអាស្រ័យការត្រាស់ដឹង) ១ ។

បុគ្គលអ្នកមានបរិយត្តិប្បដិភាណ តើដូចម្តេច ។ បុគ្គលពួកខ្លះក្នុងលោកនេះ បានរៀនពុទ្ធវចនៈ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភុតធម្មៈ វេទល្លៈ ។ ការបេះដឹងរមែងភ្លឺច្បាស់ដល់បុគ្គលនោះ ព្រោះអាស្រ័យការរៀនសូត្រ ។ នេះ បុគ្គលមានបរិយត្តិប្បដិភាណ ។

បុគ្គលអ្នកមានបរិបុច្ឆាបដិភាណ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសាកសួរក្នុងប្រយោជន៍របស់ខ្លួនផង ក្នុងប្រយោជន៍នៃការបេះដឹងផង ក្នុងលក្ខណៈផង ក្នុងហេតុផង ក្នុងការណ៍គួរនិងការណ៍មិនគួរផង ។ ការបេះដឹងរមែងភ្លឺច្បាស់ ដល់បុគ្គលនោះ ព្រោះអាស្រ័យការសាកសួរនោះ ។ នេះ បុគ្គលមានបរិបុច្ឆាបដិភាណ ។

កតមោ អធិគមប្បដិភាណវា ។ ឥធេកច្ចស្ស អធិគតា ហោន្តិ ចត្តារោ សតិប្បដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ ចត្តារិ សាមញ្ញផលានិ ចតស្សោ បដិសម្ភិទា ឆ អភិញ្ញា ។ តស្ស អត្ថោ ញាតោ ធម្មោ ញាតោ និរុត្តិ ញាតា ។ អត្ថេ ញាតេ អត្ថោ បដិភាយតិ ។ ធម្មេ ញាតេ ធម្មោ បដិភាយតិ ។ និរុត្តិយា ញាតាយ និរុត្តិ បដិភាយតិ ។ ឥមេសុ តីសុ ញាណំ បដិភាណប្បដិសម្ភិទា ។ ឥមាយ បដិភាណប្បដិសម្ភិទាយ ឧបេតោ សមុបេតោ ឧបគតោ សមុបគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ ហោតិ សោ វុច្ចតិ បដិភាណវា ។ យស្ស បរិយត្តិ នត្ថិ បរិបុច្ឆា នត្ថិ អធិគមោ នត្ថិ កឹ តស្ស បដិភាយិស្សតីតិ សង្ខា ច បដិភាណវា ។

(៨៧) ន សទ្ធោ ន វិរជ្ជតីតិ ន សទ្ធោតិ សាមំ សយំ អភិញ្ញាតំ អត្តបច្ចក្ខំ ធម្មំ ន កស្សចិ សទ្ទហតិ អញ្ញស្ស សមណស្ស វា ព្រាហ្មណស្ស វា ទេវស្ស វា

បុគ្គលអ្នកមានអធិគមប្បដិភាណ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកត្រាស់ដឹងសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គមានអង្គ ៨ សាមញ្ញផល ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ ។ បុគ្គលនោះយល់អត្ថ យល់ធម៌ យល់និរុត្តិ ។ អត្ថរមែងភ្លឺច្បាស់ក្នុងសេចក្តីដែលខ្លួនដឹង ។ ធម៌រមែងភ្លឺច្បាស់ក្នុងធម៌ដែលខ្លួនដឹង ។ និរុត្តិរមែងភ្លឺច្បាស់ក្នុងនិរុត្តិដែលខ្លួនដឹង ។ ញាណក្នុងសភាវៈទាំងបីនេះ ឈ្មោះថា បដិភាណប្បដិសម្ភិទា ។ បុគ្គលណា ព្រមព្រៀង មូលមិត្ត ចូលទៅជិត អែបនែប កៀកកើយ ផ្តេកផ្តិត ប្រកប ដោយបដិភាណប្បដិសម្ភិទានេះ បុគ្គលនោះ លោកហៅថា អ្នកមានបដិភាណ ។ បរិយត្តិ មិនមានដល់បុគ្គលណា ការសាកសួរក៏មិនមាន ការត្រាស់ដឹងក៏មិនមាន ការបេះដឹងទឹងភ្លឺច្បាស់ដល់បុគ្គលនោះដូចម្តេចបាន ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកទន់ភ្លន់ផង អ្នកមានប្រាជ្ញាវាងវៃផង ។

(៨៧) អធិប្បាយពាក្យថា រមែងជាអ្នកមិនមានជំនឿ មិនប្រាសចាកតម្រេក ត្រង់ពាក្យថា មិនមានជំនឿ សេចក្តីថា បុគ្គលរមែងមិនជឿធម៌ដែលខ្លួនដឹងដោយខ្លួនឯង ដែលជាធម៌ជាក់ច្បាស់ ក្នុងខ្លួនហើយ (អំពីសំណាក់)របស់បុគ្គលណាមួយ ទោះជាសមណៈដទៃក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី

មារស្ស វា(1) ព្រហ្មុនោ វា ។ សព្វេ សង្ខារា អនិច្ចាតិ សាមំ សយមភិញ្ញាតំ អត្តបច្ចក្ខំ ធម្មំ ន កស្សចិ សទ្ទហតិ អញ្ញស្ស សមណស្ស វា ព្រាហ្មណស្ស វា ទេវស្ស វា មារស្ស វា ព្រហ្មុនោ វា ។ សព្វេ សង្ខារា ទុក្ខាតិ ។ សព្វេ ធម្មា អនត្តាតិ ។ អវិជ្ជាបច្ចយា សង្ខារាតិ ។ បេ ។ ជាតិបច្ចយា ជរាមរណន្តិ ។ អវិជ្ជានិរោធា សង្ខារនិរោធោតិ ។ បេ ។ ជាតិនិរោធា ជរាមរណនិរោធោតិ ។ ឥទំ ទុក្ខន្តិ ។ បេ ។ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ ។ ឥមេ អាសវាតិ ។ បេ ។ អយំ អាសវនិរោធគាមិនី បដិបទាតិ ។ ឥមេ ធម្មា អភិញ្ញេយ្យាតិ ។ បេ ។ ឥមេ ធម្មា សច្ឆិកាតព្វាតិ ។ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច បញ្ចន្នំ ឧបាទានក្ខន្ធានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច ចតុន្នំ មហាភូតានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច ។

---

១ ឱ. ឯត្ថន្តរេ នរស្ស វាតិ ទិស្សតិ ។

## បុកភេទសុត្តនិទ្ទេស ទី ១០

មារក្តី ព្រហ្មក្តី ។ រមែងមិនជឿធម៌ដែលខ្លួនដឹងដោយខ្លួនឯងហើយ ដែលជាធម៌ជាក់ច្បាស់ក្នុងខ្លួនហើយ (អំពីសំណាក់) របស់បុគ្គលណាមួយ ទោះជាសមណៈជនក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ថា សង្ខារទាំងឡាយទាំងពួង មិនទៀង ។ ថា សង្ខារទាំងឡាយទាំងពួង ជាទុក្ខ ។ ថា ធម៌ទាំងឡាយទាំងពួងជាអនត្តា ។ ថា សង្ខារទាំងឡាយ (កើតមាន) ព្រោះអវិជ្ជាជាបច្ច័យ ។បេ។ ថា ជរា មរណៈ (កើតមាន) ព្រោះជាតិជាបច្ច័យ ។ ថា ការរលត់នៃសង្ខារព្រោះការរលត់អវិជ្ជា ។បេ។ ការរលត់ជរាមរណៈ ព្រោះការរលត់ជាតិ ។ ថា នេះទុក្ខ ។បេ។ ថា នេះទុក្ខនិរោធគាមិនីបដិបទា ។ ថា នេះអាសវៈទាំងឡាយ ។បេ។ ថា នេះអាសវនិរោធគាមិនីបដិបទា ។ ថា នេះធម៌ដែលត្រូវដឹង ។បេ។ ថា នេះធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ។ (បុគ្គលរមែងមិនជឿ) នូវការកើតឡើងផង នូវសេចក្តីវិនាសផង នូវអានិសង្សផង នូវទោសផង នូវការរលាស់ចេញផង នៃផស្សាយតនៈទាំង ៦ នូវការកើតឡើងផង នូវសេចក្តីវិនាសផង នូវអានិសង្សផង នូវទោសផង នូវការរលាស់ចេញផង នៃឧបាទានក្ខន្ធ ៥ នូវការកើតឡើងផង នូវសេចក្តីវិនាសផង នូវអានិសង្សផង នូវទោសផង នូវការរលាស់ចេញផង នៃមហាភូតរូប ៤ ។

យំ កិញ្ចិ សមុទយធម្មំ សព្វំ តំ និរោធធម្មន្តិ សាមំ សយមភិញ្ញាតំ អត្តបច្ចក្ខំ ធម្មំ ន កស្សចិ សទ្ទហតិ អញ្ញស្ស សមណស្ស វា ព្រាហ្មណស្ស វា ទេវស្ស វា មារស្ស វា ព្រហ្មុនោ វា ។ វុត្តំ ហេតំ ភគវតា សទ្ទហសិ ត្វំ សារីបុត្ត សទ្ធិន្ទ្រិយំ ភាវិតំ ពហុលីកតំ អមតោគធំ ហោតិ អមតបរាយនំ អមតបរិយោសានំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ភាវិតំ ពហុលីកតំ អមតោគធំ ហោតិ អមតបរាយនំ អមតបរិយោសានន្តិ ។ ន ខ្វាហំ ឯត្ថ ភន្តេ ភគវតោ សទ្ធាយ គច្ឆាមិ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ភាវិតំ ពហុលីកតំ អមតោគធំ ហោតិ អមតបរាយនំ អមតបរិយោសានំ យេសំ ន្ហេតំ ភន្តេ អញ្ញាតំ អស្ស អទិដ្ឋំ អវិទិតំ អសច្ឆិកតំ អផុសិតំ បញ្ញាយ តេ តត្ថ បរេសំ សទ្ធាយ គច្ឆេយ្យុំ

បុគ្គលរមែងមិនជឿធម៌ដែលខ្លួនដឹងដោយខ្លួនឯងហើយ ដែលជាធម៌ជាក់ច្បាស់ក្នុងខ្លួនហើយ (អំពីសំណាក់) របស់បុគ្គលណាមួយ ទោះជាសមណៈដទៃក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ថា ធម្មជាតណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅជាធម្មតា ។ ពិតណាស់ ពាក្យនុ៎ះ ព្រះមានព្រះភាគត្រាស់ថា ម្នាលសារីបុត្រ អ្នកជឿដែរឬ ថា សទ្ធិន្ទ្រិយ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ជាធម្មជាតចូលទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ជាធម្មជាតចូលទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត ។ (ព្រះសារីបុត្រក្រាបទូលថា) បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនលុះក្នុងការជឿ តាមព្រះមានព្រះភាគ ក្នុងហេតុនុ៎ះថា សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ជាធម្មជាតចូលទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុតដូច្នេះទេ បពិត្រព្រះអង្គដ៏ចំរើនគុណជាតមានសទ្ធិន្ទ្រិយជាដើមនុ៎ះ ដែលពួកជនណា មិនដឹង មិនឃើញមិនយល់មិនបានធ្វើឲ្យជាក់ច្បាស់មិនប៉ះពាល់ដោយប្រាជ្ញា តាមពិតទេ ពួកជនទាំងនោះ គប្បីលុះក្នុងការជឿតាមពួកជនដទៃ ក្នុងហេតុនោះថា

## ទសមោ បុរាភេទសុត្តនិទ្ទេសោ

សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ភាវិតំ ពហុលីកតំ អមតោគធំ ហោតិ អមតបរាយនំ អមតបរិយោសានន្តិ យេសញ្ហុ ខោ ឯតំ ភន្តេ ញាតំ ទិដ្ឋំ វិទិតំ សច្ឆិកតំ ផុសិតំ បញ្ញាយ និក្កង្ខា តេ តត្ថ និព្វិចិកិច្ឆា សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ភាវិតំ ពហុលីកតំ អមតោគធំ ហោតិ អមតបរាយនំ អមតបរិយោសានន្តិ មយ្ហញ្ហុ ខោ ឯតំ ភន្តេ ញាតំ ទិដ្ឋំ វិទិតំ សច្ឆិកតំ ផុសិតំ បញ្ញាយ និក្កង្ខោហំ តត្ថ និព្វិចិកិច្ឆោ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ ភាវិតំ ពហុលីកតំ អមតោគធំ ហោតិ អមតបរាយនំ អមតបរិយោសានន្តិ ។

## បុភកេទសុត្តនិទ្ទេស ទី ១០

សទ្ធិន្ទ្រិយ ។ បេ ។ បញ្ញិន្ទ្រិយ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ជាធម្មជាតចូលទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត បពិត្រព្រះអង្គដ៏ចំរើន ចំណែកខាងគុណជាតមានសទ្ធិន្ទ្រិយជាដើមនុ៎ះ ដែលពួកជនណា បានដឹង ឃើញ យល់ ធ្វើឲ្យជាក់ច្បាស់ ប៉ះពាល់ ដោយប្រាជ្ញាហើយ ពួកជននោះ ជាអ្នកមិនមានសេចក្តីសង្ស័យ មិនមានសេចក្តីងឿងឆ្ងល់ ក្នុងហេតុនោះថា សទ្ធិន្ទ្រិយ វិរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ជាធម្មជាតចូលទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត បពិត្រព្រះអង្គដ៏ចំរើន ចំណែកខាងគុណជាតមានសទ្ធិន្ទ្រិយជាដើមនុ៎ះ ដែលខ្ញុំព្រះអង្គ បានដឹង ឃើញ យល់ ធ្វើឲ្យជាក់ច្បាស់ ប៉ះពាល់ ដោយប្រាជ្ញាហើយ ខ្ញុំព្រះអង្គមិនមានសេចក្តីសង្ស័យ មិនមានសេចក្តីងឿងឆ្ងល់ ក្នុងហេតុនោះថា សទ្ធិន្ទ្រិយ វិរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ជាធម្មជាតចូលទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត ។

សាធុ សាធុ សារីបុត្ត យេសញ្ហេតំ សារីបុត្ត អញ្ញាតំ អស្ស អទិដ្ឋំ អវិទិតំ អសច្ឆិកតំ អផុសិតំ បញ្ញាយ តេ តត្ថ បរេសំ សទ្ធាយ គច្ឆេយ្យុំ សទ្ធិន្ទ្រិយំ ។ បេ ។ បញ្ញិន្ទ្រិយំ ភាវិតំ ពហុលីកតំ អមតោគធំ ហោតិ បមតបរាយនំ អមតបរិយោសានន្តិ ។

អស្សទ្ធោ អកតញ្ញូ ច សន្ធិច្ឆេទោ ច យោ នរោ
ហតាវកាសោ វន្តាសោ ស វេ ឧត្តមបោរិសោតិ ។

ន វិរជ្ជតីតិ(១) សព្វេ ពាលបុថុជ្ជនា រជ្ជន្តិ កល្យាណ-បុថុជ្ជនំ ឧបាទាយ សត្ត សេខា វិរជ្ជន្តិ អរហា នេវ រជ្ជតិ នោ វិរជ្ជតិ ។ វិរតោ សោ ខយា រាគស្ស វីតរាគត្តា ខយា ទោសស្ស វីតទោសត្តា ខយា មោហស្ស វីតមោហត្តា ។ សោ វុដ្ឋវាសោ

---

១ ម. ន សព្វេន វិរជ្ជតីតិ ។

(ព្រះមានព្រះភាគ ទ្រង់សរសើរថា) ម្នាលសារីបុត្រ ប្រពៃហើយ ប្រពៃហើយ ម្នាលសារីបុត្រ ពិតណាស់ គុណជាតមានសទ្ធិន្ទ្រិយជាដើមនុ៎ះ ដែលពួកជនណា មិនទាន់ដឹង មិនទាន់ឃើញ មិនទាន់យល់ មិនទាន់ធ្វើឲ្យជាក់ច្បាស់ មិនទាន់ប៉ះពាល់ ដោយប្រាជ្ញាទេ ពួកជននោះ គប្បីលុះក្នុងការជឿតាមជនដទៃ ក្នុងហេតុនោះថា សទ្ធិន្ទ្រិយ ។បេ។ បញ្ញិន្ទ្រិយ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ជាធម្មជាតចូលទៅកាន់អមតៈ មានអមតៈប្រព្រឹត្តទៅខាងមុខ មានអមតៈជាទីបំផុត ។

ជនណា ជាអ្នកមិនជឿផង ជាអ្នកដឹងនូវព្រះនិព្វានដែល
បុគ្គលមិនធ្វើផង ជាអ្នកកាត់តំណផង ជាអ្នកមានឱកាសកំចាត់
បង់ហើយផង ជាអ្នកខ្ជាក់ចោលនូវសេចក្តីប៉ុនប៉ងផង ជន
នោះឯង ឈ្មោះថា ឧត្តមបុរស ។

ពាក្យថា មិនប្រាសចាកតម្រេក អធិប្បាយថា ពួកពាលបុថុជ្ជនទាំងអស់ រមែងត្រេកអរ សេខបុគ្គល ៧ ពួក រាប់ទាំងកល្យាណបុថុជ្ជនរមែងទ្រាន់ ព្រះអរហន្តមិនត្រេក មិនទ្រាន់ ។ ព្រះអរហន្តនោះ ជាអ្នកប្រាសចាកតម្រេក ព្រោះការអស់រាគៈ ហេតុតែលោកប្រាសចាករាគៈ ព្រោះការអស់ទោសៈ ហេតុតែលោកប្រាសចាកទោសៈ ព្រោះការអស់មោហៈ ហេតុតែលោកប្រាសចាកមោហៈ ។ ព្រះអរហន្តនោះ មានការអប់រំនៅស្រេចហើយ

ចិណ្ណាចរណោ ។ បេ ។ នត្ថិ តស្ស បុរេក្ខតាតិ ន សទ្ធោ ន វិរជ្ជតិ ។ តេនាហ ភគវា

សាតិយេសុ អនស្សាវី អតិមានេ ច នោ យុតោ
សណ្ហោ ច បដិភាណវា ន សទ្ធោ ន វិរជ្ជតីតិ ។
(៨៨) លាភកម្យា ន សិក្ខតិ អលាភេ ច ន កុប្បតិ
អវិរុទ្ធោ ច តណ្ហាយ រសេ ច នានុគិជ្ឈតិ ។

(៨៩) លាភកម្យា ន សិក្ខតិ អលាភេ ច ន កុប្បតីតិ កថំ លាភកម្យា សិក្ខតិ ។ ឥធ ភិក្ខវេ ភិក្ខុ ភិក្ខុំ បស្សតិ លាភឹ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ តស្ស ឯវំ ហោតិ កេន នុ ខោ អយមាយស្មា លាភី ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ។

## បុរាភេទសុត្តនិទ្ទេស ទី ១០

មានការប្រព្រឹត្តិសន្សំហើយ ។បេ។ ការកើតទៀតរបស់ព្រះអរហន្តនោះ មិនមាន ហេតុនោះ (ទ្រង់ត្រាស់ថា) មិនមានជំនឿ មិនប្រាសចាកតម្រេក ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

បុគ្គលអ្នកមិនស្រស់ស្រាយ ក្នុងវត្ថុជាទីត្រេកអរផង អ្នកមិន
ប្រកបក្នុងការមើលងាយផង អ្នកទន់ភ្លន់ផង អ្នកមានប្រាជ្ញា
វាងវៃផង រមែងជាអ្នកមិនមានជំនឿ មិនប្រាសចាកតម្រេក ។

(៨៨) បុគ្គលមិនសិក្សា ព្រោះប្រាថ្នាលាភផង មិនក្រោធ
ព្រោះមិនមានលាភផង មិនអាក់អន់ ព្រោះតណ្ហាផង មិន
ជាប់ ព្រោះរសផង ។

(៨៩) ពាក្យថា បុគ្គលមិនសិក្សា ព្រោះប្រាថ្នាលាភផង មិនក្រោធ ព្រោះមិនមានលាភផង អធិប្បាយថា បុគ្គលសិក្សា ព្រោះលាភ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញភិក្ខុជាអ្នកមានលាភខាងចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារទាំងឡាយ ។ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា លោកមានអាយុនេះ ជាអ្នកមានលាភខាងចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារទាំងឡាយ ដោយហេតុ ដូចម្តេចហ្ន៎ ។

តស្ស ឯវំ ហោតិ អយំ ខោ អាយស្មា សុត្តន្តិកោ តេន អយមាយស្មា លាភី ចីវរបិណ្ឌបាតសេនាសនគិលាន-បច្ចយភេសជ្ជបរិក្ខារានន្តិ ។ សោ លាភហេតុ លាភ-បច្ចយា លាភការណា លាភាភិនិព្វត្តិយា លាភំ បរិបា-ចេន្តោ សុត្តន្តំ បរិយាបុណាតិ ។ ឯវម្បិ លាភកាម្យា សិក្ខតិ ។ អថវា ភិក្ខុ ភិក្ខុំ បស្សតិ លាភឹ ចីវរបិ-ណ្ឌបាតសេនាសនគិលានបច្ចយភេសជ្ជបរិក្ខារានំ ។ តស្ស ឯវំ ហោតិ កេន នុ ខោ អយមាយស្មា លាភី ចីវរបិណ្ឌបាតសេនាសនគិលានបច្ចយភេសជ្ជ-បរិក្ខារានន្តិ ។ តស្ស ឯវំ ហោតិ អយំ ខោ អាយស្មា វិនយធរោ ។ បេ ។ អភិធម្មិកោ តេន អយមាយស្មា លាភី ចីវរបិណ្ឌបាតសេនាសនគិលានបច្ចយភេសជ្ជ-បរិក្ខារានន្តិ ។ សោ លាភហេតុ លាភបច្ចយា លាភ-ការណា លាភាភិនិព្វត្តិយា លាភំ បរិបាចេន្តោ អភិធម្មំ បរិយាបុណាតិ ។ ឯវម្បិ លាភកាម្យា សិក្ខតិ ។

ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា លោកមានអាយុនេះ ជាអ្នកចេះព្រះសូត្រ លោកមានអាយុនេះ ទើបជាអ្នកមានលាភ ខាងចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយ ដោយហេតុនោះ ។ ភិក្ខុនោះ កាលខ្នះខ្នែងលាភ ក៏រៀនយកព្រះសូត្រ ព្រោះហេតុនៃលាភ ព្រោះបច្ច័យនៃលាភ ព្រោះលាភជាហេតុ ព្រោះការកើតឡើងនៃលាភ បុគ្គលសិក្សា ព្រោះប្រាថ្នាលាភ យ៉ាងនេះឯង ។ មួយទៀត ភិក្ខុឃើញភិក្ខុជាអ្នកមានលាភ ខាងចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយ ។ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា លោកមានអាយុនេះ ជាអ្នកមានលាភខាងចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយ ដោយហេតុដូចម្តេចហ្ន៎ ។ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា លោកមានអាយុនេះ ជាអ្នកទ្រទ្រង់វិន័យ ។បេ។ ជាអ្នកចេះអភិធម្ម ទើបលោកមានអាយុនេះ ជាអ្នកមានលាភ ខាងចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយ ដោយហេតុនោះ ។ ភិក្ខុនោះ កាលខ្នះខ្នែងលាភ ក៏រៀនអភិធម្ម ព្រោះហេតុនៃលាភ ព្រោះបច្ច័យនៃលាភ ព្រោះលាភជាហេតុ ព្រោះការកើតឡើងនៃលាភ ។ បុគ្គលសិក្សា ព្រោះប្រាថ្នាលាភ យ៉ាងនេះឯង ។

## ទសមោ បុគ្គលភេទសុត្តនិទ្ទេសោ

ឥធ ភិក្ខុ ភិក្ខុំ បស្សតិ លាភឹ ចីវរបិណ្ឌបាតសេនា-
សនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ តស្ស ឯវំ
ហោតិ កេន នុ ខោ អយមាយស្មា លាភី ចីវរបិណ្ឌ-
បាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ។
តស្ស ឯវំ ហោតិ អយំ ខោ អាយស្មា អារញ្ញិកោ
បិណ្ឌបាតិកោ បំសុកូលិកោ តេចីវរិកោ សបទាន-
ចារិកោ ខលុបច្ឆាភត្តិកោ នេសជ្ជិកោ យថាសន្ថតិ-
កោ តេន អយមាយស្មា លាភី ចីវរបិណ្ឌបាតសេនា-
សនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ។ សោ លាភ-
ហេតុ លាភប្បច្ចយា លាភការណា លាភាភិនិព្វត្តិយា
លាភំ បរិបាបេន្តោ អារញ្ញិកោ ហោតិ ។បេ។ យថា-
សន្ថតិកោ ហោតិ ។ ឯវម្បិ លាភកម្យា សិក្ខតិ ។

បុរាភេទសុត្តនិទ្ទេស ទី ១០

មួយទៀត ភិក្ខុឃើញភិក្ខុជាអ្នកមានលាភខាងចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា លោកមានអាយុនេះ ជាអ្នកមានលាភ ខាងចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយ ដោយហេតុដូចម្តេចហ្ន៎ ៗ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា លោកមានអាយុនេះ ជាអ្នកប្រព្រឹត្តអារញ្ញិកធុតង្គ បិណ្ឌបាតិកធុតង្គ បង្សុកូលិកធុតង្គ តេចីវរិកធុតង្គ សបទានចារិកធុតង្គ ខលុបច្ឆាភត្តិកធុតង្គ នេសជ្ជិកធុតង្គ យថាសន្ថតិកធុតង្គ ទើបលោកមានអាយុនេះ ជាអ្នកមានលាភខាងចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយ ដោយហេតុនោះ ៗ ភិក្ខុនោះ កាលខ្វះខ្វងលាភ ទើបជាអ្នកប្រព្រឹត្តអារញ្ញិកធុតង្គ ។ បេ ។ យថាសន្ថតិកធុតង្គ ព្រោះហេតុនៃលាភ ព្រោះបច្ច័យនៃលាភ ព្រោះលាភជាហេតុ ព្រោះការកើតឡើងនៃលាភ ៗ បុគ្គលសិក្សា ព្រោះប្រាថ្នាលាភ យ៉ាងនេះឯង ៗ

កថំ ន លោកកម្យា សិក្ខតិ ។ ឥធ ភិក្ខុ ន លោកហេតុ ន លោកបច្ចយា ន លោកការណា ន លោកាភិនិព្វត្តិយា ន លោកំ បរិបាចេន្តោ យាវទេវ អត្តទមថាយ អត្តសមថាយ អត្តបរិនិព្វាបនត្ថាយ សុត្តន្តំ បរិយាបុណាតិ វិនយំ បរិយាបុណាតិ អភិធម្មំ បរិយាបុណាតិ ។ ឯវម្បិ ន លោកកម្យា សិក្ខតិ ។ អថវា ភិក្ខុ ន លោកហេតុ ន លោកបច្ចយា ន លោកការណា ន លោកាភិនិព្វត្តិយា ន លោកំ បរិបាចេន្តោ យាវទេវ អប្បិច្ឆញ្ញេវ និស្សាយ សន្តុដ្ឋិញ្ញេវ និស្សាយ សល្លេខញ្ញេវ និស្សាយ បវិវេកញ្ញេវ និស្សាយ ឥទមត្ថិតញ្ញេវ(១) និស្សាយ អារញ្ញិកោ ហោតិ បិណ្ឌបាតិកោ ហោតិ បំសុកូលិកោ ហោតិ តេចីវរិកោ ហោតិ សបទានចារិកោ ហោតិ ខលុបច្ឆាភត្តិកោ ហោតិ នេសជ្ជិកោ ហោតិ យថាសន្ថតិកោ ហោតិ ។ ឯវម្បិ ន លោកកម្យា សិក្ខតីតិ លោកកម្យា ន សិក្ខតិ ។

១ ម. ឥទមត្ថិកញ្ញេវ ។

បុគ្គលមិនសិក្សាព្រោះប្រាថ្នាលាភ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ មិនមែនព្រោះហេតុនៃលាភ មិនមែនព្រោះបច្ច័យនៃលាភ មិនមែនព្រោះលាភជាហេតុ មិនមែនព្រោះការកើតឡើងនៃលាភទេ កាលមិនខ្វះខ្វែងរកលាភ ក៏រៀនព្រះសូត្រ រៀនព្រះវិន័យ រៀនព្រះអភិធម្ម ដើម្បីទូន្មានខ្លួន ដើម្បីរម្ងាប់ចិត្ត ដើម្បីរំលត់ចិត្ត តែប៉ុណ្ណោះ បុគ្គលមិនសិក្សាព្រោះប្រាថ្នាលាភ យ៉ាងនេះឯង ។ មួយទៀត ភិក្ខុមិនមែនព្រោះហេតុនៃលាភ មិនមែនព្រោះបច្ច័យនៃលាភ មិនមែនព្រោះលាភជាហេតុ មិនមែនព្រោះការកើតឡើងនៃលាភទេ កាលមិនខ្វះខ្វែងរកលាភ អាស្រ័យសេចក្តីមិនប្រាថ្នា អាស្រ័យសេចក្តីសន្តោស អាស្រ័យសេចក្តីផូរផង់ អាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យតែ្តដែលមានតែម្យ៉ាងប៉ុណ្ណោះ ហើយជាអ្នកប្រព្រឹត្តអារញ្ញិកធុតង្គ បិណ្ឌបាតិកធុតង្គ បង្សុកូលិកធុតង្គ តេចីវរិកធុតង្គ សបទានចារិកធុតង្គ ខលុបច្ឆាភត្តិកធុតង្គ នេសជ្ជិកធុតង្គ យថាសន្ថតិកធុតង្គ បុគ្គលមិនសិក្សា ព្រោះប្រាថ្នាលាភ យ៉ាងនេះឯង ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលមិនសិក្សា ព្រោះប្រាថ្នាលាភ ។

## ទសមោ បុរាភេទសុត្តនិទ្ទេសោ

(៩០) អលាភេ ច ន កុប្បតីតិ កថំ អលាភេ កុប្បតិ ។ ឥធេកច្ចោ កុលំ វា ន លភាមិ គណំ វា ន លភាមិ អាវាសំ វា ន លភាមិ លាភំ វា ន លភាមិ យសំ វា ន លភាមិ បសំសំ វា ន លភាមិ សុខំ វា ន លភាមិ ចីវរំ វា ន លភាមិ បិណ្ឌបាតំ វា ន លភាមិ សេនាសនំ វា ន លភាមិ គិលានប្បច្ចយភេសជ្ជបរិក្ខារំ វា ន លភាមិ គិលានុបដ្ឋាកំ វា ន លភាមិ អប្បញ្ញាតោម្ហីតិ កុប្បតិ ព្យាបជ្ជតិ បតិដ្ឋិយតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។ ឯវំ អលាភេ កុប្បតិ ។

កថំ អលាភេ ន កុប្បតិ ។ ឥធ ភិក្ខុ កុលំ វា ន លភាមិ គណំ វា ន លភាមិ អាវាសំ វា ន លភាមិ លាភំ វា ន លភាមិ យសំ វា ន លភាមិ បសំសំ វា ន លភាមិ សុខំ វា ន លភាមិ ចីវរំ វា ន លភាមិ បិណ្ឌបាតំ វា ន លភាមិ សេនាសនំ វា ន លភាមិ គិលានប្បច្ចយភេសជ្ជបរិក្ខារំ វា ន លភាមិ គិលានុបដ្ឋាកំ វា ន លភាមិ អប្បញ្ញាតោម្ហីតិ ន កុប្បតិ ន ព្យាបជ្ជតិ ន បតិដ្ឋិយតិ ន កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។

## បុរាភេទសុត្តនិទ្ទេស ទី ១០

(៩០) ពាក្យថា បុគ្គលមិនក្រោធ ព្រោះមិនមានលាភផង អធិប្បាយថា បុគ្គលមិនក្រោធ ព្រោះមិនមានលាភ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ក្រោធ គុំគួន បៀតបៀន ធ្វើនូវសេចក្តីក្រោធ ការប្រទូស្ត ការអាក់អន់ ឲ្យប្រាកដ ដោយគិតថា អាត្មាអញមិនបានត្រកូល (ឧបដ្ឋាក)ក្តី មិនបានពួកក្តី មិនបានអាវាសក្តី មិនបានលាភក្តី មិនបានយសក្តី មិនបានសេចក្តីសរសើរក្តី មិនបានសុខក្តី មិនបានចីវរក្តី មិនបានបិណ្ឌបាតក្តី មិនបានសេនាសនៈក្តី មិនបានគិលានប្បច្ច័យភេសជ្ជបរិក្ខារក្តី មិនបានអ្នកបំរើជម្ងឺក្តី អាត្មាអញមិនមែនជាអ្នកល្បីឈ្មោះ ។ បុគ្គលក្រោធ ព្រោះមិនមានលាភ យ៉ាងនេះឯង ។

បុគ្គលមិនក្រោធ ព្រោះមិនមានលាភ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ មិនក្រោធ មិនគុំគួន មិនថ្នាំងថ្នាក់ មិនធ្វើនូវសេចក្តីក្រោធ ការប្រទូស្ត ការអាក់អន់ ឲ្យប្រាកដថា អាត្មាអញមិនបានត្រកូលក្តី មិនបានពួកក្តី មិនបានអាវាសក្តី មិនបានលាភក្តី មិនបានយសក្តី មិនបានសេចក្តីសរសើរក្តី មិនបានសុខក្តី មិនបានចីវរក្តី មិនបានបិណ្ឌបាតក្តី មិនបានសេនាសនៈក្តី មិនបានគិលានប្បច្ច័យភេសជ្ជបរិក្ខារក្តី មិនបានអ្នកបំរើជម្ងឺក្តី អាត្មាអញមិនមែនជាអ្នកល្បីឈ្មោះ ។

ឃរំ អលាភេ ន កុប្បតីតិ លាភកម្យា ន សិក្ខតិ អលាភេ ច ន កុប្បតិ ។

(៩១) អវិរុទ្ធោ ច តណ្ហាយ រសេ ច នានុគិជ្ឈតីតិ វិរុទ្ធោតិ យោ ចិត្តស្ស អាឃាតោ បដិឃាតោ អនុវិរោធោ(១) កោបោ បកោបោ សម្បកោបោ ទោសោ បទោសោ សម្បទោសោ ចិត្តស្ស ព្យាបត្តិ មនោបទោសោ(២) កោធោ កុជ្ឈនា កុជ្ឈិតត្តំ ទោសោ ទុស្សនា ទុស្សិតត្តំ ព្យាបត្តិ ព្យាបជ្ជនា ព្យាបជ្ជិតត្តំ វិរោធោ បដិវិរោធោ ចណ្ឌិក្កំ អស្សុរោបោ អនត្តមនតា ចិត្តស្ស អយំ វុច្ចតិ វិរោធោ ។ យស្សេសោ វិរោធោ បហីនោ សមុច្ឆិន្នោ វូបសន្តោ បដិប្បស្សទ្ធោ អភព្វុប្បត្តិកោ ញាណគ្គិនា ទឌ្ឍោ សោ វុច្ចតិ អវិរុទ្ធោ ។ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ រសោតិ មូលរសោ ខន្ធរសោ តចរសោ បត្តរសោ បុប្ផរសោ ផលរសោ អម្ពិលំ មធុរំ តិត្តកំ កដុកំ លោណិកំ ខារិកំ លម្ពិលំ កសាវោ សាទុ អសាទុ សីតំ ឧណ្ហំ ។

---

១ ម. បដិឃំ បដិវិរោធោ ។ ២ ឱ. ឯត្ថន្តរេ ចិត្តស្សាតិ ទិស្សតិ ។

បុគ្គលមិនក្រោធ ព្រោះមិនមានលាភ យ៉ាងនេះឯង ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលមិនសិក្សាដើម្បីលាភផង មិនក្រោធ ព្រោះមិនមានលាភផង ។

[៩១] អធិប្បាយពាក្យថា មិនអាក់អន់ព្រោះតណ្ហាផង មិនជាប់ព្រោះរសផង ត្រង់ពាក្យថា ការអាក់អន់ មានសេចក្តីថា ការបៀតបៀន ការផ្នាំងផ្នាក់ ការខឹង ការក្រោធ ការខឹងញ័រ ការក្រោធខ្លាំង ការអាក់អន់ ការប្រទូស្ត ការប្រទូស្តខ្លាំងនៃចិត្ត ការទុំទួននៃចិត្ត ការប្រទូស្តក្នុងចិត្ត ការក្រេវក្រោធ អាការក្រោធ ភាពនៃចិត្តក្រោធ ការអាក់អន់ អាការអាក់អន់ ភាពនៃចិត្តអាក់អន់ ការទុំទួន អាការទុំទួន ភាពនៃចិត្តទុំទួន កំហឹង កំហឹងតប ភាពនៃចិត្តកាច ការសម្រក់ទឹកភ្នែក ភាពនៃចិត្តមិនត្រេកអរ ឯណា នេះហៅថា ការអាក់អន់ ។ ការអាក់អន់ ភិក្ខុណា បានលះបង់ ផ្តាច់ផ្តិល ធ្វើឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ភិក្ខុនោះ លោកហៅថា អ្នកមិនអាក់អន់ ។ ពាក្យថា តណ្ហា គឺរូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា រស គឺរសនៃឫសគល់ ឬមើម រសដើម រសសម្បក រសស្លឹក រសផ្កា រសផ្លែ រសជូរ ផ្អែម ល្វីង ហឹរ ប្រៃ ខារ ជូរអែម ចត់ ឆ្ងាញ់ មិនឆ្ងាញ់ ត្រជាក់ ក្តៅ ។

## ទសមោ បុរាភេទសុត្តនិទ្ទេសោ

សន្តេកេ សមណព្រាហ្មណា រសគិទ្ធា តេ ជិវ្ហគ្គេន រសគ្គានិ បរិយេសន្តា អាហិណ្ឌន្តិ ។ តេ អម្ពិលំ លភិត្វា អនម្ពិលំ បរិយេសន្តិ អនម្ពិលំ លភិត្វា អម្ពិលំ បរិយេសន្តិ ។ មធុរំ លភិត្វា អមធុរំ បរិយេសន្តិ អមធុរំ លភិត្វា មធុរំ បរិយេសន្តិ ។ តិត្តកំ លភិត្វា អតិត្តកំ បរិយេសន្តិ អតិត្តកំ លភិត្វា តិត្តកំ បរិយេសន្តិ ។ កដុកំ លភិត្វា អកដុកំ បរិយេសន្តិ អកដុកំ លភិត្វា កដុកំ បរិយេសន្តិ ។ លោណិកំ លភិត្វា អលោណិកំ បរិយេសន្តិ អលោណិកំ លភិត្វា លោណិកំ បរិយេសន្តិ ។ ខារិកំ លភិត្វា អខារិកំ បរិយេសន្តិ អខារិកំ លភិត្វា ខារិកំ បរិយេសន្តិ ។ លម្ពិលំ លភិត្វា កសាវំ បរិយេសន្តិ កសាវំ លភិត្វា លម្ពិលំ បរិយេសន្តិ ។ សាទុំ លភិត្វា អសាទុំ បរិយេសន្តិ អសាទុំ លភិត្វា សាទុំ បរិយេសន្តិ ។ សីតំ លភិត្វា ឧណ្ហំ បរិយេសន្តិ ឧណ្ហំ លភិត្វា សីតំ បរិយេសន្តិ

## បុរាភេទសុត្តនិទ្ទេស ទី ១០

ពួកសមណព្រាហ្មណ៍ខ្លះ ជាអ្នកជាប់ក្នុងរស ពួកសមណព្រាហ្មណ៍ទាំងនោះ ដើរស្វែងរករសដ៏ប្រសើរ ព្រោះចុងអណ្តាត ។ ពួកសមណៈព្រាហ្មណ៍នោះ បានរសជូរ ស្វែងរករសមិនជូរ បានរសមិនជូរ ស្វែងរករសជូរ ។ បានរសផ្អែម ស្វែងរករសមិនផ្អែម បានរសមិនផ្អែម ស្វែងរករសផ្អែម ។ បានរសល្វីង ស្វែងរករសមិនល្វីង បានរសមិនល្វីង ស្វែងរករសល្វីង ។ បានរសហឹរ ស្វែងរករសមិនហឹរ បានរសមិនហឹរ ស្វែងរករសហឹរ ។ បានរសប្រៃ ស្វែងរករសមិនប្រៃ បានរសមិនប្រៃ ស្វែងរករសប្រៃ ។ បានរសខារ ស្វែងរករសមិនខារ បានរសមិនខារ ស្វែងរករសខារ ។ បានរសជូរអែម ស្វែងរករសចត់ បានរសចត់ ស្វែងរករសជូរអែម ។ បានរសឆ្ងាញ់ ស្វែងរករសមិនឆ្ងាញ់ បានរសមិនឆ្ងាញ់ ស្វែងរករសឆ្ងាញ់ ។ បានរសត្រជាក់ ស្វែងរករសក្តៅ បានរសក្តៅ ស្វែងរករសត្រជាក់ ។

តេ យំ យំ លភិត្វា តេន តេន ន សន្តុស្សន្តិ អបរាបរំ បរិយេសន្តិ មនាបិកេសុ រសេសុ រត្តា គិទ្ធា គធិតា មុច្ឆិតា អជ្ឈោបន្នា លគ្គា លគ្គិតា បលិពុទ្ធា ។ យស្ស(១) រសតណ្ហា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា សោ បដិសង្ខា យោនិសោ អាហារំ អាហារេតិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសូបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។ យថា វណំ អាលិម្បេយ្យ យាវទេវ រោបនត្ថាយ យថា វា បន អក្ខំ អព្ភញ្ជេយ្យ យាវទេវ ភារស្ស និត្ថរណត្ថាយ យថា វា បន បុត្តមំសអាហារំ អាហារេយ្យ យាវទេវ កន្តារស្ស និត្ថរណត្ថាយ

---

១ ម. យស្សេសា ។

ពួកសមណព្រាហ្មណ៍នោះ បានសេណា ៗ មិនសន្តោសនឹងសេនោះ ៗ រមែងស្វែងរកសេប្វែក ៗ ជាអ្នកត្រេកអរ ញៀន លោភ ឡិបឡប់ ជ្រុលជ្រប់ ជាប់ចិត្ត បំពាក់ លង់នៅ ក្នុងសេទាំងឡាយ ដែលជាទីពេញចិត្ត ។ តណ្ហាក្នុងសេ ភិក្ខុណាបានលះបង់ ផ្ដាច់ផ្ដិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ភិក្ខុនោះពិចារណាដោយឧបាយ រមែងបរិភោគអាហារដោយគិតថា អាត្មាអញបរិភោគ មិនមែនដើម្បីលេង មិនមែនដើម្បីស្រវឹង មិនមែនដើម្បីប្រដាប់ មិនមែនដើម្បីស្អិតស្អាង (បរិភោគ) ដើម្បីតាំងនៅនៃកាយនេះ ដើម្បីញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដើម្បីបំបាត់បង់សេចក្ដីលំបាក ដើម្បីអនុគ្រោះដល់ព្រហ្មចារ្យ តែប៉ុណ្ណោះ អាត្មាអញកំចាត់បង់វេទនាចាស់ (ឃ្លាន) ទាំងមិនឲ្យវេទនាថ្មី (ឆ្អែតហួស) កើតឡើង ការត្រាប់ទៅ (ដោយឥរិយាបថ) ផង ការមិនមានទោសផង ការនៅជាសុខសប្បាយផង នឹងមានដល់អាត្មាអញដោយឧបាយដូចនេះ ។ បុគ្គលលាបដំបៅ ដើម្បីប្រយោជន៍ឲ្យជុះ (សាច់) តែប៉ុណ្ណោះ យ៉ាងណាមិញ មួយទៀត បុគ្គលលាបភ្លៅរទេះ ដើម្បីប្រយោជន៍ដល់ការផ្ទុកភារៈ តែប៉ុណ្ណោះ យ៉ាងណាមិញ មួយវិញទៀត បុគ្គលបរិភោគអាហារគឺសាច់កូន ដើម្បីប្រយោជន៍ដល់ការឆ្លងទូរកន្ដារតែប៉ុណ្ណោះ យ៉ាងណាមិញ

## ទសមោ បុរាភេទសុត្តនិទ្ទេសោ

ឯវមេវ ភិក្ខុ បដិសង្ខា យោនិសោ អាហារំ អាហារេតិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ រសតណ្ហំ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតិ រសតណ្ហាយ អារតោ វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ អវិរុទ្ធោ ច តណ្ហាយ រសេ ច នានុគិជ្ឈតិ ។ តេនាហ ភគវា

លាភកម្យា ន សិក្ខតិ អលាភេ ច ន កុប្បតិ
អវិរុទ្ធោ ច តណ្ហាយ រសេ ច នានុគិជ្ឈតីតិ ។

(៩២) ឧបេក្ខកោ សទា សតោ ន លោកេ មញ្ញតី សមំ
ន វិសេសី ន នីចេយ្យោ តស្ស នោ សន្តិ ឧស្សទា ។

ភិក្ខុពិចារណាដោយឧបាយ បរិភោគអាហារដោយគិតថា អាត្មាអញបរិភោគ មិនមែនដើម្បីលេង មិនមែនដើម្បីស្រវឹង មិនមែនដើម្បីប្រដាប់ មិនមែនដើម្បីស្អិតស្អាង (បរិភោគ) ដើម្បីឲ្យតាំងនៅនៃកាយនេះ ដើម្បីញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដើម្បីបំបាត់បង់សេចក្តីលំបាក ដើម្បីអនុគ្រោះដល់ព្រហ្មចារ្យ តែប៉ុណ្ណោះ អាត្មាអញកំចាត់បង់វេទនាចាស់ ទាំងមិនឲ្យវេទនាថ្មីកើតឡើង ការត្រាច់ទៅ (ដោយឥរិយាបថ) ផង ការមិនមានទោសផង ការនៅជាសុខសប្បាយផង នឹងមានដល់អាត្មាអញដោយឧបាយដូចនេះ ភិក្ខុរមែងលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើតណ្ហាក្នុងរសមិនឲ្យកើតមាន ជាអ្នកចៀសវាង វៀរស្រឡះ ប្រាសចេញ ចាកតណ្ហាក្នុងរស មានចិត្តប្រាសចាកសេចក្តីសល់វល់ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនអាក់អន់ព្រោះតណ្ហាផង មិនជាប់ព្រោះរសផង ។ ហេតុនោះ ព្រះមានព្រះភាគត្រាសថា

បុគ្គលមិនសិក្សា ព្រោះប្រាថ្នាលាភផង មិនក្រោធព្រោះ
មិនមានលាភផង មិនអាក់អន់ព្រោះតណ្ហាផង មិនជាប
ព្រោះរសផង ។

(៩២) បុគ្គលណាជាអ្នកព្រងើយកន្តើយ មានស្មារតីគ្រប់កាល មិនប្រកាន់ថាស្មើ មិនប្រកាន់ថាវិសេស មិនប្រកាន់ថាថោកទាបក្នុងលោក ធម៌ជាគ្រឿងដុះដាលរបស់បុគ្គលនោះ មិនមានទេ ។

[៩៣] ឧបេក្ខកោ សទា សតោតិ ឧបេក្ខកោតិ ឆឡង្គុបេក្ខាយ សមន្នាគតោ ចក្ខុនា រូបំ ទិស្វា នេវ សុមនោ ហោតិ ន ទុម្មនោ ឧបេក្ខកោ វិហរតិ សតោ សម្បជានោ ។ សោតេន សទ្ទំ សុត្វា ។ ឃានេន គន្ធំ ឃាយិត្វា ។ ជិវ្ហាយ រសំ សាយិត្វា ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ មនសា ធម្មំ វិញ្ញាយ នេវ សុមនោ ហោតិ ន ទុម្មនោ ឧបេក្ខកោ វិហរតិ សតោ សម្បជានោ ។ ចក្ខុនា រូបំ ទិស្វា មនាបំ នាភិគិជ្ឈតិ នាភិហំសតិ ន រាគំ ជនេតិ ។ តស្ស ឋិតោវ កាយោ ហោតិ ឋិតំ ចិត្តំ អជ្ឈត្តំ សុសណ្ឋិតំ សុវិមុត្តំ ។ ចក្ខុនា ខោ បនេវ រូបំ ទិស្វា អមនាបំ ន មង្កុ ហោតិ អប្បតិដ្ឋិតចិត្តោ អទីនមនសោ អព្យាបន្នចេតសោ ។ តស្ស ឋិតោវ កាយោ ហោតិ ឋិតំ ចិត្តំ អជ្ឈត្តំ សុសណ្ឋិតំ សុវិមុត្តំ ។ សោតេន សទ្ទំ សុត្វា ។ ឃានេន គន្ធំ ឃាយិត្វា ។ ជិវ្ហាយ រសំ សាយិត្វា ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។

[៩៣] អធិប្បាយពាក្យថា ជាអ្នកព្រងើយកន្តើយ មានស្មារតីគ្រប់កាល ត្រង់ពាក្យថា ព្រងើយកន្តើយ សេចក្តីថា បុគ្គលប្រកបដោយឆឡង្គុបេក្ខា ឃើញរូបដោយភ្នែកហើយ ជាអ្នកមិនមានចិត្តត្រេកអរ មិនមានចិត្តអាក់អន់ ជាអ្នកព្រងើយកន្តើយ មានស្មារតី ដឹងខ្លួន ៗ ឮសំឡេងដោយត្រចៀក ៗ ធុំក្លិនដោយច្រមុះ ៗ លិទ្ធភ្លក្សរសដោយអណ្តាត ៗ ប៉ះពាល់ផ្សព្វដោយកាយ ៗ ដឹងធម្មារម្មណ៍ដោយចិត្តហើយ ជាអ្នកមិនមានចិត្តត្រេកអរ មិនមានចិត្តអាក់អន់ ជាអ្នកព្រងើយកន្តើយ មានស្មារតី ដឹងខ្លួន ៗ ឃើញរូបដោយភ្នែកហើយ មិនត្រូវការ មិនត្រេកអរ ចំពោះអារម្មណ៍ជាទីពេញចិត្ត មិនញុំាងរាគៈឲ្យកើតឡើង ៗ កាយរបស់បុគ្គលនោះ ក៏តាំងនៅខ្ជាប់ខ្ជួន ចិត្តក៏ឋិតនៅខាងក្នុងសន្តាន ឋិតនៅដោយល្អ រួបស្រួលដោយប្រពៃ (ចាកអាសវៈ) ៗ ឃើញរូបដោយភ្នែក ជាអ្នកមិនស្អប់ចំពោះអារម្មណ៍មិនជាទីពេញចិត្ត មានចិត្តមិនអាក់អន់ មានចិត្តមិនរួញរា មានចិត្តមិនគុំគួន ៗ កាយរបស់បុគ្គលនោះ ក៏តាំងនៅខ្ជាប់ខ្ជួន ចិត្តក៏ឋិតនៅខាងក្នុងសន្តាន ឋិតនៅដោយល្អ រួបស្រួលដោយប្រពៃ ៗ ឮសំឡេងដោយត្រចៀក ៗ ធុំក្លិនដោយច្រមុះ ៗ លិទ្ធភ្លក្សរស ដោយអណ្តាត ៗ ពាល់ត្រូវផ្សព្វ ដោយកាយ ៗ

## ទសមោ បុរាភេទសុត្តនិទ្ទេសោ

មនសា ធម្មំ វិញ្ញាយ មនាបំ នាភិគិជ្ឈតិ នាភិហាសតិ ន រាគំ ជនេតិ ។ តស្ស ឋិតោ វ កាយោ ហោតិ ឋិតំ ចិត្តំ អជ្ឈត្តំ សុសណ្ឋិតំ សុវិមុត្តំ ។ មនសា ខោ បនេវ ធម្មំ វិញ្ញាយ អមនាបំ ន មង្កុ ហោតិ អប្បតិដ្ឋិតចិត្តោ អលីនមនសោ អព្យាបន្នចេតសោ ។ តស្ស ឋិតោ វ កាយោ ហោតិ ឋិតំ ចិត្តំ អជ្ឈត្តំ សុសណ្ឋិតំ សុវិមុត្តំ ។ ចក្ខុនា រូបំ ទិស្វា មនាបាមនាបេសុ រូបេសុ តស្ស ឋិតោ វ កាយោ ហោតិ ឋិតំ ចិត្តំ អជ្ឈត្តំ សុសណ្ឋិតំ សុវិមុត្តំ ។ សោតេន សទ្ទំ សុត្វា ។ ឃានេន គន្ធំ ឃាយិត្វា ។ ជិវ្ហាយ រសំ សាយិត្វា ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ មនសា ធម្មំ វិញ្ញាយ មនាបាមនាបេសុ ធម្មេសុ តស្ស ឋិតោ វ កាយោ ហោតិ ឋិតំ ចិត្តំ អជ្ឈត្តំ សុសណ្ឋិតំ សុវិមុត្តំ ។ ចក្ខុនា រូបំ ទិស្វា

ដឹងច្បាស់ធម្មារម្មណ៍ ដោយចិត្តហើយ រមែងមិនត្រូវការ មិនត្រេកអរ ចំពោះអារម្មណ៍ ជាទីពេញចិត្ត មិនញុំាងរាគៈឲ្យកើតឡើង ។ កាយរបស់បុគ្គលនោះ ក៏តាំងនៅខ្ជាប់ខ្ជួន ចិត្តក៏ឋិតនៅ ខាងក្នុងសណ្ឋាន ឋិតនៅដោយល្អ រួចស្រឡះ ដោយប្រពៃ ។ ដឹងច្បាស់ធម្មារម្មណ៍ ដោយចិត្តហើយ ជាអ្នកមិនស្អប់ចំពោះអារម្មណ៍មិនជាទីពេញចិត្ត មានចិត្តមិនអាក់អន់ មានចិត្តមិនរួញរា មានចិត្តមិនគុំគួន ។ កាយរបស់បុគ្គលនោះ តាំងនៅខ្ជាប់ខ្ជួន ចិត្តក៏ឋិតនៅខាងក្នុងសណ្ឋាន ឋិតនៅដោយល្អ រួចស្រឡះដោយប្រពៃ ។ ឃើញរូបដោយភ្នែក កាយរបស់បុគ្គលនោះ តាំងនៅខ្ជាប់ខ្ជួន ក្នុងរូបទាំងឡាយជាទីពេញចិត្ត ឬមិនជាទីពេញចិត្ត ចិត្តក៏ឋិតនៅខាងក្នុងសណ្ឋាន ឋិតនៅដោយល្អ រួចស្រឡះដោយប្រពៃ ។ ឮសំឡេងដោយត្រចៀក ។ ធុំក្លិនដោយច្រមុះ ។ លិទ្ធភ្លក្សរសដោយអណ្តាត ។ ពាល់ត្រូវផ្សព្វដោយកាយ ។ ដឹងច្បាស់ធម្មារម្មណ៍ដោយចិត្ត កាយរបស់បុគ្គលនោះ តាំងនៅខ្ជាប់ខ្ជួនក្នុងធម៌ទាំងឡាយជាទីពេញចិត្ត ឬមិនជាទីពេញចិត្ត ចិត្តក៏ឋិតនៅខាងក្នុងសណ្ឋាន ឋិតនៅដោយល្អ រួចស្រឡះដោយប្រពៃ ។ ឃើញរូបដោយភ្នែក

រជនីយេ ន រជ្ជតិ ទោសនីយេ ន ទុស្សតិ មោហនីយេ ន មុយ្ហតិ កោបនីយេ ន កុប្បតិ កិលេសនីយេ ន កិលិស្សតិ មទនីយេ ន មជ្ជតិ ។ សោតេន សទ្ទំ សុត្វា ។ ឃានេន គន្ធំ ឃាយិត្វា ។ ជិហ្វាយ រសំ សាយិត្វា ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ មនសា ធម្មំ វិញ្ញាយ រជនីយេ ន រជ្ជតិ ទោសនីយេ ន ទុស្សតិ មោហនីយេ ន មុយ្ហតិ កោបនីយេ ន កុប្បតិ កិលេសនីយេ ន កិលិស្សតិ មទនីយេ ន មជ្ជតិ ។ ទិដ្ឋេ ទិដ្ឋមត្តោ សុតេ សុតមត្តោ មុតេ មុតមត្តោ វិញ្ញាតេ វិញ្ញាតមត្តោ ទិដ្ឋេ ន លិម្បតិ សុតេ ន លិម្បតិ មុតេ ន លិម្បតិ វិញ្ញាតេ ន លិម្បតិ ។ ទិដ្ឋេ អនូបយោ (១) អនិស្សិតោ អប្បដិពទ្ធោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតិ ។ សុតេ មុតេ វិញ្ញាតេ អនូបយោ អនិស្សិតោ អប្បដិពទ្ធោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតិ ។

---

១ ម. ឯត្ថន្តរេ អនបាយោតិ ទិស្សតិ ។

ហើយ រមែងមិនត្រេកអរក្នុងវត្ថុដែលគួរត្រេកអរ មិនខឹងក្នុងវត្ថុដែលគួរខឹង មិនវង្វេងក្នុងវត្ថុដែលគួរវង្វេង មិនកំរើកក្នុងវត្ថុដែលគួរកំរើក មិនសៅហ្មងក្នុងវត្ថុដែលគួរសៅហ្មង មិនស្រវឹងក្នុងវត្ថុដែលគួរស្រវឹង ។ ឮសំឡេងដោយត្រចៀក ។ ធុំក្លិនដោយច្រមុះ ។ លិទ្ធភ្លក្សរសដោយអណ្តាត ។ ពាល់ត្រូវផ្សព្វដោយកាយ ។ ដឹងច្បាស់ធម្មារម្មណ៍ដោយចិត្តហើយ រមែងមិនត្រេកអរក្នុងវត្ថុដែលគួរត្រេកអរ មិនខឹងក្នុងវត្ថុដែលគួរខឹង មិនវង្វេងក្នុងវត្ថុដែលគួរវង្វេង មិនកំរើកក្នុងវត្ថុដែលគួរកំរើក មិនសៅហ្មងក្នុងវត្ថុដែលគួរសៅហ្មង មិនស្រវឹងក្នុងវត្ថុដែលគួរស្រវឹង ។ គ្រាន់តែឃើញរូបដែលឃើញ គ្រាន់តែឮសំឡេងដែលឮ គ្រាន់តែប៉ះពាល់ផស្សៈដែលប៉ះពាល់ គ្រាន់តែដឹងច្បាស់ធម្មារម្មណ៍ ដែលដឹងច្បាស់ រមែងមិនប្រឡាក់ចំពោះរូបដែលឃើញ មិនប្រឡាក់ចំពោះសំឡេងដែលឮ មិនប្រឡាក់ចំពោះផស្សៈដែលប៉ះពាល់ មិនប្រឡាក់ចំពោះធម្មារម្មណ៍ដែលដឹង ។ មិនប្រាថ្នាចំពោះរូបដែលឃើញ មិនអាស្រ័យ មិនជាប់ចំពាក់ ជាអ្នករួចស្រឡះ ប្រាសចេញ មានចិត្តប្រាសចាកសេចក្តីសល់វល់ ។ មិនប្រាថ្នាចំពោះសំឡេងដែលឮ ចំពោះផស្សៈដែលប៉ះពាល់ ចំពោះធម្មារម្មណ៍ដែលដឹង មិនអាស្រ័យ មិនជាប់ចំពាក់ ជាអ្នករួចស្រឡះ ប្រាសចេញ មានចិត្តប្រាសចាកសេចក្តីសល់វល់ ។

ទសមោ បុរាភេទសុត្តនិទ្ទេសោ

សំវិជ្ជតិ អរហតោ ចក្ខុ បស្សតិ អរហា ចក្ខុនា រូបំ
ឆន្ទរាគោ អរហតោ នត្ថិ សុវិមុត្តចិត្តោ អរហា ។ សំវិជ្ជតិ
អរហតោ សោតំ សុណាតិ អរហា សោតេន សទ្ទំ ឆន្ទរា-
គោ អរហតោ នត្ថិ សុវិមុត្តចិត្តោ អរហា ។ សំវិជ្ជតិ អរ-
ហតោ ឃានំ ឃាយតិ អរហា ឃានេន គន្ធំ ឆន្ទរាគោ
អរហតោ នត្ថិ សុវិមុត្តចិត្តោ អរហា ។ សំវិជ្ជតិ អរហតោ
ជិវ្ហា សាយតិ អរហា ជិវ្ហាយ រសំ ឆន្ទរាគោ អរហតោ
នត្ថិ សុវិមុត្តចិត្តោ អរហា ។ សំវិជ្ជតិ អរហតោ
កាយោ ផុស្សតិ អរហា កាយេន ផោដ្ឋព្វំ ឆន្ទរាគោ
អរហតោ នត្ថិ សុវិមុត្តចិត្តោ អរហា ។ សំវិជ្ជតិ
អរហតោ មនោ វិជានាតិ អរហា មនសា ធម្មំ ឆន្ទរា-
គោ អរហតោ នត្ថិ សុវិមុត្តចិត្តោ អរហា ។ ចក្ខុ
រូបារាមំ រូបរតំ រូបសម្មុទិតំ តំ អរហតោ ទន្តំ គុត្តំ
រក្ខិតំ សំវុតំ តស្ស ច សំវរាយ ធម្មំ ទេសេតិ ។

ភ្នែករបស់ព្រះអរហន្តមានគ្រប់គ្រាន់ ព្រះអរហន្តឃើញរូបដោយភ្នែក តែឆន្ទរាគរបស់ព្រះអរហន្តមិនមានទេ (ព្រោះ) ព្រះអរហន្តមានចិត្តរួចស្រឡះហើយដោយប្រពៃ ។ ត្រចៀករបស់ព្រះអរហន្តមានគ្រប់គ្រាន់ ព្រះអរហន្តឮសំឡេងដោយត្រចៀក តែឆន្ទរាគរបស់ព្រះអរហន្តមិនមានទេ (ព្រោះ) ព្រះអរហន្តមានចិត្តរួចស្រឡះហើយដោយប្រពៃ ។ ច្រមុះរបស់ព្រះអរហន្តមានគ្រប់គ្រាន់ ព្រះអរហន្តធុំក្លិនដោយច្រមុះ តែឆន្ទរាគរបស់ព្រះអរហន្តមិនមានទេ (ព្រោះ) ព្រះអរហន្តមានចិត្តរួចស្រឡះហើយដោយប្រពៃ ។ អណ្តាតរបស់ព្រះអរហន្តមានគ្រប់គ្រាន់ ព្រះអរហន្តលិទ្ធភ្លក្សរសដោយអណ្តាត តែឆន្ទរាគរបស់ព្រះអរហន្តមិនមានទេ (ព្រោះ) ព្រះអរហន្តមានចិត្តរួចស្រឡះហើយដោយប្រពៃ ។ កាយរបស់ព្រះអរហន្តមានគ្រប់គ្រាន់ ព្រះអរហន្តពាល់ត្រូវផោដ្ឋព្វៈដោយកាយ តែឆន្ទរាគរបស់ព្រះអរហន្តមិនមានទេ (ព្រោះ) ព្រះអរហន្តមានចិត្តរួចស្រឡះហើយដោយប្រពៃ ។ ចិត្តរបស់ព្រះអរហន្តមានគ្រប់គ្រាន់ ព្រះអរហន្តដឹងធម្មារម្មណ៍ដោយចិត្ត តែឆន្ទរាគរបស់ព្រះអរហន្តមិនមានទេ (ព្រោះ) ព្រះអរហន្តមានចិត្តរួចស្រឡះហើយ ដោយប្រពៃ ។ ភ្នែកមានរូបជាទីត្រេកអរ ត្រេកអរហើយក្នុងរូប រីករាយព្រមក្នុងរូប តែភ្នែកនោះ ព្រះអរហន្តបានទូន្មាន គ្រប់គ្រង រក្សា សង្រួមហើយ ទាំងព្រះអរហន្តនោះ សំដែងធម៌ដើម្បីការសង្រួមភ្នែកនោះ ។

សោតំ សទ្ទកាមំ ។ ឃានំ គន្ធកាមំ ។ ជិវ្ហា រសកាមា រសរតា រសសម្មុទិតា សា អរហតោ ទន្តា គុត្តា រក្ខិតា សំវុតា តស្ស ច សំវរាយ ធម្មំ ទេសេតិ ។ កាយោ ផោដ្ឋព្វកាមោ ។ មនោ ធម្មកាមោ ធម្មរតោ ធម្មសម្មុទិតោ សោ អរហតោ ទន្តោ គុត្តោ រក្ខិតោ សំវុតោ តស្ស ច សំវរាយ ធម្មំ ទេសេតិ ។

ទន្តំ នយន្តិ សមិតឹ ទន្តំ រាជាភិរូហតិ
ទន្តោ សេដ្ឋោ មនុស្សេសុ យោតិវាក្យំ តិតិក្ខតិ ។
វរមស្សតរា ទន្តា អាជានីយា ច សិន្ធវា
កុញ្ជរា ច មហានាគា អត្តទន្តោ តតោ វរំ ។

ត្រចៀកមានសំឡេងជាទីត្រេកអរ ។ ច្រមុះមានក្លិនជាទីត្រេកអរ ។ អណ្តាតមានរសជាទីត្រេកអរ ត្រេកអរហើយក្នុងរស រីករាយព្រមក្នុងរស តែអណ្តាតនោះ ព្រះអរហន្ត បានទូន្មាន គ្រប់គ្រង រក្សា សង្រួមហើយ ទាំងព្រះអរហន្តនោះសំដែងធម៌ ដើម្បីការសង្រួមអណ្តាតនោះ ។ កាយមានផ្សព្វជាទីត្រេកអរ ។ ចិត្តមានធម្មារម្មណ៍ជាទីត្រេកអរ ត្រេកអរហើយក្នុងធម្មារម្មណ៍ រីករាយព្រមក្នុងធម្មារម្មណ៍ តែចិត្តនោះ ព្រះអរហន្ត បានទូន្មាន គ្រប់គ្រង រក្សា សង្រួមហើយ ទាំងព្រះអរហន្តនោះ សំដែងធម៌ដើម្បីការសង្រួមចិត្តនោះ ។

ពួកជនរមែងនាំពាហនៈ (មានដំរីជាដើម) ដែលហាត់ហើយ
ទៅកាន់ទីប្រជុំ ព្រះរាជារមែងឡើងគង់ពាហនៈ ដែលហាត់
ហើយ បណ្តាមនុស្សទាំងឡាយ មនុស្សណាអត់ធន់នឹង
ពាក្យពោលត្រគោះ មនុស្សនោះ ឈ្មោះថា ជាអ្នកហាត់
ហើយ ជាបុគ្គលប្រសើរផុត ។ សេះអស្សតរក្តី សេះ
សិន្ធពអាជានេយ្យក្តី ដំរីដ៏ប្រសើរជាកុញ្ជរជាតិក្តី ដែល
គេបង្ហាត់ហើយ ឈ្មោះថា ជាសត្វដ៏ប្រសើរ តែបុគ្គល
អ្នកមានខ្លួនទូន្មានហើយ ប្រសើរជាងសត្វទាំងនោះ ។

## ទសមោ បុរាភេទសុត្តនិទ្ទេសោ

ន ហិ ឃាតេហិ យោគេហិ កច្ចេយ្យ អគតិំ(១) ធិសំ

យថាត្តនា សុនេត្តេន នេត្តា នេត្តេន គច្ឆតិ

វិជាសុ ន វិកម្បន្តិ វិប្បមុត្តា បុនព្ភវា

ឧត្តក្ខមឹ អនុប្បត្តា តេ លោកេ វិជិតាវិនោ ។

យស្សិន្ទ្រិយានិ ភាវិតានិ

អជ្ឈត្តំ ច ពហិទ្ធា ច សព្វលោកេ

និព្វិជ្ឈិមំ បរញ្ច លោកំ

កាលំ កង្ខតិ ភាវិតោ សុនេត្តោតិ

ឧបេក្ខកោ ។ សនាតិ(២) សព្វទា សព្វកាលំ

និច្ចកាលំ ធុវកាលំ ។បេ។ បច្ឆិមេ វយោខន្ធេ ។

---

១ ឱ. អបតំ ។ ២ ឱ. ម. សទាតិ សទា ។

## បុរាភេទសុត្តនិទ្ទេស ទី ១០

បុគ្គលមិនគប្បីទៅកាន់ទិស ដែលមិនធ្លាប់ទៅ គឺព្រះនិព្វាន ដោយយានទាំងឡាយនោះបានទេ លុះតែបុគ្គល អ្នកមានខ្លួនទូន្មាន ទើបទៅកាន់ទិស គឺព្រះនិព្វាន ដោយខ្លួនដែលទូន្មានហើយ ទូន្មានល្អហើយ ។

ព្រះអរហន្តទាំងឡាយ រួចស្រឡះចាកភពថ្មី ដល់ហើយនូវទន្តភូមិ គឺអរហត្តផល រមែងមិនកំរើក ក្នុងតណ្ហានឹងទិដ្ឋិផ្សេង ៗ ព្រះអរហន្តទាំងនោះ ឈ្មោះថាជាអ្នកមានជ័យជំនះក្នុងលោក ។

ឥន្ទ្រិយទាំងឡាយ ដែលព្រះខីណាស្រពណា ចំរើនហើយ ព្រះខីណាស្រពនោះ ឈ្មោះថាមានធម៌ចំរើនហើយ មានខ្លួនទូន្មានល្អហើយ ដឹងច្បាស់នូវអារម្មណ៍ទាំងខាងក្នុងខាងក្រៅ ក្នុងលោកទាំងពួងផង នូវលោកនេះផង នូវលោកខាងមុខផង រមែងរង់ចាំ នូវកាលកិរិយា (តែប៉ុណ្ណោះ)

ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកព្រងើយកន្តើយ ។ ពាក្យថា ក្នុងកាលទាំងពួង គឺ គ្រប់កាល អស់កាលទាំងពួង អស់កាលជានិច្ច អស់កាលដ៏ទៀងទាត់ ។ បេ ។ ក្នុងគំនរនៃបច្ឆិមវ័យ ។

សតោតិ ចតូហិ ការណេហិ សតោ កាយេ កាយានុបស្សនាសតិបដ្ឋានំ ភាវេន្តោ សតោ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សនាសតិបដ្ឋានំ ភាវេន្តោ សតោ ។បេ។ សោ វុច្ចតិ សតោតិ ឧបេក្ខកោ សទា សតោ។

(៩៦) ន លោកេ មញ្ញតី សមន្តិ សទិសោហមស្មីតិ មានំ ន ជនេតិ ជាតិយា វា គោត្តេន វា ។បេ។ អញ្ញតរញ្ញតរេន វា វត្ថុនាតិ ន លោកេ មញ្ញតិ សមំ។

(៩៧) ន វិសេសី ន នីចេយ្យោតិ សេយ្យោហមស្មីតិ អតិមានំ ន ជនេតិ ជាតិយា វា គោត្តេន វា ។បេ។ អញ្ញតរញ្ញតរេន វា វត្ថុនា ។ ហីនោហមស្មីតិ មានំ ន ជនេតិ ជាតិយា វា គោត្តេន វា ។បេ។ អញ្ញតរញ្ញតរេន វា វត្ថុនាតិ ន វិសេសី ន នីចេយ្យោ

ពាក្យថា មានស្មារតី គឺមានស្មារតីដោយហេតុ ៤ យ៉ាង គឺ បុគ្គលចំរើនកាយានុបស្សនាសតិប្បដ្ឋានក្នុងកាយ ឈ្មោះថា អ្នកមានស្មារតី ១ ក្នុងវេទនាទាំងឡាយ ១ ក្នុងចិត្ត ១ បុគ្គលចំរើនធម្មានុបស្សនាសតិប្បដ្ឋានក្នុងធម៌ទាំងឡាយ ឈ្មោះថា អ្នកមានស្មារតី ១ ។បេ។ បុគ្គលនោះលោកហៅថា អ្នកមានស្មារតី ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកព្រងើយកន្តើយ មានស្មារតី គ្រប់កាល ។

(៩៤) ពាក្យថា មិនប្រកាន់ថាស្មើ ក្នុងលោក គឺមិនញុំាងមានះឲ្យកើតឡើង ដោយសារជាតិក្តី ដោយសារគោត្រក្តី ។បេ។ ដោយសារវត្ថុណាមួយក្តីថា អាត្មាអញជាបុគ្គលស្មើ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនប្រកាន់ថាស្មើ ក្នុងលោក ។

(៩៥) ពាក្យថា មិនប្រកាន់ថាវិសេស មិនប្រកាន់ថាថោកទាប អធិប្បាយថា បុគ្គលមិនញុំាងអតិមានះឲ្យកើតឡើង ដោយសារជាតិក្តី ដោយសារគោត្រក្តី ។បេ។ ដោយសារវត្ថុណាមួយក្តីថា អាត្មាអញជាបុគ្គលប្រសើរ ។ មិនញុំាងមានះឲ្យកើតឡើង ដោយសារជាតិក្តី ដោយសារគោត្រក្តី ។បេ។ ដោយសារវត្ថុណាមួយក្តីថា អាត្មាអញថោកទាប ហេតុនោះ (ទ្រង់ត្រាស់ថា) មិនប្រកាន់ថាវិសេស មិនប្រកាន់ថាថោកទាប ។

(៩៦) តស្ស នោ សន្តិ ឧស្សទាតិ តស្សាតិ អរហតោ ខីណាសវស្ស ។ ឧស្សទាតិ សត្តុស្សទា រាគុស្សទោ ទោសុស្សទោ មោហុស្សទោ មានុស្សទោ ទិដ្ឋុស្សទោ កិលេសុស្សទោ កម្មុស្សទោ ។ តស្សិមេ ឧស្សទា នត្ថិ ន សន្តិ ន សំវិជ្ជន្តិ នុបលព្ភន្តិ បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍាតិ តស្ស នោ សន្តិ ឧស្សទា ។ តេនាហ ភគវា

ឧបេក្ខកោ សទា សតោ ន លោកេ មញ្ញតី សមំ
ន វិសេសី ន នីចេយ្យោ តស្ស នោ សន្តិ ឧស្សទាតិ ។

(៩៧) យស្ស និស្សយតា នត្ថិ ញត្វា ធម្មំ អនិស្សិតោ
ភវាយ វិភវាយ ច តណ្ហា យស្ស ន វិជ្ជតិ ។

## បុរាភេទសុត្តនិទ្ទេស ទី ១០

(៩៦) អធិប្បាយពាក្យថា ធម៌ជាគ្រឿងផុះផាលរបស់បុគ្គលនោះ មិនមានទេ ត្រង់ពាក្យថា របស់បុគ្គលនោះ គឺរបស់ព្រះអរហន្តខីណាស្រព ។ ពាក្យថាធម៌ជាគ្រឿងផុះផាល បានដល់ធម៌ជាគ្រឿងផុះផាល ៧ គឺ ធម៌ជាគ្រឿងផុះផាលគឺរាគៈ ផុះផាលគឺទោសៈ ផុះផាលគឺមោហៈ ផុះផាលគឺមានះ ផុះផាលគឺទិដ្ឋិ ផុះផាលគឺកិលេស ផុះផាលគឺកម្ម ។ ធម៌ជាគ្រឿងផុះផាលទាំងនេះ របស់ព្រះអរហន្ត មិនមាន ឥតមាន លែងមាន លោកលែងបាន គឺ លោកលះបង់ ផ្ដាច់ផ្ដិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ធម៌ជាគ្រឿងផុះផាលរបស់បុគ្គលនោះមិនមានទេ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលណា ជាអ្នកព្រងើយកន្តើយ មានស្មារតី គ្រប់កាល
រមែងមិនប្រកាន់ថាស្មើ មិនប្រកាន់ថាវិសេស មិនប្រកាន់ថា
ថោកទាប ក្នុងលោក ធម៌ជាគ្រឿងផុះផាលរបស់បុគ្គល
នោះ មិនមានទេ ។

(៩៧) និស្ស័យនៃបុគ្គលណា មិនមាន មួយទៀត តណ្ហា
ក្នុងភពនិងវិភព នៃបុគ្គលណា មិនមាន បុគ្គលនោះ
មិនអាស្រ័យ ព្រោះដឹងនូវធម៌ ។

(៩៨) យស្ស និស្សយតា នត្ថីតិ យស្សាតិ អរហតោ ខីណាសវស្ស ។ និស្សយាតិ ទ្វេ និស្សយា តណ្ហានិស្សយោ ច ទិដ្ឋិនិស្សយោ ច ។ បេ ។ អយំ តណ្ហានិស្សយោ ។ បេ ។ អយំ ទិដ្ឋិនិស្សយោ ។ តស្ស តណ្ហានិស្សយោ បហីនោ ទិដ្ឋិនិស្សយោ បដិនិស្សដ្ឋោ តណ្ហានិស្សយស្ស បហីនត្តា ទិដ្ឋិនិស្សយស្ស បដិនិស្សដ្ឋត្តា និស្សយតា យស្ស នត្ថិ ន សំវិជ្ជតិ នុបលព្ភតិ បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍាតិ យស្ស និស្សយតា នត្ថិ ។

(៩៩) ញត្វា ធម្មំ អនិស្សិតោតិ ញត្វាតិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា សព្វេ សង្ខារា អនិច្ចាតិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា សព្វេ សង្ខារា ទុក្ខាតិ សព្វេ ធម្មា អនត្តាតិ ។ បេ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា ។ អនិស្សិតោតិ

(៩៨) អធិប្បាយពាក្យថា និស្ស័យ នៃបុគ្គលណា មិនមាន ត្រង់ពាក្យថា នៃបុគ្គលណា គឺនៃព្រះអរហន្តខីណាស្រព ។ ពាក្យថា និស្ស័យ បានដល់និស្ស័យ ២ យ៉ាង គឺ តណ្ហានិស្ស័យ ១ ទិដ្ឋិ-និស្ស័យ ១ ។ បេ ។ នេះតណ្ហានិស្ស័យ ។ បេ ។ នេះទិដ្ឋិនិស្ស័យ ។ តណ្ហានិស្ស័យ ព្រះអរហន្តនោះ លះបង់ហើយ ទិដ្ឋិនិស្ស័យលោករលាស់ចេញហើយ និស្ស័យនៃបុគ្គលណា មិនមាន ឥតមាន លោកមិនបាន គឺលោកលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ព្រោះតណ្ហា-និស្ស័យលោកលះបង់ហើយ ព្រោះទិដ្ឋិនិស្ស័យលោករលាស់ចេញហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) និស្ស័យនៃបុគ្គលណា មិនមាន ។

(៩៩) អធិប្បាយពាក្យថា បុគ្គលនោះមិនអាស្រ័យព្រោះដឹងនូវធម៌ ត្រង់ពាក្យថា ព្រោះដឹង គឺ ព្រោះដឹង ស្គាល់ ថ្លឹង ពិចារណា យល់ច្បាស់ ធ្វើឲ្យប្រាកដថា សង្ខារទាំងពួងមិនទៀង ព្រោះដឹង ស្គាល់ ថ្លឹង ពិចារណា ឃើញច្បាស់ ធ្វើឲ្យប្រាកដថា សង្ខារទាំងពួងជាទុក្ខ ។ បេ ។ ថាធម៌ទាំងឡាយទាំងពួងជាអនត្តា ព្រោះដឹង ស្គាល់ ថ្លឹង ពិចារណា យល់ច្បាស់ ធ្វើឲ្យប្រាកដថា ធម្មជាតណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ជាធម្មតា ។ ពាក្យថា មិនអាស្រ័យ

ទ្វេ និស្សយា តណ្ហានិស្សយោ ច ទិដ្ឋិនិស្សយោ ច ។បេ។ អយំ តណ្ហានិស្សយោ ។បេ។ អយំ ទិដ្ឋិនិស្សយោ ។ តណ្ហានិស្សយំ បហាយ ទិដ្ឋិនិស្សយំ បដិនិស្សជ្ជិត្វា ចក្ខុំ អនិស្សិតោ សោតំ អនិស្សិតោ ឃានំ អនិស្សិតោ ជិវ្ហំ អនិស្សិតោ កាយំ អនិស្សិតោ មនំ អនិស្សិតោ រូបេ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ កុលំ គណំ អាវាសំ ។បេ។ ទិដ្ឋសុតមុតវិញ្ញាតព្វេ ធម្មេ អនិស្សិតោ អនល្លីនោ អនុបគតោ អនជ្ឈោសិតោ អនធិមុត្តោ និក្ខន្តោ និស្សដោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ ញត្វា ធម្មំ អនិស្សិតោ ។

(១០០) ភវាយ វិភវាយ ច តណ្ហា យស្ស ន វិជ្ជតីតិ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ យស្សាតិ អរហតោ ខីណាសវស្ស ។ ភវាយាតិ ភវទិដ្ឋិយា ។ វិភវាយាតិ វិភវទិដ្ឋិយា ។ ភវាយាតិ សស្សតទិដ្ឋិយា ។ វិភវាយាតិ ឧច្ឆេទទិដ្ឋិយា ។ ភវាយាតិ បុនប្បុនំ ភវាយ បុនប្បុនំ គតិយា បុនប្បុនំ ឧបបត្តិយា បុនប្បុនំ បដិសន្ធិយា

បុរាភេទសុត្តនិទ្ទេស ទី ១០

បានដល់និស្ស័យ ២ យ៉ាងគឺ តណ្ហានិស្ស័យ ១ ទិដ្ឋិនិស្ស័យ ១ ។ បេ ។ នេះតណ្ហានិស្ស័យ ។ បេ ។ នេះទិដ្ឋិនិស្ស័យ ។ ព្រះអរហន្តលះបង់នូវតណ្ហានិស្ស័យ រលាស់ចេញនូវទិដ្ឋិនិស្ស័យ មិនអាស្រ័យចក្ខុ មិនអា-ស្រ័យសោតៈ មិនអាស្រ័យឃានៈ មិនអាស្រ័យជិវ្ហា មិនអាស្រ័យកាយ មិនអាស្រ័យចិត្ត មិនអាស្រ័យរូប សំឡេង ក្លិន រស ផ្សព្វ ត្រកូល ពួក អាវាស ។ បេ ។ មិនអាស្រ័យ មិនជាប់ មិនកៀកកើយ មិនជ្រុលជ្រប់ មិនចុះស៊ប់ គឺលោកឃ្លាតចេញ រលាស់ចេញ រួចស្រឡះ ប្រាសចេញ មានចិត្តប្រាសចាកសេចក្ដីសល់វល់ ក្នុងធម៌ដែលគប្បីឃើញ ឮ ប៉ះពាល់ ឬដឹង ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះមិនអាស្រ័យ ព្រោះដឹងនូវធម៌ ។

(១០០) អធិប្បាយពាក្យថា តណ្ហាក្នុងភពនិងវិភពនៃបុគ្គលណាមិនមាន ត្រង់ពាក្យថា តណ្ហា គឺរូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា នៃបុគ្គលណា គឺ នៃព្រះអរហន្តខីណាស្រព ។ ពាក្យថា ក្នុងភព គឺ ក្នុងភវទិដ្ឋិ ។ ពាក្យថា វិភព គឺ ក្នុងវិភវទិដ្ឋិ ។ ពាក្យថា ក្នុងភព គឺ ក្នុងសស្សតទិដ្ឋិ ។ ពាក្យថា វិភព គឺ ក្នុងឧច្ឆេទទិដ្ឋិ ។ ពាក្យថា ក្នុងភព គឺ ក្នុងភពរឿយៗ ក្នុងគតិរឿយៗ ក្នុងការកើតឡើងរឿយៗ ក្នុងបដិសន្ធិរឿយៗ

បុនព្ភវំ អត្តភាវាភិនិព្វត្តិយា ។ តណ្ហា យស្ស នត្ថិ ន សំវិជ្ជតិ នុបលព្ភតិ បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍាតិ ភវាយ វិភវាយ ច តណ្ហា យស្ស ន វិជ្ជតិ ។

តេនាហ ភគវា

យស្ស និស្សយតា នត្ថិ ញត្វា ធម្មំ អនិស្សិតោ
ភវាយ វិភវាយ ច តណ្ហា យស្ស ន វិជ្ជតីតិ ។

(១០៧) តំ ព្រូមិ ឧបសន្តោតិ កាមេសុ អនបេក្ខិនំ
គន្ថា តស្ស ន វិជ្ជន្តិ អតារិ សោ វិសត្តិកំ ។

(១០៨) តំ ព្រូមិ ឧបសន្តោតីតិ សន្តោ ឧបសន្តោ វូបសន្តោ និព្វុតោ បដិប្បស្សទ្ធោតិ តំ ព្រូមិ តំ កថេមិ តំ ភណាមិ តំ ទីបយាមិ តំ វោហារាមីតិ តំ ព្រូមិ ឧបសន្តោតិ ។

ក្នុងកិរិយាកើតជាអត្តភាពរឿយ ៗ ។ តណ្ហានៃបុគ្គលណា មិនមាន ឥតមាន លោកមិនបាន គឺលោកលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) តណ្ហាក្នុងភពនិងវិភព នៃបុគ្គលណា មិនមាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

និស្ស័យនៃបុគ្គលណាមិនមាន មួយទៀត តណ្ហាក្នុងភព
និងវិភព នៃបុគ្គលណា មិនមាន បុគ្គលនោះ មិនអាស្រ័យ
ព្រោះដឹងនូវធម៌ ។

(១០១) តថាគតពោល នូវបុគ្គលអ្នកមិនអាល័យ ក្នុងកាម
ទាំងឡាយនោះ ថាជាអ្នកស្ងប់ គន្ថៈ (កិលេសជាគ្រឿង
ចាក់ស្រេះ) នៃបុគ្គលនោះ មិនមានទេ បុគ្គលនោះ បាន
ឆ្លងហើយ នូវវិសត្តិកាតណ្ហា ។

(១០២) ពាក្យថា តថាគតពោលនូវបុគ្គលនោះ ថាជាអ្នកស្ងប់ គឺតថាគតពោលនូវបុគ្គលនោះ សំដែងនូវបុគ្គលនោះ និយាយនូវបុគ្គលនោះ បំភ្លឺនូវបុគ្គលនោះ បញ្ចេញនូវបុគ្គលនោះ ថាជាអ្នកស្ងប់ អ្នករម្ងាប់ អ្នកចូលទៅជិតស្ងប់ អ្នករលត់ទុក្ខ អ្នកសះស្បើយទុក្ខ ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតពោលបុគ្គលនោះថា ជាអ្នកស្ងប់ ។

## ទសមោ បុរាភេទសុត្តនិទ្ទេសោ

(១០៣) កាមេសុ អនបេក្ខិនន្តិ កាមាតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។បេ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។បេ។ ឥមេ វុច្ចន្តិ កិលេសកាមា ។ វត្ថុកាមេ បរិជានិត្វា កិលេសកាមេ បហាយ បជហិត្វា វិនោទិត្វា ព្យន្តីករិត្វា អនភាវង្កមិត្វា កាមេសុ អនបេក្ខី(១) វីតកាមោ ចត្តកាមោ វន្តកាមោ មុត្តកាមោ បហីនកាមោ បដិនិស្សដ្ឋកាមោ(២) វីតរាគោ ចត្តរាគោ វន្តរាគោ មុត្តរាគោ បហីនរាគោ បដិនិស្សដ្ឋរាគោ និច្ឆាតោ និព្វុតោ សីតិភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតីតិ កាមេសុ អនបេក្ខិនំ ។

(១០៤) គន្ថា តស្ស ន វិជ្ជន្តីតិ គន្ថាតិ ចត្តារោ គន្ថា អភិជ្ឈា កាយគន្ថោ ព្យាបាទោ កាយគន្ថោ សីលព្វតបរាមាសោ កាយគន្ថោ ឥទំសច្ចាភិនិវេសោ កាយគន្ថោ ។ អត្តនោ ទិដ្ឋិយា រាគោ អភិជ្ឈា កាយគន្ថោ ។ បរវាទេសុ អាឃាតោ អប្បច្ចយោ ព្យាបាទោ កាយគន្ថោ ។

---

១ ម. អនបេក្ខិនោ ។ ២ ម. ឯត្តន្តរេ កាមេសូតិ ទិស្សតិ ។

## បុរាភេទសុត្តនិទ្ទេស ទី ១០

[១០៣] អធិប្បាយពាក្យថា អ្នកមិនអាល័យក្នុងកាមទាំងឡាយ ត្រង់ពាក្យថា កាម បើតាមឧទ្ទាន បានដល់កាម ២ គឺ វត្ថុកាម ១ កិលេសកាម ១ ។បេ។ នេះ ហៅថា វត្ថុកាម ។បេ។ នេះ ហៅថា កិលេសកាម ។ ព្រះអរហន្តកំណត់ដឹងវត្ថុកាម លះបង់ កំចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវកិលេសកាម ជាអ្នកមិនអាល័យក្នុងកាមទាំងឡាយ ជាអ្នកមានកាមទៅប្រាស មានកាមលះបង់ មានកាមខ្ជាក់ចេញ មានកាមរួចស្រឡះ មានកាមបោះបង់ មានកាមរលាស់ចេញ មានរាគៈទៅប្រាស មានរាគៈលះបង់ មានរាគៈខ្ជាក់ចេញ មានរាគៈរួចស្រឡះ មានរាគៈបោះបង់ មានរាគៈរលាស់ចេញ ជាអ្នកមិនមានប្រាថ្នា ជាអ្នករលត់ទុក្ខ ជាអ្នកត្រជាក់ ទទួលសុខ មានចិត្តដ៏ប្រសើរ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមិនអាល័យក្នុងកាមទាំងឡាយ ។

[១០៤] អធិប្បាយពាក្យថា គន្ថៈនៃបុគ្គលនោះមិនមានទេ ត្រង់ពាក្យថា គន្ថៈ បានដល់គន្ថៈ ៤ យ៉ាង គឺ អភិជ្ឈាកាយគន្ថៈ ១ ព្យាបាទកាយគន្ថៈ ១ សីលព្វតបរាមាសកាយគន្ថៈ ១ ឥទំសច្ចាភិនិវេសកាយគន្ថៈ ១ ។ តម្រេកក្នុងទិដ្ឋិរបស់ខ្លួន ឈ្មោះថា អភិជ្ឈាកាយគន្ថៈ ។ ការគុំគួន ការអាក់អន់ ក្នុងវាទៈរបស់បុគ្គលដទៃ ឈ្មោះថា ព្យាបាទកាយគន្ថៈ ។

អត្តនោ សីលំ វា វតំ វា សីលព្វតំ វា បកាសេតិ សីលព្វតបរាមាសោ កាយគន្ថោ ។ អត្តនោ ទិដ្ឋិ ឥទំ សច្ចាភិនិវេសោ កាយគន្ថោ ។ តស្សាតិ អរហតោ ខីណាសវស្ស ។ គន្ថា តស្ស ន វិជ្ជន្តីតិ គន្ថា តស្ស នត្ថិ ន សន្តិ ន សំវិជ្ជន្តិ នុបលព្ភន្តិ បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍាតិ គន្ថា តស្ស ន វិជ្ជន្តិ ។

(១០៨) អតារិ សោ វិសត្តិកន្តិ វិសត្តិកា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។បេ។ អភិជ្ឈា លោភោ អកុសលមូលំ ។ វិសត្តិកាតិ កេនដ្ឋេន វិសត្តិកា ។ វិសតាតិ វិសត្តិកា ។ វិសាលាតិ វិសត្តិកា ។ វិសដាតិ វិសត្តិកា ។ វិសមាតិ វិសត្តិកា ។ វិសក្កតីតិ វិសត្តិកា ។ វិសំហរតីតិ វិសត្តិកា ។ វិសំវាទិកាតិ វិសត្តិកា ។ វិសមូលាតិ វិសត្តិកា ។ វិសផលាតិ វិសត្តិកា ។

បុគ្គលស្លាបអន្ទើលសីល ឬវត ឬកសីលទីងវតរបស់ខ្លួន ឈ្មោះថា សីលព្វតបរាមាសកាយគន្ថៈ ។ ទិដ្ឋិរបស់ខ្លួន ឈ្មោះថា ឥទំសច្ចាភិនិវេសកាយគន្ថៈ ។ ពាក្យថា នៃបុគ្គលនោះ គឺនៃព្រះអរហន្តខីណាស្រព ។ ពាក្យថា គន្ថៈនៃបុគ្គលនោះមិនមានទេ បានសេចក្តីថា គន្ថៈនៃបុគ្គលនោះ មិនមាន ឥតមាន លែងមាន លោកមិនបាន គឺលោកលះបង់ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) គន្ថៈនៃបុគ្គលនោះ មិនមានទេ ។

(១០៥) ពាក្យថា បុគ្គលនោះ បានចួងហើយនូវវិសត្តិកាតណ្ហា អធិប្បាយថា តណ្ហា លោកហៅថា វិសត្តិកា បានដល់តម្រេក តម្រេកខ្លាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ សំនួរត្រង់ពាក្យថា វិសត្តិកា ចុះវិសត្តិកា ដោយអត្ថដូចម្តេច ។ ឈ្មោះថា វិសត្តិកា ព្រោះជាធម្មជាតិផ្សាយទៅ កាន់អារម្មណ៍ ។ ឈ្មោះថា វិសត្តិកា ព្រោះជាធម្មជាតិដ៏ទូលាយ ។ ឈ្មោះថា វិសត្តិកា ព្រោះជាធម្មជាតិជ្រួតជ្រាប ។ ឈ្មោះថា វិសត្តិកា ព្រោះជាធម្មជាតិមិនស្មើ ។ ឈ្មោះថា វិសត្តិកា ព្រោះជាធម្មជាតិអត់ធន់ ។ ឈ្មោះថា វិសត្តិកា ព្រោះជាធម្មជាតិនាំត្រឡប់ (ចាកអកុសលធម៌) ។ ឈ្មោះថា វិសត្តិកា ព្រោះជាធម្មជាតិឲ្យពោលខុស ។ ឈ្មោះថា វិសត្តិកា ព្រោះជាធម្មជាតិមានផ្ទៃជាពិស ។

## ទសមោ បុរាភេទសុត្តនិទ្ទេសោ

វិសបរិភោគាតិ វិសត្តិកា ។ វិសាលា វា បន សា តណ្ហា រូបេ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ កុលេ គណេ អាវាសេ ។បេ។ ទិដ្ឋ សុត មុត វិញ្ញាតព្វេសុ ធម្មេសុ វិសដា វិត្ថតាតិ វិសត្តិកា ។ អតារិ សោ វិសត្តិកន្តិ សោ ឥមំ វិសត្តិកំ តណ្ហំ អតារិ ឧត្តរិ បត្តរិ សមតិក្កមិ វីតិវត្តតីតិ អតារិ សោ វិសត្តិកំ ។ តេនាហ ភគវា

តំ ព្រូមិ ឧបសន្តោតិ   កាមេសុ អនបេក្ខិនំ
គន្ថា តស្ស ន វិជ្ជន្តិ   អតារិ សោ វិសត្តិកន្តិ ។

(១០៦) ន តស្ស បុត្តា បសវោ   ខេត្តំ វត្ថុញ្ច វិជ្ជតិ
អត្តំ(១) វាបិ និរត្តំ វា   ន តស្មឹ ឧបលព្ភតិ ។

---

១ ម. អត្តា ។

## បុរាភេទសុត្តនិទ្ទេស ទី ១០

ឈ្មោះថា វិសត្តិកា ព្រោះជាធម្មជាតិមានគ្រឿងបរិភោគជាពិស ។ មួយទៀត តណ្ហានោះ ជាធម្មជាតិដ៏ទូលាយ ជ្រួតជ្រាប ផ្សាយទៅ ក្នុងរូប ក្នុងសំឡេង ក្នុងក្លិន ក្នុងរស ក្នុងផ្សព្វ ក្នុងត្រកូល ក្នុងពួក ក្នុងអាវាស ។ បេ ។ ក្នុងធម៌ទាំងឡាយ ដែលឃើញ ឮ ប៉ះពាល់ ឬគួរដឹង ព្រោះហេតុនោះ តណ្ហា ទើបឈ្មោះថា វិសត្តិកា ។ ពាក្យថា បុគ្គលនោះ បានឆ្លងហើយនូវវិសត្តិកាតណ្ហា គឺបុគ្គលនោះ បានឆ្លង ឆ្លងឡើង ឆ្លងកាត់ ឈានកន្លង ប្រព្រឹត្តកន្លង នូវតណ្ហា ដែលឈ្មោះថាវិសត្តិកានេះ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ បានឆ្លងនូវវិសត្តិកាតណ្ហា ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

តថាគតពោលនូវបុគ្គលអ្នកមិនអាល័យ ក្នុងកាមទាំងឡាយ
នោះ ថាជាអ្នកស្ងប់ គន្ថៈនៃបុគ្គលនោះ មិនមានទេ
បុគ្គលនោះ បានឆ្លងហើយ នូវវិសត្តិកាតណ្ហា ។

(១០៦) បុត្ត សត្វចិញ្ចឹម ស្រែ ទីដី របស់បុគ្គលនោះ មិនមាន
ទេ អត្តទិដ្ឋិក្តី និរត្តទិដ្ឋិក្តី គេរកមិនបានក្នុងបុគ្គលនោះឡើយ ។

(១០៧) ន តស្ស បុត្តា បសវោ ខេត្តំ វត្ថុញ្ច វិជ្ជតីតិ នត្ថិ បដិក្ខេបោ ។ តស្សាតិ អរហតោ ខីណាសវស្ស ។ បុត្តាតិ ចត្តារោ បុត្តា អត្តជោ បុត្តោ ខេត្តជោ បុត្តោ ទិន្នកោ បុត្តោ អន្តេវាសិកោ បុត្តោ ។ បសវោតិ អជេឡកា កុក្កុដសូករា ហត្ថិគវាស្សវឡវា ។ ខេត្តន្តិ សាលិក្ខេត្តំ វីហិក្ខេត្តំ មុគ្គក្ខេត្តំ មាសក្ខេត្តំ យវក្ខេត្តំ គោធុមក្ខេត្តំ តិលក្ខេត្តំ ។ វត្ថុន្តិ ឃរវត្ថុ កោដ្ឋកវត្ថុ បុរេវត្ថុ បច្ឆាវត្ថុ អារាមវត្ថុ វិហារវត្ថុ ។ ន តស្ស បុត្តា បសវោ ខេត្តំ វត្ថុញ្ច វិជ្ជតីតិ តស្ស បុត្តបរិគ្គហោ វា បសុបរិគ្គហោ វា ខេត្តបរិគ្គហោ វា វត្ថុបរិគ្គហោ វា នត្ថិ ន សន្តិ ន សំវិជ្ជតិ នុបលព្ភតិ បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍាតិ ន តស្ស បុត្តា បសវោ ខេត្តំ វត្ថុញ្ច វិជ្ជតិ(១) ។

១ ម. វិជ្ជន្តិ ។

(១០៧) អធិប្បាយពាក្យថា បុត្រ សត្វចិញ្ចឹម ស្រែ ទីផ្ទះ របស់បុគ្គលនោះ មិនមានទេ ត្រង់ពាក្យថា មិន គឺជាពាក្យឃាត់ ។ ពាក្យថា របស់បុគ្គលនោះ គឺរបស់ព្រះអរហន្តខីណាស្រព ។ ពាក្យថា បុត្រ បានដល់បុត្រ ៤ ពួក គឺ បុត្រកើតអំពីខ្លួន ១ បុត្រកើតក្នុងខេត្រ ១ បុត្រដែលគេឲ្យ ១ បុត្រគឺសិស្ស ១ ។ ពាក្យថា សត្វចិញ្ចឹម គឺ ពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះឈ្មោលនិងសេះញី ។ ពាក្យថា ស្រែ គឺ ស្រែស្រូវសាលី ស្រែស្រូវធម្មតា ស្រែសណ្ដែកបាយ ស្រែសណ្ដែកពងមាន់ ស្រែស្រូវដំណើប ស្រែស្រូវស្រងែ ស្រែល្ង ។ ពាក្យថា ទី គឺ ទីផ្ទះ ទីជង្រុក ទីខាងមុខ ទីខាងក្រោយ ទីសួនច្បារ ទីលំនៅ ។ ពាក្យថា បុត្រ សត្វចិញ្ចឹម ស្រែ ទីផ្ទះ របស់បុគ្គលនោះ មិនមានទេ បានសេចក្ដីថា ការហួងហែងបុត្តក្ដី ការហួងហែងសត្វចិញ្ចឹមក្ដី ការហួងហែងស្រែក្ដី ការហួងហែងទីក្ដី របស់បុគ្គលនោះ មិនមាន ឥតមាន លែងមាន បុគ្គលនោះមិនបាន គឺលោកលះបង់ ផ្ដាច់ផ្ដិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) បុត្រ សត្វចិញ្ចឹម ស្រែ ទីផ្ទះ របស់បុគ្គលនោះ មិនមានទេ ។

## ទសមោ បុរាភេទសុត្តនិទ្ទេសោ

(១០៨) អត្តំ វាបិ និរត្តំ(១) វា ន តស្មឹ ឧបលព្ភតីតិ អត្តាតិ សស្សតទិដ្ឋិ(២) នត្ថិ(៣) និរត្តាតិ ឧច្ឆេទទិដ្ឋិ នត្ថិ អត្តាតិ គហិតំ នត្ថិ និរត្តាតិ មុញ្ចិតព្វំ នត្ថិ ។ យស្ស នត្ថិ គហិតំ តស្ស នត្ថិ មុញ្ចិតព្វំ យស្ស នត្ថិ មុញ្ចិតព្វំ តស្ស នត្ថិ គហិតំ ។ គហណមុញ្ចនំ សមតិក្កន្តោ អរហា វុឌ្ឍិបរិហានិវីតិវត្តោ ។ សោ វុដ្ឋវាសោ ចិណ្ណចរណោ ។បេ។ នត្ថិ តស្ស បុនព្ភវោតិ អត្តំ វាបិ និរត្តំ វា ន តស្មឹ ឧបលព្ភតីតិ។ តេនាហ ភគវា

ន តស្ស បុត្តា បសវោ ខេត្តំ វត្ថុញ្ច វិជ្ជតិ(៤)
អត្តំ វាបិ និរត្តំ វា ន តស្មឹ ឧបលព្ភតីតិ ។

(១០៩) យេន(៥) វជ្ជុំ បុថុជ្ជនា អថោ សមណព្រាហ្មណា
តំ តស្ស អបុរេក្ខតំ តស្មា វាទេសុ នេជតិ ។

---

១ ម. អត្តា វាបិ និរត្តា ។ ២ ម. អត្តទិដ្ឋិ ។ ៣ ម. នត្ថីតិ ន ទិស្សតិ ។ ៤ ម. វិជ្ជន្តិ។
៥ ម. យេន នំ ។

## បុភេទសុត្តនិទ្ទេស ទី ១០

(១០៨) អធិប្បាយពាក្យថា អត្តទិដ្ឋិកី និរត្តទិដ្ឋិកី គេរកមិនបានក្នុងបុគ្គលនោះឡើយ ត្រង់ពាក្យថា អត្តា គឺសស្សតទិដ្ឋិ មិនមាន ពាក្យថា និរត្តា គឺឧច្ឆេទទិដ្ឋិ មិនមាន ការប្រកាន់ថាអត្តា មិនមាន ការគប្បីដោះថា និរត្តា មិនមាន ។ ការប្រកាន់នៃបុគ្គលណា មិនមាន ការគប្បីដោះនៃបុគ្គលនោះ មិនមាន ការគប្បីដោះនៃបុគ្គលណា មិនមាន ការប្រកាន់នៃបុគ្គលនោះ មិនមាន ។ ព្រះអរហន្តកន្លងផុតការប្រកាន់នឹងការដោះ ប្រព្រឹត្តកន្លង នូវការចំរើននឹងការសាបសូន្យ ។ ព្រះអរហន្តនោះ មានការនៅ (ក្នុងអរិយវាសៈ) នៅរួចហើយ មានការប្រព្រឹត្តសន្សំហើយ ។ បេ ។ កពច្ឆ្មរបស់លោក មិនមាន ហេតុនោះ (ទ្រង់ត្រាស់ថា) អត្តទិដ្ឋិកី និរត្តទិដ្ឋិកី គេរកមិនបានក្នុងបុគ្គលនោះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុត្រ សត្វចិញ្ចឹម ស្រែ ទីដីរបស់បុគ្គលនោះ មិនមានទេ
អត្តទិដ្ឋិកី និរត្តទិដ្ឋិកី គេរកមិនបានក្នុងបុគ្គលនោះឡើយ ។

(១០៩) មួយទៀត សមណៈព្រាហ្មណ៍ទាំងឡាយ ជាបុថុជ្ជន គប្បីពោលដោយកិលេសណា បុគ្គលនោះ មិនធ្វើកិលេសនោះឲ្យជាប្រធាន ព្រោះហេតុនោះ បុគ្គលនោះ មិនញាប់ញ័រ ក្នុងវាទៈទាំងឡាយ ។

(១១០) យេន(១) វជ្ជុំ បុថុជ្ជនា អថោ សមណ-ព្រាហ្មណាតិ បុថុជ្ជនាតិ កេនដ្ឋេន បុថុជ្ជនា ។ បុថុ កិលេសេ ជនេន្តីតិ បុថុជ្ជនា ។ បុថុ អវិហតសក្កាយ-ទិដ្ឋិកាតិ បុថុជ្ជនា ។ បុថុ សត្ថារានំ មុខុល្លោកិ-កាតិ បុថុជ្ជនា ។ បុថុ សព្វគតីហិ អាវុដិតាតិ(២) បុថុជ្ជនា ។ បុថុ នានាភិសង្ខារេហិ អភិសង្ខរោន្តីតិ បុថុជ្ជនា ។ បុថុ នានាឱឃេហិ វុយ្ហន្តីតិ បុថុជ្ជនា ។ បុថុ នានាសន្តាបេហិ សន្តប្បន្តីតិ បុថុជ្ជនា ។ បុថុ នានាបរិឡាហេហិ បរិឌយ្ហន្តីតិ បុថុជ្ជនា ។ បុថុ បញ្ចសុ កាមគុណេសុ រត្តា គិទ្ធា គធិតា មុច្ឆិតា អជ្ឈោបន្នា លគ្គា លគ្គិតា បលិពុទ្ធាតិ បុថុជ្ជនា ។ បុថុ បញ្ចហិ នីវរណេហិ អាវុតា និវុតា ឱផុដា បិហិតា បដិច្ឆន្នា បដិកុជ្ជិតាតិ បុថុជ្ជនា ។ សមណាតិ យេកេចិ ឥតោ ពហិទ្ធា បរិព្វាជុបគតា បរិព្វាជសមាបន្នា ។

---

១ ម. យេន នំ ។ ២ ម. អាវុដ្ឋិតាតិ ។

(១១០) អធិប្បាយពាក្យថា មួយទៀត សមណព្រាហ្មណ៍ទាំងឡាយ ជាបុថុជ្ជន គប្បីពោលដោយកិលេសណា សំនួរត្រង់ពាក្យថា បុថុជ្ជន ចុះបុថុជ្ជន ដោយអត្ថដូចម្ដេច ។ ឈ្មោះថា បុថុជ្ជន ព្រោះញុំាងកិលេសក្រាស់ឲ្យកើត ។ ឈ្មោះថា បុថុជ្ជន ព្រោះមិនទាន់កំចាត់បង់សក្កាយទិដ្ឋិដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកយល់មុខសាស្ដាទាំងឡាយដ៏ច្រើន ។ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកត្រូវគតិទាំងពួងដ៏ច្រើនរួបរឹត ។ ឈ្មោះថា បុថុជ្ជន ព្រោះតាក់តែងដោយអភិសង្ខារផ្សេងៗដ៏ច្រើន ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រូវជំនន់ផ្សេងៗ ដ៏ច្រើនបន្សាត់ទៅ ។ ឈ្មោះថា បុថុជ្ជន ព្រោះអន្ទះអន្ទែងដោយសេចក្ដីអន្ទះអន្ទែងផ្សេងៗដ៏ច្រើន ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រូវសេចក្ដីក្ដៅក្រហាយផ្សេងៗ ដ៏ច្រើនដុតហើយ ។ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកត្រេកអរ ចង់បាន ធ្លាក់ចុះ ងុលងប់ ជ្រុលជ្រប់ ជាប់នៅ ចំពាក់នៅ សាន់ភ៉ន់នៅ ក្នុងកាមគុណទាំង៥ដ៏ច្រើន ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រូវនីវរណៈ ទាំង៥ ដ៏ច្រើន ខ្ទប់ រាំង ហ៊ុម បិទ បាំង គ្របហើយ ។ ពាក្យថា សមណៈ គឺ ពួកជនណាមួយចូលទៅរកបរិព្វាជក ជាខាងក្រៅសាសនានេះ បួសជាបរិព្វាជក ។

## ទសមោ បុរាភេទសុត្តនិទ្ទេសោ

ព្រាហ្មណាតិ យេកេចិ ភោវាទិកា ។ យេន វុឌ្ឍិ បុថុជ្ជនា អថោ សមណព្រាហ្មណាតិ បុថុជ្ជនា យេន រាគេន វេទយុំ យេន ទោសេន វេទយុំ យេន មោហេន វេទយុំ យេន មានេន វេទយុំ យាយ ទិដ្ឋិយា វេទយុំ យេន ឧទ្ធច្ចេន វេទយុំ យាយ វិចិកិច្ឆាយ វេទយុំ យេហិ អនុសយេហិ វេទយុំ រត្តាតិ វា ទុដ្ឋាតិ វា មូឡ្ហាតិ វា វិនិពទ្ធាតិ វា បរាមដ្ឋាតិ វា វិក្ខេបគតាតិ វា អនិដ្ឋង្គតាតិ វា ថាមគតាតិ វា ។ តេ អភិសង្ខារ បហីនា អភិសង្ខារនំ បហីនត្តា គតិយោ យេន វេទយុំ នេរយិកោតិ វា តិរច្ឆានយោនិកោតិ វា បិត្តិវិសយិកោតិ វា មនុស្សោតិ វា ទេវោតិ វា រូបីតិ វា អរូបីតិ វា សញ្ញីតិ វា អសញ្ញីតិ វា នេវសញ្ញីនាសញ្ញីតិ វា ។

## បុរាភេទសុត្តនិទ្ទេស ទី ១០

ពាក្យថា ព្រាហ្មណ៍ គឺពួកជនណាមួយ ជាភោវាទិ ៗ ពាក្យថា មួយទៀត សមណព្រាហ្មណ៍ទាំងឡាយជាបុថុជ្ជន គប្បីពោលដោយកិលេសណា បានសេចក្តីថា ពួកបុថុជ្ជនគប្បីពោលដោយរាគៈណា គប្បីពោលដោយទោសៈណា គប្បីពោលដោយមោហៈណា គប្បីពោលដោយមានះណា គប្បីពោលដោយទិដ្ឋិណា គប្បីពោលដោយឧទ្ធច្ចៈណា គប្បីពោលដោយវិចិកិច្ឆាណា គប្បីពោលដោយអនុស័យណា ថា (អ្នកនេះ) ជាអ្នកត្រេកអរ ឬថាជាអ្នកប្រទូស្ត ថាជាអ្នកវង្វេង ឬថាជាអ្នកជាប់ចំពាក់ ថាជាអ្នកស្ទាបអង្អែល ឬថាជាអ្នកដល់នូវសេចក្តីរាយមាយ ថាជាអ្នកមិនដាច់ស្រេច ឬថាជាអ្នកដល់នូវកំឡាំង ៗ អភិសង្ខារទាំងនោះ បុគ្គលនោះលះបង់ហើយ ព្រោះលោកលះបង់ នូវអភិសង្ខារទាំងឡាយអស់ហើយ ពួកបុថុជ្ជន គប្បីពោលនូវគតិទាំងឡាយ ថា (អ្នកនេះ) ជាអ្នកកើតក្នុងនរក ឬថាជាអ្នកកើតក្នុងកំណើតតិរច្ឆាន ថាជាអ្នកកើតក្នុងបិត្តិវិស័យ ឬថាជាមនុស្ស ថាជា-ទេវតា ឬថាជារូបព្រហ្ម ថាជាអរូបព្រហ្ម ឬថាជាសញ្ញីសត្វ ថាជាអសញ្ញីសត្វ ឬថាជានេវសញ្ញីនាសញ្ញីសត្វ ដោយហេតុណា ៗ

សោ ហេតុ នត្ថិ បច្ចយោ នត្ថិ ការណំ នត្ថិ យេន វទេយ្យុំ កថេយ្យុំ ភណេយ្យុំ ទីបយេយ្យុំ វោហរេយ្យុន្តិ យេន វជ្ជុំ បុថុជ្ជនា អថោ សមណព្រាហ្មណា ។

(១១១) តំ តស្ស អបុរេក្ខតន្តិ តស្សាតិ អរហតោ ខីណាសវស្ស ។ បុរេក្ខារាតិ ទ្វេ បុរេក្ខារា តណ្ហាបុរេក្ខារោ ច ទិដ្ឋិបុរេក្ខារោ ច ។បេ។ អយំ តណ្ហាបុរេក្ខារោ ។បេ។ អយំ ទិដ្ឋិបុរេក្ខារោ ។ តស្ស តណ្ហាបុរេក្ខារោ បហីនោ ទិដ្ឋិបុរេក្ខារោ បដិនិស្សដ្ឋោ តណ្ហាបុរេក្ខារស្ស បហីនត្តា ទិដ្ឋិបុរេក្ខារស្ស បដិនិស្សដ្ឋត្តា ន តណ្ហំ វា ទិដ្ឋឹ វា បុរតោ កត្វា ចរតិ ន តណ្ហាធជោ ន តណ្ហាកេតុ ន តណ្ហាធិបតេយ្យោ ន ទិដ្ឋិធជោ ន ទិដ្ឋិកេតុ ន ទិដ្ឋាធិបតេយ្យោ ន តណ្ហាយ វា ទិដ្ឋិយា វា បរិវារិតោ ចរតីតិ តំ តស្ស អបុរេក្ខតំ ។

ពួកបុថុជ្ជន គប្បីពោល គប្បីសំដែង គប្បីពណ៌នា គប្បីបំភ្លឺ គប្បីថ្លែង ដោយហេតុណា ហេតុនោះមិនមាន បច្ច័យនោះមិនមាន ការណ៍នោះមិនមាន ហេតុនោះ (ទ្រង់ត្រាស់ថា) មួយទៀត សមណព្រាហ្មណ៍ទាំងឡាយជាបុថុជ្ជន គប្បីពោលដោយកិលេសណា ។

(១១១) អធិប្បាយពាក្យថា បុគ្គលនោះមិនធ្វើកិលេសនោះឲ្យជាប្រធាន ត្រង់ពាក្យថា បុគ្គលនោះ គឺព្រះអរហន្តខីណាស្រព ។ ពាក្យថា ការធ្វើឲ្យជាប្រធាន បានដល់ការធ្វើឲ្យជាប្រធានមាន ២ គឺ ការធ្វើឲ្យជាប្រធានគឺតណ្ហា ១ ការធ្វើឲ្យជាប្រធានគឺទិដ្ឋិ ១ ។បេ។ នេះ ការធ្វើឲ្យជាប្រធានគឺតណ្ហា ។បេ។ នេះ ការធ្វើឲ្យជាប្រធានគឺទិដ្ឋិ ។ ការធ្វើឲ្យជាប្រធានគឺតណ្ហា បុគ្គលនោះលះបង់ហើយ ការធ្វើឲ្យជាប្រធានគឺទិដ្ឋិ បុគ្គលនោះរលាស់ចោលហើយ ព្រោះលោកលះបង់នូវការធ្វើឲ្យជាប្រធានគឺតណ្ហា ព្រោះលោករលាស់ចោលនូវការធ្វើឲ្យជាប្រធានគឺទិដ្ឋិ លោកទើបមិនប្រព្រឹត្តធ្វើតណ្ហាឬទិដ្ឋិឲ្យជាប្រធាន ជាអ្នកមិនមានទង់ជ័យគឺតណ្ហា មិនមានទង់គឺតណ្ហា មិនមានតណ្ហាជាអធិបតី មិនមានទង់ជ័យគឺទិដ្ឋិ មិនមានទង់គឺទិដ្ឋិ មិនមានទិដ្ឋិជាអធិបតី មិនត្រូវតណ្ហាឬទិដ្ឋិប្រព្រឹត្តចោមរោម ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះមិនធ្វើកិលេសនោះឲ្យជាប្រធាន ។

ទសមោ បុរាភេទសុត្តនិទ្ទេសោ

(១១៦) តស្មា វាទេសុ នេជតីតិ តស្មាតិ តស្មា តំការណា តំហេតុ តប្បច្ចយា តំនិទានា វាទេសុ ឧបវាទេសុ និន្ទាយ គរហាយ អកិត្តិយា អវណ្ណា-ហារិកាយ នេជតិ ន ឥញ្ជតិ ន ចលតិ ន វេធតិ នប្បវេធតិ ន សម្បវេធតីតិ តស្មា វាទេសុ នេជតិ ។ តេនាហ ភគវា

យេន នំ វជ្ជុំ បុថុជ្ជនា អថោ សមណព្រាហ្មណា
តំ តស្ស អបុរេក្ខតំ តស្មា វាទេសុ នេជតីតិ ។

(១១៧) វីតគេធោ អមច្ឆរី ន ឱស្សេសុ[១] វទតេ មុនិ
ន សមេសុ ន ឱមេសុ កប្បំ នេតិ អកប្បិយោ ។

---

១ ម. ឧស្សេសុ ។

## បុរភេទសុត្តនិទ្ទេស ទី ១០

(១១២) ពាក្យថា ព្រោះហេតុនោះ ក្នុងបទថា ព្រោះហេតុនោះ បុគ្គលនោះមិនញាប់ញ័រក្នុងវាទៈទាំងឡាយ គឺ ព្រោះហេតុនោះ ព្រោះការណ៍នោះ ព្រោះទំនងនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ បុគ្គលនោះ មិនញាប់ញ័រ ឥតញាប់ញ័រ មិនកម្រើក មិនរន្ធត់ មិនរំជួយ មិនប្រែត្រឡប់ ក្នុងវាទៈទាំងឡាយ គឺក្នុងឧបវាទៈ ក្នុងពាក្យនិន្ទា ក្នុងពាក្យតិះដៀល ក្នុងពាក្យបង្អាប់ ក្នុងពាក្យមិននាំមកនូវគុណ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះហេតុនោះ បុគ្គលនោះ មិនញាប់ញ័រក្នុងវាទៈទាំងឡាយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

មួយទៀត សមណព្រាហ្មណ៍ទាំងឡាយ ជាបុថុជ្ជន គប្បី
ពោលដោយកិលេសណា បុគ្គលនោះ មិនធ្វើកិលេសនោះ
ឲ្យជាប្រធាន ព្រោះហេតុនោះ បុគ្គលនោះ មិនញាប់ញ័រ
ក្នុងវាទៈទាំងឡាយ ។

(១១៣) បុគ្គលជាអ្នកប្រាសចាកសេចក្តីប្រាថ្នា ជាអ្នកមិនមាន
សេចក្តីកំណាញ់ ជាមុនិ មិនពោលក្នុងហេតុ ដ៏ខ្ពស់ទេ
មិនពោលក្នុងហេតុដ៏ស្មើទេ មិនពោលក្នុងហេតុដ៏ថោកទាប
ទេ ជាអ្នកមិនមានកប្បៈ មិនដល់នូវកប្បៈ ។

(១១៤) វីតគេធោ អមច្ឆរីតិ គេធោ វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។បេ។ អភិជ្ឈា លោភោ អកុសលមូលំ ។ យស្សេសោ គេធោ បហីនោ សមុច្ឆិន្នោ វូបសន្តោ បដិប្បស្សទ្ធោ អភព្វុប្បត្តិកោ ញាណគ្គិនា ទឌ្ឍោ សោ វុច្ចតិ វីតគេធោ ។ សោ រូបេ អគិទ្ធោ ។បេ។ ទិដ្ឋសុតមុតវិញ្ញាតព្វេសុ ធម្មេសុ អគិទ្ធោ អគធិតោ អមុច្ឆិតោ អនជ្ឈោបន្នោ វីតគេធោ ចត្តគេធោ វន្តគេធោ មុត្តគេធោ បដិនិស្សដ្ឋគេធោ និច្ឆាតោ និព្វុតោ សីតិភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតីតិ វីតគេធោ ។ អមច្ឆរីតិ មច្ឆរិយន្តិ បញ្ច មច្ឆរិយានិ អាវាសមច្ឆរិយំ កុលមច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ ធម្មមច្ឆរិយំ យំ ឯវរូបំ មច្ឆរិយំ ។បេ។ គាហោ ឥទំ វុច្ចតិ មច្ឆរិយំ ។ យស្សេតំ មច្ឆរិយំ

(១១៤) ពាក្យថា ជាអ្នកប្រាសចាកសេចក្តីប្រាថ្នា ជាអ្នកមិនមានសេចក្តីកំណាញ់ អធិប្បាយថា តណ្ហា លោកហៅថា សេចក្តីប្រាថ្នា បានដល់ តម្រេក តម្រេកខ្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ សេចក្តីប្រាថ្នានេះ បុគ្គលណាលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកប្រាសចាកសេចក្តីប្រាថ្នា ។ បុគ្គលនោះ មិនប្រាថ្នាក្នុងរូប ។ បេ ។ មិនប្រាថ្នា មិនចំពាក់ មិនងុលងប់ មិនជ្រុលជ្រប់ ក្នុងពួកធម៌ដែលគប្បីឃើញ ឮ ប៉ះពាល់ ឬដឹង គឺជាអ្នកប្រាសចាកការប្រាថ្នា លះបង់ការប្រាថ្នា ខ្ជាក់ចោលការប្រាថ្នា រួចចាកការប្រាថ្នា រលាស់ចោលការប្រាថ្នា មិនមានសេចក្តីស្រេកឃ្លាន មានទុក្ខរលត់ហើយ ជាអ្នកត្រជាក់ សោយសុខនៅដោយចិត្តដ៏ប្រសើរ ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកប្រាសចាកសេចក្តីប្រាថ្នា ។ ពាក្យថា សេចក្តីកំណាញ់ ក្នុងបទថា មិនមានសេចក្តីកំណាញ់ បានដល់សេចក្តីកំណាញ់ ៥ គឺ កំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់វណ្ណៈ ១ កំណាញ់ធម៌ ១ សេចក្តីកំណាញ់ឯណា មានសភាពយ៉ាងនេះ ។ បេ ។ សេចក្តីប្រកាន់ នេះ លោកហៅថា សេចក្តីកំណាញ់ ។ សេចក្តីកំណាញ់នេះ

បហីនំ សមុច្ឆិន្នំ វូបសន្តំ បដិប្បស្សទ្ធំ អភព្វុប្បត្តិកំ ញាណគ្គិនា ទឌ្ឍំ សោ វុច្ចតិ អមច្ឆរីតិ វីតគេធោ អមច្ឆរី ។

(១១៥) ន ឧស្សេសុ វទតេ មុនិ ន សមេសុ ន ឱមេសុតិ មុនីតិ មោនំ វុច្ចតិ ញាណំ ។ បេ ។ សង្គជាលមតិច្ច សោ មុនិ ។ មុនិ សេយ្យោហមស្មីតិ វា សទិសោហមស្មីតិ វា ហីនោហមស្មីតិ វា ន វទតិ ន កថេតិ ន ភណតិ ន ទីបយតិ ន វោហរតីតិ ន ឧស្សេសុ វទតេ មុនិ ន សមេសុ ន ឱមេសុ ។

(១១៦) កប្បំ នេតិ អកប្បិយោតិ កប្បោតិ ទ្វេ កប្បា តណ្ហាកប្បោ ច ទិដ្ឋិកប្បោ ច ។ បេ ។ អយំ តណ្ហាកប្បោ ។ បេ ។ អយំ ទិដ្ឋិកប្បោ ។

បុគ្គលភេទសុត្តនិទ្ទេស ទី ១០

បុគ្គលណា បានលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតពោលដោយភ្លើងគឺញាណហើយ បុគ្គលនោះលោកហៅថា អ្នកមិនមានសេចក្តីកំណាញ់ ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកប្រាសចាកសេចក្តីប្រាថ្នា ជាអ្នកមិនមានសេចក្តីកំណាញ់ ។

(១១៥) ពាក្យថា ជាមុនិ មិនពោលក្នុងហេតុដ៏ខ្ពស់ទេ មិនពោលក្នុងហេតុដ៏ស្មើទេ មិនពោលក្នុងហេតុដ៏ថោកទាបទេ ត្រង់ពាក្យថា មុនិ សេចក្តីថា ញាណ លោកហៅថា មោនៈ ។បេ។ មុនិនោះ បានកន្លងនូវបណ្តាញជាគ្រឿងជាប់ចំពាក់ ។ មុនិ មិនពោល មិនសំដែង មិនពណ៌នា មិនបំភ្លឺ មិនថ្លែងថា អាត្មាអញជាបុគ្គលប្រសើរ ឬថា អាត្មាអញជាបុគ្គលប្រហែលនឹងគេ ឬក៏ថាអាត្មាអញជាបុគ្គលថោកទាបជាងគេដូច្នេះឡើយ ហេតុនោះ (ទ្រង់ត្រាស់ថា) មុនិមិនពោលក្នុងហេតុដ៏ខ្ពស់ទេ មិនពោលក្នុងហេតុដ៏ស្មើទេ មិនពោលក្នុងហេតុដ៏ថោកទាបទេ ។

(១១៦) ពាក្យថា កប្បៈ ក្នុងបទថា ជាអ្នកមិនមានកប្បៈ មិនដល់នូវកប្បៈ បានដល់កប្បៈ ២ គឺ កប្បៈគឺតណ្ហា ១ កប្បៈគឺទិដ្ឋិ ១ ។ បេ ។ នេះ កប្បៈគឺតណ្ហា ។ បេ ។ នេះ កប្បៈគឺទិដ្ឋិ ។

តស្ស តណ្ហាកប្បោ បហីនោ ទិដ្ឋិកប្បោ បដិនិស្សដ្ឋោ តណ្ហាកប្បស្ស បហីនត្តា ទិដ្ឋិកប្បស្ស បដិនិស្សដ្ឋត្តា តណ្ហាកប្បំ វា ទិដ្ឋិកប្បំ វា នេតិ ន ឧបេតិ ន ឧបគច្ឆតិ ន គណ្ហាតិ ន បរាមសតិ នាភិនិវិសតីតិ កប្បំ នេតិ ។ អកប្បិយោតិ កប្បាតិ ទ្វេ កប្បា តណ្ហាកប្បោ ច ទិដ្ឋិកប្បោ ច ។ បេ ។ អយំ តណ្ហាកប្បោ ។ បេ ។ អយំ ទិដ្ឋិកប្បោ ។ តស្ស តណ្ហាកប្បោ បហីនោ ទិដ្ឋិកប្បោ បដិនិស្សដ្ឋោ តស្ស តណ្ហាកប្បស្ស បហីនត្តា ទិដ្ឋិកប្បស្ស បដិនិស្សដ្ឋត្តា តណ្ហាកប្បំ វា ទិដ្ឋិកប្បំ វា ន កប្បេតិ ន ជនេតិ ន សញ្ជនេតិ ន និព្វត្តេតិ នាភិនិព្វត្តេតីតិ កប្បំ នេតិ អកប្បិយោ ។ តេនាហ ភគវា

វីតគេធោ អមច្ឆរី ន ឧស្សេសុ វទតេ មុនិ
ន សមេសុ ន ឱមេសុ កប្បំ នេតិ អកប្បិយោតិ ។

មុនិនោះ លះបង់កប្បៈគឺតណ្ហា រលាស់ចោលកប្បៈគឺទិដ្ឋិហើយ ព្រោះលះបង់កប្បៈគឺតណ្ហា ព្រោះរលាស់ចោលកប្បៈគឺទិដ្ឋិ ទើបលោកមិនដល់ មិនចូលទៅជិតដល់ មិនចូលទៅរក មិនប្រកាន់ មិនស្ទាបអង្អែល មិនប្រកាន់ស្អិត នូវកប្បៈគឺតណ្ហា ឬកប្បៈគឺទិដ្ឋិ ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកមិនមានកប្បៈ ។ ពាក្យថា កប្បៈ ក្នុងបទថា ជាអ្នកមិនមានកប្បៈ បានដល់ កប្បៈ ២ គឺ កប្បៈគឺតណ្ហា ១ កប្បៈគឺទិដ្ឋិ ១ ។ បេ ។ នេះកប្បៈគឺតណ្ហា ។ បេ ។ នេះ កប្បៈគឺទិដ្ឋិ ។ មុនិនោះ លះបង់កប្បៈគឺតណ្ហា រលាស់ចោលកប្បៈគឺទិដ្ឋិហើយ ព្រោះលោកលះបង់កប្បៈគឺតណ្ហា ព្រោះលោករលាស់ចោលកប្បៈគឺទិដ្ឋិ ទើបលោកមិនឲ្យសម្រេច មិនឲ្យកើត មិនឲ្យកើតព្រម មិនបង្កើត មិនបង្កើតបំពោះ នូវកប្បៈគឺតណ្ហា ឬកប្បៈគឺទិដ្ឋិ ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកមិនមានកប្បៈ មិនដល់នូវកប្បៈ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលជាអ្នកប្រាសចាកសេចក្តីប្រាថ្នា ជាអ្នកមិនមានសេចក្តី
កំណាញ់ ជាមុនិ មិនពោល ក្នុងហេតុដ៏ខ្ពស់ទេ មិន
ពោលក្នុងហេតុដ៏ស្មើទេ មិនពោលក្នុងហេតុដ៏ថោកទាបទេ
ជាអ្នកមិនមានកប្បៈ មិនដល់នូវកប្បៈ ។

## ទសមោ បុរាភេទសុត្តនិទ្ទេសោ

(១១៧) យស្ស លោកេ សកំ នត្ថិ អសតា ច ន សោចតិ
ធម្មេសុ ច ន គច្ឆតិ ស វេ សន្តោតិ វុច្ចតិ ។

(១១៨) យស្ស លោកេ សកំ នត្ថីតិ យស្សាតិ អរហតោ ខីណាសវស្ស ។ សកំ នត្ថីតិ យស្ស មយ្ហំ វា ឥទំ បរេសំ វា ឥទន្តិ កិញ្ចិ រូបគតំ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ គហិតំ បរាមដ្ឋំ អភិនិវិដ្ឋំ អជ្ឈោសិតំ អធិមុត្តំ នត្ថិ ។ បេ ។ ញាណគ្គិនា ទឌ្ឍន្តិ យស្ស លោកេ សកំ នត្ថិ ។

(១១៩) អសតា ច ន សោចតីតិ វិបរិណតំ វា វត្ថុំ ន សោចតិ វិបរិណតស្មឹ វា វត្ថុស្មឹ ន សោចតិ ចក្ខុ មេ វិបរិណតន្តិ ន សោចតិ សោតំ មេ ឃានំ មេ ជិវ្ហា

## បុរាភេទសុត្តនិទ្ទេស ទី ១០

(១១៧) ការហួងហែងថាជារបស់ខ្លួន ក្នុងលោក នៃបុគ្គលណា
មិនមាន បុគ្គលណា មិនសោកស្ដាយ ព្រោះវត្ថុដែលមិន
មានផង មិនលុះក្នុងធម៌ទាំងឡាយផង បុគ្គលនោះឯង
លោកហៅថា អ្នកស្ងប់ ។

(១១៨) ពាក្យថា ការហួងហែងថាជារបស់ខ្លួនក្នុងលោក នៃបុគ្គលណាមិនមាន ត្រង់ពាក្យថា នៃបុគ្គលណា គឺនៃព្រះអរហន្តខីណាស្រព ។ ពាក្យថា ការហួងហែងថាជារបស់ខ្លួនមិនមាន សេចក្ដីថា វត្ថុណាមួយ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលបុគ្គលកួចកាន់ ស្ទាប អង្អែល ប្រកាន់មាំ ចុះចិត្តស៊ប់ បង្អោនទៅថា នេះរបស់អញ ឬនេះរបស់ពួកជនដទៃដូច្នេះ នៃបុគ្គលណា មិនមាន ។ បេ ។ ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ការហួងហែងថាជារបស់ខ្លួនក្នុងលោក នៃបុគ្គលណា មិនមាន ។

(១១៩) អធិប្បាយពាក្យថា មិនសោកស្ដាយ ព្រោះវត្ថុដែលមិនមានផង គឺមិនសោកនឹងវត្ថុដែលប្រែប្រួលហើយ ឬមិនសោកក្នុងវត្ថុដែលប្រែប្រួលហើយ គឺមិនសោកថា ភ្នែករបស់អញប្រែប្រួលហើយ មិនសោកស្ដាយ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងកន្ទក់កន្ទេញ មិនដល់នូវសេចក្ដីវង្វេងថា ត្រចៀករបស់អញ ច្រមុះរបស់អញ អណ្ដាតរបស់អញ

មេ កាយោ មេ មនោ មេ រូបា មេ សទ្ទា មេ គន្ធា មេ រសា មេ ផោដ្ឋព្វា មេ កុលំ មេ គណោ មេ អាវាសោ មេ លាភោ មេ យសោ មេ បសំសា មេ សុខំ មេ ចីវរំ មេ បិណ្ឌបាតោ មេ សេនាសនំ មេ គិលានប្បច្ចយភេសជ្ជបរិក្ខារោ មេ មាតា មេ បិតា មេ ភាតា មេ ភគិនី មេ បុត្តោ មេ ធីតា មេ មិត្តា មេ អមច្ចា មេ ញាតកា មេ សាលោហិតា មេ វិបរិណាមតិ ច សោចតិ ច កិលមតិ ច បរិទេវតិ ច ឧរត្តាឡិំ កន្ទតិ ច សម្មោហំ អាបជ្ជតីតិ ឯវម្បិ អសតា ច ច សោចតិ ។ អថវា អសាតាយ(១) ទុក្ខាយ វេទនាយ ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ ច សោចតិ ច កិលមតិ ច បរិទេវតិ ច ឧរត្តាឡិំ កន្ទតិ ច សម្មោហំ អាបជ្ជតិ ។ ចក្ខុរោគេន ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ ច សោចតិ ច កិលមតិ ច បរិទេវតិ ច ឧរត្តាឡិំ កន្ទតិ ច សម្មោហំ អាបជ្ជតិ ។ សោតរោគេន ឃានរោគេន ជិវ្ហារោគេន កាយរោគេន សីសរោគេន កណ្ណរោគេន មុខរោគេន ទន្តរោគេន

---

១ ម. អសត្តាយ ។ ឱ. អសតាយ ។

កាយ របស់អញ ចិត្ត របស់អញ រូប របស់អញ សំឡៀក របស់អញ ក្លិនរបស់អញ រសរបស់អញ ផ្សព្វរបស់អញ ត្រកូល របស់អញ ពួករបស់អញ អាវាសរបស់អញ លាភរបស់អញ យស របស់អញ សេចក្ដីសរសើររបស់អញ សុខរបស់អញ ចីវររបស់អញ បិណ្ឌបាតរបស់អញ សេនាសនៈរបស់អញ គិលានប្បច្ច័យភេសជ្ជបរិក្ខារ របស់អញ មាតារបសអញ បិតារបស់អញ បងប្អូនប្រុសរបស់អញ បងប្អូនស្រីរបស់អញ កូនប្រុសរបស់អញ កូនស្រីរបស់អញ មិត្តរបស់អញ អាមាត្យរបស់អញ ញាតិរបស់អញ ពួកសាលោហិតរបស់អញ ប្រែប្រួលហើយ ដូច្នេះឡើយ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនសោកស្ដាយ ព្រោះវត្ថុដែលមិនមាន យ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលត្រូវទុក្ខ-វេទនាមិនជាទីត្រេកអរ ប៉ះពាល់ហើយ គ្របសង្កត់ហើយ ប្រជុំព្រមហើយ ប្រកបព្រមហើយ ក៏មិនសោក មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងកន្ទក់កន្ទេញ មិនដល់ នូវសេចក្ដីវង្វេង ។ បុគ្គលត្រូវរោគក្នុងភ្នែក ប៉ះពាល់ហើយ គ្របសង្កត់ហើយ ប្រជុំព្រមហើយ ប្រកបព្រមហើយ ក៏មិនសោក មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងកន្ទក់កន្ទេញ មិនដល់ នូវសេចក្ដីវង្វេង ។ មុគ្គលត្រូវរោគក្នុងត្រចៀក រោគក្នុងច្រមុះ រោគក្នុងអណ្ដាត រោគក្នុងកាយ រោគក្នុងក្បាល រោគត្រង់ស្លឹកត្រចៀក រោគក្នុងមាត់ រោគក្នុងធ្មេញ

## ទសមោ បុរាភេទសុត្តនិទ្ទេសោ

កាសេន សាសេន បិនាសេន ឌាហេន ជរេន កុច្ឆិរោគេន មុច្ឆាយ បក្ខន្ទិកាយ សុលាយ វិសូចិកាយ កុដ្ឋេន គណ្ឌេន កិលាសេន សោសេន អបមារេន ទទ្ទុយា កណ្ឌុយា កច្ឆុយា រខសាយ វិតច្ឆិកាយ លោហិតេន បិត្តេន មធុមេហេន អំសាយ បិឡកាយ ភគន្ទលាយ បិត្តសមុដ្ឋានេហិ អាពាធេហិ សេម្ហសមុដ្ឋានេហិ អាពាធេហិ វាតសមុដ្ឋានេហិ អាពាធេហិ សន្និបាតិកេហិ អាពាធេហិ ឧតុបរិណាមជេហិ អាពាធេហិ វិសមបរិហារជេហិ អាពាធេហិ ឱបក្កមិកេហិ អាពាធេហិ កម្មវិបាកជេហិ អាពាធេហិ(១) សីតេន ឧណ្ហេន ជិឃច្ឆាយ បិបាសាយ ឧច្ចារេន បស្សាវេន ឌំសមកសវាតាតបសិរឹសបសម្ផស្សេហិ ផុដ្ឋោ បរេតោ សមោហិតោ សមន្នាគតោ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតីតិ ឃរម្បិ អសតា ច ន សោចតិ ។ អថវា អសន្តេ អសំវិជ្ជមានេ អនុបលព្ភិយមានេ អហោ វត មេ តំ តំ វត មេ នត្ថិ សិយា វត មេ តំ តំ វតាហំ ន លភាមីតិ

១ ម. បិត្តសមុដ្ឋានេន អាពាធេន ។ល។ កម្មវិបាកជេន អាពាធេន ។

បុរាភេទសុត្តនិទ្ទេស ទី ១០

រោគក្អក ហឺត បួសដូងប្រមុះ ក្តៅក្រហាយ ស្គាំងស្គម រោគក្នុងផ្ទៃ វិលមុខ ធ្លាក់ឈាម ចុកសៀត ចុះផ្ទៃ ឃ្លង់ ពក ស្រែង រីងរៃ ឆ្កួតជ្រូក ដំណួចពិស រមាស់ កម រោគកើតក្នុងទ្វារដោយក្របក ឃ្លង់ដែក ឈាម ប្រមាត់ ប្រមេះផ្អែម បួសដូងដុះ បួស បួសដូងបាត អាពាធតាំងឡើងអំពីប្រមាត់ អាពាធតាំងឡើងអំពីស្លេស្ម អាពាធតាំងឡើងអំពីខ្យល់ អាពាធតាំឡើងអំពីធាតុប្រជុំគ្នា អាពាធកើតអំពីរដូវប្រែប្រួល អាពាធកើតអំពីការរក្សាឥរិយាបថមិនស្មើ អាពាធកើតអំពីសេចក្ដីព្យាយាមរបស់គេ មានវាយចងជាដើម អាពាធកើតអំពីផលកម្ម ត្រជាក់ ក្តៅ ឃ្លាន ស្រេក ឧច្ចារៈ បស្សាវៈ សម្ផស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃ ពស់តូច និងពស់ធំ ពាល់ត្រូវហើយ គ្របសង្កត់ហើយ ប្រជុំព្រមហើយ ប្រកបព្រមហើយ ក៏មិនសោក មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងកន្ទក់កន្ទេញ មិនដល់នូវសេចក្ដីវង្វេង ហេតុនោះ (ទ្រង់ត្រាស់ថា) មិនសោកស្ដាយព្រោះវត្ថុដែលមិនមាន យ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលកាលបើវត្ថុមិនមាន មិនមានព្រម ដែលលោកមិនបាន ក៏មិនសោក មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងកន្ទក់កន្ទេញ មិនដល់នូវសេចក្ដីវង្វេងថា អើហ្ន៎ វត្ថុនោះរបស់អញ អើហ្ន៎ វត្ថុនោះអញ មិនមាន ធ្វើម្ដេចហ្ន៎ វត្ថុនោះអញគប្បីមាន អើហ្ន៎ អញមិនបានវត្ថុនោះ

ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតីតិ ឯវម្បិ អសតា ច ន សោចតិ ។

[១២០] ធម្មេសុ ច ន គច្ឆតីតិ ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយាគតឹ គច្ឆតិ ន រាគវសេន គច្ឆតិ ន ទោសវសេន គច្ឆតិ ន មោហវសេន គច្ឆតិ ន មានវសេន គច្ឆតិ ន ទិដ្ឋិវសេន គច្ឆតិ ន ឧទ្ធច្ចវសេន គច្ឆតិ ន វិចិកិច្ឆាវសេន គច្ឆតិ ន អនុសយវសេន គច្ឆតិ ន វគ្គេហិ ធម្មេហិ យាយតិ និយ្យតិ វុយ្ហតិ សំហរិយតីតិ ធម្មេសុ ច ន គច្ឆតិ ។

[១២១] ស វេ សន្តោតិ វុច្ចតីតិ សោ សន្តោ ឧបសន្តោ វូបសន្តោ និព្វុតោ បដិប្បស្សទ្ធោតិ វុច្ចតិ កថិយតិ ភណិយតិ ទីបិយតិ វោហរិយតីតិ ស វេ សន្តោតិ វុច្ចតិ ។ តេនាហ ភគវា

ដូច្នេះឡើយ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនសោកស្តាយ ព្រោះវត្ថុដែលមិនមាន យ៉ាងនេះខ្លះ ។

(១៤០) ពាក្យថា មិនលុះក្នុងធម៌ទាំងឡាយផង គឺមិនលុះឆន្ទាគតិ មិនលុះទោសាគតិ មិនលុះមោហាគតិ មិនលុះភយាគតិ មិនលុះដោយអំណាចរាគៈ មិនលុះដោយអំណាចទោសៈ មិនលុះដោយអំណាចមោហៈ មិនលុះដោយអំណាចមានះ មិនលុះដោយអំណាចទិដ្ឋិ មិនលុះដោយអំណាចឧទ្ធច្ចៈ មិនលុះដោយអំណាចវិចិកិច្ឆា មិនលុះដោយអំណាចអនុស័យ មិនត្រូវធម៌ជាពួកដឹកនាំទៅ មិននាំចេញ មិនបន្សាត់ មិនប្រមូល ហេតុនោះ (ទ្រង់ត្រាស់ថា) មិនលុះក្នុងធម៌ទាំងឡាយ ។

(១៤១) ពាក្យថា បុគ្គលនោះឯង លោកហៅថា អ្នកស្ងប់ គឺបុគ្គលនោះ លោកហៅ លោកសំដែង លោកពណ៌នា លោកបំភ្លឺ លោកថ្លែងថា ជាអ្នកស្ងប់ អ្នកស្ងប់រម្ងាប់ អ្នកស្ងប់ស្ងាត់ អ្នកមានទុក្ខរលត់ អ្នកស្ងួតស្ងប់ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះឯង លោកហៅថា អ្នកស្ងប់ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ទសមោ បុរាភេទសុត្តនិទ្ទេសោ

យស្ស លោកេ សកំ នត្ថិ អសតា ច ន សោចតិ

ធម្មេសុ ច ន គច្ឆតិ ស វេ សន្តោតិ វុច្ចតីតិ ៗ

ទសមោ បុរាភេទសុត្តនិទ្ទេសោ និដ្ឋិតោ ។

## បុរាភេទសុត្តនិទ្ទេស ទី ១០

ការហួងហែងថាជារបស់ខ្លួន ក្នុងលោក នៃបុគ្គលណា មិនមាន បុគ្គលណា មិនសោកស្តាយ ព្រោះវត្ថុដែលមិនមានផង មិនលុះក្នុងធម៌ទាំងឡាយផង បុគ្គលនោះឯង លោកហៅថា អ្នកស្ងប់ ។

ចប់ បុរាភេទសុត្តនិទ្ទេស ទី ១០ ។

# ឯកាទសមោ កលហវិវាទសុត្តនិទ្ទេសោ

(១៦២) កុតោ បហូតា កលហា វិវាទា
បរិទេវសោកា សហមច្ឆរា ច
មានាតិមានា សហបេសុណា ច
កុតោ បហូតា តេ តទិង្ឃ ព្រូហិ ។

(១៦៣) កុតោ បហូតា កលហា វិវាទាតិ កល-ហោតិ ឯកេន អាការេន កលហោបិ វិវាទោបិ តញ្ញេវ យោ កលហោ សោ វិវាទោ យោ វិវាទោ សោ កលហោ ។ អថវា អបរេន អាការេន វិវាទោ វុច្ចតិ កលហស្ស បុព្វភាគោ វិវាទោ ។ រាជានោបិ រាជូហិ វិវទន្តិ ខត្តិយាបិ ខត្តិយេហិ វិវទន្តិ ព្រាហ្មណាបិ ព្រាហ្មណេហិ វិវទន្តិ គហបតីបិ គហបតីហិ វិវទន្តិ មាតាបិ បុត្តេន វិវទតិ បុត្តោបិ មាតរា វិវទតិ បិតាបិ បុត្តេន វិវទតិ បុត្តោបិ បិតរា វិវទតិ ភាតាបិ ភាតរា វិវទតិ ភគិនីបិ ភគិនិយា វិវទតិ ភាតាបិ ភគិនិយា វិវទតិ ភគិនីបិ ភាតរា វិវទតិ សហាយោបិ សហា-យេន វិវទតិ អយំ វិវាទោ ។ កតមោ កលហោ ។

# កលហវិវាទសុត្តនិទ្ទេស ទី ១១

(១៦៦) (ព្រះពុទ្ធនិម្មិតត្រាស់សួរថា) ជំលោះ វិវាទ សេចក្តីខ្សឹកខ្សួល សេចក្តីសោក ព្រមទាំងសេចក្តីកំណាញ់ មានះ នឹងអតិមានះ ព្រម ទាំងការញុះញង់ កើតអំពីណា កិលេសទាំងនោះ កើតអំពីណា សូមព្រះអង្គសំដែងសេចក្តី ដែលខ្ញុំសួរនោះ ។

(១៦៧) អធិប្បាយពាក្យថា ជំលោះ វិវាទ កើតអំពីណា ត្រង់ពាក្យថា ជំលោះ សេចក្តីថា ជំលោះក្តី វិវាទក្តី ដូចគ្នាដោយអាការតែមួយ ជំលោះណា ជំលោះនោះ ឈ្មោះថាវិវាទ វិវាទណា វិវាទនោះឈ្មោះថាជំលោះ ។ម្យ៉ាងទៀត ដោយអាការផ្សេងគ្នា វិវាទជាបុព្វភាគនៃជំលោះ លោកហៅថា វិវាទ ។ ពួកព្រះរាជាជជែកនឹងពួកព្រះរាជាពួកខត្តិយៈជជែកនឹងពួកខត្តិយៈ ពួកព្រាហ្មណ៍ជជែកនឹងពួកព្រាហ្មណ៍ពួកគហបតីជជែកនឹងពួកគហបតី មាតាជជែកនឹងបុត្រ បុត្រជជែកនឹងមាតា បិតាជជែកនឹងបុត្រ បុត្រជជែកនឹងបិតា បងប្អូនប្រុសជជែកនឹងបងប្អូនប្រុស បងប្អូនស្រីជជែកនឹងបងប្អូនស្រី បងប្អូនប្រុសជជែកនឹងបងប្អូនស្រី បងប្អូនស្រីជជែកនឹងបងប្អូនប្រុស សំឡាញ់ជជែកនឹងសំឡាញ់ នេះ ហៅថា វិវាទ ។ ជំលោះ តើដូចម្តេច ។

## ឯកាទសមោ កលហវិវាទសុត្តនិទ្ទេសោ

អាគារិកា ទណ្ឌបសុតា កាយេន វាចាយ កលហំ ករោន្តិ បព្វជិតា អាបត្តឹ អាបជ្ជន្តា កាយេន វាចាយ កលហំ ករោន្តិ អយំ កលហោ ។ កុតោ បហូតា កលហា វិវាទាតិ កលហា ច វិវាទា ច កុតោ បហូតា កុតោ ជាតា កុតោ សញ្ជាតា កុតោ និព្វត្តា កុតោ អភិនិព្វត្តា កុតោ បាតុភូតា កឹនិទានា កឹសមុទយា កឹជាតិកា កឹបភវាតិ កលហស្ស ច មូលំ វិវាទស្ស ច មូលំ បុច្ឆតិ ហេតុំ បុច្ឆតិ និទានំ បុច្ឆតិ សម្ភវំ បុច្ឆតិ បភវំ បុច្ឆតិ សមុដ្ឋានំ បុច្ឆតិ អាហារំ បុច្ឆតិ អារម្មណំ បុច្ឆតិ បច្ចយំ បុច្ឆតិ សមុទយំ បុច្ឆតិ បបុច្ឆតិ យាចតិ អជ្ឈេសតិ បសាទេតីតិ កុតោ បហូតា កលហា វិវាទា ។

(១២៤) បរិទេវសោកា សហមច្ឆរា ចាតិ បរិទេវោតិ ញាតិព្យសនេន វា ផុដ្ឋស្ស ភោគព្យសនេន វា ផុដ្ឋស្ស រោគព្យសនេន វា ផុដ្ឋស្ស សីលព្យសនេន វា ផុដ្ឋស្ស ទិដ្ឋិព្យសនេន វា ផុដ្ឋស្ស

កលហវិវាទសុត្តនិទ្ទេស ទី ១០

ពួកគ្រហស្ថ ជាអ្នកខ្វល់ខ្វាយ ក្នុងការស្វែងរកទោស តែងធ្វើជំលោះ ដោយកាយវាចា ពួកបព្វជិតកាលត្រូវអាបត្តិ ក៏ធ្វើជំលោះ ដោយកាយវាចា នេះ ហៅថា ជំលោះ ។ ពាក្យថា ជំលោះ វិវាទ កើតអំពីណា គឺពុទ្ធនិម្មិត សួរមូល សួរហេតុ សួរនិទាន សួរការកើតព្រម សួរការផ្តើមកើត សួរសមុដ្ឋាន សួរអាហារ សួរអារម្មណ៍ សួរបច្ច័យ សួរសមុទ័យ សួរឈ្លប-ឈ្លី អង្វរ អារាធនា ចោទ នូវសមុទ័យ នៃជំលោះនឹងវិវាទថា ជំលោះ វិវាទ កើតអំពីណា កអំពីណា កើតព្រមអំពីណា ដុះអំពីណា ដុះដាល អំពីណា កើតប្រាកដអំពីណា មានអ្វីជានិទាន មានអ្វីជាសមុទ័យ មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ហេតុនោះ (ត្រាស់សួរថា) ជំលោះ វិវាទ កើតអំពីណា ។

(១៦៤) អធិប្បាយពាក្យថា សេចក្តីខ្សឹកខ្សួល សេចក្តីសោក ព្រមទាំងសេចក្តីកំណាញ់ ត្រង់ពាក្យថា សេចក្តីខ្សឹកខ្សួល គឺការយំ ការខ្សឹកខ្សួល អាការយំ អាការខ្សឹកខ្សួល ភាពនៃការយំ ភាពនៃការខ្សឹកខ្សួល សំដី ការពោល ការពោលផ្សេង ៗ ការពោលរវើរវាយ អាការពោលរវើរវាយ ភាពនៃការពោលរវើរវាយ នៃបុគ្គល ដែលត្រូវសេចក្តីវិនាសញាតិប៉ះពាល់ក្តី សេចក្តីវិនាសភោគៈប៉ះពាល់ក្តី សេចក្តីវិនាសគឺរោគប៉ះពាល់ក្តី សេចក្តីវិនាសសីលប៉ះពាល់ក្តី សេចក្តីវិនាសទិដ្ឋិប៉ះពាល់ក្តី

អញ្ញតរញ្ញតរេន វា ព្យសនេន សមន្នាគតស្ស អញ្ញត-
រញ្ញតរេន វា ទុក្ខធម្មេន ផុដ្ឋស្ស អាទេវោ បរិទេវោ
អាទេវនា បរិទេវនា អាទេវិតត្តំ បរិទេវិតត្តំ វាចា បលាបោ
វិប្បលាបោ លាលប្បោ លាលប្បាយនា លាលប្បាយិ-
តត្តំ ។ សោកោតិ ញាតិព្យសនេន វា ផុដ្ឋស្ស ភោគ-
ព្យសនេន វា ផុដ្ឋស្ស រោគព្យសនេន វា ផុដ្ឋស្ស សីល-
ព្យសនេន វា ផុដ្ឋស្ស ទិដ្ឋិព្យសនេន វា ផុដ្ឋស្ស
អញ្ញតរញ្ញតរេន វា ព្យសនេន សមន្នាគតស្ស
អញ្ញតរញ្ញតរេន វា ទុក្ខធម្មេន ផុដ្ឋស្ស សោកោ
សោចនា សោចិតត្តំ អន្តោសោកោ អន្តោបរិសោកោ
អន្តោឌាហោ អន្តោបរិឌាហោ ចេតសោ បរិជ្ឈាយនា
ទោមនស្សំ សោកសល្លំ ។ មច្ឆរិយន្តិ បញ្ច មច្ឆរិយានិ
អាវាសមច្ឆរិយំ កុលមច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ
ធម្មមច្ឆរិយំ យំ ឯវរូបំ មច្ឆរិយំ មច្ឆរាយនា មច្ឆរាយិតត្តំ
វេវិច្ឆំ កទរិយំ កដុកញ្ចុកតា អគ្គហិតត្តំ ចិត្តស្ស ឥទំ
វុច្ចតិ មច្ឆរិយំ ។ អបិច ខន្ធមច្ឆរិយម្បិ មច្ឆរិយំ ធាតុមច្ឆរិ-
យម្បិ មច្ឆរិយំ អាយតនមច្ឆរិយម្បិ មច្ឆរិយំ គាហោ
ឥទំ វុច្ចតិ មច្ឆរិយន្តិ បរិទេវសោកា សហមច្ឆរា ច ។

ដែលប្រកបដោយសេចក្តីវិនាសណាមួយក្តី ទុក្ខធម៌ណាមួយប៉ះពាល់ក្តី ។ ពាក្យថា សោក គឺសោក អាការសោក ភាពនៃសោក ការស្ងួតខាងក្នុង ការក្រៀមក្រំខាងក្នុង ការក្តៅខាងក្នុង ការក្តួលក្តៅខាងក្នុង អាការដុតពេលចិត្ត ទោមនស្ស សរគឺសោក នៃបុគ្គលដែលត្រូវសេចក្តីវិនាសញាតិប៉ះពាល់ក្តី ត្រូវវិនាសភោគៈប៉ះពាល់ក្តី ត្រូវវិនាសគឺរោគប៉ះពាល់ក្តី ត្រូវវិនាសសីលប៉ះពាល់ក្តី ត្រូវវិនាសទិដ្ឋិប៉ះពាល់ក្តី ដែលប្រកបដោយសេចក្តីវិនាសណាមួយក្តី ត្រូវទុក្ខធម៌ណាមួយប៉ះពាល់ក្តី ។ ពាក្យថា សេចក្តីកំណាញ់ បានដល់សេចក្តីកំណាញ់ ៥ គឺ កំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់វណ្ណៈ ១ កំណាញ់ធម៌ ១ សេចក្តីកំណាញ់ អាការនៃសេចក្តីកំណាញ់ ភាពនៃសេចក្តីកំណាញ់ ការប្រាថ្នាខុស ភាពនៃចិត្តស្វិតស្វាញ ភាពនៃចិត្តរួញ ភាពមិនយកចិត្តនៃបុគ្គលដទៃ ឯណាមានសភាពយ៉ាងនេះ នេះហៅថា ការកំណាញ់ ។ មួយទៀត ការកំណាញ់ខន្ធ ក៏ហៅថា កំណាញ់ ការកំណាញ់ធាតុ ក៏ហៅថាកំណាញ់ ការកំណាញ់អាយតនៈ ក៏ហៅថាកំណាញ់ សេចក្តីប្រកាន់ នេះហៅថា ការកំណាញ់ ហេតុនោះ (ទ្រង់ត្រាស់សួរថា) សេចក្តីខ្សឹកខ្សួល សេចក្តីសោក ព្រមទាំងសេចក្តីកំណាញ់ទាំងឡាយ ។

ឯកាទសមោ កលហវិវាទសុត្តនិទ្ទេសោ

[១២៨] មានាតិមានា សហាបេសុណា ចាតិ មានោតិ ឥធេកច្ចោ មានំ ជនេតិ ជាតិយា វា គោត្តេន វា កោលបុត្តិយេន វា វណ្ណបោក្ខរតាយ វា ធនេន វា អជ្ឈេនេន វា កម្មាយតនេន វា សិប្បាយតនេន វា វិជ្ជដ្ឋានេន វា សុតេន វា បដិភានេន វា អញ្ញតរញ្ញតរេន វា វត្ថុនា ។ អតិមានោតិ ឥធេកច្ចោ អញ្ញំ(១) អតិមញ្ញតិ ជាតិយា វា គោត្តេន វា ។បេ។ អញ្ញតរញ្ញតរេន វា វត្ថុនា ។ បេសុញ្ញន្តិ ឥធេកច្ចោ បិសុណវាចោ ហោតិ ឥតោ សុត្វា អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ឥមេសំ អក្ខាតា អមូសំ ភេទាយ ឥតិ សមគ្គានំ វា ភេត្តា(២) ភិន្នានំ វា អនុប្បទាតា វគ្គារាមោ វគ្គរតោ វគ្គនន្ទី វគ្គករណឹ វាចំ ភាសិតា ហោតិ ឥទំ វុច្ចតិ បេសុញ្ញំ ។ អបិច ទ្វីហិ ការណេហិ បេសុញ្ញំ ឧបសំហរតិ បិយកម្យតាយ វា ភេទាធិប្បាយោ វា ។

---

១ ម. បរំ ។ ២ ម. ភេទេ ។

## កលហវិវាទសុត្តនិទ្ទេស ទី ១១

(១២៥) អធិប្បាយពាក្យថា មានះនឹងអតិមានះ ព្រមទាំងការញុះញង់ទាំងឡាយ ត្រង់ពាក្យថា មានះ សេចក្តីថា បុគ្គលខ្លះក្នុងលោកនេះ ញុំាងមានះឲ្យកើត ដោយជាតិក្តី ដោយគោត្រក្តី ដោយភាពនៃខ្លួនជាកូនអ្នកមានត្រកូលក្តី ដោយភាពជាអ្នកមានពណ៌សម្បុរល្អក្តី ដោយទ្រព្យក្តី ដោយការរៀនមន្តក្តី ដោយការងារក្តី ដោយសិប្បៈក្តី ដោយថ្នាក់នៃវិជ្ជាក្តី ដោយសុតៈក្តី ដោយបដិភាណក្តី ដោយវត្ថុណាមួយក្តី ៗ ពាក្យថា អតិមានះ សេចក្តីថា បុគ្គលខ្លះក្នុងលោកនេះ មើលងាយបុគ្គលដទៃ ដោយជាតិក្តី ដោយគោត្រក្តី ។ បេ ។ ដោយវត្ថុណាមួយក្តី ៗ ពាក្យថា ការញុះញង់ សេចក្តីថា បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានសំដីញុះញង់ គឺឮអំពីពួកជនឯណោះហើយ ប្រាប់ពួកជនឯណោះ ដើម្បីបំបែកពួកជនឯនេះ ឬឮអំពីពួកជនឯណោះហើយ ប្រាប់ពួកជនឯនេះ ដើម្បីបំបែកពួកជនឯណោះ ជាអ្នកបំបែកពួកជនដែលព្រមព្រៀងគ្នាហើយផង ជាអ្នកបន្ថែមកំឡាំងដល់ពួកជនបែកបាក់គ្នាហើយផង ជាអ្នកមានពួកជាទីត្រេកអរ ត្រេកអរក្នុងពួក រីករាយក្នុងពួក ពោលវាចាដែលធ្វើឲ្យជាពួក នេះលោកហៅថា ការញុះញង់ ៗ មួយទៀត ជនបង្កការញុះញង់ដោយហេតុ ២ គឺ ដោយសេចក្តីប្រាថ្នាឲ្យគាប់ ឬ មានសេចក្តីប្រាថ្នានឹងបំបែក ៗ

កថំ បិយកាម្យតាយ បេសុញ្ញំ ឧបសំហរតិ ។ ឥមស្ស បិយោ ភវិស្សាមិ មនាបោ ភវិស្សាមិ វិស្សាសិកោ ភវិស្សាមិ អព្ភន្តរិកោ ភវិស្សាមិ សុហទយោ ភវិស្សាមីតិ ឯវំ បិយកាម្យតាយ បេសុញ្ញំ ឧបសំហរតិ ។ កថំ ភេទាធិប្បាយោ បេសុញ្ញំ ឧបសំហរតិ ។ កថំ ឥមេ នានា អស្សុ វិនា អស្សុ វគ្គា អស្សុ ទ្វេធា អស្សុ ទ្វេជ្ឈា អស្សុ ទ្វេបក្ខា អស្សុ ភិជ្ជេយ្យុំ ន សមាគច្ឆេយ្យុំ ទុក្ខំ ន ផាសុ វិហរេយ្យុន្តិ ឯវំ ភេទាធិប្បាយោ បេសុញ្ញំ ឧបសំហរតីតិ មានាតិមានា សហា បេសុណា ច ។

ជនបង្កការញុះញង់ ដោយសេចក្តីប្រាថ្នាឲ្យគាប់ តើដូចម្តេច ។ ជនបង្កការញុះញង់ ដោយសេចក្តីប្រាថ្នាដើម្បីឲ្យគាប់ យ៉ាងនេះថា អាត្មាអញ់ នឹងជាទីស្រឡាញ់ ជាទីគាប់ចិត្ត ជាអ្នកសិទ្ធសាល ជាអ្នកនៅខាងក្នុង ជាអ្នកមានចិត្តល្អ នៃជននេះ ។

ជនជាអ្នកមានសេចក្តីប្រាថ្នាដើម្បីបំបែក ទើបបង្កការញុះញង់ តើដូចម្តេច ។ ជនមានសេចក្តីប្រាថ្នាដើម្បីបំបែក ទើបបង្កការញុះញង់យ៉ាងនេះថា ធ្វើម្តេចហ្ន៎ ជនទាំងនេះគប្បីផ្សេងៗគ្នា គប្បីប្រាសចាកគ្នា ទៅជាពួក ទៅជាបំណែកពីរ ទៅជាមានអធ្យាស្រ័យពីរ ទៅជាពីរពួក គប្បីបែកគ្នា មិនគប្បីព្រមព្រៀងគ្នា គប្បីនៅជាទុក្ខ មិនសប្បាយ ហេតុនោះ (ទ្រង់ត្រាស់សួរថា) មានះនឹងអតិមានះ ព្រមទាំងការញុះញង់ ។

## ឯកាទសមោ កលហវិវាទសុត្តនិទ្ទេសោ

(១២៦) កុតោ បហូតា តេ តទិង្ឃ ព្រូហីតិ កលហោ ច វិវាទោ ច បរិទេវោ ច សោកោ ច មច្ឆរិយញ្ច មានោ ច អតិមានោ ច បេសុញ្ញញ្ច(១) ឥមេ អដ្ឋ កិលេសា កុតោ បហូតា កុតោ ជាតា កុតោ សញ្ជាតា កុតោ និព្វត្តា កុតោ អភិនិព្វត្តា កុតោ បាតុភូតា កឹនិទានា កឹសមុទយា កឹជាតិកា កឹបភវាតិ ឥមេសំ អដ្ឋន្នំ កិលេសានំ មូលំ បុច្ឆតិ ហេតុំ បុច្ឆតិ និទានំ បុច្ឆតិ សម្ភវំ បុច្ឆតិ បភវំ បុច្ឆតិ សមុដ្ឋានំ បុច្ឆតិ អាហារំ បុច្ឆតិ អារម្មណំ បុច្ឆតិ បច្ចយំ បុច្ឆតិ សមុទយំ បុច្ឆតិ បបុច្ឆតិ យាចតិ អជ្ឈេសតិ បសាទេតីតិ កុតោ បហូតា តេ ។ តទិង្ឃ ព្រូហីតិ ឥង្ឃ ព្រូហិ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរ វិភជ ឧត្តានីករោហិ បកាសេហីតិ កុតោ បហូតា តេ តទិង្ឃ ព្រូហិ ។ តេនាហ សោ និម្មិតោ

---

១ ម. បេសុញ្ញញ្ចាតិ ។

កលហវិវាទសុត្តនិទ្ទេស ទី ១១

(១២៦) ពាក្យថា កិលេសទាំងនោះ កើតអំពីទីណា សូមព្រះអង្គទ្រង់សំដែងសេចក្តីដែលខ្ញុំសួរនោះ គឺពុទ្ធនិមិត្តនោះ សួរមូល សួរហេតុ សួរនិទាន សួរការកើត សួរហេតុជាដែនកើតមុន សួរសមុដ្ឋាន សួរអាហារ សួរអារម្មណ៍ សួរបច្ច័យ សួរ សួរឈ្មោះឈ្មី អង្វរ អារាធនា ទោទ ទូវសមុទ័យ នៃកិលេសទាំង៨នេះថា កិលេសទាំង៨នេះ គឺ ជំលោះ១ វិវាទ១ ការខ្សឹកខ្សួល១ សេចក្តីសោក១ សេចក្តីកំណាញ់១ មានះ១ អតិមានះ១ ការញុះញង់១ កើតអំពីណា កអំពីណា កើតព្រមអំពីណា ដុះអំពីណា ដុះដាលអំពីណា កើតប្រាកដអំពីណា មានអ្វីជានិទាន មានអ្វីជាសមុទ័យ កើតអំពីអ្វី មានអ្វីជាដែនកើតមុន ហេតុនោះ (ទ្រង់ត្រាស់សួរថា) កិលេសទាំងនោះ កើតអំពីណា ។ ពាក្យថា សូមព្រះអង្គទ្រង់សំដែងសេចក្តីដែលខ្ញុំសួរនោះ គឺសូមព្រះអង្គពោល ប្រាប់ សំដែង បញ្ញត្ត តំកល់ទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ (ទ្រង់ត្រាស់សួរថា) កិលេសទាំងនោះ កើតអំពីណា សូមព្រះអង្គទ្រង់សំដែងសេចក្តីដែលខ្ញុំសួរនោះ ។ ហេតុនោះ ព្រះពុទ្ធនិម្មិតនោះ ត្រាស់សួរថា

កុតោ បហូតា កលហា វិវាទា
បរិទេវសោកា សហមច្ឆរា ច
មានាតិមានា សហបេសុណា ច
កុតោ បហូតា តេ តទិង្ឃ ព្រូហីតិ ។

(១៤៧) បិយប្បហូតា កលហា វិវាទា
បរិទេវសោកា សហមច្ឆរា ច
មានាតិមានា សហបេសុណា ច
មច្ឆេរយុត្តា កលហា វិវាទា
វិវាទជាតេសុ ច បេសុណានិ ។

(១៤៨) បិយប្បហូតា កលហា វិវាទា បរិទេវសោកា សហមច្ឆរា ចាតិ បិយាតិ ទ្វេ បិយា សត្តា វា សង្ខារា វា ។

កតមេ សត្តា បិយា ។ ឥធ យស្ស តេ ហោន្តិ អត្ថកាមា ហិតកាមា ផាសុកាមា យោគក្ខេមកាមា មាតា វា បិតា វា ភាតា វា ភគិនី វា បុត្តា វា ធីតា វា មិត្តា វា អមច្ចា វា ញាតី វា សាលោហិតា វា ឥមេ សត្តា បិយា ។

ជំលោះ វិវាទ សេចក្ដីខ្សឹកខ្សួល សេចក្ដីសោក ព្រមទាំងសេចក្ដីកំណាញ់ មានះ នឹងអតិមានះ ព្រមទាំងពាក្យញុះញង់ កើតអំពីណា កិលេសទាំងនោះ កើតអំពីណា សូមព្រះអង្គសំដែងសេចក្ដីដែលខ្ញុំសួរនោះ ។

(១៦៧) (ព្រះមានព្រះភាគ ត្រាស់ថា) ជំលោះ វិវាទ សេចក្ដីខ្សឹកខ្សួល សេចក្ដីសោក ព្រមទាំងសេចក្ដីកំណាញ់ មានះនឹងអតិមានះ ព្រមទាំងការញុះញង់ កើតអំពីសភាវៈជាទីស្រឡាញ់ (មួយទៀត) ជំលោះ វិវាទ (ជាដើម) កើតក្នុងសេចក្ដីកំណាញ់ កាលបើវិវាទកើតហើយ ជនទាំងឡាយ (ក៏បង្ក) នូវការញុះញង់ ។

(១៦៨) អធិប្បាយពាក្យថា ជំលោះ វិវាទ សេចក្ដីខ្សឹកខ្សួល សេចក្ដីសោក ព្រមទាំងសេចក្ដីកំណាញ់ កើតអំពីសភាវៈជាទីស្រឡាញ់ ត្រង់ពាក្យថា សភាវៈជាទីស្រឡាញ់ បានដល់ សភាវៈជាទីស្រឡាញ់២ គឺ ពួកសត្វ ឬពួកសង្ខារ ។

ពួកសត្វជាទីស្រឡាញ់ តើដូចម្ដេច ។ ក្នុងលោកនេះ ជនទាំងនោះ គឺមាតាក្ដី បិតាក្ដី បងប្អូនប្រុសក្ដី បងប្អូនស្រីក្ដី កូនប្រុសក្ដី កូនស្រីក្ដី មិត្រក្ដី អាមាត្យក្ដី ញាតិក្ដី សាលោហិតក្ដី ជាអ្នកប្រាថ្នាសេចក្ដីចំរើន ប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្ដីសប្បាយ ប្រាថ្នាសេចក្ដីក្សេមក្សាន្តចាកយោគៈ ដល់បុគ្គលនោះ នេះ ពួកសត្វជាទីស្រឡាញ់ ។

ឯកាទសមោ កលហវិវាទសុត្តនិទ្ទេសោ

កតមេ សង្ខារា បិយា ។ មនាបិកា រូបា មនាបិកា សទ្ទា មនាបិកា គន្ធា មនាបិកា រសា មនាបិកា ផោដ្ឋព្វា ឥមេ សង្ខារា បិយា ។

បិយវត្ថុអច្ឆេទសង្កិនោបិ កលហំ ករោន្តិ អច្ឆិជ្ជន្តេបិ កលហំ ករោន្តិ អច្ឆិន្នេបិ កលហំ ករោន្តិ ។ បិយវត្ថុវិបរិណាមសង្កិនោបិ កលហំ ករោន្តិ វិបរិណាមន្តេបិ កលហំ ករោន្តិ វិបរិណតេបិ កលហំ ករោន្តិ ។ បិយវត្ថុអច្ឆេទសង្កិនោបិ វិវទន្តិ អច្ឆិជ្ជន្តេបិ វិវទន្តិ អច្ឆិន្នេបិ វិវទន្តិ ។ បិយវត្ថុវិបរិណាមសង្កិនោបិ វិវទន្តិ វិបរិណាមន្តេបិ វិវទន្តិ វិបរិណតេបិ វិវទន្តិ ។ បិយវត្ថុអច្ឆេទសង្កិនោបិ បរិទេវន្តិ អច្ឆិជ្ជន្តេបិ បរិទេវន្តិ អច្ឆិន្នេបិ បរិទេវន្តិ ។ បិយវត្ថុវិបរិណាមសង្កិនោបិ បរិទេវន្តិ វិបរិណាមន្តេបិ បរិទេវន្តិ វិបរិណតេបិ បរិទេវន្តិ ។

ពួកសង្ខារជាទីស្រឡាញ់ តើដូចម្តេច ។ រូបជាទីគាប់ចិត្ត សំឡេងជាទីគាប់ចិត្ត ក្លិនជាទីគាប់ចិត្ត រសជាទីគាប់ចិត្ត ផោដ្ឋព្វៈជាទីគាប់ចិត្ត នេះពួកសង្ខារជាទីស្រឡាញ់ ។

ពួកជនមានសេចក្តីរង្កៀស ក្នុងការដណ្តើមយកវត្ថុជាទីស្រឡាញ់ ធ្វើនូវជំលោះក៏មាន កាលបើត្រូវគេកំពុងដណ្តើម ធ្វើនូវជំលោះក៏មាន កាលបើវត្ថុត្រូវគេដណ្តើមហើយ ធ្វើនូវជំលោះក៏មាន ។ មានសេចក្តីរង្កៀសក្នុងការប្រែប្រួលនៃវត្ថុជាទីស្រឡាញ់ ធ្វើនូវជំលោះក៏មាន កាលបើវត្ថុកំពុងប្រែប្រួល ធ្វើនូវជំលោះក៏មាន កាលបើវត្ថុប្រែប្រួលហើយ ធ្វើនូវជំលោះក៏មាន ។ មានសេចក្តីរង្កៀសក្នុងការដណ្តើមយកនូវវត្ថុជាទីស្រឡាញ់ ទាស់ទែងក៏មាន កាលបើត្រូវគេកំពុងដណ្តើម ទាស់ទែងក៏មាន កាលបើវត្ថុត្រូវគេដណ្តើមហើយ ទាស់ទែងក៏មាន ។ សេចក្តីរង្កៀសក្នុងការប្រែប្រួលនៃវត្ថុជាទីស្រឡាញ់ ទាស់ទែងក៏មាន កាលបើវត្ថុកំពុងប្រែប្រួល ទាស់ទែងក៏មាន កាលបើវត្ថុប្រែប្រួលហើយ ទាស់ទែងក៏មាន ។ មានសេចក្តីរង្កៀសក្នុងការដណ្តើមយកវត្ថុជាទីស្រឡាញ់ ខ្សឹកខ្សួលក៏មាន កាលបើគេកំពុងដណ្តើម ខ្សឹកខ្សួលក៏មាន កាលបើវត្ថុត្រូវគេដណ្តើមហើយ ខ្សឹកខ្សួលក៏មាន ។ មានសេចក្តីរង្កៀសក្នុងការប្រែប្រួលនៃវត្ថុជាទីស្រឡាញ់ ខ្សឹកខ្សួលក៏មាន កាលបើវត្ថុកំពុងប្រែប្រួល ខ្សឹកខ្សួលក៏មាន កាលបើវត្ថុប្រែប្រួលហើយ ខ្សឹកខ្សួលក៏មាន ។

បិយវត្ថុអច្ឆេទសង្កិនោបិ សោចន្តិ អច្ឆិជ្ជន្តេបិ សោចន្តិ អច្ឆិន្នេបិ សោចន្តិ ។ បិយវត្ថុវិបរិណាមសង្កិនោបិ សោចន្តិ វិបរិណាមន្តេបិ សោចន្តិ វិបរិណតេបិ សោចន្តិ ។ បិយវត្ថុំ រក្ខន្តិ គោបេន្តិ បរិគ្គណ្ហន្តិ មមាយន្តិ មច្ឆរាយន្តិ ។

(១២៩) មានាតិមានា សហាបេសុណា ចាតិ បិយវត្ថុំ និស្សាយ មានំ ជនេន្តិ បិយវត្ថុំ និស្សាយ អតិមានំ ជនេន្តិ ។

កថំ បិយវត្ថុំ និស្សាយ មានំ ជនេន្តិ ។ មយំ លាភិនោ មនាបិកានំ រូបានំ សទ្ទានំ គន្ធានំ រសានំ ផោដ្ឋព្វានន្តិ ឯវំ បិយវត្ថុំ និស្សាយ មានំ ជនេន្តិ ។

កថំ បិយវត្ថុំ និស្សាយ អតិមានំ ជនេន្តិ ។ មយំ លាភិនោ មនាបិកានំ រូបានំ សទ្ទានំ គន្ធានំ រសានំ ផោដ្ឋព្វានំ ឥមេ បន ន លាភិនោ(១) មនាបិកានំ រូបានំ សទ្ទានំ គន្ធានំ រសានំ ផោដ្ឋព្វានន្តិ ឯវំ បិយវត្ថុំ និស្សាយ អតិមានំ ជនេន្តិ ។

១ ម. ឥមេ បនញ្ញេ ន លាភិនោ ។

មានសេចក្តីរង្កៀសក្នុងការដណ្តើមយកនូវវត្ថុជាទីស្រឡាញ់ សោកក៏មាន កាលបើត្រូវគេកំពុងដណ្តើម សោកក៏មាន កាលបើវត្ថុត្រូវគេដណ្តើមហើយ សោកក៏មាន ។ មានសេចក្តីរង្កៀសក្នុងការប្រែប្រួលនៃវត្ថុជាទីស្រឡាញ់ សោកក៏មាន កាលបើវត្ថុកំពុងប្រែប្រួល សោកក៏មាន កាលបើវត្ថុប្រែប្រួលហើយ សោកក៏មាន ។ ពួកជនតែងតែរក្សា គ្រប់គ្រង ហួងហែង ប្រកាន់ កំណាញ់ នូវវត្ថុជាទីស្រឡាញ់ ។

(១៤៩) ពាក្យថា មានះនឹងអតិមានះ ព្រមទាំងការពោះញង់ សេចក្តីថា ពួកជនអាស្រ័យវត្ថុជាទីស្រឡាញ់ហើយ ញុំាងមានះឲ្យកើត អាស្រ័យវត្ថុជាទីស្រឡាញ់ហើយ ញុំាងអតិមានះឲ្យកើត ។

ពួកជនអាស្រ័យវត្ថុជាទីស្រឡាញ់ហើយ ញុំាងមានះឲ្យកើត តើដូចម្តេច ។ ពួកជនអាស្រ័យវត្ថុជាទីស្រឡាញ់ ហើយញុំាងមានះឲ្យកើតយ៉ាងនេះថា យើងទាំងឡាយ ជាអ្នកបាននូវរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ជាទីពេញចិត្ត ។

ពួកជនអាស្រ័យវត្ថុជាទីស្រឡាញ់ហើយ ញុំាងអតិមានះឲ្យកើត តើដូចម្តេច ។ ពួកជនអាស្រ័យវត្ថុជាទីស្រឡាញ់ ហើយញុំាងអតិមានះឲ្យកើតយ៉ាងនេះថា យើងទាំងឡាយ ជាអ្នកបាននូវរូប សំ-ឡេង ក្លិន រស ផោដ្ឋព្វៈ ជាទីពេញចិត្ត ឯជនទាំងនេះ ជាអ្នកមិនបាននូវរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ជាទីពេញចិត្តទេ ។

បេសុញ្ញន្តិ ឥធេកច្ចោ បិសុណវាចោ ហោតិ ឥតោ សុត្វា អមុត្រ អក្ខាតា ឥមេសំ ភេទាយ ។បេ។ ឯវំ ភេទាធិប្បាយោ បេសុញ្ញំ ឧបសំហរតីតិ ។បេ។ មានាតិមានា សហបេសុណា ច ។

(១៣០) មច្ឆេរយុត្តា កលហា វិវាទាតិ កលហោ ច វិវាទោ ច បរិទេវោ ច សោកោ ច មានោ ច អតិមានោ ច បេសុញ្ញញ្ច ឥមេ សត្ត កិលេសា មច្ឆរិយេ យុត្តា បយុត្តា អាយុត្តា សមាយុត្តាតិ មច្ឆេរយុត្តា កលហា វិវាទា ។

(១៣១) វិវាទជាតេសុ ច បេសុណានីតិ វិវាទេ ជាតេ សញ្ជាតេ និព្វត្តេ អភិនិព្វត្តេ បាតុភូតេ បេសុញ្ញំ ឧបសំហរន្តិ ឥតោ សុត្វា អមុត្រ អក្ខាយន្តិ ឥមេសំ ភេទាយ អមុត្រ វា សុត្វា ឥមេសំ អក្ខាយន្តិ អមូសំ ភេទាយ ឥតិ សមគ្គានំ វា ភេត្តា ភិន្នានំ វា អនុប្បទាតា វគ្គារាមា វគ្គរតា វគ្គនន្ទី វគ្គករណឹ វាចំ ភាសិតា ហោន្តិ ឥទំ វុច្ចតិ បេសុញ្ញំ ។

ពាក្យថា ការញុះញង់ គឺជនពួកខ្លះក្នុងលោកនេះ ជាអ្នកមានសំដីញុះញង់ គឺឮអំពីពួកជនឯណោះហើយ ប្រាប់ពួកជនឯណោះ ដើម្បីបំបែកពួកជននេះ ។ បេ ។ ជនមានសេចក្ដីប្រាថ្នាដើម្បីបំបែក បង្កនូវការញុះញង់យ៉ាងនេះ ហេតុនោះ ។ បេ ។ មានះនឹងអតិមានះ ព្រមទាំងការញុះញង់ ។

(១៣០) ពាក្យថា ជំលោះ វិវាទ (ជាដើម) កើតក្នុងសេចក្ដីកំណាញ់ សេចក្ដីថា កិលេសទាំង ៧ នេះ គឺ ជំលោះ១ វិវាទ១ ការខ្សឹកខ្សួល១ សេចក្ដីសោក១ មានះ១ អតិមានះ១ ការញុះញង់១ ប្រកប ប្រកបសព្វគ្រប់ ប្រកបទូទៅ ប្រកបទូទៅព្រម ក្នុងសេចក្ដីកំណាញ់ ហេតុនោះ (ទ្រង់ត្រាស់ថា) ជំលោះ វិវាទ (ជាដើម) កើតក្នុងសេចក្ដីកំណាញ់ ។

(១៣១) ពាក្យថា កាលបើវិវាទកើតហើយ ជនទាំងឡាយ (ក៏បង្ក) នូវការញុះញង់ អធិប្បាយថា កាលវិវាទកើតហើយ កើតព្រមហើយ លេចឡើងហើយ លេចឡើងចំពោះហើយ កើតប្រាកដហើយ ជនទាំងឡាយ បង្កនូវការញុះញង់ គឺឮអំពីពួកជនឯណោះហើយ ប្រាប់ពួកជនឯណោះ ដើម្បីបំបែកពួកជននេះ ឬឮអំពីពួកជនឯណោះ ហើយប្រាប់ពួកជននេះ ដើម្បីបំបែកពួកជនឯណោះ ជាអ្នកបំបែកពួកជន ដែលព្រមព្រៀងគ្នាផង ជាអ្នកបន្ថែមកំឡាំងដល់ពួកជនដែលបែកគ្នាហើយផង ជាអ្នកមានពួកជាទីត្រេកអរ ត្រេកអរក្នុងពួក រីករាយក្នុងពួក ពោលវាចាដែលធ្វើឲ្យជាពួក នេះហៅថា ការញុះញង់ ។

អមុំ ច ទ្វីហិ ការណេហិ បេសុញ្ញំ ឧបសំហរន្តិ បិយកម្យតាយ វា ភេទាធិប្បាយា វា ។

កថំ បិយកម្យតាយ បេសុញ្ញំ ឧបសំហរន្តិ ។ ឥមស្ស បិយា ភវិស្សាម មនាបា ភវិស្សាម វិស្សាសិកា ភវិស្សាម អព្ភន្តរិកា ភវិស្សាម សុហទយា ភវិស្សាមាតិ ឯវំ បិយកម្យតាយ បេសុញ្ញំ ឧបសំហរន្តិ ។

កថំ ភេទាធិប្បាយា បេសុញ្ញំ ឧបសំហរន្តិ ។

កថំ ឥមេ នានា អស្សុ វិនា អស្សុ វគ្គា អស្សុ ទ្វេធា អស្សុ ទ្វេជ្ឈា អស្សុ ទ្វេបក្ខា អស្សុ ភិជ្ជេយ្យុំ ន សមាគច្ឆេយ្យុំ ទុក្ខំ ន ផាសុ វិហរេយ្យុន្តិ ឯវំ ភេទាធិប្បាយា បេសុញ្ញំ ឧបសំហរន្តីតិ វិវាទជាតេសុ ច បេសុណានិ ។ តេនាហ ភគវា

បិយប្បហូតា កលហា វិវាទា
បរិទេវសោកា សហមច្ឆរា ច
មានាតិមានា សហបេសុណា ច
មច្ឆេរយុត្តា កលហា វិវាទា
វិវាទជាតេសុ ច បេសុណានីតិ ។

មួយទៀត ពួកជនបង្កការទាស់ទែង ដោយហេតុពីរ គឺ ដោយសេចក្តីប្រាថ្នាឲ្យគាប់ ឬមានសេចក្តីប្រាថ្នាដើម្បីបំបែកគេ ។

ពួកជនបង្កការទាស់ទែង ដោយសេចក្តីប្រាថ្នាឲ្យគាប់ តើដូចម្តេច ។ ពួកជនបង្កការទាស់ទែង ដោយសេចក្តីប្រាថ្នាឲ្យគាប់ យ៉ាងនេះថា យើងទាំងឡាយនឹងជាទីស្រឡាញ់ ជាទីគាប់ចិត្ត ប្រកបដោយសេចក្តីស្និទ្ធស្នាល ជាអ្នកខាងក្នុង ជាអ្នកមានចិត្តល្អ នៃជននេះ ។

ពួកជនមានសេចក្តីប្រាថ្នាដើម្បីបំបែក ហើយបង្កការទាស់ទែង តើដូចម្តេច ។ ពួកជនមានសេចក្តីប្រាថ្នាដើម្បីបំបែក បង្កការទាស់ទែងយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ជនពួកនេះគប្បីផ្សេង ៗ គ្នា គប្បីប្រាសចាកគ្នា ទៅជាពួក ទៅជាចំណែកពីរ មានអន្លើស្រយពីរ មានពួកពីរ គប្បីបែកគ្នា មិនគប្បីមកជួបគ្នា គប្បីនៅជាទុក្ខ មិនសប្បាយ ហេតុនោះ (ទ្រង់ត្រាស់ថា ) កាលបើវិវាទកើតហើយ (ជនទាំងឡាយក៏បង្ក ) នូវការទាស់ទែង ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ជំលោះ វិវាទ សេចក្តីខ្សឹកខ្សួល សេចក្តីសោក ព្រមទាំងសេចក្តីកំណាញ់ មានះនឹងអតិមានះ ព្រមទាំងការទាស់ទែង កើតអំពីសភាវៈជាទីស្រឡាញ់ (មួយទៀត) ជំលោះ វិវាទ (ជាដើម) កើតក្នុងសេចក្តីកំណាញ់ កាលបើវិវាទកើតហើយ (ជនទាំងឡាយក៏បង្ក) នូវការទាស់ទែង ។

(១៣៦) បិយា សុ លោកស្មិំ(១) កុតោនិទានា

យេ ចាបិ លោភា វិចរន្តិ លោកេ

អាសា ច និដ្ឋា ច កុតោនិទានា

យេ សម្បរាយាយ នរស្ស ហោន្តិ ។

(១៣៧) បិយា សុ លោកស្មិំ កុតោនិទានាតិ បិយា កុតោនិទានា កុតោ ជាតា កុតោ សញ្ជាតា កុតោ និព្វត្តា កុតោ អភិនិព្វត្តា កុតោ បាតុភូតា កឹនិទានា កឹសមុទយា កឹជាតិកា កឹបភវាតិ បិយានំ មូលំ បុច្ឆតិ ។បេ។ សមុទយំ បុច្ឆតិ បបុច្ឆតិ យាចតិ អជ្ឈេសតិ បសាទេតីតិ បិយា សុ លោកស្មិំ កុតោ-និទានា ។

(១៣៨) យេ ចាបិ លោភា វិចរន្តិ លោកេតិ យេចា-បីតិ ខត្តិយា ច ព្រាហ្មណា ច វេស្សា ច សុទ្ទា ច គហដ្ឋា ច បព្វជិតា ច ទេវា ច មនុស្សា ច ។ លោភាតិ យោ លោភោ លុព្ភនា លុព្ភិតត្តំ សារាគោ សារ-ជ្ជនា សារជ្ជិតត្តំ អភិជ្ឈា លោភោ អកុសលមូលំ ។

---

១ ឱ.ម. លោកស្មឹ ។

កលហវិវាទសុត្តនិទ្ទេស ទី ១១

(១៣២) (ព្រះពុទ្ធនិម្មិត ត្រាស់សួរថា) អើចុះ សត្វនឹងសង្ខារជាទីស្រឡាញ់ក្នុងលោក (របស់ពួកជន) ដែលត្រាច់ទៅក្នុងលោក ព្រោះលោភៈ មានអ្វីជានិទាន ចំណង់បំណងនឹងសេចក្ដីសម្រេច ដែលជាទីពឹងរបស់នរជន មានអ្វីជានិទាន ។

(១៣៣) ពាក្យថា សត្វនឹងសង្ខារ ជាទីស្រឡាញ់ ក្នុងលោក មានអ្វីជានិទាន គឺព្រះពុទ្ធនិម្មិតសួរនូវមូល ។ បេ ។ សួរ សួរឈ្លបឈ្លី អង្វរ អារាធនា ចោទ នូវសមុទ័យ នៃសត្វនឹងសង្ខារ ជាទីស្រឡាញ់ថា សត្វនឹងសង្ខារ ជាទីស្រឡាញ់ កើតអំពីណា កអំពីណា កើតព្រមអំពីណា ដុះអំពីណា ដុះដាលអំពីណា កើតប្រាកដអំពីណា មានអ្វីជានិទាន មានអ្វីជាសមុទ័យ មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ហេតុនោះ (ទ្រង់ត្រាស់សួរថា) អើចុះ សត្វនឹងសង្ខារជាទីស្រឡាញ់ក្នុងលោក មានអ្វីជានិទាន ។

(១៣៤) អធិប្បាយពាក្យថា ពួកជន ដែលត្រាច់ទៅក្នុងលោក ព្រោះលោភៈ ត្រង់ពាក្យថា ពួកជន បានដល់ ពួកក្សត្រ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ គ្រហស្ថ បព្វជិត ទេវតា នឹងមនុស្ស ។ ពាក្យថា ព្រោះលោភៈ បានដល់ លោភៈ អាការនៃលោភៈ ភាពនៃលោភៈ សេចក្ដីត្រេកអរ មានកំឡាំង អាការនៃសេចក្ដីត្រេកអរ មានកំឡាំង ភាពនៃសេចក្ដីត្រេកអរ មានកំឡាំង អភិជ្ឈា លោភៈ អកុសលមូល ។

វិចរន្តីតិ វិចរន្តិ វិហរន្តិ ឥរិយន្តិ វត្តន្តិ បាលេន្តិ យបេន្តិ យាបេន្តិ ។ លោកោតិ អបាយលោកោ មនុស្សលោកោ ទេវលោកោ ខន្ធលោកោ ធាតុលោកោ អាយតន-លោកោតិ យេ ភបិ លោកា វិចរន្តិ លោកេ ។

(១៣៨) អាសា ច និដ្ឋា ច កុតោនិទានាតិ អាសា ច និដ្ឋា ច កុតោនិទានា កុតោ ជាតា កុតោ សញ្ជាតា កុតោ និព្វត្តា កុតោ អភិនិព្វត្តា កុតោ បាតុភូតា កឹនិទានា កឹសមុទយា កឹជាតិកា កឹ-បភវាតិ អាសាយ ច និដ្ឋាយ ច មូលំ បុច្ឆតិ ។ បេ ។ សមុទយំ បុច្ឆតិ បពុច្ឆតិ យាចតិ អជ្ឈេសតិ បសា-ទេតីតិ អាសា ច និដ្ឋា ច កុតោនិទានា ។

(១៣៩) យេ សម្បរាយាយ នរស្ស ហោន្តីតិ យេ នរស្ស បរាយនា ហោន្តិ ទីបា ហោន្តិ តាណា ហោន្តិ លេណា ហោន្តិ សរណា ហោន្តិ នរោ និដ្ឋាបរាយ-ណោ ហោតីតិ យេ សម្បរាយាយ នរស្ស ហោន្តិ ។

**តេនាហ សោ និម្មិតោ**

ពាក្យថា ត្រាច់ទៅ គឺត្រាច់ទៅ នៅ ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ហេតុនោះ (ទ្រង់ត្រាស់សួរថា) ពួកជនដែលត្រាច់ទៅក្នុងលោក ព្រោះលោកៈ ។

(១៣៥) ពាក្យថា បំណងនឹងសេចក្តីសម្រេច មានអ្វីជានិទាន គឺព្រះពុទ្ធនិម្មិតសួរ ទូលសួរ ។ បេ ។ សួរ សួរឈ្វេចឈ្វី អង្វរ អាពធនា ចោទ នូវសមុទ័យ នៃបំណង នឹងសេចក្តីសម្រេចថា បំណងនឹងសេចក្តីសម្រេច កើតអំពីណា កអំពីណា កើតព្រមអំពីណា ដុះអំពីណា ដុះដាលអំពីណា កើតប្រាកដអំពីណា មានអ្វីជានិទាន មានអ្វីជាសមុទ័យ មានអ្វីជាកំណើត មានអ្វីជា ដែនកើតមុន ហេតុនោះ (ទ្រង់ត្រាស់សួរថា) បំណងនឹងសេចក្តីសម្រេច មានអ្វីជានិទាន ។

(១៣៦) ពាក្យថា ដែលជាទីពឹងរបស់នរជន បានដល់ធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងខាងមុខ ជាទីពឹង ជាទីពំនាក់ ជាទីជ្រក ជាទីពួករបស់នរជន គឺថា នរជនមានសេចក្តីសម្រេច ប្រព្រឹត្តទៅខាងមុខ ហេតុនោះ (ទ្រង់ត្រាស់សួរថា) ដែលជាទីពឹងរបស់នរជន ។ ហេតុនោះ ព្រះពុទ្ធនិម្មិតនោះ ត្រាស់សួរថា

ឯកាទសមោ កលហវិវាទសុត្តនិទ្ទេសោ

បិយា សុ លោកស្មឹ កុតោនិទានា
យេ ចាបិ លោភា វិចរន្តិ លោកេ
អាសា ច និដ្ឋា ច កុតោនិទានា
យេ សម្បរាយាយ នរស្ស ហោន្តីតិ ។

(១៣៧) ឆន្ទានិទានានិ បិយានិ លោកេ
យេ ចាបិ លោភា វិចរន្តិ លោកេ
អាសា ច និដ្ឋា ច ឥតោនិទានា
យេ សម្បរាយាយ នរស្ស ហោន្តិ ។

(១៣៨) ឆន្ទានិទានានិ បិយានិ លោកេតិ ឆន្ទោតិ យោ កាមេសុ កាមច្ឆន្ទោ កាមរាគោ កាមនន្ទី កាមតណ្ហា កាមស្នេហោ កាមបរិឡាហោ កាមមុច្ឆា កាមជ្ឈោសានំ កាមោឃោ កាមយោគោ កាមុបាទានំ កាមច្ឆន្ទនីវរណំ ។ អបិច បញ្ច ឆន្ទា បរិយេសនច្ឆន្ទោ បដិលាភច្ឆន្ទោ បរិភោគច្ឆន្ទោ សន្និធិច្ឆន្ទោ វិសជ្ជនច្ឆន្ទោ ។

អើចុះសត្វទាំងសង្ខារជាទីស្រឡាញ់ក្នុងលោក (របស់ពួកជន) ដែលត្រាច់ទៅក្នុងលោក ព្រោះលោកៈ មានអ្វីជានិទាន ទាំងបំណងនឹងសេចក្ដីសម្រេច ដែលជាទីពឹង របស់នរជន មានអ្វីជានិទាន ។

(១៣៧) (ព្រះមានព្រះភាគ ត្រាស់ថា) សត្វទាំងសង្ខារ ជាទីស្រឡាញ់ក្នុងលោក (របស់ពួកជន) ដែលត្រាច់ទៅក្នុងលោក ព្រោះលោកៈ មានឆន្ទៈជានិទាន ទាំងបំណងនឹងសេចក្ដីសម្រេច ដែលជាទីពឹងរបស់នរជន ក៏មានឆន្ទៈនេះ ជានិទានដែរ ។

(១៣៨) អធិប្បាយពាក្យថា សត្វទាំងសង្ខារជាទីស្រឡាញ់ក្នុងលោក មានឆន្ទៈជានិទាន ត្រង់ពាក្យថា ឆន្ទៈ បានដល់ កាមច្ឆន្ទៈក្នុងកាមទាំងឡាយ សេចក្ដីត្រេកអរក្នុងកាម ការរីករាយក្នុងកាម បំណងក្នុងកាម ការស្រឡាញ់ក្នុងកាម សេចក្ដីក្រហល់ក្រហាយព្រោះកាម ការងុលងប់ក្នុងកាម ការជ្រុលជ្រប់ក្នុងកាម អន្ទង់គឺកាម ការប្រកបក្នុងកាម សេចក្ដីប្រកាន់ក្នុងកាម ការរពាំងព្រោះកាមច្ឆន្ទៈ ។ មួយទៀត ឆន្ទៈ មាន ៥ គឺ បរិយេសនច្ឆន្ទៈ ១ បដិលាភច្ឆន្ទៈ ១ បរិភោគច្ឆន្ទៈ ១ សន្និធិច្ឆន្ទៈ ១ វិសជ្ជនច្ឆន្ទៈ ១ ។

កតមោ បរិយេសនច្ឆន្ទោ ។ ឥធេកច្ចោ អជ្ឈោសិតោយេវ អត្ថិកោ ឆន្ទជាតោ រូបេ បរិយេសតិ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ បរិយេសតិ អយំ បរិយេសនច្ឆន្ទោ ។

កតមោ បដិលាភច្ឆន្ទោ ។ ឥធេកច្ចោ អជ្ឈោសិតោយេវ អត្ថិកោ ឆន្ទជាតោ រូបេ បដិលភតិ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ បដិលភតិ អយំ បដិលាភច្ឆន្ទោ ។

កតមោ បរិភោគច្ឆន្ទោ ។ ឥធេកច្ចោ អជ្ឈោសិតោយេវ អត្ថិកោ ឆន្ទជាតោ រូបេ បរិភុញ្ជតិ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ បរិភុញ្ជតិ អយំ បរិភោគច្ឆន្ទោ ។

កតមោ សន្និធិច្ឆន្ទោ ។ ឥធេកច្ចោ អជ្ឈោសិតោយេវ អត្ថិកោ ឆន្ទជាតោ ធនសន្និចយំ ករោតិ អាបទាសុ ភវិស្សតីតិ អយំ សន្និធិច្ឆន្ទោ ។

កតមោ វិសជ្ជនច្ឆន្ទោ ។ ឥធេកច្ចោ អជ្ឈោសិតោយេវ អត្ថិកោ ឆន្ទជាតោ ធនំ វិសជ្ជេតិ ហត្ថារោហានំ អស្សារោហានំ រថិកានំ ធនុគ្គហានំ បត្តិកានំ ឥមេ មំ រក្ខិស្សន្តិ គោបិស្សន្តិ សម្បរិវារិស្សន្តីតិ អយំ វិសជ្ជនច្ឆន្ទោ ។

បរិយេសនច្ឆន្ទៈ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ត្រូវកាមគ្របសង្កត់ហើយ ជាអ្នកត្រូវការ មានឆន្ទៈកើតហើយ ក៏ស្វែងរករូប ស្វែងរកសំឡេង ក្លិន រស ផោដ្ឋព្វៈ នេះ បរិយេសនច្ឆន្ទៈ ។

បដិលាភច្ឆន្ទៈ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ត្រូវកាមគ្របសង្កត់ហើយ ជាអ្នកត្រូវការ មានឆន្ទៈកើតហើយ ក៏បានរូប បានសំឡេង ក្លិន រស ផោដ្ឋព្វៈ នេះ បដិលាភច្ឆន្ទៈ ។

បរិភោគច្ឆន្ទៈ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ត្រូវកាមគ្របសង្កត់ហើយ ជាអ្នកត្រូវការ មានឆន្ទៈកើតហើយ ក៏ប្រើប្រាស់រូប ប្រើប្រាស់សំឡេង ក្លិន រស ផោដ្ឋព្វៈ នេះ បរិភោគច្ឆន្ទៈ ។

សន្និធិច្ឆន្ទៈ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ត្រូវកាមគ្របសង្កត់ហើយ ជាអ្នកត្រូវការ មានឆន្ទៈកើតហើយ ក៏ធ្វើការសន្សំទ្រព្យ ដោយគិតថា ទ្រព្យនឹងមានក្នុងកាលមានសេចក្តីអន្តរាយ នេះ សន្និធិច្ឆន្ទៈ ។

វិសជ្ជនច្ឆន្ទៈ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ត្រូវកាមគ្របសង្កត់ហើយ ជាអ្នកត្រូវការ មានឆន្ទៈកើតហើយ ក៏ចាយទ្រព្យ ឲ្យដល់ពួកអ្នកជិះដំរី ពួកអ្នកជិះសេះ ពួកអ្នកជិះរថ ពួកខ្មាន់ធ្នូ ពួកថ្មើរជើង ដោយគិតថា ជនទាំងនេះ នឹងរក្សា គ្រប់គ្រង ហោមរោម អាត្មាអញ នេះ វិសជ្ជនច្ឆន្ទៈ ។

ឯកាទសមោ កលហវិវាទសុត្តនិទ្ទេសោ

បិយានីតិ ទ្វេ បិយា សត្តា ច សង្ខារា ច ។បេ។ ឥមេ សត្តា បិយា ។បេ។ ឥមេ សង្ខារា បិយា ។ ឆន្ទនិទានានិ បិយានិ លោកេតិ បិយា ឆន្ទនិទានា ឆន្ទសមុទយា ឆន្ទជាតិកា ឆន្ទប្បភវាតិ ឆន្ទនិទានានិ បិយានិ លោកេ ។

(១៣៩) យេ ចាបិ លោភា វិចរន្តិ លោកេតិ យេ ចាបីតិ ខត្តិយា ច ព្រាហ្មណា ច វេស្សា ច សុទ្ទា ច គហដ្ឋា ច បព្វជិតា ច ទេវា ច មនុស្សា ច ។ លោភាតិ យោ លោភោ លុព្ភនា លុព្ភិតត្តំ សារាគោ សារជ្ជនា សារជ្ជិតត្តំ អភិជ្ឈា លោភោ អកុសលមូលំ ។ វិចរន្តីតិ វិចរន្តិ វិហរន្តិ ឥរិយន្តិ វត្តន្តិ បាលេន្តិ យបេន្តិ យាបេន្តិ ។ លោកេតិ អបាយលោកេ ។បេ។ អាយតនលោកេតិ យេ ចាបិ លោភា វិចរន្តិ លោកេ ។

កលហវិភាគសុត្តនិទ្ទេស ទី ១១

ពាក្យថា សត្វនឹងសង្ខារជាទីស្រឡាញ់ បានដល់ពួកសត្វឬសង្ខារជាទីស្រឡាញ់ទាំងពីរ ។ បេ ។ នេះ ពួកសត្វជាទីស្រឡាញ់ ។ បេ ។ នេះ ពួកសង្ខារជាទីស្រឡាញ់ ។ ពាក្យថា សត្វនឹងសង្ខារជាទីស្រឡាញ់ក្នុងលោក មានឆន្ទៈជានិទាន គឺសត្វនឹងសង្ខារជាទីស្រឡាញ់ មានឆន្ទៈជានិទាន មានឆន្ទៈជាសមុទ័យ មានឆន្ទៈជាកំណើត មានឆន្ទៈជាដែនកើតមុន ហេតុនោះ (ទ្រង់ត្រាស់ថា) សត្វនឹងសង្ខារជាទីស្រឡាញ់ក្នុងលោក មានឆន្ទៈ ជានិទាន ។

(១៣៩) ពាក្យថា ពួកជនណា ក្នុងបទថា ពួកជនដែលត្រាច់ទៅក្នុងលោក ព្រោះលោភៈ គឺពួកក្សត្រ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ គ្រហស្ថ បព្វជិត ទេវតា នឹង មនុស្ស ។ ពាក្យថា ព្រោះលោភៈ បានដល់លោភៈ អាការៈនៃលោភៈ ភាពនៃលោភៈ សេចក្ដីត្រេកអរមានកំឡាំង អាការៈនៃសេចក្ដីត្រេកអរមានកំឡាំង ភាពនៃសេចក្ដីត្រេកអរមានកំឡាំង អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា ត្រាច់ទៅ គឺត្រាច់ទៅ នៅ ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។ បេ ។ ក្នុងអាយតនលោក ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកជនដែលត្រាច់ទៅ ក្នុងលោកព្រោះលោភៈ ។

(១៦០) អាសា ច និដ្ឋា ច កុតោនិទានាតិ អាសា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ និដ្ឋាតិ ឥធេកច្ចោ រូបំ បរិយេសន្តោ រូបំ បដិលភតិ រូបនិដ្ឋោ ហោតិ ។ សទ្ទំ គន្ធំ រសំ ផោដ្ឋព្វំ កុលំ គណំ អាវាសំ លាភំ យសំ បសំសំ សុខំ ចីវរំ បិណ្ឌបាតំ សេនាសនំ គិលានប្បច្ចយភេសជ្ជបរិក្ខារំ សុត្តន្តំ វិនយំ អភិធម្មំ អារញ្ញិកង្គំ បិណ្ឌបាតិកង្គំ បំសុកូលិកង្គំ តេចីវរិកង្គំ សបទានចារិកង្គំ ខលុបច្ឆាភត្តិកង្គំ នេសជ្ជិកង្គំ យថាសន្ថតិកង្គំ បឋមំ ឈានំ ទុតិយំ ឈានំ តតិយំ ឈានំ ចតុត្ថំ ឈានំ អាកាសានញ្ចាយតនសមាបត្តឹ វិញ្ញាណញ្ចាយតនសមាបត្តឹ អាកិញ្ចញ្ញាយតនសមាបត្តឹ នេវសញ្ញានាសញ្ញាយតនសមាបត្តឹ បរិយេសន្តោ នេវសញ្ញានាសញ្ញាយតនសមាបត្តឹ បដិលភតិ នេវសញ្ញានាសញ្ញាយតនសមាបត្តិនិដ្ឋោ ហោតិ ។

អាសាយ កសតេ ខេត្តំ ពីជំ អាសាយ វប្បតិ
អាសាយ ភណិជា យន្តិ សមុទ្ទំ ធនហារកា

(១៤០) ពាក្យថា បំណងនឹងសេចក្តីសម្រេច មានឆន្ទៈនេះ ជានិទានដែរ អធិប្បាយថា តណ្ហា លោកហៅថា បំណង បានដល់ សេចក្តីត្រេកអរ សេចក្តីត្រេកអរមានកំឡាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា សេចក្តីសម្រេច សេចក្តីថា បុគ្គលខ្លះ ក្នុងលោកនេះ ស្វែងរករូប ក៏បានរូប ឈ្មោះថា អ្នកមានរូបសម្រេចហើយ ។ ស្វែងរកសំឡេង ក្លិន រស ផោដ្ឋព្វៈ ត្រកូល ពួក អាវាស លាភ យស សេចក្តីសរសើរ សេចក្តីសុខ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ ព្រះសូត្រ ព្រះវិន័យ ព្រះអភិធម្ម អារញ្ញិកធុតង្គ បិណ្ឌបាតិកធុតង្គ បំសុកូលិកធុតង្គ តេចីវរិកធុតង្គ សបទានចារិកធុតង្គ ខលុបច្ឆាភត្តិកធុតង្គ នេសជ្ជិកធុតង្គ យថាសន្ថតិកធុតង្គ បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន អាកាសានញ្ចាយតនសមាបត្តិ វិញ្ញាណញ្ចាយតនសមាបត្តិ អាកិញ្ចញ្ញាយតនសមាបត្តិ នេវសញ្ញានាសញ្ញាយតនសមាបត្តិ ក៏បាននូវនេវសញ្ញានាសញ្ញាយតនសមាបត្តិ ឈ្មោះថា អ្នកមាននេវសញ្ញានាសញ្ញាយតនសមាបត្តិសម្រេចហើយ ។

បុគ្គលភ្ជួរស្រែដោយបំណង បុគ្គលសាបព្រោះពូជ ក៏ដោយបំ
ណង ពួកឈ្មួញនាំយកទ្រព្យទៅកាន់សមុទ្រ ក៏ដោយបំណង

យាយ អាសាយ តិដ្ឋាមិ សា មេ អាសា សមិជ្ឈតីតិ ។ និដ្ឋា វុច្ចតេ អាសាយ សមិទ្ធិ(១) ។ អាសា ច និដ្ឋា ច ឥតោនិទានាតិ អាសា ច និដ្ឋា ច ឥតោឆន្ទនិទានា ឆន្ទសមុទយា ឆន្ទជាតិកា ឆន្ទប្បភវាតិ អាសា ច និដ្ឋា ច ឥតោនិទានា ។

(៣៤៣) យេ សម្បរាយាយ នរស្ស ហោន្តីតិ យេ នរស្ស បរាយណា ហោន្តិ ទីបា ហោន្តិ តាណា ហោន្តិ លេណា ហោន្តិ សរណា ហោន្តិ គតិ និដ្ឋាបរាយណោ ហោន្តីតិ យេ សម្បរាយាយ នរស្ស ហោន្តិ ។

តេនាហ ភគវា

ឆន្ទានិទានានិ បិយានិ លោកេ
យេ ចាបិ លោភា វិចរន្តិ លោកេ
អាសា ច និដ្ឋា ច ឥតោនិទានា
យេ សម្បរាយាយ នរស្ស ហោន្តីតិ ។

១ ម. អាសាយ សមិទ្ធិ វុច្ចតេ និដ្ឋា ។

កលហវិវាទសុត្តនិទ្ទេស ទី ១១

អាត្មាអញតាំងនៅដោយបំណងណា បំណងនោះ ក៏សម្រេច

ដល់អាត្មាអញ ។

ការសម្រេច នៃបំណង លោកហៅថា សេចក្ដីសម្រេច ។

ពាក្យថា បំណង នឹងសេចក្ដីសម្រេច មានឆន្ទៈនេះជានិទាន គឺបំណង នឹងសេចក្ដីសម្រេច មានឆន្ទៈនេះជានិទាន មានឆន្ទៈជាសមុទ័យ មាន ឆន្ទៈជាកំណើត មានឆន្ទៈជាដែនកើតមុន ហេតុនោះ (ទ្រង់ត្រាស់ថា) បំណងនឹងសេចក្ដីសម្រេច មានឆន្ទៈនេះជានិទាន ។

(១៤១) ពាក្យថា ដែលជាទីពឹងរបស់នរជន គឺធម៌ទាំងឡាយ ណា ប្រព្រឹត្តទៅខាងមុខ ជាទីពឹង ជាទីពំនាក់ ជាទីជ្រកកោន ជាទី ពួករបស់នរជន គឺថា នរជនមានសេចក្ដីសម្រេច ប្រព្រឹត្តទៅខាងមុខ ហេតុនោះ (ទ្រង់ត្រាស់ថា) ដែលជាទីពឹងរបស់នរជន ។

ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

សត្វទាំងឡាយ ដែលជាទីស្រឡាញ់ ក្នុងលោក (របស់ពួកជន)
ដែលត្រាច់ទៅ ក្នុងលោក ព្រោះលោភៈ មានឆន្ទៈជា
និទាន ទាំងបំណងនឹងសេចក្ដីសម្រេច ដែលជាទីពឹង
របស់នរជន ក៏មានឆន្ទៈជានិទានដែរ ។

(១៦២) ឆន្ទោ នុ លោកស្មិំ កុតោនិទានោ
វិនិច្ឆយា ចាបិ កុតោ បហូតា
កោធោ មោសវជ្ជញ្ច កថំកថា ច
យេ វាបិ ធម្មា សមណេន វុត្តា ។

(១៦៣) ឆន្ទោ នុ លោកស្មិំ កុតោនិទានោតិ ឆន្ទោ កុតោនិទានោ កុតោ ជាតោ កុតោ សញ្ជាតោ កុតោ និព្វត្តោ កុតោ អភិនិព្វត្តោ កុតោ បាតុភូតោ កិំនិទានោ កិំសមុទយោ កិំជាតិកោ កិំបភវោតិ ឆន្ទស្ស មូលំ បុច្ឆតិ ។បេ។ សមុទយំ បុច្ឆតិ បបុច្ឆតិ យាចតិ អជ្ឈេសតិ បសាទេតីតិ ឆន្ទោ នុ លោកស្មិំ កុតោនិទានោ ។

(១៦៤) វិនិច្ឆយា ចាបិ កុតោ បហូតាតិ វិនិច្ឆយា កុតោ បហូតា កុតោ ជាតា កុតោ សញ្ជាតា កុតោ និព្វត្តា កុតោ អភិនិព្វត្តា កុតោ បាតុភូតា កិំនិទានា កិំសមុទយា កិំជាតិកា កិំបភវាតិ វិនិច្ឆយានំ មូលំ បុច្ឆតិ ។បេ។ សមុទយំ បុច្ឆតិ បបុច្ឆតិ យាចតិ អជ្ឈេសតិ បសាទេតីតិ វិនិច្ឆយា ចាបិ កុតោ បហូតា ។

(១៤២) (ព្រះពុទ្ធនិម្មិតសួរថា) ចុះ ឆន្ទៈក្នុងលោក មានអ្វីជានិទាន ទាំងវិនិច្ឆ័យទាំងឡាយ នឹងធម៌ទាំងឡាយណា ដែលសមណៈពោលហើយ ធម៌ទាំងនោះ គឺសេចក្តីក្រោធ ១ ការពោលពាក្យកុហក ១ សេចក្តីសង្ស័យ ១ កើតអំពីណា ។

(១៤៣) ពាក្យថា ចុះឆន្ទៈ ក្នុងលោក មានអ្វីជានិទាន គឺព្រះពុទ្ធនិម្មិតសួរនូវមូល ។ បេ ។ សួរ សួរឈ្មោះបញ្ហា អង្វរ អារាធនា ហៅនូវសមុទ័យនៃឆន្ទៈថា ឆន្ទៈកើតអំពីណា កអំពីណា កើតព្រមអំពីណា ដុះអំពីណា ដុះដាលអំពីណា កើតប្រាកដអំពីណា មានអ្វីជានិទាន មានអ្វីជាសមុទ័យ មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ហេតុនោះ (ទ្រង់ត្រាស់សួរថា) ចុះឆន្ទៈ ក្នុងលោក មានអ្វីជានិទាន ។

(១៤៤) ពាក្យថា ទាំងវិនិច្ឆ័យទាំងឡាយ កើតអំពីណា គឺព្រះពុទ្ធនិម្មិត សួរនូវមូល ។ បេ ។ សួរ សួរឈ្មោះបញ្ហា អង្វរ អារាធនា ហៅនូវសមុទ័យនៃវិនិច្ឆ័យទាំងឡាយថា វិនិច្ឆ័យទាំងឡាយ កើតអំពីណា កអំពីណា កើតព្រមអំពីណា ដុះអំពីណា ដុះដាលអំពីណា កើតប្រាកដអំពីណា មានអ្វីជានិទាន មានអ្វីជាសមុទ័យ មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ហេតុនោះ (ទ្រង់ត្រាស់សួរថា) ទាំងវិនិច្ឆ័យទាំងឡាយ កើតអំពីណា ។

## ឯកាទសមោ កលហវិវាទសុត្តនិទ្ទេសោ

[១៤៥] កោធោ មោសវជ្ជញ្ច កថំកថា ចាតិ កោធោតិ យោ(១) ចិត្តស្ស អាឃាតោ បដិឃាតោ បដិឃំ បដិវិរោធោ កោបោ បកោបោ សម្បកោបោ ទោសោ បទោសោ សម្បទោសោ ចិត្តស្ស ព្យាបត្តិ មនោបទោសោ កោធោ កុជ្ឈនា កុជ្ឈិតត្តំ ទោសោ ទុស្សនា ទុស្សិតត្តំ ព្យាបត្តិ ព្យាបជ្ជនា ព្យាបជ្ជិតត្តំ វិរោធោ បដិវិរោធោ ចណ្ឌិក្កំ អស្សុរោបោ អនត្តមនតា ចិត្តស្ស ។ មោសវជ្ជំ វុច្ចតិ មុសាវាទោ ។ កថំកថា វុច្ចតិ វិចិកិច្ឆាតិ កោធោ មោសវជ្ជញ្ច កថំកថា ច ។

[១៤៦] យេបិ ធម្មា សមណេន វុត្តាតិ យេបីតិ យេ កោធេន ច មោសវជ្ជេន ច កថំកថាយ ច សហគតា សហជាតា សំសដ្ឋា សម្បយុត្តា ឯកុប្បាទា ឯកនិរោធា ឯកវត្ថុកា ឯការម្មណា ឥមេ វុច្ចន្តិ យេបិ ធម្មា ។ អថវា យេបីតិ កិលេសា(២) អញ្ញជាតិកា អញ្ញវិហិតា ឥមេ វុច្ចន្តិ យេបិ ធម្មា ។

---

១ ម យោ ឯវរូបោ ។ ២ ម.យេ តេ កិលេសា ។

កលហវិវាទសុត្តនិទ្ទេស ទី ១១

(១៨៥) អធិប្បាយពាក្យថា សេចក្តីក្រោធ១ ការពោលពាក្យកុហក១ សេចក្តីសង្ស័យ ១ ត្រង់ពាក្យថា សេចក្តីក្រោធ បានដល់ការគុំគួននៃចិត្ត សេចក្តីចង្អៀតចង្អល់ សេចក្តីគានគឹង សេចក្តីថ្នាំងថ្នាក់ ការខឹង ការខឹងខ្លាំង ការខឹងក្រៃលែង ការប្រទូស្ត ការប្រទូស្តខ្លាំង ការប្រទូស្តក្រៃលែង ព្យាបាទនៃចិត្ត ការប្រទូស្តក្នុងចិត្ត ការក្រោធ អាការក្រោធ ភាពនៃការក្រោធ ការប្រទូស្ត អាការប្រទូស្ត ភាពនៃការប្រទូស្ត ការព្យាបាទ អាការព្យាបាទ ភាពនៃការព្យាបាទ ការខឹង ការខឹងតប ការក្តាច ការសម្រក់ទឹកភ្នែក សេចក្តីមិនត្រេកអរនៃចិត្ត ។ មុសាវាទ លោកហៅថា ការពោលពាក្យកុហក ។ វិចិកិច្ឆា លោកហៅថា សេចក្តីសង្ស័យ ហេតុនោះ (ទ្រង់ត្រាស់សួរថា) សេចក្តីក្រោធ១ ការពោលពាក្យកុហក១ សេចក្តីសង្ស័យ១ ។

(១៨៦) អធិប្បាយពាក្យថា ធម៌ទាំងឡាយណា ដែលសមណៈពោលហើយ ត្រង់ពាក្យថា ធម៌ទាំងឡាយណា គឺធម៌ទាំងឡាយណា ជាធម៌ប្រព្រឹត្តទៅជាមួយគ្នា កើតព្រមគ្នា ច្រឡំគ្នា ប្រកបព្រមគ្នា មានការកើតឡើងតែមួយ មានការរលត់តែមួយ មានវត្ថុតែមួយ មានអារម្មណ៍តែមួយ ជាមួយនឹងសេចក្តីក្រោធផង ការពោលពាក្យកុហកផង សេចក្តីសង្ស័យផង ទាំងនេះលោកពោលថា ធម៌ទាំងឡាយណា ។ ម្យ៉ាងទៀត ពាក្យថា ធម៌ទាំងឡាយណា គឺកិលេសទាំងឡាយ មានសភាវៈដទៃ តាំងនៅដោយអាការៈដទៃ ទាំងនេះលោកពោលថា ធម៌ទាំងឡាយណា ។

សមណេន វុត្តាតិ សមណេន សមិតបាបេន ព្រាហ្មណេន ពាហិតបាបេន ភិក្ខុនា ភិន្នកិលេសមូលេន សព្វាកុសលមូលពន្ធនា បមុត្តេន វុត្តា បវុត្តា អាចិក្ខិតា ទេសិតា បញ្ញាបិតា បដ្ឋបិតា វិវដា វិភត្តា ឧត្តានីកតា បកាសិតាតិ យេ ចាបិ ធម្មា សមណេន វុត្តា ។ តេនាហ សោ និម្មិតោ

ឆន្ទោ នុ លោកស្មិំ កុតោនិទានោ
វិនិច្ឆយា ចាបិ កុតោ បហូតា
កោធោ មោសវជ្ជញ្ច កថំកថា ច
យេ ចាបិ ធម្មា សមណេន វុត្តាតិ ។

(១៤៧) សាតំ អសាតន្តិ យមាហុ លោកេ
តមូបនិស្សាយ បហោតិ ឆន្ទោ
រូបេសុ ទិស្វា វិភវំ ភវញ្ច
វិនិច្ឆយំ កុព្វតេ(១) ជន្តុ លោកេ ។

(១៤៨) សាតំ អសាតន្តិ យមាហុ លោកេតិ សាតន្តិ សុខា ច វេទនា ឥដ្ឋញ្ច វត្ថុ ។

---

១ ម. កុព្វតិ ។

ពាក្យថា ដែលសមណៈពោលហើយ គឺសមណៈមានបាបរម្ងាប់ហើយ ព្រាហ្មណ៍មានបាបបន្សាត់បង់ហើយ ភិក្ខុមានកិលេសមូល ទម្លាយបង់ហើយ ជាអ្នករួចស្រឡះចាកចំណងគឺអកុសលមូលទាំងពួង ពោល ពោលដោយប្រការៈ ប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាសហើយ ហេតុនោះ (ទ្រង់ត្រាស់សួរថា) នឹងធម៌ទាំងឡាយណា ដែលសមណៈពោលហើយ ៗ ហេតុនោះ ព្រះពុទ្ធនិម្មិតសួរថា

ចុះឆន្ទៈក្នុងលោក មានអ្វីជានិទាន ទាំងវិនិច្ឆ័យទាំងឡាយ
នឹងធម៌ទាំងឡាយណា ដែលសមណៈពោលហើយ ធម៌
ទាំងនោះ គឺសេចក្ដីក្រោធ ១ ការពោលពាក្យកុហក ១
សេចក្ដីសង្ស័យ ១ កើតអំពីណា ៗ

(១៤៧) (ព្រះមានព្រះភាគ ត្រាស់ថា) ជនទាំងឡាយពោលនូវ
ធម្មជាតណាថាឆ្ងាញ់នឹងមិនឆ្ងាញ់ ក្នុងលោក ឆន្ទៈកើតឡើង
អាស្រ័យនូវធម្មជាតនោះ ជនក្នុងលោក ឃើញនូវសេចក្ដីវិនាស
នឹងសេចក្ដីចំរើន ក្នុងរូបទាំងឡាយហើយ ក៏ធ្វើនូវវិនិច្ឆ័យ ៗ

(១៤៨) ពាក្យថា ជនទាំងឡាយ ពោលនូវធម្មជាតណាថា ឆ្ងាញ់នឹងមិនឆ្ងាញ់ ក្នុងលោក ត្រង់ពាក្យថា ឆ្ងាញ់ បានដល់សុខវេទនាផង

អសាតន្តិ ទុក្ខា ច វេទនា អនិដ្ឋញ្ច វត្ថុ ។ យមាហុ លោកេតិ យំ អាហំសុ យំ កថេន្តិ យំ ភណន្តិ យំ ទីបយន្តិ យំ វោហរន្តីតិ សាតំ អសាតន្តិ យមាហុ លោកេ ។

(១៤៩) តមូបនិស្សាយ បហោតិ ឆន្ទោតិ សាតាសាតំ និស្សាយ សុខទុក្ខំ និស្សាយ សោមនស្សទោមនស្សំ និស្សាយ ឥដ្ឋានិដ្ឋំ និស្សាយ អនុនយបដិឃំ និស្សាយ ឆន្ទោ ហោតិ បហោតិ ជាយតិ សញ្ជាយតិ និព្វត្តតិ អភិនិព្វត្តតីតិ តមូបនិស្សាយ បហោតិ ឆន្ទោ ។

(១៥០ រូបេសុ ទិស្វា វិភវំ ភវញ្ចាតិ រូបេសូតិ ចត្តារោ ច មហាភូតា ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបំ ។

កតមោ រូបានំ ភវោ ។ យោ រូបានំ ជាតិ សញ្ជាតិ និព្វត្តិ អភិនិព្វត្តិ បាតុភាវោ អយំ រូបានំ ភវោ ។

វត្ថុជាទីស្រឡាញ់ផង ៗ ពាក្យថា មិនឆ្ងាញ់ បានដល់ទុក្ខវេទនាផង វត្ថុមិនជាទីស្រឡាញ់ផង ៗ ពាក្យថា ពោលនូវធម្មជាតណា ក្នុងលោក គឺពោលនូវធម្មជាតណា សំដែងនូវធម្មជាតណា ពណ៌នានូវធម្មជាតណា បំភ្លឺនូវធម្មជាតណា ថ្លែងនូវធម្មជាតណា ហេតុនោះ (ទ្រង់ត្រាស់ថា) ជនទាំងឡាយ ពោលនូវធម្មជាតណាថា ឆ្ងាញ់ និងមិនឆ្ងាញ់ក្នុងលោក ៗ

(១៤៩) ឆន្ទៈកើតឡើង អាស្រ័យធម្មជាតនោះ គឺឆន្ទៈ កើតមាន កើតប្រាកដ កើតឡើង កើតឡើងព្រម លេចឡើង លេចឡើងចំពោះ អាស្រ័យវត្ថុឆ្ងាញ់និងមិនឆ្ងាញ់ អាស្រ័យសុខនិងទុក្ខ អាស្រ័យសោមនស្ស និងទោមនស្ស អាស្រ័យវត្ថុជាទីស្រឡាញ់ និងមិនជាទីស្រឡាញ់ អាស្រ័យសេចក្ដីត្រេកអរ និងសេចក្ដីថ្នាំងថ្នាក់ ហេតុនោះ (ទ្រង់ត្រាស់ថា) ឆន្ទៈកើតឡើង អាស្រ័យនូវធម្មជាតនោះ ៗ

(១៥០) អធិប្បាយពាក្យថា ឃើញសេចក្ដីវិនាស និងសេចក្ដីចំរើន ក្នុងរូបទាំងឡាយ ត្រង់ពាក្យថា ក្នុងរូបទាំងឡាយ បានដល់មហាភូតរូប ៤ និងរូបដែលអាស្រ័យមហាភូតរូប ៤ ។

សេចក្ដីចំរើនឡើង នៃរូបទាំងឡាយ តើដូចម្ដេច ៗ សេចក្ដីចំរើន ការកើត ការកើតព្រម ការលេចឡើង ការលេចឡើងចំពោះ ការកើតប្រាកដនៃរូបទាំងឡាយឯណា នេះសេចក្ដីចំរើននៃរូបទាំងឡាយ ។

កតមោ រូបានំ វិគមោ ។ យោ រូបានំ ខយោ វយោ ភេទោ បរិភេទោ អនិច្ចតា អន្តរធានំ អយំ រូបានំ វិគមោ ។ រូបេសុ ទិស្វា វិភវំ ភវញ្ញាតិ រូបេសុ ភវញ្ញូ វិភវញ្ញូ ទិស្វា បស្សិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ រូបេសុ ទិស្វា វិភវំ ភវញ្ញូ ។

(១៥១) វិនិច្ឆយំ កុព្វតេ ជន្តុ លោកេតិ វិនិច្ឆយាតិ ទ្វេ វិនិច្ឆយា តណ្ហាវិនិច្ឆយោ ច ទិដ្ឋិវិនិច្ឆយោ ច ។ កថំ តណ្ហាវិនិច្ឆយំ ករោតិ ។ ឥធេកច្ចស្ស អនុប្បន្នា ចេវ ភោគា ន ឧប្បជ្ជន្តិ ឧប្បន្នា ច ភោគា បរិក្ខយំ គច្ឆន្តិ ។ តស្ស ឯវំ ហោតិ កេន នុ ខោ មេ ឧបាយេន អនុប្បន្នា ចេវ ភោគា ន ឧប្បជ្ជន្តិ ឧប្បន្នា ច ភោគា បរិក្ខយំ គច្ឆន្តិ ។ តស្ស បន ឯវំ ហោតិ

សេចក្តីវិនាសនៃរូបទាំងឡាយ តើដូចម្តេច ។ ការអស ការសូន្យ ការបែកធ្លាយ ការធ្លុះធ្លាយ ការមិនទៀងទាត់ ការអន្តរធាននៃរូបទាំងឡាយ ឯណា នេះ សេចក្តីវិនាសនៃរូបទាំងឡាយ ។

ពាក្យថា ឃើញសេចក្តីវិនាស នឹងសេចក្តីចំរើនក្នុងរូបទាំងឡាយ គឺឃើញ យល់ ថ្លឹង ពិចារណា ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដនូវសេចក្តីចំរើននឹងសេចក្តីវិនាស ក្នុងរូបទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) ឃើញសេចក្តីវិនាស នឹងសេចក្តីចំរើន ក្នុងរូបទាំងឡាយ ។

(១៨១) អធិប្បាយពាក្យថា ជនក្នុងលោកធ្វើនូវវិនិច្ឆ័យ ត្រង់ពាក្យថា វិនិច្ឆ័យ បានដល់វិនិច្ឆ័យ ២ គឺ តណ្ហាវិនិច្ឆ័យ ១ ទិដ្ឋិវិនិច្ឆ័យ ១ ។

បុគ្គលធ្វើតណ្ហាវិនិច្ឆ័យ តើដូចម្តេច ។ ភោគៈទាំងឡាយរបស់បុគ្គលខ្លះ ក្នុងលោកនេះ ដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង ភោគៈទាំងឡាយ ដែលកើតឡើងហើយ ក៏ដល់នូវការអស់រលីងផង ។ បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ដោយហេតុដូចម្តេចហ្ន៎ ភោគៈទាំងឡាយ របស់អាត្មាអញ ដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង ភោគៈទាំងឡាយ ដែលកើតឡើងហើយ ក៏ដល់នូវការអស់រលីងផង ។ មួយវិញទៀត បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា

សុរាមេរយមជ្ជប្បមាទដ្ឋានានុយោគំ អនុយុត្តស្ស មេ អនុប្បន្នា ចេវ ភោគា ន ឧប្បជ្ជន្តិ ឧប្បន្នា ច ភោគា បរិក្ខយំ គច្ឆន្តិ វិកាលវិសិខាចរិយានុយោគំ អនុយុត្តស្ស មេ អនុប្បន្នា ចេវ ភោគា ន ឧប្បជ្ជន្តិ ឧប្បន្នា ច ភោគា បរិក្ខយំ គច្ឆន្តិ សមជ្ជាភិចរណំ អនុយុត្តស្ស មេ ជូតប្បមាទដ្ឋានានុយោគំ អនុយុត្តស្ស មេ បាបមិត្តានុយោគំ អនុយុត្តស្ស មេ អនុប្បន្នា ចេវ ភោគា ន ឧប្បជ្ជន្តិ ឧប្បន្នា ច ភោគា បរិក្ខយំ គច្ឆន្តិ អាលស្សានុយោគំ អនុយុត្តស្ស មេ អនុប្បន្នា ចេវ ភោគា ន ឧប្បជ្ជន្តិ ឧប្បន្នា ច ភោគា បរិក្ខយំ គច្ឆន្តីតិ ។ ឯវំ ញាណំ តត្វា ន ភោគានំ អបាយមុខានិ ន សេវតិ(១) ។ ឯវម្បិ តណ្ហាវិនិច្ឆយំ ករោតិ ។

---

១ ឱ. ម. ឯត្តកេ ច ភោគានំ អាបាយមុខានិ សេវតីតិ ទិស្សតិ ។

កលហវិវាទសុត្តនិទ្ទេស ទី ១១

កាលបើអាត្មាអញប្រកបរឿយ ៗ នូវការប្រកបក្នុងហេតុជាទីតាំង នៃសេចក្តីប្រមាទ គឺសុរានិងមេរ័យ ភោគៈទាំងឡាយ ដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង ភោគៈទាំងឡាយ ដែលកើតឡើងហើយ ក៏ដល់នូវការអស់រលីងផង កាលបើអាត្មាអញ ប្រកបរឿយ ៗ នូវការប្រកបក្នុងការដើរលេងតាមច្រកក្នុងវេលាយប់ ភោគៈទាំងឡាយ ដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង ភោគៈទាំងឡាយ ដែលកើតឡើងហើយ ក៏ដល់នូវការអស់រលីងផង កាលបើអាត្មាអញ ប្រកបរឿយ ៗ នូវការដើរទៅកាន់ទីមហោស្រព កាលបើអាត្មាអញ ប្រកបរឿយ ៗ នូវការប្រកបក្នុងហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺល្បែងភ្នាល់ កាលបើអាត្មាអញប្រកបរឿយ ៗ នូវការប្រកបដោយមិត្រអាក្រក់ ភោគៈទាំងឡាយ ដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង ភោគៈទាំងឡាយ ដែលកើតឡើងហើយ ក៏ដល់នូវការអស់រលីងផង កាលបើអាត្មាអញ ប្រកបរឿយ ៗ នូវការប្រកបក្នុងការខ្ជិលច្រអូស ភោគៈទាំងឡាយ ដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង ភោគៈទាំងឡាយ ដែលកើតឡើងហើយ ក៏ដល់នូវការអស់រលីងផង ។ បុគ្គលនោះធ្វើនូវការដឹងយ៉ាងនេះហើយ ក៏មិនសេពនូវប្រធាននៃសេចក្តីវិនាស ៦ យ៉ាងនៃភោគទាំងឡាយ ។ បុគ្គលធ្វើតណ្ហាវិនិច្ឆ័យ យ៉ាងនេះខ្លះ ។

អថវា កសិយា វា វណិជ្ជាយ វា គោរក្ខេន វា ឥស្សត្ថេន វា រាជបោរិសេន វា សិប្បញ្ញតរេន វា បដិបជ្ជតិ ។ ឯវម្បិ តណ្ហាវិនិច្ឆយំ ការេតិ ។

កថំ ទិដ្ឋិវិនិច្ឆយំ ការេតិ ។ ចក្ខុស្មឹ ឧប្បន្នេ ជានាតិ អត្តា មេ ឧប្បន្នោតិ ។ ចក្ខុស្មឹ អន្តរហិតេ ជានាតិ អត្តា មេ អន្តរហិតោ វិគតោ មេ អត្តាតិ ។ ឯវម្បិ ទិដ្ឋិវិនិច្ឆយំ ការេតិ ។ សោតស្មឹ ឃានស្មឹ ជិវ្ហាយ កាយស្មឹ រូបស្មឹ សទ្ទស្មឹ គន្ធស្មឹ រសស្មឹ ផោដ្ឋព្វស្មឹ ឧប្បន្នេ ជានាតិ អត្តា មេ ឧប្បន្នោតិ ។ ផោដ្ឋព្វស្មឹ អន្តរហិតេ ជានាតិ អត្តា មេ អន្តរហិតោ វិគតោ មេ អត្តាតិ ។ ឯវម្បិ ទិដ្ឋិវិនិច្ឆយំ ការេតិ ជនេតិ សញ្ជនេតិ និព្វត្តេតិ អភិនិព្វត្តេតិ ។

ជន្តូតិ សត្តោ នរោ មាណវោ ។បេ។ មនុជោតិ ។ លោកេតិ អបាយលោកេ ។បេ។ អាយតនលោកេតិ ។ វិនិច្ឆយំ កុរុតេ ជន្តុ លោកេ ។ តេនាហ ភគវា

សាតំ អសាតន្តិ យមាហុ លោកេ
តមូបនិស្សាយ បហោតិ ឆន្ទោ

មួយទៀត ជនប្រកបដោយកសិកម្មក្តី ពាណិជ្ជកម្មក្តី គោរក្ខកម្មក្តី សិល្បៈធ្នូក្តី ភាពអ្នកបំរើរាជការក្តី សិល្បៈណាមួយក្តី ។ បុគ្គលធ្វើតណ្ហាវិនិច្ឆ័យ យ៉ាងនេះខ្លះ ។

ជនធ្វើទិដ្ឋិវិនិច្ឆ័យ តើដូចម្តេច ។ កាលចក្ខុកើតហើយ បុគ្គលដឹងថា ខ្លួនអាត្មាអញកើតហើយ ។ កាលចក្ខុវិនាសហើយ បុគ្គលក៏ដឹងថា ខ្លួនអាត្មាអញវិនាសហើយ ខ្លួនអាត្មាអញទៅប្រាសហើយ ។ ជនធ្វើទិដ្ឋិវិនិច្ឆ័យ យ៉ាងនេះខ្លះ ។ កាលត្រចៀក ច្រមុះ អណ្តាត កាយ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ កើតហើយ បុគ្គលក៏ដឹងថាខ្លួនអាត្មាអញកើតហើយ ។ កាលផោដ្ឋព្វៈវិនាសហើយ បុគ្គលក៏ដឹងថា ខ្លួនអាត្មាអញវិនាសហើយ ខ្លួនអាត្មាអញទៅប្រាសហើយ ។ បុគ្គលធ្វើឲ្យកើត ឲ្យកើតព្រម ឲ្យលេចឡើង ឲ្យលេចឡើងចំពោះ នូវទិដ្ឋិវិនិច្ឆ័យ យ៉ាងនេះខ្លះ ។

ពាក្យថា ជន គឺសត្វ នរៈ មាណព ។ បេ ។ សត្វកើតអំពីមនុស្ស ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។ បេ ។ អាយតនលោក ហេតុនោះ (ទ្រង់ត្រាស់ថា) ជនក្នុងលោក ធ្វើនូវវិនិច្ឆ័យ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ជនទាំងឡាយ ពោលនូវធម្មជាតណាថា ត្រូវចិត្តនិងមិនត្រូវចិត្ត
ក្នុងលោក ឆន្ទៈកើតឡើង អាស្រ័យ នូវធម្មជាតនោះ

ឯកាទសមោ កលហវិវាទសុត្តនិទ្ទេសោ

រូបេសុ ទិស្វា វិភវំ ភវញ្ច
វិនិច្ឆយំ កុព្វតេ ជន្តុ លោកេតិ ។

(១៨២) កោធោ មោសវជ្ជញ្ច កថំកថា ច
ឯតេបិ ធម្មា ទ្វយមេវ សន្តេ
កថំកថី ញាណបថាយ សិក្ខេ
ញត្វា បវុត្តា សមណេន ធម្មា ។

(១៨៣) កោធោ មោសវជ្ជញ្ច កថំកថា ចាតិ កោធោតិ យោ ចិត្តស្ស អាឃាតោ បដិឃាតោ ។បេ។ មោសវជ្ជំ វុច្ចតិ មុសាវាទោ ។ កថំកថា វុច្ចតិ វិចិកិច្ឆា ។ ឥដ្ឋំ វត្ថុំ និស្សាយបិ កោធោ ជាយតិ ។ អនិដ្ឋំ វត្ថុំ និស្សាយបិ កោធោ ជាយតិ ។ ឥដ្ឋំ វត្ថុំ និស្សាយបិ មុសាវាទោ ឧប្បជ្ជតិ ។ អនិដ្ឋំ វត្ថុំ និស្សាយបិ មុសាវាទោ ឧប្បជ្ជតិ ។ ឥដ្ឋំ វត្ថុំ និស្សាយបិ កថំកថា ឧប្បជ្ជតិ ។ អនិដ្ឋំ វត្ថុំ និស្សាយបិ កថំកថា ឧប្បជ្ជតិ ។

ជនក្នុងលោកឃើញ នូវសេចក្តីវិនាសនិងសេចក្តីចំរើន ក្នុងរូបទាំងឡាយហើយ ក៏ធ្វើនូវវិនិច្ឆ័យ ។

(១៥២) កាលធម្មជាតទាំងពីរ គឺឆ្ងាញ់និងមិនឆ្ងាញ់ មាន ទើបធម៌ទាំងនេះ គឺសេចក្តីក្រោធ ១ ការពោលពាក្យកុហក ១ សេចក្តីសង្ស័យ ១ (ក៏កើតឡើងដែរ) ជនអ្នកមានសេចក្តីសង្ស័យ គប្បីសិក្សា តាមគន្លងញាណ ជាធម៌ដែលសមណៈជ្រាបហើយពោល ។

(១៥២) អធិប្បាយពាក្យថា សេចក្តីក្រោធ១ ការពោលពាក្យកុហក១ សេចក្តីសង្ស័យ ១ ត្រង់ពាក្យថា សេចក្តីក្រោធ បានដល់ការបង្អៀតបង្អល់ ការថ្ពាំងថ្ពាក់នៃចិត្ត ។ បេ ។ មុសាវាទ លោកហៅថា ការពោលពាក្យកុហក ។ វិចិកិច្ឆា លោកហៅថា សេចក្តីសង្ស័យ ។ សេចក្តីក្រោធកើត អាស្រ័យវត្ថុជាទីប្រាថ្នាក៏មាន ។ សេចក្តីក្រោធកើត អាស្រ័យវត្ថុមិនជាទីប្រាថ្នាក៏មាន ។ មុសាវាទកើត អាស្រ័យវត្ថុជាទីប្រាថ្នាក៏មាន ។ មុសាវាទកើត អាស្រ័យវត្ថុមិនជាទីប្រាថ្នាក៏មាន ។ សេចក្តីសង្ស័យកើត អាស្រ័យវត្ថុជាទីប្រាថ្នាក៏មាន ។ សេចក្តីសង្ស័យកើត អាស្រ័យវត្ថុមិនជាទីប្រាថ្នាក៏មាន ។

កថំ អនិដ្ឋំ វត្ថុំ និស្សាយ កោធោ ជាយតិ(១) ។ អនត្ថំ មេ អចរីតិ កោធោ ជាយតិ អនត្ថំ មេ ចរតីតិ កោធោ ជាយតិ អនត្ថំ មេ ចរិស្សតីតិ កោធោ ជាយតិ ។ បិយស្ស មេ មនាបស្ស អនត្ថំ អចរិ អនត្ថំ ចរតិ អនត្ថំ ចរិស្សតីតិ កោធោ ជាយតិ ។ អប្បិយស្ស មេ អមនាបស្ស អត្ថំ អចរិ អត្ថំ ចរតិ អត្ថំ ចរិស្សតីតិ កោធោ ជាយតិ ។ ឯវំ អនិដ្ឋំ វត្ថុំ និស្សាយ កោធោ ជាយតិ ។

កថំ ឥដ្ឋំ វត្ថុំ និស្សាយ កោធោ ជាយតិ ។ ឥដ្ឋវត្ថុអច្ឆិន្នសញ្ញិតោបិ កោធោ ជាយតិ អច្ឆិជ្ជន្តេបិ កោធោ ជាយតិ អច្ឆិន្នេបិ កោធោ ជាយតិ ។ ឥដ្ឋវត្ថុវិបរិណាមសញ្ញិតោបិ កោធោ ជាយតិ វិបរិណាមន្តេបិ កោធោ ជាយតិ វិបរិណតេបិ

---

១ ម. ឯត្ថន្តរេ បកតិយា អនិដ្ឋំ វត្ថុំ និស្សាយ កោធោ ជាយតីតិ ទិស្សតិត្តិ ។

ក្រោធកើត អាស្រ័យវត្ថុមិនជាទីប្រាថ្នា តើដូចម្តេច ។ ក្រោធកើត ដោយគិតថា គេបានប្រព្រឹត្តនូវហេតុមិនជាប្រយោជន៍ដល់អញ ក្រោធកើតដោយគិតថា គេកំពុងប្រព្រឹត្តនូវហេតុមិនជាប្រយោជន៍ដល់អញ ក្រោធកើត ដោយគិតថា គេនឹងប្រព្រឹត្តនូវហេតុមិនជាប្រយោជន៍ដល់អញ ។ ក្រោធកើត ដោយគិតថា គេបានប្រព្រឹត្តនូវហេតុមិនជាប្រយោជន៍ កំពុងប្រព្រឹត្តនូវហេតុមិនជាប្រយោជន៍ នឹងប្រព្រឹត្តនូវហេតុមិនជាប្រយោជន៍ ដល់បុគ្គលដែលជាទីស្រឡាញ់ ជាទីពេញចិត្តរបស់អញ ។ ក្រោធកើត ដោយគិតថា គេបានប្រព្រឹត្តនូវហេតុជាប្រយោជន៍ កំពុងប្រព្រឹត្តនូវហេតុជាប្រយោជន៍ នឹងប្រព្រឹត្តនូវហេតុជាប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អញ ។ ក្រោធកើត អាស្រ័យវត្ថុមិនជាទីប្រាថ្នា យ៉ាងនេះឯង ។

ក្រោធកើត អាស្រ័យវត្ថុជាទីប្រាថ្នា តើដូចម្តេច ។ កាលបុគ្គលមានសេចក្តីរង្កៀស ក្នុងការដណ្តើម នូវវត្ថុជាទីប្រាថ្នា ក្រោធកើត ក៏មាន កាលត្រូវគេកំពុងដណ្តើម ក្រោធកើតក៏មាន កាលវត្ថុដែលត្រូវគេដណ្តើមហើយ ក្រោធកើត ក៏មាន ។ កាលបុគ្គលមានសេចក្តីអង្កៀស ក្នុងការប្រែប្រួល ចាកវត្ថុជាទីប្រាថ្នា ក្រោធកើតក៏មាន កាលវត្ថុដែលកំពុងប្រែប្រួល ក្រោធកើតក៏មាន

កោធោ ជាយតិ ។ ឯវំ ឥដ្ឋំ វត្ថុំ និស្សាយ កោធោ ជាយតិ ។

កថំ អនិដ្ឋំ វត្ថុំ និស្សាយ មុសាវាទោ ឧប្បជ្ជតិ ។ ឥធេកច្ចោ អន្ទុពន្ធនេន វា ពទ្ធោ តស្ស ពន្ធនស្ស មោក្ខត្ថាយ សម្បជានមុសា ភាសតិ ។ រជ្ជុពន្ធនេន វា ពទ្ធោ ។ សង្ខលិកពន្ធនេន វា ពទ្ធោ ។ វេត្តពន្ធនេន វា ពទ្ធោ ។ លតាពន្ធនេន វា ពទ្ធោ ។ បរិក្ខេបពន្ធនេន(១) វា ពទ្ធោ ។ គាមនិគមនគរពន្ធនេន(២) វា ពទ្ធោ ។ ជនបទពន្ធនេន វា ពទ្ធោ តស្ស ពន្ធនស្ស មោក្ខត្ថាយ សម្បជានមុសា ភាសតិ ។ ឯវំ អនិដ្ឋំ វត្ថុំ និស្សាយ មុសាវាទោ ឧប្បជ្ជតិ ។

កថំ ឥដ្ឋំ វត្ថុំ និស្សាយ មុសាវាទោ ឧប្បជ្ជតិ ។ ឥធេកច្ចោ មនាបិកានំ រូបានំ ហេតុ សម្បជានមុសា ភាសតិ ។ មនាបិកានំ សទ្ទានំ គន្ធានំ រសានំ ផោដ្ឋព្វានំ ហេតុ ចីវរហេតុ បិណ្ឌបាតហេតុ សេនាសនហេតុ

---

១ ម. បក្ខេបពន្ធនេន វា ពទ្ធោ ។ បរិក្ខេបពន្ធនេន ។ ២ ឱ. ម. គាមនិគមនគររដ្ឋពន្ធនេន ។

កាលវត្ថុដែលប្រែប្រួលហើយ ក្រោធកើតក៏មាន ។ ក្រោធកើតអាស្រ័យវត្ថុជាទីប្រាថ្នា យ៉ាងនេះឯង ។

មុសាវាទ កើត អាស្រ័យវត្ថុមិនជាទីប្រាថ្នា តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាប់ដោយចំណងគឺខ្នោះ ហើយពោលមុសាទាំងដឹងខ្លួន ដើម្បីរួចចាកចំណងនោះខ្លះ ។ ជាប់ដោយចំណងគឺខ្សែខ្លះ ។ ជាប់ដោយចំណងគឺច្រវាក់ខ្លះ ។ ជាប់ដោយចំណងគឺផ្តៅខ្លះ ។ ជាប់ដោយចំណងគឺវល្លិខ្លះ ។ ជាប់ដោយចំណងគឺរបងខ្លះ ។ ជាប់ដោយចំណងគឺស្រុក និគម នគរខ្លះ ។ ជាប់ដោយចំណងគឺជនបទខ្លះ ពោលមុសាទាំងដឹងខ្លួន ដើម្បីរួចចាកចំណងនោះ ។ មុសាវាទកើត អាស្រ័យវត្ថុមិនជាទីប្រាថ្នា យ៉ាងនេះឯង ។

មុសាវាទកើត អាស្រ័យវត្ថុជាទីប្រាថ្នា តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ និយាយកុហកទាំងដឹងខ្លួន ព្រោះហេតុនៃរូបជាទីពេញចិត្ត ។ និយាយកុហកទាំងដឹងខ្លួន ព្រោះហេតុនៃសំឡេង ខ្លិន រស ផោដ្ឋព្វៈ ជាទីពេញចិត្ត ព្រោះហេតុនៃចីវរ ព្រោះហេតុនៃបិណ្ឌបាត

គិលានប្បច្ចយភេសជ្ជបរិក្ខារហេតុ សម្បជានមុសា ភាសតិ ។ ឯវំ ឥដ្ឋំ វត្ថុំ និស្សាយ មុសាវាទោ ឧប្បជ្ជតិ ។

កថំ អនិដ្ឋំ វត្ថុំ និស្សាយ កថំកថា ឧប្បជ្ជតិ ។ មុច្ចិស្សាមិ នុ ខោ ចក្ខុរោគតោ ន នុ ខោ មុច្ចិស្សាមិ ចក្ខុរោគតោ មុច្ចិស្សាមិ នុ ខោ សោតរោគតោ ឃានរោគតោ ជិវ្ហារោគតោ កាយរោគតោ សីសរោគតោ កណ្ណរោគតោ មុខរោគតោ មុច្ចិស្សាមិ នុ ខោ ទន្តរោគតោ ន នុ ខោ មុច្ចិស្សាមិ ទន្តរោគតោតិ ។ ឯវំ អនិដ្ឋំ វត្ថុំ និស្សាយ កថំកថា ឧប្បជ្ជតិ ។

កថំ ឥដ្ឋំ វត្ថុំ និស្សាយ កថំកថា ឧប្បជ្ជតិ ។ លភិស្សាមិ នុ ខោ មនាបិកេ(១) រូបេ ន នុ ខោ លភិស្សាមិ មនាបិកេ(២) រូបេ លភិស្សាមិ នុ ខោ មនាបិកេ(៣) សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ កុលំ គណំ អាវាសំ លាភំ យសំ បសំសំ សុខំ ចីវរំ បិណ្ឌបាតំ សេនាសនំ គិលានប្បច្ចយភេសជ្ជបរិក្ខារន្តិ ។ ឯវំ ឥដ្ឋំ វត្ថុំ និស្សាយ កថំកថា ឧប្បជ្ជតីតិ កោធោ មោសវជ្ជញ្ច កថំកថា ច ។

---

១-២. ៣ ម. មនាបិយេ ។

ព្រោះហេតុនៃសេនាសនៈ ព្រោះហេតុនៃគិលានប្បច្ច័យភេសជ្ជបរិក្ខារ ។ មុសាវាទកើត អាស្រ័យវត្ថុជាទីប្រាថ្នា យ៉ាងនេះឯង ។

សេចក្តីសង្ស័យ កើត អាស្រ័យវត្ថុមិនជាទីប្រាថ្នា តើដូចម្តេច ។ បុគ្គលគិតថា អញនឹងរួចអំពីចក្ខុរោគឬ ឬនឹងមិនរួចអំពីចក្ខុរោគទេ អញនឹងរួចអំពីសោតរោគ ឃានរោគ ជិវ្ហារោគ កាយរោគ សីសរោគ កណ្ណរោគ មុខរោគ អញនឹងរួចអំពីទន្តរោគឬ ឬនឹងមិនរួចអំពីទន្តរោគទេៗ សេចក្តីសង្ស័យកើត អាស្រ័យវត្ថុមិនជាទីប្រាថ្នា យ៉ាងនេះឯង ។

សេចក្តីសង្ស័យ កើត អាស្រ័យវត្ថុជាទីប្រាថ្នា តើដូចម្តេច ។ បុគ្គលគិតថា អញនឹងបានរូបទាំងឡាយ ជាទីពេញចិត្តឬ ឬនឹងមិនបានរូបទាំងឡាយ ជាទីពេញចិត្តទេ អញនឹងបានសំឡេងទាំងឡាយ ក្លិនទាំងឡាយ រសទាំងឡាយ ផោដ្ឋព្វៈទាំងឡាយ ត្រកូល ពួក អាវាស លាភ យស សេចក្តីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ ជាទីពេញចិត្ត ឬហ៎ ៗ សេចក្តីសង្ស័យកើត អាស្រ័យវត្ថុជាទីប្រាថ្នា យ៉ាងនេះឯង ហេតុនោះ (ទ្រង់ត្រាស់ថា) សេចក្តីក្រោធ ១ ការពោលពាក្យកុហក ១ សេចក្តីសង្ស័យ ១ ។

(១៥៤) ឯតេបិ ធម្មា ទ្វយមេវ សន្តេតិ សាតាសាតេ សន្តេ សុខទុក្ខេ សន្តេ សោមនស្សទោមនស្សេ សន្តេ ឥដ្ឋានិដ្ឋេ សន្តេ អនុនយប្បដិឃេ សន្តេ សំវិជ្ជមានេ[1]ឧបលព្ភិយមានេតិ ឯតេបិ ធម្មា ទ្វយមេវ សន្តេ ។

(១៥៥) កថំកថី ញាណបថាយ សិក្ខេតិ ញាណម្បិ ញាណបថោ ញាណស្ស អារម្មណម្បិ ញាណបថោ ញាណសហភុនោបិ ធម្មា ញាណបថោ ។ យថា អរិយមគ្គោ អរិយបថោ ទេវមគ្គោ ទេវបថោ ព្រហ្មមគ្គោ ព្រហ្មបថោ ឯវមេវ ញាណម្បិ ញាណបថោ ញាណស្ស អារម្មណម្បិ ញាណបថោ ញាណសហភុនោបិ ធម្មា ញាណបថោ ។ សិក្ខេតិ តិស្សោ សិក្ខា អធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។

កតមា អធិសីលសិក្ខា ។ ឥធ ភិក្ខុ សីលវា ហោតិ

---

១ ម. ឯត្ថន្តរេ អត្ថីតិ ទិស្សតិ ។

កលហវិវាទសុត្តនិទ្ទេស ទី ១១

(១៩៤) ពាក្យថា កាលបើធម៌ទាំងពីរមាន ធម៌ទាំងឡាយនុ៎ះ សេចក្តីថា កាលបើវត្ថុជាទីត្រេកអរ នឹងមិនជាទីត្រេកអរមាន កាលបើសុខ នឹងទុក្ខមាន កាលបើសោមនស្ស នឹងទោមនស្សមាន កាលបើវត្ថុជាទីប្រាថ្នានឹងមិនជាទីប្រាថ្នាមាន កាលបើតម្រេកនឹងសេចក្តីបង្អៀតបង្អល់មាន មានគ្រប់គ្រាន់ បុគ្គលបាន ហេតុនោះ (ទ្រង់ត្រាស់ថា) កាលបើធម៌ទាំងពីរមាន ធម៌ទាំងឡាយនុ៎ះ ។

(១៩៥) ពាក្យថា ជនអ្នកមានសេចក្តីសង្ស័យ គប្បីសិក្សាតាមគន្លងញាណ អធិប្បាយថា ញាណ ឈ្មោះថា គន្លងញាណ អារម្មណ៍របស់ញាណ ក៏ឈ្មោះថា គន្លងញាណ ពួកធម៌កើតជាមួយនឹងញាណ ក៏ឈ្មោះថា គន្លងញាណ ។ ផ្លូវដ៏ប្រសើរ ឈ្មោះថា គន្លងដ៏ប្រសើរ ផ្លូវដ៏ត្រកាល ឈ្មោះថា គន្លងដ៏ត្រកាល ផ្លូវដ៏ខ្ពង់ខ្ពស់ ឈ្មោះថា គន្លងដ៏ខ្ពង់ខ្ពស់ យ៉ាងណាមិញ ញាណ ក៏ឈ្មោះថា គន្លងញាណ អារម្មណ៍របស់ញាណ ក៏ឈ្មោះថា គន្លងញាណ ពួកធម៌កើតជាមួយនឹងញាណ ក៏ឈ្មោះថា គន្លងញាណ យ៉ាងនោះដែរ ។ ពាក្យថា គប្បីសិក្សា បានដល់សិក្ខា ៣ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។

អធិសីលសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល

បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ខុទ្ទកោ សីលក្ខន្ធោ មហន្តោ សីល-ក្ខន្ធោ សីលំ បតិដ្ឋា អាទិ ចរណំ សំយមោ សំវរោ មុខំ បមុខំ កុសលានំ ធម្មានំ សមាបត្តិយា អយំ អធិ-សីលសិក្ខា ។

កតមា អធិចិត្តសិក្ខា ។ ឥធ ភិក្ខុ វិវិច្ចេវ កា-មេហិ ។បេ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ អធិចិត្តសិក្ខា ។

កតមា អធិបញ្ញាសិក្ខា ។ ឥធ ភិក្ខុ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។បេ។ អយំ ទុក្ខនិរោ-ធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឥមេ អាសវាតិ យថាភូតំ បជានាតិ ។បេ។ អយំ អាសវនិរោធគាមិនី-បដិបទាតិ យថាភូតំ បជានាតិ អយំ អធិបញ្ញាសិក្ខា ។

សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញភ័យចំពោះទោសទាំងឡាយ បន្តិចបន្តួច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ សីលក្ខន្ធតូច សីលក្ខន្ធធំ សីល ទីតំកល់ ទីខាងដើម ការប្រព្រឹត្តិ ការប្រយ័ត្ន ការសង្រួម ប្រធាន ប្រមុខ នៃការចួបប្រសព្វ នូវកុសលធម៌ទាំងឡាយ នេះ អធិសីលសិក្ខា ។

អធិចិត្តសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន នេះ អធិចិត្តសិក្ខា ។

អធិប្បញ្ញាសិក្ខា តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ដែលទៅក្នុងការកើតឡើងនិងវិនាស ជាបញ្ញាដ៏ប្រសើរ អាចទំលុះទំលាយ (នូវកិលេស) ជាគ្រឿងដល់នូវការអស់ទុក្ខដោយប្រពៃ ភិក្ខុនោះ ដឹងច្បាស់តាមពិតថា នេះទុក្ខ ។ បេ ។ ដឹងច្បាស់តាមពិតថា នេះ ទុក្ខនិរោធគាមិនីបដិបទា ដឹងច្បាស់តាមពិតថា នេះអាសវៈទាំងឡាយ ។ បេ ។ ដឹងច្បាស់តាមពិតថា នេះអាសវនិរោធគាមិនីបដិបទា នេះ អធិប្បញ្ញាសិក្ខា ។

កថំកថី ញាណបថាយ សិក្ខេតិ កថំកថី បុគ្គលោ សកង្ខោ សវិលេខោ សទ្វេឡ្ហកោ សវិចិកិច្ឆោ ញាណាធិគមាយ ញាណផុសនាយ ញាណសច្ឆិកិរិយាយ អធិសីលម្បិ សិក្ខេយ្យ អធិចិត្តម្បិ សិក្ខេយ្យ អធិបញ្ញម្បិ សិក្ខេយ្យ ។ ឥមា តិស្សោ សិក្ខា អាវជ្ជេន្តោ សិក្ខេយ្យ ជានន្តោ សិក្ខេយ្យ បស្សន្តោ សិក្ខេយ្យ បច្ចវេក្ខន្តោ សិក្ខេយ្យ ចិត្តំ អធិដ្ឋហន្តោ សិក្ខេយ្យ សទ្ធាយ អធិមុច្ចន្តោ សិក្ខេយ្យ វីរិយំ បគ្គណ្ហន្តោ សិក្ខេយ្យ សតឹ ឧបដ្ឋហន្តោ សិក្ខេយ្យ ចិត្តំ សមាទហន្តោ សិក្ខេយ្យ បញ្ញាយ បជានន្តោ សិក្ខេយ្យ អភិញ្ញេយ្យំ អភិជានន្តោ សិក្ខេយ្យ បរិញ្ញេយ្យំ បរិជានន្តោ សិក្ខេយ្យ បហាតព្វំ បជហន្តោ សិក្ខេយ្យ ភាវេតព្វំ ភាវេន្តោ សិក្ខេយ្យ សច្ឆិកាតព្វំ សច្ឆិករោន្តោ សិក្ខេយ្យ អាចរេយ្យ សមាចរេយ្យ សមាទាយ វត្តេយ្យាតិ កថំកថី ញាណបថាយ សិក្ខេ ។

## កលហវិវាទសុត្តនិទ្ទេស ទី ១១

ពាក្យថា ជនអ្នកមានសេចក្តីសង្ស័យ គប្បីសិក្សាតាមគន្លងញាណ សេចក្តីថា បុគ្គលអ្នកសង្ស័យ មានសេចក្តីងឿងឆ្ងល់ មានស្មារតីទូស (ក្នុងចិត្ត) មានផ្លូវបែកជាពីរ មានវិចិកិច្ឆា គប្បីសិក្សាអធិសីលផង គប្បីសិក្សាអធិចិត្តផង គប្បីសិក្សាអធិប្បញ្ញាផង ដើម្បីបានញាណ ដើម្បីពាល់ត្រូវញាណ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវញាណ ។ គប្បីរំពឹងសិក្សាសិក្ខាទាំង ៣ នេះ គប្បីដឹងសិក្សា គប្បីឃើញសិក្សា គប្បីពិចារណាសិក្សា គប្បីតាំងចិត្តសិក្សា គប្បីចុះចិត្តស៊ប់ក្នុងសទ្ធាសិក្សា គប្បីផ្គងវីរិយៈសិក្សា គប្បីតម្កល់សតិសិក្សា គប្បីតាំងចិត្តសិក្សា គប្បីដឹងច្បាស់ដោយប្រាជ្ញាសិក្សា គប្បីដឹងធម៌ដែលគួរដឹងសិក្សា គប្បីកំណត់ធម៌ដែលគួរកំណត់សិក្សា គប្បីលះបង់ធម៌ដែលគួរលះបង់សិក្សា គប្បីចំរើនធម៌ដែលគួរចំរើនសិក្សា គប្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់សិក្សា ប្រព្រឹត្តទូទៅ ប្រព្រឹត្តដោយល្អ ប្រព្រឹត្តដឿកាន់ ហេតុនោះ (ទ្រង់ត្រាស់ថា) ជនអ្នកមានសេចក្តីសង្ស័យ គប្បីសិក្សាតាមគន្លងញាណ ។

(១៩៦) ញត្វា បវុត្តា សមណេន ធម្មាតិ ញត្វា(១) ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា វុត្តា បវុត្តា អាចិក្ខិតា ទេសិតា បញ្ញបិតា បដ្ឋបិតា វិវដា វិភត្តា ឧត្តានីកតា បកាសិតា ។ សព្វេ សង្ខារា អនិច្ចាតិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា វុត្តា បវុត្តា អាចិក្ខិតា ទេសិតា បញ្ញបិតា បដ្ឋបិតា វិវដា វិភត្តា ឧត្តានីកតា បកាសិតា ។ សព្វេ សង្ខារា ទុក្ខាតិ ។ សព្វេ ធម្មា អនត្តាតិ ។ អវិជ្ជាបច្ចយា សង្ខារា ។បេ។ ជាតិបច្ចយា ជរាមរណន្តិ ។ អវិជ្ជានិរោធា សង្ខារនិរោធោ ។បេ។ ជាតិនិរោធា ជរាមរណនិរោធោតិ ។ ឥទំ ទុក្ខន្តិ ។បេ។ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ ។ ឥមេ អាសវាតិ ។បេ។ អយំ អាសវនិរោធគាមិនីបដិបទាតិ ។ ឥមេ ធម្មា អភិញ្ញេយ្យាតិ ។ ឥមេ ធម្មា បរិញ្ញេយ្យាតិ ។ ឥមេ ធម្មា បហាតព្វាតិ ។ ឥមេ ធម្មា ភាវេតព្វាតិ ។

---

១ ម. ញត្វាតិ ញត្វា ។

(១៨៦) ពាក្យថា ជាធម៌ដែលសមណៈជ្រាប ហើយពោល សេចក្តីថា ធម៌ទាំងឡាយ ដែលព្រះអង្គជ្រាប ស្គាល់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដ ពោល ពោលទូទៅ ប្រាប់ សំដែង បញ្ញត្ត តម្កល់ទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាសទុកហើយ ។ ធម៌ទាំងឡាយដែលព្រះអង្គជ្រាប ស្គាល់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដ ពោល ពោលទូទៅ ប្រាប់ សំដែង បញ្ញត្ត តម្កល់ទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាសទុកហើយថា សង្ខារទាំងពួងមិនទៀង ។ ថា សង្ខារទាំងពួងជាទុក្ខ ។ ថា ធម៌ទាំងពួងជាអនត្តា ។ ថា សង្ខារទាំងឡាយ (កើតមាន) ព្រោះអវិជ្ជាជាបច្ច័យ ។បេ។ ជរាមរណៈ (កើតមាន) ព្រោះជាតិជាបច្ច័យ ។ ថា ការរលត់សង្ខារ ព្រោះការរលត់អវិជ្ជា ។បេ។ ការរលត់ជរាមរណៈ ព្រោះការរលត់ជាតិ ។ ថា នេះជាទុក្ខ ។បេ។ នេះ ទុក្ខនិរោធគាមិនីបដិបទា ។ ថា នេះ អាសវៈ ។បេ។ នេះ អាសវនិរោធគាមិនីបដិបទា ។ ថា នេះពួកធម៌ដែលគួរត្រាស់ដឹង ។ ថា នេះពួកធម៌ដែលគួរកំណត់ដឹង ។ ថា នេះពួកធម៌ដែលគួរលះ ។ ថា នេះពួកធម៌ដែលគួរចំរើន ។

ឯកាទសមោ កលហវិវាទសុត្តនិទ្ទេសោ

ឥមេ ធម្មា សច្ចិកាតព្វាតិ ។ ឆន្នំ ផស្សាយ-
តនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច
និស្សរណញ្ច បញ្ចន្នំ ឧបាទានក្ខន្ធានំ ចតុន្នំ មហា-
ភូតានំ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ញត្វា
ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា
វុត្តា បវុត្តា អាចិក្ខិតា ទេសិតា បញ្ញបិតា បដ្ឋបិតា វិវដា
វិភត្តា ឧត្តានីកតា បកាសិតា ។ វុត្តំ ហេតំ ភគវតា
អភិញ្ញាយាហំ ភិក្ខវេ ធម្មំ ទេសេមិ នោ អនភិញ្ញាយ
សនិទានាហំ ភិក្ខវេ ធម្មំ ទេសេមិ នោ អនិទានំ សប្បា-
ដិហារិយាហំ ភិក្ខវេ ធម្មំ ទេសេមិ នោ អប្បាដិហារិយំ
តស្ស មយ្ហំ ភិក្ខវេ អភិញ្ញាយ ធម្មំ ទេសយតោ នោ
អនភិញ្ញាយ សនិទានំ ធម្មំ ទេសយតោ នោ អនិ-
ទានំ សប្បាដិហារិយំ ធម្មំ ទេសយតោ នោ អប្បាដិហា-
រិយំ ករណីយោ ឱវាទោ ករណីយា អនុសាសនី

## កលហវិវាទសុត្តនិទ្ទេស ទី ១១

ថា នេះពួកធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ៗ ធម៌ទាំងឡាយ ដែលព្រះអង្គជ្រាប ស្គាល់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដ ពោល ពោលទូទៅ ប្រាប់ សំដែង បញ្ញត្ត តម្កល់ទុក បើក បែក ធ្វើឲ្យរាក់ ប្រកាសទុកហើយថា ( តថាគតដឹងច្បាស់ ) នូវហេតុជាទីកើតឡើងផង សេចក្ដីវិនាសផង អានិសង្សផង ទោសផង ការរលាស់ចេញនូវផស្សាយតនៈទាំង ៦ ផង បណ្ដាឧបាទានក្ខន្ធទាំង ៥ មហាភូតរូបទាំង ៤ វត្ថុណាមួយ មានកិរិយាកើតឡើងជាធម្មតា វត្ថុទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ៗ ពិតណាស់ ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងធម៌ ដើម្បីត្រាស់ដឹង មិនមែនសំដែងដើម្បីមិនឲ្យត្រាស់ដឹងទេ ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងធម៌ប្រកបដោយហេតុ មិនមែនសំដែងឥតហេតុទេ ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងធម៌ប្រកបដោយបាដិហារ្យ (ធម៌ជាគ្រឿងស្រោចស្រង់) មិនមែនសំដែងឥតបាដិហារ្យទេ ម្នាលភិក្ខុទាំងឡាយ កាលតថាគតនោះ សំដែងធម៌ដើម្បីត្រាស់ដឹង មិនសំដែងដើម្បីមិនត្រាស់ដឹងទេ កាលតថាគតសំដែងធម៌ប្រកបដោយហេតុ មិនសំដែងឥតហេតុ កាលតថាគតសំដែងធម៌ ប្រកបដោយបាដិហារ្យ មិនសំដែងឥតបាដិហារ្យ ឱវាទបុគ្គលគួរធ្វើ អនុសាសនី ក៏បុគ្គលគួរធ្វើ

អលញ្ច បន តេ កិច្ចាយ តុដ្ឋិយា អលំ ទាមោជ្ជាយ អលំ សោមនស្សាយ សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ធម្មោ សុប្បដិបន្នោ សង្ឃោតិ ។ ឥមស្មិំ ច បន វេយ្យាករណស្មិំ ភញ្ញមានេ ទសសហស្សី លោកធាតុ អកម្បិត្ថាតិ ញត្វា បវុត្តា សមណេន ធម្មា ។ តេនាហ ភគវា

កោធោ មោសវជ្ជញ្ច កថំកថា ច
ឯតេបិ ធម្មា ទ្វយមេវ សន្តេ ។
កថំកថី ញាណបថាយ សិក្ខេ
ញត្វា បវុត្តា សមណេន ធម្មាតិ ។

(១៤៧) សាតំ អសាតញ្ច កុតោនិទានា
កិស្មិំ អសន្តេ ន ភវន្តិ ហេតេ
វិភវំ ភវញ្ចាបិ យមេតមត្ថំ
ឯតម្មេ បព្រូហិ យតោនិទានំ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរតែក្រេកអរ គួរតែរីករាយ គួរតែសោមនស្សថា ព្រះមានព្រះភាគ ព្រះអង្គត្រាស់ដឹងដោយប្រពៃ ព្រះធម៌ព្រះមានព្រះភាគសំដែងដោយប្រពៃ ព្រះសង្ឃប្រតិបត្តិហើយដោយប្រពៃ ។ កាលវេយ្យាករណ៍នេះ ដែលព្រះអង្គសំដែង លោកធាតុទាំងមួយហ្មឺនក៏កម្រើកញាប់ញ័រ ហេតុនោះ (ទ្រង់ត្រាស់ថា) ជាធម៌ដែលសមណៈជ្រាបហើយពោល ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

កាលធម្មជាតទាំងពីរ គឺឆ្មាញ់នឹងមិនឆ្មាញ់មាន ធម៌ទាំងនេះគឺ សេចក្ដីក្រោធ១ ការពោលពាក្យកុហក១ សេចក្ដីសង្ស័យ ១ (ក៏កើតមានដែរ) ជនអ្នកមានសេចក្ដីសង្ស័យ គប្បីសិក្សាតាមគន្លងញាណ ជាធម៌ដែលសមណៈជ្រាបហើយពោល ។

[១៩៧] (ព្រះពុទ្ធនិម្មិតសួរថា) សេចក្ដីត្រេកអរនឹងមិនត្រេកអរ មានអ្វីជាហេតុ កាលបើអ្វីមិនមាន ទើបធម៌ទាំងនុ៎ះមិនមាន សេចក្ដីណា គឺការវិនាស នឹងការចំរើន សូមព្រះអង្គសំដែងប្រាប់ខ្ញុំ នូវសេចក្ដីនុ៎ះ ថាមានវត្ថុណាជាហេតុ ។

## ឯកាទសមោ កលហវិវាទសុត្តនិទ្ទេសោ

(១៥៨) សាតំ អសាតញ្ច កុតោនិទានាតិ សាតាសាតា កុតោនិទានា កុតោ ជាតា កុតោ សញ្ជាតា កុតោ និព្វត្តា កុតោ អភិនិព្វត្តា កុតោ បាតុភូតា កឹនិទានា កឹសមុទយា កឹជាតិកា កឹបភវាតិ សាតាសាតានំ មូលំ បុច្ឆតិ ។ បេ ។ សមុទយំ បុច្ឆតិ បបុច្ឆតិ យាចតិ អជ្ឈេសតិ បសាទេតីតិ សាតំ អសាតញ្ច កុតោនិទានា ។

(១៥៩) កិស្មឹ អសន្តេ ន ភវន្តិ ហេតេតិ កិស្មឹ អសន្តេ អសំវិជ្ជមានេ[១] អនុបលព្ភិយមានេ សាតាសាតា ន ភវន្តិ នប្បភវន្តិ ន ជាយន្តិ ន សញ្ជាយន្តិ ន និព្វត្តន្តិ នាភិនិព្វត្តន្តីតិ កិស្មឹ អសន្តេ ន ភវន្តិ ហេតេ ។

(១៦០) វិភវំ ភវញ្ចាបិ យមេតមត្ថន្តិ កតមោ សាតាសាតានំ ភវោ ។ យោ សាតាសាតានំ ភវោ សម្ភវោ[២] ជាតិ សញ្ជាតិ និព្វត្តិ អភិនិព្វត្តិ បាតុភាវោ

---

១ ម. ឯត្ថន្តរេ នត្ថីតិ ទិស្សតិ ។ ២ ម. បភវោ ។

កលហវិវាទសុត្តនិទ្ទេស ទី ១១

[១៥៨] ពាក្យថា សេចក្ដីត្រេកអរនឹងមិនត្រេកអរ មានអ្វីជាហេតុ គឺព្រះពុទ្ធនិម្មិតសួររកឫសគល់ ។ បេ ។ សួររក សួរឈ្លបឈ្លើ សូមអាពធនា ហោទ ចំពោះហេតុជាទីកើតឡើង នៃវេទនាជាទីត្រេកអរនឹងមិនជាទីត្រេកអរថា វេទនាជាទីត្រេកអរនឹងមិនជាទីត្រេកអរ មានអ្វីជាហេតុ កើតអំពីណា កើតព្រមអំពីណា ផ្សួបផ្ដើមអំពីណា កើតចំពោះឡើងអំពីណា កើតប្រាកដអំពីណា មានអ្វីជាហេតុ មានអ្វីជាដែនប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ហេតុនោះ (ទ្រង់ត្រាស់សួរថា) សេចក្ដីត្រេកអរនឹងមិនត្រេកអរ មានអ្វីជាហេតុ ។

[១៥៩] ពាក្យថា កាលបើអ្វីមិនមាន ធម៌ទាំងនុះមិនមាន គឺកាលបើអ្វីមិនមាន មិនមានសព្វគ្រប់ ដែលបុគ្គលមិនបាន ទើបវេទនាជាទីត្រេកអរនឹងមិនជាទីត្រេកអរមិនមាន មិនមានប្រាកដ មិនកើត មិនកើតព្រម មិនផ្សួបផ្ដើម មិនកើតចំពោះ ហេតុនោះ (ទ្រង់ត្រាស់សួរថា) កាលបើអ្វីមិនមាន ធម៌ទាំងនុះមិនមាន ។

[១៦០] ពាក្យថា សេចក្ដីណា គឺការវិនាស នឹងការចំរើន អធិប្បាយថា សេចក្ដីចំរើន នៃវេទនាជាទីត្រេកអរ នឹងមិនជាទីត្រេកអរ តើដូចម្ដេច ។ សេចក្ដីចំរើន ការដុះដាល កិរិយាកើត កិរិយាកើតព្រម កិរិយាផ្សួបផ្ដើម កិរិយាកើតចំពោះ កិរិយាកើតប្រាកដ នៃវេទនាជាទីត្រេកអរ នឹងមិនជាទីត្រេកអរ ឯណា

អយំ សាតាសាតានំ ភវេ ។ កតមោ សាតាសាតានំ វិភវេ ។ យោ សាតាសាតានំ ខយោ វយោ ភេទោ បរិភេទោ អនិច្ចតា អន្តរធានំ អយំ សាតាសាតានំ វិភវេ ។ យមេតមត្ថន្តិ យំ បរមត្ថន្តិ វិភវំ ករញ្ញាមិ យមេតមត្ថំ ។

(១៦១) ឯតម្មេ បព្រូហិ យតោនិទានន្តិ ឯតន្តិ យំ បុច្ឆាមិ យំ យាចាមិ យំ អជ្ឈេសាមិ យំ បសាទេមិ ។ បព្រូហីតិ ព្រូហិ អាចិក្ខ ទេសេហិ បញ្ញាបេហិ បដ្ឋបេហិ វិវរ វិភជ ឧត្តានីករោហិ បកាសេហីតិ ឯតម្មេ បព្រូហិ ។ យតោនិទានន្តិ យំនិទានំ យំសមុទយំ យំជាតិកំ យំបភវន្តិ ឯតម្មេ បព្រូហិ យតោនិទានំ ។ តេនាហ សោ និម្មិតោ

នេះឈ្មោះថា សេចក្ដីចំរើននៃវេទនាជាទីត្រេកអរនឹងមិនជាទីត្រេកអរ ។ សេចក្ដីវិនាសនៃវេទនាជាទីត្រេកអរ នឹងមិនជាទីត្រេកអរ តើដូចម្ដេច ។ ការអស់ ការសូន្យ ការបែកធ្លាយ ការខ្ចប់ខ្ចី ការមិនទៀង ការបាត់បង់ទៅ នៃវេទនាជាទីត្រេកអរនឹងមិនជាទីត្រេកអរ ឯណា នេះឈ្មោះថា សេចក្ដីវិនាសនៃវេទនាជាទីត្រេកអរនឹងមិនជាទីត្រេកអរ ។ ពាក្យថា សេចក្ដីណា គឺសេចក្ដីដទៃណា ហេតុនោះ (ទ្រង់ត្រាស់សួរថា) សេចក្ដីណា គឺការវិនាស នឹងការចំរើន ។

(១៦១) ពាក្យថា សូមព្រះអង្គសំដែងប្រាប់ខ្ញុំ នូវសេចក្ដីនុ៎ះ ថាមានវត្ថុណាជាហេតុ ត្រង់ពាក្យថា នុ៎ះ គឺខ្ញុំសួរគេសេចក្ដីណា ខ្ញុំសូមសេចក្ដីណា ខ្ញុំអារាធនាសេចក្ដីណា ខ្ញុំជ្រះថ្លាសេចក្ដីណា ។ ពាក្យថា សូមសំដែង គឺសូមពោល ប្រាប់ សំដែង បញ្ញត្ត តម្កល់ទុក បើក បែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ (ទ្រង់ត្រាស់សួរថា) សូមព្រះអង្គសំដែងប្រាប់ខ្ញុំ នូវសេចក្ដីនុ៎ះ ។ ពាក្យថា មានវត្ថុណាជាហេតុ គឺមានវត្ថុណាជាហេតុ មានវត្ថុណាជាដែនកើត មានវត្ថុណាជាកំណើត មានវត្ថុណាជាដែនកើតមុន ហេតុនោះ (ទ្រង់ត្រាស់សួរថា) សូមព្រះអង្គសំដែងប្រាប់ខ្ញុំ នូវសេចក្ដីនុ៎ះ ថាមានវត្ថុណាជាហេតុ ។ ហេតុនោះ ពុទ្ធនិម្មិតនោះ សួរថា

ឯកាទសមោ កលហវិវាទសុត្តនិទ្ទេសោ

សាតំ អសាតញ្ច កុតោនិទានា
កិស្មឹ អសន្តេ ន ភវន្តិ ហេតេ
វិភវំ ភវញ្ចាបិ យមេតមត្ថំ
ឯតំ មេ បព្រូហិ យតោនិទានន្តិ

(១៦២) ផស្សនិទានំ(១) សាតំ អសាតំ
ផស្សេ អសន្តេ ន ភវន្តិ ហេតេ
វិភវំ ភវញ្ចាបិ យមេតមត្ថំ
ឯតន្តេ បព្រូមិ ឥតោនិទានំ ។

(១៦៣) ផស្សនិទានំ សាតំ អសាតន្តិ សុខវេទនីយំ ផស្សំ បដិច្ច ឧប្បជ្ជតិ សុខា វេទនា ។ សា(២) តស្សេវ សុខវេទនីយស្ស ផស្សស្ស និរោធា(៣) តជ្ជំ វេទយិតំ សុខវេទនីយំ ផស្សំ បដិច្ច ឧប្បន្នា សុខា វេទនា សា និរុជ្ឈតិ សា វូបសម្មតិ ។ ទុក្ខវេទនីយំ ផស្សំ បដិច្ច ឧប្បជ្ជតិ ទុក្ខា វេទនា ។ សា តស្សេវ ទុក្ខវេទនីយស្ស ផស្សស្ស និរោធា តជ្ជំ វេទយិតំ ទុក្ខវេទនីយំ ផស្សំ បដិច្ច ឧប្បន្នា ទុក្ខា វេទនា សា និរុជ្ឈតិ សា វូបសម្មតិ ។

---

១ ម. ផស្សំ និទានំ ។ ២ ម. យា ។ ៣ ម. យំ តជ្ជំ ។

កលហវិវាទសុត្តនិទ្ទេស ទី ១១

សេចក្តីត្រេកអរនឹងមិនត្រេកអរ មានអ្វីជាហេតុ កាលបើអ្វីមិនមាន ទើបធម៌ទាំងនុ៎ះមិនមាន សេចក្តីណា គឺការវិនាសនឹងការចំរើន សូមព្រះអង្គសំដែងប្រាប់ខ្ញុំ នូវសេចក្តីនុ៎ះ ថាមានវត្ថុណាជាហេតុ ។

(១៦២) (ព្រះមានព្រះភាគ ត្រាស់ថា) សេចក្តីត្រេកអរនឹងមិនត្រេកអរ មានផស្សៈជាហេតុ កាលបើផស្សៈមិនមាន ទើបធម៌ទាំងនុ៎ះមិនមាន សេចក្តីណា គឺការវិនាសនឹងការចំរើន តថាគត សំដែងទូលព្រះអង្គនូវសេចក្តីនុ៎ះ ថាមានវត្ថុនេះជាហេតុ ។

(១៦៣) ពាក្យថា សេចក្តីត្រេកអរនឹងមិនត្រេកអរ មានផស្សៈជាហេតុ អធិប្បាយថា សុខវេទនាកើត អាស្រ័យផស្សៈជាទីតាំងនៃសុខវេទនា ។ ព្រោះរលត់ផស្សៈ ជាតាំងនៃសុខវេទនានោះឯង សុខវេទនាដែលកើតរួចហើយ ព្រោះអាស្រ័យផស្សៈ ជាទីតាំងនៃសុខវេទនា កើតអំពីផស្សៈនោះ ដែលសាយរួចហើយ នោះរលត់ស្ងប់រម្ងាប់ ។ ទុក្ខវេទនាកើតឡើង ព្រោះអាស្រ័យផស្សៈ ជាទីតាំងនៃទុក្ខវេទនា ។ ព្រោះរលត់ផស្សៈជាទីតាំងនៃទុក្ខវេទនានោះឯង ទុក្ខវេទនាដែលកើតរួចហើយ ព្រោះអាស្រ័យផស្សៈ ជាទីតាំងនៃទុក្ខវេទនា កើតអំពីផស្សៈមុននោះ ដែលសាយរួចហើយ នោះរលត់ស្ងប់រម្ងាប់ ។

អទុក្ខមសុខវេទនីយំ ផស្សំ បដិច្ច ឧប្បជ្ជតិ អទុក្ខមសុខា វេទនា ។ សា តស្សេវ អទុក្ខមសុខវេទនីយស្ស ផស្សស្ស និរោធា តជ្ជំ វេទយិតំ អទុក្ខមសុខវេទនីយំ ផស្សំ បដិច្ច ឧប្បន្នា អទុក្ខមសុខា វេទនា សា និរុជ្ឈតិ សា វូបសម្មតិ ។ ផស្សនិទានំ សាតំ អសាតន្តិ សាតាសាតា ផស្សនិទានា ផស្សសមុទយា ផស្សជាតិកា ផស្សប្បភវាតិ ផស្សនិទានំ សាតំ អសាតំ ។

(៣៦៤) ផស្សេ អសន្តេ ន ភវន្តិ ហេតេតិ ផស្សេ អសន្តេ អសំវិជ្ជមានេ អនុបលព្ភិយមានេ សាតាសាតា ន ភវន្តិ នប្បភវន្តិ ន ជាយន្តិ ន សញ្ជាយន្តិ ន និព្វត្តន្តិ នាភិនិព្វត្តន្តិ ន បាតុភវន្តីតិ ផស្សេ អសន្តេ ន ភវន្តិ ហេតេ ។

អទុក្ខមសុខវេទនា កើតឡើង ព្រោះអាស្រ័យផស្សៈ ជាទីតាំងនៃអទុក្ខមសុខវេទនា ។ ព្រោះរលត់ផស្សៈ ជាទីតាំង នៃអទុក្ខមសុខវេទនានោះឯង អទុក្ខមសុខវេទនា ដែលកើតឡើងហើយព្រោះអាស្រ័យផស្សៈ ជាទីតាំងនៃអទុក្ខមសុខវេទនា កើតអំពីផស្សៈនោះ ដែលសោយរួចហើយ នោះរលត់ស្ងប់រម្ងាប់ ។ ពាក្យថា សេចក្តីត្រេកអរនឹងមិនត្រេកអរ មានផស្សៈជាហេតុ បានសេចក្តីថា វេទនាជាទីត្រេកអរនឹងមិនជាទីត្រេកអរ មានផស្សៈជាហេតុ មានផស្សៈជាទីប្រជុំកើតឡើង មានផស្សៈជាកំណើត មានផស្សៈជាដែនកើតមុន ហេតុនោះ (ទ្រង់ត្រាស់ថា) សេចក្តីត្រេកអរនឹងមិនត្រេកអរ មានផស្សៈជាហេតុ ។

(១៦៤) ពាក្យថា កាលបើផស្សៈមិនមាន ធម៌ទាំងឡាយនុ៎ះក៏មិនមាន គឺកាលបើផស្សៈមិនមាន មិនមានសព្វគ្រប់ ដែលបុគ្គលមិនបាន វេទនាជាទីត្រេកអរនឹងមិនត្រេកអរក៏មិនមាន មិនមានប្រាកដ មិនកើត មិនកើតព្រម មិនផុបផ្តើម មិនកើតចំពោះ មិនកើតប្រាកដ ហេតុនោះ (ទ្រង់ត្រាស់ថា) កាលបើផស្សៈមិនមាន ធម៌ទាំងឡាយនុ៎ះ ក៏មិនមាន ។

(១៦៨) វិភវំ ភវញ្ចាបិ យមេតមត្ថន្តិ ភវទិដ្ឋិបិ ផស្ស-និទានា វិភវទិដ្ឋិបិ ផស្សនិទានា ។ យមេតមត្ថន្តិ យំ បរមត្ថន្តិ វិភវំ ភវញ្ចាបិ យមេតមត្ថំ ។

(១៦៩) ឯតន្តេ បព្រូមិ ឥតោនិទានន្តិ ឯតន្តិ យំ បុច្ឆសិ យំ យាចសិ យំ អជ្ឈេសសិ យំ បសាទេសិ ។ បព្រូមីតិ ព្រូមិ អាចិក្ខាមិ ទេសេមិ បញ្ញបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានីករោមិ បកាសេមីតិ ឯតន្តេ បព្រូមិ ។ ឥតោនិទានន្តិ ឥតោផស្សនិទានំ ផស្ស-សមុទយំ ផស្សជាតិកំ ផស្សប្បភវន្តិ ឯតន្តេ បព្រូមិ ឥតោនិទានំ ។ តេនាហ ភគវា

## កលហវិវាទសុត្តនិទ្ទេស ទី ១១

(១៦៥) ពាក្យថា សេចក្ដីណា គឺការវិនាស នឹងការចំរើន សេចក្ដីថា កិរិយាឃើញថាចំរើន ក៏មានផស្សៈជាហេតុ កិរិយាឃើញថាវិនាស ក៏មានផស្សៈជាហេតុ ។ ត្រង់ពាក្យថា សេចក្ដីណា គឺ សេចក្ដីដទៃណា ហេតុនោះ (ទ្រង់ត្រាស់ថា) សេចក្ដីណា គឺការវិនាសនឹងការចំរើន ។

(១៦៦) អធិប្បាយពាក្យថា តថាគតសំដែងទូលព្រះអង្គ នូវសេចក្ដីនុះ ថាមានវត្ថុនេះជាហេតុ ត្រង់ពាក្យថា នុះ គឺព្រះអង្គសួរសេចក្ដីណា សូមសេចក្ដីណា អារាធនាសេចក្ដីណា ជ្រះថ្លាសេចក្ដីណា ។ ពាក្យថា តថាគតសំដែង គឺតថាគតពោល ប្រាប់ សំដែង បញ្ញត្ត តម្កល់ទុក បើក បែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតសំដែងទូលព្រះអង្គ នូវសេចក្ដីនុះ ។ ពាក្យថា មានវត្ថុនេះជាហេតុ គឺ មានផស្សៈនេះជាហេតុ មានផស្សៈជាទីប្រជុំកើត មានផស្សៈជាកំណើត មានផស្សៈជាដែនកើតមុន ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតសំដែងទូលព្រះអង្គ នូវសេចក្ដីនុះ ថាមានវត្ថុនេះជាហេតុ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ផស្សនិទានំ(១) សាតំ អសាតំ

ផស្សេ អសន្តេ ន ភវន្តិ ហេតេ

វិភវំ ភវញ្ចាបិ យមេតមត្ថំ

ឯតន្តេ បព្រូមិ ឥតោនិទានន្តិ ។

(១៦៧) ផស្សោ នុ លោកស្មិំ កុតោនិទានោ

បរិគ្គហា ចាបិ កុតោ បហូតា

កិស្មឹ អសន្តេ ន មមត្តមត្ថិ

កិស្មឹ វិភូតេ ន ផុសន្តិ ផស្សា ។

(១៦៨) ផស្សោ នុ លោកស្មិំ កុតោនិទានោតិ ផស្សោ កុតោនិទានោ កុតោ ជាតោ កុតោ សញ្ជាតោ កុតោ និព្វត្តោ កុតោ អភិនិព្វត្តោ កុតោ បាតុភូតោ កឹនិទានោ កឹសមុទយោ កឹជាតិកោ កឹបភវោតិ ផស្សស្ស មូលំ បុច្ឆតិ ។បេ។ សមុទយំ បុច្ឆតិ បបុច្ឆតិ យាចតិ អជ្ឈេសតិ បសាទេតីតិ ផស្សោ នុ លោកស្មិំ កុតោនិទានោ ។

១ ម. ផស្សំ និទានំ ។

សេចក្តីត្រេកអរនឹងមិនត្រេកអរ មានផស្សៈជាហេតុ កាលបើផស្សៈមិនមាន ទើបធម៌ទាំងនោះមិនមាន សេចក្តីណា គឺការវិនាសនឹងការចំរើន តថាគតសំដែងទូលព្រះអង្គ នូវសេចក្តីនុ៎ះ ថាមានវត្ថុនេះជាហេតុ ។

(១៦៧) (ព្រះពុទ្ធនិម្មិត សួរថា) ផស្សៈក្នុងលោក មានអ្វីជាហេតុ ទាំងសេចក្តីហួងហែងកើតអំពីអ្វី កាលបើអ្វីមិនមាន ទើបសេចក្តីប្រកាន់ថារបស់អញក៏មិនមាន កាលបើអ្វីប្រាសចេញ ទើបផស្សៈមិនពាល់ត្រូវ ។

(១៦៨) ពាក្យថា ផស្សៈក្នុងលោកមានអ្វីជាហេតុ គឺព្រះពុទ្ធនិម្មិតសួររកឫសគល់នៃផស្សៈ ។ បេ ។ សួរ សួរឈ្លេចឈ្លី អង្វរ អារា-ធនា ជ្រះថ្លានូវហេតុដែលនាំឲ្យកើតផស្សៈ ថា ផស្សៈមានហេតុអំពីអ្វី កើតអំពីអ្វី កើតព្រមអំពីអ្វី ផ្តួចផ្តើមអំពីអ្វី កើតចំពោះអំពីអ្វី កើតប្រាកដអំពីអ្វី មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ហេតុនោះ (ទ្រង់ត្រាស់ថា) ផស្សៈក្នុងលោក មានអ្វីជាហេតុ ។

(១៦៩) បរិគ្គហា ចាបិ កុតោ បហូតាតិ បរិគ្គហា កុតោ បហូតា កុតោ ជាតា កុតោ សញ្ជាតា កុតោ និព្វត្តា កុតោ អភិនិព្វត្តា កុតោ បាតុភូតា កឹនិទានា កឹសមុទយា កឹជាតិកា កឹបភវាតិ បរិគ្គហានំ មូលំ បុច្ឆតិ ។បេ។ សមុទយំ បុច្ឆតិ បបុច្ឆតិ យាចតិ អជ្ឈេសតិ បសាទេតីតិ បរិគ្គហា ចាបិ កុតោ បហូតា ។

(១៧០) កិស្មឹ អសន្តេ ន មមត្តមត្ថីតិ កិស្មឹ អសន្តេ អសំវិជ្ជមានេ អនុបលព្ភិយមានេ មមត្តា នត្ថិ ន សន្តិ ន សំវិជ្ជន្តិ នុបលព្ភន្តិ បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍាតិ កិស្មឹ អសន្តេ ន មមត្តមត្ថិ ។

កលហវិភាវសុត្តនិទ្ទេស ទី ១១

(១៦៩) ពាក្យថា ទាំងសេចក្តីហួងហែង កើតអំពីអ្វី គឺព្រះពុទ្ធ-និម្មិតសួរកេហ្សសិតលល់ នៃសេចក្តីហួងហែង ។ បេ ។ សួរ សួរឈ្មោះ ឈ្មោះ អង្វរ អាពាធនា ជ្រះថ្លា នូវហេតុដែលនាំឲ្យកើតសេចក្តីហួងហែង ថា សេចក្តីហួងហែងកើតអំពីអ្វី កើតអំពីណា កើតព្រម អំពីអ្វី ផុចផ្តើមអំពីអ្វី កើតចំពោះអំពីអ្វី កើតប្រាកដអំពីអ្វី មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើតមុន ហេតុនោះ (ទ្រង់ត្រាស់សួរថា) ទាំងសេចក្តីហួងហែង កើតអំពីអ្វី ។

(១៧០) ពាក្យថា កាលបើអ្វីមិនមាន ទើបសេចក្តីប្រកាន់ថារបស់អញក៏មិនមាន គឺកាលបើអ្វីមិនមាន មិនមានសព្វគ្រប់ ដែលបុគ្គលមិនបាន ទើបសេចក្តីប្រកាន់ថារបស់អញ មិនមាន ឥតមាន លែងមាន ដែលបុគ្គលមិនបាន គឺលោកលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់សួរថា) កាលបើអ្វីមិនមាន ទើបសេចក្តីប្រកាន់ថារបស់អញក៏មិនមាន ។

(១៧១) កិស្មឹ វិភូតេ ន ផុសន្តិ ផស្សាតិ កិស្មឹ វិភូតេ វិភាវិតេ អតិក្កន្តេ សមតិក្កន្តេ វីតិវត្តេ ន ផស្សា ផុសន្តីតិ កិស្មឹ វិភូតេ ន ផុសន្តិ ផស្សា ។ តេនាហ សោ និម្មិតោ

ផស្សោ នុ លោកស្មិំ កុតោនិទានោ
បរិគ្គហា ចាបិ កុតោ បហូតា
កិស្មឹ អសន្តេ ន មមត្តមត្ថិ
កិស្មឹ វិភូតេ ន ផុសន្តិ ផស្សាតិ ។

(១៧២) នាមញ្ច រូបញ្ច បដិច្ច ផស្សោ
ឥច្ឆានិទានានិ បរិគ្គហានិ
ឥច្ឆាយសន្ត្យា ន មមត្តមត្ថិ
រូបេ វិភូតេ ន ផុសន្តិ ផស្សា ។

(១៧៣) នាមញ្ច រូបញ្ច បដិច្ច ផស្សោតិ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ចក្ខុញ្ច រូបា ច រូបស្មឹ ចក្ខុសម្ផស្សំ ឋបេត្វា សម្បយុត្តកា ធម្មា នាមស្មឹ ឯវម្បិ នាមញ្ច រូបញ្ច បដិច្ច ផស្សោ ។

(១៧១) ពាក្យថា កាលបើអ្វីប្រាសចេញ ទើបផស្សៈមិនពាល់ត្រូវ គឺកាលបើអ្វីប្រាសចេញ បាត់បង់ កន្លងទៅ កន្លងផុត ប្រព្រឹត្តកន្លង ទើបផស្សៈមិនពាល់ត្រូវ ហេតុនោះ (ទ្រង់ត្រាស់សួរថា) កាលបើអ្វីប្រាសចេញ ទើបផស្សៈមិនពាល់ត្រូវ ។ ហេតុនោះ ពុទ្ធនិម្មិតនោះសួរថា

ផស្សៈក្នុងលោកមានអ្វីជាហេតុ តាំងសេចក្តីហួងហែងកើត
អំពីអ្វី កាលបើអ្វីមិនមាន ទើបសេចក្តីប្រកាន់ថារបស់អញ ក៏
មិនមាន កាលបើអ្វីប្រាសចេញ ទើបផស្សៈមិនពាល់ត្រូវ ។

(១៧២) (ព្រះមានព្រះភាគទ្រង់ថា) ផស្សៈ (កើត) ព្រោះ
អាស្រ័យនាមនឹងរូប សេចក្តីហួងហែង មានសេចក្តីប្រាថ្នា
ជាហេតុ កាលបើសេចក្តីប្រាថ្នាមិនមាន សេចក្តីប្រកាន់ថា
របស់អញ ក៏មិនមាន កាលបើរូបប្រាសចេញ ផស្សៈទាំង
ឡាយ ក៏មិនពាល់ត្រូវ ។

(១៧៣) ពាក្យថា ផស្សៈ (កើត) ព្រោះអាស្រ័យនាមនឹងរូប អធិប្បាយថា ចក្ខុវិញ្ញាណកើត ព្រោះអាស្រ័យចក្ខុនឹងរូប ការប្រជុំនៃធម៌ទាំង ៣ (១) ទើបផស្សៈកើត វៀរលែងចក្ខុប្រសាទ នឹងរូបារម្មណ៍ក្នុងប៉ែករូប ១ ចក្ខុសម្ផស្ស ១ ទើបពួកធម៌ដ៏សម្បយុត្ត ក្នុងប៉ែកនាម(២) (កើត) ផស្សៈ (កើត) ព្រោះអាស្រ័យនាមនឹងរូប យ៉ាងនេះខ្លះ ។

---

១ សំដៅយកចក្ខុ១ រូប១ វិញ្ញាណ១ ។ ២ សំដៅយកពួកនាមធម៌ មានវេទនាជាដើម។ អដ្ឋកថា ។

ឯកាទសមោ កលហវិវាទសុត្តនិទ្ទេសោ

សោតញ្ច បដិច្ច សទ្ទេ ច ឧប្បជ្ជតិ សោតវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ សោតញ្ច សទ្ទា ច រូបស្មឹ សោតសម្ផស្សំ ឋបេត្វា សម្បយុត្តកា ធម្មា នាមស្មឹ ឯវម្បិ នាមញ្ច រូបញ្ច បដិច្ច ផស្សោ ។ ឃានញ្ច បដិច្ច គន្ធេ ច ឧប្បជ្ជតិ ឃានវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ឃានញ្ច គន្ធា ច រូបស្មឹ ឃានសម្ផស្សំ ឋបេត្វា សម្បយុត្តកា ធម្មា នាមស្មឹ ឯវម្បិ នាមញ្ច រូបញ្ច បដិច្ច ផស្សោ ។ ជិវ្ហញ្ច បដិច្ច រសេ ច ឧប្បជ្ជតិ ជិវ្ហាវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ជិវ្ហា ច រសា ច រូបស្មឹ ជិវ្ហាសម្ផស្សំ ឋបេត្វា សម្បយុត្តកា ធម្មា នាមស្មឹ ឯវម្បិ នាមញ្ច រូបញ្ច បដិច្ច ផស្សោ ។ កាយញ្ច បដិច្ច ផោដ្ឋព្វេ ច ឧប្បជ្ជតិ កាយវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ កាយោ ច ផោដ្ឋព្វា(១) ច រូបស្មឹ កាយសម្ផស្សំ ឋបេត្វា សម្បយុត្តកា ធម្មា នាមស្មឹ ឯវម្បិ នាមញ្ច រូបញ្ច បដិច្ច ផស្សោ ។ មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ

---

១ ឱ. ផោដ្ឋព្វោ ។

សោតវិញ្ញាណកើត ព្រោះអាស្រ័យត្រចៀកនឹងសំឡេង ការប្រជុំនៃធម៌ទាំង ៣ ទើបផស្សៈ (កើត) វៀរលែងសោតបសាទ នឹងសទ្ទារម្មណ៍ក្នុងប៉ែករូប ១ សោតសម្ផស្ស ១ ទើបពួកធម៌ដ៏សម្បយុត្តក្នុងប៉ែកនាម (កើត) ផស្សៈ (កើត) ព្រោះអាស្រ័យនាមនឹងរូប យ៉ាងនេះខ្លះ ។ ឃានវិញ្ញាណកើត ព្រោះអាស្រ័យច្រមុះនឹងក្លិន ការប្រជុំនៃធម៌ទាំង ៣ ទើបផស្សៈ (កើត) វៀរលែងឃានបសាទនឹងគន្ធារម្មណ៍ ក្នុងប៉ែករូប ១ ឃានសម្ផស្ស ១ ទើបពួកធម៌ដ៏សម្បយុត្ត ក្នុងប៉ែកនាម (កើត) ផស្សៈ (កើត) ព្រោះអាស្រ័យនាមនឹងរូប យ៉ាងនេះខ្លះ ។ ជិវ្ហាវិញ្ញាណកើត ព្រោះអាស្រ័យអណ្តាតនឹងរស ការប្រជុំនៃធម៌ទាំង ៣ ទើបផស្សៈ (កើត) វៀរលែងជិវ្ហាបសាទ នឹងរសារម្មណ៍ក្នុងប៉ែករូប ១ ជិវ្ហាសម្ផស្ស ១ ទើបពួកធម៌សម្បយុត្ត ក្នុងប៉ែកនាម (កើត) ផស្សៈ (កើត) ព្រោះអាស្រ័យនាមនឹងរូប យ៉ាងនេះខ្លះ ។ កាយវិញ្ញាណកើត ព្រោះអាស្រ័យកាយនឹងផ្សព្វ ការប្រជុំនៃធម៌ទាំង ៣ ទើបផស្សៈ (កើត) វៀរលែងកាយបសាទនឹងផោដ្ឋព្វារម្មណ៍ ក្នុងប៉ែករូប ១ កាយសម្ផស្ស ១ ទើបពួកធម៌ដ៏សម្បយុត្ត ក្នុងប៉ែកនាម (កើត) ផស្សៈ (កើត) ព្រោះអាស្រ័យនាមនឹងរូប យ៉ាងនេះខ្លះ ។ មនោវិញ្ញាណកើត ព្រោះអាស្រ័យមនោនឹងធម្មារម្មណ៍ ការប្រជុំធម៌ទាំង ៣ ទើបផស្សៈ (កើត)

វត្ថុរូបំ រូបស្មឹ ធម្មា រូបំ នោ រូបស្មឹ មនោសម្ផស្សំ បភេទា សម្បយុត្តកា ធម្មា នាមស្មឹ ឍវម្បិ នាមញ្ច រូបញ្ច បដិច្ច ផស្សោ ។

(១៧៤) ឥច្ឆានិទានានិ បរិគ្គហានីតិ ឥច្ឆា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។បេ។ អភិជ្ឈា លោភោ អកុសលមូលំ ។ បរិគ្គហាតិ ទ្វេ បរិគ្គហា តណ្ហាបរិ-គ្គហោ ច ទិដ្ឋិបរិគ្គហោ ច ។បេ។ អយំ តណ្ហាបរិគ្គហោ ។បេ។ អយំ ទិដ្ឋិបរិគ្គហោ ។ ឥច្ឆានិទានានិ បរិគ្គហានីតិ បរិគ្គហា ឥច្ឆានិទានា ឥច្ឆាហេតុកា ឥច្ឆាបច្ចយា ឥច្ឆាការណា ឥច្ឆាបភវាតិ ឥច្ឆានិទានានិ បរិគ្គហានិ ។

(១៧៥) ឥច្ឆាយសន្ត្យា ន មមត្តមត្ថីតិ ឥច្ឆា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។បេ។ អភិជ្ឈា លោភោ

ទៀតលែងកើតឡើងក្នុងរូបក្នុងប៉ែករូប នឹងពួកធម៌មានរូបក្នុងប៉ែករូប១ មនោសម្ផស្ស១ ទើបពួកធម៌ដ៏សម្បយុត្ត ក្នុងប៉ែកនាម (កើត) ផស្សៈ (កើត) ព្រោះអាស្រ័យនាមនឹងរូប យ៉ាងនេះខ្លះ ។

(១៧៨) ពាក្យថា សេចក្តីហួងហែង មានសេចក្តីប្រាថ្នាជាហេតុ អធិប្បាយថា តណ្ហា លោកហៅថា សេចក្តីប្រាថ្នា បានដល់ រាគៈ រាគៈខ្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា សេចក្តីហួងហែង បានដល់ សេចក្តីហួងហែង ២ គឺសេចក្តីហួងហែងគឺតណ្ហា ១ សេចក្តីហួងហែងគឺទិដ្ឋិ ១ ។ បេ ។ នេះ សេចក្តីហួងហែងគឺតណ្ហា ។ បេ ។ នេះ សេចក្តីហួងហែងគឺទិដ្ឋិ ។ ពាក្យថា សេចក្តីហួងហែង មានសេចក្តីប្រាថ្នាជាហេតុ បានសេចក្តីថា សេចក្តីហួងហែង មានសេចក្តីប្រាថ្នាជានិទាន មានសេចក្តីប្រាថ្នាជាហេតុ មានសេចក្តីប្រាថ្នាជាបច្ច័យ មានសេចក្តីប្រាថ្នាជាអំពើ មានសេចក្តីប្រាថ្នាជាដែនកើតមុន ហេតុនោះ (ទ្រង់ត្រាស់ថា) សេចក្តីហួងហែងមានសេចក្តីប្រាថ្នាជាហេតុ។

(១៧៩) ពាក្យថា កាលបើសេចក្តីប្រាថ្នាមិនមាន សេចក្តីប្រកាន់ថារបស់អញ ក៏មិនមាន អធិប្បាយថា តណ្ហា លោកហៅថា សេចក្តីប្រាថ្នា បានដល់ រាគៈ រាគៈខ្លាំង ។ បេ ។ អភិជ្ឈា លោភៈ

ឯកាទសមោ កលហវិវាទសុត្តនិទ្ទេសោ

អកុសលមូលំ ។ មមត្តាតិ ទ្វេ មមត្តា តណ្ហាមមត្តញ្ច ទិដ្ឋិមមត្តញ្ច ។បេ។ ឥទំ តណ្ហាមមត្តំ ។បេ។ ឥទំ ទិដ្ឋិមមត្តំ ។ ឥច្ឆាយ សន្ត្យា ន មមត្តមត្ថីតិ ឥច្ឆាយ អសន្ត្យា អសំវិជ្ជមានាយ នុបលព្ភិយមានាយ មមត្តា នត្ថិ ន សន្តិ ន សំវិជ្ជន្តិ នុបលព្ភន្តិ បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍាតិ ឥច្ឆាយ សន្ត្យា ន មមត្តមត្ថិ ។

(១៧៦) រូបេ វិភូតេ ន ផុសន្តិ ផស្សាតិ រូបេតិ ចត្តារោ ច មហាភូតា ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបំ ។ រូបេ វិភូតេតិ ចតូហិ ការណេហិ រូបំ វិភូតំ ហោតិ ញាតវិភូតេន តីរណវិភូតេន បហានវិភូតេន សមតិក្កមវិភូតេន ។

កថំ ញាតវិភូតេន រូបំ វិភូតំ ហោតិ ។

អកុសលមូល ។ ពាក្យថា សេចក្ដីប្រកាន់ថារបស់អញ បានដល់សេចក្ដីប្រកាន់ ២ គឺសេចក្ដីប្រកាន់គឺតណ្ហា ១ សេចក្ដីប្រកាន់គឺទិដ្ឋិ ១ ។បេ។ នេះសេចក្ដីប្រកាន់គឺតណ្ហា ។បេ។ នេះសេចក្ដីប្រកាន់គឺទិដ្ឋិ ។ ពាក្យថា កាលបើសេចក្ដីប្រាថ្នាមិនមាន សេចក្ដីប្រកាន់ថារបស់អញ ក៏មិនមាន សេចក្ដីថា កាលបើសេចក្ដីប្រាថ្នា មិនមាន មិនមានសព្វគ្រប់ បុគ្គលមិនបាន សេចក្ដីប្រកាន់ថារបស់អញ ក៏មិនមាន ឥតមាន លែងមាន បុគ្គលមិនបាន គឺលោកបានលះបង់ ផ្ដាច់ផ្ដិល ធ្វើឲ្យស្ងប់ ឲ្យស្ងប់ រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) កាលបើសេចក្ដីប្រាថ្នាមិនមាន សេចក្ដីប្រកាន់ថារបស់អញ ក៏មិនមាន ។

(១៧៦) អធិប្បាយពាក្យថា កាលបើរូបប្រាសចេញ ផស្សៈទាំងឡាយក៏មិនពាល់ត្រូវ ត្រង់ពាក្យថា រូប គឺ មហាភូតរូប ៤ នឹងឧបាទាយរូប របស់មហាភូតរូបទាំង ៤ ។ ត្រង់ពាក្យថា កាលបើរូបប្រាសចេញ គឺ រូបប្រាសចេញដោយហេតុ ៤ គឺ ដោយការប្រាសចេញព្រោះការដឹង ១ ដោយការប្រាសចេញព្រោះការពិចារណា ១ ដោយការប្រាសចេញព្រោះការលះ ១ ដោយការប្រាសចេញព្រោះការប្រព្រឹត្តិកន្លង ១ ។

រូបប្រាសចេញ ដោយការប្រាសចេញព្រោះការដឹង តើដូចម្ដេច ។

រូបំ ជានាតិ យង្កិញ្ចិ រូបំ សព្វំ រូបំ ចត្តារោ ច មហាភូតា ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបន្តិ ជានាតិ បស្សតិ ឯវំ ញាតវិភូតេន រូបំ វិភូតំ ហោតិ ។

កថំ តីរណវិភូតេន រូបំ វិភូតំ ហោតិ ។ ឯវំ ញាតំ កត្វា រូបំ តីរេតិ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ ឦតិតោ ឧបទ្ទវតោ ភយតោ ឧបសគ្គតោ ចលតោ បភង្គុតោ អទ្ធុវតោ អតាណតោ អលេណតោ អសរណតោ រិត្តតោ តុច្ឆតោ សុញ្ញតោ អនត្តតោ អាទីនវតោ វិបរិណាមធម្មតោ អសារកតោ អឃមូលតោ វធកតោ វិភវតោ សាសវតោ សង្ខតតោ មារាមិសតោ ជាតិធម្មតោ ជរាធម្មតោ ព្យាធិធម្មតោ មរណធម្មតោ សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មតោ សង្កិលេសិកធម្មតោ សមុទយតោ អត្ថង្គមតោ អស្សាទតោ អាទីនវតោ និស្សរណតោ តីរេតិ ឯវំ តីរណវិភូតេន រូបំ វិភូតំ ហោតិ ។

បុគ្គលស្គាល់រូប គឺស្គាល់ ឃើញថា រូបឯណានីមួយ រូបទាំងអស់នោះជា មហាភូតរូប ៤ និងឧបាទាយរូបរបស់មហាភូតរូបទាំង ៤ ដូច្នេះ រូបប្រាសចេញ ដោយការប្រាសចេញព្រោះការដឹង យ៉ាងនេះឯង ។

រូបប្រាសចេញ ដោយការប្រាសចេញព្រោះការពិចារណា តើដូចម្តេច ។ បុគ្គលធ្វើការដឹងយ៉ាងនេះ ហើយពិចារណានូវរូប គឺពិចារណា ដោយសេចក្តីថាមិនទៀង ថាជាទុក្ខ ជារោគ ជាបូស ជាសរ ជាសេចក្តីលំបាក ជាអាពាធ ជារបស់ដទៃ ជារបស់ទ្រុឌទ្រោម ជាចង្រៃ ជាឧបទ្រព ជាភ័យ ជាឧបសគ្គ ជារបស់ញាប់ញ័រ ជារបស់បែកធ្លាយ ជារបស់មិនទៀង ទីពឹងមិនបាន ផ្អែកមិនបាន ទីអាងមិនបាន ជារបស់ស្ងួចស្តើង ជារបស់ទទេ ជារបស់សោះសូន្យ មិនមែនជារបស់ខ្លួន ជាទោស ជាសភាវៈប្រែប្រួល មិនមានខ្លឹម ជាឫសនៃសេចក្តីលំបាក ជាអ្នកសម្លាប់ ជារបស់វិនាស ប្រកបដោយអាសវៈ ជារបស់ដែលបច្ច័យតាក់តែង ជានុយនៃមារ មានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា មានសេចក្តីស្លាប់ជាធម្មតា មានសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ជាធម្មតា ប្រកបដោយសេចក្តីសៅហ្មងជាធម្មតា ជារបស់ប្រជុំកើតឡើង ជារបស់វិនាសទៅ ជាអានិសង្ស ជាទោស ជាគ្រឿងរលាស់ចោល រូបប្រាសចេញ ដោយការប្រាសចេញព្រោះការពិចារណា យ៉ាងនេះឯង ។

កថំ បហានវិភូតេន រូបំ វិភូតំ ហោតិ ។ ឯវំ តិរេត្វា(១) រូបេ ឆន្ទរាគំ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតិ ។ វុត្តំ ហេតំ ភគវតា យោ រូបេ ភិក្ខវេ ឆន្ទរាគោ តំ បជហថ ឯវន្តំ បហីនំ ភវិស្សតិ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អាយតឹ អនុប្បាទធម្មំ ។ ឯវំ បហានវិភូតេន រូបំ វិភូតំ ហោតិ ។

កថំ សមតិក្កមវិភូតេន រូបំ វិភូតំ ហោតិ ។ ចតស្សោ អរូបសមាបត្តិយោ បដិលទ្ធស្ស រូបា វិភូតា ហោន្តិ វិភាវិតា អតិក្កន្តា សមតិក្កន្តា វីតិវត្តា ឯវំ សមតិក្កមវិភូតេន រូបំ វិភូតំ ហោតិ ។ ឥមេហិ ចតូហិ ការណេហិ រូបំ វិភូតំ ហោតិ ។

រូបេ វិភូតេ ន ផុសន្តិ ផស្សាតិ រូបេ វិភូតេ វិភាវិតេ អតិក្កន្តេ សមតិក្កន្តេ វីតិវត្តេ បញ្ច ផស្សា ន ផុសន្តិ ចក្ខុសម្ផស្សោ សោតសម្ផស្សោ ឃានសម្ផស្សោ

---

១ ម តីរេត្វា ។

កលហវិវាទសុត្តនិទ្ទេស ទី ១១

រូបប្រាសចេញ ដោយការប្រាសចេញ ព្រោះការលះ តើដូចម្តេច ។ បុគ្គលត្រិះរិះយ៉ាងនេះ ហើយលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវឆន្ទរាគក្នុងរូប ។ សមដូចពាក្យនុះ ដែលព្រះមានព្រះភាគសំដែងហើយថា ម្នាលភិក្ខុទាំងឡាយ ឆន្ទរាគឯណាក្នុងរូប អ្នកទាំងឡាយគួរលះបង់ឆន្ទរាគនោះចេញ កាលបើធ្វើបានយ៉ាងនេះ រូបនោះនឹងជារបស់ដែលអ្នកលះបង់ហើយ ឲ្យមានឫសគល់រលីងហើយ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនកើតទៀត មិនឲ្យមានការកើតតទៅ ។ រូបប្រាសចេញ ដោយការប្រាសចេញព្រោះការលះ យ៉ាងនេះឯង ។

រូបប្រាសចេញ ដោយការប្រាសចេញ ព្រោះការប្រព្រឹត្តិកន្លង តើដូចម្តេច ។ រូបទាំងឡាយរបស់បុគ្គល អ្នកបានអរូបសមាបត្តិទាំង ៤ ជារូបប្រាសចេញ បាត់បង់ កន្លង ឈានកន្លង ប្រព្រឹត្តកន្លងហើយ រូបប្រាសចេញ ដោយការប្រាសចេញ ព្រោះការប្រព្រឹត្តិកន្លង យ៉ាងនេះឯង ។ នេះ រូបប្រាសចេញដោយហេតុទាំង ៤ ។

ពាក្យថា កាលបើរូបប្រាសចេញ ផស្សៈទាំងឡាយក៏មិនពាល់ត្រូវ បានសេចក្តីថា កាលបើរូបប្រាសចេញ បាត់បង់ កន្លង ឈានកន្លង ប្រព្រឹត្តកន្លងហើយ ផស្សៈទាំង ៥ គឺ ចក្ខុសម្ផស្ស សោតសម្ផស្ស ឃានសម្ផស្ស

ជិវ្ហាសម្ផស្សោ កាយសម្ផស្សោតិ រូបេ វិភូតេ ន ផុសន្តិ ផស្សា ។ តេនាហ ភគវា

នាមញ្ច រូបញ្ច បដិច្ច ផស្សោ
ឥច្ឆានិទានានិ បរិគ្គហានិ
ឥច្ឆាយសន្ត្យា ន មមត្តមត្ថិ
រូបេ វិភូតេ ន ផុសន្តិ ផស្សាតិ ។

(១៧៧) កថំសមេតស្ស វិភោតិ រូបំ
សុខំ ទុក្ខំ វាបិ កថំ វិភោតិ
ឯតម្មេ បព្រូហិ យថា វិភោតិ
តំ ជានិយាម(១) ឥតិ មេ មនោ អហុ ។

(១៧៨) កថំសមេតស្ស វិភោតិ រូបន្តិ កថំសមេតស្ស(២) កថំបដិបន្នស្ស កថំឥរិយន្តស្ស កថំបវត្តេន្តស្ស(៣) កថំបាលេន្តស្ស កថំយបេន្តស្ស កថំយាបេន្តស្ស រូបំ វិភោតិ វិភាវិយ្យតិ អតិក្កមិយ្យតិ សមតិក្កមិយ្យតិ វីតិវត្តិយ្យតីតិ កថំសមេតស្ស វិភោតិ រូបំ ។

---

១ ម. ជានិស្សាម ។ ២ ឱ. ម. កថំសមេតស្សាតិ កថំសមេតស្ស ។ ៣ ម. កថំវត្តន្តស្ស ។

ជិវ្ហាសម្ផស្ស កាយសម្ផស្ស ក៏មិនពាល់ត្រូវ ហេតុនោះ (ទ្រង់ត្រាស់ថា) កាលបើរូបប្រាសចេញ ផស្សៈទាំងឡាយក៏មិនពាល់ត្រូវ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ផស្សៈ (កើត) ព្រោះអាស្រ័យនាមនិងរូប សេចក្តីហួងហែង
មានសេចក្តីប្រាថ្នាជាហេតុ កាលបើសេចក្តីប្រាថ្នាមិនមាន
សេចក្តីប្រកាន់ថារបស់អញ ក៏មិនមាន កាលបើរូបប្រាស
ចេញ ផស្សៈទាំងឡាយ ក៏មិនពាល់ត្រូវ ។

(១៧៧) (ព្រះពុទ្ធនិម្មិត សួរថា) បុគ្គលអ្នកព្រមព្រៀង
ដូចម្តេច រូបទើបបាត់បង់ទៅ ទាំងសុខនិងទុក្ខ បាត់
បង់ទៅ ដោយប្រការដូចម្តេច សូមព្រះអង្គពោលដំណើរ
នុ៎ះដល់ខ្ញុំ ឲ្យខ្ញុំយល់ច្បាស់ថា (សុខនិងទុក្ខ) បាត់បង់ទៅ
ដោយប្រការយ៉ាងណា ព្រោះថា ខ្ញុំមានចិត្តដូច្នេះ ។

(១៧៨) ពាក្យថា បុគ្គលអ្នកព្រមព្រៀងដូចម្តេច រូបទើបបាត់បង់ទៅ គឺ បុគ្គលអ្នកព្រមព្រៀងដូចម្តេច ប្រតិបត្តិដូចម្តេច សម្រេចដូចម្តេច ប្រព្រឹត្តទៅដូចម្តេច រក្សាដូចម្តេច រស់នៅដូចម្តេច ញុំាងអត្តភាពឲ្យរស់នៅដូចម្តេច រូបទើបបាត់បង់ វិនាសកន្លង ឈានកន្លង ប្រព្រឹត្តកន្លងទៅបាន ហេតុនោះ (ទ្រង់ត្រាស់សួរថា) បុគ្គលអ្នកព្រមព្រៀងដូចម្តេច រូបទើបបាត់បង់ទៅ ។

ឯកាទសមោ កលហវិវាទសុត្តនិទ្ទេសោ

(១៧៩) សុខំ ទុក្ខំ វាបិ កថំ វិភោតីតិ សុខញ្ច ទុក្ខញ្ច កថំ វិភោតិ វិភាវិស្សតិ អតិក្កមិស្សតិ សមតិក្កមិស្សតិ វីតិវត្តិស្សតីតិ សុខំ ទុក្ខំ វាបិ កថំ វិភោតិ ។

(១៨០) ឯតម្មេ បព្រូហិ យថា វិភោតីតិ ឯតន្តិ យំ បុច្ឆាមិ យំ យាចាមិ យំ អជ្ឈេសាមិ យំ បសាទេមីតិ ឯតំ ។ មេ បព្រូហីតិ មេ ព្រូហិ អាចិក្ខ ទេសេហិ បញ្ញាបេហិ បដ្ឋបេហិ វិវរ វិភជ ឧត្តានីករោហិ បកាសេហីតិ ឯតម្មេ បព្រូហិ ។ យថា វិភោតីតិ យថា វិភោតិ វិភាវិស្សតិ អតិក្កមិស្សតិ សមតិក្កមិស្សតិ វីតិវត្តិស្សតីតិ ឯតម្មេ បព្រូហិ យថា វិភោតិ ។

## កលហវិវាទសុត្តនិទ្ទេស ទី ១១

(១៧៩) ពាក្យថា ទាំងសុខទឹងទុក្ខ បាត់បង់ទៅ ដោយប្រការដូចម្ដេច គឺសុខទឹងទុក្ខ បាត់បង់ទៅ វិនាស កន្លង ឈានកន្លង ប្រព្រឹត្តកន្លងទៅ ដោយប្រការដូចម្ដេច ៗ ហេតុនោះ (ទ្រង់ត្រាស់សួរថា) ទាំងសុខទឹងទុក្ខ បាត់បង់ទៅ ដោយប្រការដូចម្ដេច ៗ

(១៨០) ពាក្យថា សូមព្រះអង្គពោលដំណើរនុ៎ះដល់ខ្ញុំ (សុខទឹងទុក្ខ) បាត់បង់ទៅ ដោយប្រការយ៉ាងណា ត្រង់ពាក្យថា ដំណើរនុ៎ះ គឺខ្ញុំសួររក ដំណើរណា សូមដំណើរណា អារាធនាដំណើរណា ហោទដំណើរណា ហេតុនោះ (ទ្រង់ត្រាស់សួរថា) ដំណើរនុ៎ះ ៗ ពាក្យថា សូមព្រះអង្គពោលដល់ខ្ញុំ គឺសូមព្រះអង្គថ្លែង ប្រាប់ សំដែង បញ្ញត្ត តម្កល់ទុក បើក បែក ធ្វើឲ្យរាក់ ប្រកាសដល់ខ្ញុំ ហេតុនោះ (ទ្រង់ត្រាស់សួរថា) សូមព្រះអង្គពោលដំណើរនុ៎ះ ដល់ខ្ញុំ ៗ ពាក្យថា (សុខទឹងទុក្ខ) បាត់បង់ទៅ ដោយប្រការយ៉ាងណា គឺ (សុខទឹងទុក្ខ) បាត់បង់ វិនាស កន្លង ឈានកន្លង ប្រព្រឹត្តកន្លងទៅ ដោយប្រការយ៉ាងណា ហេតុនោះ (ទ្រង់ត្រាស់សួរថា) សូមព្រះអង្គពោលដំណើរនុ៎ះ ដល់ខ្ញុំ (សុខទឹងទុក្ខ) បាត់បង់ទៅ ដោយប្រការយ៉ាងណា ៗ

(១៨១) តំ ជានិយាម ឥតិ មេ មនោ អហូតិ តំ ជានិយាមាតិ តំ ជានេយ្យាម អាជានេយ្យាម វិជានេយ្យាម បដិវិជានេយ្យាម បដិវិជ្ឈេយ្យាមាតិ តំ ជានិយាម ។ ឥតិ មេ មនោ អហូតិ ឥតិ មេ ចិត្តំ អហុ ឥតិ មេ សង្កប្បោ អហុ ឥតិ មេ វិញ្ញាណំ អហូតិ តំ ជានិយាម ឥតិ មេ មនោ អហុ ។ តេនាហ សោ និម្មិតោ

កថំសមេតស្ស វិភោតិ រូបំ
សុខំ ទុក្ខំ វាបិ កថំ វិភោតិ
ឯតម្មេ បព្រូហិ យថា វិភោតិ
តំ ជានិយាម ឥតិ មេ មនោ អហូតិ ។

(១៨២) ន សញ្ញសញ្ញី ន វិសញ្ញសញ្ញី
នោបិ អសញ្ញី ន វិភូតសញ្ញី
ឯវំសមេតស្ស វិភោតិ រូបំ

(១៨១) ពាក្យថា ឲ្យខ្ញុំយល់ច្បាស់ ព្រោះថា ខ្ញុំមានចិត្តដូច្នេះ ត្រង់ពាក្យថា ឲ្យខ្ញុំយល់ច្បាស់ គឺ ឲ្យខ្ញុំដឹង ដឹងជាក់ ដឹងច្បាស់ ដឹងប្រាកដ ចាក់ធ្លុះបំពោះ ហេតុនោះ (ទ្រង់ត្រាស់សួរថា) ឲ្យខ្ញុំយល់ច្បាស់ ។ ពាក្យថា ខ្ញុំមានចិត្តដូច្នេះ គឺចិត្តរបស់ខ្ញុំបានមានហើយដូច្នេះ តម្រិះរបស់ខ្ញុំ បានមានហើយដូច្នេះ វិញ្ញាណរបស់ខ្ញុំ បានមានហើយដូច្នេះ ហេតុនោះ (ទ្រង់ត្រាស់សួរថា) ឲ្យខ្ញុំយល់ច្បាស់ ព្រោះថា ខ្ញុំមានចិត្តដូច្នេះ ។ ហេតុនោះ ព្រះពុទ្ធនិម្មិតនោះពោលថា

បុគ្គលអ្នកព្រមព្រៀងដូចម្ដេច រូបទើបបាត់បង់ទៅ ទាំងសុខ
ទឹងទុក្ខ បាត់បង់ទៅ ដោយប្រការដូចម្ដេច សូមព្រះអង្គពោល
ដំណើរនុ៎ះដល់ខ្ញុំ ឲ្យខ្ញុំយល់ច្បាស់ថា (សុខទឹងទុក្ខ) បាត់
បង់ទៅ ដោយប្រការយ៉ាងណា ព្រោះថា ខ្ញុំមានចិត្តដូច្នេះ ។

(១៨២) (ព្រះមានព្រះភាគត្រាស់ថា) មិនមែនបុគ្គលមានសញ្ញា
ដោយសញ្ញា (ប្រក្រតី)ទេ មិនមែនបុគ្គលមានសញ្ញាដោយសញ្ញា
វិបល្លាសទេ[១] មិនមែនបុគ្គលមិនមានសញ្ញាទេ[២] មិនមែនបុគ្គល
មានសញ្ញាវិនាសទេ[៣] បុគ្គលអ្នកព្រមព្រៀងយ៉ាងនេះ រូប

១ សំដៅយកមនុស្សឆ្កួត ឬអ្នកមានចិត្តរវើរវាយ ។ ២ លោកចូលនិរោធ ឬ អសញ្ញីសត្វ ។ ៣ អ្នកចូលអរូបឈាន ។ អដ្ឋកថា ។

ឯកាទសមោ កលហវិវាទសុត្តនិទ្ទេសោ

សញ្ញានិទានា ហិ បបញ្ចសង្ខា ។

(១៨៣) ន សញ្ញសញ្ញី ន វិសញ្ញសញ្ញីតិ សញ្ញសញ្ញិនោ វុច្ចន្តិ យេ បកតិសញ្ញាយ ឋិតា ន បិ សោ បកតិសញ្ញាយ ឋិតោ ។ វិសញ្ញសញ្ញិនោ វុច្ចន្តិ ឧម្មត្តកា យេ ច ខិត្តចិត្តា ន បិ សោ ឧម្មត្តកោ នោបិ ខិត្តចិត្តោតិ ន សញ្ញសញ្ញី ន វិសញ្ញសញ្ញី ។

(១៨៤) នោបិ អសញ្ញី ន វិភូតសញ្ញីតិ អសញ្ញិនោ វុច្ចន្តិ និរោធសមាបន្នា យេ ច អសញ្ញសត្តា ន បិ សោ និរោធសមាបន្នោ នោបិ អសញ្ញសត្តោ ។ វិភូតសញ្ញិនោ វុច្ចន្តិ យេ ចតុន្នំ អរូបសមាបត្តីនំ លាភិនោ ន បិ សោ ចតុន្នំ អរូបសមាបត្តីនំ លាភីតិ នោបិ អសញ្ញី ន វិភូតសញ្ញី ។

រមែងវិនាស ព្រោះថា បបញ្ចសង្ខា (ធម៌ជាគ្រឿងញុំាងសត្វឲ្យយឺតយូរ) មានសញ្ញាជាហេតុ ។

(១៨៣) ពាក្យថា មិនមែនបុគ្គលមានសញ្ញា ដោយសញ្ញា (ប្រក្រតី)ទេ មិនមែនបុគ្គលមានសញ្ញា ដោយសញ្ញាវិបល្លាសទេ សេចក្តីថា ពួកជនណាឋិតនៅដោយសញ្ញាប្រក្រតី ពួកជននោះ លោកហៅថា អ្នកមានសញ្ញាដោយសញ្ញាប្រក្រតី ឯបុគ្គលនោះ មិនមែនឋិតនៅដោយសញ្ញាប្រក្រតីទេ ។ ពួកមនុស្សឆ្កួត នឹងពួកជនណា មានចិត្តរវើរវាយ ពួកជននោះ លោកហៅថា អ្នកមានសញ្ញាដោយសញ្ញាវិបល្លាស ឯបុគ្គលនោះមិនមែនឆ្កួត ទាំងមិនមែនមានចិត្តរវើរវាយទេ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនមែនបុគ្គលមានសញ្ញាដោយសញ្ញា (ប្រក្រតី)ទេ មិនមែនបុគ្គលមានសញ្ញាដោយសញ្ញាវិបល្លាសទេ ។

(១៨៤) ពាក្យថា មិនមែនបុគ្គលមិនមានសញ្ញាទេ មិនមែនបុគ្គលមានសញ្ញាវិនាសទេ សេចក្តីថា ពួកបុគ្គលអ្នកចូលនិរោធនឹងពួកអសញ្ញសត្វឯណា ពួកបុគ្គលនោះ លោកហៅថា អ្នកមិនមានសញ្ញា ឯបុគ្គលនោះ មិនមែនអ្នកចូលនិរោធ ទាំងមិនមែនអសញ្ញសត្វទេ ។ ពួកជនណា ជាអ្នកបានអរូបសមាបត្តិ ៤ ពួកជននោះ លោកហៅថា អ្នកមានសញ្ញាវិនាស ឯបុគ្គលនោះមិនមែនអ្នកបានអរូបសមាបត្តិ ៤ ទេ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនមែនបុគ្គលមិនមានសញ្ញាទេ មិនមែនបុគ្គលមានសញ្ញាវិនាសទេ ។

(១៨៥) ឯវំ សមេតស្ស វិភោតិ រូបន្តិ ឥធ ភិក្ខុ សុខស្ស ច បហានា ។បេ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាកាសានញ្ចាយតនសមាបត្តិបដិលាភត្ថាយ ចិត្តំ(១) អភិនិន្នាមេតិ អរូបមគ្គសមង្គីតិ ឯវំ សមេតស្ស ឯវំ បដិបន្នស្ស ឯវំ ឥរិយន្តស្ស ឯវំ វត្តេន្តស្ស ឯវំ បាលេន្តស្ស ឯវំ យបេន្តស្ស ឯវំ យាបេន្តស្ស រូបំ វិភោតិ វិភាវិយ្យតិ អតិក្កមិយ្យតិ សមតិក្កមិយ្យតិ វីតិវត្តិយ្យតីតិ ឯវំ សមេតស្ស វិភោតិ រូបំ ។

(១៨៦) សញ្ញានិទានា ហិ បបញ្ចសង្ខាតិ បបញ្ចាយេវ បបញ្ចសង្ខា តណ្ហាបបញ្ចសង្ខា ទិដ្ឋិបបញ្ចសង្ខា មានបបញ្ចសង្ខា សញ្ញានិទានា សញ្ញាសមុទយា សញ្ញាជាតិកា សញ្ញាបភវាតិ សញ្ញានិទានា ហិ បបញ្ចសង្ខា ។ តេនាហ ភគវា

---

១ ឱ. ម. ឯត្ថន្តរេ អភិនីហរតីតិ ទិស្សតិ ។

(១៨៥) ពាក្យថា បុគ្គលអ្នកព្រមព្រៀងយ៉ាងនេះ រូបរមែងវិនាស អធិប្បាយថា ភិក្ខុក្នុងសាសនានេះ ព្រោះការលះបង់សុខផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន កាលបើចិត្តតម្កល់ស៊ប់ បរិសុទ្ធ ផូរផង់ មិនមានកិលេស មានឧបក្កិលេសទៅប្រាសហើយ ជាចិត្តទន់ គួរដល់ការងារកម្ម ជាចិត្តនឹងនួន មិនញាប់ញ័រ យ៉ាងនេះហើយ ភិក្ខុនោះ ជាអ្នកព្រមព្រៀងក្នុងផ្លូវនៃអរូបសមាបត្តិ រមែងបង្អោនចិត្តទៅដើម្បីការបានអាកាសានញ្ចាយតនសមាបត្តិ បុគ្គលអ្នកព្រមព្រៀងយ៉ាងនេះ ប្រតិបត្តិយ៉ាងនេះ សម្រេចយ៉ាងនេះ ប្រព្រឹត្តយ៉ាងនេះ រក្សាយ៉ាងនេះ រស់នៅយ៉ាងនេះ ញុំាងអត្តភាពឲ្យរស់នៅយ៉ាងនេះ ដោយប្រការដូច្នេះ រូបរមែងវិនាសបាត់បង់ ឈានកន្លង ប្រព្រឹត្តកន្លងទៅ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលអ្នកព្រមព្រៀងយ៉ាងនេះ រូបរមែងវិនាស ។

(១៨៦) ពាក្យថា ព្រោះបបញ្ចសង្ខា មានសញ្ញាជាហេតុ សេចក្តីថា ធម៌ជាគ្រឿងញុំាងសត្វឲ្យយឺតយូរហ្នឹងឯង ឈ្មោះថា បបញ្ចសង្ខា បានដល់បបញ្ចសង្ខាគឺតណ្ហា បបញ្ចសង្ខាគឺទិដ្ឋិ បបញ្ចសង្ខាគឺមានះ មានសញ្ញាជាហេតុ មានសញ្ញាជាហេតុនាំឲ្យកើត មានសញ្ញាជាកំណើត មានសញ្ញាជាដែនកើតមុន ហេតុនោះ (ទ្រង់ត្រាស់ថា) បបញ្ចសង្ខា មានសញ្ញាជាហេតុ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ឯកាទសមោ កលហវិវាទសុត្តនិទ្ទេសោ

ន សញ្ញសញ្ញី ន វិសញ្ញសញ្ញី
នោបិ អសញ្ញី ន វិភូតសញ្ញី
ឯវំសមេតស្ស វិភោតិ រូបំ
សញ្ញានិទានា ហិ បបញ្ចសង្ខាតិ ៗ

(១៨៧) យន្តំ អបុច្ឆិម្ហ អកិត្តយី នោ
អញ្ញន្តំ បុច្ឆាម តទិង្ឃ ព្រូហិ
ឯត្តាវតគ្គំ នោ(១) វទន្តិ ហេកេ
យក្ខស្ស សុទ្ធឹ ឥធ បណ្ឌិតាសេ
ឧទាហុ អញ្ញំបិ វទន្តិ ឯត្តោ ៗ

(១៨៨) យន្តំ អបុច្ឆិម្ហ អកិត្តយី នោតិ យន្តំ អបុច្ឆិម្ហ អយាចិម្ហ អជ្ឈេសិម្ហ បសាទយិម្ហ ៗ អកិត្តយី នោតិ កិត្តិតំ បកិត្តិតំ អាចិក្ខិតំ ទេសិតំ បញ្ញបិតំ បដ្ឋបិតំ វិវដំ វិភត្តំ ឧត្តានីកតំ បកាសិតន្តិ យន្តំ អបុច្ឆិម្ហ អកិត្តយី នោ ៗ

---

១ ម. នុ ៗ

មិនមែនបុគ្គលមានសញ្ញា ដោយសញ្ញា (ប្រក្រតី) ទេ មិនមែនបុគ្គលមានសញ្ញាដោយសញ្ញាវិបល្លាសទេ មិនមែនបុគ្គលមិនមានសញ្ញាទេ មិនមែនបុគ្គលមានសញ្ញាវិនាសទេ បុគ្គលអ្នកព្រមព្រៀងយ៉ាងនេះ រូបរមែងវិនាស ព្រោះថា បបញ្ចសង្ខា មានសញ្ញាជាហេតុ ។

(១៨៧) (ព្រះពុទ្ធនិម្មិតសួរថា) យើងខ្ញុំបានសួរសេចក្តីណា ព្រះអង្គបានប្រាប់សេចក្តីនោះហើយ យើងខ្ញុំសូមសួរសេចក្តីដទៃចំពោះព្រះអង្គទៀត សូមព្រះអង្គ ប្រាប់សេចក្តីនោះ សមណព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ ជាបណ្ឌិត ពោលនូវសេចក្តីបរិសុទ្ធិរបស់យក្សថាប្រសើរ ដោយហេតុមានប្រ-មាណប៉ុណ្ណោះឬ ឬក៏ពោលសេចក្តីបរិសុទ្ធិដទៃ អំពីហេតុនេះ ។

(១៨៨) ពាក្យថា យើងខ្ញុំបានសួរសេចក្តីណា ព្រះអង្គបានប្រាប់សេចក្តីនោះហើយ គឺយើងខ្ញុំបានសួរ បានអង្វរ បានអារាធនា បានជ្រះថ្លានូវហេតុណា ។ ពាក្យថា ព្រះអង្គបានប្រាប់សេចក្តីនោះហើយ គឺព្រះអង្គបានសំដែង សំដែងទូទៅ ប្រាប់ ទេសនា បញ្ញត្ត តម្កល់ទុក បើក បែក ធ្វើឲ្យរាក់ ប្រកាសទុកហើយ ហេតុនោះ (ទ្រង់ត្រាស់សួរថា) យើងខ្ញុំបានសួរសេចក្តីណា ព្រះអង្គបានប្រាប់សេចក្តីនោះហើយ ។

(១៨៩) អញ្ញន្តំ បុច្ឆាម តទិង្ឃ ព្រូហីតិ អញ្ញន្តំ បុច្ឆាម អញ្ញន្តំ យាចាម អញ្ញន្តំ អជ្ឈេសាម អញ្ញន្តំ បសាទេម ឧត្តរឹ តំ បុច្ឆាម ។ តទិង្ឃ ព្រូហីតិ ឥង្ឃ ព្រូហិ អាចិក្ខ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរ វិភជ ឧត្តានីករោហិ បកាសេហីតិ អញ្ញន្តំ បុច្ឆាម តទិង្ឃ ព្រូហិ ។

(១៩០) ឯត្តាវតគ្គំ នោ វទន្តិ ហេកេ យក្ខស្ស សុទ្ធឹ ឥធ បណ្ឌិតាសេតិ ឯកេ សមណព្រាហ្មណា ឯត្តា-វតា អរូបសមាបត្តិយោ អគ្គំ សេដ្ឋំ វិសេដ្ឋំ បាមោក្ខំ ឧត្តមំ បវរំ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ ។ យក្ខស្សាតិ សត្តស្ស នរស្ស មាណវស្ស បោសស្ស បុគ្គលស្ស ជីវស្ស(១) ជាតុស្ស ជន្តុស្ស ឥន្ទគុស្ស(២)

១ ឱ. ម. ជគុស្ស ។ ២ ម ហិន្ទគុស្ស ។

(១៨៩) ពាក្យថា យើងខ្ញុំសូមសួរសេចក្ដីដទៃ ចំពោះព្រះអង្គទៀត សូមព្រះអង្គប្រាប់សេចក្ដីនោះ គឺយើងខ្ញុំសួរហេតុឯទៀត ចំពោះព្រះអង្គ សូមហេតុឯទៀត ចំពោះព្រះអង្គ អារាធនាហេតុឯទៀត ចំពោះព្រះអង្គ ជ្រះថ្លាហេតុឯទៀត ចំពោះព្រះអង្គ គឺសួរព្រះអង្គនូវសេចក្ដីដទៃតទៅទៀត ។ ពាក្យថា សូមព្រះអង្គប្រាប់សេចក្ដីនោះ គឺសូមព្រះអង្គពោល ប្រាប់ សំដែង បញ្ញត្ត តម្កល់ទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ (ទ្រង់ត្រាស់សួរថា) យើងខ្ញុំសូមសួរសេចក្ដីដទៃ ចំពោះព្រះអង្គទៀត សូមព្រះអង្គប្រាប់សេចក្ដីនោះ ។

(១៩០) ពាក្យថា សមណព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ ជាបណ្ឌិត ពោលនូវសេចក្ដីបរិសុទ្ធិ របស់យក្សថាប្រសើរ ដោយហេតុមានប្រមាណប៉ុណ្ណេះឬ សេចក្ដីថា សមណព្រាហ្មណ៍ ពួកខ្លះ ពោល សំដែង និយាយ បំភ្លឺ បញ្ចេញ នូវសេចក្ដីបរិសុទ្ធិ ថា ប្រសើរ ប្រសើរដោយវិសេស ប្រសើរបំផុត ជាប្រធាន ជាឧត្ដម ថ្លៃថ្លា ដោយហេតុមានប្រមាណប៉ុណ្ណេះ គឺដោយអរូបសមាបត្តិ ។ ពាក្យថា របស់យក្ស គឺរបស់សត្វ ជន មាណព បុរស បុគ្គល សត្វមានជីវិត សត្វមានជាតិ សត្វមានជក សត្វទៅដោយឥន្ទ្រិយ

មនុជស្ស ។ សុទ្ធិន្តិ សុទ្ធី វិសុទ្ធី បរិសុទ្ធី មុត្តី វិមុត្តី បរិមុត្តី ។ ឥធ បណ្ឌិតាសេតិ ឥធ បណ្ឌិតវាទា ថិរវាទា ញាណវាទា(១) ហេតុវាទា លក្ខណវាទា ការណវាទា ឋានវាទា សកាយ លទ្ធិយាតិ ឯត្តាវតគ្គំ នោ វទន្តិ ហេកេ យក្ខស្ស សុទ្ធី ឥធ បណ្ឌិតាសេ ។

(១៩១) ឧទាហុ អញ្ញំបិ វទន្តិ ឯត្តោតិ ឧទាហុ ឯកេ សមណព្រាហ្មណា ឯតា អរូបសមាបត្តិយោ អតិក្កមិត្វា សមតិក្កមិត្វា វីតិវត្តិត្វា ឯត្តោ អរូបតោ(២) អញ្ញំ ឧត្តរី យក្ខស្ស សុទ្ធី វិសុទ្ធី បរិសុទ្ធី មុត្តី វិមុត្តី បរិមុត្តី វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ ឧទាហុ អញ្ញំបិ វទន្តិ ឯត្តោ ។ តេវាហ សោ និម្មិតោ

១ ម. ថិរវាទា ញាយវាទា ។ ២ ម. អរូបសមាបត្តិតោ ។

សត្វកើតអំពីមនុស្ស ។ ពាក្យថា នូវសេចក្តីបរិសុទ្ធិ គឺនូវសេចក្តីស្អាត សេចក្តីផូរផង់ដោយវិសេស សេចក្តីម៉ត់ចត់ដោយជុំវិញ កិរិយារួច ការរួចដោយវិសេស ការរួចស្រឡះ ។ ពាក្យថា ជាបណ្ឌិតក្នុងលោកនេះ គឺពួកជនក្នុងលោកនេះ អ្នកមានវាទៈជាបណ្ឌិត មានវាទៈប្រកបដោយប្រាជ្ញា មានវាទៈប្រកបដោយញាណ មានវាទៈប្រកបដោយហេតុ មានវាទៈប្រកបដោយលក្ខណៈ មានវាទៈសមតាមការណ៍ មានវាទៈសមតាមឋានៈ សមតាមលទ្ធិរបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់សួរថា) សមណព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ ជាបណ្ឌិត ពោលនូវសេចក្តីបរិសុទ្ធិរបស់យក្សថា ប្រសើរ ដោយហេតុមានប្រមាណប៉ុណ្ណោះឬ ។

(១៩១) ពាក្យថា ឬក៏ពោលសេចក្តីបរិសុទ្ធិដទៃ អំពីហេតុនេះ សេចក្តីថា សមណព្រាហ្មណ៍ពួកខ្លះ ក្នុង ឈានក្នុង ប្រព្រឹត្តក្នុង នូវអរូបសមាបត្តិទាំងនុ៎ះ ហើយពោល សំដែង និយាយ បំភ្លឺ បញ្ចេញ នូវសេចក្តីស្អាត សេចក្តីផូរផង់ដោយវិសេស សេចក្តីម៉ត់ចត់ដោយជុំវិញ កិរិយារួច ការរួចដោយវិសេស ការរួចស្រឡះដទៃរបស់យក្ស ជាគុណជាតិក្រៅលែងជាងហេតុនេះ គឺជាងអរូបសមាបត្តិ ហេតុនោះ (ទ្រង់ត្រាស់សួរថា) ឬក៏ពោលសេចក្តីបរិសុទ្ធិដទៃ អំពីហេតុនេះ ។ ហេតុនោះ ព្រះពុទ្ធនិម្មិតនោះពោលថា

យន្តំ អបុច្ឆិម្ហ អកិត្តយី នោ
អញ្ញន្តំ បុច្ឆាម តទិង្ឃ ព្រូហិ
ឯត្តាវតគ្គំ នោ វទន្តិ ហេកេ
យក្ខស្ស សុទ្ធឹ ឥធ បណ្ឌិតាសេ
ឧទាហុ អញ្ញំបិ វទន្តិ ឯត្តោ ។

(១៩២) ឯត្តាវតគ្គំបិ វទន្តិ ហេកេ
យក្ខស្ស សុទ្ធឹ ឥធ បណ្ឌិតាសេ
តេសំ បុនេកេ សមយំ វទន្តិ
អនុបាទិសេសេ កុសលាវទានា ។

(១៩៣) ឯត្តាវតគ្គំបិ វទន្តិ ហេកេ យក្ខស្ស សុទ្ធឹ ឥធ បណ្ឌិតាសេតិ សន្តេកេ សមណព្រាហ្មណា សស្សតវាទា ឯត្តាវតា អរូបសមាបត្តិយោ(១) អគ្គំ សេដ្ឋំ វិសេដ្ឋំ បាមោក្ខំ ឧត្តមំ បវរំ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ ។

---

១ ម. ឯតា អរូបសមាបត្តិយោ ។

យើងខ្ញុំបានសួរសេចក្តីណា ព្រះអង្គបានប្រាប់សេចក្តីនោះហើយ យើងខ្ញុំសូមសួរសេចក្តីដទៃ ចំពោះព្រះអង្គទៀត សូមព្រះអង្គ ប្រាប់សេចក្តីនោះ សមណព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ ជាបណ្ឌិត ពោលនូវសេចក្តីបរិសុទ្ធិ របស់យក្ស ថាប្រសើរ ដោយហេតុមានប្រមាណប៉ុណ្ណេះឬ ឬក៏ពោលសេចក្តីបរិសុទ្ធិដទៃ អំពីហេតុនេះ ។

(១៩២) (ព្រះមានព្រះភាគ ត្រាស់ថា) សមណព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ ជាបណ្ឌិត ពោលនូវសេចក្តីបរិសុទ្ធិរបស់យក្សថា ប្រសើរ ដោយហេតុមានប្រមាណប៉ុណ្ណេះ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍មួយពួកទៀត ជាអ្នកប្រកាន់ថាខ្លួនឈ្លាសវៃ តែងពោលនូវសម័យ ក្នុងអនុបាទិសេសៈ ។

(១៩៣) ពាក្យថា សមណព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ ជាបណ្ឌិត ពោលនូវសេចក្តីបរិសុទ្ធិ របស់យក្សថា ប្រសើរ ដោយហេតុមានប្រមាណប៉ុណ្ណេះ សេចក្តីថា មានសមណព្រាហ្មណ៍ពួកខ្លះ ជាសស្សតវាទ ពោល សំដែង និយាយ បំភ្លឺ បញ្ចេញ (នូវសេចក្តីបរិសុទ្ធិ) ថាប្រសើរ ប្រសើរដោយវិសេស ប្រសើរបំផុត ជាប្រធាន ជាឧត្តម ថ្លៃថ្លា ដោយហេតុមានប្រមាណប៉ុណ្ណេះ គឺ ដោយអរូបសមាបត្តិ ។

យក្ខស្សាតិ សត្តស្ស នរស្ស មាណវស្ស បោសស្ស បុគ្គលស្ស ជីវស្ស ជាតុស្ស ជន្តុស្ស ឥន្ទគុស្ស មនុជស្ស ។ សុទ្ធិន្តិ សុទ្ធិ វិសុទ្ធិ បរិសុទ្ធិ មុត្តិ វិមុត្តិ បរិមុត្តិ ។ ឥធ បណ្ឌិតាសេតិ ឥធ បណ្ឌិតវាទា ធីរវាទា ញាណវាទា ហេតុវាទា លក្ខណវាទា ការណវាទា ឋានវាទា សកាយ លទ្ធិយាតិ ឯត្តាវតគ្គំបិ វទន្តិ ហេកេ យក្ខស្ស សុទ្ធឹ ឥធ បណ្ឌិតាសេ ។

(១៩៦) តេសំ បុនេកេ សមយំ វទន្តិ អនុបាទិសេសេ កុសលាវទានាតិ តេសំយេវ សមណព្រាហ្មណានំ ឯកេ សមណព្រាហ្មណា ឧច្ឆេទវាទា ភវតណ្ហិតា វិភវំ អភិនន្ទន្តិ តេ សត្តស្ស សមំ ឧបសមំ វូបសមំ និរោធំ បដិប្បស្សទ្ធឹ វទន្តិ

ពាក្យថា របស់យក្ស គឺ របស់សត្វ ជន មាណព បុរស បុគ្គល សត្វមានជីវិត សត្វមានជាតិ សត្វមានជក សត្វទៅដោយឥន្ទ្រិយ សត្វកើតអំពីមនុស្ស ។ ពាក្យថា នូវសេចក្តីបរិសុទ្ធិ គឺនូវសេចក្តីស្អាត សេចក្តីផូរផង់ដោយវិសេស សេចក្តីមិនសៅហ្មង ដោយជុំវិញ ការរួច ការរួចដោយវិសេស ការរួចស្រឡះ ។ ពាក្យថា ជាបណ្ឌិត ក្នុងលោកនេះ គឺជាអ្នកមានវាទៈជាបណ្ឌិតមា នវាទៈប្រកបដោយប្រាជ្ញា មានវាទៈប្រកបដោយញាណ មានវាទៈប្រកបដោយហេតុ មានវាទៈប្រកបដោយលក្ខណៈ មានវាទៈប្រកបដោយការណ៍ មានវាទៈសមតាមឋានៈ សមតាមលទ្ធិ របស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) សមណព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ ជាបណ្ឌិត ពោលនូវសេចក្តីបរិសុទ្ធិរបស់យក្សថាប្រសើរ ដោយហេតុមានប្រមាណប៉ុណ្ណោះ ។

(១៩៨) ពាក្យថា បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍មួយពួកទៀត ជាអ្នកប្រកាន់ថាខ្លួនឈ្លាសវៃ ពោលនូវសម័យក្នុងអនុបាទិសេសៈ សេចក្តីថា បណ្តាសមណព្រាហ្មណ៍ទាំងនោះឯងសមណព្រាហ្មណ៍ពួកខ្លះ ជាឧច្ឆេទវាទ ជាអ្នកតក់ស្លុតអំពីភព ហើយត្រេកអរនូវការប្រាសចាកភព សមណព្រាហ្មណ៍ទាំងនោះ ពោលនូវសេចក្តីស្ងប់ ការស្ងប់វិសេស ការស្ងប់ម្យ៉ាង ការរលត់ ការស្ងប់ឈឹង

យតោ កិរ ភោ អយំ អត្តា កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណា ។ ឯត្តាវតា អនុបាទិសេសេវាតិ ។ កុសលាវទានាតិ កុសលវាទា បណ្ឌិតវាទា ធីរវាទា ញាណវាទា ហេតុវាទា លក្ខណវាទា ការណវាទា ឋានវាទា សកាយ លទ្ធិយាតិ តេសំ បុនេកេ សមយំ វទន្តិ អនុបាទិសេសេ កុសលាវទានា ។ តេនាហ ភគវា

ឯត្តាវតគ្គំបិ វទន្តិ ហេកេ
យក្ខស្ស សុទ្ធឹ ឥធ បណ្ឌិតាសេ
តេសំ បុនេកេ សមយំ វទន្តិ
អនុបាទិសេសេ កុសលាវទានាតិ ។

របស់សត្វថា ម្នាលអ្នកទាំងឡាយដ៏ចំរើន កាលដែល អត្តា (ខ្លួនឬចិត្ត) នេះ បែកធ្លាយពង្សកាយ ស្លាប់ទៅ រមែងសូន្យ វិនាស មិនកើតទៀត ។ អត្តានោះ ជាសភាវៈមិនមានទុក្ខជាទីសល់នៅ ដោយហេតុត្រឹមប៉ុណ្ណោះ ។ ពាក្យថា ជាអ្នកប្រកាន់ថាខ្លួនឈ្លាសវៃ គឺ ជាអ្នកមានវាទៈដ៏ឈ្លាស មានវាទៈជាបណ្ឌិត មានវាទៈប្រកបដោយប្រាជ្ញា មានវាទៈប្រកបដោយញាណ មានវាទៈប្រកបដោយហេតុ មានវាទៈប្រកបដោយលក្ខណៈ មានវាទៈប្រកបដោយការណ៍ មានវាទៈសមតាមឋានៈ សមតាមលទ្ធិរបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍មួយពួកទៀត ជាអ្នកប្រកានថាខ្លួនឈ្លាសវៃ តែងពោលនូវសម័យ ក្នុងអនុបាទិសេសៈ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> សមណព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ ជាបណ្ឌិត ពោលនូវសេចក្តីបរិសុទ្ធិ របស់យក្សថា ប្រសើរ ដោយហេតុមានប្រមាណប៉ុណ្ណោះ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណ-ព្រាហ្មណ៍មួយពួកទៀត ជាអ្នកប្រកាន់ថាខ្លួនឈ្លាសវៃ ពោលនូវសម័យ ក្នុងអនុបាទិសេសៈ ។

## ឯកាទសមោ កលហវិវាទសុត្តនិទ្ទេសោ

(១៩៥) ឯតេ ច ញត្វា ឧបនិស្សិតាតិ

ញត្វា មុនី និស្សយេ សោ វិមំសី

ញត្វា វិមុត្តោ ន វិវាទមេតិ

ភវាភវាយ ន សមេតិ ធីរោ ។

(១៩៦) ឯតេ ច ញត្វា ឧបនិស្សិតាតិ ឯតេតិ ទិដ្ឋិគតិកេ ។ ឧបនិស្សិតាតិ សស្សតទិដ្ឋិនិស្សិតាតិ ញត្វា ឧច្ឆេទទិដ្ឋិនិស្សិតាតិ ញត្វា សស្សតុច្ឆេទទិដ្ឋិនិស្សិតាតិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ ឯតេ ច ញត្វា ឧបនិស្សិតាតិ ។

(១៩៧) ញត្វា មុនី និស្សយេ សោ វិមំសីតិ មុនីតិ មោនំ វុច្ចតិ ញាណំ ។បេ។ សង្គជាលមតិច្ច សោ មុនិ ។ មុនិ សស្សតទិដ្ឋិនិស្សិតាតិ ញត្វា ឧច្ឆេទទិដ្ឋិនិស្សិតាតិ ញត្វា សស្សតុច្ឆេទទិដ្ឋិនិស្សិតាតិ ញត្វា[១] ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា ។

---

១ ឱ ញត្វាតិ ញត្វា ។

កលហវិវាទសុត្តនិទ្ទេស ទី ១១

(១៩៥) មុនិ ជាអ្នកមានប្រាជ្ញា ជាធីរៈនោះ ដឹងនូវពួកជនទាំងនុ៎ះថា ជាអ្នកអាស្រ័យ (នូវទិដ្ឋិ) ផង ដឹងនូវនិស្ស័យទាំងឡាយផង លុះដឹងហើយទើបជាអ្នករួចស្រឡះ រមែងមិនដល់នូវវិវាទ មិនអន្ទោលទៅ ក្នុងកពតូចកពធំ ។

(១៩៦) ពាក្យថា ដឹងនូវពួកជនទាំងនុ៎ះ ថាជាអ្នកអាស្រ័យ (នូវទិដ្ឋិ) ផង ត្រង់ពាក្យថា ពួកជនទាំងនុ៎ះ គឺ បុគ្គលអ្នកលុះក្នុងទិដ្ឋិ ។ ពាក្យថា ជាអ្នកអាស្រ័យ គឺដឹងថា ជាអ្នកអាស្រ័យសស្សតទិដ្ឋិ ដឹងថា ជាអ្នកអាស្រ័យឧច្ឆេទទិដ្ឋិ ដឹង ស្គាល់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដថា ជាអ្នកអាស្រ័យសស្សតទិដ្ឋិ នឹង ឧច្ឆេទទិដ្ឋិ ហេតុនោះ (ទ្រង់ត្រាស់ថា) ដឹងនូវពួកជនទាំងនុ៎ះថា ជាអ្នកអាស្រ័យ (នូវទិដ្ឋិ) ផង ។

(១៩៧) ពាក្យថា មុនិ ជាអ្នកមានប្រាជ្ញានោះ ដឹងនូវនិស្ស័យទាំងឡាយ ត្រង់ពាក្យថា មុនិ សេចក្តីថា ញាណ លោកហៅថា មោនៈ ។បេ។ មុនិនោះ កន្លងនូវបណ្តាញ ជាគ្រឿងជាប់ចំពាក់ ។ មុនិដឹងថា បុគ្គលនេះ អាស្រ័យសស្សតទិដ្ឋិ ដឹងថា បុគ្គលនេះ អាស្រ័យឧច្ឆេទទិដ្ឋិ ដឹង ស្គាល់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដថា បុគ្គលនេះអាស្រ័យសស្សតទិដ្ឋិ នឹង ឧច្ឆេទទិដ្ឋិ ។

សោ វិមំសីតិ បណ្ឌិតោ បញ្ញវា ពុទ្ធិមា ញាណី វិភាវី មេធាវីតិ ញត្វា មុនី និស្សយេ សោ វិមំសី ។

(១៩៨) ញត្វា វិមុត្តោ ច វិធមេតីតិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា មុត្តោ វិមុត្តោ បរិមុត្តោ សុវិមុត្តោ អច្ចន្តអនុបាទាវិមោក្ខេន សព្វេ សង្ខារា អនិច្ចាតិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា មុត្តោ វិមុត្តោ បរិមុត្តោ សុវិមុត្តោ អច្ចន្តអនុបាទាវិមោក្ខេន សព្វេ សង្ខារា ទុក្ខាតិ សព្វេ ធម្មា អនត្តាតិ ។បេ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា មុត្តោ វិមុត្តោ បរិមុត្តោ សុវិមុត្តោ អច្ចន្តអនុបាទាវិមោក្ខេនាតិ ញត្វា វិមុត្តោ ។ ច វិធមេតីតិ ច កលហំ ករោតិ ច ភណ្ឌនំ ករោតិ ច វិគ្គហំ ករោតិ ច

ពាក្យថា មុនិជាអ្នកមានប្រាជ្ញានោះ គឺជាបណ្ឌិត អ្នកមានប្រាជ្ញា អ្នកមានសេចក្តីត្រាស់ដឹង អ្នកមានញាណ អ្នកមានសេចក្តីឈ្វេងយល់ អ្នកមានប្រាជ្ញាជាគ្រឿងកំចាត់កិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) មុនិជាអ្នកមានប្រាជ្ញានោះ ដឹងនូវនិស្ស័យទាំងឡាយ ។

(១៩៨) ពាក្យថា លុះដឹងហើយ ទើបជាអ្នករួចស្រឡះ រមែងមិនដល់នូវវិវាទ គឺ លុះដឹង ស្គាល់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដហើយ ទើបជាអ្នករួច រួចស្រឡះ រួចផុត រួចស្រឡះដោយប្រពៃ ដោយអចួនអនុបាទាវិមោក្ខ គឺថា លុះដឹង ស្គាល់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដថា សង្ខារទាំងពួងមិនទៀង ហើយជាអ្នករួច រួចស្រឡះ រួចផុត រួចដោយប្រពៃ ដោយអចួនអនុបាទាវិមោក្ខ លុះដឹង ស្គាល់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដថា សង្ខារទាំងពួង ជាទុក្ខ ថា ធម៌ទាំងពួងជាអនត្តា ។ បេ ។ ថា វត្ថុណាមួយ មានកិរិយាកើតជាធម្មតា វត្ថុទាំងអស់នោះមានកិរិយារលត់ទៅវិញជាធម្មតា ហើយជាអ្នករួច រួចស្រឡះ រួចផុត រួចស្រឡះដោយប្រពៃ ដោយអចួនអនុបាទាវិមោក្ខ ហេតុនោះ (ទ្រង់ត្រាស់ថា) លុះដឹងហើយ ទើបជាអ្នករួចស្រឡះ ។ ពាក្យថា រមែងមិនដល់នូវវិវាទ គឺរមែងមិនធ្វើនូវកិរិយាឈ្លោះប្រកែក មិនធ្វើនូវជម្លោះ មិនធ្វើ នូវសេចក្តីប្រកួតប្រកាន់ មិនធ្វើនូវវិវាទ មិនធ្វើនូវការទាស់ទែង ។ សមដូចពាក្យនុ៎ះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា

ឯកាទសមោ កលហវិវាទសុត្តនិទ្ទេសោ

វិវាទំ ការេតិ ន មេធគំ ការេតិ ។ វុត្តំ ហេតំ ភគវតា ឯវំ វិមុត្តចិត្តោ ខោ អគ្គិវេស្សន ភិក្ខុ ន កេនចិ សំវទតិ ន កេនចិ វិវទតិ យញ្ច លោកេ វុត្តំ តេន ច វោហរតិ អបរាមសន្តិ ។ ញត្វា ន វិវាទមេតិ ។

(១៩៩) ភវាភវាយ ន សមេតិ ធីរោតិ ភវាភវាយាតិ ភវាភវាយ កម្មភវាយ បុនព្ភវាយ កាមភវាយ កម្មភវាយ កាមភវាយ បុនព្ភវាយ រូបភវាយ កម្មភវាយ រូបភវាយ បុនព្ភវាយ អរូបភវាយ កម្មភវាយ អរូបភវាយ បុនព្ភវាយ បុនប្បុនំ ភវាយ បុនប្បុនំ គតិយា បុនប្បុនំ ឧបបត្តិយា បុនប្បុនំ បដិសន្ធិយា បុនប្បុនំ អត្តភាវាភិនិព្វត្តិយា ន សមេតិ ន សមាគច្ឆតិ ន គណ្ហាតិ ន បរាមសតិ នាភិនិវិសតិ ។ ធីរោតិ ធីរោ បណ្ឌិតោ បញ្ញវា ពុទ្ធិមា ញាណី វិភាវី មេធាវីតិ ភវាភវាយ ន សមេតិ ធីរោ ។ តេនាហ ភគវា

ម្នាលអគ្គិវេស្សនៈ ភិក្ខុមានចិត្តរួចស្រឡះយ៉ាងនេះហើយ រមែងមិនឈ្លោះនឹងនរណាមួយ មិនទាស់ទែងនឹងនរណាមួយ ពាក្យឯណា ដែលគេនិយាយហើយក្នុងលោក ភិក្ខុនោះរមែងពោលតាមពាក្យនោះ តែមិនប្រកាន់ ។ ហេតុនោះ (ទ្រង់ត្រាស់ថា) លុះដឹងហើយ ទើបជាអ្នករួចស្រឡះ រមែងមិនដល់នូវវិវាទ ។

(១៩៩) ពាក្យថា ជាធីរៈ មិនអន្ទោលទៅ ក្នុងភពតូចភពធំ ត្រង់ពាក្យថា ក្នុងភពតូចភពធំ គឺមិនអន្ទោលទៅ មិនមក មិនកាន់យក មិនស្ទាបអង្អែល មិនជាប់ចំពាក់ ក្នុងកម្មភព បុនព្ភព ឈ្មោះថាក្នុងភពតូចភពធំ កាមភព ឈ្មោះកម្មភព កាមភព ឈ្មោះបុនព្ភព រូបភព ឈ្មោះកម្មភព រូបភព ឈ្មោះបុនព្ភព អរូបភព ឈ្មោះកម្មភព អរូបភព ឈ្មោះបុនព្ភព ក្នុងការកើតរឿយ ៗ ទៅរឿយ ៗ ការកើតឡើងរឿយ ៗ បដិសន្ធិរឿយ ៗ ការកើតឡើងចំពោះនៃអត្តភាពរឿយ ៗ ។ ពាក្យថា ជាធីរៈ គឺជាអ្នកប្រាជ្ញ ជាបណ្ឌិត អ្នកមានប្រាជ្ញ អ្នកមានការត្រាស់ដឹង មានញាណ មានសេចក្ដីឈ្វេងយល់ មានប្រាជ្ញាទំលុះទំលាយ ហេតុនោះ (ទ្រង់ត្រាស់ថា) ជាធីរៈ មិនអន្ទោលទៅក្នុងភពតូចភពធំ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ឯតេ ច ញត្វា ឧបនិស្សិតាតិ
ញត្វា មុនី និស្សយេ សោ វិមំសី
ញត្វា វិមុត្តោ ន វិវាទមេតិ
ភវាភវាយ ន សមេតិ ធីរោតិ ។

ឯកាទសមោ កលហវិវាទសុត្តនិទ្ទេសោ និដ្ឋិតោ ។

មុនិជាអ្នកមានប្រាជ្ញា ជាធីរៈនោះ ដឹងនូវពួកជនទាំងនុ៎ះថា ជាអ្នកអាស្រ័យ (នូវទិដ្ឋិ) ផង ដឹងនូវនិស្ស័យទាំងឡាយផង លុះដឹងហើយ ទើបជាអ្នករួចស្រឡះ រមែងមិនដល់នូវវិវាទ មិនអន្ទោលទៅ ក្នុងភពតូចភពធំ ។

ចប់ កលហវិវាទសុត្តនិទ្ទេស ទី ១១ ។

## ទ្វាទសមោ ចូឡវិយ្យូហសុត្តនិទ្ទេសោ

(២០០) សកំ សកំ ទិដ្ឋិបរិព្វសានា
វិគ្គយ្ហ នានា(១) កុសលា វទន្តិ(២)
យោ ឯវំ ជានាតិ ស វេទិ ធម្មំ
ឥទំ បដិក្កោសមកេវលី សោ ។

(២០១) សកំ សកំ ទិដ្ឋិបរិព្វសានាតិ សន្តេកេ សមណព្រាហ្មណា ទិដ្ឋិគតិកា តេ ទ្វាសដ្ឋិយា ទិដ្ឋិគតានំ អញ្ញតរញ្ញតរំ ទិដ្ឋិគតំ គហេត្វា ឧគ្គហេត្វា គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វា សកាយ សកាយ ទិដ្ឋិយា វសន្តិ សំវសន្តិ អាវសន្តិ បរិវសន្តិ ។ យថា អាគារិកា វា ឃរេសុ វសន្តិ សាបត្តិកា វា អាបត្តីសុ វសន្តិ សកិលេសា វា កិលេសេសុ វសន្តិ ឯវមេវ សន្តេកេ សមណព្រាហ្មណា ទិដ្ឋិគតិកា តេ ទ្វាសដ្ឋិយោ ទិដ្ឋិគតានំ អញ្ញតរញ្ញតរំ ទិដ្ឋិគតំ គហេត្វា ឧគ្គហេត្វា គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វា សកាយ សកាយ ទិដ្ឋិយា វសន្តិ សំវសន្តិ អាវសន្តិ បរិវសន្តីតិ សកំ សកំ ទិដ្ឋិបរិព្វសានា ។

---

១ ម. នានំ ។ ២ ម. បជានាតី បវេទិ ធម្មំ ។

# ចូឡវិយូហសុត្តនិទ្ទេស ទី ១២

(២០០) (ព្រះពុទ្ធនិម្មិតសួរថា) ជនទាំងឡាយ ប្រកាន់ថា ខ្លួនឈ្លាសវៃ ជាអ្នកដំអក់នៅ ក្នុងទិដ្ឋិរបស់ខ្លួន ៗ រមែង ប្រកាន់យក (នូវទិដ្ឋិនោះ) ហើយពោលផ្សេងៗ ថា បុគ្គល ណាដឹងយ៉ាងនេះ បុគ្គលនោះ ឈ្មោះថាដឹងធម៌ បុគ្គល ណា បដិសេធសេចក្ដីនេះ បុគ្គលនោះ ឈ្មោះថាមិនមាន គុណធម៌បរិបូណ៌ ។

(២០១) ពាក្យថា ជាអ្នកដំអក់នៅក្នុងទិដ្ឋិរបស់ខ្លួន ៗ អធិប្បាយ ថា មានសមណព្រាហ្មណ៍ពួកខ្លះ ជាអ្នកលុះក្នុងទិដ្ឋិ សមណព្រាហ្មណ៍ ទាំងនោះ កាន់យក រៀនយក ប្រកាន់ បរាមាសអង្អែល ជាប់ ចិត្ត បណ្ដាទិដ្ឋិ ៦២ នូវទិដ្ឋិណាមួយ ហើយនៅ នៅរួម នៅគ្រប់គ្រង នៅត្រាំ ក្នុងទិដ្ឋិរបស់ខ្លួន ៗ ។ ពួកអ្នកមានផ្ទះក្ដី រមែងនៅក្នុងផ្ទះ ពួកអ្នកត្រូវអាបត្តិក្ដី រមែងនៅក្នុងអាបត្តិ ពួកអ្នកប្រកបដោយកិលេសក្ដី រមែងនៅក្នុងកិលេស យ៉ាងណា មានសមណព្រាហ្មណ៍ពួកខ្លះ ជាអ្នកលុះ ក្នុងទិដ្ឋិ សមណព្រាហ្មណ៍ទាំងនោះ កាន់យក រៀនយក ប្រកាន់យក បរាមាសអង្អែល ជាប់ចិត្ត បណ្ដាទិដ្ឋិ ទាំង ៦២ នូវទិដ្ឋិណាមួយ ហើយនៅ នៅរួម នៅគ្រប់គ្រង នៅត្រាំ ក្នុងទិដ្ឋិ របស់ខ្លួន ៗ ហេតុនោះ (ទ្រង់ត្រាស់សួរថា) ជាអ្នកដំអក់នៅក្នុងទិដ្ឋិរបស់ខ្លួន ៗ ។

(២០២) វិគ្គយ្ហ នានា កុសលា វទន្តីតិ វិគ្គយ្ហាតិ គហេត្វា ឧគ្គហេត្វា គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វា ។ នានា វទន្តីតិ នានា វទន្តិ វិវិធំ វទន្តិ អញ្ញោញ្ញំ វទន្តិ បុថុ វទន្តិ ន ឯកំ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ ។ កុសលាតិ កុសលវាទា បណ្ឌិតវាទា ថិរវាទា ញាណវាទា ហេតុវាទា លក្ខណវាទា ការណវាទា ឋានវាទា សកាយ លទ្ធិយាតិ វិគ្គយ្ហ នានា កុសលា វទន្តិ ។

(២០៣) យោ ឯវំ ជានាតិ ស វេទិ ធម្មន្តិ យោ ឥមំ ធម្មំ ទិដ្ឋិំ បដិបទំ មគ្គំ ជានាតិ សោ ធម្មំ វេទិ អញ្ញាសិ អបស្សិ បដិវិជ្ឈីតិ យោ ឯវំ ជានាតិ ស វេទិ ធម្មំ ។

(២០២) អធិប្បាយពាក្យថា ប្រកាន់ថា ខ្លួនឈ្លាសវៃ រមែងប្រកាន់យក (នូវទិដ្ឋិនោះ) ហើយពោលផ្សេង ៗ ត្រង់ពាក្យថា ប្រកាន់យក គឺកាន់យក រៀនយក ប្រកាន់យក បបោសអង្អែល ជាប់ចិត្ត ។ ពាក្យថា ពោលផ្សេង ៗ គឺនិយាយផ្សេង ៗ ពោលពាក្យមានប្រការផ្សេងៗ ពោលពាក្យដទៃ ៗ ពោលពាក្យច្រើន ពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយ នូវពាក្យជាអនេក ។ ពាក្យថា ប្រកាន់ថា ជាអ្នកឈ្លាសវៃ បានសេចក្តីថា មានវាទៈដ៏ឈ្លាស មានវាទៈជាបណ្ឌិត មានវាទៈជាអ្នកប្រាជ្ញ មានវាទៈប្រកបដោយញាណ មានវាទៈត្រូវតាមទំនង មានវាទៈប្រកបដោយលក្ខណៈ មានវាទៈប្រកបដោយហេតុ មានវាទៈគួរដល់ឋានៈតាមលទ្ធិរបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់សួរថា) ប្រកាន់ថាខ្លួនឈ្លាសវៃ រមែងប្រកាន់យក (នូវទិដ្ឋិនោះ) ហើយពោលពាក្យផ្សេងៗ ។

(២០៣) ពាក្យថា បុគ្គលណាដឹងយ៉ាងនេះ បុគ្គលនោះឈ្មោះថាដឹងធម៌ គឺបុគ្គលណា ដឹងនូវធម៌ នូវទិដ្ឋិ នូវបដិបទា នូវមគ្គនេះ បុគ្គលនោះ ឈ្មោះថាដឹង បានដឹង បានឃើញ ចាក់ធ្លុះនូវធម៌ ហេតុនោះ (ទ្រង់ត្រាស់សួរថា) បុគ្គលណា ដឹងយ៉ាងនេះ បុគ្គលនោះឈ្មោះថាដឹងធម៌ ។

ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ

(២០៨) ឥទំ បដិក្កោសមកេវលី សោតិ យោ
ឥទំ ធម្មំ ទិដ្ឋឹ បដិបទំ មគ្គំ បដិក្កោសតិ អកេវលី
សោ អសមត្តោ អបរិបុណ្ណោ ហីនោ និហីនោ
ឱមកោ លាមកោ ជតុក្កោ(១) បរិត្តោតិ ឥទំ
បដិក្កោសមកេវលី សោ ។ តេនាហ សោ និម្មិតោ

សកំ សកំ ទិដ្ឋិបរិព្វសានា
វិគ្គយ្ហ នានា កុសលា វទន្តិ
យោ ឯវំ ជានាតិ ស វេទិ ធម្មំ
ឥទំ បដិក្កោសមកេវលី សោតិ ។

(២០៩) ឯវម្បិ វិគ្គយ្ហ វិវាទយន្តិ(២)
ពាលោ បរោ អក្កុសលោតិ ចាហុ
សច្ចោ នុ វាទោ កតមោ ឥមេសំ
សព្វេវ ហីមេ កុសលាវទានា ។

---

១ ម. ឆតុក្កោ ។ ២ ឱ វិវាទិយន្តិ ។

ចូឡវិយូហសុត្តនិទ្ទេស ទី ១២

(២០៨) ពាក្យថា បុគ្គលណា បដិសេធសេចក្តីនេះ បុគ្គលនោះ ឈ្មោះថាមិនមានគុណធម៌បរិបូណ៌ គឺ បុគ្គលណា ឃាត់នូវធម៌ នូវទិដ្ឋិ នូវបដិបទា នូវមគ្គនេះ បុគ្គលនោះ ឈ្មោះថាជាមនុស្សមិនពេញលេញ មិនគ្រប់គ្រាន់ មិនបរិបូណ៌ ជាបុគ្គលថោកទាប ហីន ហោច អាប់ឱន លាមក គម្រក់ រលីបរលាប ហេតុនោះ (ទ្រង់ត្រាស់សួរថា) បុគ្គលណា បដិសេធសេចក្តីនេះ បុគ្គលនោះ ឈ្មោះថាមិនមានគុណធម៌បរិបូណ៌ ។ ហេតុនោះ ព្រះពុទ្ធនិម្មិតនោះ ត្រាស់សួរថា

ជនទាំងឡាយ ប្រកាន់ថាខ្លួនឈ្លាសវៃ ជាអ្នកដំអក់នៅក្នុង
ទិដ្ឋិ របស់ខ្លួនៗ រមែងប្រកាន់យក (នូវទិដ្ឋិនោះ) ហើយ
ពោលផ្សេងៗ ថា បុគ្គលណា ដឹងយ៉ាងនេះ បុគ្គលនោះ
ឈ្មោះថាដឹងធម៌ បុគ្គលណា បដិសេធសេចក្តីនេះ បុគ្គល
នោះ ឈ្មោះថាមិនមានគុណធម៌បរិបូណ៌ ។

(២០៩) ជនទាំងឡាយ ប្រកាន់យ៉ាងនេះហើយ រមែងទាស់
ទែងគ្នា ទាំងពោលថាជាមនុស្សពាល ទន់ទាប មិនឈ្លាសវៃ
តើវាទៈដូចម្តេច របស់ជនទាំងនេះ ជាវាទៈពិត ព្រោះថា
ជនទាំងនេះ ជាអ្នកពោលថា ខ្លួនឈ្លាសវៃ ទាំងអស់គ្នា ។

(២០៦) ឯវម្បិ វិគ្គយ្ហ វិវាទយន្តីតិ ឯវំ គហេត្វា ឧគ្គហេត្វា គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វា វិវាទយន្តិ កលហំ ករោន្តិ ភណ្ឌនំ (វិគ្គហំ) ករោន្តិ វិវាទំ ករោន្តិ មេធគំ ករោន្តិ ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ ។បេ។ និព្ពេធេហិ វា សចេ បហោសីតិ ឯវម្បិ វិគ្គយ្ហ វិវាទយន្តិ ។

(២០៧) ពាលោ បរោ អកុសលោតិ ចាហូតិ បរោ ពាលោ ហីនោ និហីនោ ឱមកោ លាមកោ ឆតុក្កោ បរិត្តោ អកុសលោ អវិទ្វា(១) អវិជ្ជាគតោ អញ្ញាណី អវិភាវី ទុប្បញ្ញោតិ ឯវមាហំសុ ឯវំ កថេន្តិ ឯវំ ភណន្តិ ឯវំ ទីបយន្តិ ឯវំ វោហរន្តីតិ ពាលោ បរោ អកុសលោតិ ចាហុ ។

១ ឱ. ម. អវិទូ ។

(២០៦) ពាក្យថា ជនទាំងឡាយ ប្រកាន់យ៉ាងនេះហើយ រមែងទាស់ទែងគ្នា សេចក្តីថា ជនទាំងឡាយ កាន់យក រៀនយក ប្រកាន់យក បរាមាសអង្អែល ជាប់ចិត្ត យ៉ាងនេះហើយ រមែងទាស់ទែងគ្នា គឺធ្វើនូវជម្លោះ ធ្វើនូវសេចក្តីប្រកួតប្រកាន់ ធ្វើនូវសេចក្តីប្រកាន់ខុស ធ្វើនូវវិវាទ ធ្វើនូវការប្រណាំងប្រជែងថា អ្នកមិនចេះធម៌វិន័យនេះទេ ។ បេ ។ ឬបើ អ្នកអាច អ្នកចូរដោះស្រាយឲ្យរួចចុះ ហេតុនោះ (ទ្រង់ត្រាស់ថា) ជនទាំងឡាយ ប្រកាន់យ៉ាងនេះហើយ រមែងទាស់ទែងគ្នា ។

(២០៧) ពាក្យថា ទាំងពោលថា ជាមនុស្សពាល ទន់ទាប មិនឈ្លាសវៃ គឺ បានពោលយ៉ាងនេះ ថ្លែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ ពន្យល់យ៉ាងនេះ អធិប្បាយយ៉ាងនេះថា បុគ្គលនេះជាមនុស្សទន់ទាប ជាបុគ្គលពាល ថោកទាប ថោកថយ អ័ប្បឱន លាមក គម្រក់ ជាមនុស្សកម្លេចកម្លី មិនឈ្លាស មិនយល់ ជាអ្នកលុះក្នុងអំណាចអវិជ្ជា ជាបុគ្គលមិនមានញាណ មិនមានការពិចារណា ដោយញាណ អ័ប្បឥតប្រាជ្ញា ហេតុនោះ ( ទ្រង់ត្រាស់សួរថា ) ទាំងពោលថា ជាមនុស្សពាល ទន់ទាប មិនឈ្លាសវៃ ។

ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ

(២០៨) សច្ចោ នុ ភោតោ កតមោ ឥមេសន្តិ ឥមេសំ សមណព្រាហ្មណានំ ភោតោ កតមោ សច្ចោ តច្ឆោ តថោ ភូតោ យាថាវោ អវិបរីតោតិ(១) សច្ចោ នុ ភោតោ កតមោ ឥមេសំ ។

(២០៩) សព្វេវ ហីមេ កុសលាវទានាតិ សព្វេវិមេ សមណព្រាហ្មណា កុសលវាទា បណ្ឌិតវាទា ធីរវាទា ញាណវាទា ហេតុវាទា លក្ខណវាទា ការណវាទា ឋានវាទា សកាយ លទ្ធិយាតិ សព្វេវ ហីមេ កុសលាវទានា ។ តេនាហ សោ និម្មិតោ

ឯវម្បិ វិគ្គយ្ហ វិវាទយន្តិ
ពាលោ បរោ អកុសលោតិ ចាហុ
សច្ចោ នុ ភោតោ កតមោ ឥមេសំ
សព្វេវ ហីមេ កុសលាវទានាតិ ។

១ ឱ. អវិបរិត្តោតិ ។

ចូឡវិយូហសុត្តនិទ្ទេស ទី ១២

[២០៨] ពាក្យថា តើវាទៈដូចម្តេច របស់ជនទាំងនេះ ជាវាទៈពិត គឺ វាទៈដូចម្តេច របស់សមណព្រាហ្មណ៍ទាំងនេះ ជាវាទៈពិត ប្រាកដ មែន ទៀងទាត់ ត្រឹមត្រូវ មិនវិបរិត ហេតុនោះ (ទ្រង់ត្រាស់សួរថា) តើវាទៈដូចម្តេច របស់ជនទាំងនេះ ជាវាទៈពិត ។

[២០៩] ពាក្យថា ព្រោះថាជនទាំងនេះ ជាអ្នកពោលថាខ្លួនឈ្លាសវៃ ទាំងអស់គ្នា គឺ សមណព្រាហ្មណ៍ទាំងអស់នេះ ជាអ្នកពោលថាខ្លួនជាអ្នកឈ្លាសវៃ ពោលថាជាបណ្ឌិត ពោលថាជាអ្នកប្រាជ្ញ ពោលថាប្រកបដោយញាណ ពោលថាត្រូវតាមទំនង ពោលថាប្រកបដោយលក្ខណៈ ពោលថាប្រកបដោយហេតុ ពោលថាគួរដល់ឋានៈ តាមលទ្ធិរបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់សួរថា) ព្រោះថា ជនទាំងនេះ ជាអ្នកពោលថាខ្លួនឈ្លាសវៃ ទាំងអស់គ្នា ។ ហេតុនោះ ព្រះពុទ្ធនិម្មិតនោះ ត្រាស់សួរថា

ជនទាំងឡាយ ប្រកាន់យាំងនេះហើយ រមែងតាស់ទែងគ្នា
ទាំងពោលថាជាមនុស្សពាល ទន់ទាប មិនឈ្លាសវៃ តើ
វាទៈដូចម្តេច របស់ជនទាំងនេះ ជាវាទៈពិត ព្រោះថា ជន
ទាំងនេះ ជាអ្នកពោលថាខ្លួនឈ្លាសវៃ ទាំងអស់គ្នា ។

[២១០] បរស្ស វេ ធម្មមនានុជានំ(១)

ពាលោមកោ ហោតិ និហីនបញ្ញោ

សព្វេវ ពាលា សុនិហីនបញ្ញា

សព្វេវិមេ ទិដ្ឋិបរិព្វសានា ។

[២១១] បរស្ស វេ ធម្មមនានុជានន្តិ បរស្ស ធម្មំ ទិដ្ឋឹ បដិបទំ មគ្គំ អនានុជានន្តោ អនានុបស្សន្តោ(២) អនានុមញ្ញន្តោ អនានុមោទន្តោតិ បរស្ស វេ ធម្មមនានុជានំ ។

[២១២] ពាលោមកោ ហោតិ និហីនបញ្ញោតិ បរោ ពាលោ ហោតិ ហីនោ និហីនោ ឱមកោ លាមកោ ជតុក្កោ បរិត្តោ ហីនប្បញ្ញោ និហីនប្បញ្ញោ ឱមកប្បញ្ញោ លាមកប្បញ្ញោ ជតុក្កប្បញ្ញោ បរិត្តប្បញ្ញោតិ ពាលោមកោ ហោតិ និហីនបញ្ញោ ។

---

១ ម. ចេ ធម្មមននុជានំ ។ ២ ឯត្ថន្តរេ អននុមនន្តោតិ ទិស្សតិ

[៦១០] (ព្រះមានព្រះភាគត្រាស់ថា) បុគ្គលពាល ជាអ្នកថោកទាប មានបញ្ញាទន់អន់ មិនយល់នូវធម៌របស់បុគ្គលដទៃ ជនទាំងអស់ជាមនុស្សពាល មានបញ្ញាទន់អន់ ជនទាំងអស់នេះ ជាអ្នកតាំងនៅក្នុងទិដ្ឋិ ។

[៦១១] ពាក្យថា មិនយល់នូវធម៌របស់បុគ្គលដទៃ គឺមិនយល់តាម មិនឃើញតាម មិនដឹងតាម មិនត្រេកអរតាម នូវធម៌ នូវទិដ្ឋិ នូវបដិបទា នូវមគ្គ របស់បុគ្គលដទៃ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនយល់នូវធម៌ របស់បុគ្គលដទៃ ។

[៦១២] ពាក្យថា បុគ្គលពាល ជាអ្នកថោកទាប មានបញ្ញាទន់អន់ គឺបុគ្គលឈ្មោះថា លង់ ថោកទាប ទន់អន់ ថោកថយ លាមក គម្រក់ ជាមនុស្សកម្សត់កម្សោយ មានបញ្ញាថោកទាប មានបញ្ញាទន់អន់ មានបញ្ញាថោកថយ មានបញ្ញាលាមក មានបញ្ញាគម្រក់ មានបញ្ញាស្តួចស្តើង ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលពាល ជាអ្នកថោកទាប មានបញ្ញាទន់អន់ ។

ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ

(២១៣) សព្វេវ ពាលា សុនិហីនបញ្ញាតិ សព្វេវិមេ សមណព្រាហ្មណា ពាលា ហីនា និហីនា ឱមកា លាមកា ឆតុក្កា បរិត្តា សព្វេវ ហីនបញ្ញា និហីនបញ្ញា ឱមកបញ្ញា លាមកបញ្ញា ឆតុក្កបញ្ញា បរិត្តបញ្ញាតិ សព្វេវ ពាលា សុនិហីនបញ្ញា ។

(២១៤) សព្វេវិមេ ទិដ្ឋិបរិព្វសានាតិ សព្វេវិមេ សមណព្រាហ្មណា ទិដ្ឋិគតិកា តេ ទ្វាសដ្ឋិយា ទិដ្ឋិគតានំ អញ្ញតរញ្ញតរំ ទិដ្ឋិគតំ គហេត្វា ឧគ្គហេត្វា គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វា សកាយ សកាយ ទិដ្ឋិយា វសន្តិ សំវសន្តិ អាវសន្តិ បរិវសន្តិ ។ យថា អាគារិកា វា ឃរេសុ វសន្តិ សាបត្តិកា វា អាបត្តីសុ វសន្តិ សកិលេសា វា កិលេសេសុ វសន្តិ ឯវមេវ សព្វេវិមេ សមណព្រាហ្មណា ទិដ្ឋិគតិកា

## ចូឡវិយូហសុត្តនិទ្ទេស ទី ១២

(៦១៣) ពាក្យថា ជនទាំងអស់ ជាមនុស្សពាល មានបញ្ញាទន់អន់ គឺពួកសមណព្រាហ្មណ៍ទាំងអស់នេះ ជាបុគ្គលល្ងង់ ថោកទាប ទន់អន់ ថោកថយ លាមក គម្រក់ ជាមនុស្សកម្ទេចកម្ទី សមណ-ព្រាហ្មណ៍ទាំងអស់ មានបញ្ញាថោកទាប មានបញ្ញាទន់អន់ មានបញ្ញាថោកថយ មានបញ្ញាលាមក មានបញ្ញាគម្រក់ មានបញ្ញាស្តួចស្តើង ហេតុនោះ (ទ្រង់ត្រាស់ថា) ជនទាំងអស់ ជាមនុស្សពាល មានបញ្ញាថោកថយ ។

(៦១៤) ពាក្យថា ជនទាំងអស់នេះ ជាអ្នកតំអក់នៅក្នុងទិដ្ឋិ គឺពួកសមណព្រាហ្មណ៍ទាំងអស់នេះ ជាអ្នកលុះក្នុងទិដ្ឋិ សមណព្រាហ្មណ៍ទាំងអស់នោះ កាន់ រៀន ប្រកាន់ បបោសអង្អែល ជាប់ចិត្ត បណ្ដាទិដ្ឋិទាំង ៦២ នូវទិដ្ឋិណាមួយ ហើយនៅ នៅរួម នៅជាប់ នៅត្រាំ ក្នុងទិដ្ឋិរបស់ខ្លួន ៗ ។ បុគ្គលមានផ្ទះក្ដី រមែងនៅក្នុងផ្ទះ បុគ្គលអ្នកត្រូវអាបត្តិក្ដី រមែងនៅក្នុងអាបត្តិ បុគ្គលប្រកបដោយកិលេសក្ដី រមែងនៅក្នុងកិលេស យ៉ាងណាមិញ ពួកសមណព្រាហ្មណ៍ទាំងអស់នេះ ជាអ្នកលុះក្នុងទិដ្ឋិ

តេ ញត្វា សទ្ធិយា ទិដ្ឋិគតានិ អញ្ញតរញ្ញតរំ ទិដ្ឋិគតំ គហេត្វា ឧគ្គហេត្វា គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វា សកាយ សកាយ ទិដ្ឋិយា វសន្តិ សំវសន្តិ អាវសន្តិ បរិវសន្តីតិ សព្វេវិមេ ទិដ្ឋិបរិព្វសានា ។ តេនាហ ភគវា

បរស្ស វេ ធម្មមនានុជានំ
ពាលោមកោ ហោតិ និហីនបញ្ញោ
សព្វេវ ពាលា សុនិហីនបញ្ញា
សព្វេវិមេ ទិដ្ឋិបរិព្វសានាតិ ។

(២១៥) សន្ទិដ្ឋិយា ចេ បន វីវទាតា(១)
សំសុទ្ធបញ្ញា កុសលា មុតីមា(២)
ន តេសំ កោចិ បរិហីនបញ្ញោ
ទិដ្ឋី ហិ តេសំបិ តថា សមត្តា ។

(២១៦) សន្ទិដ្ឋិយា ចេ បន វីវទាតាតិ សកាយ ទិដ្ឋិយា សកាយ ខន្តិយា សកាយ រុចិយា សកាយ លទ្ធិយា វីវទាតា បរិយោទាតា អសង្កិលិដ្ឋាតិ(៣) សន្ទិដ្ឋិយា ចេ បន វីវទាតា ។

---

១ ម. បេវ ន វេវទាតា ។ ២ ម. មុតិមា ។ ៣ ម. អនវេវទាតា អភិទាតា អបរិ. យោទាតា សំកិលិដ្ឋា សំកិលេសិកាតីតិ ទិស្សន្តិ ។

សមណព្រាហ្មណ៍ទាំងនោះ កាន់ រៀន ប្រកាន់ បបោសអង្អែល ជាប់ចិត្ត បណ្ដាទិដ្ឋិទាំង ៦២ នូវទិដ្ឋិណាមួយ ហើយនៅ នៅរួម នៅជាប់ នៅត្រាំ ក្នុងទិដ្ឋិរបស់ខ្លួន ។ ហេតុនោះ (ទ្រង់ត្រាស់ថា) ជនទាំងអស់នេះ ជាអ្នកតំអក់នៅក្នុងទិដ្ឋិ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលពាល ជាអ្នកថោកទាប មានបញ្ញាទន់អន់ រមែង
មិនយល់នូវធម៌ របស់បុគ្គលដទៃ ជនទាំងអស់ ជាមនុស្ស
ពាល មានបញ្ញាទន់អន់ ជនទាំងអស់នេះ ជាអ្នកតំអក់នៅ
ក្នុងទិដ្ឋិ ។

(២១៥) ប្រសិនបើ បុគ្គលទាំងឡាយ ជាអ្នកមានបញ្ញា
ឈ្លាសវៃ មានបញ្ញាបរិសុទ្ធល្អ មានញាណដ៏ផូរផង់ ដោយ
ទិដ្ឋិរបស់ខ្លួន បណ្ដាបុគ្គលទាំងឡាយនោះ បុគ្គលណា
មួយ មានបញ្ញាទន់អន់ ឥតមានទេ ព្រោះថា ជនទាំងនោះ
បានប្រកាន់ទិដ្ឋិយ៉ាងនោះហើយ ។

(២១៦) ពាក្យថា ដ៏ផូរផង់ដោយទិដ្ឋិរបស់ខ្លួន គឺផូរផង់ ស្អាត មិនសៅហ្មង ដោយទិដ្ឋិរបស់ខ្លួន ដោយការគួររបស់ខ្លួន ដោយសេចក្ដីគាប់ចិត្តរបស់ខ្លួន ដោយលទ្ធិរបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) ដ៏ផូរផង់ ដោយទិដ្ឋិរបស់ខ្លួន ។

ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ

(២១៧) សំសុទ្ធបញ្ញា កុសលា មតីមាតិ សុទ្ធប្បញ្ញា វិសុទ្ធប្បញ្ញា បរិសុទ្ធប្បញ្ញា វោទាតប្បញ្ញា បរិយោទាតប្បញ្ញា ។ អថវា សុទ្ធទស្សនា វិសុទ្ធទស្សនា បរិសុទ្ធទស្សនា វោទាតទស្សនា បរិយោទាតទស្សនាតិ សំសុទ្ធបញ្ញា ។ កុសលាតិ កុសលា បណ្ឌិតា បញ្ញវន្តោ ពុទ្ធិមន្តោ ញាណិនោ វិភាវិនោ មេធាវិនោតិ សំសុទ្ធបញ្ញា កុសលា ។ មតីមាតិ មតិមា បណ្ឌិតា បញ្ញវន្តោ ពុទ្ធិមន្តោ ញាណិនោ វិភាវិនោ មេធាវិនោតិ សំសុទ្ធបញ្ញា កុសលា មតីមា ។

(២១៨) ន តេសំ កោចិ បរិហីនបញ្ញោតិ តេសំ សមណព្រាហ្មណានំ ន កោចិ ហីនប្បញ្ញោ និហីនប្បញ្ញោ ឱមកប្បញ្ញោ លាមកប្បញ្ញោ ជតុក្កប្បញ្ញោ បរិត្តប្បញ្ញោ(១) ។ អថវា(២) សព្វេវ អគ្គប្បញ្ញា សេដ្ឋប្បញ្ញា

១ ម. ឯត្ថន្តរេ អត្ថីតិ ទិស្សតិ ។ ២ ម. អយំ បាឋោ នត្ថិ ។

ចូឡវិយូហសុត្តនិទ្ទេស ទី ១២

(៦១៧) ពាក្យថា បុគ្គលទាំងឡាយ ជាអ្នកមានបញ្ញាឈ្មោះវៃ មានបញ្ញាបរិសុទ្ធល្អ គឺមានបញ្ញាស្អាត មានបញ្ញាស្អាតវិសេស មានបញ្ញាបរិសុទ្ធ មានបញ្ញាថ្លាស្អាត មានបញ្ញាផូរផង់ ៗ ឬថា មានការឃើញស្អាត មានការឃើញស្អាតវិសេស មានការឃើញបរិសុទ្ធ មានការឃើញហ្មត់ចត់ មានការឃើញផូរផង់ ហេតុនោះ (ទ្រង់ត្រាស់ថា) មានបញ្ញាបរិសុទ្ធល្អ ៗ ពាក្យថា ឈ្មោះវៃ គឺប៉ិនប្រសប់ ជាបណ្ឌិត មានបញ្ញា មានបញ្ញាជាគ្រឿងដឹង មានញាណ មានបញ្ញាជាគ្រឿងបំភ្លឺ មានបញ្ញាជាគ្រឿងទំលាយកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) ឈ្មោះវៃ មានបញ្ញាបរិសុទ្ធល្អ ៗ ពាក្យថា មានបញ្ញា គឺមានការដឹងជាបណ្ឌិត មានបញ្ញា មានបញ្ញាជាគ្រឿងដឹង មានញាណ មានបញ្ញាជាគ្រឿងបំភ្លឺ មានបញ្ញាជាគ្រឿងទំលាយកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលទាំងឡាយ ជាអ្នកមានបញ្ញាឈ្មោះវៃ មានបញ្ញាបរិសុទ្ធ ៗ

(៦១៨) ពាក្យថា បណ្តាបុគ្គលទាំងឡាយនោះ បុគ្គលណាមួយ មានបញ្ញាទន់អន់ ឥតមានទេ គឺបណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ណាមួយ មានបញ្ញាថោកទាប មានបញ្ញាទន់អន់ មានបញ្ញាថោកថយ មានបញ្ញាលាមក មានបញ្ញាគម្រក់ មានបញ្ញាស្តួចស្តើង ឥតមានទេ ៗ គឺថា សមណព្រាហ្មណ៍ទាំងអស់ មានបញ្ញាដ៏លើសលុប មានបញ្ញាប្រសើរ

ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ

វិសេដ្ឋបញ្ញា បាមោក្ខបញ្ញា ឧត្តមបញ្ញា បវរបញ្ញាតិ ន តេសំ កោចិ បរិហីនបញ្ញោ ។

(៤១៩) ទិដ្ឋី ហិ តេសំបិ តថា សមត្តាតិ តេសំ សមណព្រាហ្មណានំ ទិដ្ឋី តថា សមត្តា សមាទិន្នា គហិតា បរាមដ្ឋា អភិនិវិដ្ឋា អជ្ឈោសិតា អធិមុត្តាតិ ទិដ្ឋីហិ តេសំបិ តថា សមត្តា ។ តេនាហ ភគវា

សន្ទិដ្ឋិយា ចេ បន វីវទាតា
សំសុទ្ធបញ្ញា កុសលា មុតីមា
ន តេសំ កោចិ បរិហីនបញ្ញោ
ទិដ្ឋី ហិ តេសំបិ តថា សមត្តាតិ ។

(៤២០) ន វាហមេតំ តថិវន្តិ(១) ព្រូមិ
យមាហុ ពាលា(២) មិថុ អញ្ញមញ្ញំ
សកំ សកំ ទិដ្ឋិមកំសុ សច្ចំ
តស្មា ហិ ពាលោតិ បរំ ទហន្តិ ។

---

១ ម. តថិវត្តិ ។ ២ ម. ពាលោ ។

មានបញ្ញាប្រសើរវិសេស មានបញ្ញាជាប្រធាន មានបញ្ញាដ៏ឧត្តម មានបញ្ញាដ៏បវរ ហេតុនោះ (ទ្រង់ត្រាស់ថា) បណ្ដាបុគ្គលទាំងនោះ បុគ្គលណាមួយ មានបញ្ញាទន់អន់ ឥតមានទេ ។

(៦១៩) ពាក្យថា ព្រោះថា ជនទាំងនោះ បានប្រកាន់ទិដ្ឋិយ៉ាងនោះហើយ គឺសមណព្រាហ្មណ៍ទាំងនោះ បានប្រកាន់ សមាទាន កាន់យក បរាមាសអង្អែល ជាប់ចិត្ត ជក់ចិត្ត ចុះចិត្តស៊ប់ ដោយប្រការដូច្នោះហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះថា ជនទាំងនោះ បានប្រកាន់ទិដ្ឋិយ៉ាងនោះហើយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ប្រសិនបើ បុគ្គលទាំងឡាយ ជាអ្នកមានបញ្ញាឈ្លាសវៃ
មានបញ្ញាបរិសុទ្ធល្អ មានញាណដ៏ផូរផង់ ដោយទិដ្ឋិ
របស់ខ្លួន បណ្ដាបុគ្គលទាំងឡាយនោះ បុគ្គលណាមួយ មាន
បញ្ញាទន់អន់ ឥតមានទេ ព្រោះថា ជនទាំងនោះ បាន
ប្រកាន់ទិដ្ឋិយ៉ាងនោះហើយ ។

(៦២០) សមណព្រាហ្មណ៍ទាំងឡាយ ជាគូ ៗ បានពោលនូវ
គ្នានឹងគ្នាថាពាល ព្រោះទិដ្ឋិណា តថាគតមិនពោលនូវទិដ្ឋិនុ៎ះ
ថាពិតទេ បុគ្គលទាំងឡាយបានធ្វើ នូវទិដ្ឋិរបស់ខ្លួន ៗ
ថាពិត ព្រោះហេតុនោះបានជា ជនទាំងឡាយ តែងយល់នូវ
បុគ្គលដទៃថាពាល ។

(២២១) ន វាហមេតំ តថិវន្តិ ព្រូមីតិ នាតិ បដិក្ខេបោ ។ ឯតន្តិ ទ្វាសដ្ឋិទិដ្ឋិគតន្តិ នាហំ ឯតំ តថំ តច្ចំ ភូតំ យាថាវំ អវិបរីតន្តិ ព្រូមិ អាចិក្ខាមិ ទេសេមិ បញ្ញាបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានីករោមិ បកាសេមីតិ ន វាហមេតំ តថិវន្តិ ព្រូមិ ។

(២២២) យមាហុ ពាលា មិថុ អញ្ញមញ្ញន្តិ មិថូតិ ទ្វេ ជនា ទ្វេ កលហការកា ទ្វេ ភណ្ឌនការកា ទ្វេ ភស្សការកា ទ្វេ វិវាទការកា ទ្វេ អធិករណការកា ទ្វេ វាទិនោ ទ្វេ សល្លាបកា ។ តេ អញ្ញមញ្ញំ ពាលោ ហីនោ និហីនោ ឱមកោ លាមកោ ជតុក្កោ បរិត្តោតិ(១) ឯវមាហំសុ ឯវំ កថេន្តិ ឯវំ ភណន្តិ ឯវំ ទីបយន្តិ ឯវំ វោហរន្តីតិ យមាហុ ពាលា មិថុ អញ្ញមញ្ញំ ។

---

១. ម. ពាលតោ ហីនតោ និហីនតោ ឱមកតោ លាមកតោ ជតុក្កតោ បរិត្តតោតិ ។

## កលហវិវាទសុត្តនិទ្ទេស ទី ១១

(២២១) អធិប្បាយពាក្យថា តថាគតមិនពោលនូវទិដ្ឋិនុ៎ះថា ពិតទេ ត្រង់ពាក្យថា មិន គឺជាពាក្យហាមឃាត់ ។ ពាក្យថា ទិដ្ឋិនុ៎ះ គឺទិដ្ឋិ ៦២ សេចក្តីថា តថាគត មិនពោល មិនប្រាប់ មិនសំដែង មិនបញ្ញត្ត មិនតាំងទុក មិនបើក មិនវែកញែក មិនធ្វើឲ្យងាយ មិនប្រកាស នូវទិដ្ឋិនុ៎ះ ថា ពិត ថា មែន ថា ប្រាកដ ថា ត្រូវ ថា មិនវិបរិត ដូច្នេះទេ ហេតុនោះ ( ទ្រង់ត្រាស់ថា ) តថាគតមិនពោលនូវទិដ្ឋិនុ៎ះ ថា ពិតទេ ។

(២២២) ពាក្យថា សមណព្រាហ្មណ៍ទាំងឡាយ ជាគូ ៗ បានពោលនូវគ្នានឹងគ្នាថា (ពាល) ព្រោះទិដ្ឋិណា ត្រង់ពាក្យថា ជាគូ ៗ បានសេចក្តីថា ជនពីរនាក់ គឺអ្នកធ្វើជម្លោះពីរនាក់ អ្នកធ្វើសេចក្តីប្រកួតប្រកាន់ពីរនាក់ អ្នកធ្វើតិរច្ឆានកថាពីរនាក់ អ្នកធ្វើវិវាទពីរនាក់ អ្នកធ្វើអធិករណ៍ពីរនាក់ អ្នកជជែកពីរនាក់ អ្នកនិយាយប៉ប៉ាច់ប៉ប៉ោចពីរនាក់ ៗ ជនទាំងនោះ ពោលយ៉ាងនេះ ថ្លែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ ពន្យល់យ៉ាងនេះ អធិប្បាយយ៉ាងនេះ នូវគ្នានឹងគ្នាថា ពាល ថោកទាប សាបសូន្យ ថោកថយ លាមក គម្រក់ កម្មេចកម្មី ហេតុនោះ (ទ្រង់ត្រាស់ថា) សមណព្រាហ្មណ៍ទាំងឡាយ ជាគូ ៗ បានពោល នូវគ្នានឹងគ្នាថា ពាល ព្រោះទិដ្ឋិណា ។

(២២៣) សកំ សកំ ទិដ្ឋិមកំសុ សច្ចន្តិ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ សកំ សកំ ទិដ្ឋិមកំសុ សច្ចំ ។ អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ សកំ សកំ ទិដ្ឋិមកំសុ សច្ចំ ។

(២២៤) តស្មា ហិ ពាលោតិ បរំ ទហន្តីតិ តស្មាតិ តស្មា តំការណា តំហេតុ តប្បច្ចយា តំនិទានា បរំ ពាលោ ហីនោ និហីនោ ឱមកោ លាមកោ ឆតុក្កោ បរិត្តោតិ ទហន្តិ បស្សន្តិ ទក្ខន្តិ ឱលោកេន្តិ និជ្ឈាយន្តិ ឧបបរិក្ខន្តីតិ តស្មា ហិ ពាលោតិ បរំ ទហន្តិ ។

តេនាហ ភគវា

ន វាហមេតំ តថិវន្តិ ព្រូមិ
យមាហុ ពាលា មិថុ អញ្ញមញ្ញំ
សកំ សកំ ទិដ្ឋិមកំសុ សច្ចំ

(៤៤៣) ពាក្យថា បុគ្គលពាលទាំងឡាយ បានធ្វើនូវទិដ្ឋិរបស់ខ្លួនៗ ជាពិត គឺបានធ្វើនូវទិដ្ឋិរបស់ខ្លួន ៗ ជាពិត ដោយពាក្យថា លោកទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ។ បានធ្វើនូវទិដ្ឋិរបស់ខ្លួន ៗ ជាពិត ដោយពាក្យថា លោកមិនទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃ ជាមោឃៈ ។ បេ ។ សត្វស្លាប់ហើយ កើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ពាក្យនេះ ជាពាក្យពិត ពាក្យដទៃ ជាមោឃៈ ។ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលពាលទាំងឡាយ បានធ្វើនូវទិដ្ឋិរបស់ខ្លួនៗជាពិត ។

(៤៤៤) ពាក្យថា ព្រោះហេតុនោះ ជនទាំងឡាយ តែងយល់នូវបុគ្គលដទៃថាពាល ត្រង់ពាក្យថា ព្រោះហេតុនោះ គឺព្រោះហេតុដូច្នោះ ព្រោះដំណើរនោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ទើបជនទាំងឡាយ យល់ ឃើញ ក្រឡេកឃើញ សំឡឹង ពិនិត្យ រំពឹង នូវបុគ្គលដទៃ ថាពាល ថោកទាប សាបលោប ថោកថយ លាមក គម្រក់ កម្សត់កម្សី ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះហេតុនោះ ជនទាំងឡាយ តែងយល់នូវបុគ្គលដទៃ ថាពាល ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

សមណព្រាហ្មណ៍ទាំងឡាយជាគូ ៗ បានពោលនូវគ្នានឹងគ្នា
ថាពាល ព្រោះទិដ្ឋិណា តថាគតមិនពោលនូវទិដ្ឋិនុ៎ះ ថាពិតទេ
បុគ្គលពាលទាំងឡាយ បានធ្វើនូវទិដ្ឋិរបស់ខ្លួន ៗ ជាពិត

តស្មា ហិ ពាលោតិ បរំ ទហន្តីតិ ។

(២២៥) យមាហុ សច្ចំ តថិយន្តិ ឯកេ
តមាហុ អញ្ញេបិ តុច្ឆំ មុសាតិ
ឯវម្បិ វិគ្គយ្ហ វិវាទយន្តិ
កស្មា ន ឯកំ សមណា វទន្តិ ។

(២២៦) យមាហុ សច្ចំ តថិយន្តិ ឯកេតិ យំ ធម្មំ ទិដ្ឋិំ បដិបទំ មគ្គំ ឯកេ សមណព្រាហ្មណា ឥទំ សច្ចំ តច្ឆំ(១) ភូតំ យាថាវំ អវិបរីតន្តិ ឯវមាហំសុ ឯវំ កថេន្តិ ឯវំ ភណន្តិ ឯវំ ទីបយន្តិ ឯវំ វោហរន្តីតិ យមាហុ សច្ចំ តថិយន្តិ ឯកេ ។

(២២៧) តមាហុ អញ្ញេបិ តុច្ឆំ មុសាតីតិ តមេវ

១ ម. ឯត្ថន្តរេ តថន្តិ ទិស្សតិ ។

ព្រោះហេតុនោះបានជា ជនទាំងឡាយ តែងយល់នូវបុគ្គលដទៃថា ពាល ។

(៤៤៥) (ព្រះពុទ្ធនិម្មិតសួរថា) សមណព្រាហ្មណ៍ពួកខ្លះ បានពោលពាក្យណា ថាជាពាក្យទៀង ជាពាក្យពិត ចំណែកសមណព្រាហ្មណ៍ទាំងឡាយដទៃទៀត បែរជាពោលពាក្យនោះ ថាជាពាក្យទទេ ជាពាក្យកុហកវិញ សមណព្រាហ្មណ៍ទាំងឡាយ ប្រកាន់យ៉ាងនេះហើយ រមែងទាស់ទែងគ្នា ព្រោះហេតុអ្វី សមណៈទាំងឡាយ មិនពោលពាក្យតែបែបមួយ ។

(៤៤៦) ពាក្យថា សមណព្រាហ្មណ៍ពួកខ្លះ បានពោលពាក្យណា ថាជាពាក្យទៀង ជាពាក្យពិត សេចក្ដីថា សមណព្រាហ្មណ៍ពួកខ្លះ ពោលយ៉ាងនេះ ថ្លែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ ពន្យល់យ៉ាងនេះ អធិប្បាយយ៉ាងនេះ នូវធម៌ ទិដ្ឋិ បដិបទា មគ្គណា ថា នេះទៀង ពិត ប្រាកដ ត្រូវ មិនវិបរិត ហេតុនោះ (ទ្រង់ត្រាស់សួរថា) សមណព្រាហ្មណ៍ពួកខ្លះ បានពោលពាក្យណា ថាជាពាក្យទៀង ជាពាក្យពិត ។

(៤៤៧) ពាក្យថា ចំណែកសមណព្រាហ្មណ៍ទាំងឡាយដទៃទៀត បែរជាពោលពាក្យនោះ ថាជាពាក្យទទេ ជាពាក្យកុហកវិញ សេចក្ដីថា

ធម្មំ ទិដ្ឋិំ បដិបទំ មគ្គំ ឯកេ សមណព្រាហ្មណា ឯតំ តុច្ឆំ ឯតំ មុសា ឯតំ អភូតំ ឯតំ អលិកំ ឯតំ អយាថាវន្តិ ឯវមាហំសុ ឯវំ កថេន្តិ ឯវំ ភណន្តិ ឯវំ ទីបយន្តិ ឯវំ វោហរន្តីតិ តមាហុ អញ្ញេបិ តុច្ឆំ មុសាតិ ។

(២២៨) ឯវម្បិ វិគ្គយ្ហ វិវាទយន្តីតិ ឯវំ គហេត្វា ឧគ្គហេត្វា គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វា វិវាទយន្តិ កលហំ ករោន្តិ ភណ្ឌនំ ករោន្តិ វិគ្គហំ ករោន្តិ វិវាទំ ករោន្តិ មេធគំ ករោន្តិ ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ ។បេ។ និព្ពេឋេហិ វា សចេ បហោសីតិ ឯវម្បិ វិគ្គយ្ហ វិវាទយន្តិ ។

(២២៩) កស្មា ន ឯកំ សមណា វទន្តីតិ កស្មាតិ កស្មា កឹការណា កឹហេតុ កឹបច្ចយា កឹនិទានា កឹសមុទយា កឹជាតិកា កឹបភវា

សមណព្រាហ្មណ៍ពួកខ្លះ ពោលយ៉ាងនេះ ថ្លែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ ពន្យល់យ៉ាងនេះ អធិប្បាយយ៉ាងនេះ នូវធម៌ នូវទិដ្ឋិ នូវបដិបទា នូវមគ្គនោះឯងថា នេះជាពាក្យទទេ នេះជាពាក្យកុហក នេះជាពាក្យមិនពិត នេះជាពាក្យមិនមែន នេះជាពាក្យមិនត្រូវ ហេតុនោះ (ទ្រង់ត្រាស់សួរថា) ចំណែកសមណព្រាហ្មណ៍ទាំងឡាយ ដទៃទៀតរៃរជាពោលពាក្យនោះ ថាជាពាក្យទទេ ជាពាក្យកុហកវិញ ។

(២២៨) ពាក្យថា សមណព្រាហ្មណ៍ទាំងឡាយ ប្រកាន់យ៉ាងនេះហើយ រមែងតាស់តែងគ្នា សេចក្តីថា សមណព្រាហ្មណ៍ទាំងឡាយ កាន់យក រៀនយក ប្រកាន់យក បពោសអង្អែល ជាប់ចិត្តយ៉ាងនេះហើយ រមែងជជែកគ្នា គឺធ្វើនូវជំលោះ ធ្វើនូវសេចក្តីប្រកួតប្រកាន់ ធ្វើនូវសេចក្តីប្រកាន់ខុស ធ្វើនូវវិវាទ ធ្វើនូវការប្រណាំងប្រជែងថា អ្នកមិនចេះធម៌វិន័យនេះទេ ។ បេ ។ ឬបើអ្នកអាច អ្នកចូរដោះស្រាយឲ្យរួចចុះ ហេតុនោះ (ទ្រង់ត្រាស់សួរថា) សមណ. ព្រាហ្មណ៍ទាំងឡាយ ប្រកាន់យ៉ាងនេះហើយ រមែងតាស់តែងគ្នា ។

(២២៩) ពាក្យថា ព្រោះហេតុអ្វី សមណៈទាំងឡាយ មិនពោលពាក្យតែមួយ សេចក្តីថា ព្រោះហេតុដូចម្តេច ព្រោះដំណើរដូចម្តេច ព្រោះហេតុអ្វី ព្រោះបច្ច័យអ្វី ព្រោះនិទានដូចម្តេច ព្រោះកិរិយាកើតឡើងដូចម្តេច ព្រោះកំណើតដូចម្តេច

## ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ

ន ឯកំ វទន្តិ នានា វទន្តិ វិវិធំ វទន្តិ អញ្ញោញ្ញំ វទន្តិ បុថុ វទន្តិ ភាសេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ កស្មា ន ឯកំ សមណា វទន្តិ ។ តេនាហ សោ និម្មិតោ

យមាហុ សច្ចំ តថិយន្តិ ឯកេ
តមាហុ អញ្ញេបិ តុច្ឆំ មុសាតិ
ឯវម្បិ វិគ្គយ្ហ វិវាទយន្តិ
កស្មា ន ឯកំ សមណា វទន្តីតិ ។

(២៣០) ឯកំ ហិ សច្ចំ ន ទុតីយមត្ថិ
យស្មឹ បជា នោ វិវទេ បជានំ
នានា តេ(១) សច្ចានិ សយំ ថុនន្តិ
តស្មា ន ឯកំ សមណា វទន្តិ ។

---

១ ម. នានាតេ ។

ព្រោះហេតុជាដែនកើតមុនដូចម្តេច សមណទាំងឡាយ មិនពោលពាក្យតែបែបមួយ បែរជាពោលផ្សេង ៗ ពោលនូវប្រការផ្សេងៗ ពោលដោយឡែកពីគ្នា ពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយច្រើនបែបទៅវិញ ហេតុនោះ (ទ្រង់ត្រាស់សួរថា) ព្រោះហេតុអ្វី សមណព្រាហ្មណ៍ទាំងឡាយ មិនពោលពាក្យតែបែបមួយ ៗ ហេតុនោះ ព្រះពុទ្ធនិម្មិតនោះត្រាស់សួរថា

សមណព្រាហ្មណ៍ពួកខ្លះ បានពោលពាក្យណា ថាជាពាក្យ
ទៀង ជាពាក្យពិត សមណៈព្រាហ្មណ៍ទាំងឡាយដទៃទៀត
បែរជាពោលពាក្យនោះ ថាជាពាក្យទទេ ជាពាក្យកុហកវិញ
សមណព្រាហ្មណ៍ទាំងឡាយ ប្រកាន់យ៉ាងនេះហើយ រមែង
ទាស់ទែងគ្នា ព្រោះហេតុអ្វី សមណៈទាំងឡាយ មិនពោល
ពាក្យតែបែបមួយ ៗ

(២៣០) (ព្រះមានព្រះភាគត្រាស់ថា) សត្វដឹងច្បាស់នូវសច្ចៈណា មិនគប្បីទាស់ទែងគ្នា សច្ចៈ (នោះ) មានតែមួយ មិនមានជាគំរប់ពីរទេ សមណព្រាហ្មណ៍ ទាំងឡាយនោះ តែងពោលតាមទំនើងខ្លួនឯង នូវសច្ចៈទាំងឡាយផ្សេង ៗ គ្នា ព្រោះហេតុនោះ បានជាសមណៈទាំងឡាយ មិនពោលពាក្យតែបែបមួយ ៗ

(២៣១) ឯកំ ហិ សច្ចំ ន ទុតិយមត្ថីតិ ឯកំ សច្ចំ វុច្ចតិ ទុក្ខនិរោធោ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។ អថវា ឯកំ សច្ចំ វុច្ចតិ មគ្គសច្ចំ និយ្យានសច្ចំ ទុក្ខនិរោធគាមិនី បដិបទា អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធីតិ ឯកំ ហិ សច្ចំ ន ទុតិយមត្ថិ ។

(២៣២) យស្មឹ បជា នោ វិវទេ បជានន្តិ យស្មិន្តិ យម្ហិ សច្ចេ ។ បជាតិ សត្តាធិវចនំ ។ បជា យំ(១) សច្ចំ បជានន្តា អាជានន្តា វិជានន្តា បដិវិជានន្តា បដិវិជ្ឈន្តា ន កលហំ ករេយ្យ ន ភណ្ឌនំ ករេយ្យ ន វិគ្គហំ ករេយ្យ ន វិវាទំ ករេយ្យ ន មេធគំ ករេយ្យ កលហំ ភណ្ឌនំ វិគ្គហំ វិវាទំ មេធគំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវំគមេយ្យន្តិ(២) យស្មឹ បជា នោ វិវទេ បជានំ ។

---

១ ម. បជានំ ។ ២ ម. ន កលហំ ករេយ្យុំ ។ល។ ព្យន្តី ករេយ្យុំ អនភាវំ គមេយ្យុន្តិ ទិស្សន្តិ ។

(៤៣១) ពាក្យថា សច្ចៈ (នោះ) មានតែមួយ មិនមានជាគំរប់ពីរទេ អធិប្បាយថា ទុក្ខនិរោធនិព្វាន លោកហៅថា សច្ចៈមួយ បានខាង សេចក្ដីរម្ងាប់សង្ខារទាំងពួង កិរិយារលាស់ចេញនូវឧបធិទាំងពួង កិរិយាអស់តណ្ហា ការប្រាសចាកតម្រេក កិរិយារលត់ ព្រះនិព្វាន ។ ម្យ៉ាងទៀត ដែលហៅថា សច្ចៈមួយ សំដៅយកមគ្គសច្ចៈ និយ្យានសច្ចៈ ទុក្ខនិរោធគាមិនីបដិបទា មគ្គមានអង្គ ៨ ដ៏ប្រសើរ គឺ សេចក្ដីយល់ត្រូវ ១ សេចក្ដីត្រិះរិះត្រូវ ១ វាចាត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ ការព្យាយាមត្រូវ ១ សេចក្ដីរឭកត្រូវ ១ ការតាំងចិត្តត្រូវ ១ ហេតុនោះ (ទ្រង់ត្រាស់ថា) សច្ចៈនោះ មានតែមួយ មិនមានជាគំរប់ពីរទេ ។

(៤៣២) ពាក្យថា សត្វដឹងច្បាស់នូវសច្ចៈណា មិនគប្បីទាស់ទែងគ្នា ត្រង់ពាក្យថា ណា គឺនូវសច្ចៈណា ។ ពាក្យថា សត្វ គឺជាឈ្មោះរបស់សត្វ ។ សត្វកាលដឹងច្បាស់ ដឹងទូទៅ ដឹងវិសេស ដឹងជាក់ ចាក់ធ្លុះ នូវសច្ចៈណា មិនគប្បីធ្វើជំលោះ មិនគប្បីធ្វើសេចក្ដីប្រកួតប្រកាន់ មិនគប្បីធ្វើសេចក្ដីប្រកាន់ខុស មិនគប្បីធ្វើវិវាទ មិនគប្បីធ្វើការប្រណាំងប្រជែង គឺគប្បីលះបង់ គប្បីបន្ទោបង់ គប្បីធ្វើឲ្យវិនាស គប្បីដល់នូវការមិនកើតមានតទៅ នូវជំលោះ សេចក្ដីប្រកួតប្រកាន់ សេចក្ដីប្រកាន់ខុស វិវាទ សេចក្ដីប្រណាំងប្រជែង ហេតុនោះ (ទ្រង់ត្រាស់ថា) សត្វដឹងច្បាស់នូវសច្ចៈណា មិនគប្បីទាស់ទែងគ្នា ។

(២៣៣) នានា តេ សច្ចានិ សយំ ថុនន្តីតិ នានា តេ សច្ចានិ សយំ ថុនន្តិ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ សយំ ថុនន្តិ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ អសស្សតោ លោកោ ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ សយំ ថុនន្តិ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ នានា តេ សច្ចានិ សយំ ថុនន្តិ ។

(២៣៤) កស្មា ន ឯកំ សមណា វទន្តីតិ កស្មាតិ កស្មា កិំការណា កិំហេតុ កិប្បច្ចយា កិំនិទានា ន ឯកំ វទន្តិ នានា វទន្តិ វិវិធំ វទន្តិ អញ្ញោញ្ញំ វទន្តិ បុថុ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ

(២៣៣) ពាក្យថា សមណព្រាហ្មណ៍ទាំងឡាយនោះ តែង ពោលតាមទំនើងខ្លួនឯង នូវសច្ចៈទាំងឡាយផ្សេង ៗ គ្នា សេចក្តីថា សមណព្រាហ្មណ៍ទាំងឡាយនោះ តែងសរសើរ ពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយ តាមទំនើងខ្លួនឯង នូវសច្ចៈទាំងឡាយផ្សេង ៗ គ្នា គឺ តែងសរសើរ ពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយ តាមទំនើងខ្លួនឯងថា លោកទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ តែង សរសើរ ពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយ តាមទំនើងខ្លួនឯងថា លោកមិនទៀង ។បេ។ សត្វស្លាប់ហើយកើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ហេតុនោះ (ទ្រង់ត្រាស់ថា) សមណព្រាហ្មណ៍ទាំងឡាយនោះ តែង ពោលតាមទំនើងខ្លួនឯង នូវសច្ចៈទាំងឡាយផ្សេង ៗ គ្នា ។

(២៣៤) ពាក្យថា ព្រោះហេតុនោះ ទើបសមណៈទាំងឡាយ មិន ពោលពាក្យតែមួយ ត្រង់ពាក្យថា ព្រោះហេតុនោះ គឺ ព្រោះហេតុ ដូច្នោះ ព្រោះដំណើរនោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាន នោះ ទើបសមណៈទាំងឡាយ មិនពោលពាក្យតែមួយ គឺពោល ផ្សេង ៗ ពោលប្រការផ្សេង ៗ ពោលដោយឡែកពីគ្នា ពោល ថ្លែង ពណ៌នាពន្យល់ អធិប្បាយ មានប្រមាណច្រើន ហេតុនោះ(ទ្រង់ត្រាស់ថា)

តស្មា ន ឯកំ សមណា វទន្តិ ។ តេនាហ ភគវា

ឯកំ ហិ សច្ចំ ន ទុតីយមត្ថិ

យស្មឹ បជា នោ វិវទេ បជានំ

នានា តេ សច្ចានិ សយំ ថុនន្តិ

តស្មា ន ឯកំ សមណា វទន្តីតិ ។

(២៣៥) កស្មា នុ សច្ចានិ វទន្តិ នានា

បវាទិយាសេ កុសលាវទានា

សច្ចានិ សុតានិ ពហូនិ នានា

ឧទាហុ តេ តក្កមនុស្សរន្តិ ។

(២៣៦) កស្មា នុ សច្ចានិ វទន្តិ នានាតិ

កស្មាតិ កស្មា កិំការណា កិំហេតុ កិំបច្ចយា

កិំនិទានា សច្ចានិ នានា វទន្តិ វិវិធានិ វទន្តិ

ព្រោះហេតុនោះ ទើបសមណៈទាំងឡាយ មិនពោលពាក្យតែបែបមួយ ៗ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

សត្វដឹងច្បាស់នូវសច្ចៈណា មិនគប្បីទាស់ទែងគ្នា សច្ចៈ (នោះ) មានតែមួយ មិនមានជាគំរប់ពីរទេ សមណៈព្រាហ្មណ៍ទាំងឡាយនោះ តែងពោលតាមទំនើងខ្លួនឯងនូវសច្ចៈទាំងឡាយផ្សេង ៗ គ្នា ព្រោះហេតុនោះ ទើបសមណៈទាំងឡាយ មិនពោលពាក្យតែបែបមួយ ៗ

[២៣៥] (ព្រះពុទ្ធនិម្មិតសួរថា) ព្រោះហេតុអ្វី ពួកសមណព្រាហ្មណ៍ ជាអ្នកប្រកាន់ថាឈ្លាសវៃ ពោល ពោលជជែកនូវសច្ចៈទាំងឡាយ ផ្សេង ៗ គ្នា សច្ចៈទាំងឡាយ ច្រើនផ្សេង ៗ តើ (សមណព្រាហ្មណ៍ទាំងនោះ) បានឮឬ ឬក៏សមណព្រាហ្មណ៍ទាំងនោះ រវើកដោយសេចក្តីត្រិះរិះទេ ៗ

[២៣៦] ពាក្យថា ព្រោះហេតុអ្វី ពួកសមណព្រាហ្មណ៍ពោលនូវសច្ចៈទាំងឡាយ ផ្សេង ៗ គ្នា ត្រង់ពាក្យថា ព្រោះហេតុអ្វី គឺ ព្រោះហេតុម្តេច ព្រោះដំណើរដូចម្តេច ព្រោះហេតុដូចម្តេច ព្រោះបច្ច័យដូចម្តេច ព្រោះនិទានដូចម្តេច ទើបពួកសមណព្រាហ្មណ៍ ពោលនូវសច្ចៈទាំងឡាយផ្សេង ៗ ពោលនូវសច្ចៈទាំងឡាយមានប្រការ ផ្សេង ៗ

ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ

អញ្ញោញ្ញានិ វទន្តិ បុថូនិ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ កស្មា នុ សច្ចានិ វទន្តិ នានា ។

(២៣៧) បវទិយាសេ កុសលាវទានាតិ បវទិយាសេតិ វិប្បវទន្តីតិបិ បវទិយាសេ ។ អថវា សកំ សកំ ទិដ្ឋិគតំ បវទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ បវទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ អសស្សតោ លោកោ ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ បវទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ ។ កុសលាវទានាតិ កុសលវាទា បណ្ឌិតវាទា ថិរវាទា ញាណវាទា ហេតុវាទា លក្ខណវាទា ការណវាទា ឋានវាទា សកាយ លទ្ធិយាតិ បវទិយាសេ កុសលាវទានា ។

ពោលដោយឡែកពីគ្នា ពោល ថ្លែង ពណ៌នា អធិប្បាយ នូវសច្ចៈទាំងឡាយមានប្រមាណច្រើន ហេតុនោះ (ទ្រង់ត្រាស់សួរថា) ព្រោះហេតុអ្វី ពួកសមណព្រាហ្មណ៍ ពោលនូវសច្ចៈទាំងឡាយផ្សេងៗគ្នា ។

[២៣៧] អធិប្បាយពាក្យថា ជាអ្នកប្រកាន់ថាឈ្លាសវៃ ពោលពោលផ្សេងៗ ត្រង់ពាក្យថា ពោលផ្សេងៗ គឺរមែងពោលផ្សេងៗ ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) ពោលផ្សេងៗ ។ មួយទៀត សមណព្រាហ្មណ៍ទាំងឡាយ ពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយនូវទិដ្ឋិរបស់ខ្លួនៗ គឺពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយថាលោកទៀង ពាក្យនេះ ជាពាក្យពិត ពាក្យដទៃ ជាមោឃៈ ពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយថា លោកមិនទៀង ។បេ។ សត្វស្លាប់ហើយកើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ពាក្យនេះ ជាពាក្យពិត ពាក្យដទៃ ជាមោឃៈ ។ ពាក្យថា អ្នកប្រកាន់ថាឈ្លាសវៃ គឺជាអ្នកពោលថាឈ្លាសវៃ ពោលថាជាបណ្ឌិត ពោលថាជាអ្នកប្រាជ្ញ ពោលថាមានញាណ ពោលត្រូវទំនង ពោលប្រកបដោយលក្ខណៈ ពោលប្រកបដោយហេតុ ពោលគួរដល់ឋានៈ តាមលទ្ធិរបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់សួរថា) ជាអ្នកប្រកាន់ថាឈ្លាសវៃ ពោល ពោលផ្សេងៗ ។

(២៣៨) សទ្ទានិ សុត្វានិ ពហូនិ នានាតិ សទ្ទានិ សុត្វានិ ពហូនិ(១) នានានិ វិវិធានិ អញ្ញោញ្ញានិ បុថូនីតិ សទ្ទានិ សុត្វានិ ពហូនិ នានា ។

(២៣៩) ឧទាហុ តេ តក្កមនុស្សរន្តីតិ ឧទាហុ តក្កេន វិតក្កេន សង្កប្បេន យាយន្តិ និយ្យន្តិ វុយ្ហន្តិ សំហារិយន្តីតិ ឯវម្បិ ឧទាហុ តេ តក្កមនុស្សរន្តិ ។ អថវា តក្កបរិយាហតំ វីមំសានុចរិតំ សយំ បដិភាណំ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ ឯវម្បិ ឧទាហុ តេ តក្កមនុស្សរន្តិ ។ តេនាហ សោ និម្មិតោ

១ ម. ពហុកានិ ។

(២៣៨) ពាក្យថា សត្វៈទាំងឡាយ ច្រើន ផ្សេងៗ (តើសមណព្រាហ្មណ៍ ទាំងនោះ) បានឮឬ សេចក្តីថា សត្វៈទាំងឡាយ ច្រើន ផ្សេងៗ មានប្រការផ្សេងៗ ដទៃ ៗ ជាអនេក (តើសមណព្រាហ្មណ៍ទាំងនោះ) បានឮឬ ហេតុនោះ (ទ្រង់ត្រាស់សួរថា) សត្វៈទាំងឡាយ ច្រើន ផ្សេង ៗ តើសមណព្រាហ្មណ៍ទាំងនោះ បានឮឬ ។

(២៣៩) ពាក្យថា ឬក៏សមណព្រាហ្មណ៍ ទាំងនោះ ពោលដោយសេចក្តីត្រិះរិះ សេចក្តីថា ឬក៏ (សមណព្រាហ្មណ៍ ទាំងនោះ) ត្រូវសេចក្តីត្រិះរិះ សេចក្តីត្រិះរិះផ្សេងៗ សេចក្តីត្រិះរិះព្រម. ឲ្យទៅ ឲ្យនាំទៅ ឲ្យសោត់ទៅ ឲ្យក្លួចទៅ ហេតុនោះ (ទ្រង់ត្រាស់សួរថា) ឬក៏ សមណព្រាហ្មណ៍ ទាំងនោះ ពោល ដោយសេចក្តីត្រិះរិះ ។ មួយទៀត សមណព្រាហ្មណ៍ ទាំងឡាយ ពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយ នូវប្រាជ្ញា ដែលស្រាវជ្រាវ ដោយសេចក្តីត្រិះរិះ ដែលរិះរក ដោយការពិចារណា ដោយខ្លួនឯង ហេតុនោះ (ទ្រង់ត្រាស់សួរថា) ឬក៏ សមណព្រាហ្មណ៍ទាំងនោះ ពោលដោយសេចក្តីត្រិះរិះ ។ ហេតុនោះ ព្រះពុទ្ធនិម្មិតនោះ ត្រាស់សួរថា

ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ

កស្មា នុ សច្ចានិ វទន្តិ នានា
បវាទិយាសេ កុសលា វទានា
សច្ចានិ សុត្តានិ ពហូនិ នានា
ឧទាហុ តេ តក្កមនុស្សរន្តិ ។

(២៤០) ន ហេវ សច្ចានិ ពហូនិ នានា
អញ្ញត្រ សញ្ញាយ និច្ចានិ លោកេ
តក្កញ្ច ទិដ្ឋីសុ បកប្បយិត្វា
សច្ចំ មុសាតិ ទ្វយធម្មមាហុ ។

(២៤១) ន ហេវ សច្ចានិ ពហូនិ នានាតិ ន ហេវ សច្ចានិ ពហុកានិ នានានិ វិវិធានិ អញ្ញោញ្ញានិ បុថូនីតិ ន ហេវ សច្ចានិ ពហូនិ នានា ។

(២៤២) អញ្ញត្រ សញ្ញាយ និច្ចានិ លោកេតិ អញ្ញត្រ សញ្ញាយ និច្ចគ្គាហា ឯកញ្ញេវ សច្ចំ លោកេ កថិយតិ ភណិយតិ ទីបិយតិ វោហរិយតិ

ព្រោះហេតុអ្វី ពួកសមណព្រាហ្មណ៍ ជាអ្នកប្រកាន់ថា ឈ្លាសវៃ ពោល ពោលដដែក នូវសច្ចៈទាំងឡាយ ផ្សេងៗ គ្នា សច្ចៈទាំងឡាយ ច្រើន ផ្សេងៗ តើ (សមណ-ព្រាហ្មណ៍ទាំងនោះ) បានឮឬ ឬក៏ សមណព្រាហ្មណ៍ ទាំងនោះ រាវរកដោយសេចក្ដីត្រិះរិះទេ ។

(៤៤០) (ព្រះមានព្រះភាគ ត្រាស់ថា) សច្ចៈទាំងឡាយ ក្នុងលោក វៀរលែងតែសេចក្ដីប្រកាន់ថាទៀងដោយសញ្ញា ចេញ មិនមែនមានច្រើន ផ្សេងៗគ្នាទេ មួយវិញទៀត ជនទាំងឡាយ តែងតាំងនូវសេចក្ដីត្រិះរិះ ក្នុងទិដ្ឋិទាំងឡាយ ហើយពោល នូវធម៌ ជាគូ ថាពិត ជាកុហក ។

(៤៤១) ពាក្យថា សច្ចៈទាំងឡាយ មិនមែនមានច្រើន ផ្សេងៗ គ្នាទេ គឺសច្ចៈទាំងឡាយមិនមែនមានច្រើន ផ្សេង ៗ មានប្រការផ្សេងៗ ដោយឡែកពីគ្នាច្រើនទេ ហេតុនោះ (ទ្រង់ត្រាស់ថា) សច្ចៈទាំងឡាយ មិនមែនមានច្រើន ផ្សេង ៗ គ្នាទេ ។

(៤៤២) អធិប្បាយពាក្យថា ក្នុងលោក វៀរលែងតែសេចក្ដីប្រកាន់ថា ទៀង ដោយសញ្ញាចេញ សេចក្ដីថា ក្នុងលោកវៀរលែងតែសេចក្ដីប្រកាន់ ថាទៀង ដោយសញ្ញាចេញ សច្ចៈ ដែលលោក ថ្លែង ពណ៌នា ពន្យល់

ទុក្ខនិរោធោ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ ។ អជភ ឋលំ សច្ចំ វុច្ចតិ មគ្គសច្ចំ និយ្យានសច្ចំ ទុក្ខនិរោធគាមិនី បដិបទា អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធីតិ អញ្ញត្រ សច្ចាយ និព្វាតិ លោកេ ។

(៤៤៣) តក្កញ្ច ទិដ្ឋីសុ បកប្បយិត្វា សច្ចំ មុសាតិ ទ្វយធម្មមាហូតិ តក្កំ វិតក្កំ សង្កប្បំ តក្កយិត្វា វិតក្កយិត្វា សង្កប្បយិត្វា ទិដ្ឋិគតានិ ជនេន្តិ សញ្ជនេន្តិ និព្វត្តេន្តិ អភិនិព្វត្តេន្តិ ទិដ្ឋិគតានិ ជនេត្វា សញ្ជនេត្វា និព្វត្តេត្វា អភិនិព្វត្តេត្វា មយ្ហំ សច្ចំ តុយ្ហំ មុសាតិ ឯវមាហំសុ ឯវំ កថេន្តិ ឯវំ ភណន្តិ ឯវំ ទីបយន្តិ ឯវំ វោហរន្តីតិ តក្កញ្ច ទិដ្ឋីសុ បកប្បយិត្វា សច្ចំ មុសាតិ ទ្វយធម្មមាហុ ។ តេនាហ ភគវា

អធិប្បាយថា មានតែមួយ គឺទុក្ខនិរោធនិព្វាន បានដល់ កិរិយារម្ងាប់នូវសង្ខារទាំងពួង កិរិយាកំចាត់បង់នូវឧបធិទាំងពួង កិរិយាអស់តណ្ហា កិរិយាប្រាសចាករាគៈ កិរិយារលត់ទុក្ខ ព្រះនិព្វាន ។ មួយទៀត សច្ចៈមួយ លោកពោលសំដៅយក មគ្គសច្ចៈ និយ្យានសច្ចៈ ទុក្ខនិរោធគាមិនីបដិបទា មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ហេតុនោះ (ទ្រង់ត្រាស់ថា) ក្នុងលោក វៀរលែងតែសេចក្តីប្រកាន់ថាទៀង ដោយសញ្ញា ។

(៤៤៣) ពាក្យថា មួយទៀត ជនទាំងឡាយ តែងតាំងនូវសេចក្តីត្រិះរិះ ក្នុងទិដ្ឋិទាំងឡាយ ហើយពោលនូវធម៌ជាគូ ថាពិត ថាកុហក សេចក្តីថា ជនទាំងឡាយ ត្រិះរិះ ត្រិះរិះផ្សេង ៗ ត្រិះរិះព្រមនូវសេចក្តីត្រិះរិះ នូវសេចក្តីត្រិះរិះផ្សេង ៗ នូវសេចក្តីត្រិះរិះព្រម ហើយញុំាងទិដ្ឋិទាំងឡាយឲ្យកើត ឲ្យកើតព្រម ឲ្យកើតឡើង ឲ្យកើតចំពោះ លុះញុំាងទិដ្ឋិទាំងឡាយ ឲ្យកើត ឲ្យកើតព្រម ឲ្យកើតឡើង ឲ្យកើតចំពោះ ហើយ ក៏ពោលយ៉ាងនេះ ថ្លែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ ពន្យល់យ៉ាងនេះ អធិប្បាយយ៉ាងនេះថា ពាក្យរបស់ខ្ញុំ ជាពាក្យពិត ពាក្យរបស់អ្នក ជាពាក្យកុហក ហេតុនោះ (ទ្រង់ត្រាស់ថា) ជនទាំងឡាយ តែងតាំងនូវសេចក្តីត្រិះរិះ ក្នុងទិដ្ឋិទាំងឡាយហើយពោល នូវធម៌ជាគូ ថាពិត ថាកុហក ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ហើយថា

ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ

ន ហេវ សច្ចានិ ពហូនិ នានា
អញ្ញត្រ សញ្ញាយ និច្ចានិ លោកេ
តក្កញ្ច ទិដ្ឋីសុ បកប្បយិត្វា
សច្ចំ មុសាតិ ទ្វយធម្មមាហុ ។

(២៤៤) ទិដ្ឋេ សុតេ សីលវតេ មុតេ វា
ឯតេ ច និស្សាយ វិមានទស្សី
វិនិច្ឆយេ ឋត្វា បហស្សមានោ(១)
ពាលោ បរោ អកុសលោតិ ចាហ ។

(២៤៥) ទិដ្ឋេ សុតេ សីលវតេ មុតេ វា ឯតេ ច និស្សាយ វិមានទស្សីតិ ទិដ្ឋំ វា ទិដ្ឋសុទ្ធឹ វា សុតំ វា សុតសុទ្ធឹ វា សីលំ វា សីលសុទ្ធឹ វា វត្តំ វា វត្តសុទ្ធឹ វា មុតំ វា មុតសុទ្ធឹ វា និស្សាយ ឧបនិស្សាយ គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វាតិ ទិដ្ឋេ សុតេ សីលវតេ មុតេ វា ។

១ ម. បហំសមានោ ។

## ចូឡវិយូហសុត្តនិទ្ទេស ទី ១២

សច្ចៈទាំងឡាយ ក្នុងលោក វៀរលែងតែសេចក្ដីប្រកាន់ថា
ទៀងដោយសញ្ញាចេញ មិនមែនមានច្រើន ផ្សេង ៗ គ្នាទេ
មួយទៀត ជនទាំងឡាយ តែងតាំងនូវសេចក្ដីត្រិះរិះ ក្នុង
ទិដ្ឋិទាំងឡាយ ហើយពោលនូវធម៌ជាគូ ថាពិត ថាកុហក ។

(២៤៤) បុគ្គលអាស្រ័យទិដ្ឋិធម៌ ទាំងនេះ គឺការឃើញក្ដី
ការឮក្ដី សីលនឹងវ័តក្ដី ការប៉ះពាល់ក្ដី ហើយជាអ្នក
ឃើញនូវការមើលងាយ ឋិតនៅក្នុងវិនិច្ឆ័យ ហើយរីករាយ
បានពោលថា បុគ្គលពាល ថោកទាប មិនឈ្លាសវៃ ។

(២៤៥) អធិប្បាយពាក្យថា បុគ្គលអាស្រ័យទិដ្ឋិធម៌ទាំងនេះ គឺការឃើញក្ដី ការឮក្ដី សីលនឹងវ័តក្ដី ការប៉ះពាល់ក្ដី ហើយជាអ្នកឃើញនូវការមើលងាយ សេចក្ដីថា បុគ្គលអាស្រ័យ ចូលទៅអាស្រ័យ កាន់យក បបោសអង្អែល ជាប់ចិត្ត នូវការឃើញ ឬនូវសេចក្ដីបរិសុទ្ធិ ព្រោះការឃើញក្ដី នូវការឮ ឬនូវសេចក្ដីបរិសុទ្ធិព្រោះការឮក្ដី នូវសីល ឬនូវសេចក្ដីបរិសុទ្ធិព្រោះសីលក្ដី នូវវ័ត ឬនូវសេចក្ដីបរិសុទ្ធិព្រោះវ័តក្ដី នូវការប៉ះពាល់ ឬនូវសេចក្ដីបរិសុទ្ធិព្រោះការប៉ះពាល់ក្ដី ហេតុនោះ (ទ្រង់ត្រាស់ថា) ការឃើញក្ដី ការឮក្ដី សីលនឹងវ័តក្ដី ការប៉ះពាល់ក្ដី ។

ឯតេ ច(១) និស្សាយ វិមានទស្សីតិ ន សម្មានេតីតិបិ វិមានទស្សី ។ អថវា ទោមនស្សំ ជនេតីតិបិ វិមានទស្សីតិ ទិដ្ឋេ សុតេ សីលវតេ មុតេ វា ឯតេ ច និស្សាយ វិមានទស្សី ។

[៤២៦] វិនិច្ឆយេ ឋត្វា បហស្សមានោតិ វិនិច្ឆយា វុច្ចន្តិ ទ្វាសដ្ឋី ទិដ្ឋិគតានិ(២) វិនិច្ឆិតទិដ្ឋិយា(៣) ឋត្វា បតិដ្ឋហិត្វា គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វាតិ វិនិច្ឆយេ ឋត្វា ។ បហស្សមានោតិ តុដ្ឋោ ហោតិ ហដ្ឋោ បហដ្ឋោ អត្តមនោ បរិបុណ្ណសង្កប្បោ ។ អថវា ទន្តវិទំសកំ ហស្សមានោតិ វិនិច្ឆយេ ឋត្វា បហស្សមានោ ។

---

១ ម. ឯតេសុ ។ ២ ឱ. ម. ឯត្ថន្តរេ ទិដ្ឋិវិនិច្ឆយោតិ ទិស្សតិ ។ ៣ ម. វិនិច្ឆយទិដ្ឋិយា ។

ពាក្យថា បុគ្គលអាស្រ័យទិដ្ឋិធម៌ទាំងនេះ ហើយជាអ្នកឃើញនូវការមើលឆ្ងាយ គឺ ឈ្មោះថា អ្នកឃើញនូវការមើលឆ្ងាយ ព្រោះហេតុមិនពប់អានខ្លះ ។ ឬថា ឈ្មោះថា អ្នកមើលឆ្ងាយ ព្រោះហេតុញុំាងទោមនស្សឲ្យកើតខ្លះ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលអាស្រ័យទិដ្ឋិធម៌ទាំងនេះ គឺការឃើញក្តី ការឮក្តី សីលនឹងវត្តក្តី ការប៉ះពាល់ក្តី ហើយជាអ្នកឃើញ នូវការមើលឆ្ងាយ ។

(៤៤៦) ពាក្យថា បិតនៅក្នុងវិនិច្ឆ័យ ហើយរីករាយ សេចក្តីថា ដែលហៅថា វិនិច្ឆ័យ បានដល់ទិដ្ឋិ ៦២ (បុគ្គល) បិតនៅ បិតនៅស៊ប់ កាន់យក ប្រកាសអង្រួល ជាប់ចិត្ត ក្នុងទិដ្ឋិដែលខ្លួនសម្រេចហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលបិតនៅក្នុងវិនិច្ឆ័យ ។ ពាក្យថា រីករាយ គឺជាអ្នកត្រេកអរ រីករាយ រីករាយទូទៅ មានចិត្តជារបស់ខ្លួន មានសេចក្តីត្រិះរិះបរិបូណ៌ ។ ឬថា សើចបញ្ចេញធ្មេញ ហេតុនោះ (ទ្រង់ត្រាស់ថា) បិតនៅក្នុងវិនិច្ឆ័យ ហើយរីករាយ ។

ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ

(២៤៧) ពាលោ បរោ អក្កុសលោតិ ចាហាតិ បរោ ពាលោ ហីនោ និហីនោ ឱមកោ លាមកោ ឆតុក្កោ បរិត្តោ អកុសលោ អវិទ្វា អវិជ្ជាគតោ អញ្ញាណី អវិភាវី(១) ទុប្បញ្ញោតិ ឯវមាហ ឯវំ កថេតិ ឯវំ ភណតិ ឯវំ ទីបយតិ ឯវំ វោហរតីតិ ពាលោ បរោ អក្កុសលោតិ ចាហ ។ តេនាហ ភគវា

ទិដ្ឋេ សុតេ សីលវតេ មុតេ វា
ឯតេ ច និស្សាយ វិមានទស្សី
វិនិច្ឆយេ ឋត្វា បហស្សមានោ
ពាលោ បរោ អក្កុសលោតិ ចាហាតិ ។

(២៤៨) យេនេវ ពាលោតិ បរំ ទហាតិ
តេនាតុមានំ កុសលោតិ ចាហ
សយមត្តនា សោ កុសលាវទានោ
អញ្ញំ វិមានេតិ តទេវ បាវ(២) ។

---

១ ឱ. ម. ឯត្ថន្តរេ អមេធាវីតិ ទិស្សតិ ។ ២ ម. តទេវ បាវទ ។

(៤៤៧) ពាក្យថា បានពោលថា បុគ្គលពាល ថោកទាប មិនឈ្លាសវៃ គឺ ពាលយ៉ាងនេះ ថ្លែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ ពន្យល់យ៉ាងនេះ អធិប្បាយយ៉ាងនេះថា បុគ្គលអន់ លង់ ថោកទាប សាបសូន្យ ថោកថយ លាមក គម្រក់ ជាមនុស្សកំរេចកំទី មិនឈ្លាសវៃ មិនមានប្រាជ្ញាជាគ្រឿងចាក់ធ្លុះ លុះក្នុងសេចក្តីល្ងង់ មិនមានញាណ មិនមានប្រាជ្ញាជាគ្រឿងបំភ្លឺ ឥតបញ្ញា ហេតុនោះ (ទ្រង់ត្រាស់ថា) បានពោលថា បុគ្គលពាល ថោកទាប មិនឈ្លាសវៃ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

បុគ្គលអាស្រ័យទិដ្ឋិធម៌ទាំងនេះ គឺការឃើញក្តី ការឮក្តី សីល
និងវត្តក្តី ការប៉ះពាល់ក្តី ហើយជាអ្នកឃើញនូវការមើល
ងាយ បិតនៅក្នុងវិនិច្ឆ័យហើយរីករាយ បានពោលថា
បុគ្គលពាល ថោកទាប មិនឈ្លាសវៃ ។

(៤៤៨) បុគ្គលយល់បុគ្គលដទៃ ថាជាបុគ្គលពាល ដោយអំពើណា
ហើយពោលចំពោះអាត្មាឯង ថាជាបុគ្គលឈ្លាសវៃ ដោយ
អំពើនោះ បុគ្គលនោះប្រកាន់ថាខ្លួនជាអ្នកឈ្លាសវៃ ដោយ
ខ្លួនឯង មើលងាយបុគ្គលដទៃ ទាំងពោលយ៉ាងនោះដែរ ។

[២៤៩] យេនេវ ពាលោតិ បរំ ទហាតីតិ យេន(១) ហេតុនា យេន បច្ចយេន យេន ការណេន យេន បភវេន បរំ ពាលតោ ហីនតោ និហីនតោ ឱមកតោ លាមកតោ ឆតុក្កតោ បរិត្តតោ ទហតិ បស្សតិ ទក្ខតិ ឱលោកេតិ និជ្ឈាយតិ ឧបបរិក្ខតីតិ យេនេវ ពាលោតិ បរំ ទហាតិ ។

[២៥០] តេនាតុមានំ កុសលោតិ ចាហាតិ អាតុមា(២) វុច្ចតិ អត្តា ។ សោបិ តេនេវ ហេតុនា តេន បច្ចយេន តេន ការណេន តេន បភវេន អត្តានំ អាហ អហមស្មិ កុសលោ បណ្ឌិតោ បញ្ញវា ពុទ្ធិមា ញាណី វិភាវី មេធាវីតិ តេនាតុមានំ កុសលោតិ ចាហ ។

---

១ ម. យេនេវ ។ ២ ម. អាតុមានោ ។

(២៤៩) ពាក្យថា បុគ្គលយល់បុគ្គលដទៃ ថាជាបុគ្គលពាល ដោយអំពើណា គឺបុគ្គលយល់ឃើញ មើលឃើញ ក្រឡេកឃើញ សំឡឹងឃើញ ពិចារណាឃើញ នូវបុគ្គលដទៃ ថាជាបុគ្គលពាល ថោក ទាប ថោកថយ ទន់ទាប លាមក គម្រក់ ជាមនុស្សកំរេចកំរី ដោយហេតុណា ដោយបច្ច័យណា ដោយដំណើរណា ដោយហេតុដើមណា ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលយល់បុគ្គលដទៃ ថាជាបុគ្គលពាល ដោយហេតុណា ។

(២៥០) ពាក្យថា ពោលចំពោះអាត្មាឯង ថាជាបុគ្គលឈ្លាសវៃ ដោយអំពើនោះ អធិប្បាយថា អត្តា លោកហៅថា អាត្មា ។ បុគ្គលនោះឯង រមែងហៅខ្លួនឯងថា អាត្មាអញ ជាអ្នកឈ្លាសវៃ ជាបណ្ឌិត មានប្រាជ្ញា មានប្រាជ្ញាជាគ្រឿងដឹង មានញាណ មានប្រាជ្ញាជាគ្រឿងបំភ្លឺ ជាមេធាវី ដោយហេតុនោះ ដោយបច្ច័យនោះ ដោយដំណើរនោះ ដោយហេតុដើមនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលពោលចំពោះអាត្មាឯង ថាជាបុគ្គលឈ្លាសវៃ ដោយអំពើនោះ ។

## ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ

(២៨១) សយមត្តនា សោ កុសលោវទានោតិ សយំ(១) អត្តានំ កុសលវាទោ បណ្ឌិតវាទោ ធីរវាទោ ញាណវាទោ ហេតុវាទោ លក្ខណវាទោ ការណវាទោ ឋានវាទោ សកាយ លទ្ធិយាតិ សយមត្តនា សោ កុសលោវទានោ ។

(២៨២) អញ្ញំ វិមានេតិ តទេវ បាវាតិ ន សម្មានេតីតិ-បិ អញ្ញំ វិមានេតិ ។ អថវា ទោមនស្សំ ជនេតីតិបិ អញ្ញំ វិមានេតិ ។ តទេវ បាវាតិ តទេវ តំ ទិដ្ឋិគតំ បាវទតិ ឥតិបាយំ បុគ្គលោ មិច្ឆាទិដ្ឋិកោ វិបរីតទ-ស្សនោតិ អញ្ញំ វិមានេតិ តទេវ បាវា ។ តេនាហ ភគវា

១ ម. សយមេវ ។

ចូឡវិយូហសុត្តនិទ្ទេស ទី ១២

(៤៩១) ពាក្យថា បុគ្គលនោះ ប្រកាន់ថាខ្លួនជាអ្នកឈ្លាសវៃ ដោយខ្លួនឯង គឺពោលថាឈ្លាសវៃ ពោលថាជាបណ្ឌិត ពោលថាជាអ្នកប្រាជ្ញ ពោលថាប្រកបដោយញាណ ពោលថាត្រូវទំនង ពោលថាប្រកបដោយលក្ខណៈ ពោលថាប្រកបដោយហេតុ ពោលថាគួរដល់ឋានៈ នូវខ្លួន ដោយខ្លួនឯង តាមលទ្ធិរបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ ប្រកាន់ថាខ្លួនជាអ្នកឈ្លាសវៃ ។

(៤៩២) ពាក្យថា មើលងាយ បុគ្គលដទៃ ទាំងពោលយ៉ាងនោះដែរ គឺមើលងាយបុគ្គលដទៃ ព្រោះហេតុមិនកប់អានខ្លះ ។ ឬមើលងាយបុគ្គលដទៃ ព្រោះហេតុញុំាងទោសឲ្យកើតខ្លះ ។ ពាក្យថា ទាំងពោលយ៉ាងនោះដែរ គឺបុគ្គលរមែងពោលប្រកាន់ នូវទិដ្ឋិនោះ ដោយប្រការដូច្នោះថា បុគ្គលនេះ ជាមិច្ឆាទិដ្ឋិ មានការយល់ខុស ដោយប្រការដូច្នេះ ហេតុនោះ (ទ្រង់ត្រាស់ថា) មើលងាយបុគ្គលដទៃ ទាំងពោលយ៉ាងនោះដែរ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

យេនេវ ពាលោតិ បរំ ទហាតិ
តេនាតុមានំ កុសលោតិ ចាហ
សយមត្តនា សោ កុសលោវទានោ
អញ្ញំ វិមានេតិ តទេវ បាវាតិ ។

(២៥៣) អតីសារំទិដ្ឋិយា(១) សោ សមត្តោ
មានេន មត្តោ បរិបុណ្ណមានី
សយមេវ សាមំ មនសាភិសិត្តោ
ទិដ្ឋី ហិ សា តស្ស តថា សមត្តា ។

(២៥៤) អតីសារំទិដ្ឋិយា សោ សមត្តោតិ អតិសារទិដ្ឋិយោ វុច្ចន្តិ ទ្វាសដ្ឋី ទិដ្ឋិគតានិ ។ កិំការណា អតិសារទិដ្ឋិយោ វុច្ចន្តិ ទ្វាសដ្ឋី ទិដ្ឋិគតានិ ។ សព្វា តា ទិដ្ឋិយោ ការណាតិក្កន្តា លក្ខណាតិក្កន្តា ហីនាតិក្កន្តា(២) តំការណា អតិសារទិដ្ឋិយោ វុច្ចន្តិ ទ្វាសដ្ឋី ទិដ្ឋិគតានិ ។ សព្វេបិ តិត្ថិយា អតិសារទិដ្ឋិយា ។ កិំការណា សព្វេបិ តិត្ថិយា អតិសារទិដ្ឋិយា ។ អញ្ញមញ្ញំ អតិក្កមិត្វា សមតិក្កមិត្វា វីតិវត្តិត្វា

---

១ ម. អតិសារទិដ្ឋិយា ។ ២ ម. ឋានាតិក្កន្តា ។ ម. សព្វាបិ ទិដ្ឋិយោ អតិសារទិដ្ឋិយោ។ កឹការណា សព្វាបិ ទិដ្ឋិយោ វុច្ចន្តិ អតិសារទិដ្ឋិយោ ។

បុគ្គលយល់ បុគ្គលដទៃ ថាជាបុគ្គលពាល ដោយអំពើណា ហើយពោល ចំពោះអាត្មាឯង ថាជាបុគ្គលឈ្លាសវៃ ដោយអំពើនោះ បុគ្គលនោះ ប្រកាន់ថាខ្លួនជាអ្នកឈ្លាសវៃ ដោយខ្លួនឯង រមែងមើលងាយបុគ្គលដទៃ ទាំងពោលយ៉ាងនោះដែរ ។

(២៥៣) បុគ្គលនោះ សម្រេចដោយទិដ្ឋិមានសារៈដ៏ក្រៃលែង ជាអ្នកស្រវឹងដោយមានះ មានមានះបរិបូណ៌ អភិសេកខ្លួនដោយចិត្តខ្លួនឯង ព្រោះថា ទិដ្ឋិនោះ បុគ្គលនោះសម្រេចហើយ ដោយប្រការដូច្នោះ ។

(២៥៤) ពាក្យថា បុគ្គលនោះសម្រេចដោយទិដ្ឋិ មានសារៈដ៏ក្រៃលែង អធិប្បាយថា ទិដ្ឋិ ៦២ ហៅថាទិដ្ឋិមានសារៈដ៏ក្រៃលែង ។ ទិដ្ឋិ ៦២ ហេតុអ្វីក៏លោកហៅថា ទិដ្ឋិមានសារៈដ៏ក្រៃលែង ។ ទិដ្ឋិទាំងអស់នោះ កន្លងនូវហេតុ កន្លងនូវលក្ខណៈ កន្លងនូវការថោកទាប ហេតុនោះ ទិដ្ឋិទាំង ៦២ ហៅថាទិដ្ឋិមានសារៈដ៏ក្រៃលែង ។ ពួកតិត្ថិយទាំងអស់ មានទិដ្ឋិ មានសារៈដ៏ក្រៃលែង ។ ហេតុអ្វីក៏ពួកតិត្ថិយទាំងអស់ មានទិដ្ឋិ មានសារៈដ៏ក្រៃលែង ។ ពួកតិត្ថិយទាំងនោះ កន្លង កន្លងព្រម ប្រព្រឹត្តកន្លង នូវគ្នានឹងគ្នា

ទិដ្ឋិគតានិ ជនេន្តិ សញ្ជនេន្តិ និព្វត្តេន្តិ អភិនិព្វត្តេន្តិ តំការណា សព្វេបិ តិត្ថិយា អតិសារទិដ្ឋិយា ។ សោ សមត្តោតិ អតិសារទិដ្ឋិយា សមត្តោ បរិបុណ្ណោ អនោមោតិ អតីសរំទិដ្ឋិយា សោ សមត្តោ ។

(២៨៨) មានេន មត្តោ បរិបុណ្ណមានីតិ សកាយ ទិដ្ឋិយា(១) មានេន មត្តោ បមត្តោ ឧម្មត្តោ អតិមត្តោតិ មានេន មត្តោ ។ បរិបុណ្ណមានីតិ បរិបុណ្ណមានី សមត្តមានី អនោមមានីតិ មានេន មត្តោ បរិបុណ្ណមានី ។

(២៨៩) សយមេវ សាមំ មនសាភិសិត្តោតិ សយមេវ អត្តានំ ចិត្តេន អភិសិញ្ចតិ អហមស្មិ កុសលោ បណ្ឌិតោ បញ្ញវា ពុទ្ធិមា ញាណី វិភាវី មេធាវីតិ សយមេវ សាមំ មនសាភិសិត្តោ ។

---

១ ម. ឯត្តន្តរេ ទិដ្ឋីតិ ទិស្សតិ ។

ហើយញុំាងទិដ្ឋិទាំងឡាយ ឲ្យកើត ឲ្យកើតព្រម ឲ្យបង្កើត ឲ្យបង្កើតបំពោះ ហេតុនោះបានជា ពួកតិរ្ថិយទាំងអស់ មានទិដ្ឋិ មានសារៈដ៏ក្រៃលែង ។ ពាក្យថា បុគ្គលនោះសម្រេច គឺសម្រេច បរិបូណ៌ មិនខ្វះខាតដោយទិដ្ឋិមានសារៈដ៏ក្រៃលែង ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះសម្រេច ដោយទិដ្ឋិ មានសារៈដ៏ក្រៃលែង ។

(២៥៥) ពាក្យថា ជាអ្នកស្រវឹងដោយមានះ មានមានះបរិបូណ៌ គឺជាអ្នកស្រវឹង ប្រមាទ ឆ្កួត ស្រវឹងលើសលុប ដោយសេចក្តីប្រកាន់ទិដ្ឋិរបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកស្រវឹងដោយមានះ ។ ពាក្យថា មានមានះបរិបូណ៌ គឺមានមានះពេញលេញ មានមានះសម្រេច មានមានះមិនខ្វះខាត ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកស្រវឹងដោយមានះ មានមានះបរិបូណ៌ ។

(២៥៦) ពាក្យថា អភិសេកខ្លួន ដោយចិត្តខ្លួនឯង គឺអភិសេកខ្លួនដោយចិត្តខ្លួនឯងថា អាត្មាអញ ជាបុគ្គលឈ្លាសវៃ ជាបណ្ឌិត មានបញ្ញា មានប្រាជ្ញាជាគ្រឿងដឹង មានញាណ មានប្រាជ្ញាជាគ្រឿងបំភ្លឺ ជាមេធាវី ហេតុនោះ (ទ្រង់ត្រាស់ថា) អភិសេកខ្លួន ដោយចិត្តខ្លួនឯង ។

(២៨៧) ទិដ្ឋី ហិ សា តស្ស តថា សមត្តាតិ តស្ស សា ទិដ្ឋិ តថា សមត្តា សមាទិន្នា គហិតា បរាមដ្ឋា អភិនិវិដ្ឋា អជ្ឈោសិតា អធិមុត្តាតិ ទិដ្ឋី ហិ សា តស្ស តថា សមត្តា ។ តេនាហ ភគវា

អតីសរំទិដ្ឋិយា សោ សមត្តោ
មានេន មត្តោ បរិបុណ្ណមានី
សយមេវ សាមំ មនសាភិសិត្តោ
ទិដ្ឋី ហិ សា តស្ស តថា សមត្តា ។

(២៨៨) បរស្ស ចេ ហិ វចសា និហីនោ
តុមោ(១) សហា ហោតិ និហីនបញ្ញោ
អថ ចេ សយំ វេទគូ ហោតិ ធីរោ
ន កោចិ ពាលោ សមណេសុ អត្ថិ ។

---

១ ម. តុម្ហោ ។

(២៤៧) ពាក្យថា ព្រោះថា ទិដ្ឋិនោះ បុគ្គលនោះ សម្រេចដោយប្រការដូច្នោះ គឺទិដ្ឋិនោះ បុគ្គលនោះ សម្រេច សមាទាន កាន់យក បរាមាសអង្អែល ជាប់ចិត្ត ចុះចិត្ត ចុះចិត្តស៊ប់ ដោយប្រការដូច្នោះ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះថា ទិដ្ឋិនោះ បុគ្គលនោះ សម្រេចដោយប្រការដូច្នោះ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

បុគ្គលនោះ សម្រេចដោយទិដ្ឋិ មានសារៈដ៏ក្រៃលែង
ជាអ្នកស្រវឹងដោយមានះ មានមានះបរិបូណ៌ អភិសេកខ្លួន
ដោយចិត្តខ្លួនឯង ព្រោះថា ទិដ្ឋិនោះ បុគ្គលនោះសម្រេច
ដោយប្រការដូច្នោះ ។

(២៤៨) ប្រសិនបើ បុគ្គលទន់អន់ដោយសារសំដី របស់
បុគ្គលដទៃ (បុគ្គលនោះ) នឹងមានបញ្ញាថោកទាបជាមួយ
មួយទៀតបុគ្គលជាវេទគូ ជាអ្នកប្រាជ្ញ ដោយខ្លួនឯងបាន
ឥតមានអ្នកណាមួយ ជាបុគ្គលពាល ក្នុងពួកសមណៈទេ ។

(២៥៩) បរស្ស ចេ ហី វចសា និហីនោតិ បរស្ស ចេ វាចាយ វចនេន និន្ទិតការណា គរហិតការណា ឧបវាទិតការណា បរោ ពាលោ ហោតិ ហីនោ និហីនោ ឱមកោ លាមកោ ឆតុក្កោ បរិត្តោតិ បរស្ស ចេ ហិ វចសា និហីនោ ។

(២៦០) តុមោ សហា ហោតិ និហីនបញ្ញោតិ សោបិ តេនេវ សហា ហោតិ ហីនបញ្ញោ និហីនបញ្ញោ ឱមកបញ្ញោ លាមកបញ្ញោ ឆតុក្កបញ្ញោ បរិត្តបញ្ញោតិ តុមោ សហា ហោតិ និហីនបញ្ញោ ។

(២៦១) អថវា[១] សយំ វេទគូ ហោតិ ធីរោតិ[២] ធីរោ បណ្ឌិតោ បញ្ញវា ពុទ្ធិមា ញាណី វិភាវី មេធាវីតិ អថវា សយំ វេទគូ ហោតិ ធីរោ ។

(២៦២) ន កោចិ ពាលោ សមណេសុ អត្ថីតិ សមណេសុ ន កោចិ ពាលោ ហីនោ និហីនោ ឱមកោ លាមកោ ឆតុក្កោ បរិត្តោ អត្ថិ

---

១ ម. អថ ចេ ។ ២ ឱ. ឯត្តន្តរេ អថវា សយំ វេទគូ ហោតីតិ ទិស្សន្តិ ។ ម អថ ចេ ។

ចូឡវិយូហសុត្តនិទ្ទេស ទី ១២

(២៥៩) ពាក្យថា ប្រសិនបើ បុគ្គលទន់អន់ដោយសារសំដី របស់បុគ្គលដទៃ គឺប្រសិនបើ បុគ្គលជាអ្នកអាប់ឱន ជាបុគ្គលពាល ថោកទាប អន់ ទន់ទាប លាមក គម្រក់ ជាមនុស្សកំទេចកំទី ព្រោះហេតុនៃសេចក្ដីនិន្ទា ព្រោះហេតុ នៃសេចក្ដីតិះដៀល ព្រោះហេតុនៃសេចក្ដីរិះគន់ ដោយសារសំដី ដោយសារពាក្យ របស់បុគ្គលដទៃ ហេតុនោះ (ទ្រង់ត្រាស់ថា) ប្រសិនបើ បុគ្គលទន់អន់ដោយសារសំដី របស់បុគ្គលដទៃ ។

(២៦០) ពាក្យថា (បុគ្គលនោះ) នឹងមានបញ្ញាថោកទាបជាមួយ គឺបុគ្គលនោះឯង ជាអ្នកមានបញ្ញាថោកទាប មានបញ្ញាថោកថយ មានបញ្ញាទន់ទាប មានបញ្ញាលាមក មានបញ្ញាគម្រក់ មានបញ្ញាស្តួចស្តើង ជាមួយនឹងបុគ្គលនោះឯង ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ នឹងជាបុគ្គលមានបញ្ញាថោកទាបជាមួយ ។

(២៦១) ពាក្យថា មួយទៀត បុគ្គលជាវេទគូ ជាអ្នកប្រាជ្ញដោយខ្លួនឯងបាន គឺបុគ្គលជាអ្នកប្រាជ្ញ ជាបណ្ឌិត មានបញ្ញា មានបញ្ញាជាគ្រឿងដឹង មានញាណ មានបញ្ញាជាគ្រឿងបំភ្លឺ ជាមេធាវី ហេតុនោះ (ទ្រង់ត្រាស់ថា) មួយទៀត បុគ្គលជាវេទគូ ជាអ្នកប្រាជ្ញដោយខ្លួនឯងបាន ។

(២៦២) ពាក្យថា ឥតមានអ្នកណាមួយ ជាបុគ្គលពាលក្នុងពួកសមណៈទេ គឺឥតមានអ្នកណាមួយ ជាបុគ្គលពាល ថោកទាប ថោកថយ ទន់ទាប លាមក គម្រក់ ជាមនុស្សកំទេចកំទី ក្នុងពួក

សព្វេ អគ្គបញ្ញា សេដ្ឋបញ្ញា វិសេដ្ឋបញ្ញា ចាមោក្ខ-
បញ្ញា ឧត្តមបញ្ញា បវរបញ្ញាតិ ន កោចិ ពាលោ
សមណេសុ អត្ថិ ។ តេនាហ ភគវា

បរស្ស ចេ ហិ វចសា និហីនោ
តុមោ សហា ហោតិ និហីនបញ្ញោ
អថ ចេ សយំ វេទគូ ហោតិ ធីរោ
ន កោចិ ពាលោ សមណេសុ អត្ថីតិ ។

(៤៦៣) អញ្ញំ ឥតោ យាភិវទន្តិ ធម្មំ
អបរទ្ធា សុទ្ធិមកេវលី តេ
ឯវម្បិ តិត្ថ្យា បុថុសោ វទន្តិ
សន្ទិដ្ឋិរាគេន ហិ ត្យាភិរត្តា ។

(៤៦៤) អញ្ញំ ឥតោ យាភិវទន្តិ ធម្មំ អបរទ្ធា
សុទ្ធិមកេវលី តេតិ ឥតោ អញ្ញំ ធម្មំ ទិដ្ឋឹ បដិបទំ មគ្គំ

សមណៈទេ គឺថា ទាំងអស់គ្នា សុទ្ធតែជាបុគ្គលមានបញ្ញាដ៏លើស មានបញ្ញាប្រសើរ មានបញ្ញាវិសេស មានបញ្ញាជាប្រធាន មានបញ្ញាដ៏ឧត្តម មានបញ្ញាដ៏បវរ ហេតុនោះ (ទ្រង់ត្រាស់ថា) ឥតមានអ្នកណាមួយ ជាបុគ្គលពាល ក្នុងពួកសមណៈទេ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ប្រសិនបើ បុគ្គលទន់អន់ដោយសារសំដី របស់បុគ្គលដទៃ
(បុគ្គលនោះ) នឹងមានបញ្ញាថោកទាបជាមួយ មួយទៀត
បុគ្គលជាវេទគូ ជាអ្នកប្រាជ្ញដោយខ្លួនឯងបាន ឥតមានអ្នក
ណាមួយ ជាបុគ្គលពាល ក្នុងពួកសមណៈទេ ។

(២៦៣) បុគ្គលទាំងឡាយណា សរសើរធម៌ដទៃ អំពីធម៌នេះ
បុគ្គលទាំងឡាយនោះ ឈ្មោះថា អ្នកឃ្លាតចាកសេចក្តីបរិសុទ្ធិ
ជាបុគ្គលមិនពេញលេញ បុគ្គលអ្នកមានលទ្ធិដូចជាកំពង់ទាំង
ឡាយ តែងពោលដោយច្រើន យ៉ាងនេះឯង ព្រោះថា
បុគ្គលទាំងឡាយនោះ ត្រេកអរក្រៃលែង ដោយសេចក្តី
ត្រេកអរនឹងទិដ្ឋិរបស់ខ្លួន ។

(២៦៤) ពាក្យថា បុគ្គលទាំងឡាយណា សរសើរធម៌ដទៃ អំពីធម៌នេះ បុគ្គលទាំងឡាយនោះ ឈ្មោះថា អ្នកឃ្លាតចាកសេចក្តីបរិសុទ្ធិ ជាបុគ្គលមិនពេញលេញ គឺបុគ្គលទាំងឡាយណា សរសើរធម៌ ទិដ្ឋិ បដិបទា

## ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ

យេ អភិវទន្តិ តេ សុទ្ធិមគ្គំ វិសុទ្ធិមគ្គំ បរិសុទ្ធិមគ្គំ វោទាតមគ្គំ បរិយោទាតមគ្គំ វិរទ្ធា អបរទ្ធា ខលិតា ភទ្ឋិតា អញ្ញាយ អបរទ្ធា អកោវិទា តេ អសមត្ថា តេ អបរិបុណ្ណា តេ ហីនា និហីនា ឱមកា លាមកា ជតុក្កា បរិត្តាតិ អញ្ញំ ឥតោ យាភិវទន្តិ ធម្មំ អបរទ្ធា សុទ្ធិមកោវិទា តេ ។

(៤៦៨) ឯវម្បិ តិត្ថ្យា បុថុសោ វទន្តីតិ តិត្ថំ វុច្ចតិ ទិដ្ឋិគតំ ។ តិត្ថ្យា វុច្ចន្តិ ទិដ្ឋិគតិកា ។ បុថុ ទិដ្ឋិយា បុថុទិដ្ឋិគតានិ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ ឯវម្បិ តិត្ថ្យា បុថុសោ វទន្តិ ។

មគ្គដទៃ អំពីធម៌នេះ បុគ្គលទាំងឡាយនោះ ឈ្មោះថា អ្នកខុស អ្នកប្រាស អ្នកភ្លាត់ អ្នកឃ្លាត ចាកផ្លូវស្អាត ផ្លូវស្អាតវិសេស ផ្លូវបរិសុទ្ធិ ផ្លូវហ្មត់ចត់ ផ្លូវផូរផង់ ជាបុគ្គលខុស មិនពេញលេញ ព្រោះមិនមានញាណ បុគ្គលទាំងឡាយនោះ មិនបានសម្រេច បុគ្គលទាំងឡាយនោះ មិនបានបរិបូណ៌ បុគ្គលទាំងឡាយនោះ ជាបុគ្គលថោកទាប ថោកថយ ទន់ទាប លាមក តម្រក់ ជាមនុស្សកំទេចកំទី ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលទាំងឡាយណា សរសើរធម៌ដទៃ អំពីធម៌នេះ បុគ្គលទាំងឡាយនោះ ឈ្មោះថា អ្នកភ្លាត់ចាកសេចក្តីបរិសុទ្ធិ ជាបុគ្គលមិនពេញលេញ ។

[៤៦៥] ពាក្យថា បុគ្គលអ្នកមានលទ្ធិ ដូចជាកំពង់ទាំងឡាយ តែងពោលដោយច្រើន យ៉ាងនេះឯង អធិប្បាយថា ទិដ្ឋិ លោកហៅថា កំពង់ ។ ពួកបុគ្គលអ្នកលុះក្នុងទិដ្ឋិ លោកហៅថា បុគ្គលអ្នកមានលទ្ធិដូចជាកំពង់ ។ បុគ្គលអ្នកប្រកប ដោយទិដ្ឋិច្រើន តែងពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយ នូវទិដ្ឋិដ៏ច្រើនទាំងឡាយ ដោយទិដ្ឋិមានប្រមាណច្រើន ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលអ្នកមានលទ្ធិដូចជាកំពង់ទាំងឡាយ តែងពោលដោយច្រើនយ៉ាងនេះខ្លះ ។

(២៦៦) សន្ទិដ្ឋិរាគេន ហិ ត្យាភិរត្តាតិ សកាយទិដ្ឋិយា(១) រាគេន រត្តា អភិរត្តាតិ សន្ទិដ្ឋិរាគេន ហិ ត្យាភិរត្តា ។ តេនាហ ភគវា

អញ្ញំ ឥតោ យាភិវទន្តិ ធម្មំ
អបរទ្ធា សុទ្ធិមកេវលី តេ
ឯវម្បិ តិត្ថ្យា បុថុសោ វទន្តិ
សន្ទិដ្ឋិរាគេន ហិ ត្យាភិរត្តាតិ ។

(២៦៧) ឥធេវ សុទ្ធឹ ឥតិ វាទយន្តិ
នាញ្ញេសុ ធម្មេសុ វិសុទ្ធិមាហុ
ឯវម្បិ តិត្ថ្យា បុថុសោ និវិដ្ឋា
សកាយនេ តត្ថ ទឡ្ហំ វទានា ។

---

១ ឱ. ម. ឯត្ថន្តរេ ទិដ្ឋីតិ ទិស្សតិ ។

(២៦៦) ពាក្យថា ព្រោះថា បុគ្គលទាំងឡាយនោះ ត្រេកអរ ក្រៃលែង ដោយសេចក្តីត្រេកអរ នឹងទិដ្ឋិរបស់ខ្លួន គឺ (បុគ្គលនោះ) ត្រេកអរ ត្រេកអរក្រៃលែង ដោយសេចក្តីត្រេកអរ នឹងទិដ្ឋិរបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះថា បុគ្គលទាំងឡាយនោះ ត្រេកអរក្រៃលែង ដោយសេចក្តីត្រេកអរ នឹងទិដ្ឋិរបស់ខ្លួន ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

បុគ្គលទាំងឡាយ ណា សរសើរធម៌ដទៃ អំពីធម៌នេះ
បុគ្គលទាំងឡាយនោះ ឈ្មោះថា អ្នកឃ្លាត ចាកសេចក្តីបរិសុទ្ធិ
ជាបុគ្គលមិនពេញលេញ បុគ្គលអ្នកមានលទ្ធិ ដូចជាកំពង់
ទាំងឡាយ តែងពោលដោយច្រើន យ៉ាងនេះឯង ព្រោះថា
បុគ្គលទាំងឡាយនោះ ត្រេកអរក្រៃលែង ដោយសេចក្តី
ត្រេកអរ នឹងទិដ្ឋិរបស់ខ្លួន ។

(២៦៧) បុគ្គលទាំងឡាយ រមែងពោលនូវសេចក្តីបរិសុទ្ធិក្នុង
ធម៌នេះឯងដូច្នេះ មិនពោលនូវសេចក្តីបរិសុទ្ធិ ក្នុងធម៌ទាំង
ឡាយឯទៀតទេ ពួកបុគ្គលអ្នកមានលទ្ធិដូចជាកំពង់ តាំង
នៅស៊ប់ក្នុងទិដ្ឋិដ៏ច្រើន យ៉ាងនេះឯង ប្រកាន់មាំ ក្នុងសកា-
យនៈ (ផ្លូវរបស់ខ្លួន) នោះ ។

[២៦៨] ឥធេវ សុទ្ធឹ ឥតិ វាទយន្តីតិ ឥធ សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥធ សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ អសស្សតោ លោកោ ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥធ សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ ឥធេវ សុទ្ធឹ ឥតិ វាទយន្តិ ។

[២៦៩] នាញ្ញេសុ ធម្មេសុ វិសុទ្ធិមាហូតិ អត្តនោ សត្ថារំ ធម្មក្ខានំ គណំ ទិដ្ឋឹ បដិបទំ មគ្គំ ឋបេត្វា សព្វេ បរវាទេ ខិបន្តិ ឧក្ខិបន្តិ បរិក្ខិបន្តិ សោ សត្ថា

## ចូឡវិយូហសុត្តនិទ្ទេស ទី ១២

(២៦៨) ពាក្យថា បុគ្គលទាំងឡាយ រមែងពោលនូវសេចក្ដីបរិសុទ្ធិ ក្នុងធម៌នេះឯងដូច្នេះ សេចក្ដីថា បុគ្គលទាំងឡាយ តែងពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយ នូវការស្អាត ស្អាតវិសេស ស្អាតដោយជុំវិញ ការរួច រួចស្រឡះ រួចដោយជុំវិញ ក្នុងធម៌របស់ខ្លួននេះ តែងពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយ នូវការស្អាត ស្អាតវិសេស ស្អាតដោយជុំវិញ ការរួច រួចស្រឡះ រួចដោយជុំវិញ ក្នុងធម៌នេះថា លោកទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ តែងពោល ថ្លែង ពណ៌នា ពន្យល់ អធិប្បាយ នូវការស្អាត ស្អាតវិសេស ស្អាតដោយជុំវិញ ការរួច រួចស្រឡះ រួចដោយជុំវិញ ក្នុងធម៌នេះថា លោកមិនទៀង ។បេ។ សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះ ជាពាក្យពិត ពាក្យដទៃជាមោឃៈ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលទាំងឡាយ រមែងពោលនូវសេចក្ដីបរិសុទ្ធិ ក្នុងធម៌នេះឯងដូច្នេះ ។

(២៦៩) ពាក្យថា មិនពោលនូវសេចក្ដីបរិសុទ្ធិ ក្នុងធម៌ទាំងឡាយឯទៀតទេ សេចក្ដីថា លើកទុកនូវសាស្ដា នូវធម៌ដែលសាស្ដាប្រាប់ នូវគណៈ នូវទិដ្ឋិ នូវបដិបទា នូវមគ្គ របស់ខ្លួនចេញ ហើយបោះបោល បោះបង់ បដិសេធ នូវវាទៈ របស់ជនដទៃ ទាំងអស់

ន សព្វញ្ញូ ធម្មោ ន ស្វាក្ខាតោ គណោ ន សុប្ប-ដិបន្នោ ទិដ្ឋិ ន ភទ្ទិកា បដិបទា ន សុប្បញ្ញត្តា មគ្គោ ន និយ្យានិកោ នេត្ថ សុទ្ធិ វា វិសុទ្ធិ វា បរិសុទ្ធិ វា មុត្តិ វា វិមុត្តិ វា បរិមុត្តិ វា នេត្ថ សុជ្ឈន្តិ វា វិសុជ្ឈន្តិ វា បរិសុជ្ឈន្តិ វា មុច្ចន្តិ វា វិមុច្ចន្តិ វា បរិមុច្ចន្តិ វា ហីនា និហីនា ឱមកា លាមកា ឆតុក្កា បរិត្តាតិ ឯវមាហំសុ ឯវំ កថេន្តិ ឯវំ ភណន្តិ ឯវំ ទីប-យន្តិ ឯវំ វោហរន្តីតិ នាញ្ញេសុ ធម្មេសុ វិសុទ្ធិមាហុ ។

(៨៧០) ឯវម្បិ តិត្ថ្យា បុថុសោ និវិដ្ឋាតិ តិត្ថំ វុច្ចតិ ទិដ្ឋិគតំ ។ តិត្ថ្យា វុច្ចន្តិ ទិដ្ឋិគតិកា ។ បុថុទិដ្ឋិយោ បុថុទិដ្ឋិគតេសុ និវិដ្ឋា បតិដ្ឋិតា អល្លីនា ឧបគតា អជ្ឈោសិតា អធិមុត្តាតិ ឯវម្បិ តិត្ថ្យា បុថុសោ និវិដ្ឋា ។

គឺពោលហើយយ៉ាងនេះ ថ្លែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ ពន្យល់យ៉ាងនេះ អធិប្បាយយ៉ាងនេះថា សាស្តានោះមិនមែនជាសព្វញ្ញូទេ ធម៌មិនមែនសាស្តាសំដែងល្អទេ គណៈមិនមែនប្រតិបត្តិត្រូវទេ ទិដ្ឋិមិនចំរើនទេ បដិបទា មិនមែនសាស្តាបញ្ញត្តល្អទេ មគ្គមិនមែនជាផ្លូវស្រោចស្រង់សត្វទេ ការស្អាតក្តី ការស្អាតវិសេសក្តី ការស្អាតដោយជុំវិញក្តី ការរួចក្តី ការរួចស្រឡះក្តី ការរួចដោយជុំវិញក្តី មិនមានក្នុងលទ្ធិនេះទេ ជនទាំងឡាយ ស្អាតក្តី ស្អាតវិសេសក្តី ស្អាតដោយជុំវិញក្តី រួចក្តី រួចវិសេសក្តី រួចដោយជុំវិញក្តី ក្នុងលទ្ធិនេះមិនមានទេ ពួកជននេះជាអ្នកថោកទាប ថោកថយ ទន់ទាប លាមក គម្រក់ អាប់ឱន ហេតុនោះ (ទ្រង់ត្រាស់ថា) មិនពោលនូវសេចក្តីបរិសុទ្ធិ ក្នុងធម៌ទាំងឡាយឯទៀតទេ ។

(៤៧០) ពាក្យថា ពួកបុគ្គល អ្នកមានលទ្ធិដូចជាកំពង់ តាំងស៊ប់ ក្នុងទិដ្ឋិដ៏ច្រើន យ៉ាងនេះឯង អធិប្បាយថា ទិដ្ឋិ លោកហៅថា កំពង់ ។ ពួកបុគ្គលអ្នកលុះក្នុងទិដ្ឋិ លោកហៅថា អ្នកមានលទ្ធិដូចជាកំពង់ ។ (ពួកបុគ្គលនោះ) តាំងនៅស៊ប់ តាំងនៅមាំ ជាប់ ដល់ស៊ប់ ជក់ចិត្ត ចុះចិត្តស៊ប់ ក្នុងទិដ្ឋិដ៏ក្រាស់ទាំងឡាយ ព្រោះទិដ្ឋិដ៏ក្រាស់ ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកបុគ្គលអ្នកមានលទ្ធិដូចជាកំពង់ តាំងនៅស៊ប់ ក្នុងទិដ្ឋិដ៏ច្រើន យ៉ាងនេឯង ។

ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ

(២៧១) សកាយនេ តត្ថ ទឡ្ហំ វទានាតិ ធម្មោ សកាយនំ ទិដ្ឋិ សកាយនំ បដិបទា សកាយនំ មគ្គោ សកាយនំ ។ សកាយនេ ទឡ្ហវាទា ថិរវាទា ពលិកវាទា អវដ្ឋិតវាទាតិ សកាយនេ តត្ថ ទឡ្ហំ វទានា ។ តេនាហ ភគវា

ឥធេវ សុទ្ធឹ ឥតិ វាទយន្តិ
នាញ្ញេសុ ធម្មេសុ វិសុទ្ធិមាហុ
ឯវម្បិ តិត្ថ្យា បុថុសោ និវិដ្ឋា
សកាយនេ តត្ថ ទឡ្ហំ វទានាតិ ។

(២៧២) សកាយនេ ចាបិ ទឡ្ហំ វទានោ
កមេត្ថ(១) ពាលោតិ បរំ ទហេយ្យ
សយមេវ សោ មេធគំ អាវហេយ្យ
បរំ វទំ ពាលមសុទ្ធិធម្មំ ។

(២៧៣) សកាយនេ ចាបិ ទឡ្ហំ វទានោតិ ធម្មោ សកាយនំ ទិដ្ឋិ សកាយនំ បដិបទា សកាយនំ មគ្គោ សកាយនំ ។ សកាយនេ ទឡ្ហវាទោ ថិរវាទោ

១ ម. កំ តត្ថ ។

(២៧១) ពាក្យថា ប្រកាន់មាំក្នុងសកាយនៈនោះ គឺ ធម៌ឈ្មោះថាសកាយនៈ ទិដ្ឋិឈ្មោះថាសកាយនៈ បដិបទាឈ្មោះថាសកាយនៈ មគ្គឈ្មោះថាសកាយនៈ ។ ជនទាំងឡាយ មានវាទៈមាំមួន មានវាទៈរឹងត្អឹង មានវាទៈដ៏មានកំឡាំង មានវាទៈខ្ជាប់ខ្ជួន ក្នុងសកាយនៈ ហេតុនោះ (ទ្រង់ត្រាស់ថា) ប្រកាន់មាំក្នុងសកាយនៈនោះ ។ ហេតុនោះព្រះមានព្រះភាគ ត្រាស់ថា

បុគ្គលទាំងឡាយរមែងពោលថា សេចក្តីបរិសុទ្ធិក្នុងធម៌នេះ
ឯង មិនពោលនូវសេចក្តីបរិសុទ្ធក្នុងធម៌ទាំងឡាយឯទៀត
ទេ ពួកបុគ្គលអ្នកមានលទ្ធិដូចជាកំពង់ តាំងនៅស៊ប់ក្នុង
ទិដ្ឋិដ៏ច្រើន យ៉ាងនេះឯង ប្រកាន់មាំក្នុងសកាយនៈនោះ ។
(២៧២) មួយទៀត បុគ្គលប្រកាន់មាំក្នុងសកាយនៈ តែងយល់
នូវបុគ្គលដទៃណាមួយ ថាជាបុគ្គលពាល ក្នុងសកាយនៈនុ៎ះ
បុគ្គលនោះ កាលពោលនូវបុគ្គលដទៃថាពាល ថាមានធម៌
មិនបរិសុទ្ធ តែងនាំមកនូវជម្លោះខ្លួនឯង ។

(២៧៣) ពាក្យថា មួយទៀត បុគ្គលប្រកាន់មាំ ក្នុងសកាយនៈ គឺ ធម៌ឈ្មោះថាសកាយនៈ ទិដ្ឋិឈ្មោះថាសកាយនៈ បដិបទាឈ្មោះថាសកា-យនៈ មគ្គឈ្មោះថាសកាយនៈ ។ បុគ្គលមានវាទៈមាំមួន មានវាទៈរឹងត្អឹង

ពលិកភាគោ អវដ្ឋិតភាគោតិ សកាយនេ វាបិ ទឡ្ហំ វទានោ ។

[២៧៤] កមេត្ថ ពាលោតិ បរំ ទហេយ្យាតិ ឃត្ថាតិ សកាយ ទិដ្ឋិយា សកាយ ខន្តិយា សកាយ រុចិយា សកាយ លទ្ធិយា បរំ ពាលតោ ហីនតោ និហីនតោ ឱមកតោ លាមកតោ ជតុក្កតោ បរិត្តតោ កំ ទហេយ្យ កំ បស្សេយ្យ កំ ទក្ខេយ្យ កំ ឱលោកេយ្យ កំ និជ្ឈាយេយ្យ កំ ឧបបរិក្ខេយ្យាតិ កមេត្ថ ពាលោតិ បរំ ទហេយ្យ ។

[២៧៥] សយមេវ សោ មេធគំ អាវហេយ្យ បរំ វទំ ពាលមសុទ្ធិធម្មន្តិ បរោ ពាលោ ហីនោ និហីនោ ឱមកោ លាមកោ ជតុក្កោ បរិត្តោ អសុទ្ធិធម្មោ អវិសុទ្ធិធម្មោ

មានវាទដ៏មានកំឡាំង មានវាទៈខ្ជាប់ខ្ជួន ក្នុងសកាយនៈ ហេតុនោះ (ទ្រង់ត្រាស់ថា) មួយទៀត បុគ្គលប្រកាន់មាំ ក្នុងសកាយនៈ ។

(២៧៤) ពាក្យថា តែងយល់ នូវបុគ្គលដទៃណាមួយ ថាជា បុគ្គលពាល ក្នុងសកាយនៈនុ៎ះ ត្រង់ពាក្យថា នុ៎ះ គឺតែងយល់ អ្នកណា ឃើញអ្នកណា មើលអ្នកណា ក្រឡេកឃើញអ្នកណា សំឡឹងឃើញអ្នកណា រំពឹងឃើញអ្នកណា ដទៃ ថាជាបុគ្គលពាល ថោកទាប ថោកថយ ទន់ទាប លាមក គម្រក់ អាប់ឱន តាម ទិដ្ឋិរបស់ខ្លួន តាមសេចក្ដីគួរ របស់ខ្លួន តាមសេចក្ដីគាប់ចិត្តរបស់ខ្លួន តាមលទ្ធិ របស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) តែងយល់នូវ បុគ្គលដទៃណាមួយ ថាជាបុគ្គលពាល ក្នុងសកាយនៈនុ៎ះ ។

(២៧៥) ពាក្យថា បុគ្គលនោះ កាលពោលនូវបុគ្គលដទៃ ថាជាបុគ្គល ពាល ថាមានធម៌មិនបរិសុទ្ធិ តែងនាំមកនូវជម្លោះខ្លួនឯង សេចក្ដីថា បុគ្គល កាលពោលយ៉ាងនេះ ថ្លែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ ពន្យល់យ៉ាងនេះ អធិប្បាយយ៉ាងនេះថា បុគ្គលនេះអាប់ឱន ពាល ថោកទាប ថោកថយ ទន់ ទាប លាមក គម្រក់ កំទេចកំទី មានធម៌មិនស្អាត មានធម៌មិនស្អាតស្អំ

ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ

អបរិសុទ្ធិធម្មោ អវោទាតធម្មោតិ ឯវំ វទន្តោ ឯវំ កថេន្តោ ឯវំ ភណន្តោ ឯវំ ទីបយន្តោ ឯវំ វោហរន្តោ សយមេវ កលហំ ភណ្ឌនំ វិគ្គហំ វិវាទំ មេធគំ អាវហេយ្យ សមាវហេយ្យ អាហរេយ្យ សមាហរេយ្យ អាកឌ្ឍេយ្យ សមាកឌ្ឍេយ្យ គណ្ហេយ្យ បរាមសេយ្យ អភិនិវិសេយ្យាតិ សយមេវ សោ មេធគំ អាវហេយ្យ បរំ វទំ ពាលមសុទ្ធិធម្មំ ។ តេនាហ ភគវា

សកាយនេ វាបិ ទឡ្ហំ វទានោ
កមេត្ថ ពាលោតិ បរំ ទហេយ្យ
សយមេវ សោ មេធគំ អាវហេយ្យ
បរំ វទំ ពាលមសុទ្ធិធម្មន្តិ ។

(៤៧៦) វិនិច្ឆយេ ឋត្វា សយំ បមាយ
ឧទ្ធំ សោ លោកស្មឹ វិវាទមេតិ
ហិត្វាន សព្វានិ វិនិច្ឆយានិ
ន មេធគំ កុព្វតេ[១] ជន្តុ លោកេ ។

---

១ ម. កុព្វតិ ។

## ចូឡវិយូហសុត្តនិទ្ទេស ទី ១២

មានធម៌មិនបរិសុទ្ធ មានធម៌មិនផូរផង់ គប្បីនាំមក នាំមកព្រម ប្រមូលមក ប្រមូលមកព្រម ទាញមក ទាញមកព្រម ប្រកាន់ បបោសអង្អែល អាស្រ័យ នូវជម្លោះ នូវសេចក្ដីប្រកួតប្រកាន់ នូវសេចក្ដីប្រកាន់ខុស នូវជំលោះ នូវការប្រណាំងប្រជែង ដោយខ្លួនឯង ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ កាលពោលនូវបុគ្គលដទៃ ថាជាបុគ្គលពាល ថាមានធម៌មិនបរិសុទ្ធ តែងនាំមកនូវជម្លោះខ្លួនឯង ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

មួយទៀត បុគ្គលប្រកាន់មាំ ក្នុងសកាយនៈ តែងយល់
នូវបុគ្គលដទៃណាមួយ ថាជាបុគ្គលពាល ក្នុងសកាយនៈ
នុះ បុគ្គលនោះ កាលពោលនូវបុគ្គលដទៃ ថាជាបុគ្គលពាល
ថាមានធម៌មិនបរិសុទ្ធ តែងនាំមកនូវជម្លោះខ្លួនឯង ។

(២៧៦) ជននោះតាំងនៅក្នុងវិនិច្ឆ័យ ប្រមាណយកដោយខ្លួន
ឯងហើយ រមែងដល់ នូវការទាស់ទែង ក្នុងលោកតទៅ
ជនលះបង់ នូវវិនិច្ឆ័យទាំងពួង រមែងមិនធ្វើ នូវជម្លោះ
ក្នុងលោក ។

(២៧៧) វិនិច្ឆយេ ឋត្វា សយំ បមាយាតិ វិនិច្ឆយា វុច្ចន្តិ ទ្វាសដ្ឋិ ទិដ្ឋិគតានិ(១) វិនិច្ឆិតទិដ្ឋិយា ឋត្វា បតិដ្ឋហិត្វា គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វាតិ វិនិច្ឆយេ ឋត្វា ។ សយំ បមាយាតិ សយំ បមាយ បមិនិត្វា អយំ សត្ថា សព្ពញ្ញូតិ សយំ បមាយ បមិនិត្វា អយំ ធម្មោ ស្វាក្ខាតោ អយំ គណោ សុប្បដិបន្នោ អយំ ទិដ្ឋិ ភទ្ទិកា អយំ បដិបទា សុបញ្ញត្តា អយំ មគ្គោ និយ្យានិកោតិ សយំ បមាយ បមិនិត្វានិ វិនិច្ឆយេ ឋត្វា សយំ បមាយ ។

(២៧៨) ឧទ្ធំ សោ(២) លោកស្មឹ វិវាទមេតីតិ ឧទ្ធំ(៣) វុច្ចតិ អនាគតំ ។ អត្តនោ វាទំ ឧទ្ធំ ឋបេត្វា សយមេវ កលហំ គណ្ហាតិ វិគ្គហំ វិវាទំ មេធគំ ឯតិ ឧបេតិ ឧបគច្ឆតិ គណ្ហាតិ បរាមសតិ អភិនិវិសតីតិ ឯវម្បិ ឧទ្ធំ សោ លោកស្មឹ វិវាទមេតិ ។

---

១ ឱ ឯត្ថន្តរេ វិនិច្ឆយេតិ ទិស្សតិ ។ ២ ម. យេ. ។ ៣ ឋ. ឧទ្ធំ សោ ។

[២៧៧] ពាក្យថា ជនតាំងនៅក្នុងវិនិច្ឆ័យ ប្រមាណយកដោយខ្លួនឯងហើយ សេចក្តីថា ទិដ្ឋិ ៦២ លោកហៅថា វិនិច្ឆ័យ ជនតាំងនៅ តាំងនៅស៊ប់ ប្រកាន់ បរាមាសអង្អែល អាស្រ័យ ក្នុងទិដ្ឋិដែលខ្លួនសម្រេចហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ជនតាំងនៅក្នុងវិនិច្ឆ័យ ។ ពាក្យថា ប្រមាណយកដោយខ្លួនឯងហើយ គឺប្រមាណយក ស្មានយក ដោយខ្លួនឯង គឺប្រមាណយក ស្មានយក ដោយខ្លួនឯងថា សាស្តានេះ ជាសព្វញ្ញូ ប្រមាណយក ស្មានយក ដោយខ្លួនឯងថា ធម៌នេះ ដែលសាស្តាសំដែងល្អហើយ ពួកនេះប្រតិបត្តិត្រូវ ទិដ្ឋិនេះចំរើន បដិបទានេះ សាស្តាបញ្ញត្តល្អហើយ មគ្គនេះ ជាទីស្រោចស្រង់សត្វ ហេតុនោះ (ទ្រង់ត្រាស់ថា) ជនតាំងនៅក្នុងវិនិច្ឆ័យ ប្រមាណយកដោយខ្លួនឯងហើយ ។

[២៧៨] ពាក្យថា ជននោះ រមែងដល់នូវការទាស់ទែង ក្នុងលោកតទៅ សេចក្តីថា អនាគត លោកហៅថា តទៅ ។ ជនតាំងទុកនូវវាទៈរបស់ខ្លួនតទៅ ហើយដល់ ចូលដល់ ចូលទៅជិត កាន់យក បរាមាសអង្អែល អាស្រ័យ នូវជម្លោះ នូវការប្រកួតប្រកាន់ នូវការប្រកាន់ខុស នូវការទាស់ទែង នូវការប្រណាំងប្រជែង ដោយខ្លួនឯង ហេតុនោះ (ទ្រង់ត្រាស់ថា) ជននោះ រមែងដល់នូវការទាស់ទែង ក្នុងលោកតទៅ យ៉ាងនេះខ្លះ ។

អថវា អញ្ញេន ឧទ្ធំ វាទេន សទ្ធិំ កលហំ ករោតិ ភណ្ឌនំ ករោតិ វិគ្គហំ ករោតិ វិវាទំ ករោតិ មេធគំ ករោតិ ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ ។បេ។ និព្វេឋេហិ វា សចេ បហោសីតិ ឯវម្បិ ឧទ្ធំ សោ លោកស្មឹ វិវាទមេតិ ។

(២៧៩) ហិត្វាន សព្វានិ វិនិច្ឆយានីតិ វិនិច្ឆយា វុច្ចន្តិ ទ្វាសដ្ឋី ទិដ្ឋិគតានិ ។ សព្វា វិនិច្ឆិតទិដ្ឋិយោ ហិត្វា ចជិត្វា បរិច្ចជិត្វា ជហិត្វា បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវំគមេត្វាតិ ហិត្វាន សព្វានិ វិនិច្ឆយានិ ។

(២៨០) ន មេធគំ កុព្វតេ ជន្តុ លោកេតិ ន កលហំ ករោតិ ន ភណ្ឌនំ ករោតិ ន វិគ្គហំ ករោតិ ន វិវាទំ ករោតិ ន មេធគំ ករោតិ ។ វុត្តំ ហេតំ ភគវតា ឯវំ វិមុត្តចិត្តោ ខោ អគ្គិវេស្សន ភិក្ខុ ន កេនចិ សំវទតិ ន កេនចិ វិវទតិ យញ្ច លោកេ វុត្តំ តេន ច វោហរតិ អបរាមសន្តិ ។

មួយទៀត (បុគ្គលនោះ) តែងធ្វើជម្លោះ ធ្វើសេចក្តីប្រកួតប្រកាន់ ធ្វើសេចក្តីប្រកាន់ខុស ធ្វើការទាស់ទែង ធ្វើការប្រណាំងប្រជែង ជាមួយនឹងវាទៈនៃជនដទៃ តទៅ ថា អ្នកមិនចេះធម្មវិន័យនេះទេ ។ បេ ។ ឬបើអ្នកអាច ចូរអ្នកដោះស្រាយចុះ ហេតុនោះ (ទ្រង់ត្រាស់ថា) ជននោះរមែងដល់នូវការទាស់ទែង ក្នុងលោកតទៅ យ៉ាងនេះខ្លះ ។

(២៧៩) ពាក្យថា ជនលះបង់នូវវិនិច្ឆ័យទាំងពួង សេចក្តីថា ទិដ្ឋិ ៦២ លោកហៅថា វិនិច្ឆ័យ ។ ជនលះបង់ លះលែង លះចោល កំចាត់បង់ កំចាត់បង់ស្រឡះ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាពតទៅទៀត នូវទិដ្ឋិដែលខ្លួនវិនិច្ឆ័យទាំងអស់ ហេតុនោះ (ទ្រង់ត្រាស់ថា) ជនលះបង់នូវវិនិច្ឆ័យទាំងពួង ។

(២៨០) ពាក្យថា ជនរមែងមិនធ្វើជម្លោះក្នុងលោក សេចក្តីថា រមែងមិនធ្វើជម្លោះ មិនធ្វើសេចក្តីប្រកួតប្រកាន់ មិនធ្វើសេចក្តីប្រកាន់ខុស មិនធ្វើសេចក្តីទាស់ទែង មិនធ្វើនូវសេចក្តីប្រណាំងប្រជែង ។ សមដូចព្រះតម្រាស់នេះ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលអគ្គិវេស្សនៈ ភិក្ខុដែលមានចិត្តផុតស្រឡះ យ៉ាងនេះហើយ រមែងមិនពោលប្រកាន់ជាមួយបុគ្គលណាមួយ មិនជជែកជាមួយបុគ្គលណាមួយ និយាយតែពាក្យណា ដែលគេនិយាយក្នុងលោកនោះ តែមិនប្រកាន់ ។

ជន្តូតិ សត្តា នរោ មាណវោ បោសោ បុគ្គលោ ជីវោ ជាតុ ជន្តុ ឥន្ទគូ មនុជោ ។ លោកេតិ អបាយលោកេ មនុស្សលោកេ ទេវលោកេ ខន្ធ-លោកេ ធាតុលោកេ អាយតនលោកេតិ ន មេធគំ កុរុតេ ជន្តុ លោកេ ។ តេនាហ ភគវា

វិនិច្ឆយេ ឋត្វា សយំ បមាយ
ឧទ្ធំ សោ លោកស្មឹ វិវាទមេតិ
ហិត្វាន សព្វានិ វិនិច្ឆយានិ
ន មេធគំ កុរុតេ ជន្តុ លោកេតិ ។

ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ និដ្ឋិតោ ។

ពាក្យថា ជន បានដល់សត្វ នរៈ មាណព បុរស បុគ្គល ជនមានជីវិត ជនមានជាតិ ជនអ្នកកើត ជនទៅដោយឥន្ទ្រិយ ជនអ្នកកើតអំពីមនុស្ស ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ហេតុនោះ (ទ្រង់ត្រាស់ថា) ជនរមែងមិនធ្វើនូវជម្លោះ ក្នុងលោក ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ជននោះតាំងនៅក្នុងវិនិច្ឆ័យ ប្រមាណយកដោយខ្លួន
ឯងហើយ រមែងដល់នូវការទាស់ទែង ក្នុងលោកតទៅ
ជនលះបង់នូវវិនិច្ឆ័យទាំងពួង រមែងមិនធ្វើ នូវជម្លោះ
ក្នុងលោក ។

ចប់ ចូឡវិយូហសុត្តនិទ្ទេស ទី ១២ ។

# តេរសមោ មហាវិយូហសុត្តនិទ្ទេសោ

(២៨១) យេ កេចិមេ ទិដ្ឋិបរិព្វសានា
ឥទមេវ សច្ចន្តិ បវាទយន្តិ(១)
សព្វេវ តេ និន្ទមន្វានយន្តិ
អថោ បសំសម្បិ លភន្តិ តត្ថ ។

(២៨២) យេ កេចិមេ ទិដ្ឋិបរិព្វសានាតិ យេ កេចីតិ សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ បរិយាទាយវចនមេតំ(២) យេ កេចីតិ ។ ទិដ្ឋិបរិព្វសានាតិ សន្តេកេ សមណព្រាហ្មណា ទិដ្ឋិគតិកា តេ ទ្វាសដ្ឋិយា ទិដ្ឋិគតានំ អញ្ញតរញ្ញតរំ ទិដ្ឋិគតំ គហេត្វា ឧគ្គហេត្វា គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វា សកាយ សកាយ ទិដ្ឋិយា វសន្តិ សំវសន្តិ អាវសន្តិ បរិវសន្តិ ។ យថា អាគារិកា វា ឃរេសុ វសន្តិ សាបត្តិកា វា អាបត្តីសុ វសន្តិ សកិលេសា វា កិលេសេសុ វសន្តិ ឯវមេវ សន្តេកេ សមណព្រាហ្មណា ទិដ្ឋិគតិកា តេ ទ្វាសដ្ឋិយា ទិដ្ឋិគតានំ អញ្ញតរញ្ញតរំ ទិដ្ឋិគតំ គហេត្វា ឧគ្គហេត្វា គណ្ហិត្វា បរាមសិត្វា

---

១ ម. សច្ចន្តិ ច វាទយន្តិ ។ ២ ម. បរិយាទិយនវចនមេតំ ។

# មហាវិយូហសុត្តនិទ្ទេស ទី ១៣

(៤៨១) (ព្រះពុទ្ធនិម្មិតត្រាស់សួរថា) ពួកសមណព្រាហ្មណ៍ណាមួយត្រាំនៅក្នុងទិដ្ឋិ តែងសំដែងថា ពាក្យនេះឯង ជាពាក្យពិត តើសមណព្រាហ្មណ៍ទាំងអស់នោះ នឹងនាំមកនូវពាក្យនិន្ទាតែម្យ៉ាងឬ ឬក៏បានពាក្យសរសើរក្នុងហេតុនោះដែរ ។

(៤៨២) អធិប្បាយពាក្យថា ពួកសមណព្រាហ្មណ៍ណាមួយ ត្រាំនៅក្នុងទិដ្ឋិ ពាក្យថា ណាមួយ គឺ គ្រប់ទាំងអស់ សព្វទាំងមូល មិនសេសសល់ ឥតសេសសល់ ពាក្យថា ណាមួយ នេះជាពាក្យអស់រលីង ។ ពាក្យថា ត្រាំនៅក្នុងទិដ្ឋិ សេចក្តីថា មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកលុះក្នុងទិដ្ឋិ សមណព្រាហ្មណ៍ទាំងនោះ កាន់ ក្ដួប-កាន់ ប្រកាន់ ស្ទាបអង្អែល ប្រកាន់ស្អិត បណ្ដាទិដ្ឋិ ៦២ នូវទិដ្ឋិណាមួយ ហើយនៅ នៅរួម នៅទូទៅ នៅត្រាំ ក្នុងទិដ្ឋិរបស់ខ្លួន ៗ ។ ពួកជនអ្នកគ្រប់គ្រងផ្ទះក្ដី រមែងនៅក្នុងផ្ទះ ពួកភិក្ខុអ្នកត្រូវអាបត្តិក្ដី រមែងនៅក្នុងអាបត្តិ ពួកជនមានកិលេសក្ដី តែងនៅក្នុងកិលេស យ៉ាងណាមិញ មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកលុះក្នុងទិដ្ឋិ ក៏យ៉ាងនោះដែរ សមណព្រាហ្មណ៍ទាំងនោះ កាន់ ក្ដួបកាន់ ប្រកាន់ ស្ទាបអង្អែល

អភិនិវិសិត្វា សកាយ សកាយ ទិដ្ឋិយា វសន្តិ សំវសន្តិ អាវសន្តិ បរិវសន្តីតិ យេ កេចិមេ ទិដ្ឋិបរិព្វសានា ។

(២៨៣) ឥទមេវ សច្ចន្តិ បវទយន្តីតិ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ អសស្សតោ លោកោ ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ ឥទមេវ សច្ចន្តិ បវទយន្តិ ។

(២៨៤) សព្វេ តេ និន្ទមន្វានយន្តីតិ សព្វេ តេ សមណព្រាហ្មណា និន្ទមេវ អន្វេន្តិ គរហមេវ អន្វេន្តិ អកិត្តិមេវ អន្វេន្តិ សព្វេ និន្ទិតាយេវ ហោន្តិ គរហិតាយេវ ហោន្តិ អកិត្តិតាយេវ ហោន្តីតិ សព្វេ តេ និន្ទមន្វានយន្តិ ។

ប្រកាន់ស្អិត បណ្ដាទិដ្ឋិ ៦២ នូវទិដ្ឋិណាមួយ ហើយនៅ នៅរួម នៅទូទៅ នៅត្រាំ ក្នុងទិដ្ឋិរបស់ខ្លួន ៗ ។ ហេតុនោះ (ទ្រង់ត្រាស់សួរថា) ពួកសមណព្រាហ្មណ៍ណាមួយ ត្រាំនៅក្នុងទិដ្ឋិ ។

(២៨៣) ពាក្យថា តែងសំដែងថា ពាក្យនេះឯង ជាពាក្យពិត គ តែងពោល សំដែង ពណ៌នា បំភ្លឺ ថ្លែងថា លោកទៀង ពាក្យនេះឯងពិត ពាក្យដទៃជាមោឃៈ តែងពោល សំដែង ពណ៌នា បំភ្លឺ ថ្លែងថា លោកមិនទៀង ។បេ។ សត្វស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះឯងពិត ពាក្យដទៃជាមោឃៈ ហេតុនោះ (ទ្រង់ត្រាស់សួរថា) តែងសំដែងថា ពាក្យនេះឯងជាពាក្យពិត ។

(២៨៤) ពាក្យថា តើសមណព្រាហ្មណ៍ទាំងអស់នោះ នឹងនាំមកនូវពាក្យនិន្ទាតែម្យ៉ាងឬ សេចក្ដីថា តើសមណព្រាហ្មណ៍ទាំងអស់នោះ នឹងនាំមកនូវនិន្ទា នាំមកនូវពាក្យតិះដៀល នាំមកនូវការសរសើរតែម្យ៉ាង គឺសមណព្រាហ្មណ៍ទាំងអស់នោះ ជាអ្នកត្រូវគេនិន្ទា ត្រូវគេតិះដៀល ត្រូវគេមិនសរសើរតែម្យ៉ាងឬ ហេតុនោះ (ទ្រង់ត្រាស់សួរថា) តើសមណព្រាហ្មណ៍ទាំងអស់នោះ នឹងនាំមកនូវពាក្យនិន្ទាតែម្យ៉ាងឬ ។

(២៨៩) អតោ បសំសម្បិ លភន្តិ តត្ថាតិ តត្ថ សកាយ ទិដ្ឋិយា សកាយ ខន្តិយា សកាយ រុចិយា សកាយ លទ្ធិយា បសំសំ ថោមនំ កិត្តិំ វណ្ណហារិកំ លភន្តិ បដិលភន្តិ អធិគច្ឆន្តិ(១) វិន្ទន្តីតិ អតោ បសំសម្បិ លភន្តិ តត្ថ ។ តេនាហ សោ និម្មិតោ

យេ កេចិមេ ទិដ្ឋិបរិព្វសានា

ឥទមេវ សច្ចន្តិ បវាទយន្តិ

សព្វេវ តេ និន្ទមន្វានយន្តិ

អថោ បសំសម្បិ លភន្តិ តត្ថាតិ ។

(២៩០) អប្បំ ហិ ឯតំ ន អលំ សមាយ

ទុវេ វិវាទស្ស ផលានិ ព្រូមិ

ឯតម្បិ ទិស្វា ន វិវាទយេថ

ខេមាភិបស្សំ អវិវាទភុម្មំ ។

---

១ ម. ឧបគច្ឆន្តិ ។

(៤៨៥) ពាក្យថា ឬក៏បាននូវពាក្យសរសើរ ក្នុងហេតុនោះដែរ សេចក្តីថា ឬក៏បាន បានចំពោះ បានប្រាកដ តែងបាន នូវពាក្យសរសើរ ពាក្យស្ញើច កិត្តិសព្ទ ពាក្យនាំមកនូវសេចក្តីសរសើរ ក្នុងហេតុនោះ គឺ ក្នុងទិដ្ឋិរបស់ខ្លួន ក្នុងសេចក្តីគួររបស់ខ្លួន ក្នុងសេចក្តីពេញចិត្តរបស់ខ្លួន ក្នុងលទ្ធិរបស់ខ្លួននោះដែរ ហេតុនោះ (ទ្រង់ត្រាស់សួរថា) ឬក៏បាននូវពាក្យសរសើរ ក្នុងហេតុនោះដែរ ។ ហេតុនោះ ព្រះពុទ្ធនិម្មិត ត្រាស់សួរថា

ពួកសមណព្រាហ្មណ៍ណាមួយ ត្រាំនៅក្នុងទិដ្ឋិ តែងសំ-
ដែងថា ពាក្យនេះឯង ជាពាក្យពិត តើសមណព្រាហ្មណ៍
ទាំងអស់នោះ នឹងនាំមកនូវពាក្យនិន្ទាតែម្យ៉ាងឬ ឬក៏បាន
នូវពាក្យសរសើរ ក្នុងហេតុនោះដែរ ។

(៤៨៦) (ព្រះមានព្រះភាគត្រាស់ថា) ផលគឺសេចក្តីសរសើរ
+នុះ មានបន្តិចបន្តួច មិនអាចដើម្បីស្ងប់រម្ងាប់បានទេ តថាគត
ពោលនូវផលនៃវិវាទ ថាមាន ២ ប្រការ បុគ្គលកាលឃើញ
ទោសនេះ ហើយឃើញច្បាស់នូវព្រះនិព្វាន ជាភូមិមិន
មានវិវាទ ជាទីក្សេមក្សាន្ត រមែងមិនទាស់ទែងទេ ។

(២៨៧) អប្បំ ហិ ឯតំ ន អលំ សមាយាតិ អប្បំ ហិ ឯតន្តិ អប្បកំ ឯតំ ឱមកំ ឯតំ ថោកំ ឯតំ លាមកំ ឯតំ ជតុក្កំ ឯតំ បរិត្តកំ ឯតន្តិ អប្បំ ហិ ឯតំ ។ ន អលំ សមាយាតិ នាលំ រាគស្ស សមាយ ទោសស្ស សមាយ មោហស្ស សមាយ កោធស្ស ឧបនាហស្ស មក្ខស្ស បឡាសស្ស ឥស្សាយ មច្ឆរិយស្ស មាយាយ សាឋេយ្យស្ស ថម្ភស្ស សារម្ភស្ស មានស្ស អតិមានស្ស មទស្ស បមាទស្ស សព្វកិលេសានំ សព្វទុច្ចរិតានំ សព្វទរថានំ សព្វបរិឡាហានំ សព្វសន្តាបានំ សព្វាកុសលាភិសង្ខារានំ សមាយ ឧបសមាយ វូបសមាយ និព្វានាយ បដិនិស្សគ្គាយ បដិប្បស្សទ្ធិយាតិ អប្បំ ហិ ឯតំ ន អលំ សមាយ ។

(២៨៨) ទ្វេ វិវាទស្ស ផលានិ ព្រូមីតិ ទិដ្ឋិកលហស្ស ទិដ្ឋិភណ្ឌនស្ស ទិដ្ឋិវិគ្គហស្ស ទិដ្ឋិវិវាទស្ស ទិដ្ឋិមេធគស្ស ទ្វេ ផលានិ ហោន្តិ ជយបរាជយោ ហោតិ លាភាលាភោ ហោតិ យសាយសោ ហោតិ

(៤៨៧) អធិប្បាយពាក្យថា ផលគឺសេចក្តីសរសើរនុ៎ះ មានបន្តិចបន្តួច មិនអាចដើម្បីស្ងប់រម្ងាប់បានទេ ត្រង់ពាក្យថា ផលគឺសេចក្តីសរសើរនុ៎ះ មានបន្តិចបន្តួចទេ គឺផលនុ៎ះមានប្រមាណតិច ផលនុ៎ះអន់ថយ ផលនុ៎ះថោក ផលនុ៎ះលាមក ផលនុ៎ះអាក្រក់ ផលនុ៎ះស្តួចស្តើង ហេតុនោះ (ទ្រង់ត្រាស់ថា) ផលនុ៎ះមានបន្តិចបន្តួច ។ ពាក្យថា មិនអាចដើម្បីរម្ងាប់បានទេ គឺមិនអាចដើម្បីរម្ងាប់រាគៈ ដើម្បីរម្ងាប់ទោសៈ ដើម្បីរម្ងាប់មោហៈ ដើម្បីរម្ងាប់កោធៈ ដើម្បីរម្ងាប់ ដើម្បីស្ងប់ស្ងាត់ ដើម្បីលត់ ដើម្បីលះបង់ ដើម្បីគ្រប់សង្កត់ នូវឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង សេចក្តីអន្ទះអន្ទែងទាំងពួង អកុសលាភិសង្ខារទាំងពួង ហេតុនោះ (ទ្រង់ត្រាស់ថា) ផលគឺសេចក្តីសរសើរនុ៎ះ មានបន្តិចបន្តួច មិនអាចដើម្បីស្ងប់រម្ងាប់បានទេ ។

(៤៨៨) ពាក្យថា តថាគតពោលនូវផលនៃវិវាទ ថាមាន ២ ប្រការ គឺតថាគតពណ៌នា ប្រាប់ សំដែង បញ្ញត្ត ផ្តើម បើក ចែក ធ្វើឲ្យរាក់ ប្រកាសថា ជម្លោះព្រោះទិដ្ឋិ ការប្រកាន់ព្រោះទិដ្ឋិ ការទាស់ទែងព្រោះទិដ្ឋិ ការវិវាទព្រោះទិដ្ឋិ ការបែកខ្ញែកព្រោះទិដ្ឋិ រមែងមានផល ២ ប្រការ គឺការឈ្នះនិងការចាញ់ លាភនិងឥតលាភ យសនិងឥតយស

និន្ទាបសំសោ ហោតិ សុខទុក្ខំ ហោតិ សោមនស្សទោមនស្សំ ហោតិ ឥដ្ឋានិដ្ឋំ ហោតិ អនុនយប្បដិឃំ ហោតិ ឧគ្ឃាតិនិគ្ឃាតិ ហោតិ អនុរោធវិរោធោ ហោតិ ។ អថវា តំ កម្មំ និរយសំវត្តនិកំ តិរច្ឆានយោនិកសំវត្តនិកំ បេត្តិវិសយិកសំវត្តនិកន្តិ ព្រូមិ អាចិក្ខាមិ ទេសេមិ បញ្ញាបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានីករោមិ បកាសេមីតិ ទុវេ វិវាទស្ស ផលានិ ព្រូមិ ។

(២៨៩) ឯតម្បិ ទិស្វា ន វិវាទយេថាតិ ឯតម្បិ ទិស្វាតិ ឯតំ អាទីនវំ ទិស្វា បស្សិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា ទិដ្ឋិកលហេសុ ទិដ្ឋិភណ្ឌនេសុ ទិដ្ឋិវិគ្គហេសុ ទិដ្ឋិវិវាទេសុ ទិដ្ឋិមេធគេសូតិ ឯតម្បិ ទិស្វា ។ ន វិវាទយេថាតិ ន កលហំ ករេយ្យ ន ភណ្ឌនំ ករេយ្យ ន វិគ្គហំ ករេយ្យ ន វិវាទំ ករេយ្យ ន មេធគំ ករេយ្យ កលហភណ្ឌនវិគ្គហវិវាទមេធគំ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវង្គមេយ្យ កលហភណ្ឌនវិគ្គហវិវាទមេធគា អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ(១) វិប្បមុត្តោ

---

១ ឱ. បដិនិស្សដ្ឋោ ។ ម. និស្សដ្ឋោ ។

និន្ទានឹងសរសើរ សុខនឹងទុក្ខ សោមនស្សនឹងទោមនស្ស អារម្មណ៍ជាទីប្រាថ្នានឹងមិនជាទីប្រាថ្នា សេចក្តីអាណិតនឹងការថ្នាំងថ្នាក់ ធូរចិត្តនឹងតឹងចិត្ត ការត្រេកអរនឹងក្រេវក្រោធ ម្យ៉ាងទៀត អំពើនោះ ជាអំពើប្រព្រឹត្តទៅដើម្បីនរក ប្រព្រឹត្តទៅដើម្បីកំណើតសត្វតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីប្រេតវិស័យ ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតពោលនូវផលនៃវិវាទថាមាន ២ ប្រការ ។

(២៨៩) អធិប្បាយពាក្យថា បុគ្គលកាលឃើញទោសនេះហើយ រមែងមិនទាស់ទែងទេ ត្រង់ពាក្យថា ឃើញទោសនេះ គឺឃើញ ជួប ថ្លឹង ពិចារណា ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដ នូវទោស ក្នុងជម្លោះព្រោះទិដ្ឋិ ក្នុងការប្រកាន់ព្រោះទិដ្ឋិ ក្នុងការទាស់ទែងព្រោះទិដ្ឋិ ក្នុងការវិវាទព្រោះទិដ្ឋិ ក្នុងការបែកខ្ញែកព្រោះទិដ្ឋិនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ឃើញនូវទោសនេះ ។ ពាក្យថា រមែងមិនទាស់ទែងទេ គឺរមែងមិនធ្វើនូវជម្លោះ មិនធ្វើនូវការប្រកាន់ មិនធ្វើនូវការទាស់ទែង មិនធ្វើនូវការវិវាទ មិនធ្វើនូវការបែកខ្ញែក គឺលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ដល់នូវការមិនកើតមាននូវជម្លោះ នូវការប្រកាន់ នូវការទាស់ទែង នូវវិវាទ នឹងការបែកខ្ញែក ជាអ្នកឆ្ងាយ វៀរបង់ ជៀសវាង ឃ្លាតចេញ លោះចេញ រួចស្រឡះ

វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យាតិ ឯតម្បិ ទិស្វា ន វិវាទយេថ ។

(៤៩០) ខេមាភិបស្សំ អវិវាទភូមិន្តិ អវិវាទភូមឹ វុច្ចតិ អមតនិព្វានំ យោ សោ សព្វសង្ខារសមថោ សព្វូបធិប-ដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ ។ ឯតំ អវិវាទភូមឹ ខេមតោ តាណតោ លេណតោ សរណតោ អភយតោ អច្ចុតតោ អមតតោ និព្វានតោ បស្សន្តោ ទក្ខន្តោ ឱលោកេន្តោ និជ្ឈាយន្តោ ឧបបរិក្ខន្តោតិ ខេមាភិបស្សំ អវិវាទភូមឹ ។ តេនាហ ភគវា

អប្បំ ហិ ឯតំ ន អលំ សមាយ
ទុវេ វិវាទស្ស ផលានិ ព្រូមិ
ឯតម្បិ ទិស្វា ន វិវាទយេថ
ខេមាភិបស្សំ អវិវាទភូមិន្តិ ។

ប្រាសចេញ ចាកជម្លោះ ចាកការប្រកាន់ ចាកការទាស់ទែង ចាកវិវាទ និងការបែកខ្ញែក តែងនៅដោយចិត្តដែលប្រាសចាកដែនគឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលកាលឃើញទោសនេះហើយ រមែងមិនទាស់ទែងទេ ។

[៥៩០] ពាក្យថា ឃើញច្បាស់នូវព្រះនិព្វាន ជាភូមិមិនមានវិវាទ ជាទីក្សេមក្សាន្ត អធិប្បាយថា អមតនិព្វាន ហៅថា ភូមិមិនមានវិវាទបានខាង ការរម្ងាប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ទុក្ខ និព្វាន ។ បុគ្គលកាលឃើញប្រមេះ រមិលមើល សំឡឹងមើល ពិនិត្យមើល នូវភូមិមិនមានវិវាទនុ៎ះថាជាទីក្សេមក្សាន្ត ជាទីពំនាក់ ជាទីជ្រកកោន ជាទីរឭក ជាទីមិនមានភ័យ ជាទីទៀងទាត់ ជាទីមិនស្លាប់ ជាទីមិនមានកិលេសជាគ្រឿងចាក់ស្រេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ឃើញច្បាស់នូវព្រះនិព្វាន ជាភូមិមិនមានវិវាទ ជាទីក្សេមក្សាន្ត ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ផលគឺសេចក្តីសរសើរនុ៎ះ មានបន្តិចបន្តួច មិនអាចដើម្បីរម្ងាប់បានទេ តថាគតពោលនូវផលនៃវិវាទថាមាន២ប្រការ បុគ្គលកាលឃើញទោសនេះហើយ ឃើញច្បាស់នូវព្រះនិព្វាន ជាភូមិមិនមានវិវាទ ជាទីក្សេមក្សាន្ត រមែងមិនទាស់ទែងទេ ។

តេរសមោ មហាវិយូហសុត្តនិទ្ទេសោ

(២៩១) យា កាចិមា សម្មុតិយោ(១) បុថុជ្ជា
សព្វាវ ឯតា ន ឧបេតិ វិទ្វា(២)
អនូបយោ សោ ឧបយំ កិមេយ្យ
ទិដ្ឋេ សុតេ ខន្តិមកុព្វមានោ ។

(២៩២) យា កាចិមា សម្មុតិយោ បុថុជ្ជាតិ យា-កាចីតិ សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ បរិយាទាយវចនមេតំ យា កាចីតិ ។ សម្មុតិយោតិ សម្មុតិយោ វុច្ចន្តិ ទ្វាសដ្ឋី ទិដ្ឋិគតានិ(៣) ។ បុថុជ្ជាតិ បុថុជ្ជនេហិ ជនិតា វា តា សម្មុតិយោតិ បុថុជ្ជា ។ បុថុនានាជនេហិ ជនិតា វា តា សម្មុតិយោតិ បុថុជ្ជាតិ យា កាចិមា សម្មុតិយោ បុថុជ្ជា ។

(២៩៣) សព្វាវ ឯតា ន ឧបេតិ វិទ្វាតិ វិទ្វា វិជ្ជាគតោ ញាណី វិភាវី មេធាវី សព្វាវ ឯតា ទិដ្ឋិសម្មុតិយោ នេតិ ន ឧបេតិ ន ឧបគច្ឆតិ

---

១ ឱ. ម. សម្មុតិយោ ។ ២ ឱ. ម. វិទូ ។ ៣ ឱ ទិដ្ឋិគតានិ ទិដ្ឋិសម្មុតិយោ ។

(២៩១) សម្មតិទាំងឡាយណាមួយ ដែលកើតអំពីបុថុជ្ជន អ្នកប្រាជ្ញរមែងមិនប្រកាន់នូវសម្មតិទាំងអស់នុ៎ះទេ (ព្រោះ) លោកមិនមានធម៌ជាគ្រឿងប្រកាន់ មិនធ្វើសេចក្ដីចូលចិត្ត ក្នុងអារម្មណ៍ដែលខ្លួនឃើញហើយ ឮហើយទេ ធ្វើម្ដេច នឹងដល់នូវធម៌ជាគ្រឿងប្រកាន់ ។

(២៩២) អធិប្បាយពាក្យថា សម្មតិទាំងឡាយណាមួយ ដែលកើតអំពីបុថុជ្ជន ត្រង់ពាក្យថា ណាមួយ គឺ គ្រប់ទាំងអស់ សព្វទាំងមូល មិនសេសសល់ ឥតសេសសល់ ពាក្យថា ណាមួយ នេះជាពាក្យអស់លើង ។ ពាក្យថា សម្មតិទាំងឡាយ គឺ ទិដ្ឋិ ៦២ លោកហៅថា សម្មតិទាំងឡាយ ។ ពាក្យថា កើតអំពីបុថុជ្ជន គឺសម្មតិទាំងនោះកើតអំពីបុថុជ្ជនទាំងឡាយ ហេតុនោះ ទើបឈ្មោះថា កើតអំពីបុថុជ្ជន ។ ឬថា សម្មតិទាំងនោះ កើតហើយអំពីជនផ្សេង ៗ ដ៏ច្រើន ហេតុនោះ ទើបឈ្មោះថា កើតអំពីបុថុជ្ជន ហេតុនោះ (ទ្រង់ត្រាស់ថា) សម្មតិទាំងឡាយណាមួយ កើតអំពីបុថុជ្ជន ។

(២៩៣) ពាក្យថា អ្នកប្រាជ្ញរមែងមិនប្រកាន់នូវសម្មតិទាំងអស់នុ៎ះទេ គឺអ្នកប្រាជ្ញជាអ្នកដល់នូវវិជ្ជា មានញាណ មានប្រាជ្ញាភ្លឺច្បាស់ មានប្រាជ្ញាជាគ្រឿងកំចាត់កិលេស មិនដល់ មិនចូលទៅជិត មិនចូលទៅរក

ន តណ្ហាតិ ន បរាមសតិ នាភិនិវិសតីតិ សព្វាវ ឯតា ន ឧបេតិ វិទ្វា ។

(២៩៨) អនូបយោ សោ ឧបយំ កិមេយ្យាតិ ឧប-យោតិ ទ្វេ ឧបយា តណ្ហូបយោ ច ទិដ្ឋូបយោ ច ។បេ។ អយំ តណ្ហូបយោ ។បេ។ អយំ ទិដ្ឋូបយោ ។ តស្ស តណ្ហូបយោ បហីនោ ទិដ្ឋូបយោ បដិនិស្សដ្ឋោ តណ្ហូប-យស្ស បហីនត្តា ទិដ្ឋូបយស្ស បដិនិស្សដ្ឋត្តា អនុបយោ បុគ្គលោ កឹ រូបំ ឧបេយ្យ ឧបគច្ឆេយ្យ គណ្ហេយ្យ បរាមសេយ្យ អភិនិវិសេយ្យ អត្តា មេតិ ។ កឹ វេទនំ កឹ សញ្ញំ កឹ សង្ខារេ កឹ វិញ្ញាណំ កឹ គតឹ កឹ ឧបបត្តឹ កឹ បដិសន្ធឹ កឹ ភវំ កឹ សំសារំ កឹ វដ្ដំ

មិនប្រកាន់ មិនស្ទាបអង្អែល មិនប្រកាន់ស្អិត នូវសម្មតិគឺទិដ្ឋិទាំងអស់នុ៎ះទេ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកប្រាជ្ញរមែងមិនប្រកាន់ នូវសម្មតិទាំងអស់នុ៎ះទេ ។

(២៩៤) អធិប្បាយពាក្យថា លោកមិនមានធម៌ជាគ្រឿងប្រកាន់ ធ្វើម្ដេចនឹងដល់នូវធម៌ជាគ្រឿងប្រកាន់ ត្រង់ពាក្យថា ធម៌ជាគ្រឿងប្រកាន់ បានដល់ ធម៌ជាគ្រឿងប្រកាន់ ២ យ៉ាង គឺ ធម៌ជាគ្រឿងប្រកាន់គឺតណ្ហា ១ ធម៌ជាគ្រឿងប្រកាន់គឺទិដ្ឋិ ១ ។ បេ ។ នេះធម៌ជាគ្រឿងប្រកាន់គឺតណ្ហា ។ បេ ។ នេះធម៌ជាគ្រឿងប្រកាន់គឺទិដ្ឋិ ។ បុគ្គលនោះ លះបង់ធម៌ជាគ្រឿងប្រកាន់គឺតណ្ហា រលាស់ចោលធម៌ជាគ្រឿងប្រកាន់គឺទិដ្ឋិ បុគ្គលមិនមានធម៌ជាគ្រឿងប្រកាន់ ព្រោះលះបង់ធម៌ជាគ្រឿងប្រកាន់គឺតណ្ហា ព្រោះរលាស់ចោលធម៌ជាគ្រឿប្រកាន់គឺទិដ្ឋិ គប្បីចូលទៅជិត ចូលទៅរក ប្រកាន់ ស្ទាបអង្អែល ប្រកាន់ស្អិត នូវរូបថាជាខ្លួនរបស់អញដូចម្ដេចកើត ។ គប្បីចូលទៅជិត ចូលទៅរក ប្រកាន់ ស្ទាបអង្អែលប្រកាន់ស្អិត នូវវេទនាដូចម្ដេចកើត នូវសញ្ញាដូចម្ដេចកើត នូវសង្ខារដូចម្ដេចកើត នូវវិញ្ញាណដូចម្ដេចកើត នូវគតិដូចម្ដេចកើត នូវឧបបត្តិដូចម្ដេចកើត នូវបដិសន្ធិដូចម្ដេចកើត នូវភពដូចម្ដេចកើត នូវសង្សារដូចម្ដេចកើត នូវវដ្ដៈដូចម្ដេចកើត

ឧបេយ្យ ឧបគច្ឆេយ្យ គណ្ហេយ្យ បរាមសេយ្យ អភិនិ-
វិសេយ្យាតិ អនូបយោ សោ ឧបយំ កិមេយ្យ ។

(២៩៨) ទិដ្ឋេ សុតេ ខន្តិមកុព្វមានោតិ ទិដ្ឋេ វា ទិដ្ឋសុទ្ធិយា វា សុតេ វា សុតសុទ្ធិយា វា មុតេ វា មុតសុទ្ធិយា វា ខន្តឹ អកុព្វមានោ ឆន្ទំ អកុព្វមានោ បេមំ អកុព្វមានោ រាគំ អកុព្វមានោ អជនយមានោ អសញ្ជនយមានោ អនិព្វត្តយមានោ នាភិនិព្វត្តយមានោតិ ទិដ្ឋេ សុតេ ខន្តិមកុព្វមានោ ។ តេនាហ ភគវា

យាកាចិមា សម្មុតិយោ បុថុជ្ជា
សព្វាវ ឯតា ន ឧបេតិ វិទ្វា
អនូបយោ សោ ឧបយំ កិមេយ្យ
ទិដ្ឋេ សុតេ ខន្តិមកុព្វមានោតិ ។

ហេតុនោះ (ទ្រង់ត្រាស់ថា) លោកមិនមានធម៌ជាគ្រឿងប្រកាន់ ធ្វើម្តេចនឹងដល់នូវធម៌ជាគ្រឿងប្រកាន់ ។

(៤៩៥) ពាក្យថា មិនធ្វើនូវសេចក្តីចូលចិត្ត ក្នុងអារម្មណ៍ដែលខ្លួនឃើញហើយ ឮហើយទេ គឺមិនធ្វើសេចក្តីចូលចិត្ត មិនធ្វើសេចក្តីពេញចិត្ត មិនធ្វើសេចក្តីស្រឡាញ់ មិនធ្វើ មិនឲ្យកើត មិនឲ្យកើតព្រម មិនឲ្យលូតលាស់ មិនឲ្យផុះផុលឡើង នូវតម្រេកក្នុងអារម្មណ៍ដែលឃើញ ឬក្នុងសេចក្តីបរិសុទ្ធិព្រោះឃើញ ក្នុងអារម្មណ៍ដែលឮ ឬក្នុងសេចក្តីបរិសុទ្ធិព្រោះឮ ក្នុងអារម្មណ៍ដែលប៉ះពាល់ ឬក្នុងសេចក្តីបរិសុទ្ធិព្រោះប៉ះពាល់ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនធ្វើនូវសេចក្តីចូលចិត្តក្នុងអារម្មណ៍ដែលខ្លួនឃើញហើយ ឮហើយទេ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

សម្មតិទាំងឡាយណាមួយ ដែលកើតអំពីបុថុជ្ជន អ្នកប្រាជ្ញរមែងមិនប្រកាន់នូវសម្មតិទាំងអស់នុះទេ (ព្រោះ) លោកមិនមានធម៌ជាគ្រឿងប្រកាន់ មិនធ្វើសេចក្តីចូលចិត្ត ក្នុងអារម្មណ៍ដែលខ្លួនឃើញហើយ ឮហើយទេ ធ្វើម្តេច នឹងដល់នូវធម៌ជាគ្រឿងប្រកាន់ ។

(៤៩៦) សីលុត្តមា សញ្ញមេនាហុ សុទ្ធឹ
វត្តំ សមាទាយ ឧបដ្ឋិតាសេ
ឥធេវ សិក្ខេម អថស្ស សុទ្ធឹ
ភវូបនីតា កុសលាវទានា ។

(៤៩៧) សីលុត្តមា សញ្ញមេនាហុ សុទ្ធិន្តិ សន្តេកេ សមណព្រាហ្មណា សីលុត្តមវាទា តេ សីលមត្តេន សញ្ញមមត្តេន សំវរមត្តេន អវីតិក្កមមត្តេន សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ អាហុ(១) វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ ។ សមណមុណ្ឌិកាបុត្តោ ឯវមាហ ចតូហិ ខោ អហំ ថបតិ(២) ធម្មេហិ សមន្នាគតំ បុរិស-បុគ្គលំ បញ្ញាបេមិ សម្បន្នកុសលំ បរមកុសលំ ឧត្តម-បត្តិបត្តំ សមណំ អយោជ្ឈំ កតមេហិ ចតូហិ ឥធ ថបតិ ន កាយេន បាបកម្មំ ករោតិ ន បាបិកំ វាចំ ភាសតិ ន បាបកំ សង្កប្បំ សង្កប្បេតិ ន បាបកំ អាជីវំ អាជីវតិ

---

១ ម. អាហំសុ ។ ២ ម. គហបតិ ។

[២៩៦] សមណព្រាហ្មណ៍ទាំងឡាយ (ណា) ជាអ្នកប្រកាន់ថា សីលឧត្តម ប្រកាន់ស្អិតនូវវត្ត បានពោលនូវសេចក្តីបរិសុទ្ធិ ដោយការសង្រួមថា យើងសិក្សានូវសេចក្តីបរិសុទ្ធិរបស់គ្រូ នោះ ក្នុងទិដ្ឋិនេះតែម្យ៉ាង (សមណព្រាហ្មណ៍ទាំងនោះ) ជាអ្នកប្រកាន់ថាខ្លួនឈ្លាសវៃ រមែងជាអ្នកចូលទៅរកភព ៗ

[២៩៧] ពាក្យថា សមណព្រាហ្មណ៍ទាំងឡាយ (ណា) ជាអ្នកប្រកាន់ថាសីលឧត្តម បានពោលនូវសេចក្តីបរិសុទ្ធិ ដោយការសង្រួម សេចក្តីថា មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកពោលថាសីលឧត្តម សមណព្រាហ្មណ៍ទាំងនោះ ពោល និយាយ សំដែង ពណ៌នា បំភ្លឺ ថ្លែង នូវសេចក្តីស្អាត ស្អាតវិសេស បរិសុទ្ធិ នូវការរួច រួចវិសេស រួចស្រឡះ ដោយគុណត្រឹមតែសីល ត្រឹមតែការសង្រួម ត្រឹមតែការរាំង ត្រឹមតែការមិនប្រព្រឹត្តិកន្លង ៗ (តួយ៉ាងដូច) សមណមុណ្ឌិកាបុត្ត បានពោលយ៉ាងនេះថា ម្នាលជាងឈើ ខ្ញុំបញ្ញត្តបុរសបុគ្គលដែលប្រកបដោយធម៌ ៤ ថាជាអ្នកមានកុសលបរិបូណ៌ មានកុសលដ៏ឧត្តម ដល់នូវគុណដែលគួរដល់ដ៏ខ្ពង់ខ្ពស់ ជាសមណៈដែលគេផ្ចាញ់មិនបាន ចុះធម៌ ៤ តើដូចម្តេច ម្នាលជាងឈើ បុគ្គលក្នុងលោកនេះ មិនធ្វើបាបកម្មដោយកាយ ១ មិនពោលពាក្យអាក្រក់ ១ មិនត្រិះរិះនូវតម្រិះអាក្រក់ ១ មិនចិញ្ចឹមជីវិតអាក្រក់ ១

ឥមេហិ វា អហំ ឋបតិ ឥទ្ធហិ ឥម្ហេហិ សមន្នាគតំ បុរិសបុគ្គលំ បញ្ញាបេមិ សម្បន្នកុសលំ បរមកុសលំ ឧត្តមប្បត្តិប្បត្តំ សមណំ អយោជ្ឈំ ។ ឯវមេវ សន្តេកេ សមណព្រាហ្មណា សីលុត្តមវាទា តេ សីលមត្តេន សញ្ញមមត្តេន សំវរមត្តេន អវីតិក្កមមត្តេន សុទ្ធិ វិសុទ្ធិ បរិសុទ្ធិ មុត្តិ វិមុត្តិ បរិមុត្តិ អាហុ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ សីលុត្តមា សញ្ញមេនាហុ សុទ្ធិ ។

(២៩៨) វត្តំ សមាទាយ ឧបដ្ឋិតាសេតិ វត្តន្តិ ហត្ថិវត្តំ វា អស្សវត្តំ វា គោវត្តំ វា អជវត្តំ វា កុក្កុរវត្តំ វា កាកវត្តំ វា វាសុទេវវត្តំ វា បុណ្ណភទ្ទវត្តំ វា មណិភទ្ទវត្តំ វា អគ្គិវត្តំ វា នាគវត្តំ វា សុបណ្ណវត្តំ វា យក្ខវត្តំ វា អសុរវត្តំ វា គន្ធព្វវត្តំ វា មហារាជវត្តំ វា ចន្ទវត្តំ វា សុរិយវត្តំ វា ឥន្ទវត្តំវា ព្រហ្មវត្តំ វា ទេវវត្តំ វា ទិសវត្តំ វា អាទាយ សមាទាយ អាទយិត្វា(១) គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វា ឧបដ្ឋិតា បច្ចុបដ្ឋិតា អល្លីនា ឧបគតា អជ្ឈោសិតា អធិមុត្តាតិ វត្តំ សមាទាយ ឧបដ្ឋិតាសេ ។

---

១ ម. អាទិយិត្វា សមាទិយិត្វា ។

ម្នាលជានឈើ ខ្ញុំបញ្ញត្តបុរសបុគ្គល ដែលប្រកបដោយធម៌ ៤ នេះឯងថា ជាអ្នកមានកុសលបរិបូណ៌ មានកុសលដ៏ឧត្តម ដល់នូវគុណដែលគួរដល់ ដ៏ខ្ពង់ខ្ពស់ ជាសមណៈដែលគេផ្ចាញ់មិនបាន ៗ មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកពោលថាសីលឧត្តម សមណព្រាហ្មណ៍ទាំងនោះ ពោល និយាយ សំដែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ នូវការរួច រួចវិសេស រួចស្រឡះ ដោយគុណត្រឹមតែសីល ត្រឹមតែការសង្រួម ត្រឹមតែការរាំង ត្រឹមតែការមិនប្រព្រឹត្តកន្លង យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) សមណព្រាហ្មណ៍ទាំងឡាយជាអ្នកប្រកាន់ថាសីលឧត្តម បានពោលនូវសេចក្តីបរិសុទ្ធិ ដោយការសង្រួម ៗ

[២៩៨] ពាក្យថា ប្រកាន់ស្អិតនូវវត្ត ត្រង់ពាក្យថា វត្ត គឺកាន់យក សមាទាន អើពើ ទទួល ស្ទាបអង្អែល ប្រកាន់ស្អិត ហើយតាំងមាំ ដំកល់ស៊ប់ ជាប់ស្អិត ចូលទៅរក ចុះចិត្តស៊ប់ ឱនទៅរក នូវវត្តដំរី វត្តសេះ វត្តគោ វត្តពពែ វត្តឆ្កែ វត្តក្អែក វត្តវាសុទេព វត្តបុណ្ណភទ្ទ វត្តមណិភទ្ទ វត្តភ្លើង វត្តនាគ វត្តគ្រុឌ វត្តយក្ស វត្តអសុរ វត្តគន្ធព្វ វត្តមហារាជ វត្តព្រះច័ន្ទ្រ វត្តព្រះអាទិត្យ វត្តព្រះឥន្ទ្រ វត្តព្រះព្រហ្ម វត្តទេវតា វត្តទិស ហេតុនោះ (ទ្រង់ត្រាស់ថា) ប្រកាន់ស្អិតនូវវត្ត ៗ

[២៩៩] ឥធេវ សិក្ខេម អថស្ស សុទ្ធិន្តិ ឥធាតិ សកាយ ទិដ្ឋិយា សកាយ ខន្តិយា សកាយ រុចិយា សកាយ លទ្ធិយា(១) សិក្ខេម អាចរេម សមាចរេម សមាទាយ វត្តាមាតិ ឥធេវ សិក្ខេម ។ អថស្ស សុទ្ធិន្តិ អថភស្ស សុទ្ធី វិសុទ្ធី បរិសុទ្ធី មុត្តី វិមុត្តី បរិមុត្តិន្តិ ឥធេវ សិក្ខេម អថស្ស សុទ្ធី ។

[៣០០] ភវូបនីតា កុសលាវទានាតិ ភវូបនីតាតិ ភវូបនីតា ភវូបគតា ភវជ្ឈោសិតា ភវាធិមុត្តាតិ ភវូបនីតា ។ កុសលាវទានាតិ កុសលវាទា បណ្ឌិតវាទា ថិរវាទា ញាយវាទា ហេតុវាទា លក្ខណវាទា ការណវាទា ឋានវាទា សកាយ លទ្ធិយាតិ

---

១ ម. ឯត្ថន្តរេ សិក្ខេមាតិ ទិស្សតិ ។

(២៩៩) អធិប្បាយពាក្យថា យើងសិក្សានូវសេចក្តីបរិសុទ្ធិរបស់គ្រូនោះ ក្នុងទិដ្ឋិនេះតែម្យ៉ាង ត្រង់ពាក្យថា ក្នុងទិដ្ឋិនេះ គឺយើងសិក្សា ប្រព្រឹត្តទៅ ប្រព្រឹត្តព្រម សមាទាន ប្រព្រឹត្តក្នុងទិដ្ឋិរបស់ខ្លួន ក្នុងសេចក្តីគួររបស់ខ្លួន ក្នុងសេចក្តីគាប់ចិត្តរបស់ខ្លួន ក្នុងលទ្ធិរបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) យើងសិក្សា ក្នុងទិដ្ឋិនេះតែម្យ៉ាង ។ ពាក្យថា នូវសេចក្តីបរិសុទ្ធិរបស់គ្រូនោះ គឺនូវការស្អាត ស្អាតវិសេស បរិសុទ្ធិ នូវការរួច រួចវិសេស រួចស្រឡះរបស់គ្រូនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) យើងសិក្សានូវសេចក្តីបរិសុទ្ធិ របស់គ្រូនោះ ក្នុងទិដ្ឋិនេះតែម្យ៉ាង ។

(៣០០) អធិប្បាយពាក្យថា (សមណព្រាហ្មណ៍ ទាំងនោះ) ជាអ្នកប្រកាន់ថា ខ្លួនឈ្លាសវៃ រមែងជាអ្នកចូលទៅរកកត ត្រង់ពាក្យថា ជាអ្នកចូលទៅរកកត គឺជាអ្នកចូលទៅជិតកាន់កត ចូលទៅរកកត ចុះស៊ប់ក្នុងកត ទុនទៅរកកត ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកចូលទៅរកកត ។ ពាក្យថា ប្រកាន់ថាខ្លួនឈ្លាសវៃ គឺជាអ្នកពោលថាឈ្លាសវៃ ពោលថាជាបណ្ឌិត ពោលថាជាអ្នកប្រាជ្ញ ពោលថាប្រកបដោយញាណ ពោលថាប្រកបដោយហេតុ ពោលថាប្រកបដោយលក្ខណៈ ពោលថាប្រកបដោយការណ៍ ពោលថាប្រកបដោយឋានៈ ក្នុងលទ្ធិរបស់ខ្លួន

ភវូបនីតា កុសលាវទានា ។ តេនាហ ភគវា

សីលុត្តមា សញ្ញមេនាហុ សុទ្ធឹ
វតំ សមាទាយ ឧបដ្ឋិតាសេ
ឥធេវ សិក្ខេម អថស្ស សុទ្ធឹ
ភវូបនីតា កុសលាវទានាតិ ។

(៣០១) សចេ ចុតោ សីលវតាតោ ហោតិ
ស(១) វេធតី កម្ម វិរាធយិត្វា
ស(២) ជប្បតី បត្ថយតី ច សុទ្ធឹ
សត្ថាវហីនោ បវសំ ឃរម្ហា ។

(៣០២) សចេ ចុតោ សីលវតាតោ ហោតីតិ ទ្វីហិ ការណេហិ សីលព្វតតោ ចវតិ បរវិច្ឆិន្ទនាយ វា ចវតិ អនភិសម្ភុណន្តោ វា ចវតិ ។

កថំ បរវិច្ឆិន្ទនាយ ចវតិ ។ បរោ វិច្ឆិន្ទេតិ សោ សត្ថា ន សព្វញ្ញូ ធម្មោ ន ស្វាក្ខាតោ គណោ ន សុប្បដិបន្នោ

១. ២ ម. ប. ។

ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកចូលទៅរកភព ប្រកាន់ថាឈ្មោសៅ ៗ

ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

សមណព្រាហ្មណ៍ទាំងឡាយ (ណា) ជាអ្នកប្រកាន់ថា សីលុត្តម ប្រកាន់ស្អិតនូវវត្ត បានពោលនូវសេចក្តីបរិសុទ្ធិដោយការសង្រួមថា យើងសិក្សានូវសេចក្តីបរិសុទ្ធិ របស់គ្រូនោះ ក្នុងទិដ្ឋិនេះតែម្យ៉ាង (សមណព្រាហ្មណ៍ទាំងនោះ) ជាអ្នកប្រកាន់ថាខ្លួនឈ្មោសៅ រមែងជាអ្នកចូលទៅរកភព ៗ

(៣០១) បើបុគ្គលណាឃ្លាតចាកសីលនិងវត្តហើយ បុគ្គលនោះរមែងញាប់ញ័រ ព្រោះឃ្លាតចាកកម្ម បុគ្គលនោះឯង តែងបង់បានផង ប្រាថ្នាផង នូវសេចក្តីបរិសុទ្ធិ ដូចបុគ្គលឃ្លាតចាកផ្ទះ ហើយសាបសូន្យចាកពួក ៗ

(៣០២) ពាក្យថា បើបុគ្គលណា ឃ្លាតចាកសីលនិងវត្តហើយ អធិប្បាយថា បុគ្គលឃ្លាតចាកសីលនិងវត្ត ដោយហេតុ ២ ប្រការគឺ ឃ្លាតដោយការលះបង់ព្រោះបុគ្គលដទៃ ឬកាលមិនសម្រេចហើយឃ្លាតៗ

បុគ្គលឃ្លាតដោយការលះបង់ ព្រោះបុគ្គលដទៃ តើដូចម្តេច ៗ បុគ្គលដទៃឲ្យលះបង់ថា សាស្តានោះ មិនមែនជាសព្វញ្ញូទេ ធម៌មិនមែនព្រះសាស្តាសំដែងដោយប្រពៃទេ គណៈមិនមែនប្រតិបត្តិដោយប្រពៃទេ

ទិដ្ឋិ ច ភទ្ទិកា បដិបទា ច សុប្បញ្ញត្តា មគ្គោ ច និយ្យានិកោ នត្ថេត្ថ សុទ្ធិ វា បរិសុទ្ធិ វា មុត្តិ វា វិមុត្តិ វា បរិមុត្តិ វា ន តត្ថ(១) សុជ្ឈន្តិ វា វិសុជ្ឈន្តិ វា បរិសុជ្ឈន្តិ វា មុច្ចន្តិ វា វិមុច្ចន្តិ វា បរិមុច្ចន្តិ វា ហីនា និហីនា ឱមកា លាមកា ជតុក្កា បរិត្តាតិ ឯវំ បរោ វិច្ឆិន្ទតិ ។ ឯវំ វិច្ឆិន្ទយមានោ សត្ថារា ចវតិ ធម្មក្ខានា ចវតិ គណា ចវតិ ទិដ្ឋិយា ចវតិ បដិបទាយ ចវតិ មគ្គតោ ចវតិ ឯវំ បរវិច្ឆិន្ទនាយ ចវតិ ។

កថំ អនភិសម្ភុណន្តោ ចវតិ ។ សីលំ អនភិសម្ភុណន្តោ សីលតោ ចវតិ វត្តំ អនភិសម្ភុណន្តោ វត្តតោ ចវតិ សីលព្វតំ អនភិសម្ភុណន្តោ សីលព្វតតោ ចវតិ ឯវំ អនភិសម្ភុណន្តោ ចវតីតិ សចេ ចុតោ សីលវតាតោ ហោតិ ។

---

១ ឱ. ម. នេត្ថ ។

ទិដ្ឋិមិនមែនល្អទេ បដិបទាមិនមែនសាស្តា នោះបញ្ញត្តដោយប្រពៃទេ មគ្គមិនមែនជាទីស្រោចស្រង់សត្វទេ សេចក្តីស្អាតក្តី ការស្អាតវិសេសក្តី ការរួចក្តី ការរួចដោយវិសេសក្តី ការរួចស្រឡះក្តី មិនមានក្នុង ក្នុងលទ្ធិនុ៎ះទេ ជនទាំងឡាយ ស្អាត ស្អាតវិសេស បរិសុទ្ធិ រួច រួចវិសេស រួចស្រឡះ ក្នុងលទ្ធិនុ៎ះមិនមានទេ ជនទាំងឡាយនោះ ជាអ្នកថោកទាប ថោកទាបពេក ទន់ទាប លាមក អាក្រក់ តិចតួច បុគ្គលដទៃឲ្យលះបង់ យ៉ាងនេះឯង ។ បុគ្គលនោះ កាលត្រូវគេឲ្យលះបង់យ៉ាងនេះ ក៏ឃ្លាតចាកសាស្តា ឃ្លាតចាកធម៌ដែលសាស្តាពោល ឃ្លាតចាកគណៈ ឃ្លាតចាកទិដ្ឋិ ឃ្លាតចាកបដិបទា ឃ្លាតចាកមគ្គ បុគ្គលឃ្លាត ដោយការលះបង់ ព្រោះបុគ្គលដទៃ យ៉ាងនេះ ។

បុគ្គលកាលមិនសម្រេចហើយឃ្លាត តើដូចម្តេច ។ បុគ្គលកាលមិនញុំាងសីលឲ្យសម្រេច ឈ្មោះថា ឃ្លាតចាកសីល មិនញុំាងវត្តឲ្យសម្រេច ឈ្មោះថាឃ្លាតចាកវត្ត មិនញុំាងសីលនិងវត្តឲ្យសម្រេច ឈ្មោះថាឃ្លាតចាកសីលនិងវត្ត បុគ្គលកាលមិនសម្រេចហើយឃ្លាត យ៉ាងនេះឯង ហេតុនោះ (ទ្រង់ត្រាស់ថា) បើបុគ្គលណា ឃ្លាតចាកសីលនិងវត្តហើយ ។

តេរសមោ មហាវិយូហសុត្តនិទ្ទេសោ

(៣០៣) ស វេធតី កម្ម វិរាធយិត្វាតិ ស វេធតីតិ សីលំ វា វត្តំ វា សីលព្វតំ វា វិរទ្ធំ មយា អបរទ្ធំ មយា ខលិតំ មយា គឡិតំ មយា អញ្ញាយ អបរទ្ធោ អហន្តិ វេធតិ បវេធតិ សម្បវេធតីតិ ស វេធតី ។ កម្ម វិរាធយិត្វាតិ បុញ្ញាភិសង្ខារំ វា អបុញ្ញាភិសង្ខារំ វា អានេញ្ជាភិសង្ខារំ វា វិរទ្ធំ មយា អបរទ្ធំ មយា ខលិតំ មយា គឡិតំ មយា អញ្ញាយ អបរទ្ធោ អហន្តិ វេធតិ បវេធតិ សម្បវេធតីតិ ស វេធតី កម្ម វិរាធយិត្វា ។

(៣០៤) ស ជប្បតី បត្ថយតី ច សុទ្ធិន្តិ ស ជប្បតីតិ សីលំ វា ជប្បតិ វត្តំ វា ជប្បតិ សីលព្វតំ វា ជប្បតិ បជប្បតិ អភិជប្បតីតិ ស ជប្បតី ។ បត្ថយតី ច សុទ្ធិន្តិ សីលសុទ្ធិំ វា បត្ថេតិ

មហាវិយូហសុត្តនិទ្ទេស ទី ១៣

(៣០៣) អធិប្បាយពាក្យថា បុគ្គលនោះរមែងញាប់ញ័រ ព្រោះភ្លាត់ឃាតកម្ម ត្រង់ពាក្យថា បុគ្គលនោះរមែងញាប់ញ័រ គឺបុគ្គលនោះរមែងញាប់ញ័រ ញាប់ញ័រខ្លាំង ញាប់ញ័រចំប្រប់ថា សីលក្តី វត្តក្តី សីលនឹងវត្តក្តី អាត្មាអញខុសហើយ អាត្មាអញប្រាសចេញហើយ អាត្មាអញភ្លាំងភ្លាត់ហើយ អាត្មាអញឃ្លៀងឃ្លាតហើយ អាត្មាអញប្រាសចាកអរហត្តផលហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះរមែងញាប់ញ័រ ។ ពាក្យថា ព្រោះភ្លាត់ឃាតកម្ម គឺបុគ្គលនោះរមែងញាប់ញ័រ ញាប់ញ័រខ្លាំង ញាប់ញ័រចំប្រប់ថា បុញ្ញាភិសង្ខារក្តី អបុញ្ញាភិសង្ខារក្តី អានេញ្ជាភិសង្ខារក្តី អាត្មាអញខុសហើយ អាត្មាអញប្រាសចេញហើយ អាត្មាអញភ្លាំងភ្លាត់ហើយ អាត្មាអញឃ្លៀងឃ្លាតហើយ អាត្មាអញប្រាសចាកអរហត្តផលហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះរមែងញាប់ញ័រ ព្រោះភ្លាត់ឃាតកម្ម ។

(៣០៤) ពាក្យថា បុគ្គលនោះឯង តែងចង់បានផង ប្រាថ្នាផង នូវសេចក្តីបរិសុទ្ធិ ត្រង់ពាក្យថា បុគ្គលនោះ ចង់បាន គឺចង់បានសីល ចង់បានវត្ត ចង់បាន ចង់បានខ្លាំង ចង់បានណាស់ នូវសីលនឹងវត្ត ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះរមែងចង់បាន ។ ពាក្យថា ប្រាថ្នាផងនូវសេចក្តីបរិសុទ្ធិ គឺប្រាថ្នានូវសេចក្តីបរិសុទ្ធិនៃសីល

វត្ថុសុទ្ធឹ វា បត្ថេតិ សីលព្វតសុទ្ធឹ វា បត្ថេតិ បិហេតិ អភិជប្បតីតិ ស ជប្បតី បត្ថយតី ច សុទ្ធឹ ។

(៣០៤) សត្ថាវហីនោ បវសំ ឃរម្ហាតិ យថា បុរិសោ ឃរតោ និក្ខន្តោ សត្ថេន សហ (១) វសេន្តោ សត្ថា ឱហីនោ តំ វា សត្ថំ អនុពន្ធតិ សកំ វា ឃរំ បច្ចាគច្ឆតិ ឯវមេវ សោ ទិដ្ឋិគតិកោ តំ វា សត្ថារំ គណ្ហាតិ អញ្ញំ វា សត្ថារំ គណ្ហាតិ តំ វា ធម្មក្ខានំ គណ្ហាតិ អញ្ញំ វា ធម្មក្ខានំ គណ្ហាតិ តំ វា គណំ គណ្ហាតិ អញ្ញំ វា គណំ គណ្ហាតិ តំ វា ទិដ្ឋឹ គណ្ហាតិ អញ្ញំ វា ទិដ្ឋឹ គណ្ហាតិ តំ វា បដិបទំ គណ្ហាតិ អញ្ញំ វា បដិបទំ គណ្ហាតិ តំ វា មគ្គំ គណ្ហាតិ អញ្ញំ វា មគ្គំ គណ្ហាតិ បរាមសតិ អភិនិវិសតីតិ សត្ថាវហីនោ បវសំ ឃរម្ហា ។ តេនាហ ភគវា

សវេ ចុតោ សីលវតាតោ ហោតិ
ស វេធតី កម្ម វិរាធយិត្វា
ស ជប្បតី បត្ថយតី ច សុទ្ធឹ
សត្ថាវហីនោ បវសំ ឃរម្ហាតិ ។

---

១ ម. បវសំ ។

ប្រាថ្នានូវសេចក្ដីបរិសុទ្ធិនៃវត្ត ប្រាថ្នា ស្រឡាញ់ ចង់បានណាស់ នូវសេចក្ដីបរិសុទ្ធិនៃសីលនិងវត្ត ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះឯង តែងចង់បានផង ប្រាថ្នាផង នូវសេចក្ដីបរិសុទ្ធិ ។

(៣០៥) ពាក្យថា (ដូច) បុគ្គលឃ្លាតចាកផ្ទះ ហើយសាបសូន្យចាកពួក សេចក្ដីថា បុរសចេញអំពីផ្ទះ នៅជាមួយនឹងពួក ឃ្លាតពួក ហើយរមែងទៅតាមពួកនោះ ឬត្រឡប់មកកាន់ផ្ទះខ្លួនវិញ យ៉ាងណា បុគ្គលអ្នកលះគន់ទិដ្ឋិនោះ រមែងប្រកាន់សាស្ដានោះ ឬប្រកាន់សាស្ដាដទៃ ប្រកាន់ធម៌ដែលសាស្ដាពោលហើយនោះ ឬប្រកាន់ធម៌ដទៃដែលសាស្ដាពោលហើយ ប្រកាន់គណៈនោះ ឬប្រកាន់គណៈដទៃ ប្រកាន់ទិដ្ឋិនោះ ឬប្រកាន់ទិដ្ឋិដទៃ ប្រកាន់បដិបទានោះ ឬប្រកាន់បដិបទាដទៃ ប្រកាន់មគ្គនោះ ឬប្រកាន់ ស្ទាបអង្អែល ប្រកាន់ស្អិត នូវមគ្គដទៃ ក៏យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) (ដូច) បុគ្គលឃ្លាតចាកផ្ទះ ហើយសាបសូន្យចាកពួក ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលណា ឃ្លាតចាកសីលនិងវត្តហើយ បុគ្គលនោះឯង
រមែងញាប់ញ័រ ព្រោះភ្លាត់ចាកកម្ម បុគ្គលនោះរមែងចង់
បានផង ប្រាថ្នាផង នូវសេចក្ដីបរិសុទ្ធិ ដូចបុគ្គលឃ្លាត
ចាកផ្ទះ ហើយសាបសូន្យចាកពួក ។

តេរសមោ មហាវិយូហសុត្តនិទ្ទេសោ

(៣០៦) សីលព្វតំ វាបិ បហាយ សព្វំ
កម្មញ្ច សាវជ្ជនវជ្ជមេតំ
សុទ្ធឹ អសុទ្ធិន្តិ អបត្ថយានោ
វិរតោ ចរេ សន្តិមនុគ្គហាយ ។

(៣០៧) សីលព្វតំ វាបិ បហាយ សព្វន្តិ សព្វា សីលសុទ្ធិយោ បហាយ បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមិត្វា សព្វា វត្តសុទ្ធិយោ បហាយ បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមិត្វា សព្វា សីលព្វតសុទ្ធិយោ បហាយ បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមិត្វាតិ សីលព្វតំ វាបិ បហាយ សព្វំ ។

(៣០៨) កម្មញ្ច សាវជ្ជនវជ្ជមេតន្តិ សាវជ្ជកម្មំ វុច្ចតិ កណ្ហំ កណ្ហវិបាកំ ។ អនវជ្ជកម្មំ វុច្ចតិ សុក្កំ សុក្កវិបាកំ ។ សាវជ្ជញ្ច កម្មំ អនវជ្ជញ្ច កម្មំ បហាយ បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមិត្វាតិ កម្មញ្ច សាវជ្ជនវជ្ជមេតំ ។

មហាវិយូហសុត្តនិទ្ទេស ទី ១៣

(៣០៦) បុគ្គលលះបង់ នូវសីលនិងវត្ត ទាំងអស់ផង នូវកម្មដែលមានទោសនិងមិនមានទោសទុះផង មិនប្រាថ្នានូវសេចក្តីបរិសុទ្ធិនិងសេចក្តីមិនបរិសុទ្ធិផង គប្បីប្រព្រឹត្តវៀរ មិនប្រកាន់នូវសេចក្តីស្ងប់ ។

(៣០៧) ពាក្យថា បុគ្គលលះបង់ នូវសីលនិងវត្តទាំងអស់ គឺ បុគ្គលលះបង់ លះលែង បន្ទោបង់ ធ្វើឲ្យវិនាស ដល់ការមិនកើតមាន នូវសេចក្តីបរិសុទ្ធិ នៃសីលទាំងអស់ លះបង់ លះលែង បន្ទោបង់ ធ្វើឲ្យវិនាស ដល់ការមិនកើតមាន នូវសេចក្តីបរិសុទ្ធិនៃវត្តទាំងអស់ លះបង់ លះលែង បន្ទោបង់ ធ្វើឲ្យវិនាស ដល់ការមិនកើតមាន នូវសេចក្តីបរិសុទ្ធិនៃសីលនិងវត្តទាំងអស់ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលលះបង់នូវសីលនិងវត្តទាំងអស់ ។

(៣០៨) ពាក្យថា នូវកម្មដែលមានទោស និងមិនមានទោសទុះផង សេចក្តីថា អំពើខ្មៅឲ្យផលខ្មៅ លោកហៅថា កម្មមានទោស ។ អំពើសឲ្យផលស លោកហៅថា កម្មមិនមានទោស ។ (បុគ្គល) លះបង់ លះលែង បន្ទោបង់ ធ្វើឲ្យវិនាស ដល់ការមិនកើតមាន នូវកម្មមានទោសផង កម្មមិនមានទោសផង ហេតុនោះ (ទ្រង់ត្រាស់ថា) នូវកម្មដែលមានទោស និងមិនមានទោសទុះផង ។

(៣០៩) សុទ្ធឹ អសុទ្ធិន្តិ អបត្ថយានោតិ អសុទ្ធឹ(១) បត្ថេន្តិ អកុសលេ ធម្មេ បត្ថេន្តិ សុទ្ធឹ(២) បត្ថេន្តិ បញ្ច កាមគុណេ បត្ថេន្តិ អសុទ្ធឹ បត្ថេន្តិ អកុសលេ ធម្មេ បត្ថេន្តិ បញ្ច កាមគុណេ បត្ថេន្តិ សុទ្ធឹ បត្ថេន្តិ ទ្វាសដ្ឋិទិដ្ឋិគតានិ បត្ថេន្តិ អសុទ្ធឹ បត្ថេន្តិ អកុសលេ ធម្មេ បត្ថេន្តិ បញ្ច កាមគុណេ បត្ថេន្តិ ទ្វាសដ្ឋិទិដ្ឋិគតានិ បត្ថេន្តិ សុទ្ធឹ បត្ថេន្តិ តេធាតុកេ កុសលេ ធម្មេ បត្ថេន្តិ អសុទ្ធឹ បត្ថេន្តិ អកុសលេ ធម្មេ បត្ថេន្តិ បញ្ច កាមគុណេ បត្ថេន្តិ ទ្វាសដ្ឋិទិដ្ឋិគតានិ បត្ថេន្តិ តេធាតុកេ កុសលេ ធម្មេ បត្ថេន្តិ សុទ្ធឹ បត្ថេន្តិ កល្យាណបុថុជ្ជនា និយាមាវក្កន្តឹ(៣) បត្ថេន្តិ សេក្ខា អគ្គធម្មំ អរហត្តំ បត្ថេន្តិ ។ អរហត្តប្បត្តោ អរហា នេវ អកុសលេ ធម្មេ បត្ថេតិ នបិ បញ្ច កាមគុណេ បត្ថេតិ នបិ ទ្វាសដ្ឋិទិដ្ឋិគតានិ បត្ថេតិ នបិ តេធាតុកេ កុសលេ ធម្មេ បត្ថេតិ នបិ និយាមាវក្កន្តឹ បត្ថេតិ នបិ អគ្គធម្មំ អរហត្តំ បត្ថេតិ ។ បត្ថនា សមតិក្កន្តោ

---

១ ឱ. ម. អសុទ្ធិន្តិ អសុទ្ធឹ ។ ២ ម. សុទ្ធិន្តិ សុទ្ធឹ ។ ៣ ម. បុថុជ្ជនកល្យាណកា និយាមាវក្កន្តឹ ។

(៣០៩) ពាក្យថា មិនប្រាថ្នាសេចក្តីបរិសុទ្ធិ ទាំងសេចក្តីមិនបរិសុទ្ធិ អធិប្បាយថា ពួកបុថុជ្ជន តែងប្រាថ្នាសេចក្តីមិនបរិសុទ្ធិ ប្រាថ្នាអកុសលធម៌ ប្រាថ្នាសេចក្តីបរិសុទ្ធិ ប្រាថ្នាកាមគុណ៥ ប្រាថ្នាសេចក្តីមិនបរិសុទ្ធិ ប្រាថ្នាអកុសលធម៌ ប្រាថ្នាកាមគុណ៥ ប្រាថ្នាសេចក្តីបរិសុទ្ធិ ប្រាថ្នាទិដ្ឋិ ៦២ ប្រាថ្នាសេចក្តីមិនបរិសុទ្ធិ ប្រាថ្នាអកុសលធម៌ ប្រាថ្នាកាមគុណ៥ ប្រាថ្នាទិដ្ឋិ ៦២ ប្រាថ្នាសេចក្តីបរិសុទ្ធិ ប្រាថ្នាកុសលធម៌ក្នុងត្រៃធាតុ ប្រាថ្នាសេចក្តីមិនបរិសុទ្ធិ ប្រាថ្នាអកុសលធម៌ ប្រាថ្នាកាមគុណ ៥ ប្រាថ្នាទិដ្ឋិ ៦២ ប្រាថ្នាកុសលធម៌ក្នុងត្រៃធាតុ ប្រាថ្នាសេចក្តីបរិសុទ្ធិ ឯកល្យាណបុថុជ្ជន ប្រាថ្នាការយាងចុះកាន់និយាមៈ(១) សេក្ខបុគ្គលប្រាថ្នាអរហត្តជាធម៌ប្រសើរ ។ កាលបើដល់ព្រះអរហត្តហើយ ព្រះអរហន្តមិនប្រាថ្នាអកុសលធម៌ មិនប្រាថ្នាកាមគុណ ៥ មិនប្រាថ្នាទិដ្ឋិ ៦២ មិនប្រាថ្នាកុសលធម៌ក្នុងត្រៃធាតុ មិនប្រាថ្នាការយាងចុះកាន់និយាមៈ មិនប្រាថ្នាព្រះអរហត្តជាធម៌ដ៏ប្រសើរ ។ ព្រះអរហន្ត កាលកន្លងសេចក្តីប្រាថ្នា

១ សំដៅយកមគ្គ ។ អដ្ឋកថា ។

អរហា វុឌ្ឍិបរិហានឹ វីតិវត្តោ ។ សោ វុដ្ឋវាសោ ចិណ្ណ-
ចរណោ ។បេ។ នត្ថិ តស្ស បុនព្ភវោតិ សុទ្ធឹ អសុទ្ធិន្តិ
អបត្ថយានោ ។

(៣១០) វិរតោ ចរេ សន្តិមនុគ្គហាយាតិ វិរតោតិ
សុទ្ធិអសុទ្ធិយា អារតោ វិរតោ បដិវិរតោ និក្ខន្តោ និ-
ស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា
វិហរតីតិ វិរតោ ។ ចរេតិ ចរេយ្យ វិចរេយ្យ ឥរិយេយ្យ
វត្តេយ្យ បាលេយ្យ យបេយ្យ យាបេយ្យាតិ វិរតោ
ចរេ ។ សន្តិមនុគ្គហាយាតិ សន្តិយោ វុច្ចន្តិ ទ្វាសដ្ឋិ-
ទិដ្ឋិគតានិ ទិដ្ឋិសន្តិយោ អគ្គណ្ហន្តោ អបរាមសន្តោ
អនភិនិវិសន្តោតិ វិរតោ ចរេ សន្តិមនុគ្គហាយ ។
តេនាហ ភគវា

ឈ្មោះថាកន្លងផុតសេចក្ដីចំរើនទាំងសេចក្ដីសាបសូន្យ ។ ព្រះអរហន្តនោះមានអរិយវាសនៅរួចហើយ មានការប្រព្រឹត្តិសន្សំហើយ ។ បេ ។ ភពថ្មីនៃព្រះអរហន្តនោះ មិនមាន ហេតុនោះ (ទ្រង់ត្រាស់ថា) មិនប្រាថ្នានូវសេចក្ដីបរិសុទ្ធិ ទាំងសេចក្ដីមិនបរិសុទ្ធិ ។

(៣១០) អធិប្បាយពាក្យថា គប្បីប្រព្រឹត្តវៀរ មិនប្រកាន់សេចក្ដីស្ងប់ ត្រង់ពាក្យថា វៀរ គឺវៀរទួទៅ វៀរស្រឡះ វៀរចំពោះ ឃ្លាតចេញ លោះចេញ រួចស្រឡះ ប្រកបប្រាស ចាកសេចក្ដីបរិសុទ្ធិ ទាំងមិនបរិសុទ្ធិ រមែងនៅដោយចិត្តដែលប្រាសចាកដែនគឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) វៀរ ។ ពាក្យថា គប្បីប្រព្រឹត្ត គឺគប្បីត្រាច់ទៅ គប្បីត្រាច់ទៅផ្សេង ៗ គប្បីញុំាងឥរិយាបថឲ្យប្រព្រឹត្តទៅ គប្បីញុំាងការប្រព្រឹត្តិឥរិយាបថឲ្យកើត គប្បីរក្សាឥរិយាបថ គប្បីបំពេញឥរិយាបថ គប្បីបង្រ្គប់ឥរិយាបថ ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីប្រព្រឹត្តវៀរ ។ ពាក្យថា មិនប្រកាន់សេចក្ដីស្ងប់ សេចក្ដីថា ទិដ្ឋិ ៦២ លោកហៅថា សេចក្ដីស្ងប់ ។ បុគ្គលមិនប្រកាន់ មិនស្ទាបអង្អែល មិនប្រកាន់ស្អិត នូវសេចក្ដីស្ងប់គឺទិដ្ឋិ ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីប្រព្រឹត្តវៀរ មិនប្រកាន់សេចក្ដីស្ងប់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

សីលព្វតំ វាបិ បហាយ សព្វំ

កម្មញ្ច សាវជ្ជនវជ្ជមេតំ

សុទ្ធឹ អសុទ្ធិន្តិ អបត្ថយានោ

វិរតោ ចរេ សន្តិមនុគ្គហាយាតិ ។

(៣១១) តមូបនិស្សាយ ជិគុច្ឆិតំ វា

អថវាបិ ទិដ្ឋំវ សុតំ មុតំ វា

ឧទ្ធំសរា(១) សុទ្ធិមនុត្ថុនន្តិ

អវីតតណ្ហាសេ ភវាភវេសុ ។

(៣១២) តមូបនិស្សាយ ជិគុច្ឆិតំ វាតិ សន្តេកេ សមណព្រាហ្មណា តបោជិគុច្ឆវាទា តបោជិគុច្ឆសារា តបោជិគុច្ឆំ និស្សិតា សន្និស្សិតា អល្លីនា ឧបគតា អជ្ឈោសិតា អធិមុត្តាតិ តមូបនិស្សាយ ជិគុច្ឆិតំ វា ។

(៣១៣) អថវាបិ ទិដ្ឋំវ សុតំ មុតំ វាតិ ទិដ្ឋំ វា ទិដ្ឋសុទ្ធឹ វា សុតំ វា សុតសុទ្ធឹ វា មុតំ វា មុតសុទ្ធឹ វា

១ ម. ឧទ្ធំបរា ។

បុគ្គលលះបង់នូវសីលនឹងវត្តទាំងអស់ផង នូវកម្មដែលមានទោស នឹងមិនមានទោសនុ៎ះផង មិនប្រាថ្នាសេចក្ដីបរិសុទ្ធិ នឹងសេចក្ដីមិនបរិសុទ្ធិផង គប្បីប្រព្រឹត្តវៀរ មិនប្រកាន់សេចក្ដីស្ងប់ ។

(៣១១) ពួកសមណព្រាហ្មណ៍ ជាខ្ទុំសកវាទ មានតណ្ហាមិនទាន់ទៅប្រាស ក្នុងភពតូចភពធំទាំងឡាយ អាស្រ័យនូវសេចក្ដីខ្ពើម (បាប) នោះ ឬអាស្រ័យនូវអារម្មណ៍ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ហើយ រមែងពោលសេចក្ដីបរិសុទ្ធិ ។

(៣១២) ពាក្យថា អាស្រ័យសេចក្ដីខ្ពើម (បាប) នោះ គឺមានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកមានវាទៈថាខ្ពើមបាបដោយតបៈ ជាអ្នកមានការខ្ពើមបាបដោយតបៈជាខ្លឹម អាស្រ័យ អាស្រ័យព្រម ជាប់ស្អិត ចូលទៅរក ចុះចិត្តស៊ប់ ឱនទៅរក នូវការខ្ពើមបាបដោយតបៈ ហេតុនោះ (ទ្រង់ត្រាស់ថា) អាស្រ័យសេចក្ដីខ្ពើម (បាប) នោះ ។

(៣១៣) ពាក្យថា នូវអារម្មណ៍ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ហើយ គឺអាស្រ័យ ចូលទៅអាស្រ័យ ប្រកាន់ ស្ទាបអង្អែល ប្រកាន់ស្អិត នូវអារម្មណ៍ដែលខ្លួនឃើញហើយ ឬនូវសេចក្ដីបរិសុទ្ធិ ព្រោះឃើញ នូវអារម្មណ៍ដែលឮហើយ ឬនូវសេចក្ដីបរិសុទ្ធិព្រោះឮ នូវអារម្មណ៍ដែលប៉ះពាល់ហើយ ឬនូវសេចក្ដីបរិសុទ្ធិ ព្រោះប៉ះពាល់

និស្សាយ ឧបនិស្សាយ គណ្ហិត្វា បរាមសិត្វា អភិនិវិសិត្វាតិ អជានិ ទិដ្ឋិំ សុតំ មុតំ វា ។

(៣១៤) ឧទ្ធំសរា សុទ្ធិមនុត្ថុនន្តីតិ សន្តេកេ សមណព្រាហ្មណា ឧទ្ធំសរាវាទា ។ កតមេ(១) សមណព្រាហ្មណា ឧទ្ធំសរាវាទា ។ យេ តេ សមណព្រាហ្មណា អច្ចន្តសុទ្ធិកា សំសារសុទ្ធិកា អកិរិយទិដ្ឋិកា សស្សតវាទា ឥមេ តេ សមណព្រាហ្មណា ឧទ្ធំសរាវាទា ។ តេ សំសារេន សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ អនុត្ថុនន្តិ(២) វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ ឧទ្ធំសរា សុទ្ធិមនុត្ថុនន្តិ ។

(៣១៥) អវីតតណ្ហាសេ ភវាភវេសូតិ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ភវាភវេសូតិ ភវាភវេ កម្មភវេ បុនព្ភវេ កាមភវេ កម្មភវេ កាមភវេ បុនព្ភវេ រូបភវេ កម្មភវេ រូបភវេ បុនព្ភវេ អរូបភវេ កម្មភវេ អរូបភវេ បុនព្ភវេ បុនប្បុនំ ភវេ បុនប្បុនំ គតិយា បុនប្បុនំ ឧបបត្តិយា

---

១ ឱ, ម. កតមេ តេ ។ ២ ម. ថុនន្តិ ។

ហេតុនោះ (ទ្រង់ត្រាស់ថា) នូវអារម្មណ៍ដែលខ្លួនឃើញហើយ ឮ ប៉ះពាល់ហើយ ។

(៣១៤) ពាក្យថា ជាទិដ្ឋិសកវាទ រមែងពោលសេចក្តីបរិសុទ្ធិ គឺមានសមណព្រាហ្មណ៍ពួកមួយ ជាទិដ្ឋិសកវាទ ។ សមណព្រាហ្មណ៍ ជាទិដ្ឋិសកវាទ តើដូចម្តេច ។ សមណព្រាហ្មណ៍ណា ជាពួកប្រកាន់ អច្ចន្តសុទ្ធិ ប្រកាន់សង្សារសុទ្ធិ ជាអកិរិយទិដ្ឋិ ជាសស្សតវាទ សមណព្រាហ្មណ៍ទាំងនេះ ឈ្មោះថា ទិដ្ឋិសកវាទ ។ សមណព្រាហ្មណ៍ទាំងនោះ តែងសរសើរ ពោល សំដែង ពណ៌នា បំភ្លឺ ថ្លែង នូវសេចក្តីស្អាត ស្អាតវិសេស បរិសុទ្ធិ រួចវិសេស រួចស្រឡះ ព្រោះសង្សារ ហេតុនោះ (ទ្រង់ត្រាស់ថា) ជាទិដ្ឋិសកវាទ រមែងពោលសេចក្តីបរិសុទ្ធិ ។

(៣១៥) ពាក្យថា មានតណ្ហាមិនទាន់ទៅប្រាស ក្នុងភពតូចភពធំទាំងឡាយ ត្រង់ពាក្យថា តណ្ហា បានដល់រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា ក្នុងភពតូចភពធំទាំងឡាយ គឺក្នុងកម្មភព បុនព្ភព ឈ្មោះថាភពតូចភពធំ គឺថា ក្នុងកាមភព ឈ្មោះកម្មភព ក្នុងកាមភព ឈ្មោះបុនព្ភព ក្នុងរូបភព ឈ្មោះកម្មភព ក្នុងរូបភព ឈ្មោះបុនព្ភព ក្នុងអរូបភព ឈ្មោះកម្មភព ក្នុងអរូបភព ឈ្មោះបុនព្ភព ក្នុងការកើតរឿយ ៗ ក្នុងការទៅរឿយ ៗ ក្នុងឧបបត្តិរឿយ ៗ

បុនព្ភវំ បដិសន្ធិយា បុនព្ភវេ អត្តភាវ ភិនិព្វត្តិយា ។ អវីតតណ្ហាសេតិ អវីតតណ្ហា អវិគតតណ្ហា អចត្ត-តណ្ហា អវន្តតណ្ហា អមុត្តតណ្ហា អប្បហីនតណ្ហា អប្បដិនិស្សដ្ឋតណ្ហាតិ អវីតតណ្ហាសេ ភវាភវេសុ ។ តេនាហ ភគវា

តបូបនិស្សាយ ជិគុច្ឆិតំ វា
អថវាបិ ទិដ្ឋំ វ សុតំ មុតំ វា
ឧទ្ធំសរា សុទ្ធិមនុត្ថុនន្តិ
អវីតតណ្ហាសេ ភវាភវេសូតិ ។

(៣១៦) បត្ថយមានស្ស ហិ ជប្បិតានិ
សំវេធិតំ វាបិ បកប្បិតេសុ
ចុតូបបាតោ ឥធ យស្ស នត្ថិ
ស កេន វេធេយ្យ កុហឹ ប ជប្បេ[១] ។

(៣១៧) បត្ថយមានស្ស ហិ ជប្បិតានីតិ បត្ថនា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។បេ។ អភិជ្ឈា លោភោ

---

១ ម. កុហឹ វជប្បេ ។

ក្ដីបដិសន្ធិរឿយ ៗ ក្ដីការកើតចំពោះនៃអត្តភាពរឿយ ៗ ។ ពាក្យថា មានតណ្ហាមិនទាន់ទៅប្រាស គឺមិនទាន់ប្រាសចាកតណ្ហា មិនទាន់ឃ្លាតចេញចាកតណ្ហា មិនទាន់លះតណ្ហា មិនទាន់ខ្ជាក់ចោលតណ្ហា មិនទាន់រួចចាកតណ្ហា មិនទាន់លះបង់តណ្ហា មិនទាន់រលាស់ចោលតណ្ហា ហេតុនោះ (ទ្រង់ត្រាស់ថា) មានតណ្ហាមិនទាន់ទៅប្រាស ក្នុងភពតូចភពធំទាំងឡាយ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ពួកសមណព្រាហ្មណ៍ជាទទ្ធំសកវាទ មានតណ្ហាមិនទាន់ទៅ
ប្រាស ក្នុងភពតូចភពធំទាំងឡាយ អាស្រ័យនូវសេចក្ដីខ្ពើម
(បាប)នោះ ឬអាស្រ័យនូវអារម្មណ៍ដែលខ្លួនឃើញ ឮ ឬប៉ះ
ពាល់ហើយ រមែងពោលសេចក្ដីបរិសុទ្ធ ។

(៣១៦) ការជាប់ចិត្តទាំងឡាយ នៃបុគ្គលកាលប្រាថ្នាក្ដី ការ
ញាប់ញ័រ ក្នុងធម៌ទាំងឡាយដែលខ្លួនកំណត់ហើយក្ដី ការ
ច្យុតិនិងការកើតក្ដី នៃបុគ្គលណា មិនមាន ក្នុងលោកនេះ
បុគ្គលនោះគប្បីញាប់ញ័រ ដោយកិលេសដូចម្ដេចកើត គប្បី
ជាប់ចិត្ត ក្នុងហេតុដូចម្ដេចកើត ។

(៣១៧) ពាក្យថា ការជាប់ចិត្តទាំងឡាយ នៃបុគ្គលកាលប្រាថ្នា សេចក្ដីថា តណ្ហា លោកហៅ សេចក្ដីប្រាថ្នា បានដល់ តម្រេក តម្រេក មានកំឡាំង ។ បេ ។ អភិជ្ឈា លោភៈ

អកុសលមូលំ ។ បត្ថយមានស្សាតិ បត្ថយមានស្ស ឥច្ឆមានស្ស សាទិយមានស្ស បិហយមានស្ស អភិជប្បយមានស្សាតិ បត្ថយមានស្ស ហិ ។ ជប្បិតានីតិ ជប្បា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។បេ។ អភិជ្ឈា លោភោ អកុសលមូលន្តិ បត្ថយមានស្ស ហិ ជប្បិតានិ ។

(៣១៨) សំវេធិតំ វាបិ បកប្បិតេសូតិ បកប្បនាតិ ទ្វេ បកប្បនា តណ្ហាបកប្បនា ច ទិដ្ឋិបកប្បនា ច ។បេ។ អយំ តណ្ហាបកប្បនា ។បេ។ អយំ ទិដ្ឋិបកប្បនា ។ វត្ថុអច្ឆេទសង្កិនោបិ(១) វេធេន្តិ អច្ឆិជ្ជន្តេបិ វេធេន្តិ អច្ឆិន្នេបិ វេធេន្តិ(២) វត្ថុវិបរិណាមសង្កិនោបិ វេធេន្តិ វិបរិណាមន្តេបិ វេធេន្តិ វិបរិណតេបិ វេធេន្តិ បវេធេន្តិ សម្បវេធេន្តីតិ សំវេធិតំ វាបិ បកប្បិតេសុ ។

---

១ អ. បវេធិតំ វាបិ បកប្បិតេសូតិ បកប្បិតំវត្ថុំ អច្ឆេទសង្កិនោបីតិ ទិស្សន្តិ ។ ២ ម. ឯកត្តរេ បកប្បិតន្តិ ទិស្សតិ ។

អកុសលមូល ។ ពាក្យថា កាលប្រាថ្នា គឺកាលត្រូវការ កាលចង់បាន កាលត្រេកអរ កាលស្រឡាញ់ កាលជាប់ចិត្ត ហេតុនោះ (ទ្រង់ត្រាស់ថា) កាលប្រាថ្នា ។ ពាក្យថា ការជាប់ចិត្តទាំងឡាយ សេចក្តីថា តណ្ហា លោកហៅថា ការជាប់ចិត្ត បានដល់ តម្រេក តម្រេក មានកំឡាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ហេតុនោះ (ទ្រង់ត្រាស់ថា) ការជាប់ចិត្តទាំងឡាយ នៃបុគ្គលកាលប្រាថ្នា ។

(៣១៨) ពាក្យថា ការញាប់ញ័រ ក្នុងធម៌ទាំងឡាយ ដែលខ្ញុំកំណត់ទុកហើយក្តី ពាក្យថា ការកំណត់ បានដល់ ការកំណត់ ២ ការកំណត់គឺតណ្ហា ១ ការកំណត់គឺទិដ្ឋិ ១ ។ បេ ។ នេះ ការកំណត់គឺតណ្ហា ។ បេ ។ នេះការកំណត់គឺទិដ្ឋិ ។ ជនទាំងឡាយ មានសេចក្តីរង្កៀស ក្នុងការដណ្តើមយកនូវវត្ថុ រមែងញាប់ញ័រ ក៏មាន កាលវត្ថុដែលគេកំពុងដណ្តើម រមែងញាប់ញ័រ ក៏មាន កាលវត្ថុត្រូវគេដណ្តើមហើយ រមែងញាប់ញ័រ ក៏មាន ជនទាំងឡាយមានសេចក្តីរង្កៀសក្នុងការប្រែប្រួលនៃវត្ថុ រមែងញាប់ញ័រ ក៏មាន កាលវត្ថុកំពុងប្រែប្រួល រមែងញាប់ញ័រក៏មាន កាលវត្ថុប្រែប្រួលហើយ រមែងញាប់ញ័រ ញាប់ញ័រខ្លាំង ញាប់ញ័រចំប្រប់ក៏មាន ហេតុនោះ (ទ្រង់ត្រាស់ថា) ការញាប់ញ័រ ក្នុងធម៌ទាំងឡាយ ដែលខ្ញុំកំណត់ហើយក្តី ។

(៣១៩) ចុតូបបាតោ ឥធ យស្ស នត្ថីតិ យស្សាតិ អរហតោ ខីណាសវស្ស អាគមនំ គមនំ(១) គមនាគមនំ កាលំ គតិ ភវាភវោ ចុតិ ច ឧបបត្តិ ច និព្វត្តិ ច ភេទោ ច ជាតិជរាមរណំ នត្ថិ ន សន្តិ ន សំវិជ្ជន្តិ នុបលព្ភន្តិ បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍាតិ ចុតូបបាតោ ឥធ យស្ស នត្ថិ ។

(៣២០) ស កេន វជ្ជេយ្យ កុហឹ ច ជប្បេតិ សោ កេន រាគេន វជ្ជេយ្យ កេន ទោសេន វជ្ជេយ្យ កេន មោហេន វជ្ជេយ្យ កេន មានេន វជ្ជេយ្យ កាយ ទិដ្ឋិយា វជ្ជេយ្យ កេន ឧទ្ធច្ចេន វជ្ជេយ្យ កាយ វិចិកិច្ឆាយ វជ្ជេយ្យ កេហិ អនុសយេហិ វជ្ជេយ្យ រត្តោតិ វា ទុដ្ឋោតិ វា មូឡ្ហោតិ វា វិនិពទ្ធោតិ វា បរាមដ្ឋោតិ វា វិក្ខេបគតោតិ វា អនិដ្ឋង្គតោតិ វា ថាមគតោតិ វា ។

---

១ ម. យស្ស គមនំ អាគមនន្តិ ទិស្សតិ ។

(៣១៩) ពាក្យថា ការច្យុតិនឹងការកើត នៃបុគ្គលណាមិនមាន ក្នុងលោកនេះ ត្រង់ពាក្យថា នៃបុគ្គលណា សេចក្តីថា ការមក ការទៅ ការទៅនឹងការមក មរណកាល ដំណើរ កពត្តូចកពធំ ការច្យុតិ ការឧបបត្តិ ការកើតនឹងការបែកធ្លាយ ជាតិជរាមរណៈ នៃព្រះអរហន្តខីណាស្រព មិនមាន គ្មាន ឥតមានសោះ មិនកើតមាន គឺលោកលះបង់ហើយ ផ្តាច់បង់ហើយ រម្ងាប់ហើយ ស្ងប់ស្ងាត់ហើយ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ការច្យុតិនឹងការកើតនៃបុគ្គលណា មិនមាន ក្នុងលោកនេះ ។

(៣២០) ពាក្យថា បុគ្គលនោះ គប្បីញាប់ញ័រដោយកិលេសដូចម្តេចកើត គប្បីជាប់ចិត្តក្នុងហេតុដូចម្តេចកើត អធិប្បាយថា បុគ្គលនោះ គប្បីញាប់ញ័រដោយរាគៈដូចម្តេច គប្បីញាប់ញ័រដោយទោសៈដូចម្តេច គប្បីញាប់ញ័រដោយមោហៈដូចម្តេច គប្បីញាប់ញ័រដោយមានះដូចម្តេច គប្បីញាប់ញ័រដោយទិដ្ឋិដូចម្តេច គប្បីញាប់ញ័រដោយឧទ្ធច្ចៈដូចម្តេច គប្បីញាប់ញ័រដោយវិចិកិច្ឆាដូចម្តេច គប្បីញាប់ញ័រដោយអនុស័យដូចម្តេចកើត ថាបុគ្គលនោះ ជាអ្នកត្រេកអរក្តី ជាជាអ្នកប្រទូស្តក្តី ជាជាអ្នកវង្វេងក្តី ជាជាអ្នកជាប់ចំពាក់ក្តី ជាជាអ្នកស្ទាបអង្អែលក្តី ជាជាអ្នកដល់នូវការរាយមាយក្តី ជាជាអ្នកដល់នូវសេចក្តីមិនដាច់ស្រេចក្តី ជាជាអ្នកដល់នូវកំឡាំងក្តី ។

តេ អភិសង្ខតា បកីណា អភិសង្ខតំ បកីណត្តា គតិយោ កេន វទេយ្យ[១] នេរយិកោតិ វា តិរច្ឆានយោនិកោតិ វា បិត្តិវិសយិកោតិ វា មនុស្សោតិ វា ទេវោតិ វា រូបីតិ វា អរូបីតិ វា សញ្ញីតិ វា អសញ្ញីតិ វា នេវសញ្ញីនាសញ្ញីតិ វា ។ សោ ហេតុ នត្ថិ បច្ចយោ នត្ថិ ការណំ នត្ថិ យេន វទេយ្យ បវទេយ្យ សម្បវទេយ្យាតិ ស កេន វទេយ្យ ។ កុហឹ បជប្បេតិ កម្ហិ ជប្បេយ្យ[២] បជប្បេយ្យ អភិជប្បេយ្យាតិ ស កេន វទេយ្យ កុហឹ បជប្បេ ។

តេនាហ ភគវា

បត្ថយមានស្ស ហិ ជប្បិតានិ
សំវេធិតំ វាបិ បកប្បិតេសុ
ចុតូបបាតោ ឥធ យស្ស នត្ថិ

---

១ ឱ. ឯត្តកេ បវទេយ្យាតិ ទិស្សតិ ។ ២ ម. កុហឹ វេជប្បេតិ កុហឹ វា ជប្បេយ្យ កិម្ហិ ជប្បេយ្យ កត្ថ ជប្បេយ្យ ។ ឱ. កត្ថ ជប្បេយ្យ ។

អភិសង្ខារទាំងឡាយនោះ បុគ្គលនោះ លះបង់ហើយ ព្រោះលះបង់អភិសង្ខាររួចហើយ លោកគប្បីញាប់ញ័រ ដោយហេតុដូចម្តេច ព្រោះគតិថា អាត្មាអញកើតក្នុងនរកក្តី ថាកើតក្នុងកំណើតតិរច្ឆានក្តី ថាកើតក្នុងប្រេតវិស័យក្តី ថាកើតជាមនុស្សក្តី ថាកើតជាទេវតាក្តី ថាកើតជារូបព្រហ្មក្តី ថាកើតជាអរូបព្រហ្មក្តី ថាកើតជាសញ្ញីព្រហ្មក្តី ថាកើតជាអសញ្ញីព្រហ្មក្តី ថាកើតជានេវសញ្ញីនាសញ្ញីព្រហ្មក្តី ។ បុគ្គលនោះគប្បីញាប់ញ័រ គប្បីញាប់ញ័រខ្លាំង គប្បីញាប់ញ័រចំប្រប់ ដោយហេតុណា ហេតុនោះមិនមាន បច្ច័យនោះមិនមាន ការណ៍នោះមិនមាន ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះគប្បីញាប់ញ័រដោយកិលេសដូចម្តេច ។ ពាក្យថា គប្បីជាប់ចិត្តក្នុងហេតុដូចម្តេចកើត គឺគប្បីជាប់ចិត្ត គប្បីជាប់ចិត្តខ្លាំង គប្បីជាប់ចិត្តចំពោះ ក្នុងហេតុដូចម្តេចកើត ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ គប្បីញាប់ញ័រដោយកិលេសដូចម្តេចកើត គប្បីជាប់ចិត្តក្នុងហេតុដូចម្តេចកើត ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ការជាប់ចិត្តទាំងឡាយ នៃបុគ្គលកាលប្រាថ្នាក្តី ការញាប់
ញ័រក្នុងធម៌ទាំងឡាយដែលខ្លួនកំណត់ហើយក្តី ការច្យុតិនឹង
ការកើតក្តី នៃបុគ្គលណា មិនមាន ក្នុងលោកនេះ

ស កោធ វេឆយ្យ កុហំ បជហេយ្យាតិ ។

(៣៦១) យមាហុ ធម្មំ បរមន្តិ ឯកេ

តមេវ ហីនន្តិ បនាហុ អញ្ញេ

សច្ចោ នុ វាទោ កតមោ ឥមេសំ

សព្វេវ ហីមេ កុសលាវទានា ។

(៣៦២) យមាហុ ធម្មំ បរមន្តិ ឯកេតិ យំ ធម្មំ ទិដ្ឋឹ បដិបទំ មគ្គំ ឯកេ សមណព្រាហ្មណា ឥទំ បរមំ អគ្គំ សេដ្ឋំ វិសេដ្ឋំ បាមោក្ខំ ឧត្តមំ បវរន្តិ ឯវមាហំសុ ឯវំ កថេន្តិ ឯវំ ភណន្តិ ឯវំ ទីបយន្តិ ឯវំ វោហរន្តីតិ យមាហុ ធម្មំ បរមន្តិ ឯកេ ។

(៣៦៣) តមេវ ហីនន្តិ បនាហុ អញ្ញេតិ តមេវ ធម្មំ ទិដ្ឋឹ បដិបទំ មគ្គំ ឯកេ សមណព្រាហ្មណា ហីនំ ឯតំ

បុគ្គលនោះ គប្បីញាប់ញ័រដោយកិលេស ដូចម្ដេចកើត គប្បីជាប់ចិត្តក្នុងហេតុដូចម្ដេចកើត ។

(៣៦១) សមណព្រាហ្មណ៍ពួកមួយ បានពោលធម៌ណា ថាឧត្តម ចំណែកសមណព្រាហ្មណ៍ ពួកដទៃ បានពោលធម៌នោះឯង ថាថោកទាប ពាក្យរបស់សមណព្រាហ្មណ៍ទាំងនេះ តើពាក្យណា ជាពាក្យពិត ព្រោះថា សមណព្រាហ្មណ៍ទាំងនេះ ជាអ្នកប្រកាន់ថាឈ្លាសវៃទាំងអស់គ្នា ។

(៣៦២) ពាក្យថា សមណព្រាហ្មណ៍ ពួកមួយ បានពោលធម៌ណាថាឧត្តម គឺសមណព្រាហ្មណ៍ពួកមួយ បានពោលយ៉ាងនេះ សំដែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ បំភ្លឺយ៉ាងនេះ ថ្លែងយ៉ាងនេះ នូវធម៌ គឺទិដ្ឋិ បដិបទា មគ្គណា ថានេះជាធម៌ដ៏ឧត្តម ខ្ពង់ខ្ពស់ ប្រសើរ ប្រសើរបំផុត ជាប្រធាន ថ្លៃថ្លា ប្រសើរក្រៃលែង ហេតុនោះ (ទ្រង់ត្រាស់ថា) សមណព្រាហ្មណ៍ពួកមួយ បានពោលធម៌ណាថាឧត្តម ។

(៣៦៣) ពាក្យថា ចំណែកសមណព្រាហ្មណ៍ពួកដទៃ បានពោលធម៌នោះឯង ថាថោកទាប គឺសមណព្រាហ្មណ៍ពួកមួយ បានពោលយ៉ាងនេះ សំដែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ បំភ្លឺយ៉ាងនេះ ថ្លែងយ៉ាងនេះ នូវធម៌ គឺទិដ្ឋិ បដិបទា មគ្គ នោះឯង ថាធម៌នេះថោកទាប

និហីនំ ឯតំ ឱមកំ ឯតំ លាមកំ ឯតំ ឆតុក្កំ ឯតំ បរិត្តកំ ឯតន្តិ ឯវមាហំសុ ឯវំ កថេន្តិ ឯវំ ភណន្តិ ឯវំ ទីបយន្តិ ឯវំ វោហរន្តីតិ តមេវ ហីនន្តិ បនាហុ អញ្ញំ ។

(៣២៤) សច្ចោ នុ វាទោ កតមោ ឥមេសន្តិ ឥមេសំ សមណព្រាហ្មណានំ វាទោ កតមោ សច្ចោ តច្ឆោ តថោ ភូតោ យាថាវោ អវិបរីតោតិ សច្ចោ នុ វាទោ កតមោ ឥមេសំ ។

(៣២៥) សព្វេវ ហីមេ កុសលាវទានាតិ សព្វេវ ហីមេ សមណព្រាហ្មណា កុសលវាទា បណ្ឌិតវាទា ធីរវាទា ញាណវាទា ហេតុវាទា លក្ខណវាទា ការណវាទា ឋានវាទា សកាយ លទ្ធិយាតិ សព្វេវ ហីមេ កុសលាវទានា ។ តេនាហ ភគវា[១]

---

១ ម. តេនាហ សោ និម្មិតោ ។

ធម៌នេះថោកទាបពេក ធម៌នេះទន់ទាប ធម៌នេះលាមក ធម៌នេះអាក្រក់ ធម៌នេះស្តួចស្តើង ហេតុនោះ (ទ្រង់ត្រាស់ថា) ចំណែកសមណព្រាហ្មណ៍ពួកដទៃ បានពោលធម៌នោះឯងថាថោកទាប ។

(៣៤៨) ពាក្យថា ពាក្យរបស់សមណព្រាហ្មណ៍ ទាំងនេះ តើពាក្យណាជាពាក្យពិត គឺពាក្យរបស់សមណព្រាហ្មណ៍ទាំងនេះ តើពាក្យណា ជាពាក្យពិត ទៀងទាត់ មិនឃៀងឃ្លាត ប្រាកដ ពិតប្រាកដ មិនប្រែប្រួល ហេតុនោះ (ទ្រង់ត្រាស់ថា) ពាក្យរបស់សមណព្រាហ្មណ៍ទាំងនេះ តើពាក្យណា ជាពាក្យពិត ។

(៣៤៩) ពាក្យថា ព្រោះថាសមណព្រាហ្មណ៍ទាំងនេះ ប្រកាន់ថាឈ្លាសវៃទាំងអស់គ្នា គឺសមណព្រាហ្មណ៍ទាំងអស់នេះ ជាអ្នកមានវាទៈថាឈ្លាសវៃ មានវាទៈថាជាបណ្ឌិត មានវាទៈថាជាអ្នកប្រាជ្ញ មានវាទៈប្រកបដោយញាណ មានវាទៈប្រកបដោយហេតុ មានវាទៈប្រកបដោយលក្ខណៈ មានវាទៈប្រកបដោយការណ៍ មានវាទៈប្រកបដោយឋានៈ ក្នុងលទ្ធិរបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះថាសមណៈព្រាហ្មណ៍ទាំងនេះ ជាអ្នកប្រកាន់ថាឈ្លាសវៃទាំងអស់គ្នា ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

យមាហុ ធម្មំ បរមន្តិ ឯកេ

តមេវ ហីនន្តិ បនាហុ អញ្ញេ

សច្ចោ នុ វាទោ កតមោ ឥមេសំ

សព្វេវ ហីមេ កុសលាវទានា ។

(៣២៦) សកំ ហិ ធម្មំ បរិបុណ្ណមាហុ

អញ្ញស្ស ធម្មំ បន ហីនមាហុ

ឯវម្បិ វិគ្គយ្ហ វិវាទយន្តិ

សកំ សកំ សម្មុតិមាហុ សច្ចំ ។

(៣២៧) សកំ ហិ ធម្មំ បរិបុណ្ណមាហូតិ សកំ ហិ ធម្មំ ទិដ្ឋឹ បដិបទំ មគ្គំ ឯកេ សមណព្រាហ្មណា ឥទំ សមត្តំ បរិបុណ្ណំ អនោមន្តិ ឯវមាហំសុ ឯវំ ភាសេន្តិ ឯវំ កថេន្តិ ឯវំ ទីបយន្តិ ឯវំ វោហរន្តីតិ សកំ ហិ ធម្មំ បរិបុណ្ណមាហុ ។

សមណព្រាហ្មណ៍ពួកមួយ បានពោលធម៌ណា ថាឧត្តម
ចំណែកសមណព្រាហ្មណ៍ពួកដទៃ បានពោលធម៌នោះឯង
ថាថោកទាប ពាក្យរបស់សមណព្រាហ្មណ៍ទាំងនេះ តើ
ពាក្យណា ជាពាក្យពិត ព្រោះថា សមណព្រាហ្មណ៍
ទាំងនេះ ជាអ្នកប្រកាន់ថាឈ្លាសវៃទាំងអស់គ្នា ។

(៣២៦) សមណព្រាហ្មណ៍ទាំងឡាយ បានពោលធម៌របស់
ខ្លួនថាបរិបូណ៌ បានពោលធម៌របស់ជនដទៃថាថោកថយ
(សមណព្រាហ្មណ៍ទាំងឡាយ) ប្រកាន់យ៉ាងនេះ រមែង
ទាស់ទែងគ្នា បានពោលនូវសម្មតិរបស់ខ្លួនៗ ថាពិត ។

(៣២៧) ពាក្យថា សមណព្រាហ្មណ៍ពួកមួយ បានពោលធម៌របស់ខ្លួនថាបរិបូណ៌ គឺសមណព្រាហ្មណ៍ពួកមួយ បានពោលយ៉ាងនេះ សំដែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ បំភ្លឺយ៉ាងនេះ ថ្លែងយ៉ាងនេះ នូវធម៌ គឺ ទិដ្ឋិ បដិបទា មគ្គ របស់ខ្លួនថា ធម៌នេះពេញលេញ បរិបូណ៌ មិនថោកថយ ហេតុនោះ (ទ្រង់ត្រាស់ថា) សមណព្រាហ្មណ៍ពួកមួយ បានពោលធម៌របស់ខ្លួនថាបរិបូណ៌ ។

(៣២៨) អញ្ញស្ស ធម្មំ បន ហីនមាហូតិ អញ្ញស្ស ធម្មំ ទិដ្ឋឹ បដិបទំ មគ្គំ ឯកេ សមណព្រាហ្មណា ហីនំ ឯតំ និហីនំ ឯតំ ឱមកំ ឯតំ លាមកំ ឯតំ ឆតុក្កំ ឯតំ បរិត្តកំ ឯតន្តិ ឯវមាហំសុ ឯវំ កថេន្តិ ឯវំ ភណន្តិ ឯវំ ទីបយន្តិ ឯវំ វោហរន្តីតិ អញ្ញស្ស ធម្មំ បន ហីនមាហុ ។

(៣២៩) ឯវម្បិ វិគ្គយ្ហ វិវាទយន្តីតិ ឯវំ គហេត្វា គណ្ហិត្វា(១) បរាមសិត្វា អភិនិវិសិត្វា វិវាទយន្តិ កលហំ ករោន្តិ ភណ្ឌនំ ករោន្តិ វិគ្គហំ ករោន្តិ វិវាទំ ករោន្តិ មេធគំ ករោន្តិ ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ ។បេ។ និព្ពេឋេហិ វា សចេ បហោសីតិ ឯវម្បិ វិគ្គយ្ហ វិវាទយន្តិ ។

(៣៣០) សកំ សកំ សម្មតិមាហុ សច្ចន្តិ សស្សតោ លោកោ ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ សកំ សកំ សម្មតិមាហុ សច្ចំ ។ តេនាហ ភគវា

---

១ ម. ឧគ្គហេត្វា គណ្ហិត្វា ។

មហាវិយូហសុត្តនិទ្ទេស ទី ១៣

(៣២៨) ពាក្យថា បានពោលធម៌ របស់ជនដទៃថាថោកថយ គឺសមណព្រាហ្មណ៍ពួកមួយ បានពោលយ៉ាងនេះ សំដែងយ៉ាងនេះ ពណ៌នាយ៉ាងនេះ បំភ្លឺយ៉ាងនេះ ថ្លែងយ៉ាងនេះ នូវធម៌គឺទិដ្ឋិ បដិបទា មគ្គ របស់ជនដទៃថា នេះថោកទាប នេះថោកទាបពេក នេះទន់ទាប នេះលាមក នេះអាក្រក់ នេះស្ដួចស្ដើង ហេតុនោះ (ទ្រង់ត្រាស់ថា) បានពោលធម៌ របស់ជនដទៃថាថោកទាប ។

(៣២៩) ពាក្យថា ប្រកាន់យ៉ាងនេះ រមែងទាស់ទែងគ្នា គឺកាន់យក ប្រកាន់ ស្ទាបអង្អែល ប្រកាន់ស្អិតយ៉ាងនេះ រមែងទាស់ទែងគ្នា គឺធ្វើនូវជម្លោះ ធ្វើនូវការប្រកាន់ ធ្វើនូវការទាស់ទែង ធ្វើនូវការវិវាទ ធ្វើនូវការបែកខ្ញែកគ្នាថា អ្នកមិនយល់ធម៌វិន័យនេះទេ ។ បេ ។ បើអ្នកអាច ចូរអ្នកដោះចុះ ហេតុនោះ (ទ្រង់ត្រាស់ថា) ប្រកាន់យ៉ាងនេះ រមែងទាស់ទែងគ្នា ។

(៣៣០) ពាក្យថា បានពោលនូវសម្មតិរបស់ខ្លួនៗថាពិត គឺថាលោកទៀង ។ បេ ។ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះពិត ពាក្យដទៃជាមោឃៈ ហេតុនោះ (ទ្រង់ត្រាស់ថា) បានពោលនូវសម្មតិរបស់ខ្លួនៗថាពិត ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

សកំ ហិ ធម្មំ បរិបុណ្ណមាហុ
អញ្ញស្ស ធម្មំ បន ហីនមាហុ
ឯវម្បិ វិគ្គយ្ហ វិវាទយន្តិ
សកំ សកំ សម្មុតិមាហុ សច្ចន្តិ ។

(៣៣១) បរស្ស ចេ វម្ភយិតេន ហីនោ
ន កោចិ ធម្មេសុ វិសេសិ អស្ស
បុថូ ហិ អញ្ញស្ស វទន្តិ ធម្មំ
និហីនតោ សម្ហិ ទឡ្ហំ វទានា ។

(៣៣២) បរស្ស ចេ វម្ភយិតេន ហីនោតិ បរស្ស ចេ វម្ភយិតការណា និន្ទិតការណា គរហិតការណា ឧបវទិតការណា បរេន ពាលោ ហោតិ ហីនោ និហីនោ ឱមកោ លាមកោ ឆតុក្កោ បរិត្តោតិ បរស្ស ចេ វម្ភយិតេន ហីនោ ។

(៣៣៣) ន កោចិ ធម្មេសុ វិសេសិ អស្សាតិ ធម្មេសុ ន កោចិ អគ្គោ សេដ្ឋោ វិសេដ្ឋោ បាមោក្ខោ ឧត្តមោ បវរោ អស្សាតិ ន កោចិ ធម្មេសុ វិសេសិ អស្ស ។

(សមណព្រាហ្មណ៍ទាំងឡាយ) បានពោលធម៌របស់ខ្លួន
ថាបរិបូណ៌ បានពោលធម៌របស់ជនដទៃ ថាថោកថយ
(សមណព្រាហ្មណ៍ទាំងឡាយ) ប្រកាន់យ៉ាងនេះ រមែង
ទាស់ទែងគ្នា បានពោលនូវសម្មតិរបស់ខ្លួនៗ ថាពិត ។

(៣៣១) ប្រសិនបើបុគ្គលជាអ្នកថោកថយ ព្រោះហេតុបុគ្គលដទៃ
បន្តុះបង្អាប់ មិនមានបុគ្គលណាមួយ វិសេសក្នុងធម៌ទាំង
ឡាយទេ ព្រោះថាបុគ្គលច្រើននាក់ ជាអ្នកមានវាទៈដ៏មាំ
ក្នុងផ្លូវរបស់ខ្លួន តែងពោលធម៌របស់ជនដទៃថាថោកទាប ។

(៣៣២) ពាក្យថា ប្រសិនបើបុគ្គលជាអ្នកថោកថយ ព្រោះហេតុបុគ្គលដទៃ បន្តុះបង្អាប់ គឺប្រសិនបើបុគ្គលជាអ្នកផ្ដេសផ្ដាស ពាល ថោកថយ ថោកទាប ទន់ទាប លាមក អាក្រក់ ស្ដួចស្ដើង ព្រោះហេតុតែបុគ្គលដទៃបន្តុះបង្អាប់ ព្រោះហេតុតែបុគ្គលដទៃនិន្ទា ព្រោះហេតុតែបុគ្គលដទៃតិះដៀល ព្រោះហេតុតែបុគ្គលដទៃដេរ ហេតុនោះ (ទ្រង់ត្រាស់ថា) ប្រសិនបើបុគ្គលជាអ្នកថោកថយ ព្រោះហេតុបុគ្គលដទៃបន្តុះបង្អាប់ ។

(៣៣៣) ពាក្យថា មិនមានបុគ្គលណាមួយវិសេស ក្នុងធម៌ទាំងឡាយ គឺមិនមានបុគ្គលណាមួយ ថ្លៃថ្លា ប្រសើរ វិសេស ជាប្រធានដ៏ឧត្តម ប្រសើរក្រៃលែង ក្នុងធម៌ទាំងឡាយទេ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនមានបុគ្គលណាមួយ វិសេសក្នុងធម៌ទាំងឡាយ ។

(៣៣៨) បុថូ ហិ អញ្ញស្ស វទន្តិ ធម្មំ និហីនតោតិ ពហុកាបិ ពហុន្នំ ធម្មំ វទន្តិ ឧបវទន្តិ និន្ទន្តិ គរហន្តិ ហីនតោ និហីនតោ ឱមកតោ លាមកតោ ឆតុក្កតោ បរិត្តតោ ពហុកាបិ ឯកស្ស ធម្មំ វទន្តិ ឧបវទន្តិ និន្ទន្តិ គរហន្តិ ហីនតោ និហីនតោ ឱមកតោ លាមកតោ ឆតុក្កតោ បរិត្តតោ ឯកកោបិ ពហុន្នំ ធម្មំ វទតិ ឧបវទតិ និន្ទតិ គរហតិ ហីនតោ និហីនតោ ឱមកតោ លាមកតោ ឆតុក្កតោ បរិត្តតោ ឯកកោបិ ឯកស្ស ធម្មំ វទតិ ឧបវទតិ និន្ទតិ គរហតិ ហីនតោ និហីនតោ ឱមកតោ លាមកតោ ឆតុក្កតោ បរិត្តតោតិ បុថូ ហិ អញ្ញស្ស វទន្តិ ធម្មំ និហីនតោ ។

(៣៣៩) សម្ហិ ទឡ្ហំវទានាតិ ធម្មោ សកាយនំ ទិដ្ឋិ សកាយនំ បដិបទា សកាយនំ មគ្គោ សកាយនំ ។ សកាយនេ ទឡ្ហវាទា ថិរវាទា ពលិកវាទា អវដ្ឋិតវាទាតិ សម្ហិ(១) ទឡ្ហំវទានា ។ តេនាហ ភគវា

១ ម. និហីនតោ សម្ហិ ។

(៣៣៤) ពាក្យថា ព្រោះថាបុគ្គលច្រើននាក់ តែងពោលធម៌របស់ជនដទៃថា ថោកទាប គឺបុគ្គលច្រើននាក់ ពោលគឺ និន្ទា តិះដៀល នូវធម៌របស់ជនច្រើននាក់ ថាថោកទាប ថោកទាបពេក ទន់ទាប លាមក អាក្រក់ សួចស្តើងក៏មាន បុគ្គលច្រើននាក់ ពោលគឺ និន្ទា តិះដៀល នូវធម៌របស់ជនម្នាក់ថាថោកទាប ថោកទាបពេក ទន់ទាប លាមក អាក្រក់ សួចស្តើងក៏មាន បុគ្គលម្នាក់ ពោលគឺ និន្ទា តិះដៀល នូវធម៌របស់ជនច្រើននាក់ថាថោកទាប ថោកទាបពេក ទន់ទាប លាមក អាក្រក់ សួចស្តើង ក៏មាន បុគ្គលម្នាក់ ពោល គឺ និន្ទា តិះដៀល នូវធម៌របស់ជនម្នាក់ ថាថោកទាប ថោកទាបពេក ទន់ទាប លាមក អាក្រក់ សួចស្តើងក៏មាន ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះថាបុគ្គលច្រើននាក់ តែងពោលធម៌របស់ជនដទៃថាថោកទាប ។

(៣៣៥) ពាក្យថា ជាអ្នកមានវាទៈដ៏មាំក្នុងផ្លូវរបស់ខ្លួន គឺធម៌ឈ្មោះថាផ្លូវរបស់ខ្លួន ទិដ្ឋិឈ្មោះថាផ្លូវរបស់ខ្លួន បដិបទាឈ្មោះថាផ្លូវរបស់ខ្លួន មគ្គឈ្មោះថាផ្លូវរបស់ខ្លួន ។ ជាអ្នកមានវាទៈដ៏មាំ មានវាទៈទៀងទាត់ មានវាទៈដ៏មានកំឡាំង មានវាទៈតាំងនៅស៊ប់ ក្នុងផ្លូវរបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកមានវាទៈដ៏មាំក្នុងផ្លូវរបស់ខ្លួន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បរស្ស ចេ វម្ភយិតេន ហីនោ
ន កោចិ ធម្មេសុ វិសេសិ អស្ស
បុថូ ហិ អញ្ញស្ស វទន្តិ ធម្មំ
និហីនតោ សម្ហិ ទឡ្ហំ វទានា ។

(៣៣៦) សធម្មបូជា ច បនា តថេវ
យថា បសំសន្តិ សកាយនានិ
សព្វេ បវាទា(១) តថិវា ភវេយ្យុំ
សុទ្ធី ហិ នេសំ បច្ចត្តមេវ ។

(៣៣៧) សធម្មបូជា ច បនា តថេវាតិ កតមា សធម្មបូជា ។ សកំ សត្ថារំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ អយំ សត្ថា សព្វញ្ញូតិ អយំ សធម្មបូជា ។ សកំ ធម្មក្ខានំ សកំ គណំ សកំ ទិដ្ឋឹ សកំ បដិបទំ សកំ មគ្គំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ អយំ មគ្គោ និយ្យានិកោតិ អយំ សធម្មបូជា ។ សធម្មបូជា ច បនា តថេវាតិ សធម្មបូជា តថា តច្ឆា ភូតា យាថាវា អវិបរីតាតិ សធម្មបូជា ច បនា តថេវ ។

---

១ ម. វិវាទ ។

ប្រសិនបើបុគ្គលជាអ្នកថោកថយ ព្រោះហេតុបុគ្គលដទៃបន្តុះ
បង្អាប់ មិនមានបុគ្គលណាមួយវិសេស ក្នុងធម៌ទាំងឡាយទេ
ព្រោះថាបុគ្គលច្រើននាក់ ជាអ្នកមានវាទៈដ៏មាំក្នុងផ្លូវរបស់ខ្លួន
តែងពោលធម៌របស់ជនដទៃថាថោកទាប ។

(៣៣៦) ការបូជាធម៌របស់ខ្លួន ជាការមានពិត ព្រោះថា
តិត្ថិយទាំងឡាយ តែងសរសើរផ្លូវទាំងឡាយរបស់ខ្លួន បើ
វាទៈទាំងអស់ គប្បីជាវាទៈពិត ម្ល៉េះសម សេចក្តីបរិសុទ្ធិ
នៃជនទាំងឡាយនោះ មានប្រាកដ ។

(៣៣៧) អធិប្បាយពាក្យថា ការបូជាធម៌របស់ខ្លួន ជាការមានពិត សំនួរថា ចុះការបូជាធម៌របស់ខ្លួន តើដូចម្តេច ។ បុគ្គលធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់អាន បូជា នូវសាស្តារបស់ខ្លួនថា សាស្តានេះជាសព្វញ្ញូ នេះឈ្មោះថាការបូជាធម៌របស់ខ្លួន ។ ធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់អាន បូជា នូវធម៌របស់ខ្លួនដែលសាស្តានោះពោលហើយ នូវគណៈរបស់ខ្លួន នូវទិដ្ឋិរបស់ខ្លួន នូវបដិបទារបស់ខ្លួន នូវមគ្គរបស់ខ្លួនថា មគ្គនេះជាទីស្រោចស្រង់ នេះឈ្មោះថា ការបូជាធម៌របស់ខ្លួន ។ ពាក្យថា ការបូជាធម៌របស់ខ្លួន ជាការមានពិត បានសេចក្តីថា ការបូជាធម៌របស់ខ្លួន ដោយប្រការដូច្នោះ ជាការបូជាមិនឃ្លៀងឃ្លាត ប្រាកដ ពិតប្រាកដ មិនប្រែប្រួល ហេតុនោះ (ទ្រង់ត្រាស់ថា) ការបូជាធម៌របស់ខ្លួន ជាការមានពិត ។

## តេរសមោ មហាវិយូហសុត្តនិទ្ទេសោ

(៣៣៨) យថា បសំសន្តិ សកាយនានីតិ ធម្មោ សកាយនំ ទិដ្ឋិ សកាយនំ បដិបទា សកាយនំ មគ្គោ សកាយនំ ។ សកាយនានិ បសំសន្តិ ថោមេន្តិ កិត្តេន្តិ វណ្ណេន្តីតិ យថា បសំសន្តិ សកាយនានិ ។

(៣៣៩) សព្វេ បវាទា តថិវ ភវេយ្យុន្តិ សព្វេ បវាទា តថា តច្ឆា ភូតា យាថាវា អវិបរីតា ភវេយ្យុន្តិ សព្វេ បវាទា តថិវ ភវេយ្យុំ ។

(៣៤០) សុទ្ធី ហិ(១) នេសំ បច្ចត្តមេវាតិ បច្ចត្តមេវ តេសំ សមណព្រាហ្មណានំ សុទ្ធិ វិសុទ្ធិ បរិសុទ្ធិ មុត្តិ វិមុត្តិ បរិមុត្តីតិ សុទ្ធី ហិ(២) នេសំ បច្ចត្តមេវ ។ តេនាហ ភគវា

សទ្ធម្មបូជា ច បនា តថេវ
យថា បសំសន្តិ សកាយនានិ
សព្វេ បវាទា តថិវ ភវេយ្យុំ
សុទ្ធី ហិ(៣) នេសំ បច្ចត្តមេវាតិ ។

---

១. ២. ៣. ម. បិ ។

(៣៣៨) ពាក្យថា ព្រោះថា ជនទាំងឡាយ តែងសរសើរនូវផ្លូវរបស់ខ្លួនទាំងឡាយ សេចក្តីថា ធម៌ឈ្មោះថាផ្លូវរបស់ខ្លួន ទិដ្ឋិឈ្មោះថាផ្លូវរបស់ខ្លួន បដិបទាឈ្មោះថាផ្លូវរបស់ខ្លួន មគ្គឈ្មោះថាផ្លូវរបស់ខ្លួន ។ ជនទាំងឡាយតែងសរសើរ ស្ងើប កោត ពណ៌នា នូវផ្លូវរបស់ខ្លួនទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះថា ជនទាំងឡាយ តែងសរសើរនូវផ្លូវរបស់ខ្លួន ។

(៣៣៩) ពាក្យថា បើ វាទៈទាំងអស់ គប្បីជាវាទៈពិត គឺបើវាទៈទាំងអស់ ជាវាទៈពិត មិនឃ្លៀតឃ្លាត ប្រាកដ ពិតប្រាកដ មិនប្រែប្រួល ហេតុនោះ (ទ្រង់ត្រាស់ថា) បើវាទៈទាំងអស់ គប្បីជាវាទៈពិត ។

(៣៤០) ពាក្យថា ម្ល៉េះសម សេចក្តីបរិសុទ្ធិ នៃជនទាំងឡាយនោះ (មាន) ប្រាកដ គឺសេចក្តីស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ នៃសមណព្រាហ្មណ៍ទាំងនោះ (មាន) ប្រាកដ ហេតុនោះ (ទ្រង់ត្រាស់ថា) ម្ល៉េះសម សេចក្តីបរិសុទ្ធិ នៃជនទាំងឡាយនោះ(មាន) ប្រាកដ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ការបូជាធម៌របស់ខ្លួន ជាការមានពិត ព្រោះថា តិត្ថិយទាំង
ឡាយ តែងសរសើរផ្លូវទាំងឡាយរបស់ខ្លួន បើវាទៈ
ទាំងអស់ គប្បីជាវាទៈពិត ម្ល៉េះសម សេចក្តីបរិសុទ្ធិនៃជន
ទាំងឡាយ នោះ (មាន) ប្រាកដ ។

(៣៤១) ន ព្រាហ្មណស្ស បរនេយ្យមត្ថិ
ធម្មេសុ និច្ឆេយ្យ សមុគ្គហីតំ
តស្មា វិវាទានិ ឧបាតិវត្តោ
ន ហិ សេដ្ឋតោ បស្សតិ ធម្មមញ្ញំ ។

(៣៤២) ន ព្រាហ្មណស្ស បរនេយ្យមត្ថីតិ នាតិ បដិក្ខេបោ ។ ព្រាហ្មណោតិ សត្តន្នំ ធម្មានំ ពាហិតត្តា ព្រាហ្មណោ ។បេ។ អនិស្សិតោ តាទិ បវុច្ចតេ ស ព្រហ្មា ។ ន ព្រាហ្មណស្ស បរនេយ្យមត្ថីតិ ព្រាហ្មណស្ស បរនេយ្យតា នត្ថិ ព្រាហ្មណោ ន បរនេយ្យោ ន បរប្បត្តិយោ ន បរប្បច្ចយោ ន បរប្បដិពទ្ធគូ(១) ជានាតិ បស្សតិ អសម្មូឡ្ហោ សម្បជានោ បដិស្សតោ ។ សព្វេ សង្ខារា អនិច្ចាតិ ព្រាហ្មណស្ស បរនេយ្យតា នត្ថិ ព្រាហ្មណោ ន បរនេយ្យោ ន បរប្បត្តិយោ ន បរប្បច្ចយោ ន បរប្បដិពទ្ធគូ ជានាតិ បស្សតិ អសម្មូឡ្ហោ សម្បជានោ បដិស្សតោ ។ សព្វេ សង្ខារា ទុក្ខាតិ

១ ម. ន បរប្បដិពទ្ធគូ ។

(៣៦១) ព្រាហ្មណ៍ មិនមានញាណ ដែលបុគ្គលដទៃគប្បីណែនាំ ទាំងមិនមានការពិចារណាក្នុងធម៌ទាំងឡាយ ហើយកាន់យកព្រមទេ ព្រោះដំណើរនោះ (ព្រាហ្មណ៍នោះ) កន្លងផុតនូវវិវាទទាំងឡាយ មិនឃើញធម៌ដទៃជាប្រសើរសោះ ។

(៣៦២) អធិប្បាយពាក្យថា ព្រាហ្មណ៍ មិនមានញាណដែលបុគ្គលដទៃគប្បីណែនាំ ត្រង់ពាក្យថា មិនមាន គឺ ជាពាក្យហាមឃាត់ ។ ពាក្យថា ព្រាហ្មណ៍ បានដល់ បុគ្គលដ៏ប្រសើរ ព្រោះបន្សាត់បង់នូវធម៌ទាំង ៧ ។បេ។ ជាអ្នកមិនអាស្រ័យតណ្ហា ជាបុគ្គលនឹងនួន បុគ្គលនោះលោកហៅថា ព្រាហ្មណ៍ ។ ពាក្យថា ព្រាហ្មណ៍មិនមានញាណដែលបុគ្គលដទៃគប្បីណែនាំ សេចក្តីថា ភាពនៃញាណ ដែលបុគ្គលដទៃគប្បីណែនាំនៃព្រាហ្មណ៍ មិនមាន គឺថា ព្រាហ្មណ៍មិនមានបុគ្គលដទៃគួរណែនាំ មិនគប្បីជឿបុគ្គលដទៃ មិនមានបុគ្គលដទៃជាទីអាង មិនដល់នូវការជាប់ចំពាក់នឹងបុគ្គលដទៃ ជាអ្នកមិនវង្វេង ដឹងខ្លួន មានស្មារតី តែងដឹង តែងឃើញ ។ ភាពនៃញាណដែលបុគ្គលដទៃគប្បីណែនាំ នៃព្រាហ្មណ៍ មិនមាន គឺថា ព្រាហ្មណ៍មិនមានបុគ្គលដទៃគួរណែនាំ មិនគប្បីជឿបុគ្គលដទៃ មិនមានបុគ្គលដទៃជាទីអាង មិនដល់នូវការជាប់ចំពាក់នឹងបុគ្គលដទៃ ជាអ្នកមិនវង្វេង ដឹងខ្លួន មានស្មារតី តែងដឹងតែងឃើញថា សង្ខារទាំងពួងមិនទៀង ។ ថា សង្ខារទាំងពួងជាទុក្ខ

។បេ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ព្រាហ្មណស្ស បរនេយ្យតា នត្ថិ ព្រាហ្មណោ ន បរនេយ្យោ ន បរបត្តិយោ ន បរប្បច្ចយោ ន បរប្បដិពទ្ធគូ ជានាតិ បស្សតិ អសម្មូឡ្ហោ សម្បជានោ បដិស្សតោតិ ន ព្រាហ្មណស្ស បរនេយ្យមត្ថិ ។

(៣៤៣) ធម្មេសុ និច្ឆេយ្យ សមុគ្គហីតន្តិ ធម្មេសូតិ ទ្វាសដ្ឋិយា ទិដ្ឋិគតេសុ ។ និច្ឆេយ្យាតិ និច្ឆិនិត្វា វិនិច្ឆិនិត្វា វិចិនិត្វា បវិចិនិត្វា តុលយិត្វា(១) តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា ឱធិគ្គាហោ ពិលគ្គាហោ វរគ្គាហោ កោដ្ឋាសគ្គាហោ ឧច្ចយគ្គាហោ សមុច្ចយគ្គាហោ ឥទំ សច្ចំ តច្ឆំ តថំ ភូតំ យាថាវំ អវិបរីតន្តិ គហិតំ បរាមដ្ឋំ អភិនិវិដ្ឋំ អជ្ឈោសិតំ អធិមុត្តំ នត្ថិ(២) ន សំវិជ្ជតិ នុបលព្ភតិ បហីនំ សមុច្ឆិន្នំ វូបសន្តំ បដិប្បស្សទ្ធំ អភព្វុប្បត្តិកំ

---

១ ឱ. ម. តីរយិត្វា ។ ២ ម. ឯត្ថន្តរេ ន សន្តីតិ ទិស្សតិ ។

។បេ។ ភាពនៃញាណដែលបុគ្គលដទៃគប្បីណែនាំ នៃព្រាហ្មណ៍ មិនមាន គឺថា ព្រាហ្មណ៍មិនមានបុគ្គលដទៃគួរណែនាំ មិនគប្បីជឿបុគ្គលដទៃ មិនមានបុគ្គលដទៃជាទីអាង មិនដល់នូវការជាប់ចំពាក់នឹងបុគ្គលដទៃ ជាអ្នកមិនវង្វេង ដឹងខ្លួន មានស្មារតី តែងដឹង តែងឃើញថា របស់ណាមួយ មានការកើតឡើងជាធម្មតា របស់ទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រាហ្មណ៍ មិនមានញាណដែលបុគ្គលដទៃគប្បីណែនាំ ។

(៣៤៣) អធិប្បាយពាក្យថា ទាំងមិនមានការពិចារណា ក្នុងធម៌ទាំងឡាយ ហើយកាន់យកព្រមទេ ត្រង់ពាក្យថា ក្នុងធម៌ទាំងឡាយ គឺក្នុងទិដ្ឋិ ៦២ ។ ពាក្យថា ពិចារណា គឺការពិនិត្យ ពិចារណា ជ្រើសរើស ថ្លឹង ត្រិះរិះ សំដែងឲ្យច្បាស់ ធ្វើឲ្យប្រាកដ ហើយកាន់យកដោយប៉ែក កាន់យកដោយចំណែក កាន់យកថាប្រសើរ កាន់យកដោយអំណាចអវយវៈ កាន់យកដោយគំនរ កាន់យកដោយការប្រមូល គឺប្រកាន់ ស្ទាបអង្អែល ប្រកាន់ស្អិត ចុះចិត្តស៊ប់ បង្អោនទៅថា នេះទៀង ពិត មិនឃ្លៀងឃ្លាត ប្រាកដ ពិតប្រាកដ មិនប្រែប្រួល ដូច្នេះ រមែងមិនមាន មិនមានព្រម មិនកើតមាន គឺលោកលះបង់ហើយ ផ្តាច់ផ្តិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន

ញាណាតិគា ឧល្លបន្តិ ធម្មេសុ និច្ឆេយ្យ សមុគ្គហីតំ ។

(៣៤៤) តស្មា វិវាទានិ ឧបាតិវត្តោតិ តស្មាតិ តស្មា តំការណា តំហេតុ តប្បច្ចយា តំនិទានា(១) ទិដ្ឋិកលហានិ ទិដ្ឋិភណ្ឌនានិ ទិដ្ឋិវិគ្គហានិ ទិដ្ឋិវិវាទានិ ទិដ្ឋិមេធគានិ ឧបាតិវត្តោ អតិក្កន្តោ សមតិក្កន្តោ វីតិវត្តោតិ តស្មា វិវាទានិ ឧបាតិវត្តោ ។

(៣៤៥) ន ហិ សេដ្ឋតោ បស្សតិ ធម្មមញ្ញន្តិ អញ្ញំ សត្ថារំ ធម្មក្ខានំ គណំ ទិដ្ឋឹ បដិបទំ មគ្គំ អញ្ញត្រ សតិបដ្ឋានេហិ អញ្ញត្រ សម្មប្បធានេហិ អញ្ញត្រ ឥទ្ធិបាទេហិ អញ្ញត្រ ឥន្ទ្រិយេហិ អញ្ញត្រ ពលេហិ អញ្ញត្រ ពោជ្ឈង្គេហិ អញ្ញត្រ អរិយា អដ្ឋង្គិកា មគ្គា អគ្គំ សេដ្ឋំ វិសេដ្ឋំ បាមោក្ខំ ឧត្តមំ បវរំ ធម្មំ ន បស្សតិ ន ទក្ខតិ ន ឱលោកេតិ ន និជ្ឈាយតិ ន ឧបបរិក្ខតីតិ ន ហិ សេដ្ឋតោ បស្សតិ ធម្មមញ្ញំ ។

តេនាហ ភគវា

---

១ ម. តំនិទានំ ។

ផុតដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ទាំងមិនមានការពិចារណាក្នុងធម៌ទាំងឡាយ ហើយកាន់យកព្រមទេ ។

(៣៤៤) ពាក្យថា ព្រោះដំណើរនោះ (ព្រាហ្មណ៍នោះ) កន្ទុងផុតនូវវិវាទទាំងឡាយ ត្រង់ពាក្យថា ព្រោះដំណើរនោះ គឺព្រោះហេតុនោះ ព្រោះការណ៍នោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ព្រាហ្មណ៍នោះ កន្ទុងផុត កន្ទុងបង់ ធ្លងផុត ធ្លងស្រឡះនូវជម្លោះព្រោះទិដ្ឋិ នូវការប្រកាន់ព្រោះទិដ្ឋិ នូវការទាស់ទែងព្រោះទិដ្ឋិ នូវការវិវាទព្រោះទិដ្ឋិ នូវការបែកខ្ញែកគ្នាព្រោះទិដ្ឋិ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះដំណើរនោះ ព្រាហ្មណ៍នោះ កន្ទុងផុតនូវវិវាទទាំងឡាយ ។

(៣៤៥) ពាក្យថា មិនឃើញធម៌ដទៃថាប្រសើរសោះ គឺមិនឃើញ មិនប្រទះ មិនរមិលមើល មិនសំឡឹងមើល មិនពិចារណាឃើញនូវសាស្តាដទៃ នូវធម៌ដែលសាស្តាពោលហើយ នូវគណៈ នូវទិដ្ឋិនូវបដិបទា នូវមគ្គធម៌ជាកំពូល ប្រសើរ វិសេស ជាប្រធាន ឧត្តមប្រសើរក្រៃលែង ព្រោះវៀរចាកសតិប្បដ្ឋាន វៀរចាកសម្មប្បធានវៀរចាកឥទ្ធិបាទ វៀរចាកឥន្ទ្រិយ វៀរចាកពលៈ វៀរចាកពោជ្ឈង្គវៀរចាកអដ្ឋង្គិកមគ្គដ៏ប្រសើរ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនឃើញធម៌ដទៃថាប្រសើរ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

តេរសមោ មហាវិយូហសុត្តនិទ្ទេសោ

ន ព្រាហ្មណស្ស បរនេយ្យមត្ថិ
ធម្មេសុ និច្ឆេយ្យ សមុគ្គហីតំ
តស្មា វិវាទានិ ឧបាតិវត្តោ
ន ហិ សេដ្ឋតោ បស្សតិ ធម្មមញ្ញំ ។

(៣៤៦) ជានាមិ បស្សាមិ តថេវ ឯតំ
ទិដ្ឋិយា ឯកេ បច្ចេន្តិ សុទ្ធឹ
អទ្ទក្ខិ ចេ កិញ្ហិ តុមស្ស តេន
អតិសិត្វា អញ្ញេន វទន្តិ សុទ្ធឹ ។

(៣៤៧) ជានាមិ បស្សាមិ តថេវ ឯតន្តិ ជានាមីតិ បរចិត្តញាណេន វា ជានាមិ បុព្វេនិវាសានុស្សតិញាណេន វា ជានាមិ ។ បស្សាមីតិ មំសចក្ខុនា វា បស្សាមិ ទិព្វេន វា ចក្ខុនា បស្សាមិ ។ តថេវ ឯតន្តិ ឯតំ តថំ តច្ឆំ ភូតំ យាថាវំ អវិបរីតន្តិ ជានាមិ បស្សាមិ តថេវ ឯតំ ។

ព្រាហ្មណ៍មិនមានញាណ ដែលបុគ្គលដទៃគប្បីណែនាំ ទាំងមិនមានការពិចារណា កន្លងធម៌ទាំងឡាយ ហើយកាន់យកព្រមទេ ព្រោះដំណើរនោះ (ព្រាហ្មណ៍នោះ) កន្លងផុតនូវវិវាទទាំងឡាយ មិនឃើញធម៌ដទៃថាប្រសើរសោះ ។

(៣៤៦) សមណព្រាហ្មណ៍ ពួកមួយ យល់នូវសេចក្តីបរិសុទ្ធិ ព្រោះការឃើញថា អាត្មាអញដឹង អាត្មាអញឃើញនូវដំណើរនេះ ពិតដូច្នោះមែន បើសមណព្រាហ្មណ៍ម្នាក់ឃើញ (នូវសេចក្តីពិត) ប្រយោជន៍អ្វីដោយការឃើញនោះរបស់សមណព្រាហ្មណ៍ម្នាក់នោះ សមណព្រាហ្មណ៍ទាំងឡាយកន្លងចោលនូវសេចក្តីបរិសុទ្ធិ រមែងពោលដោយហេតុដទៃ ។

(៣៤៧) អធិប្បាយពាក្យថា អាត្មាអញដឹង អាត្មាអញឃើញនូវដំណើរនេះ ពិតដូច្នោះមែន ត្រង់ពាក្យថា អាត្មាអញដឹង គឺអាត្មាអញដឹង ដោយបរចិត្តញាណ ឬដឹងដោយបុព្វេនិវាសានុស្សតិញាណ ។ ពាក្យថា អាត្មាអញឃើញ គឺអាត្មាអញឃើញដោយមំសចក្ខុ ឬឃើញដោយទិព្វចក្ខុ ។ ពាក្យថា ដំណើរនេះ ពិតដូច្នោះមែន គឺដំណើរនេះ ពិត មិនឃ្លៀងឃ្លាត ប្រាកដ ពិតប្រាកដ មិនប្រែប្រួល ហេតុនោះ (ទ្រង់ត្រាស់ថា) អាត្មាអញដឹង អាត្មាអញឃើញ នូវដំណើរនេះ ពិតដូច្នោះមែន ។

(៣៦៨) ទិដ្ឋិយា ឯកេ បច្ចេន្តិ សុទ្ធិន្តិ ទិដ្ឋិយា ឯកេ សមណព្រាហ្មណា សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ បច្ចេន្តិ ។ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ទិដ្ឋិយា ឯកេ សមណព្រាហ្មណា សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ បច្ចេន្តិ ។ អសស្សតោ លោកោ ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ទិដ្ឋិយា ឯកេ សមណព្រាហ្មណា សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ បច្ចេន្តីតិ ទិដ្ឋិយា ឯកេ បច្ចេន្តិ សុទ្ធឹ ។

(៣៦៩) អទ្ទក្ខិ ចេ កិញ្ហិ តុមស្ស តេនាតិ អទ្ទក្ខីតិ បរចិត្តញាណេន វា អទ្ទក្ខិ បុព្វេនិវាសានុស្សតិញាណេន វា អទ្ទក្ខិ មំសចក្ខុនា វា អទ្ទក្ខិ ទិព្វេន វា ចក្ខុនា អទ្ទក្ខីតិ អទ្ទក្ខិ ចេ ។

(៣៤៨) ពាក្យថា សមណព្រាហ្មណ៍ពួកមួយ យល់នូវសេចក្តីបរិសុទ្ធិ ដោយការឃើញ សេចក្តីថា សមណព្រាហ្មណ៍ពួកមួយ យល់នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ដោយការឃើញ ។ គឺថាសមណព្រាហ្មណ៍ពួកមួយ យល់នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ដោយការឃើញថា លោកទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ។ សមណព្រាហ្មណ៍ ពួកមួយ យល់នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ដោយការឃើញថា លោកមិនទៀង ។ បេ ។ សត្វស្លាប់ហើយ កើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ហេតុនោះ (ទ្រង់ត្រាស់ថា) សមណព្រាហ្មណ៍ពួកមួយ យល់នូវសេចក្តីបរិសុទ្ធិ ដោយការឃើញ ។

(៣៤៩) អធិប្បាយពាក្យថា បើសមណព្រាហ្មណ៍ម្នាក់ ឃើញ (នូវសេចក្តីពិត) ប្រយោជន៍អ្វី ដោយការឃើញនោះ របស់សមណព្រាហ្មណ៍ម្នាក់នោះ ត្រង់ពាក្យថា បើសមណព្រាហ្មណ៍ម្នាក់ឃើញ គឺឃើញដោយបរចិត្តញាណ ឬឃើញដោយបុព្វេនិវាសានុស្សតិញាណ ឃើញដោយមំសចក្ខុ ឬឃើញដោយទិព្វចក្ខុ ហេតុនោះ (ទ្រង់ត្រាស់ថា) បើសមណព្រាហ្មណ៍ម្នាក់ ឃើញ (នូវសេចក្តីពិត) ។

តេរសមោ មហាវិយូហសុត្តនិទ្ទេសោ

កិញ្ចិ ទុមស្ស តេជាតិ តស្ស តេន ឧស្សេនេន កឹ កាជំ ទុក្ខបរិញ្ញា អត្ថិ ច សមុទយស្ស បហានំ អត្ថិ ច មគ្គភាវនា អត្ថិ ច ផលសច្ឆិកិរិយា អត្ថិ ច រាគស្ស សមុច្ឆេទប្បហានំ អត្ថិ ច ទោសស្ស សមុច្ឆេទប្បហានំ អត្ថិ ច មោហស្ស សមុច្ឆេទប្បហានំ អត្ថិ ច កិលេសានំ សមុច្ឆេទប្បហានំ អត្ថិ ច សំសារវដ្ដស្ស ឧបច្ឆេទោ អត្ថីតិ អទ្ទក្ខិ ចេ កិញ្ចិ ទុមស្ស តេន ។

(៣៩០) អតិសិត្វា អញ្ញេន វទន្តិ សុទ្ធិំ តេ ទិដ្ឋិយា សុទ្ធិមគ្គំ វិសុទ្ធិមគ្គំ បរិសុទ្ធិមគ្គំ វោទាតមគ្គំ បរិយោទាតមគ្គំ អតិក្កមិត្វា សមតិក្កមិត្វា វីតិវត្តិត្វា អញ្ញត្រ សតិប្បដ្ឋានេហិ អញ្ញត្រ សម្មប្បធានេហិ អញ្ញត្រ ឥទ្ធិបាទេហិ អញ្ញត្រ ឥន្ទ្រិយេហិ អញ្ញត្រ ពលេហិ អញ្ញត្រ ពោជ្ឈង្គេហិ អញ្ញត្រ អរិយា អដ្ឋង្គិកា មគ្គា សុទ្ធិំ វិសុទ្ធិំ បរិសុទ្ធិំ មុត្តិំ វិមុត្តិំ បរិមុត្តិំ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ ឃរម្ប អតិសិត្វា អញ្ញេន វទន្តិ សុទ្ធិំ ។

ពាក្យថា ប្រយោជន៍អ្វីដោយការឃើញនោះ របស់សមណព្រាហ្មណ៍ម្នាក់នោះ គឺប្រយោជន៍អ្វីដោយការឃើញនោះ របស់សមណព្រាហ្មណ៍ម្នាក់នោះ គឺថាការកំណត់ទុក្ខមានដូចម្ដេចកើត ការលះបង់សមុទ័យមិនមាន ការចំរើនមគ្គមិនមាន ការធ្វើឲ្យជាក់ច្បាស់នូវផលមិនមាន ការលះបង់រាគៈដោយសមុច្ឆេទមិនមាន ការលះបង់ទោសៈដោយសមុច្ឆេទ មិនមាន ការលះបង់មោហៈដោយសមុច្ឆេទ មិនមាន ការលះបង់កិលេសទាំងឡាយដោយសមុច្ឆេទមិនមាន ការផ្ដាច់ផ្ដិលសង្សារវដ្ដក៏មិនមាន ហេតុនោះ (ទ្រង់ត្រាស់ថា) បើសមណព្រាហ្មណ៍ម្នាក់ឃើញ (នូវសេចក្ដីពិត) ប្រយោជន៍អ្វីដោយការឃើញនោះ របស់សមណព្រាហ្មណ៍ម្នាក់នោះ ។

(៣៩០) ពាក្យថា សមណព្រាហ្មណ៍ទាំងឡាយ កន្លងចោល នូវសេចក្ដីបរិសុទ្ធិ រមែងពោលដោយហេតុដទៃ សេចក្ដីថា សមណៈព្រាហ្មណ៍ទាំងនោះ កន្លង រំលង កន្លងចោល នូវមគ្គដ៏ស្អាត មគ្គស្អាតវិសេស មគ្គបរិសុទ្ធិ មគ្គផូរផង់ មគ្គផូរផង់ក្រៃលែង ដោយទិដ្ឋិ គឺវៀរចាកសតិប្បដ្ឋាន វៀរចាកសម្មប្បធាន វៀរចាកឥទ្ធិបាទ វៀរចាកឥន្ទ្រិយ វៀរចាកពលៈ វៀរចាកពោជ្ឈង្គៈ វៀរចាកអដ្ឋង្គិកមគ្គដ៏ប្រសើរ ហើយពោល សំដែង ពណ៌នា បំភ្លឺ ថ្លែង នូវសេចក្ដីស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ហេតុនោះ (ទ្រង់ត្រាស់ថា) កន្លងចោល នូវសេចក្ដីបរិសុទ្ធិ រមែងពោលដោយហេតុដទៃ យ៉ាងនេះខ្លះ ។

អថវា ពុទ្ធា ច ពុទ្ធសាវកា ច បច្ចេកពុទ្ធា ច តេសំ ទិដ្ឋិយា(១) អសុទ្ធិមគ្គំ អវិសុទ្ធិមគ្គំ អបរិសុទ្ធិមគ្គំ អវោទាតមគ្គំ អបរិយោទាតមគ្គំ អតិក្កមិត្វា សមតិក្កមិត្វា វីតិវត្តិត្វា ចតូហិ សតិបដ្ឋានេហិ ចតូហិ សម្មប្បធានេហិ ចតូហិ ឥទ្ធិបាទេហិ បញ្ចហិ ឥន្ទ្រិយេហិ បញ្ចហិ ពលេហិ សត្តហិ ពោជ្ឈង្គេហិ អរិយេន អដ្ឋង្គិកេន មគ្គេន សុទ្ធិំ វិសុទ្ធិំ បរិសុទ្ធិំ មុត្តិំ វិមុត្តិំ បរិមុត្តិំ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ ឯវម្បិ អតិសិត្វា អញ្ញេន វទន្តិ សុទ្ធិំ ។ តេនាហ ភគវា

ជានាមិ បស្សាមិ តថេវ ឯតំ
ទិដ្ឋិយា ឯកេ បច្ចេន្តិ សុទ្ធិំ
អទ្ទក្ខិ ចេ កិញ្ហិ តុមស្ស តេន
អតិសិត្វា អញ្ញេន វទន្តិ សុទ្ធិន្តិ ។

១ ឱ. ម. តិត្ថិយានំ ។

ម្យ៉ាងទៀត ព្រះពុទ្ធទាំងឡាយក្តី សាវ័ករបស់ព្រះពុទ្ធទាំងឡាយក្តី ព្រះបច្ចេកពុទ្ធទាំងឡាយក្តី កន្លង រំលង កន្លងបោល នូវមគ្គមិនស្អាត មគ្គមិនស្អាតវិសេស មគ្គមិនបរិសុទ្ធិ មគ្គមិនផូរផង់ មគ្គមិនផូរផង់ក្រៃលែង នៃទិដ្ឋិរបស់សមណព្រាហ្មណ៍ទាំងនោះ ហើយពោល សំដែង ពណ៌នា បំភ្លឺ ថ្លែង នូវសេចក្តីស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ដោយសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ហេតុនោះ (ទ្រង់ត្រាស់ថា) សមណព្រាហ្មណ៍ទាំងឡាយ កន្លងបោល រមែងពោលនូវសេចក្តីបរិសុទ្ធិ ដោយហេតុដទៃ យ៉ាងនេះខ្លះ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

សមណព្រាហ្មណ៍ពួកមួយ យល់នូវសេចក្តីបរិសុទ្ធិព្រោះការឃើញថា អាត្មាអញដឹង អាត្មាអញឃើញ នូវដំណើរនេះពិតដូច្នោះមែន បើសមណព្រាហ្មណ៍ម្នាក់ឃើញ (នូវសេចក្តីពិត) ប្រយោជន៍អ្វី ដោយការឃើញនោះ របស់សមណ. ព្រាហ្មណ៍ម្នាក់នោះ សមណព្រាហ្មណ៍ទាំងឡាយ កន្លងបោល នូវសេចក្តីបរិសុទ្ធិ រមែងពោលដោយហេតុដទៃ ។

តេរសមោ មហាវិយូហសុត្តនិទ្ទេសោ

(៣៨១) បស្សំ នរោ ទក្ខតិ នាមរូបំ
ទិស្វាន វា ញស្សតិ(១) តានិមេវ
កាមំ ពហុំ បស្សតុ អប្បកំ វា
ន ហិ តេន សុទ្ធឹ កុសលា វទន្តិ ។

(៣៨២) បស្សំ នរោ ទក្ខតិ នាមរូបន្តិ បស្សំ នរោតិ(២) បរចិត្តញ្ញាណេន វា បស្សន្តោ បុព្វេនិវាសានុស្សតិញ្ញាណេន វា បស្សន្តោ មំសចក្ខុនា វា បស្សន្តោ ទិព្វេន វា ចក្ខុនា បស្សន្តោ នាមរូបញ្ញេវ ទក្ខតិ និច្ចតោ សុខតោ អត្តតោ ន តេសំ ធម្មានំ សមុទយំ វា អត្ថង្គមំ វា អស្សាទំ វា អាទីនវំ វា និស្សរណំ វា ទក្ខតីតិ បស្សំ នរោ ទក្ខតិ នាមរូបំ ។

(៣៨៣) ទិស្វាន វា ញស្សតិ តានិមេវាតិ ទិស្វាតិ បរចិត្តញ្ញាណេន វា ទិស្វា បុព្វេនិវាសានុស្សតិញ្ញាណេន វា ទិស្វា មំសចក្ខុនា វា ទិស្វា ទិព្វេន វា ចក្ខុនា ទិស្វា នាមរូបញ្ញេវ ទិស្វា ញស្សតិ និច្ចតោ សុខតោ អត្តតោ ន តេសំ ធម្មានំ សមុទយំ វា អត្ថង្គមំ វា អស្សាទំ វា អាទីនវំ វា និស្សរណំ វា

---

១ ម. វិញ្ញាយតិ ។ ២ ម. នរោ ទក្ខតិ ។

មហាវិយូហសុត្តនិទ្ទេស ទី ១៣

(៣៩១) នរជនកាលឃើញ តែងឃើញនាមរូប លុះឃើញហើយ រមែងដឹងនូវនាមរូបនោះឯង បុគ្គលឃើញកាមច្រើនក៏មាន ឃើញនាមរូបតិចក៏មាន ចំណែកអ្នកឈ្លាសទាំងឡាយ មិនពោលនូវសេចក្ដីបរិសុទ្ធិ ដោយការឃើញនោះទេ ។

(៣៩២) អធិប្បាយពាក្យថា នរជនកាលឃើញ តែងឃើញនាមរូប ត្រង់ពាក្យថា នរជនកាលឃើញ គឺ កាលឃើញ ដោយបរចិត្តញាណក្ដី ឃើញដោយបុព្វេនិវាសានុស្សតិញ្ញាណក្ដី ឃើញដោយមំសចក្ខុក្ដី ឃើញដោយទិព្វចក្ខុក្ដី គឺតែងឃើញនូវនាមរូបនោះឯង ជាទៀង ជាសុខ ជាខ្លួន តែមិនឃើញនូវការកើត ឬការរលត់ អានិសង្ស ឬទោស ឬក៏ការរលាស់ចោល នូវធម៌ទាំងនោះទេ ហេតុនោះ (ទ្រង់ត្រាស់ថា) នរជនកាលឃើញ តែងឃើញនាមរូប ។

(៣៩៣) ពាក្យថា លុះឃើញហើយតែងដឹងនូវនាមរូបនុះឯង ត្រង់ពាក្យថា គឺលុះឃើញហើយ គឺលុះឃើញហើយ ដោយបរចិត្តញាណក្ដី លុះឃើញហើយ ដោយបុព្វេនិវាសានុស្សតិញ្ញាណក្ដី លុះឃើញហើយ ដោយមំសចក្ខុក្ដី លុះឃើញហើយ ដោយទិព្វចក្ខុក្ដី លុះឃើញហើយ នូវនាមរូបនោះឯង តែងដឹងជាទៀង ជាសុខ ជាខ្លួន តែមិនដឹងនូវការកើត ឬការរលត់ អានិសង្ស ឬទោស ឬក៏ការរលាស់ចោល នូវធម៌ទាំងនោះទេ

ញស្សតីតិ ទិស្វាន វា ញស្សតិ តានិមេវ ។

(៣៨៤) កាមំ ពហុំ បស្សតុ អប្បកំ វាតិ កាមំ ពហុកំ វា បស្សន្តោ នាមរូបំ អប្បកំ វា និច្ចតោ សុខតោ អត្តតោតិ កាមំ ពហុំ បស្សតុ អប្បកំ វា ។

(៣៨៥) ន ហិ តេន សុទ្ធិំ កុសលា វទន្តីតិ កុសលាតិ យេ តេ ខន្ធកុសលា ធាតុកុសលា អាយតនកុសលា បដិច្ចសមុប្បាទកុសលា សតិប្បដ្ឋានកុសលា សម្មប្បធានកុសលា ឥទ្ធិបាទកុសលា ឥន្ទ្រិយកុសលា ពលកុសលា ពោជ្ឈង្គកុសលា មគ្គកុសលា ផលកុសលា និព្វានកុសលា តេ កុសលា បរចិត្តញ្ញាណេន វា បុព្វេនិវាសានុស្សតិញ្ញាណេន វា មំសចក្ខុនា វា ទិព្វេន វា ចក្ខុនា នាមរូបទស្សនេន សុទ្ធិំ វិសុទ្ធិំ បរិសុទ្ធិំ មុត្តិំ វិមុត្តិំ បរិមុត្តិំ ន វទន្តិ ន កថេន្តិ ន ភណន្តិ ន ទីបយន្តិ ន វោហរន្តីតិ ន ហិ តេន សុទ្ធិំ កុសលា វទន្តិ ។ តេនាហ ភគវា

ហេតុនោះ (ទ្រង់ត្រាស់ថា) លុះឃើញហើយ តែងដឹងនូវនាមរូបនោះឯង ។

(៣៩៤) ពាក្យថា បុគ្គលឃើញកាមច្រើន ក៏មាន ឃើញនាមរូបតិច ក៏មាន គឺ ឃើញកាមច្រើនក្តី នាមរូបតិចក្តី ថាទៀង ថាសុខ ថាខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) ឃើញកាមច្រើនក៏មាន ឃើញនាមរូបតិចក៏មាន ។

(៣៩៥) អធិប្បាយពាក្យថា ចំណែកជនអ្នកឈ្លាសទាំងឡាយ មិនពោល នូវសេចក្តីបរិសុទ្ធិ ដោយការឃើញនោះទេ ត្រង់ពាក្យថា ជនអ្នកឈ្លាស គឺជនណា ជាអ្នកឈ្លាសក្នុងខន្ធ អ្នកឈ្លាសក្នុងធាតុ អ្នកឈ្លាសក្នុងអាយតនៈ អ្នកឈ្លាសក្នុងបដិច្ចសមុប្បាទ អ្នកឈ្លាសក្នុងសតិប្បដ្ឋាន អ្នកឈ្លាសក្នុងសម្មប្បធាន អ្នកឈ្លាសក្នុងឥទ្ធិបាទ អ្នកឈ្លាសក្នុងឥន្ទ្រិយ អ្នកឈ្លាសក្នុងពលៈ អ្នកឈ្លាសក្នុងពោជ្ឈង្គៈ អ្នកឈ្លាសក្នុងមគ្គ អ្នកឈ្លាសក្នុងផល អ្នកឈ្លាសក្នុងព្រះនិព្វាន ជនអ្នកឈ្លាសទាំងនោះ រមែងមិនពោល មិនសំដែង មិនពណ៌នា មិនបំភ្លឺ មិនថ្លែង នូវសេចក្តីស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ដោយការឃើញនាមរូប ដោយបរចិត្តញាណក្តី ដោយបុព្វេនិវាសានុស្សតិញាណក្តី ដោយមំសចក្ខុក្តី ដោយទិព្វចក្ខុក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) ចំណែកជនអ្នកឈ្លាសទាំងឡាយ មិនពោលនូវសេចក្តីបរិសុទ្ធិ ដោយការឃើញនោះទេ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

តេរសមោ មហាវិយូហសុត្តនិទ្ទេសោ

បស្សំ នរោ ទក្ខតិ នាមរូបំ
ទិស្វាន វា ញស្សតិ តានិមេវ
កាមំ ពហុំ បស្សតុ អប្បកំ វា
ន ហិ តេន សុទ្ធិំ កុសលា វទន្តិ ។

(៣៩៦) និវិស្សវាទី ន ហិ សុព្វិនាយោ
បកប្បិតំ(១) ទិដ្ឋិ បុរេក្ខរានោ
យំ និស្សិតោ តត្ថ សុភំវទានោ
សុទ្ធិំវទោ(២) តត្ថ តថទ្ទសា(៣) សោ ។

(៣៩៧) និវិស្សវាទី ន ហិ សុព្វិនាយោតិ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ និវិស្សវាទី ។ អសស្សតោ លោកោ ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ និវិស្សវាទី ។ ន ហិ សុព្វិនាយោតិ និវិស្សវាទី ទុព្វិនយោ ទុញ្ញាបយោ(៤) ទុន្និជ្ឈាបយោ ទុប្បេក្ខាបយោ ទុប្បសាទយោតិ និវិស្សវាទី ន ហិ សុព្វិនាយោ ។

---

១ ម. បកប្បិតា ។ ២ ម. សុទ្ធិវទោ ។ ៣ ម. តថទ្ទសោ ។ ៤ ម. ទុប្បញ្ញាបយោ ។

នរជនកាលឃើញ តែងឃើញនាមរូប លុះឃើញហើយ រមែងដឹងនូវនាមរូបនោះឯង បុគ្គលឃើញកាមច្រើនក៏មាន ឃើញនាមរូបតិចក៏មាន ចំណែកជនអ្នកឈ្លាសទាំងឡាយ មិនពោលនូវសេចក្តីបរិសុទ្ធិ ដោយការឃើញនោះទេ ។

(៣៩៦) បុគ្គលណាជាអ្នកមានវាទៈតាំងនៅមាំ ដែលគេមិនអាចទូន្មានបានងាយ អ្នកធ្វើទិដ្ឋិដែលតែងតាំងហើយឲ្យជាប្រធាន បុគ្គលនោះអាស្រ័យសភាវៈណា ជាអ្នកពោលថាល្អ ពោលថាបរិសុទ្ធិ ក្នុងសភាវៈនោះ ឃើញថាពិតក្នុងសភាវៈនោះ ។

(៣៩៧) ពាក្យថា បុគ្គលណាជាអ្នកមានវាទៈតាំងនៅមាំ ដែលគេមិនអាចទូន្មានបានងាយ គឺជាអ្នកមានវាទៈតាំងនៅមាំថា លោកទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ។ ជាអ្នកមានវាទៈតាំងនៅមាំថា លោកមិនទៀង ។បេ។ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ។ ពាក្យថា ដែលគេមិនអាចទូន្មានបានងាយ គឺបុគ្គលអ្នកមានវាទៈតាំងនៅមាំ គេទូន្មានបានដោយក្រ ឲ្យដឹងបានដោយក្រ ឲ្យយល់បានដោយក្រ ឲ្យឃើញបានដោយក្រ ឲ្យជ្រះថ្លាបានដោយក្រ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលណាជាអ្នកមានវាទៈតាំងនៅមាំ ដែលគេមិនអាចទូន្មានបានងាយ ។

(៣៥៨) បកប្បិតំ ទិដ្ឋិ បុរេក្ខរានោតិ បកប្បិតំ អភិសង្ខតំ សណ្ឋបិតំ(១) ទិដ្ឋិ បុរក្ខតោ បុរតោ កត្វា ចរតិ ទិដ្ឋិទ្ធជោ ទិដ្ឋិកេតុ ទិដ្ឋាធិបតេយ្យោ ទិដ្ឋិយា បរិវារិតោ ចរតីតិ បកប្បិតំ ទិដ្ឋិ បុរេក្ខរានោ ។

(៣៥៩) យំ និស្សិតោ តត្ថ សុភំវទានោតិ យំ និស្សិតោតិ យំ សត្ថារំ ធម្មក្ខានំ គណំ ទិដ្ឋិំ បដិបទំ មគ្គំ និស្សិតោ សន្និស្សិតោ(២) អល្លីនោ ឧបគតោ អជ្ឈោសិតោ អធិមុត្តោតិ យំ និស្សិតោ ។ តត្ថាតិ សកាយ ទិដ្ឋិយា សកាយ ខន្តិយា សកាយ រុចិយា សកាយ លទ្ធិយា ។ សុភំវទានោតិ សុភវាទោ សោភណវាទោ បណ្ឌិតវាទោ ធីរវាទោ ញាណវាទោ(៣) ហេតុវាទោ លក្ខណវាទោ ការណវាទោ ឋានវាទោ សកាយ លទ្ធិយាតិ យំ និស្សិតោ តត្ថ សុភំវទានោ ។

---

១ ម. កប្បិតាបកប្បិតា អភិសង្ខតា សណ្ឋបិតា ។ ២ ម. អាទិស្សិតោ ។ ៣ ម. ធីរវាទោ ញាយវាទោ ។

(៣៥៨) ពាក្យថា អ្នកធ្វើទិដ្ឋិដែលតែងតាំងហើយឲ្យជាប្រធាន គឺប្រព្រឹត្តធ្វើឲ្យជាប្រមុខ ធ្វើឲ្យជាប្រធាន នូវទិដ្ឋិដែលតែងតាំងហើយ តាក់តែងហើយ តំកល់ទុកហើយ គឺថា ជាអ្នកមានទិដ្ឋិជាទង់ជ័យ មានទិដ្ឋិជាទង់ មានទិដ្ឋិជាអធិបតី ត្រូវទិដ្ឋិរួបរឹត ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកធ្វើនូវទិដ្ឋិដែលតែងតាំងហើយឲ្យជាប្រធាន ។

(៣៥៩) អធិប្បាយពាក្យថា អាស្រ័យនូវសភាវៈណា ជាអ្នកពោលថាល្អ ក្នុងសភាវៈនោះ ត្រង់ពាក្យថា អាស្រ័យនូវសភាវៈណា គឺអាស្រ័យ អាស្រ័យព្រម ជាប់ស្អិត ចូលទៅរក ជ្រួលជ្រប់ ឱនទៅរក នូវសាស្ដា នូវធម៌ដែលសាស្ដាពោលហើយ នូវគណៈ នូវទិដ្ឋិ នូវបដិបទា នូវមគ្គ ណា ហេតុនោះ (ទ្រង់ត្រាស់ថា) អាស្រ័យនូវសភាវៈណា ។ ពាក្យថា ក្នុងសភាវៈនោះ គឺក្នុងទិដ្ឋិរបស់ខ្លួន ក្នុងសេចក្ដីចូលចិត្តរបស់ខ្លួន ក្នុងការពេញចិត្តរបស់ខ្លួន ក្នុងលទ្ធិរបស់ខ្លួន ។ ពាក្យថា ជាអ្នកពោលថាល្អ គឺជាអ្នកពោលថាល្អ ពោលថាស្អាត ពោលថាជាបណ្ឌិត ពោលថាជាអ្នកប្រាជ្ញ ពោលប្រកបដោយញាណ ពោលប្រកបដោយហេតុ ពោលប្រកបដោយលក្ខណៈ ពោលប្រកបដោយការណ៍ ពោលប្រកបដោយឋានៈ ក្នុងលទ្ធិរបស់ខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) អាស្រ័យនូវសភាវៈណា ជាអ្នកពោលថាល្អ ក្នុងសភាវៈនោះ ។

(៣៦០) សុទ្ធិំវទោ តត្ថ តថទ្ទសា សោតិ សុទ្ធិំវទោតិ សុទ្ធិវាទោ វិសុទ្ធិវាទោ បរិសុទ្ធិវាទោ វោទានវាទោ បរិយោទានវាទោ ។ អថវា សុទ្ធិទស្សនោ វិសុទ្ធិទស្សនោ បរិសុទ្ធិទស្សនោ វោទានទស្សនោ បរិយោទានទស្សនោតិ សុទ្ធិំវទោ ។ តត្ថាតិ សកាយ ទិដ្ឋិយា សកាយ ខន្តិយា សកាយ រុចិយា សកាយ លទ្ធិយា ។ តថទ្ទសា សោតិ តថំ តច្ឆំ ភូតំ យាថាវំ អវិបរីតន្តិ អទ្ទស អទ្ទក្ខិ អបស្សិ បដិវិជ្ឈីតិ សុទ្ធិំវទោ តត្ថ តថទ្ទសា សោ ។ តេនាហ ភគវា

និវិស្សវាទី ន ហិ សុទ្ធិនាយោ
បកប្បិតំ ទិដ្ឋិ បុរេក្ខរានោ
យំ និស្សិតោ តត្ថ សុភំវទានោ
សុទ្ធិំវទោ តត្ថ តថទ្ទសា សោតិ ។

មហាវិយូហសុត្តនិទ្ទេស ទី ១៣

(៣៦០) អធិប្បាយពាក្យថា បុគ្គលនោះជាអ្នកពោលថាបរិសុទ្ធិ ឃើញថាពិត ក្នុងសភាវៈនោះ ត្រង់ពាក្យថា ជាអ្នកពោលថាបរិសុទ្ធិ គឺជាអ្នកពោលថាស្អាត ពោលថាស្អាតវិសេស ពោលថាបរិសុទ្ធិ ពោលថាផូរផង់ ពោលថាផូរផង់ក្រៃលែង ។ ឬថា ជាអ្នកឃើញថាស្អាត ឃើញថាស្អាតវិសេស ឃើញថាបរិសុទ្ធិ ឃើញថាផូរផង់ ឃើញថាផូរផង់ក្រៃលែង ហេតុនោះ (ទ្រង់ត្រាស់ថា) ពោលថាបរិសុទ្ធិ ។ ពាក្យថា ក្នុងសភាវៈនោះ គឺក្នុងទិដ្ឋិរបស់ខ្លួន ក្នុងការចូលចិត្តរបស់ខ្លួន ក្នុងការពេញចិត្តរបស់ខ្លួន ក្នុងលទ្ធិរបស់ខ្លួន ។ ពាក្យថា បុគ្គលនោះឃើញ ថាពិត គឺឃើញ មើលឃើញ យល់ ចាក់ធ្លុះ ថាពិត មិនឃ្លៀងឃ្លាត ប្រាកដ ពិតប្រាកដ មិនប្រែប្រួល ហេតុនោះ ( ទ្រង់ត្រាស់ថា ) បុគ្គលនោះ ជាអ្នកពោលថាបរិសុទ្ធិ ឃើញថាពិតក្នុងសភាវៈនោះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

បុគ្គលណាជាអ្នកមានវាទៈតាំងនៅមាំ ដែលគេមិនអាចទូន្មាន
បានឆ្ងាយ អ្នកធ្វើទិដ្ឋិដែលតែងតាំងហើយ ឲ្យជាប្រធាន
បុគ្គលនោះអាស្រ័យសភាវៈណា ជាអ្នកពោលថាល្អ ពោល
ថាបរិសុទ្ធិ ក្នុងសភាវៈនោះ ឃើញថាពិតក្នុងសភាវៈនោះ ។

(៣៦១) ន ព្រាហ្មណោ កប្បមុបេតិ សង្ខំ

ន ទិដ្ឋិសារី នបិ ញាណពន្ធុ

ញត្វា ច សោ សម្មតិយោ(១) បុថុជ្ជា

ឧបេក្ខតិ ឧគ្គហណន្តិ មញ្ញេ ។

(៣៦២) ន ព្រាហ្មណោ កប្បមុបេតិ សង្ខន្តិ ជាតិ បដិក្ខេបោ ។ ព្រាហ្មណោតិ សត្តន្នំ ធម្មានំ ពាហិតត្តា ព្រាហ្មណោ ។បេ។ អសិតោ តាទិ បវុច្ចតេ ស ព្រហ្មា ។ កប្បាតិ ទ្វេ កប្បា តណ្ហាកប្បោ ច ទិដ្ឋិកប្បោ ច ។បេ។ អយំ តណ្ហាកប្បោ ។បេ។ អយំ ទិដ្ឋិកប្បោ ។ សង្ខា វុច្ចតិ ញាណំ យា បញ្ញា បជានា ។បេ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ ន ព្រាហ្មណោ កប្បមុបេតិ សង្ខន្តិ ព្រាហ្មណោ សង្ខាយ ជានិត្វា តុលយិត្វា តិរយិត្វា វិភាវយិត្វា វិភូតំ កត្វា សព្វេ សង្ខារា អនិច្ចាតិ សព្វេ សង្ខារា ទុក្ខាតិ

---

១ ម សម្មុតិយោ ។

(៣៦១) ព្រាហ្មណ៍ពិចារណាហើយ រមែងមិនដល់នូវការ
កំណត់ មិនលុះក្នុងទិដ្ឋិ ទាំងមិនមានផៅពង្សដោយញាណ
ព្រោះព្រាហ្មណ៍នោះ ដឹងសម្មតិទាំងឡាយ ដែលកើត
អំពីបុថុជ្ជន លោកព្រងើយកន្តើយ នឹងទិដ្ឋិ ដែលជនទាំង
ឡាយដទៃ កំពុងប្រកាន់ ។

(៣៦២) អធិប្បាយពាក្យថា ព្រាហ្មណ៍ពិចារណាហើយ រមែងមិនដល់នូវការកំណត់ ត្រង់ពាក្យថា មិន គឺជាពាក្យហាមឃាត់ ។ ពាក្យថា ព្រាហ្មណ៍ គឺបុគ្គលដែលឈ្មោះថាព្រាហ្មណ៍ ព្រោះបន្សាត់បង់នូវធម៌ទាំង ៧ ។បេ។ ជាអ្នកមិនអាស្រ័យតណ្ហា ជាបុគ្គលនឹងនួន បុគ្គលនោះ លោកហៅថា ព្រាហ្មណ៍ ។ ពាក្យថា ការកំណត់ បានដល់ការកំណត់ ២ ការកំណត់គឺតណ្ហា ១ ការកំណត់គឺទិដ្ឋិ ១ ។បេ។ នេះការកំណត់គឺតណ្ហា ។បេ។ នេះ ការកំណត់គឺទិដ្ឋិ ។ ញាណ លោកហៅថា ការពិចារណា បានដល់បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ។ ពាក្យថា ព្រាហ្មណ៍ពិចារណាហើយ រមែងមិនដល់នូវការកំណត់ គឺព្រាហ្មណ៍ពិចារណាហើយ ដឹងហើយ ថ្លឹងហើយ ត្រិះរិះហើយ ធ្វើឲ្យច្បាស់ហើយ ធ្វើឲ្យប្រាកដហើយ ថាសង្ខារទាំងពួងមិនទៀង ថាសង្ខារទាំងពួងជាទុក្ខ

។បេ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ សង្ខាយ ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា តណ្ហាកប្បំ វា ទិដ្ឋិកប្បំ វា(១) ន ឧបេតិ ន ឧបគច្ឆតិ ន គណ្ហាតិ ន បរាមសតិ នាភិនិវិសតីតិ ន ព្រាហ្មណោ កប្បមុបេតិ សង្ខំ ។

(៣៦៣) ន ទិដ្ឋិសារី នបិ ញាណពន្ធូតិ តស្ស ទ្វាសដ្ឋី ទិដ្ឋិគតានិ បហីនានិ សមុច្ឆិន្នានិ វូបសន្តានិ បដិប្បស្សទ្ធានិ អភព្វុប្បត្តិកានិ ញាណគ្គិនា ទឌ្ឍានិ សោ ទិដ្ឋិយា ន យាយតិ ន និយ្យតិ ន វុយ្ហតិ ន សំហារីយតិ នបិ តំ ទិដ្ឋិគតំ សារតោ បច្ចេតិ បច្ចាគច្ឆតីតិ ន ទិដ្ឋិសារី ។ នបិ ញាណពន្ធូតិ អដ្ឋសមាបត្តិញាណេន វា បញ្ចាភិញ្ញាញាណេន វា មិច្ឆាញាណេន វា តណ្ហាពន្ធុំ វា ទិដ្ឋិពន្ធុំ វា ន ករោតិ ន ជនេតិ ន សញ្ជនេតិ ន និព្វត្តេតិ នាភិនិព្វត្តេតីតិ ន ទិដ្ឋិសារី នបិ ញាណពន្ធុ ។

---

១ ម. ឯតន្តរេ នេតីតិ ទិស្សតិ ។

។បេ។ ពិចារណាហើយ ដឹងហើយ ថ្លឹងហើយ ត្រិះរិះហើយ ធ្វើឲ្យច្បាស់ហើយ ធ្វើឲ្យប្រាកដហើយថា របស់ណាមួយ មានកិរិយាកើតឡើងជាធម្មតា របស់ទាំងអស់នោះ មានសេចក្ដីរលត់ទៅវិញជាធម្មតា រមែងមិនដល់ មិនចូលទៅជិត មិនប្រកាន់ មិនស្ទាបអង្អែល មិនប្រកាន់ស្អិត នូវការកំណត់គឺតណ្ហាក្ដី នូវការកំណត់គឺទិដ្ឋិក្ដី ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រាហ្មណ៍ពិចារណាហើយ រមែងមិនដល់នូវការកំណត់។

[៣៦៣] ពាក្យថា មិនលុះក្នុងទិដ្ឋិ ទាំងមិនមានផៅពង្សដោយញាណ សេចក្ដីថាទិដ្ឋិ ៦២ បុគ្គលនោះ បានលះបង់ ផ្ដាច់ផ្ដិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ ទិដ្ឋិឲ្យទៅមិនបាន នាំទៅមិនបាន បន្សាត់ទៅមិនបាន គួប យកទៅមិនបាន មិនមក មិនត្រឡប់មក កាន់ទិដ្ឋិនោះថា មានខ្លឹម ហេតុនោះ (ទ្រង់ត្រាស់ថា) មិនលុះក្នុងទិដ្ឋិ ។ ពាក្យថា ទាំងមិនមានផៅពង្សដោយញាណ គឺមិនធ្វើ មិនឲ្យកើត មិនឲ្យកើតព្រម មិនបង្កើត មិនបង្កើតចំពោះ នូវផៅពង្សគឺតណ្ហាក្ដី នូវផៅពង្សគឺទិដ្ឋិក្ដី ដោយសមាបត្តិញ្ញាណ ៨ ក្ដី ដោយអភិញ្ញាញ្ញាណ ៥ ក្ដី ដោយមិច្ឆាញ្ញាណក្ដី ហេតុនោះ (ទ្រង់ត្រាស់ថា) មិនលុះក្នុងទិដ្ឋិ ទាំងមិនមានផៅពង្សដោយញាណ ។

(៣៦៤) ញត្វា ច សោ សម្មុតិយោ បុថុជ្ជាតិ ញត្វាតិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា សព្វេ សង្ខារា អនិច្ចាតិ សព្វេ សង្ខារា ទុក្ខាតិ ។បេ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ ញត្វា ច សោ ។ សម្មុតិយោតិ វុច្ចន្តិ ទ្វាសដ្ឋី ទិដ្ឋិគតានិ(១) ។ បុថុជ្ជាតិ បុថុជ្ជនេហិ ជនិតា វា តា សម្មុតិយោតិ បុថុជ្ជា ។ បុថុនានាជនេហិ ជនិតា វា(២) តា សម្មុតិយោតិ បុថុជ្ជាតិ ញត្វា ច សោ សម្មុតិយោ បុថុជ្ជា ។

(៣៦៥) ឧបេក្ខតិ ឧគ្គហណន្តិ មញ្ញេតិ អញ្ញេ តណ្ហាវសេន ទិដ្ឋិវសេន គណ្ហន្តិ បរាមសន្តិ អភិនិវិសន្តិ អរហា ឧបេក្ខតិ ន គណ្ហាតិ ន បរាមសតិ នាភិនិវិសតីតិ

---

១ ម. ឯត្ថន្តរេ ទិដ្ឋិសមុទយោតិ ទិស្សតិ ។ ២ ម បុថុនានាជាតិយា វា ។

(៣៦៨) អធិប្បាយពាក្យថា ព្រាហ្មណ៍នោះ ដឹងសម្មតិទាំងឡាយ ដែលកើតអំពីបុថុជ្ជន ត្រង់ពាក្យថា ដឹង គឺដឹង យល់ ថ្លឹង ត្រិះរិះ ធ្វើឲ្យច្បាស់ ធ្វើឲ្យប្រាកដហើយថា សង្ខារទាំងពួងមិនទៀង ថាសង្ខារទាំងពួងជាទុក្ខ ។បេ។ ដឹង យល់ ថ្លឹងត្រិះរិះ ធ្វើឲ្យច្បាស់ ធ្វើឲ្យប្រាកដហើយថា របស់ណាមួយមានកិរិយាកើតឡើង ជាធម្មតា របស់ទាំងអស់នោះ មានកិរិយារលត់ទៅវិញ ជាធម្មតា ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រាហ្មណ៍នោះដឹង ។ ទិដ្ឋិ ៦២ លោកហៅថា សម្មតិ ។ ពាក្យថា ដែលកើតអំពីបុថុជ្ជន គឺសម្មតិទាំងនោះកើតអំពីបុថុជ្ជនទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) ដែលកើតអំពីបុថុជ្ជន ។ ម្យ៉ាងទៀត សម្មតិទាំងនោះ កើតអំពីជនផ្សេង ៗ ហេតុនោះ (ទ្រង់ត្រាស់ថា) ដែលកើតអំពីបុថុជ្ជន ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រាហ្មណ៍នោះដឹងថា សម្មតិទាំងឡាយ ដែលកើតអំពីបុថុជ្ជន ។

(៣៦៩) ពាក្យថា រមែងព្រងើយកន្តើយ នឹងទិដ្ឋិដែលជនទាំងឡាយដទៃ កំពុងប្រកាន់ គឺជនទាំងឡាយដទៃ ប្រកាន់ ស្ទាបអង្អែល ប្រកាន់ស្អិត ដោយអំណាចតណ្ហា ដោយអំណាចទិដ្ឋិ ព្រះអរហន្តព្រងើយកន្តើយ មិនប្រកាន់ មិនស្ទាបអង្អែល មិនប្រកាន់ស្អិត

តេរសមោ មហាវិយូហសុត្តនិទ្ទេសោ

ឧបេក្ខតី ឧគ្គហណន្តិ មញ្ញេ ។ តេនាហ ភគវា

ន ព្រាហ្មណោ កប្បមុបេតិ សង្ខំ
ន ទិដ្ឋិសារី នបិ ញាណពន្ធុ
ញត្វា ច សោ សម្មុតិយោ បុថុជ្ជា
ឧបេក្ខតី ឧគ្គហណន្តិ មញ្ញេតិ ។

(៣៦៦) វិសជ្ជ គន្ថានិ មុនីធ លោកេ
វិវាទជាតេសុ ន វគ្គសារី
សន្តោ អសន្តេសុ ឧបេក្ខកោ សោ
អនុគ្គហោ ឧគ្គហណន្តិ មញ្ញេ ។

(៣៦៧) វិសជ្ជ គន្ថានិ មុនីធ លោកេតិ គន្ថាតិ ចត្តារោ គន្ថា អភិជ្ឈា កាយគន្ថោ ព្យាបាទោ កាយគន្ថោ សីលព្វតបរាមាសោ កាយគន្ថោ ឥទំសច្ចាភិនិវេសោ កាយគន្ថោ ។ អត្តនោ ទិដ្ឋិយា រាគោ អភិជ្ឈា កាយគន្ថោ ។

ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រងើយកន្តើយ នឹងទិដ្ឋិដែលជនទាំងឡាយដទៃ កំពុងប្រកាន់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ព្រាហ្មណ៍ពិចារណាហើយ រមែងមិនដល់នូវការកំណត់ មិនលុះក្នុងទិដ្ឋិ ទាំងមិនមានផៅពង្សដោយញាណ ព្រោះព្រាហ្មណ៍នោះដឹងសម្មតិទាំងឡាយ ដែលកើតអំពីបុថុជ្ជន លោកព្រងើយកន្តើយនឹងទិដ្ឋិ ដែលជនទាំងឡាយដទៃ កំពុងប្រកាន់ ។

(៣៦៦) មុនិក្នុងលោកនេះ លះបង់នូវគន្ថៈទាំងឡាយ កាលវិវាទទាំងឡាយកើតឡើងហើយ លោកជាអ្នកមិនលុះក្នុងពួក កាលពួកជនមិនស្ងប់ លោកជាអ្នកស្ងប់ ជាអ្នកព្រងើយ ជាអ្នកមិនប្រកាន់ នូវលទ្ធិដែលជនទាំងឡាយដទៃ កំពុងប្រកាន់ ។

(៣៦៧) អធិប្បាយពាក្យថា មុនិក្នុងលោកនេះ លះបង់នូវគន្ថៈទាំងឡាយ ត្រង់ពាក្យថា គន្ថៈ បានដល់គន្ថៈ ៤ គឺ អភិជ្ឈាកាយគន្ថៈ ព្យាបាទកាយគន្ថៈ សីលព្វតបរាមាសកាយគន្ថៈ ឥទំសច្ចាភិនិវេសកាយគន្ថៈ ។ តម្រេកក្នុងទិដ្ឋិរបស់ខ្លួន ហៅថា អភិជ្ឈាកាយគន្ថៈ ។

បរវាទេសុ អាឃាតោ អប្បច្ចយោ ព្យាបាទោ កាយ-
គន្ថោ ។ អត្តនោ សីលំ វា វត្តំ វា សីលព្វតំ វា បរាមសតិ
សីលព្វតបរាមាសោ កាយគន្ថោ ។ អត្តនោ ទិដ្ឋិ ឥទំ-
សច្ចាភិនិវេសោ កាយគន្ថោ ។ វិសជ្ជេតិ គន្ថេ
វោសជ្ជិត្វា វា វិសជ្ជ ។ អថវា គន្ថេ គធិតេ គន្ថិតេ
ពទ្ធេ វិពទ្ធេ អាពទ្ធេ លគ្គេ លគ្គិតេ បលិពុទ្ធេ ពន្ធនេ
ផោដយិត្វា វា វិសជ្ជ ។ យថា វយ្ហំ វា រថំ វា សកដំ វា
សន្ទមានិកំ វា សជ្ជំ វិសជ្ជំ ករោន្តិ វិកោបេន្តិ ឯវមេវ
គន្ថេ វោសជ្ជិត្វា វា វិសជ្ជ អថវា គន្ថេ គធិតេ គន្ថិតេ
ពទ្ធេ វិពទ្ធេ អាពទ្ធេ លគ្គេ លគ្គិតេ បលិពុទ្ធេ ពន្ធនេ
ផោដយិត្វា វា វិសជ្ជ ។ មុនីតិ មោនំ វុច្ចតិ ញាណំ
យា បញ្ញា បជាននា ។បេ។ សង្គជាលមតិច្ច សោ
មុនិ ។ ឥធាតិ ឥមិស្សា ទិដ្ឋិយា ។បេ។ ឥមស្មិំ
មនុស្សលោកេតិ វិសជ្ជ គន្ថានិ មុនីធ លោកេ ។

ការគុំគួន ការអាក់អន់ ក្នុងវាទៈរបស់បុគ្គលដទៃ ហៅថា ព្យាបាទកាយគន្ថៈ ។ បុគ្គលស្ទាបអង្អែលសីលឬវត្ត ឬក៏សីលវត្តរបស់ខ្លួន ហៅថា សីលព្វតបរាមាសកាយគន្ថៈ ។ សេចក្តីយល់ឃើញរបស់ខ្លួន ហៅថា ឥទំសច្ចាភិនិវេសកាយគន្ថៈ ។ ពាក្យថា លះបង់ គឺបោះបង់ ឬលះចោលនូវគន្ថៈទាំងឡាយ ។ ឬថា ស្រាយ ឬគ្រដោះចេញ នូវគន្ថៈទាំងឡាយ ដែលចាក់ស្រេះ ក្រង ឆ្វាក់ ពាក់ព័ន្ធ ពាក់មាំ ជាប់ ជំពាក់ បង់មាំ បង់ជាប់ ។ ជនទាំងឡាយរុះរើ ធ្វើឲ្យខ្ទេចខ្ទី នូវវក្តី រថក្តី រទេះក្តី រថទ្រង់គ្រឿងក្តី យ៉ាងណាមិញ មុនិបោះបង់ ឬលះចោលនូវគន្ថៈទាំងឡាយ ឬថាស្រាយ ឬគ្រដោះចេញនូវគន្ថៈទាំងឡាយ ដែលចាក់ស្រេះ ក្រង ឆ្វាក់ ពាក់ព័ន្ធ ជាប់មាំ ជាប់ ជំពាក់ បង់មាំ បង់ជាប់ យ៉ាងនោះដែរ ។ ពាក្យថាមុនិ សេចក្តីថា ញាណ បញ្ញា ការដឹងច្បាស់ លោកហៅថា មោនៈ ។បេ។ មុនិនោះ កន្លងនូវសំណាញ់ គឺកិលេសជាគ្រឿងបំពាក់ ។ ពាក្យថា ក្នុងលោកនេះ គឺក្នុងទិដ្ឋិនេះ ។បេ។ ក្នុងមនុស្សលោកនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) មុនិក្នុងលោកនេះ លះបង់នូវគន្ថៈទាំងឡាយ ។

តេរសមោ មហាវិយូហសុត្តនិទ្ទេសោ

(៣៦៨) វិវាទជាតេសុ ច វគ្គសារីតិ វិវាទជាតេសុ សញ្ជាតេសុ និព្វត្តេសុ អភិនិព្វត្តេសុ បាតុភូតេសុ ឆន្ទាគតឹ គច្ឆន្តេសុ ទោសាគតឹ គច្ឆន្តេសុ មោហាគតឹ គច្ឆន្តេសុ ភយាគតឹ គច្ឆន្តេសុ ច ឆន្ទាគតឹ គច្ឆតិ ច ទោសាគតឹ គច្ឆតិ ច មោហាគតឹ គច្ឆតិ ច ភយាគតឹ គច្ឆតិ ច រាគវសេន គច្ឆតិ ច ទោសវសេន គច្ឆតិ ច មោហវសេន គច្ឆតិ ច មានវសេន គច្ឆតិ ច ទិដ្ឋិវសេន គច្ឆតិ ច ឧទ្ធច្ចវសេន គច្ឆតិ ច វិចិកិច្ឆាវសេន គច្ឆតិ ច អនុសយវសេន គច្ឆតិ ច វគ្គេហិ ធម្មេហិ យាយតិ និយ្យតិ វុយ្ហតិ សំហារិយតីតិ វិវាទជាតេសុ ច វគ្គសារី ។

(៣៦៩) សន្តោ អសន្តេសុ ឧបេក្ខកោ សោតិ សន្តោតិ រាគស្ស សន្តត្តា សន្តោ ទោសស្ស សន្តត្តា សន្តោ មោហស្ស សន្តត្តា សន្តោ ។បេ។ សព្វាកុសលាភិសង្ខារានំ សន្តត្តា សមិតត្តា វូបសមិតត្តា វិជ្ឈាតត្តា និព្វុតត្តា វិគតត្តា បដិប្បស្សទ្ធត្តា សន្តោ ឧបសន្តោ វូបសន្តោ និព្វុតោ បដិប្បស្សទ្ធោតិ សន្តោ ។

មហាវិយូហសុត្តនិទ្ទេស ទី ១៣

[៣៦៨] ពាក្យថា កាលវិវាទទាំងឡាយ (កើតហើយ) លោកជាអ្នកមិនលុះក្នុងពួក គឺកាលវិវាទទាំងឡាយកើតព្រមហើយ លេចឡើង លេចឡើងចំពោះ កើតប្រាកដ កាលដល់នូវឆន្ទាគតិ ដល់នូវទោ-សាគតិ ដល់នូវមោហាគតិ ដល់នូវភយាគតិ លោកក៏មិនដល់នូវឆន្ទាគតិ មិនដល់នូវទោសាគតិ មិនដល់នូវមោហាគតិ មិនដល់នូវភយាគតិ មិនលុះដោយអំណាចរាគៈ មិនលុះដោយអំណាចទោសៈ មិនលុះដោយអំណាចមោហៈ មិនលុះដោយអំណាចមានះ មិនលុះដោយអំណាចទិដ្ឋិ មិនលុះដោយអំណាចឧទ្ធច្ចៈ មិនលុះដោយអំណាចវិចិកិច្ឆា មិនលុះដោយអំណាចអនុស័យ គឺមិនត្រូវធម៌ជាពួក ឲ្យទៅ នាំទៅ បន្សាត់ទៅ ក្តួចយកទៅ ហេតុនោះ (ទ្រង់ត្រាស់ថា) កាលវិវាទទាំងឡាយ (កើតហើយ) លោកជាអ្នកមិនលុះក្នុងពួក ។

[៣៦៩] អធិប្បាយពាក្យថា កាលបើពួកជនមិនស្ងប់ លោកជាអ្នកស្ងប់ ជាអ្នកព្រងើយកន្តើយ ត្រង់ពាក្យថា ជាអ្នកស្ងប់ គឺជាអ្នកស្ងប់ព្រោះស្ងប់រាគៈ ជាអ្នកស្ងប់ ព្រោះស្ងប់ទោសៈ ជាអ្នកស្ងប់ ព្រោះស្ងប់មោហៈ ។ បេ ។ ជាអ្នកស្ងប់ រម្ងាប់ ស្ងប់ស្ងៀម រលត់ ស្ងប់រម្ងាប់ព្រោះស្ងប់ រម្ងាប់ ស្ងប់ស្ងៀម រលាយ រលត់ ទៅប្រាស ស្ងប់រម្ងាប់នូវអកុសលាភិសង្ខារទាំងពួង ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកស្ងប់ ។

អសន្តេសូតិ អសន្តេសុ អនុបសន្តេសុ អវូបសន្តេសុ អនិព្វុតេសុ អប្បដិប្បស្សទ្ធេសូតិ សន្តោ អសន្តេសុ ។ ឧបេក្ខកោ សោតិ អរហា ឆឡង្គុបេក្ខាយ សមន្នាគតោ ចក្ខុនា រូបំ ទិស្វា នេវ សុមនោ ហោតិ ន ទុម្មនោ ឧបេក្ខកោ វិហរតិ សតោ សម្បជានោ ។ សោតេន សទ្ទំ សុត្វា ។បេ។ កាលំ កង្ខតិ ភាវិតោ សុទន្តោតិ សន្តោ អសន្តេសុ ឧបេក្ខកោ សោ ។

(៣៧០) អនុគ្គហោ ឧគ្គហណន្តិ មញ្ញេតិ អញ្ញេ តណ្ហាវសេន ទិដ្ឋិវសេន គណ្ហន្តិ បរាមសន្តិ អភិនិវិសន្តិ អរហា ឧបេក្ខតិ ន គណ្ហាតិ ន បរាមសតិ នាភិនិវិសតីតិ អនុគ្គហោ ឧគ្គហណន្តិ មញ្ញេ ។ តេនាហ ភគវា

ពាក្យថា កាលពួកជនមិនស្ងប់ គឺកាលពួកជនមិនស្ងប់ មិនរម្ងាប់ មិនស្ងប់ស្ងៀម មិនរលត់ មិនស្ងប់រម្ងាប់ ហេតុនោះ (ទ្រង់ត្រាស់ថា) កាលពួកជនមិនស្ងប់ លោកជាអ្នកស្ងប់ ។ ពាក្យថា លោកជាអ្នកព្រងើយកន្តើយ សេចក្តីថា ព្រះអរហន្តប្រកបដោយឆឡង្គុបេក្ខា ឃើញរូបដោយភ្នែក ជាអ្នកមានចិត្តមិនរីករាយ មានចិត្តមិនអាក់អន់ នៅព្រងើយមានសតិសម្បជញ្ញៈ ។ ព្រួសំឡេងដោយត្រចៀក ។ បេ ។ ជាអ្នកអប់រំខ្លួនខ្លួនល្អ រង់ចាំតែមរណកាល ហេតុនោះ (ទ្រង់ត្រាស់ថា) កាលពួកជនមិនស្ងប់ លោកជាអ្នកស្ងប់ ជាអ្នកព្រងើយកន្តើយ ។

(៣៧០) ពាក្យថា ជាអ្នកមិនប្រកាន់ នូវលទ្ធិដែលជនទាំងឡាយដទៃ កំពុងប្រកាន់ គឺជនដទៃ រមែងប្រកាន់ ស្ទាបអង្អែលប្រកាន់ស្អិត ដោយអំណាចតណ្ហា ដោយអំណាចទិដ្ឋិ ព្រះអរហន្តតែងព្រងើយ មិនប្រកាន់ មិនស្ទាបអង្អែល មិនប្រកាន់ស្អិត ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកមិនប្រកាន់ នូវលទ្ធិដែលជនទាំងឡាយដទៃ កំពុងប្រកាន់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

តេរសមោ មហាវិយូហសុត្តនិទ្ទេសោ

វិសជ្ជ គន្ថានិ មុនីធ លោកេ
វិវាទជាតេសុ ន វគ្គសារី
សន្តោ អសន្តេសុ ឧបេក្ខកោ សោ
អនុគ្គហោ ឧគ្គហណន្តិ មញ្ញេតិ ។

(៣៧១) បុព្វាសវេ ហិត្វា នវេ អកុព្វំ(១)
ន ឆន្ទគូ នោបិ និវិដ្ឋវាទី
ស វិប្បមុត្តោ ទិដ្ឋិគតេហិ ធីរោ
ន លិម្បតី លោកេ អនត្តគរហី ។

(៣៧២) បុព្វាសវេ ហិត្វា នវេ អកុព្វន្តិ បុព្វាសវា(២) វុច្ចន្តិ អតីតា រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណំ ។ អតីតេ សង្ខារេ អារព្ភ យេ កិលេសា ឧប្បជ្ជេយ្យុំ តេ កិលេសេ ហិត្វា ចជិត្វា បរិច្ចជិត្វា បជហិត្វា វិនោទិត្វា ព្យន្តីករិត្វា អនភាវង្គមិត្វាតិ បុព្វាសវេ ហិត្វា ។

---

១ ម. អកុព្វំ ។ ២ ម អកុព្វន្ត ។

មុនិ ក្នុងលោកនេះ លះបង់នូវគន្ថៈទាំងឡាយ កាលវិវាទទាំងឡាយ (កើតហើយ) លោកជាអ្នកមិនលុះក្នុងពួក កាលពួកជនមិនស្ងប់ លោកជាអ្នកស្ងប់ ជាអ្នកព្រងើយកន្តើយ ជាអ្នកមិនប្រកាន់ នូវលទ្ធិដែលជនទាំងឡាយដទៃ កំពុងប្រកាន់ ។

(៣៧១) អ្នកប្រាជ្ញនោះ លះបង់អាសវៈខាងដើម មិនធ្វើអាសវៈថ្មី មិនដល់នូវឆន្ទាគតិ ជាអ្នកមិនមានវាទៈតាំងមាំ រួចស្រឡះ ចាកទិដ្ឋិទាំងឡាយ ជាអ្នកមិនតិះដៀលខ្លួនឯង មិនប្រឡាក់ក្នុងលោក ។

(៣៧២) ពាក្យថា លះបង់អាសវៈខាងដើម មិនធ្វើអាសវៈថ្មី សេចក្តីថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាអតីត លោកហៅថា អាសវៈខាងដើម កិលេសណា ប្រារព្ធសង្ខារទាំងឡាយ ជាអតីត ហើយកើតឡើង (អ្នកប្រាជ្ញ) លះបង់ លះបោល លះស្រឡះ លះផ្តាច់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវកិលេសទាំងនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) លះបង់អាសវៈខាងដើម ។

នវេ អកុព្វន្តិ នវា វុច្ចន្តិ បច្ចុប្បន្នា រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណំ ។ បច្ចុប្បន្នេ សង្ខារេ អារព្ភ ឆន្ទំ អកុព្វមានោ បេមំ អកុព្វមានោ ភតិំ អកុព្វមានោ អជនយមានោ អសញ្ជនយមានោ អនិព្វត្តយមានោ នាភិនិព្វត្តយមានោតិ បុព្វាសវេ ហិត្វា នវេ អកុព្វំ ។

(៣៧៣) ន ឆន្ទគូ នោបិ និវិសវាទីតិ ន ឆន្ទគូតិ(១) ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយាគតឹ គច្ឆតិ ន រាគវសេន គច្ឆតិ ន ទោសវសេន គច្ឆតិ ន មោហវសេន គច្ឆតិ ន មានវសេន គច្ឆតិ ន ទិដ្ឋិវសេន គច្ឆតិ ន ឧទ្ធច្ចវសេន គច្ឆតិ ន វិចិកិច្ឆាវសេន គច្ឆតិ ន អនុសយវសេន គច្ឆតិ ន វគ្គេហិ ធម្មេហិ យាយតិ និយ្យតិ វុយ្ហតិ សំហរិយតីតិ(២) ន ឆន្ទគូ ។ នោបិ និវិស្សវាទីតិ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ន និវិស្សវាទី អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា

---

១ ម. ឆន្ទគូតីតិ នត្ថិ ។ ២ ម. នសំហរិយ្យតីតិ ។

ពាក្យថា មិនធ្វើអាសវៈថ្មី សេចក្ដីថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាបច្ចុប្បន្ន លោកហៅថា អាសវៈថ្មី ៗ លោកមិនធ្វើឆន្ទៈ មិនធ្វើសេចក្ដីស្រឡាញ់ មិនធ្វើតម្រេក មិនឲ្យកើត មិនឲ្យកើតព្រម មិនឲ្យលេចឡើង មិនឲ្យលេចឡើងចំពោះ ព្រោះប្រារព្ធសង្ខារជាបច្ចុប្បន្ន ហេតុនោះ (ទ្រង់ត្រាស់ថា) លះបង់អាសវៈខាងដើម មិនធ្វើអាសវៈថ្មី ៗ

(៣៧៣) អធិប្បាយពាក្យថា មិនដល់នូវឆន្ទាគតិ មិនមានវាទៈតាំងមាំ ត្រង់ពាក្យថា មិនដល់នូវឆន្ទាគតិ គឺមិនដល់នូវឆន្ទាគតិ មិនដល់នូវទោសាគតិ មិនដល់នូវមោហាគតិ មិនដល់នូវភយាគតិ មិនលុះដោយអំណាចរាគៈ មិនលុះដោយអំណាចទោសៈ មិនលុះដោយអំណាចមោហៈ មិនលុះដោយអំណាចមានះ មិនលុះដោយអំណាចទិដ្ឋិ មិនលុះដោយអំណាចឧទ្ធច្ចៈ មិនលុះដោយអំណាចវិចិកិច្ឆា មិនលុះដោយអំណាចអនុស័យ មិនត្រូវធម៌ជាពួកឲ្យទៅ នាំទៅ បន្សាត់ទៅ កួបយកទៅទេ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនដល់នូវឆន្ទាគតិ ៗ ពាក្យថា ជាអ្នកមិនមានវាទៈតាំងមាំ គឺជាអ្នកមិនមានវាទៈតាំងមាំថា លោកទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ថាលោកមិនទៀង ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ។ បេ ។ ជាអ្នកមិនមានវាទៈតាំងមាំថា សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀត ក៏មិនមែន

ឥទមេវ សច្ចំ មោឃមញ្ញន្តិ ន និវិស្សវាទីតិ ន ជន្តុ នោបិ និវិស្សវាទី ។

(៣៧៤) ស វិប្បមុត្តោ ទិដ្ឋិគតេហិ ធីរោតិ តស្ស ទ្វាសដ្ឋី ទិដ្ឋិគតានិ បហីនានិ សមុច្ឆិន្នានិ វូបសន្តានិ បដិប្បស្សទ្ធានិ អភព្វុប្បត្តិកានិ ញាណគ្គិនា ទឌ្ឍានិ សោ ទិដ្ឋិគតេហិ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ ។ ធីរោតិ ធីរោ បណ្ឌិតោ បញ្ញវា ពុទ្ធិមា ញាណី វិភាវី មេធាវីតិ ស វិប្បមុត្តោ ទិដ្ឋិគតេហិ ធីរោ ។

(៣៧៥) ន លិម្បតី លោកេ អនត្តគរហីតិ លេបាតិ ទ្វេ លេបា តណ្ហាលេបោ ច ទិដ្ឋិលេបោ ច ។បេ។ អយំ តណ្ហាលេបោ ។បេ។ អយំ ទិដ្ឋិលេបោ ។ តស្ស តណ្ហាលេបោ បហីនោ ទិដ្ឋិលេបោ បដិនិស្សដ្ឋោ តណ្ហាលេបស្ស[១] បហីនត្តា ទិដ្ឋិលេបស្ស បដិនិស្សដ្ឋត្តា អនុបលិត្តោ អបាយលោកេ ន លិម្បតិ មនុស្សលោកេ ន លិម្បតិ ទេវលោកេ ន លិម្បតិ ខន្ធលោកេ ន លិម្បតិ ធាតុលោកេ ន លិម្បតិ

១ ម. តស្ស តណ្ហាលេបស្ស ។

ពាក្យនេះ ជាពាក្យពិត ពាក្យដទៃជាមោឃៈ ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកមិនដល់នូវឆន្ទាគតិ មិនមានវាទៈតាំងមាំ ។

(៣៧៤) អ្នកប្រាជ្ញនោះ រួចស្រឡះចាកទិដ្ឋិទាំងឡាយ គឺទិដ្ឋិ ៦២ អ្នកប្រាជ្ញនោះ លះបង់ ផ្ដាច់ផ្ដិល ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ អ្នកប្រាជ្ញនោះ រួចស្រឡះ ប្រាសចាកទិដ្ឋិទាំងឡាយ មានចិត្តប្រាសចាកដែន គឺកិលេស ។ ពាក្យថា អ្នកប្រាជ្ញ គឺអ្នកប្រាជ្ញ បណ្ឌិត អ្នកមានប្រាជ្ញា មានកិរិយាដឹង មានញាណ មានប្រាជ្ញាធ្លុះ មានប្រាជ្ញាជាគ្រឿងទំលាយកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកប្រាជ្ញនោះ រួចស្រឡះចាកទិដ្ឋិទាំងឡាយ ។

(៣៧៥) អធិប្បាយពាក្យថា ជាអ្នកមិនតិះដៀលខ្លួនឯង មិនប្រឡាក់ក្នុងលោក ត្រង់ពាក្យថា ប្រឡាក់ បានដល់ការប្រឡាក់ ២ គឺ ការប្រឡាក់គឺតណ្ហា ១ ការប្រឡាក់គឺទិដ្ឋិ ១ ។ បេ ។ នេះការប្រឡាក់គឺតណ្ហា ។ បេ ។ នេះការប្រឡាក់គឺទិដ្ឋិ ។ បុគ្គលនោះ លះបង់ការប្រឡាក់គឺតណ្ហា រលាស់ចោលការប្រឡាក់គឺទិដ្ឋិ បុគ្គលនោះ ជាអ្នកមិនប្រឡាក់ ព្រោះលះបង់ការប្រឡាក់គឺតណ្ហា រលាស់ចោលការប្រឡាក់គឺទិដ្ឋិ រមែងមិនប្រឡាក់ក្នុងអបាយលោក មិនប្រឡាក់ក្នុងមនុស្សលោក មិនប្រឡាក់ក្នុងទេវលោក មិនប្រឡាក់ក្នុងខន្ធលោក

អាយតនលោកេ ច លិម្បតិ ច សំលិម្បតិ ឧបលិម្បតិ អលិត្តោ អសំលិត្តោ អនុបលិត្តោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ ន លិម្បតិ លោកេ ។ អនត្តគរហីតិ ទ្វីហិ ការណេហិ អត្តានំ គរហតិ កតត្តា ច អកតត្តា ច ។ កថំ កតត្តា ច អកតត្តា ច អត្តានំ គរហតិ ។ កតំ មេ កាយទុច្ចរិតំ អកតំ មេ កាយសុចរិតន្តិ អត្តានំ គរហតិ កតំ មេ វចីទុច្ចរិតំ កតំ មេ មនោទុច្ចរិតំ កតោ មេ បាណាតិបាតោ ។ បេ ។ កតា មេ មិច្ឆាទិដ្ឋិ អកតា មេ សម្មាទិដ្ឋីតិ អត្តានំ គរហតិ ។ ឯវំ កតត្តា ច អកតត្តា ច អត្តានំ គរហតិ ។ អថវា សីលេសុម្ហិ ន បរិបូរការីតិ អត្តានំ គរហតិ ឥន្ទ្រិយេសុម្ហិ អគុត្តទ្វារោតិ ភោជនេ អមត្តញ្ញុម្ហីតិ ជាគរិយមននុយុត្តោតិ ន សតិសម្បជញ្ញេន សមន្នាគតោតិ អភាវិតា មេ ចត្តារោ សតិបដ្ឋានាតិ អភាវិតា មេ ចត្តារោ សម្មប្បធានាតិ អភាវិតា មេ ចត្តារោ ឥទ្ធិបាទាតិ អភាវិតានិ មេ បញ្ចិន្ទ្រិយានីតិ អភាវិតានិ មេ

មិនប្រឡាក់ក្នុងធាតុលោក មិនប្រឡាក់ មិនប្រឡាក់ព្រម មិនចូលទៅប្រឡាក់ ក្នុងអាយតនលោក ជាអ្នកមិនប្រឡាក់ មិនប្រឡាក់ព្រម មិនចូលទៅជិតប្រឡាក់ ឃ្លាតចេញ រលាស់ចេញ រួចស្រឡះ មិនប្រកបសម្រេចនៅដោយចិត្តដែលប្រាសចាកដែនគឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) មិនប្រឡាក់ក្នុងលោក ។ ពាក្យថា ជាអ្នកមិនតិះដៀលខ្លួនឯង សេចក្ដីថា បុគ្គលរមែងតិះដៀលខ្លួនឯងដោយហេតុ ២ គឺ អំពើដែលខ្លួនធ្វើហើយ ១ មិនធ្វើហើយ ១ ។ តិះដៀលខ្លួនឯង ព្រោះអំពើដែលខ្លួនធ្វើហើយ នឹងមិនធ្វើហើយ តើដូចម្ដេច ។ តិះដៀលខ្លួនឯងថា កាយទុច្ចរិតអញធ្វើហើយ កាយសុច្ចរិតអញមិនបានធ្វើ តិះដៀលខ្លួនឯងថា វចីទុច្ចរិតអញធ្វើហើយ មនោទុច្ចរិតអញធ្វើហើយ បាណាតិបាតអញធ្វើហើយ ។ បេ ។ មិច្ឆាទិដ្ឋិ អញធ្វើហើយ សម្មាទិដ្ឋិអញមិនបានធ្វើ ។ តិះដៀលខ្លួនឯង ព្រោះអំពើដែលខ្លួនធ្វើហើយ នឹងមិនធ្វើហើយយ៉ាងនេះឯង ។ ម្យ៉ាងទៀត តិះដៀលខ្លួនឯងថា អញមិនបានបំពេញក្នុងសីលទាំងឡាយ តិះដៀលខ្លួនឯងថា អញមិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ថាអញមិនដឹងប្រមាណក្នុងភោជន ថាអញមិនប្រកបរឿយ ៗ នូវការភ្ញាក់រឭក ថាអញមិនប្រកបដោយសតិនឹងសម្បជញ្ញៈ ថាសតិប្បដ្ឋានទាំង ៤ អញមិនបានចំរើន ថាសម្មប្បធាន ៤ អញមិនបានចំរើន ថាឥទ្ធិបាទ ៤ អញមិនបានចំរើន ថាឥន្ទ្រិយ ៥ អញមិនបានចំរើន

តេរសមោ មហាវិយូហសុត្តនិទ្ទេសោ

បញ្ញា ពលា នីតិ អភាវិតា មេ សត្ត ពោជ្ឈង្គាតិ អភាវិតោ មេ អរិយោ អដ្ឋង្គិកោ មគ្គោតិ ទុក្ខំ មេ អបរិញ្ញាតន្តិ ទុក្ខសមុទយោ មេ អប្បហីនោតិ មគ្គោ មេ អភាវិតោតិ និរោធោ មេ អសច្ឆិកតោតិ អត្តានំ គរហតិ ។ ឯវំ កតត្តា ច អកតត្តា ច អត្តានំ គរហតិ ។ ឯវំ អត្តគរហិយំ កម្មំ(១) អកុព្វមានោ អជនយមានោ អសញ្ជនយមានោ អនិព្វត្តយមានោ នាភិនិព្វត្តយមានោ អនត្តគរហីតិ ន លិម្បតី លោកេ អនត្តគរហី ។ តេនាហ ភគវា

បុព្វាសវេ ហិត្វា នវេ អកុព្វំ
ន ឆន្ទគូ នោបិ និវិស្សវាទី
ស វិប្បមុត្តោ ទិដ្ឋិគតេហិ ធីរោ
ន លិម្បតី លោកេ អនត្តគរហីតិ ។

(៣៧៦) ស សព្វធម្មេសុ វិសេនិភូតោ
យង្កិញ្ចិ ទិដ្ឋំវ(២) សុតំ មុតំ វា
ស បន្នភារោ មុនិ វិប្បមុត្តោ
ន កប្បិយោ នូបរតោ ន បត្ថិយោ(តិ ភគវា) ។

---

១ ម. ឯវំ អត្តគរហី តយិទំ កម្មំ ។ ២ ម. ទិដ្ឋញ្ច ។

ជាពលៈ ៥ អញមិនបានចំរើន ជាពោជ្ឈង្គ ៧ អញមិនបានចំរើន ជាអដ្ឋង្គិកមគ្គដ៏ប្រសើរ អញមិនបានចំរើន ជាទុក្ខអញមិនបានកំណត់ដឹង ជាទុក្ខសមុទ័យ អញមិនបានលះបង់ ជាមគ្គ អញមិនបានចំរើន ជានិរោធ អញមិនបានធ្វើឲ្យជាក់ច្បាស់ ។ តិះដៀលខ្លួនឯង ព្រោះអំពើដែលខ្លួនធ្វើនឹងមិនធ្វើហើយ យ៉ាងនេះឯង ។ មិនធ្វើ មិនឲ្យកើតព្រម មិនឲ្យលេចឡើង មិនឲ្យលេចឡើងចំពោះ នូវអំពើដែលគួរតិះដៀលខ្លួនយ៉ាងនេះ ឈ្មោះថាជាអ្នកមិនតិះដៀលខ្លួនឯង ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកមិនតិះដៀលខ្លួន រមែងមិនប្រឡាក់ក្នុងលោក ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

អ្នកប្រាជ្ញនោះ លះបង់អាសវៈខាងដើម មិនធ្វើអាសវៈថ្មី
មិនដល់នូវឆន្ទាគតិ ជាអ្នកមិនមានវាទៈតាំងមាំ រួចស្រឡះ
បាកទិដ្ឋិទាំងឡាយ ជាអ្នកមិនតិះដៀលខ្លួនឯង មិនប្រឡាក់
ក្នុងលោក ។

(៣៧៦) (ព្រះមានព្រះភាគទ្រង់ត្រាស់ថា) បុគ្គលនោះធ្វើ
សេនាណាមួយ ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ហើយ ឲ្យ
វិនាសក្នុងធម៌ទាំងពួង បុគ្គលនោះមានភារៈដាក់ចុះហើយ
ជាមុនិ រួចស្រឡះហើយ ជាអ្នកមិនមានការកំណត់ មិន
ត្រេកអរ មិនមានសេចក្ដីប្រាថ្នា ។

(៣៧៧) ស សព្វធម្មេសុ វិសេនិភូតោ យង្កិញ្ចិ ទិដ្ឋំវ សុតំ មុតំ វា សេនា វុច្ចតិ មារសេនា ។ កាយទុច្ចរិតំ មារសេនា វចីទុច្ចរិតំ មារសេនា មនោទុច្ចរិតំ មារសេនា រាគោ ទោសោ មោហោ កោធោ ឧបនាហោ មក្ខោ បឡាសោ ឥស្សា មច្ឆរិយំ មាយា សាឋេយ្យំ ថម្ភោ សារម្ភោ មានោ អតិមានោ មទោ បមាទោ សព្វេ កិលេសា សព្វេ ទុច្ចរិតា សព្វេ ទរថា សព្វេ បរិឡាហា សព្វេ សន្តាបា សព្វាកុសលាភិសង្ខារា មារសេនា ។ វុត្តំ ហេតំ ភគវតា

កាមា តេ បឋមា សេនា ទុតិយារតិ វុច្ចតិ
តតិយា ខុប្បិបាសា តេ ចតុត្ថី តណ្ហា បវុច្ចតិ
បញ្ចមំ ថីនមិទ្ធន្តេ ឆដ្ឋា ភីរុ(១) បវុច្ចតិ
សត្តមី វិចិកិច្ឆា តេ មក្ខោ ថម្ភោ តេ អដ្ឋមោ
លាភោ សិលោកោ សក្ការោ មិច្ឆាលទ្ធោ ច យោ យសោ
យោ ចត្តានំ សមុក្កំសេ បរេ ច អវជានតិ

---

១ ឱ. ម. ភីរូ ។

(៣៧៧) ពាក្យថា បុគ្គលនោះធ្វើសេនាណាមួយ ដែលខ្លួនឃើញ ៗ ប៉ះពាល់ហើយ ឲ្យវិនាសកុសលធម៌ទាំងពួង អធិប្បាយថា មារសេនា លោកហៅថា សេនា ។ កាយទុច្ចរិត ជាមារសេនា វចីទុច្ចរិត ជាមារសេនា មនោទុច្ចរិត ជាមារសេនា រាគៈ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង ការអន្ទះអន្ទែងទាំងពួង អកុសលាភិសង្ខារទាំងពួង ជាមារសេនា ។ សមដូចជាព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

កាមទាំងឡាយ ជាសេនាទី ១ របស់អ្នក សេចក្តីមិន
ត្រេកអរ គេហៅថា សេនាទី ២ សេចក្តីស្រេកឃ្លាន
ជាសេនាទី ៣ របស់អ្នក តណ្ហា គេហៅថា សេនាទី ៤
ថីនមិទ្ធៈ ជាសេនាទី ៥ របស់អ្នក សេចក្តីខ្លាច គេ
ហៅថា សេនាទី ៦ វិចិកិច្ឆា ជាសេនាទី ៧ របស់អ្នក
ការលុបគុណគេ ការរឹងរូស ជាសេនាទី ៨ របស់អ្នក
លាភៈ សេចក្តីសរសើរ សក្ការៈ យស ដែលបុគ្គលបាន
ខុសហើយក្តី បុគ្គលលើកខ្លួនក្តី បុគ្គលបង្អាប់អ្នកដទៃក្តី

ឯសា នមុចិ តេ សេនា កណ្ហស្សាភិប្បហារិណី

ន នំ អសូរោ ជិនាតិ ជេត្វា ច លភតេ សុខន្តិ ។

យតោ ចតូហិ អរិយមគ្គេហិ សព្វា ច មារសេនា សព្វេ ច បដិសេនិករា កិលេសា ជិតា ច បរាជិតា ច ភគ្គា វិប្បលុត្តា បរម្មុខា សោ វុច្ចតិ វិសេនិភូតោ ។ សោ ទិដ្ឋេ វិសេនិភូតោ សុតេ មុតេ វិញ្ញាតេ វិសេនិភូតោតិ ស សព្វធម្មេសុ វិសេនិភូតោ យង្កិញ្ចិ ទិដ្ឋំ សុតំ មុតំ វា ។

(៣៧៨) ស បន្នភារោ[១] មុនិ វិប្បមុត្តោតិ ភារោតិ តយោ ភារា ខន្ធភារោ កិលេសភារោ អភិសង្ខារភារោ ។ កតមោ ខន្ធភារោ ។ បដិសន្ធិយា រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណំ អយំ ខន្ធភារោ ។ កតមោ កិលេសភារោ ។ រាគោ ទោសោ មោហោ ។បេ។

---

១ ម. សម្បន្នភារោ ។

ម្នាលមារ នុះជាសេនារបស់អ្នក ដែលនាំមកនូវធម៌ខ្មៅ
បុគ្គលមិនក្លៀវក្លា មិនឈ្នះ នូវសេនានោះទេ បុគ្គលលុះ
ឈ្នះនូវសេនានោះ ទើបបានសុខ ។

មារសេនាទាំងអស់ផង កិលេសជាទីទំនាស់ទាំងអស់ផង ដែលបុគ្គលផ្ចាញ់ហើយ ទាំងធ្វើឲ្យចាញ់ហើយ បំបាត់បង់ រំលត់រំលាយ ក្នុងទីកំបាំងមុខ ដោយអរិយមគ្គ ៤ ក្នុងកាលណា ក្នុងកាលនោះ បុគ្គលនោះ លោកហៅថា អ្នកធ្វើសេនាឲ្យវិនាស ៗ បុគ្គលនោះជាអ្នកធ្វើសេនាឲ្យវិនាស ក្នុងធម៌ដែលខ្លួនឃើញ ជាអ្នកធ្វើសេនាឲ្យវិនាស ក្នុងធម៌ដែលខ្លួនឮ ដែលប៉ះពាល់ ដែលដឹងច្បាស់ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ ជាអ្នកធ្វើសេនាណាមួយទាំងពួង ដែលខ្លួនឃើញ ឮ ឬប៉ះពាល់ហើយ ឲ្យវិនាសក្នុងធម៌ទាំងពួង ។

(៣៧៨) អធិប្បាយពាក្យថា បុគ្គលនោះ មានភារៈដាក់ចុះហើយ ជាមុនិ រួចស្រឡះហើយ ត្រង់ពាក្យថា ភារៈ បានដល់ភារៈ ៣ គឺខន្ធភារៈ១ កិលេសភារៈ១ អភិសង្ខារភារៈ១ ។ ខន្ធភារៈ តើដូចម្តេច ។ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ អំពីបដិសន្ធិ នេះ ខន្ធភារៈ ។ កិលេសភារៈ តើដូចម្តេច ។ រាគៈ ទោសៈ មោហៈ ។ បេ ។

សព្វាកុសលាភិសង្ខារា អយំ កិលេសកាយោ ។ កតមោ អភិសង្ខារកាយោ ។ បុញ្ញាភិសង្ខារោ អបុញ្ញាភិសង្ខារោ អានេញ្ជាភិសង្ខារោ អយំ អភិសង្ខារកាយោ ។ យតោ ទុក្ខកាយោ ច កិលេសកាយោ ច អភិសង្ខារកាយោ ច បហីនា ហោន្តិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា សោ វុច្ចតិ បន្នកាយោ បតិតកាយោ ឱរោបិតកាយោ សមោរោបិតកាយោ និក្ខិត្តកាយោ បដិប្បស្សទ្ធកាយោ ។ មុនីតិ មោនំ វុច្ចតិ ញាណំ យា បញ្ញា បជាននា វិចយោ បវិចយោ ធម្មវិចយោ សល្លក្ខណា ឧបលក្ខណា បច្ចុបលក្ខណា បណ្ឌិច្ចំ កោសល្លំ នេបុញ្ញំ វេភព្យា ចិន្តា ឧបបរិក្ខា ភូរី មេធា បរិណាយិកា វិបស្សនា សម្បជញ្ញំ បតោទោ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ បញ្ញាសត្ថំ បញ្ញាបាសាទោ បញ្ញាអាលោកោ បញ្ញាឱភាសោ បញ្ញាបជ្ជោតោ បញ្ញារតនំ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ តេន ញាណេន សមន្នាគតោ

អកុសលាភិសង្ខារទាំងអស់ នេះ កិលេសភារៈ ។ អភិសង្ខារភារៈ តើដូចម្តេច ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អានេញ្ជាភិសង្ខារ នេះ អភិសង្ខារភារៈ ។ ខន្ធភារៈ កិលេសភារៈ និងអភិសង្ខារ-ភារៈ បុគ្គលលះបង់ហើយ ផ្តាច់បង់ឫសគល់ហើយ ធ្វើមិនឲ្យមានទីនៅ ដូចជាទីនៅនៃដើមត្នោត ដល់នូវការមិនមាន មានការមិនកើតតទៅទៀត ជាធម្មតា ក្នុងកាលណា (ក្នុងកាលនោះ) បុគ្គលនោះ លោកហៅថា អ្នកមានភារៈដាក់ចុះហើយ ជាអ្នកមានភារៈធ្លាក់ចុះ ទំលាក់ភារៈចោល ជម្រុះភារៈចេញ ដាក់ភារៈចេញ មានភារៈស្ងប់រម្ងាប់ហើយ ។ ពាក្យថា ជាមុនិ សេចក្តីថា ញាណ លោកហៅថា មោនៈ បានដល់បញ្ញា ការដឹងច្បាស់ ការសន្សំ ការជ្រើសរើស ការពិចារណាធម៌ ការកំណត់ព្រម ការចូលទៅកំណត់ ការកំណត់ចំពោះ ភាពជាអ្នកប្រាជ្ញ ភាពជាអ្នកឈ្លាស ភាពជាអ្នកមានប្រាជ្ញាល្អិត ភាពជាអ្នកចេះវែកញែក ការគិត ការពិ-ចារណា ប្រាជ្ញាដូចផែនដី ប្រាជ្ញាអាចកំចាត់បង់កិលេស ប្រាជ្ញាជាគ្រឿងគ្រួតត្រា ការឃើញច្បាស់ ការដឹងព្រម បញ្ញាដូចជាជន្លួញ បញ្ញាជាធំ បញ្ញាជាកម្លាំង បញ្ញាជាសស្ត្រាវុធ បញ្ញាដូចប្រាសាទ បញ្ញាជាពន្លឺ បញ្ញាជារស្មី បញ្ញាជាគ្រឿងបំភ្លឺ បញ្ញាជាកែវ ការមិនវង្វេង ការសន្សំធម៌ ការយល់ត្រូវ បុគ្គលអ្នកប្រកបដោយញាណនោះ

មុនិ មោនប្បត្តោតិ ។ តីណិ មោនេយ្យានិ កាយមោនេយ្យំ វចីមោនេយ្យំ មនោមោនេយ្យំ ។

កតមំ កាយមោនេយ្យំ ។ តិវិធានំ កាយទុច្ចរិតានំ បហានំ កាយមោនេយ្យំ ។ តិវិធំ កាយសុចរិតំ កាយមោនេយ្យំ ។ កាយារម្មណំ ញាណំ(១) កាយមោនេយ្យំ ។ កាយបរិញ្ញា កាយមោនេយ្យំ ។ បរិញ្ញាសហគតោ មគ្គោ កាយមោនេយ្យំ ។ កាយេ ឆន្ទរាគស្ស បហានំ កាយមោនេយ្យំ កាយសង្ខារនិរោធោ ចតុត្ថជ្ឈានសមាបត្តិ កាយមោនេយ្យំ ។ ឥទំ កាយមោនេយ្យំ ។

កតមំ វចីមោនេយ្យំ ។ ចតុព្វិធានំ វចីទុច្ចរិតានំ បហានំ វចីមោនេយ្យំ ។ ចតុព្វិធំ វចីសុចរិតំ វចីមោនេយ្យំ ។ វាចារម្មណំ ញាណំ វចីមោនេយ្យំ ។ វាចាបរិញ្ញា វចីមោនេយ្យំ ។ បរិញ្ញាសហគតោ មគ្គោ វចីមោនេយ្យំ ។ វាចាយ ឆន្ទរាគស្ស បហានំ វចីមោនេយ្យំ ។ វចីសង្ខារនិរោធោ ទុតិយជ្ឈានសមាបត្តិ វចីមោនេយ្យំ ។ ឥទំ វចីមោនេយ្យំ ។

---

១ ម. កាយារម្មណេ ។

ឈ្មោះថា មុនិ ជាអ្នកដល់នូវមោនៈ ។ មោនេយ្យៈ មាន ៣ គឺ កាយមោនេយ្យៈ ១ វចីមោនេយ្យៈ ១ មនោមោនេយ្យៈ ១ ។

កាយមោនេយ្យៈ តើដូចម្តេច ។ ការលះបង់កាយទុច្ចរិត ៣ ប្រការ ឈ្មោះថា កាយមោនេយ្យៈ ។ កាយសុចរិត ៣ ប្រការ ឈ្មោះថា កាយ-មោនេយ្យៈ ។ ញាណមានកាយជាអារម្មណ៍ ឈ្មោះថា កាយមោនេយ្យៈ ការកំណត់ដឹងកាយ ឈ្មោះថា កាយមោនេយ្យៈ ។ មគ្គប្រកបដោយការកំណត់ដឹង ឈ្មោះថា កាយមោនេយ្យៈ ។ ការលះបង់ឆន្ទរាគក្នុងកាយ ឈ្មោះថា កាយមោនេយ្យៈ ។ ចតុត្ថជ្ឈានសមាបត្តិជាគ្រឿងរលត់កាយសង្ខារ ឈ្មោះថា កាយមោនេយ្យៈ ។ នេះ កាយមោនេយ្យៈ ។

វចីមោនេយ្យៈ តើដូចម្តេច ។ ការលះវចីទុច្ចរិត ៤ ប្រការ ឈ្មោះថា វចីមោនេយ្យៈ ។ វចីសុចរិត ៤ ប្រការ ឈ្មោះថា វចីមោនេយ្យៈ ។ ញាណមានវាចាជាអារម្មណ៍ ឈ្មោះថា វចីមោនេយ្យៈ ។ ការកំណត់ដឹងដោយវាចា ឈ្មោះថា វចីមោនេយ្យៈ ។ មគ្គប្រកបដោយការកំណត់ដឹង ឈ្មោះថា វចីមោនេយ្យៈ ។ ការលះបង់ឆន្ទរាគក្នុងវាចា ឈ្មោះថា វចីមោនេយ្យៈ ។ ទុតិយជ្ឈានសមាបត្តិ ជាគ្រឿងរលត់វចីសង្ខារ ឈ្មោះថា វចីមោនេយ្យៈ ។ នេះ វចីមោនេយ្យៈ ។

កតមំ មនោមោនេយ្យំ ។ តិវិធានំ មនោទុច្ចរិតានំ បហានំ មនោមោនេយ្យំ ។ តិវិធំ មនោសុចរិតំ មនោមោនេយ្យំ ។ ចិត្តារម្មណំ ញាណំ មនោមោនេយ្យំ ។ ចិត្តបរិញ្ញា មនោមោនេយ្យំ ។ បរិញ្ញាសហគតោ មគ្គោ មនោមោនេយ្យំ ។ ចិត្តេ ឆន្ទរាគស្ស បហានំ មនោមោនេយ្យំ ។ ចិត្តសង្ខារនិរោធោ សញ្ញាវេទយិតនិរោធសមាបត្តិ មនោមោនេយ្យំ ។ ឥទំ មនោមោនេយ្យំ

កាយមុនឹ វាចាមុនឹ មនោមុនិមនាសវំ
មុនឹ មោនេយ្យសម្បន្នំ អាហុ សព្វប្បហាយិនំ ។
កាយមុនឹ វាចាមុនឹ មនោមុនិមនាសវំ
មុនឹ មោនេយ្យសម្បន្នំ អាហុ និន្ហាតបាបកំ ។

ឥមេហិ មោនេយ្យេហិ ធម្មេហិ សមន្នាគតា ឆ មុនយោ អាគារមុនយោ អនាគារមុនយោ សេក្ខមុនយោ អសេក្ខមុនយោ បច្ចេកមុនយោ មុនិមុនយោ ។ កតមេ អាគារមុនយោ ។ យេ តេ អាគារិកា ទិដ្ឋបទា វិញ្ញាតសាសនា ឥមេ អាគារមុនយោ ។

មនោមោនេយ្យៈ តើដូចម្តេច ។ ការលះបង់មនោទុច្ចរិត ៣ ប្រការ ឈ្មោះថា មនោមោនេយ្យៈ ។ មនោសុចរិត ៣ ប្រការ ឈ្មោះថា មនោមោនេយ្យៈ ។ ញាណមានចិត្តជាអារម្មណ៍ ឈ្មោះថា មនោមោនេយ្យៈ ។ ការកំណត់ដោយចិត្ត ឈ្មោះថា មនោមោនេយ្យៈ ។ មគ្គប្រកបដោយការកំណត់ដឹង ឈ្មោះថា មនោមោនេយ្យៈ ។ ការលះឆន្ទរាគក្នុងចិត្ត ឈ្មោះថា មនោមោនេយ្យៈ ។ សញ្ញាវេទយិតនិរោធសមាបត្តិជាគ្រឿងរលត់ចិត្តសង្ខារ ឈ្មោះថា មនោមោនេយ្យៈ ។ នេះ មនោមោនេយ្យៈ ។

បណ្ឌិតទាំងឡាយ ពោលនូវអ្នកប្រាជ្ញផ្លូវកាយ អ្នកប្រាជ្ញផ្លូវ
វាចា អ្នកប្រាជ្ញផ្លូវចិត្ត អ្នកប្រាជ្ញមិនមានអាសវៈ ដែលបរិបូណ៌
ដោយមោនេយ្យធម៌ ថាជាអ្នកលះបង់នូវបាបទាំងពួង ។
បណ្ឌិតទាំងឡាយ ពោលនូវអ្នកប្រាជ្ញផ្លូវកាយ អ្នកប្រាជ្ញផ្លូវ
វាចា អ្នកប្រាជ្ញផ្លូវចិត្ត អ្នកប្រាជ្ញមិនមានអាសវៈ ដែលបរិ-
បូណ៌ ដោយមោនេយ្យធម៌ ថាជាអ្នកលាងបាប ។

មុនិប្រកបដោយមោនេយ្យធម៌ទាំងនេះ មាន ៦ ពួក គឺ អាគារមុនិ អនាគារមុនិ សេក្ខមុនិ អសេក្ខមុនិ បច្ចេកមុនិ មុនិមុនិ ។ ពួកអាគារមុនិ តើដូចម្តេច ។ ពួកគ្រហស្ថណា បានឃើញនូវបទ គឺព្រះនិព្វាន បានដឹងច្បាស់នូវសាសនា ពួកនេះ ឈ្មោះអាគារមុនិ ។

តេរសមោ មហាវិយូហសុត្តនិទ្ទេសោ

កតមេ អនាគារមុនយោ យេ តេ បព្វជិតា ទិដ្ឋបទា វិញ្ញាតសាសនា ឥមេ អនាគារមុនយោ ។ សត្ត សេក្ខា សេក្ខមុនយោ ។ អរហន្តោ អសេក្ខមុនយោ ។ បច្ចេកពុទ្ធា បច្ចេកមុនយោ ។ មុនិមុនយោ តថាគតា អរហន្តោ សម្មាសម្ពុទ្ធា ។

ន មោនេន មុនិ ហោតិ មូឡ្ហរូបោ អវិទ្ទសុ
យោ ច តុលំវ បគ្គយ្ហ វរមាទាយ បណ្ឌិតោ
បាបានិ បរិវជ្ជេតិ ស មុនិ តេន សោ មុនិ
យោ មុនាតិ ឧភោ លោកេ មុនិ តេន បវុច្ចតិ
អសតញ្ច សតញ្ច ញត្វា ធម្មំ
អជ្ឈត្តំ ពហិទ្ធា ច សព្វលោកេ
ទេវមនុស្សេហិ បូជិតោ
យោ សោ(១) សង្គជាលមតិច្ច សោ មុនិ ។

---

១ ម. សោតិ នត្ថិ ។

ពួកអនាគារមុនិ តើដូចម្តេច ។ ពួកបព្វជិតណា បានឃើញនូវបទ គឺព្រះនិព្វាន បានដឹងច្បាស់នូវសាសនា ពួកនេះ ឈ្មោះអនាគារមុនិ ។ សេក្ខបុគ្គល ៧ ពួក ឈ្មោះសេក្ខមុនិ ។ ពួកព្រះអរហន្ត ឈ្មោះអសេក្ខ-មុនិ ។ ពួកព្រះបច្ចេកពុទ្ធ ឈ្មោះបច្ចេកមុនិ ។ ព្រះតថាគតទាំងឡាយ ជាអរហន្ត សម្មាសម្ពុទ្ធ ឈ្មោះមុនិមុនិ ។

បុគ្គលមានសភាពជាអ្នកវង្វេង មិនមានការចេះដឹង មិន
មែនឈ្មោះថាមុនិ ដោយការស្ងៀមទេ លុះតែបុគ្គលណា
ជាបណ្ឌិត កាន់យកធម៌ដ៏ប្រសើរ ហើយវៀរបង់ នូវបាប
ទាំងឡាយ ដូចបុគ្គល ផ្គង នូវជញ្ជីង (ហើយថ្លឹង)
បុគ្គលនោះ ឈ្មោះថាមុនិ បុគ្គលនោះ ឈ្មោះថាមុនិ ដោយ
ហេតុនោះ បុគ្គលណា ដឹងនូវប្រយោជន៍ទាំងពីរក្នុងលោក
បុគ្គលនោះ ទើបតថាគតហៅថា មុនិ ដោយហេតុនោះ
បុគ្គលណា ដឹងធម៌របស់ពួកអសប្បុរសផង របស់ពួក
សប្បុរសផង ទាំងខាងក្នុង ទាំងខាងក្រៅ ក្នុងលោក
ទាំងអស់ ជាបុគ្គលដែលទេវតានិងមនុស្សទាំងឡាយបូជា
ហើយ បានឆ្លងនូវសំណាញ់ គឺកិលេសជាគ្រឿងចំពាក់
បុគ្គលនោះ ឈ្មោះថា មុនិ ។

វិប្បមុត្តោតិ មុនិនោ រាគា ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ ទោសា ចិត្តំ មោហា ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ ។បេ។ សព្វាកុសលាភិសង្ខារេហិ ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តន្តិ ស បន្នភារោ(១) មុនិ វិប្បមុត្តោ ។

(៣៧៩) ន កប្បិយោ នូបរតោ ន បត្ថិយោតិ ភគវាតិ កប្បោតិ ទ្វេ កប្បា តណ្ហាកប្បោ ច ទិដ្ឋិកប្បោ ច ។បេ។ អយំ តណ្ហាកប្បោ ។បេ។ អយំ ទិដ្ឋិកប្បោ ។ តស្ស តណ្ហាកប្បោ បហីនោ ទិដ្ឋិកប្បោ បដិនិស្សដ្ឋោ តណ្ហាកប្បស្ស បហីនត្តា ទិដ្ឋិកប្បស្ស បដិនិស្សដ្ឋត្តា តណ្ហាកប្បំ វា ទិដ្ឋិកប្បំ វា ន កប្បេតិ ន ជនេតិ ន សញ្ជនេតិ ន និព្វត្តេតិ នាភិនិព្វត្តេតីតិ ន កប្បិយោ ។ នូបរតោតិ សព្វេ ពាលបុថុជ្ជនា កល្យាណបុថុជ្ជនំ ឧបាទាយ សត្ត សេក្ខា

១ ម. សម្បន្នភារោ ។

ពាក្យថា រួចស្រឡះ គឺ ចិត្តរបស់មុនិ រួច រួចវិសេស រួចស្រឡះ ចាករាគៈ ចិត្ត (រួចស្រឡះ) ចាកទោសៈ ចិត្ត រួច រួចវិសេស រួចស្រឡះ ចាកមោហៈ ។ បេ ។ ចិត្ត រួច រួចវិសេស រួចស្រឡះ ចាកអកុសលាភិសង្ខារទាំងអស់ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ មានភារៈដាក់ចុះហើយ ជាមុនិរួចស្រឡះហើយ ។

(៣៧៩) អធិប្បាយពាក្យថា ព្រះមានព្រះភាគ (ទ្រង់ត្រាស់ថា) ជាអ្នកមិនមានការកំណត់ មិនត្រេកអរ មិនមានសេចក្តីប្រាថ្នា ត្រង់ពាក្យថា ការកំណត់ បានដល់ការកំណត់ ២ គឺ ការកំណត់គឺតណ្ហា ១ ការកំណត់គឺទិដ្ឋិ ១ ។ បេ ។ នេះ ការកំណត់គឺតណ្ហា ។ បេ ។ នេះ ការកំណត់គឺទិដ្ឋិ ។ បុគ្គលនោះ លះបង់នូវការកំណត់គឺតណ្ហា រលាស់ចោលនូវការកំណត់គឺទិដ្ឋិ ព្រោះបានលះបង់ការកំណត់គឺតណ្ហា រលាស់ចោលការកំណត់គឺទិដ្ឋិ បុគ្គលនោះ មិនកំណត់ មិនឲ្យកើត មិនឲ្យកើតព្រម មិនឲ្យលេចឡើង មិនឲ្យលេចឡើងចំពោះ នូវការកំណត់គឺតណ្ហា ឬការកំណត់គឺទិដ្ឋិ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនមានការកំណត់ ។ ពាក្យថា ជាអ្នកមិនត្រេកអរ សេចក្តីថា ពាលបុថុជ្ជនទាំងអស់ រមែងត្រេកអរ សេក្ខបុគ្គលទាំង ៧ ពួក រាប់យកកល្យាណបុថុជ្ជនផង

អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិក-
តស្ស សច្ឆិកិរិយាយ អារមត្តិ វិរមត្តិ បដិវិរមត្តិ អរោ
អារតោ អស្ស វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្ប-
មុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យា-
តិ(១) ន កប្បិយោ នូបរតោ ។ ន បត្ថិយោតិ បត្ថនា
វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។បេ។ អភិជ្ឈា
លោភោ អកុសលមូលំ ។ យស្សេសា បត្ថនា បហីនា
សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញា-
ណគ្គិនា ទឌ្ឍា សោ វុច្ចតិ ន បត្ថិយោ ។ ភគវាតិ
គារវាធិវចនំ ។ អបិច ភគ្គរាគោតិ ភគវា ។ ភគ្គ-
ទោសោតិ ភគវា ។ ភគ្គមោហោតិ ភគវា ។
ភគ្គមានោតិ ភគវា ។ ភគ្គទិដ្ឋីតិ ភគវា ។

---

១ ម. វិហរតីតិ ។

រមែងត្រេកអរទួទៅ ត្រេកអរចំពោះ ដើម្បីដល់នូវគុណដែលខ្លួនមិនទាន់ដល់ ដើម្បីបាននូវគុណដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ ឯព្រះអរហន្តជាអ្នកឆ្ងាយ វៀរបង់ វៀរចំពោះ ឃ្លាតចេញ រលាស់ចោល រួចស្រឡះ មិនប្រកប មានចិត្តប្រាសចាកដែនគឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) មិនមានការកំណត់ មិនត្រេកអរ ។ ពាក្យថា មិនមានសេចក្តីប្រាថ្នា សេចក្តីថា តណ្ហា លោកហៅថា សេចក្តីប្រាថ្នា បានដល់សេចក្តីត្រេកអរ សេចក្តីត្រេកអរដ៏មានកំឡាំង ។បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ សេចក្តីប្រាថ្នានុ៎ះ បុគ្គលណា លះបង់ហើយ ផ្តាច់ផ្តិលហើយ ឲ្យស្ងប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះលោកហៅថា អ្នកមិនមានសេចក្តីប្រាថ្នា ។ ពាក្យថា ព្រះមានព្រះភាគ ជាពាក្យពោលដោយគោរព ។ ម្យ៉ាងទៀត ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បង់រាគៈ ។ ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បង់ទោសៈ ។ ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បង់មោហៈ ។ ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បង់មានះ ។ ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បង់ទិដ្ឋិ ។

ភក្តកណ្ដាកោតិ កតមា ។ ភក្តកិលេសោតិ កតមា ។ កដិ វិកដិ បដិវិកដិ ធម្មរតនន្តិ កតមា ។ កហំ អន្តការេ-តិ កតមា ។ ភាវិតកាយោតិ កតមា ។ ភាវិតសីលោតិ ភាវិតចិត្តោតិ ភាវិតបញ្ញោតិ កតមា ។ កដិ ហ កតមា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហសេយ្យកានិ បដិសល្លានសារុប្បានីតិ កតមា ។ ភាគី ហ កតមា ចីវរ-បិណ្ឌបាតសេនាសនគិលានបច្ចយភេសជ្ជបរិក្ខារានន្តិ កតមា ។ ភាគី ហ កតមា អត្ថរសស្ស ធម្មរសស្ស វិមុត្តិរសស្ស អធិសីលស្ស អធិចិត្តស្ស អធិបញ្ញា-យាតិ កតមា ។ ភាគី ហ កតមា ចតុន្នំ ឈានានំ ចតុន្នំ អប្បមញ្ញានំ ចតុន្នំ អរូបសមាបត្តីនន្តិ កតមា ។

ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បង់នូវបំរុង ១ ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់បំបាក់បង់នូវកិលេស ១ ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់ចែក រំលែក ញែក នូវធម្មរតនៈ ១ ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់ធ្វើនូវទីបំផុតនៃភពទាំងឡាយ ១ ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់ចំរើនព្រះកាយ ១ ឈ្មោះថា ព្រះមានព្រះភាគ ព្រោះហេតុទ្រង់ចំរើនសីល ចំរើនចិត្ត ចំរើនបញ្ញា ១ មួយទៀត ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុទ្រង់គប់រកនូវសេនាសនៈទាំងឡាយដ៏ស្ងាត់ គឺព្រៃតូចនិងព្រៃធំ ជាព្រៃមិនមានសំឡេង មិនមានការគឹកកង ជាព្រៃប្រាសចាកខ្យល់កាយនៃជន ជាព្រៃស្ងប់ស្ងាត់ចាកមនុស្ស សមគួរដល់ការពួនសម្ងំ ១ មួយទៀត ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ ១ មួយទៀត ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគទ្រង់មានភាគ នៃអត្ថរស ធម្មរស វិមុត្តិរស អធិសីល អធិចិត្ត អធិប្បញ្ញា ១ មួយទៀត ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃឈាន ៤ អប្បមញ្ញា ៤ អរូបសមាបត្តិ ៤ ១

ភាគី វា ភគវា អដ្ឋន្នំ វិមោក្ខានំ អដ្ឋន្នំ អភិភាយតនានំ នវន្នំ អនុបុព្វវិហារសមាបត្តីនន្តិ ភគវា ។ ភាគី វា ភគវា ទសន្នំ សញ្ញាភាវនានំ ទសន្នំ កសិណសមាបត្តីនំ អានាបានស្សតិសមាធិស្ស អសុភសមាបត្តិយាតិ ភគវា ។ ភាគី វា ភគវា ចតុន្នំ សតិបដ្ឋានានំ ចតុន្នំ សម្មប្បធានានំ ចតុន្នំ ឥទ្ធិបាទានំ បញ្ចន្នំ ឥន្ទ្រិយានំ បញ្ចន្នំ ពលានំ សត្តន្នំ ពោជ្ឈង្គានំ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្សាតិ ភគវា ។ ភាគី វា ភគវា ទសន្នំ តថាគតពលានំ ចតុន្នំ វេសារជ្ជានំ ចតុន្នំ បដិសម្ភិទានំ ឆន្នំ អភិញ្ញានំ ឆន្នំ ពុទ្ធធម្មានន្តិ ភគវា ។ ភគវាតិ នេតំ នាមំ មាតរា កតំ ន បិតរា កតំ ន ភាតរា កតំ ន ភគិនិយា កតំ ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ កតំ ន សមណព្រាហ្មណេហិ កតំ ន ទេវតាហិ កតំ វិមោក្ខន្តិកមេតំ ពុទ្ធានំ ភគវន្តានំ ពោធិយា មូលេ សហ សព្វញ្ញុតញ្ញាណស្ស បដិលាភា សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ន កប្បិយោ ន្ទូបរតោ ន បត្ថិយោតិ ភគវា ។

តេនាហ ភគវា

មួយទៀត ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃវិមោក្ខ ៨ អភិភាយតនៈ ៨ អនុបុព្វវិហារសមាបត្តិ ៩ ។ មួយទៀត ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគទ្រង់មានភាគនៃសញ្ញាភាវនា ១០ កសិណសមាបត្តិ ១០ អានាបានស្សតិសមាធិ អសុភសមាបត្តិ ។ មួយទៀត ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ។ មួយវិញទៀត ឈ្មោះថាព្រះមានព្រះភាគ ព្រោះហេតុព្រះមានព្រះភាគ ទ្រង់មានភាគនៃតថាគតពលៈ ១០ វេសារជ្ជៈ ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ ពុទ្ធធម៌ ៦ ។ ព្រះនាមថាព្រះមានព្រះភាគ នេះមិនមែនមាតាធ្វើ មិនមែនបិតាធ្វើ មិនមែនបងប្អូនប្រុសធ្វើ មិនមែនបងប្អូនស្រីធ្វើ មិនមែនពួកមិត្តអាមាត្យធ្វើ មិនមែនពួកញាតិសាលោហិតធ្វើ មិនមែនពួកសមណព្រាហ្មណ៍ធ្វើ មិនមែនពួកទេវតាធ្វើទេ ព្រះនាមថាព្រះមានព្រះភាគនេះ របស់ព្រះពុទ្ធទាំងឡាយ ដ៏មានព្រះភាគ ជាព្រះនាមកើតក្នុងទីបំផុតវិមោក្ខ ការបញ្ញត្តិថា មានព្រះភាគ នេះ (កើត) អំពីការត្រាស់ដឹង ព្រមដោយការបានចំពោះនូវសព្វញ្ញុតញ្ញាណ ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគ (ត្រាស់ថា) មិនមានការកំណត់ មិនត្រេកអរ មិនមានសេចក្តីប្រាថ្នា ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ស សព្វធម្មេសុ វិសេនិភូតោ
យង្កិញ្ចិ ទិដ្ឋំវ សុតំ មុតំ វា
ស បន្នភារោ មុនិ វិប្បមុត្តោ
ន កប្បិយោ នូបរតោ ន បត្ថិយោតិ
ភគវាតិ ៗ

តេរសមោ មហាវិយូហសុត្តនិទ្ទេសោ និដ្ឋិតោ ។

ព្រះមានព្រះភាគ (ទ្រង់ត្រាស់ថា) បុគ្គលនោះ ធ្វើសេនាណាមួយ ដែលឃើញ ឮ ប៉ះពាល់ហើយ ឲ្យវិនាសក្នុងធម៌ទាំងពួង បុគ្គលនោះមានភារៈដាក់ចុះហើយ ជាមុនិ រួចស្រឡះហើយ ជាអ្នកមិនមានការកំណត់ មិនត្រេកអរ មិនមានសេចក្តីប្រាថ្នា ។

ចប់ មហាវិយូហសុត្តនិទ្ទេស ទី ១៣ ។

---

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស មហានិទ្ទេសោ

## ទុតិយោ ភាគោ

---

មាតិកា អង្កេ


មហានិទ្ទេសេ នវមោ មាគណ្ឌិយសុត្តនិទ្ទេសោ . . ១

ទសមោ បុរាភេទសុត្តនិទ្ទេសោ . . . . . ៥១

ឯកាទសមោ កលហវិវាទសុត្តនិទ្ទេសោ . . ១៤២

ទ្វាទសមោ ចូឡវិយូហសុត្តនិទ្ទេសោ . . . ២០៥

តេរសមោ មហាវិយូហសុត្តនិទ្ទេសោ . . . ២៤៧


---

# សុត្តន្តបិដក

## ខុទ្ទកនិកាយ មហានិទ្ទេស

## ទុតិយភាគ

មាតិកា ទំព័រ


មហានិទ្ទេស មាគណ្ឌិយសុត្តនិទ្ទេស ទី ៩ . . . ១

បុរាភេទសុត្តនិទ្ទេស ទី ១០ . . . . . . ៤១

កលហវិវាទសុត្តនិទ្ទេស ទី ១១ . . . . ១៦២

ចូឡវិយូហសុត្តនិទ្ទេស ទី ១២ . . . . ២០៤

មហាវិយូហសុត្តនិទ្ទេស ទី ១៣ . . . . ២៦៧

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ដាប | ដាប់ | ២២ | ១៦ |
| បូល | បូរ | ២៦ | ២ |
| ៣ គឺការ | ៣ ការ | ,, | ១៨ |
| ដបម្ដេច | ដូចម្ដេច | ២៩ | ១០ |
| ដែលនិមិត្ត | ដែលជានិមិត្ត | ៣២ | ៦ |
| មិនប្រា  ចាក | មិនប្រាសចាក | ៣៣ | ១៨ |
| កយាគត | កយាគតិ | ៣៧ | ,, |
| វិច្ឆិកិច្ឆា | វិចិកិច្ឆា | ៣៨ | ៤ |
| ផ្ដាប់បង់ | ផ្ដាច់បង់ | ៤៤ | ៣ |
| មានះ  នាះ | មានះនោះ | ៤៤ | ១៤ |
| រកភយ | រីកភយ | ៥៦ | ៦ |
| ទិដ្ឋ្ឋិ | ទិដ្ឋិ | ៥៨ | ១៦ |
| ចារិកធុតង្គ | សបទានចារិកធុតង្គ | ៦៦ | ១០ |
| សបទានធុតង្គ | ធុតង្គ | ,, | ១១ |
| ព្រមព្រៀង | ព្រមព្រៀង | ៧១ | ១៤ |

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| បិណ្ឌបាត. | បិណ្ឌបាត | ៧៥ | ១១ |
| របស | របស់ | ,, | ១២ |
| ដិក្ហសម្ពស្ស | ដិក្ហសម្ពស្សៈ | ៧៦ | ១៦ |
| មិនសោយស្តាយ | មិនសោកស្តាយ | ៧៨ | ១៥ |
| កាធេៈ | កោធៈ | ៧៩ | ៨ |
| ឃ្មើសន៍ឃ្ម | ឃ្មើសឃ្មន៍ | ៩០ | ,, |
| តេចីវរកធុតង្គ៍ | តេចីវរិកធុតង្គ | ៩២ | ៦ |
| ផ្តាចផ្តិល | ផ្តាច់ផ្តិល | ៩៧ | ១២ |
| ខ្ទះខ្ទែន៍លាក | ខ្ទះខ្ទែន៍រកលាក | ១០៦ | ៥ |
| ,, | ,, | ,, | ១៦ |
| ,, | ,, | ១០៧ | ១១ |
| ព្រាះដា | ព្រោះដា | ១២៦ | ១៤ |
| ព្រាហ្ម | ព្រាហ្មណ៍ | ១២៩ | ១៥ |
| អន្ទះអន្ទ្យែង | អន្ទះអន្ទែង | ១៣០ | ១១ |
| មានទុក្ខលរត | មានទុក្ខរលត់ | ១៣៤ | ១២ |
| មុគ្គល | បុគ្គល | ១៣៨ | ១៧ |
| តាំ ឡើង | តាំងឡើង | ១៣៩ | ៧ |

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ពា្យថា | ពាក្យថា | ១៦១ | ៣ |
| នេះខ្ល | នេះខ្លះ | ១៦៦ | ៤ |
| (១៥២) | (១៥៣) | ១៦៧ | ៩ |
| អង្កៀស | រង្កៀស | ១៦៨ | ១៧ |
| ធម្មជាតា | ធម្មតា | ១៧៥ | ៩ |
| បាដិហារ្យ | បាដិហារិយ៍ | " | ១៣ |
| " | " | " | ១៤ |
| " | " | " | ១៧ |
| ជាតាំង | ជាទីតាំង | ១៧៩ | ១២ |
| ទ្រង់ថា | ទ្រង់ត្រាស់ថា | ១៨៤ | ៩ |
| សំដោយក | សំដៅយក | " | ១៩ |
| ធម៌សដ៏ម្បយុត្ត | ធម៌ដ៏សម្បយុត្ត | ១៨៥ | ១២ |
| សំដោ | សំដៅ | ១៩២ | ១៧ |
| រវើរកាយ | រវើរវាយ | " | " |
| បុគ្គលនាះ | បុគ្គលនោះ | ១៩៣ | ១៨ |
| សូមតាមលទ្ធិ | សមតាមលទ្ធិ | ១៩៧ | ៨ |
| (១៥៣) | (១៩៣) | ១៩៨ | ១៤ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ព្រាហ្មមួយ | ព្រាហ្មណ៍មួយ | ១៩៩ | " |
| សេបក្តី | សេចក្តី | " | ១៨ |
| ប្រកាន | ប្រកាន់ | ២០០ | ១០ |
| មិតាស់ | មិនទាស់ | ២០៣ | ៣ |
| ត្រាស់ហើថា | ត្រាស់ហើយថា | ២២៦ | ១៩ |
| គឺពាលយ៉ាងនេះ | គឺពេលយ៉ាងនេះ | ២២៩ | ៣ |
| មានបញ្ញាថោក | មានបញ្ញាថោក | ២៣៥ | ១២ |
| គបុគ្គល | គឺបុគ្គល | ២៣៦ | ១៩ |
| បរិសុទ្ធ | បរិសុទ្ធិ | ២៤១ | ៩ |
| មានវាទ | មានវាទៈ | ២៤២ | ២ |
| សុត្តនិទ្ទេ | សុត្តនិទ្ទេស | ២៤៧ | ១ |
| ព្រាណ៍ | ព្រាហ្មណ៍ | ២៤៨ | ៤ |
| ជ្រាគ្រឿប្រកាន់ | ជាគ្រឿងប្រកាន់ | ២៥៤ | ១២ |
| គី | គឺ | " | " |
| បរចិត្តញណ | បរចិត្តញ្ញាណ | ២៨៤ | ១៧ |
| អគ្គិកមគ្គ | អដ្ឋង្គិកមគ្គ | ២៨៥ | ១៦ |
| ដទៃ | ដទៃ | ២៩៥ | ១២ |

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | បដ្ឋលេខាយំ |
|---|---|---|---|
| ន. មយ្ហំ | ន មយ្ហំ | ៤ | ១៦ |
| ទិដ្ឋីសញ្ញោជនំ | ទិដ្ឋិសញ្ញោជនំ | ៦ | ១៤ |
| បរិសុទ្ធ | បរិសុទ្ធី | ១៣ | ៨ |
| អសី | អសី | " | ១៤ |
| ឥមញ្ច | ឥមញ្ច | ១៤ | ៥ |
| បឋមសិតញ្ញ | បឋមសិតញ្ញ | ១៥ | ១៣ |
| នាកិទិវសិតញ្ញ | នាកិទិវសិតញ្ញា | " | " |
| ឯវម្បិ | ឯវម្បិ | " | " |
| វត្តម្បី | វតម្បិ | ២០ | ១០ |
| ឧបម្ភសំប ិបាទនំ | ឧបម្ភសំបដិបាទនំ | ៣៩ | ១៩ |
| កនិកាយស្ស | ខុទ្ទកនិកាយស្ស | ៤២ | ១ |
| និព្វនគតោ | និព្វានគតោ | ៤៣ | ៣ |
| និព្វនបយ្យត្តោ | និព្វានបយ្យត្តោ | " | " |
| បរិវរតោ | បរិវារិតោ | ៥៩ | ២ |
| អនាគតមទ្ធានំ | អនាគតមទ្ធានំ | ៦០ | " |
| ហោតិ អត្ថិ | ហោតិ ៗ អត្ថិ | ៦២ | ៨ |
| រម | មេ | ៦៨ | ១៧ |

## វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | រដ្ឋុលេខាយំ |
|---|---|---|---|
| មហានទ្ទេសោ | មហានិទ្ទេសោ | ៧០ | ១ |
| សមស្សោ | សម្មស្សោ | ៧៦ | ៦ |
| អ កុហកោ | អកុហកោ | ៧៩ | ២ |
| បដិលី នា | បដិលីនោ | " | ១២ |
| ឧញ្ញា បរិយាយ | ឧញ្ញាបរិយាយ | ៨០ | ១៣ |
| នសមោ | ទសមោ | ៨៥ | ១ |
| " | " | ៨៧ | " |
| យុត្តោ | យុតោ | ៩៦ | ៩ |
| " | " | " | ១២ |
| " | " | ៩៨ | ២ |
| យុត្តោ | យុតោ | " | ១១ |
| បរេសំ | បរេសំ | ១០៤ | ៤ |
| បិដេ | បិដកេ | ១២៦ | ១ |
| បរិគ្គណ្ហេន្តិ | បរិគ្គណ្ហន្តិ | ១៥០ | ៥ |
| ទិស្សតិន្តិ | ទិស្សតិ | ១៦៨ | ១៥ |
| រដ្ឋុពន្ធ | រដ្ឋុពន្ធៈ | ១៦៩ | ៦ |

# វិរុទ្ធាវិរុទ្ធបត្តិ

| វិរុទ្ធពាក្យ | អវិរុទ្ធពាក្យ | ទំព័រ | បន្ទាត់ទី |
|---|---|---|---|
| នទ្ទេសា | និទ្ទេសា | ២០៣ | ១ |
| បេធាវី | មេធាវី | " | ១៤ |
| បជានាតី | បជានាតិ | ២០៥ | ១៨ |
| អហតីតិ | អហរតីតិ | ២២៩ | ៦ |
| អាទីនាំ | អាទីនាំ | ២៥១ | ១០ |
| ធម្ម- | ធម្ម | ២៦៤ | ៦ |
| ទុម្ពសកាធា | ទុម្ពសកាធា | ២៦៧ | " |
| (៣៥៤) | (៣៥៥) | ២៨៨ | " |
| អក្រុត្តិន | អក្រុត្តិនិ | ២៩៩ | ១៥ |
| និវិសរាទី | និវិស្សរាទី | ៣០០ | ៧ |
| អភាវិតាតិ | អភាវិតានិ | ៣០២ | ១៨ |

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយប្រាក់អំណោយនៃ
អ្នកខាងក្រោមនេះ ៖

Printing costs were met through the gift of

Mrs. Fukuko Kasahara
3-4-2 Minami, Azamino, Aoba-ku, Yokohama-shi, Kanagawa-ken 225
Japan

この本は次の方によって復刻されました。

笠原福子
〒225　神奈川県横浜市青葉区あざみ野南3-4-2

ព្រះត្រៃបិដក ភាគទី ១១០ " អភិធម្មបិដក "

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ការបោះពុម្ពជាថ្មីឡើងវិញ របស់សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

បោះពុម្ព ថ្ងៃទី ១០ កក្កដា ឆ្នាំ ១៩៩៤

សហប្រតិបត្តិការរៀបរៀង និងបោះពុម្ពនៅប្រទេសជប៉ុន

TRIPITAKA VOL. 65 (of 110 volumes total)
"SUTTANTA PITAKA"
Published by the Buddhist Institute, Phnom Penh
Reproduced with the kind cooperation of the
TRIPITAKA PUBLISHING COMMITTEE
First edition December 8, 1994
Printed in Japan by Hirosaki Sogo Printing Ltd.

トリピタカ（南伝大蔵経）全110巻・第65巻スッタンタピタカ（経部）

発　行：プノンペン仏教研究所
復刻救援：カンボジア版トリピタカ(南伝大蔵経)復刻救援委員会
発　行：1994年12月８日

印刷・製本／弘前相互印刷株式会社
製作にあたり弘前相互印刷株式会社の多大な協力を得ました。

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE